សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economique
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០២១

សាស្ត្រាចារ្យណែនាំ
បណ្ឌិត សឿន សោភ័ណ

ស្រាវជ្រាវដោយនិស្សិត :
ក. សឿន ចាន់ថេង
ពៅ ដេយវិន

ជំនាញ : រដ្ឋបាលសាធារណៈ
ជំនាន់ទី ១៤

ឆ្នាំសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទ **ពៅ ដេយវីន** និងនាងខ្ញុំ **សឿន ចាន់ថេង** ជានិស្សិតបរិញ្ញាបត្រ រដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០២១ សូមធ្វើការសម្ដែងនូវមនោសញ្ចេតនាប្រកបដោយកត្តញ្ញុតាធម៌ និងគោរពថ្លែងអំណរអគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

## <u>សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ</u>

- លោកឪពុក **វណ្ណ ពៅ** និងអ្នកម្ដាយ **ពៅ សុផាត** ដែលជាឪពុកម្ដាយរបស់និស្សិតឈ្មោះ **ពៅ ដេយវីន** ដែលបានផ្ដល់នូវកំណើត ដំបូន្មាន ភាពកក់ក្ដៅ ការមើលថែ តាំងពីតូចរហូតមក ព្រមទាំងផ្ដល់នូវឱកាសឱ្យយើងខ្ញុំបានសិក្សារៀនសូត្រ ព្រមទាំងឧបត្ថម្ភគាំទ្រទាំងផ្នែកថវិកា និងផ្នែកប្រាជ្ញាស្មារតី ដោយធ្វើការលើកទឹកចិត្ត ជំរុញ និងបណ្ដុះនូវស្មារតី ខិតខំ ប្រឹងប្រែង សង្វាត ឧិហាត ក្នុងការរៀនសូត្រ ក្នុងបេសកកម្មក្រេបជញ្ជក់នូវចំណេះដឹង ពង្រឹងនូវពុទ្ធិ តាំងពីកម្រិតមត្តេយសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។
- អ្នកម្ដាយ **សួន សុផល** ដែលជាម្ដាយរបស់និស្សិតឈ្មោះ **សឿន ចាន់ថេង** ដែលបានផ្ដល់នូវកំណើត ដំបូន្មាន ភាពកក់ក្ដៅ ការមើលថែ តាំងពីតូចរហូតមក ព្រមទាំងផ្ដល់នូវឱកាសឱ្យយើងខ្ញុំបានសិក្សារៀនសូត្រ ព្រមទាំងឧបត្ថម្ភគាំទ្រទាំងផ្នែកថវិកា និងផ្នែកប្រាជ្ញាស្មារតី ដោយធ្វើការលើកទឹកចិត្ត ជំរុញ និងបណ្ដុះនូវស្មារតី ខិតខំ ប្រឹងប្រែង សង្វាត ឱហាត ក្នុងការរៀនសូត្រ ក្នុងបេសកកម្មក្រេបជញ្ជក់នូវចំណេះដឹង ពង្រឹងនូវពុទ្ធិ តាំងពីកម្រិតមត្តេយសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។
- **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតិឱ្យយើងខ្ញុំចូលសិក្សារៀនសូត្រនៅសាកលវិទ្យាល័យនេះ និងផ្ដល់នូវភាពកក់ក្ដៅទំនុកចិត្ត ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការរៀនសូត្រ នៅកម្រិតឧត្តមសិក្សានេះ។
- **លោកសាស្ត្រាចារ្យ បណ្ឌិត សឿន សោភ័ណ ជាសាស្ត្រាចារ្យណែនាំ** ដែលបានឆ្លៀតឱកាសដ៏មមាញឹក ព្រមទាំងចំណាយពេលវេលាដ៏មានតម្លៃផ្ទាល់ខ្លួន ដើម្បីបង្ហាត់បង្ហាញ ណែនាំ ជាពិសេសផ្ដល់នូវការលើកទឹកចិត្ត រួមជាមួយនិងឯកសារមួយចំនួនមកដល់យើងខ្ញុំទាំងពីរ ក្នុងការសម្រួលដល់ដំណើរការរៀបចំសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។
- សាកលវិទ្យាធិការ ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ លោកគ្រូ-អ្នកគ្រូ បុគ្គលិកសិក្សាគ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានធ្វើការខិតខំប្រឹងប្រែងក្នុងការផ្ទេរនូវពុទ្ធិចំណេះដឹង ព្រមទាំងបង្កនូវភាពងាយស្រួល និងភាពកក់ក្ដៅក្នុងដំណើរការសិក្សានេះផងដែរ។

ជាទីបញ្ចប់យើងខ្ញុំ សូមគោរពប្រសិទ្ធពរបវរសួស្តីជូនដល់ លោកឪពុក អ្នកម្តាយ ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សា ទាំងអស់ភប់ប្រសប់តែសេចក្តីសុខ សេចក្តីចម្រើន និងជោគជ័យគ្រប់ភារកិច្ចការងារ។

# អារម្ភកថា

មនុស្សគ្រប់រូបអាចរស់នៅបានដោយសេរី ក្នុងពិភពលោកមួយដែលមានសន្តិភាព និងយុត្តិធម៌ លុះត្រាតែមានការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ កាលពីអតីតកាល មនុស្សមួយចំនួន បានប្រព្រឹត្តអំពើឃោរឃៅ និងគួរឱ្យខ្លាចដល់មនុស្សដទៃទៀត ពីព្រោះយើង មិនបានយកចិត្តទុកដាក់ដល់សិទ្ធិមនុស្ស។ ឥលូវនេះ មនុស្សគ្រប់រូបបានរួបរួមគ្នាដើម្បីឱ្យប្រាកដប្រជាថា ពួកគេមានសេរីភាពក្នុងការនិយាយស្តី និងគិតអ្វីដែលពួកគេចង់ធ្វើ និងមិនរស់នៅក្នុងភាពភ័យខ្លាច ភាពអត់ឃ្លាន ឬការឈឺចាប់ដូចពីសម័យអតីតកាលឡើយ។ ហេតុនេះហើយ ទើបក្រុមយើងខ្ញុំបានលើកយកប្រធានបទ **«សិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា»** មកសិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារនេះឡើង ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីសិទ្ធិ ការអនុវត្តជាក់ស្តែង ជាពិសេសយន្តការនៃការការពារផ្សេងៗ។

នៅក្នុងការចងក្រងនូវឯកសារនេះឡើង យើងខ្ញុំទាំងពីរនាក់បានខិតខំសិក្សា និងស្រាវជ្រាវប្រមូលឯកសារពាក់ព័ន្ធផ្សេងៗជាច្រើនមានដូចជា បទដ្ឋានគតិយុត្តិសិទ្ធិមនុស្សអន្តរជាតិ រដ្ឋធម្មនុញ្ញ សេចក្តីប្រកាស កតិកាសញ្ញា កិច្ចព្រមព្រៀង សៀវភៅច្បាប់ផ្សេងៗ និងពិគ្រោះយោបល់ជាមួយលោកគ្រូសាស្ត្រាចារ្យណែនាំ ក្នុងការស្វែងរកទិន្នន័យដែលជាក់លាក់ និងច្បាស់លាស់ ដើម្បីបង្កើតជាសារណាបញ្ចប់ការសិក្សានេះឡើង។ យើងខ្ញុំសង្ឃឹមថា សារណាបញ្ចប់ការសិក្សាមួយនេះ នឹងក្លាយជាចំណែកតូចមួយសម្រាប់បម្រើក្នុងវិស័យអប់រំ និងជាឯកសារជំនួយស្មារតីដល់សិស្ស និស្សិតជំនាន់ក្រោយ ជាពិសេសបម្រើដល់សិស្ស និស្សិត ដែលចូលចិត្តស្រាវជ្រាវ និងសិក្សាស្វែងយល់។

ដោយហេតុថា កិច្ចការស្រាវជ្រាវមួយនេះអាចនឹងមាននូវ ចំណុចខ្វះខាត មិនទាន់គ្រប់ជ្រុងជ្រោយ ឬមានការលើសលួសត្រង់ចំនុចណាមួយនៅក្នុងការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លោងឃ្លា ការរៀបរៀងដោយប្រការណាមួយដោយអចេតនា។

ជាចុងក្រោយ យើងខ្ញុំទាំងពីររូបសូមធ្វើការអធ្យាស្រ័យ និងខន្តីអភ័យទោសរាល់កំហុសឆ្គងទាំងឡាយដែលមាននៅក្នុងកិច្ចការមួយនេះ ហើយយើងខ្ញុំសូមស្វាគមន៍នូវរាល់មតិរិះគន់ទាំងឡាយពីសំណាក់ សាស្ត្រាចារ្យ លោកគ្រូ-អ្នកគ្រូ និងមិត្តៗនិស្សិតទាំងអស់ផងដែរ ក្នុងការចូលរួមកែតម្រូវនូវចំណុចខ្វះខាត ក៏ដូចជាញ៉ាំងឱ្យមានការស្រាវជ្រាវនេះកាន់តែមានភាពច្បាស់លាស់ទាំងខ្លឹមសារ និងកាន់តែមានអត្ថន័យ។

# មាតិកា

ទំព័រ

**បញ្ជីអក្សរកាត់** ........ vii

**សេចក្តីផ្តើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២

៧. រចនាសម្ពន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១**

**សញ្ញាណទូទៅនៃសិទ្ធិមនុស្ស**

**១.១ កំណើតមនុស្ស និងសិទ្ធិ** ........ ៤

១.១.១ មនុស្ស ........ ៤

១.១.១.១ កំណើតមនុស្ស ........ ៤

**១.២ ទស្សនៈវិជ្ជាស្តីពីសិទ្ធិមនុស្ស** ........ ៤

១.២.១ សិទ្ធិសីលធម៌ ........ ៥

១.២.២ សិទ្ធិនីត្យានុកូល ........ ៥

១.២.៣ សិទ្ធិវិជ្ជមាន និង សិទ្ធិអវិជ្ជមាន ........ ៥

១.២.៣.១ សិទ្ធិវិជ្ជមាន ........ ៥

១.២.៣.២ សិទ្ធិអវិជ្ជមាន ........ ៦

១.២.៤ ការរំលោភសិទ្ធិវិជ្ជមាន និងសិទ្ធិអវិជ្ជមាន ........ ៦

**១.៣ ប្រភពនៃសិទ្ធិ** ........ ៧

១.៣.១ ទំនៀមទំលាប់ (Customary Rights) ........ ៧

១.៣.២ ច្បាប់ (សិទ្ធិនីត្យានុកូល) ........ ៧

១.៣.៣ កិច្ចសន្យា (Contractual Rights) ..... ៧

**១.៤ សិទ្ធិ និងសិទ្ធិមនុស្ស** ..... ៧

១.៤.១ និយមន័យសិទ្ធិ ..... ៧

១.៤.២ សិទ្ធិមនុស្ស ..... ៧

១.៤.៣ សិទ្ធិ និងកាតព្វកិច្ច ..... ៨

១.៤.៣.១ បុគ្គលទទួលបានសិទ្ធិ ..... ៨

១.៤.៣.២ សិទ្ធិ ..... ៨

១.៤.៣.៣ អ្នកជាប់កាតព្វកិច្ច ..... ៨

**១.៥ ចរិកលក្ខណៈសិទ្ធិមនុស្ស និងគោលការណ៍ទូទៅនៃសិទ្ធិមនុស្ស** ..... ៩

១.៥.១ ចរិកលក្ខណៈនៃសិទ្ធិមនុស្ស ..... ៩

១.៥.១.១ សិទ្ធិមនុស្ស គឺជាសិទ្ធិដែលមិនអាចដកហូតបាន ..... ៩

១.៥.១.២ សិទ្ធិមនុស្ស គឺជាសិទ្ធិដែលមិនអាចបំបែកបាន ..... ៩

១.៥.១.៣ សិទ្ធិមនុស្ស គឺជាសិទ្ធិដែលមានលក្ខណៈសាកល ..... ៩

**១.៦ គោលការណ៍ទូទៅនៃសិទ្ធិមនុស្ស** ..... ១០

១.៦.១ សាកលភាព និងភាពមិនអាចដកហូតបាន ..... ១០

១.៦.២ ភាពបំបែកមិនបាន ..... ១០

១.៦.៣ អន្តរនិស្សរភាព និងអន្តរទំនាក់ទំនង ..... ១១

១.៦.៤ សមភាព និងភាពមិនមានការរើសអើង ..... ១១

១.៦.៥ សិទ្ធិចូលរួម និងបញ្ញាប័ន ..... ១១

១.៦.៦ គណនេយ្យភាព និងនីតិរដ្ឋ ..... ១១

**១.៧ ទ្រឹស្តីសិទ្ធិមនុស្ស** ..... ១២

១.៧.១ ទ្រឹស្តីអាទិទេពអំពីសិទ្ធិមនុស្ស ..... ១២

១.៧.២ ទ្រឹស្តីសិទ្ធិពីធម្មជាតិនៃសិទ្ធិមនុស្ស ..... ១២

១.៧.៣ ទ្រឹស្តីទំនើបនៃសិទ្ធិមនុស្ស ..... ១៣

១.៧.៣.១ សិទ្ធិនយោបាយ ..... ១៣

១.៧.៣.២ សិទ្ធិពលរដ្ឋ ឬសិទ្ធិស៊ីវិល ..... ១៣

១.៧.៣.៣ សិទ្ធិសេដ្ឋកិច្ច ..... ១៣

១.៧.៣.៤ សិទ្ធិសង្គម ........................................................................................................................ ១៤
១.៧.៣.៥ សិទ្ធិវប្បធម៌ ...................................................................................................................... ១៤

## ជំពូកទី២

## បទដ្ឋានគតិយុត្តិអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស

**២.១ ធម្មនុញ្ញសហប្រជាជាតិ** ....................................................................................................១៦
**២.២ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស**( UDHR ) .............................................................................១៦
**២.៣ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ...............................................................១៨
២.៣.១ ពិធីសារបន្ថែមលើកតិកាសញ្ញាពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គល ...................១៩
២.៣.២ ពិធីសារបន្ថែមលើកតិកាសញ្ញាព័ន្ធនឹងការលប់ចោលទោសប្រហារជីវិត............................២០
**២.៤ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** ........................................................២១
២.៤.១ ពិធីសារបន្ថែមលើកតិកាសញ្ញាពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គល....................២២
**២.៥ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍** ..........២២
**២.៦ អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ**............២៤
២.៦.១ ពិសារបន្ថែមលើអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ..........២៥
**២.៧ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប** ...........................................................................២៦
២.៧.១ ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ...................................................................................២៧
**២.៨ អនុសញ្ញាស្តីពីសិទ្ធិកុមារ**..........................................................................................................២៨
២.៨.១ ពិសារបន្ថែមលើអនុសញ្ញាពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ .............២៩
២.៨.២ ពិសារបន្ថែមលើអនុសញ្ញាពាក់ព័ន្ធនឹងការលក់កុមារពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ.....២៩
**២.៩ អនុសញ្ញាស្តីពីសិទ្ធិជនពិការ** ......................................................................................................៣០
២.៩.១ ពិសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ ................................................................................៣០
**២.១០ អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន**...........................................................................៣១
២.១០.១ ពិធីសារពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន ........................................................................................៣១
**២.១១ អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍**
.......................................................................................................................................................៣២

# ជំពូកទី៣

# សិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

**៣.១ សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា** ..... ៣៣
៣.១.១ ដើមកំណើតសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ..... ៣៣
៣.១.២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ..... ៣៣
៣.១.២.១ អំពីព្រះមហាក្សត្រ ..... ៣៤
៣.១.២.២ អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋ ..... ៣៤
៣.១.២.៣ អំពីរបបនយោបាយ ..... ៣៦
៣.១.២.៤ អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច ..... ៣៦
៣.១.២.៥ អំពីអំណាចតុលាការ ..... ៣៦
**៣.២ សិទ្ធិមនុស្ស និងការអនុវត្តជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា** ..... ៣៧
៣.២.១ សិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា ..... ៣៧
៣.២.១.១ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ..... ៣៧
៣.២.១.២ ប្រវត្តិការិយាល័យ(OHCHR)ប្រចាំកម្ពុជា ..... ៣៨
៣.២.១.៣ តួនាទី និងភារកិច្ចរបស់ការិយាល័យ(OHCHR)ប្រចាំកម្ពុជា ..... ៣៨
៣.២.២ ស្ថានភាព និងការអនុវត្តជាក់ស្តែងនៃសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា ..... ៣៩
៣.២.២.១ ស្ថានភាពសិទ្ធិមនុស្សក្នុងឆ្នាំ២០១៧ ..... ៣៩
ក. ការបំបិទលំហសង្គមស៊ីវិល ..... ៤០
ខ. ការបង្ក្រាបធ្ងន់ធ្ងរលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ..... ៤០
គ. ការរីករាលដាលនៃការដាក់កំហិតសិទ្ធិខ្លួនឯងតាមប្រព័ន្ធអ៊ីនធឺណិត ..... ៤០
ឃ. ការរារាំងសេរីភាពខាងការជួបប្រជុំ ..... ៤១
ង. ការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ..... ៤១
ច. សិទ្ធិសង្គម និងសេដ្ឋកិច្ច ..... ៤១
ឆ. សិទ្ធិរបស់កម្មករ ..... ៤២
៣.២.២.២ ស្ថានភាពសិទ្ធិមនុស្សក្នុងឆ្នាំ២០១៨ ..... ៤២
ក. សេរីភាពខាងបញ្ចេញមតិ ..... ៤៣
ខ. ការបំបិទបណ្តាញផ្សព្វផ្សាយព័ត៌មានឯករាជ្យ ..... ៤៣

គ. ការកើនឡើងនូវការចាប់ពិរុទ្ធលើបណ្ដាញអ៊ីនធឺណិត ........ ៤៣
ឃ. សេរីភាពខាងការជួបប្រជុំ ........ ៤៤
ង. ការឃាឃីចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ........ ៤៤
ច. សិទ្ធិសង្គមកិច្ច វប្បធម៌ និងសេដ្ឋកិច្ច ........ ៤៤
ឆ. សិទ្ធិកម្មករ ........ ៤៥
៣.២.២.៣ ស្ថានភាពសិទ្ធិមនុស្សក្នុងឆ្នាំ២០១៩ ........ ៤៦
ក. សិទ្ធិសេរីភាពខាងការជួបប្រជុំ ........ ៤៦
ខ. សិទ្ធិសង្គមកិច្ច វប្បធម៌ និងសេដ្ឋកិច្ច ........ ៤៦
គ. សិទ្ធិកម្មករ ........ ៤៧
ឃ. សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ........ ៤៧
៣.២.២.៤ ស្ថានភាពសិទ្ធិមនុស្សក្នុងឆ្នាំ២០២០ ........ ៤៧
ក. សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ........ ៤៨
ខ. សិទ្ធិសេរីភាពខាងការសិក្សាអប់រំ និងពិធីវប្បធម៌ ........ ៤៨
គ. សេរីភាពបង្កើតអង្គការ ឬសមាគម ........ ៤៩
ឃ. សិទ្ធិកម្មករ ........ ៤៩
ង. សិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ........ ៤៨

## ជំពូកទី៤

## យន្តការការពារសិទ្ធិមនុស្សនៅកម្ពុជា

**៤.១ ការរំលោភសិទ្ធិមនុស្ស** ........ ៥០
**៤.២ យន្តការការពារសិទ្ធិមនុស្សថ្នាក់ជាតិ** ........ ៥០
៤.២.១ គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្ដឹង និងអង្កេតព្រឹទ្ធសភា ........ ៥០
៤.២.២ គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្ដឹង និងអង្កេតរដ្ឋសភា ........ ៥១
៤.២.៣ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជានៃរាជរដ្ឋាភិបាល ........ ៥១
៤.២.៤ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ........ ៥២
៤.២.៥ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ........ ៥២
៤.២.៥.១ ក្រសួងយុត្តិធម៌ ........ ៥២
៤.២.៥.២ ក្រសួងយុការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ ........ ៥២

៤.២.៦ តុលាការឧទ្ធរណ៍ និងតុលាការកំពូល ........ ៥២
**៤.៣ យន្តការការពារសិទ្ធិមនុស្សថ្នាក់ក្រោមជាតិ** ........ ៥៣
**៤.៤ យន្តការការពារសិទ្ធិមនុស្សថ្នាក់អន្តរជាតិ** ........ ៥៣
**៤.៥ ស្ថាប័នបង្កើតដោយធម្មនុញ្ញសហប្រជាជាតិ** ........ ៥៣
៤.៥.១ ក្រុមប្រឹក្សាសិទ្ធិមនុស្ស ........ ៥៣
៤.៥.២ យន្តការពិនិត្យរបាយការណ៍រដ្ឋភាគីជាសកលតាមកាលកំណត់ ........ ៥៣
៤.៥.៣ នីតិវិធីពិសេស ........ ៥៤
៤.៥.៤ គណៈកម្មាធិការសិទ្ធិមនុស្ស ........ ៥៤
៤.៥.៤.១ គណៈកម្មាធិការសិទ្ធិមនុស្ស(ICCPR) ........ ៥៤
៤.៥.៤.២ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌(ICESCR) ........ ៥៤
៤.៥.៤.៣ គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍(CERD) ........ ៥៥
៤.៥.៤.៤ គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ(CEDAW) ........ ៥៥
៤.៥.៤.៥ គណៈកម្មាធិការស្តីពីប្រឆាំងទារុណកម្ម(CAT) ........ ៥៥
៤.៥.៤.៦ អនុគណៈកម្មាធិការបង្ការទារុណកម្ម(SPT) ........ ៥៦
៤.៥.៤.៧ គណៈកម្មាធិការស្តីពីសិទ្ធិកុមារ(CRC) ........ ៥៦
៤.៥.៤.៨ គណៈកម្មាធិការស្តីពីសិទ្ធិពលករទេសន្តប្រវេសន៍(CMW) ........ ៥៧
៤.៥.៤.៩ គណៈកម្មាធិការស្តីពីសិទ្ធិជនពិការ(CRPD) ........ ៥៧
៤.៥.៤.១០ គណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ(CED) ........ ៥៨
៤.៥.៥ តួនាទី និងសមាសភាព ........ ៥៨
៤.៥.៥.១ តួនាទី ........ ៥៨
៤.៥.៥.២ សមាសភាព ........ ៥៩
**សេចក្តីសន្និដ្ឋាន** ........ ៦០
**អនុសាសន៍** ........ ៦២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- UDHR = សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- OPCAT = ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប
- OHCHR = ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
- ICCPR = គណៈកម្មាធិការសិទ្ធិមនុស្ស
- CED = គណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ
- CRPD = គណៈកម្មាធិការស្តីពីសិទ្ធិជនពិការ
- CMW = គណៈកម្មាធិការស្តីពីសិទ្ធិពលករទេសន្តប្រវេសន៍
- CRC = គណៈកម្មាធិការស្តីពីសិទ្ធិកុមារ
- SPT = អនុគណៈកម្មាធិការបង្ការទារុណកម្ម
- OPCAT = ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនិងការធ្វើទារុណកម្មអមនុស្សធម៌ ឬការដាក់ទណ្ឌកម្ម
- CAT = គណៈកម្មាធិការស្តីពីប្រឆាំងទារុណកម្ម
- CEDAW = គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ
- CERD = គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍
- ICESCR = គណៈកម្មធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីបោះឆ្នោត ឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជាបានក្លាយជាប្រទេសដែលប្រកាន់យកនូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានព្រះមហាក្សត្រជាព្រះប្រមុខរដ្ឋ ក្រោមការដឹកនាំនៅក្នុងនីតិកាលទីមួយ(១) ប្រទេសកម្ពុជាបានខិតខំបង្កើតនូវច្បាប់អង្គិនជាច្រើន ដើម្បីស្ដារប្រទេសជាតិមកវិញ។ ជុំវិញទាក់ទងទៅនឹងសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការសហប្រជាជាតិ បានរក្សាទុកការិយាល័យមួយដែលបានផ្ដោតសំខាន់លើការការពារ និងការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជានៅឆ្នាំ១៩៩៣។ ការិយាល័យមួយនេះផ្ដោតសំខាន់ទៅលើសិទ្ធិមនុស្សជាចម្បងដែលគេស្គាល់ថាជា "ការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR)"។ ការិយាល័យនេះអនុវត្តអាណត្តិជាសាកលរបស់ឧត្តមស្នងការ ក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្ស។ ការិយាល័យ (OHCHR) ធ្វើការជាមួយរដ្ឋាភិបាល អង្គភាពយុត្តិធម៌ និង អង្គភាពនីតិបញ្ញត្តិ សង្គមស៊ីវិល និងអង្គការជាតិ និងអន្តរជាតិផ្សេងទៀត ដើម្បីគាំទ្រដល់ការបង្រួបបង្រួមសន្តិភាព និងការអភិវឌ្ឍដែលមានការចូលរួមពីសំណាក់កម្ពុជា។ ទីភ្នាក់ងារនេះ គឺជាផ្នែកមួយនៃលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ជាអង្គការអន្តររដ្ឋាភិបាល ដែលមានរដ្ឋជាសមាជិកចំនួនមួយរយកៅសិបពីរ (១៩២)។

នៅក្នុងរបាយការណ៍សិក្សាស្រាវជ្រាវនេះ យើងខ្ញុំគ្រាន់តែចង់បង្ហាញអំពីចំណុចខ្លះដែលពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្សដូចជា តើរដ្ឋភាគីមានកាតព្វកិច្ចអ្វីខ្លះ? និងស្ថាប័នដែលពាក់ព័ន្ធបានចូលរួមចំណែកអ្វីខ្លះ? ក្នុងកិច្ចការសិទ្ធិមនុស្ស ដើម្បីឱ្យបានជ្រាបកាន់តែច្បាស់ យើងខ្ញុំសូមបញ្ជាក់អំពី បុគ្គលណាខ្លះជាអ្នកទទួលបានសិទ្ធិទាំងនោះ។ បុគ្គលគ្រប់រូបមានសិទ្ធិដូចៗគ្នា មិនថាក្មេងស្រី ក្មេងប្រុស បុរស ស្ត្រី ទោះបីចាស់ ឬក្មេង ក្រ ឬមាន ជាអ្នកមាន ឬគ្មានអំណាច ជាមនុស្សសំខាន់ ឬក៏អត់ ទោះបីអ្នកនោះមានគំនិតខុសគ្នា ជំនឿ ឬសាសនាផ្សេងគ្នា ឬនិយាយភាសាផ្សេងគ្នា ឬមកពីប្រទេសផ្សេងក៏ដោយ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

មកទល់ពេលនេះ យើងទាំងអស់គ្នាបានដឹងខ្លះអំពី សិទ្ធិមនុស្ស។ សិទ្ធិមនុស្ស (លក្ខណៈសាកល) គឺជាការធានា ដោយស្របច្បាប់ជាសកល ដើម្បីការពារក្រុម ឬបុគ្គលប្រឆាំងនឹងសកម្មភាព ដែលបំពារបំពានដល់សេរីភាព និងសេចក្ដីថ្លៃថ្នូរជាមូលដ្ឋានរបស់មនុស្ស។ ដូចនេះសំនួរនៅក្នុងប្រធានបទស្រាវជ្រាវនេះ ចង់ចោទសួរអំពីៈ

- តើការអនុវត្តសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

- តើមានលិខិតបទដ្ឋានគតិយុត្តិអន្តរជាតិណាខ្លះដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស?
- តើការអនុវត្តនៃសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានស្ថានភាពយ៉ាងដូចម្ដេច?
- តើមានស្ថាប័នណាខ្លះដែលពាក់ព័ន្ធក្នុងការអនុវត្តសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលបំណងស្វែងរកឱ្យឃើញនូវចំណុចសំខាន់ស្ដីពីកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងដំណើរការប្រព្រឹត្តទៅនៃការអនុវត្តសិទ្ធិមនុស្សនៅកម្ពុជា។ ក្នុងការសិក្សាស្រាវជ្រាវនេះធ្វើឡើង ដើម្បីជាប្រយោជន៍នៅក្នុងការយល់ដឹង និងដើម្បីចែកជាពុទ្ធិទៅដល់បងប្អូនមិត្តនិស្សិតនៅក្នុងការសិក្សារៀនសូត្រស្វែងយល់បន្ថែមពាក់ព័ន្ធនឹងសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃការសិក្សានេះ គឺយើងធ្វើការសិក្សានៅក្នុងរង្វង់នៃកាតព្វកិច្ច និងសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។ ជាងនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំធ្វើការពឹងផ្អែកលើលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ដូចជា **ច្បាប់សិទ្ធិមនុស្សកម្ពុជា អង្គការសហប្រជាជាតិ ២០០៨** ជាដើម។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ចំពោះសារៈសំខាន់នៃការស្រាវជ្រាវនេះ នឹងចូលរួមជាផ្នែកមួយដ៏សំខាន់សម្រាប់ការសិក្សាស្រាវជ្រាវរបស់បងប្អូនមិត្តនិស្សិត ក៏ដូចជាចូលរួមជាវិភាគទាន នៅក្នុងចែកជាពុទ្ធិជូនទៅដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងការយល់ដឹងបន្ថែមទៀតពាក់ព័ន្ធទៅនឹងកាតព្វកិច្ច និងសិទ្ធិរបស់មនុស្ស។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាស្រាវជ្រាវពីប្រធានបទ **"សិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា"** ឱ្យបានចេញជាសមិទ្ធិផលនៃស្នាដៃមួយនេះឡើង។ យើងខ្ញុំបានលើកយកវិធីសាស្ត្រមួយចំនួន ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យចងក្រងជាឯកសារ រួចយកមកសរសេរតាមបែបពិពណ៌នា ដោយផ្អែកលើប្រភពដូចខាងក្រោម៖

- ឯកសារដកស្រង់ខ្លឹមសារសំខាន់ៗ និងចាំបាច់នានា ដែលប្រមូលបានពីលិខិតបទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិដែលមានជាធរមាន មានដូចជា ច្បាប់ អនុសញ្ញា កាតិកាសញ្ញា សេចក្ដីប្រកាស សៀវភៅ របាយការណ៍ ព្រមទាំងឯកសារសិស្សច្បងមួយចំនួន ដែលយើងខ្ញុំបានដាក់នៅក្នុងឧបសម្ព័ន្ធ និងឯកសារយោងខ្លះៗ។

- ឯកសារដែលមានប្រភពចេញពី បណ្ដាញសង្គម គេហទំព័រផ្លូវការរបស់ស្ថាប័នពាក់ព័ន្ធ និង បណ្ណាល័យអេឡិចត្រូនិចនានា ជាពិសេសបណ្ណាល័យរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចផ្ទាល់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សានេះ យើងខ្ញុំបានធ្វើការបែងចែកជាបួន (៤)ជំពូកធំៗ៖

- សេចក្ដីផ្ដើម៖ ផ្នែកនេះចង់បង្ហាញឱ្យឃើញអំពី លំនាំបញ្ហាស្រាវជ្រាវ ចំណោទបញ្ហាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- ជំពូកទី១ សញ្ញាណទូទៅនៃសិទ្ធិមនុស្ស៖ នៅក្នុងជំពូកនេះ យើងខ្ញុំនឹងបង្ហាញឱ្យឃើញអំពីនិយមន័យ គោលការណ៍ទូទៅ ប្រភពនៃសិទ្ធិ ទស្សនៈផ្សេងៗដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។
- ជំពូកទី២ បទដ្ឋានគតិយុត្តអន្តរជាតិនានាស្ដីអំពីសិទ្ធិមនុស្ស៖ នៅក្នុងជំពូកនេះ យើងខ្ញុំចង់បង្ហាញអំពី លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ជាពិសេសកាតព្វកិច្ចរបស់រដ្ឋភាគី និងស្ថាប័នដែលពាក់ព័ន្ធ។
- ជំពូកទី៣ សិទ្ធមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា៖ នៅក្នុងជំពូកនេះ យើងខ្ញុំចង់បង្ហាញអំពី ដំណើរការប្រព្រឹត្តទៅនៃសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា និងស្ថានភាពសិទ្ធមនុស្សជាក់ស្ដែងនៅប្រទេសកម្ពុជា ឆ្នាំ២០១៧ ដល់ ឆ្នាំ២០២០។
- ជំពូកទី៤ យន្តការការការពារសិទ្ធិមនុស្សនៅកម្ពុជា៖ នៅក្នុងជំពូកនេះ យើងខ្ញុំចង់បង្ហាញអំពី អង្គភាពណាដែលបានចូលរួមចំណែកក្នុងការការពារសិទ្ធិមនុស្ស។
- សេចក្ដីសន្និដ្ឋាន និងអនុសាសន៍៖ យើងខ្ញុំនឹងធ្វើការលើកឡើងនូវសេចក្ដីសន្និដ្ឋានជារួម និងលើកយកនៅចំនុចមួយចំនួនមកផ្ដល់ជាអនុសាសន៍ ដែលពួកយើងខ្ញុំបានរកឃើញនៅក្នុងប្រធានបទនេះ។

# ជំពូកទី១
# សញ្ញាណទូទៅនៃសិទ្ធិមនុស្ស

# ជំពូកទី១

# សញ្ញាណទូទៅនៃសិទ្ធិមនុស្ស

## ១.១. កំណើតមនុស្ស និងសិទ្ធិ

### ១.១.១. មនុស្ស

មនុស្ស ជាសភាវម្យ៉ាងដែលមានលក្ខណៈខុសពីសត្វដទៃ។ មនុស្សមានចំណេះដឹងខ្ពស់ជាង និងមានលក្ខណៈជឿនលឿនជាងសត្វដទៃ។

#### ១.១.១.១. កំណើតមនុស្ស

មនុស្សដែលរស់នៅលើផែនដីយើងនេះ មានកំណើតប្រហែលជាងមួយលានឆ្នាំមកហើយមកដល់ពេលនេះ។ ក្រុមអ្នកវិទ្យាសាស្ត្របានធ្វើការសិក្សាស្រាវជ្រាវមួយ ដើម្បីរកមើលប្រភពដើមរបស់មនុស្ស។ នៅក្នុងការស្រាវជ្រាវនេះ គេទទួលបានលទ្ធផលជាច្រើន ដែលបង្ហាញថា ដើមកំណើតរបស់មនុស្ស គឺចាប់ផ្ដើមនៅលើទឹកដីមួយ នៃទ្វីបអាហ្វ្រិកប៉ែកខាងកើត។

លោកសាស្ត្រាចារ្យ Ulf Gyllemsten (APPSLA University) បានរកឃើញ DNA/ADN ដោយបានបញ្ជាក់ថា មនុស្ស គឺមានប្រភពចេញពីអាហ្វ្រិក។ នៅក្នុងការសិក្សាស្រាវជ្រាវនេះ គេបានឱ្យឈ្មោះទ្រឹស្ដីនេះថា ជាទ្រឹស្ដីចេញពីទ្រឹស្ដីអាហ្វ្រិកនៅប៉ែកខាងលិច (The theory is out of Southern)។ ទ្រឹស្ដីនេះបានបង្កើតទស្សនៈនៃមនុស្សជាតិទូទៅមួយ ដែលជាគ្រឹះនៃទស្សនវិជ្ជានៃសិទ្ធិមនុស្ស។ ទស្សនៈនៃមនុស្សជាតិទូទៅ បានកំណត់ថា មនុស្សទាំងអស់មានលក្ខណៈខុសគ្នា មានសភាវៈដូចគ្នា ហើយមានសេចក្ដីត្រូវការដូចគ្នា គឺសំដៅទៅលើចរិកលក្ខណៈដូចគ្នា មានសភាវៈដូចគ្នា ហើយមានសេចក្ដីត្រូវការដូចគ្នា ប៉ុន្តែមានលក្ខណៈខុសគ្នារបស់មនុស្ស គឺនៅត្រង់ពូជសាសន៍ ជាតិសាសន៍ ភេទ តើលក្ខណៈខុសគ្នារបស់មនុស្សនេះបណ្ដាលមកពីអ្វី? ចំពោះភាពខុសគ្នារវាងពូជសាសន៍របស់មនុស្ស គឺបណ្ដាលមកពីការរស់នៅរបស់មនុស្ស ចំពោះជាតិសាសន៍ គឺបណ្ដាលមកពីការវិវឌ្ឍរបស់សង្គមដែលគេរស់នៅ គឺមានលក្ខណៈខុសគ្នា ដោយសារប្រពៃណី ទំនៀមទំលាប់ សាសនា...។ល។ កត្តាភេទ គឺមកពីកត្តារបស់ធម្មជាតិ ដើម្បីបន្តពូជពង្សវង្សត្រកូលរបស់ មនុស្ស។

## ១.២. ទស្សនៈវិជ្ជាស្ដីពីសិទ្ធិមនុស្ស

ទស្សនៈវិជ្ជារបស់សិទ្ធិមនុស្ស ដោយផ្អែកលើទស្សនៈនៃមនុស្សជាតិទូទៅ ដោយមិនផ្អែកទៅលើភាពខុសគ្នាចំពោះពូជសាសន៍ ជាតិសាសន៍ ភេទ ប្រភពកំណើត វណ្ណសង្គម ពណ៌សម្បុរ..។ល។

សិទ្ធិ គឺជាការទាមទារ ឬការប្រគល់ឱ្យនៃអំណាចមួយ ដែលបុគ្គលជឿថាមាន ឬគួរតែមាន។ **សិទ្ធិត្រូវបានបែងចែកជាពីរ (២) គឺ៖ សិទ្ធិសីលធម៌(Moral Rights) និងសិទ្ធិនីត្យានុកូល(Legal Rights)។**

**១.២.១. សិទ្ធិសីលធម៌** ( Moral Rights )

សិទ្ធិសីលធម៌ គឺជាប្រភេទសិទ្ធិដែលមនុស្សគ្រប់រូបមានចំណេះដឹង យល់ឃើញនៅក្នុងបរិបទសង្គមមួយ ដែលគេកំពុងរស់នៅ ឬនៅក្នុងវប្បធម៌របស់ពួកគេដែលមិនមានលក្ខណៈចាប់បង្ខំទេ គឺការប្រតិបត្តិរបស់មនុស្សដែលយល់ថាត្រឹមត្រូវ។ សិទ្ធិសីលធម៌ មានដូចជា ការខិនលំទោនចំពោះចាស់ទុំជាដើម។

**សិទ្ធិសីលធម៌ មានលក្ខណៈដូចតទៅៈ**

១. សិទ្ធិទាំងឡាយណាដែលត្រូវបានប្រជាជនគោរពប្រតិបត្តិ

២. សិទ្ធិទាំងឡាយណាដែលមានលក្ខណៈសមហេតុសមផល

៣. សិទ្ធិទាំងឡាយណាដែលមានលក្ខណៈចាំបាច់

៤. សិទ្ធិទាំងឡាយណាដែលមិនទាន់សរសេរជាលាយលក្ខណ៍អក្សរ ឬរដ្ឋមិនទាន់បានចែងសិទ្ធិនោះនៅក្នុងច្បាប់នៅឡើយ ប៉ុន្តែត្រូវបានប្រជាជនទទួលស្គាល់។

**១.២.២. សិទ្ធិនីត្យានុកូល** ( Legal Rights )

សិទ្ធិនីត្យានុកូល គឺជាសិទ្ធិត្រូវបានបង្កើតឡើងដោយច្បាប់ ហើយមានលក្ខណៈចាប់បង្ខំ។ សិទ្ធិនីត្យានុ-កូល គឺជាសិទ្ធិតំណាងឱ្យផលប្រយោជន៍ណាមួយសម្រាប់មនុស្ស ដែលត្រូវបានការពារដោយសង្គម ឬដោយរដ្ឋ ដែលមានស្ថាប័នសមត្ថកិច្ចជាអ្នកការពារដូចជា ស្ថាប័នតុលាការ នគរបាល និងស្ថាប័នពាក់ព័ន្ធផ្សេងៗ។

សិទ្ធិនីត្យានុកូល មានលក្ខណៈដូចតទៅៈ

១. ត្រូវបានប្រជាជនទទួលស្គាល់

២. រដ្ឋាភិបាលយកទៅចែងជាលាយលក្ខណ៍អក្សរនៅក្នុងច្បាប់

ទោះបីជាសិទ្ធិសីលធម៌ក្តី សិទ្ធិនីត្យានុកូលក្តី សិទ្ធិទាំងពីរនេះ គឺនៅតែជាសិទ្ធិមនុស្សដដែល។

**១.២.៣. សិទ្ធិវិជ្ជមាន និងសិទ្ធិអវិជ្ជមាន** ( Positive Rights and Negative Rights )

**១.២.៣.១. សិទ្ធិវិជ្ជមាន** ( Positive Rights )

សិទ្ធិវិជ្ជមាន គឺជាសិទ្ធិដែលត្រូវបំពេញនូវអ្វីដែលមានពិតប្រាកដ ឬជាក់ស្តែង និងជាសិទ្ធិដែលផ្តល់ឱ្យមនុស្សគ្រប់រូបទាមទារ ឬប្រគល់នូវអំណាចឱ្យមានអ្វីមួយ។

ភាគច្រើនសិទ្ធិទាំងនោះរួមមានៈ

១. សិទ្ធិទទួលបាននូវម្ហូបអាហារ

២. សិទ្ធិទទួលបានការសិក្សា

៣. សិទ្ធិទទួលបាននិរភ័យសង្គម

៤. សិទ្ធិទទួលបានការងារធ្វើ

៥. សិទ្ធិទទួលបានការឧបត្ថម្ភពេលគ្មានការងារធ្វើ

៦. សិទ្ធិក្នុងការបោះឆ្នោត

៧. សិទ្ធិទទួលបាននូវការថែទាំសុខភាព

សិទ្ធិទាំងនេះទាមទារឱ្យមានការធានា និងការអន្តរាគមន៍ពីរដ្ឋឬសង្គម។ ការអន្តរាគមន៍ពីរដ្ឋជាលក្ខណៈសំខាន់នៃសិទ្ធិនេះ។

**១.២.៣.២. សិទ្ធិអវិជ្ជមាន** ( Negative Rights )

សិទ្ធិអវិជ្ជមាន គឺជាសិទ្ធិមនុស្សដែលគេផ្តល់ឱ្យមនុស្ស ឬទុកឱ្យមនុស្ស រស់នៅដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅ។ ម្យ៉ាងវិញទៀត សិទ្ធិអវិជ្ជមាន គឺជាការទាមទារឱ្យមានកន្លែងមួយមានសុវត្ថិភាព ឬសន្តិសុខសម្រាប់បុគ្គលម្នាក់ៗ។

ភាគច្រើនសិទ្ធិទាំងនោះរួមមាន៖

១. សេរីភាពខាងសតិសម្បជញ្ញៈ

២. សេរីភាពខាងសាសនា

៣. សេរីភាពក្នុងការសម្តែងមតិ

៤. សេរីភាពក្នុងការធ្វើដំណើរដោយសេរី

៥. សេរីភាពរួចផុតពីការធ្វើទារុណកម្ម

៦. សេរីភាពក្នុងការបង្កើតសមាគមន៍

៧. សេរីភាពក្នុងការគោរពជីវិតឯកជន

### ១.២.៤. ការរំលោភសិទ្ធិវិជ្ជមាន និងសិទ្ធិអវិជ្ជមាន

១. ចរិកលក្ខណៈនៃការរំលោភសិទ្ធិវិជ្ជមាន គឺស្តែងឡើងតាមរយៈការមិនយកចិត្តទុកដាក់ចំពោះបញ្ហាដែលកើតមានឡើងពីសំណាក់រដ្ឋ ឬសង្គម។

ឧទាហរណ៍៖ ការមិនយកចិត្តទុកដាក់ព្យាបាលអ្នកជម្ងឺនៅមន្ទីរពេទ្យ, ការមិនរវល់ពីការសាងសង់សាលារៀន...។ល។

២. ចរិកលក្ខណៈនៃការរំលោភសិទ្ធិអវិជ្ជមាន គឺស្តែងឡើងតាមរយៈសកម្មភាពជាក់ស្តែង ដែលយើងអាចមើលឃើញ។

ឧទាហរណ៍៖ ការរុះរើផ្ទះអ្នកដទៃ ដែលមានការការពារដោយច្បាប់ត្រឹមត្រូវ, ការចុះឆែកឆេរផ្ទះរបស់អ្នកដទៃដោយគ្មានហេតុផលច្បាស់លាស់ និងស្របច្បាប់...។ល។

## ១.៣. ប្រភពនៃសិទ្ធិ

ប្រភពនៃសិទ្ធិ និងប្រភពនៃសិទ្ធិមនុស្សមិនដូចគ្នាទេ។ ប្រភពនៃសិទ្ធិកើតឡើងពី ទំនៀមទំលាប់ ច្បាប់ និងកិច្ចសន្យា។

### ១.៣.១. ទំនៀមទំលាប់ ( Customary Rights )

សិទ្ធិនេះត្រូវបានគេទទួលស្គាល់ ឬបញ្ញត្តិដោយទំនៀមទំលាប់។ សិទ្ធិប្រភេទនេះ គឺពុំមានលក្ខណៈដូចគ្នាទេ ពីតំបន់មួយទៅតំបន់មួយ និងពីប្រទេសមួយទៅប្រទេសមួយទៀត។ ឧទាហរណ៍៖ ពិធីរៀបមង្គលការ...។

### ១.៣.២. ច្បាប់ ( សិទ្ធិនីត្យានុកូល )

សិទ្ធិនីត្យានុកូល គឺជាសិទ្ធិដែលមានបញ្ញត្តិនៅក្នុងច្បាប់ សិទ្ធិនេះនៅតាមបណ្ដារប្រទេសមួយចំនួនមិនដូចគ្នាទេ ពេលខ្លះវាមិនមានលក្ខណៈត្រឹមត្រូវ។ ឧទាហរណ៍៖ សិទ្ធិរវាងបុរស និងស្ត្រី, ការគ្រប់គ្រងគ្រួសារ, ការបែងចែកទ្រព្យសម្បត្តិ, អំណាចមេបា,អាពាហ៍ពិពាហ៍...។

### ១.៣.៣. កិច្ចសន្យា ( Contractual Rights )

សិទ្ធិនេះកើតចេញពីកិច្ចសន្យា ដែលគេឱ្យឈ្មោះថា សិទ្ធិក្នុងកិច្ចសន្យា។ សិទ្ធិប្រភេទនេះ មាននៅក្នុងរបរជំនួញ ហើយនៅក្នុងកិច្ចសន្យានេះ គូភាគីបានកំណត់អំពីសិទ្ធិ និងកាតព្វកិច្ច ដែលត្រូវបំពេញឱ្យគ្នាទៅវិញទៅមកក្នុងកិច្ចសន្យានោះ។ ឧទាហរណ៍៖ កិច្ចសន្យាលក់ទិញ, កិច្ចសន្យាជួល, កិច្ចសន្យាបញ្ចាំ, កិច្ចសន្យាបញ្ញើ, កិច្ចសន្យាដឹកជញ្ជូន, កិច្ចសន្យាធានារ៉ាប់រង...។ល។

## ១.៤. សិទ្ធិ និងសិទ្ធិមនុស្ស

### ១.៤.១. និយមន័យសិទ្ធិ

សិទ្ធិ គឺជាការទាមទារ ឬជាការប្រគល់ឱ្យនូវអំណាចដែលបុគ្គល ឬក៏មនុស្សម្នាក់ៗជឿថា ឬត្រូវតែមាន។ រីឯពាក្យមនុស្សវិញ នៅពេលណាដែលយើងយកពាក្យសិទ្ធិទៅបន្ថែមលើពាក្យមនុស្ស យើងឱ្យន័យពាក្យសិទ្ធិនេះ មានអត្ថន័យពិសេសមួយ ដែលគេហៅថា "សិទ្ធិមនុស្ស"។

### ១.៤.២. សិទ្ធិមនុស្ស

សិទ្ធិមនុស្ស គឺជាការទាក់ទងទៅនឹងអ្វីដែលមានសារប្រយោជន៍ដល់មនុស្សជាតិ។

ឧទាហរណ៍៖ សិទ្ធិរស់រានមានជីវិត, សេរីភាពរួចផុតពីការធ្វើទារុណ្ណកម្ម, សិទ្ធិរស់នៅក្នុងក្រុមគ្រួសារ, សិទ្ធិរស់នៅក្នុងសហគមន៍.....។ល។

សិទ្ធិមនុស្ស (លក្ខណៈសាកល) គឺជាការធានាដោយស្របច្បាប់ជាសកល ដើម្បីការពារក្រុម ឬបុគ្គលប្រឆាំងនឹងសកម្មភាព ដែលបំពារបំពានដល់សេរីភាព និងសេចក្ដីថ្លៃថ្នូរជាមូលដ្ឋានរបស់មនុស្ស។

**១.៤.៣. សិទ្ធិ និងកាតព្វកិច្ច**

កាតព្វកិច្ច មានសារសំខាន់ក្នុងការធ្វើឱ្យសិទ្ធិណាមួយកើតចេញជារូបរាងពិតប្រាកដ យើងអាចនិយាយបានថា ពុំមានសិទ្ធិណាមួយដែលបានកើតឡើងដោយគ្មានការទាក់ទងជាមួយកាតព្វកិច្ចនោះទេ។ ទំនាក់ទំនងរវាងសិទ្ធិ និងកាតព្វកិច្ច មានធាតុសំខាន់បី (៣)៖

- បុគ្គលទទួលបានសិទ្ធិ
- សិទ្ធិ
- អ្នកជាប់កាតព្វកិច្ច

**១.៤.៣.១. បុគ្គលទទួលបានសិទ្ធិ**

បុគ្គលទទួលបានសិទ្ធិ គឺជាបុគ្គលដែលទាមទារយកសិទ្ធិទាំងនោះ ពីអ្នកជាប់កាតព្វកិច្ច។ បុគ្គលទទួលបានសិទ្ធិ ជួនកាលទទួលរងនូវការរំលោភបំពាន ជាហេតុនាំឱ្យបុគ្គលទាំងនោះ នាំគ្នាបង្កើតជាក្រុមមួយឡើង។ ឧទាហរណ៍៖ នារី, កុមារ, ជនជាតិដើមភាគតិច, កម្មករ, ចាស់ជរា, ជនពិការ...។ល។

**១.៤.៣.២. សិទ្ធិ**

មនុស្សទាមទារយកសិទ្ធិពិតប្រាកដរបស់ខ្លួន នេះគឺជាសិទ្ធិ ហើយសិទ្ធិទាំងនេះ ត្រូវបានរៀបចំទៅតាមបែបបទ ឬរបៀបដូចៗគ្នា អាចជាសិទ្ធិសីលធម៌ សិទ្ធិនីត្យានុកូល មានសិទ្ធិខ្លះទៀតវាបានកើតចេញមកដែលគេអះអាងថា ជាសិទ្ធិពីធម្មជាតិ ឬជាសិទ្ធិកើតពីកំណើត។

សិទ្ធិខ្លះទៀត មនុស្សជាអ្នកបង្កើតឡើងផងដែរ ហើយសិទ្ធិទាំងនោះទាក់ទងនឹងសិទ្ធិបុគ្គលដទៃ និងក្រុមមនុស្សមួយក្រុម។ ឧទាហរណ៍៖ សិទ្ធិវប្បធម៌, សិទ្ធិសេដ្ឋកិច្ច, សិទ្ធិធ្វើនយោបាយ, សិទ្ធិពលរដ្ឋ....។ល។

នៅមានសិទ្ធិខ្លះទៀត ដែលមនុស្សបង្កើតឡើងផងដែរ ហើយសិទ្ធិទាំងនោះទាក់ទងនឹងបុគ្គលដទៃ និងក្រុមមនុស្សមួយក្រុម។ ឧទាហរណ៍៖ សិទ្ធិនារី, សិទ្ធិកុមារ, សិទ្ធិជនជាតិដើមភាគតិច, សិទ្ធិជនពិការ, សិទ្ធិជនមានកើតជម្ងឺអេដស៍, សិទ្ធិកម្មករ...។ល។

**១.៤.៣.៣. អ្នកជាប់កាតព្វកិច្ច**

បុគ្គលទាមទារសិទ្ធិទាំងនេះពីអ្នកជាប់កាតព្វកិច្ច ហើយអ្នកជាប់កាតព្វកិច្ចអាចជាបុគ្គល ជាស្ថាប័នរបស់រដ្ឋ ហើយជាពិសេសគឺរដ្ឋ ជួនកាលអ្នកផ្តល់សិទ្ធិឱ្យគេ ខ្លួនឯងបែរជាអ្នករំលោភសិទ្ធិនោះទៅវិញ។ ឧទាហរណ៍៖ ចៅក្រម, ឪពុកម្តាយ, នគរបាល, គ្រូពេទ្យ...។ល។ សុទ្ធតែជាអ្នកជាប់កាតព្វកិច្ច។ រដ្ឋ ជាអ្នកជាប់កាតព្វកិច្ចច្រើនជាងគេ ព្រោះដើម្បីធ្វើឱ្យសិទ្ធិប្រជាពលរដ្ឋចេញជារូបរាងឡើង។ នៅពេលគេទទួលស្គាល់សិទ្ធិទាំងនេះហើយ ជាទូទៅសិទ្ធិទាំងនេះ ត្រូវបានគេដាក់បញ្ចូលក្នុងច្បាប់ ឬរដ្ឋធម្មនុញ្ញក្នុងប្រទេសនោះ។ រីឯតួនាទីការពារសិទ្ធិទាំងនោះ ត្រូវបានគេផ្តល់ឱ្យទៅស្ថាប័នតុលាការ ជាអ្នកការពារ។ ស្ថាប័នតុលាការជាឆ្នាំ

ការពារសិទ្ធិសេរីភាពទាំងនោះ (សេរីភាពទាំងនោះ ការពារដោយតុលាការរដ្ឋបាល សេរីភាពឯកជន ត្រូវបានការពារដោយតុលាការរដ្ឋប្បវេណី)។

## ១.៥. ចរិកលក្ខណៈនៃសិទ្ធិមនុស្ស និងគោលការណ៍ទូទៅនៃសិទ្ធិមនុស្ស

### ១.៥.១. ចរិកលក្ខណៈនៃសិទ្ធិមនុស្ស

ទស្សនវិទូបន្តជជែកវែកញែកអំពីធម្មជាតិនៃសិទ្ធិមនុស្ស ប៉ុន្តែសហគមន៍អន្តរជាតិបានចាប់ផ្តើមធ្វើការប្តេជ្ញាចិត្តគួរឱ្យភ្ញាក់ផ្អើលចំពោះសិទ្ធិមនុស្ស តាមរយៈការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សក្នុងឆ្នាំ ១៩៤៨។ ចាប់តាំងពីពេលនោះមក សហគមន៍អន្តរជាតិបានបង្កើតនូវគំនិតដ៏មានឥទ្ធិពលរបស់សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស (UDHR)។ UDHR មិនត្រូវបានគេបម្រុងទុក ដើម្បីឱ្យមានកាតព្វកិច្ចស្របច្បាប់នោះទេ ប៉ុន្តែការបង្កើតបទដ្ឋានរបស់ខ្លួននៅក្នុងសន្ធិសញ្ញាភ្ជាប់ជាបន្តបន្ទាប់ជាច្រើនដូចជាអនុសញ្ញា ឬកតិកាសញ្ញា ធ្វើឱ្យដំហរស្របច្បាប់នៃបទដ្ឋានរបស់ខ្លួនមានឥទ្ធិពលមកដល់ពេលបច្ចុប្បន្ន។ យោងតាមគោលការណ៍ទាំងនេះ ចរិកលក្ខណៈនៃសិទ្ធិមនុស្សលេចធ្លោសំខាន់ៗមានដូចខាងក្រោម៖

#### ១.៥.១.១. សិទ្ធិមនុស្ស គឺជាសិទ្ធិដែលមិនអាចដកហូតបាន

មនុស្សគ្រប់រូបមិនអាចបាត់បង់សិទ្ធិទាំងអស់នោះបានឡើយ ដោយសារសិទ្ធិទាំងនោះត្រូវបានភ្ជាប់នឹងការពិតនៃអត្តិភាពមនុស្ស ដែលមានជាប់នឹងគ្រប់មនុស្សជាតិទាំងអស់តាំងពីកំណើតមកម្ល៉េះ ហើយសិទ្ធិទាំងនេះគ្មាននណាម្នាក់អាចដកហូតបានឡើយ។

#### ១.៥.១.២. សិទ្ធិមនុស្ស គឺជាសិទ្ធិដែលមិនអាចបំបែកបាន

សិទ្ធិរបស់មនុស្សម្នាក់ៗគ្រប់ជាន់ថ្នាក់ទាំងមូល មិនត្រូវបានគេបំបែកហើយផ្ទេរឱ្យទៅនរណាម្នាក់ផ្សេងឡើយ។ ជាពិសេសទៅទៀត វាមានលក្ខណៈពឹងផ្អែកគ្នាទៅវិញទៅមក (អន្តរនិស្សរភាព) និងអន្តរទំនាក់ទំនងគ្នាជានិច្ច (បំពេញឱ្យគ្នាទៅវិញទៅមក) ដោយមិនត្រូវអនុវត្តដាច់ដោយឡែកតែឯងបានឡើយ។

#### ១.៥.១.៣. សិទ្ធិមនុស្ស គឺជាសិទ្ធិដែលមានលក្ខណៈសាកល

មនុស្សគ្រប់រូបអនុវត្តសិទ្ធិរបស់ពួកគេស្មើៗគ្នា ស្របតាមច្បាប់នៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយមិនមានពេលវេលាកំណត់នោះឡើយ។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសិទ្ធិរបស់ខ្លួនដោយមិនមានការបែកចែកពីដើមកំណើត ឬពូជសាសន៍ ជនជាតិដើម ពណ៌សម្បុរ ភេទ និន្នាការនយោបាយ ពិការភាព ភាសា ជំនឿសាសនា ឬគំនិតយោបល់ ដើមកំណើតជាតិ ឬសង្គម ឋានៈផ្សេងទៀត។ល។

យើងគួរកត់សម្គាល់ថាសាកលភាវូបនីយកម្ម នៃសិទ្ធិមនុស្សមិនមានលក្ខណៈណាមួយដែលគំរាមកំហែងដល់ភាពសម្បូរបែបនៃបុគ្គល ឬវប្បធម៌ខុសគ្នានោះទេ។ ដោយគ្មានការរើសអើង សិទ្ធិមនុស្ស គឺមានលក្ខណៈសាកល មិនអាចដកហូតបាន និងមិនអាចបំបែកបាន និងជាពិសេសគឺ មានលក្ខណៈអន្តរនិស្សរភាព និង

អន្តរទំនាក់ទំនង។ សិទ្ធិមនុស្សមានលក្ខណៈសាកល ដោយសារមនុស្សគ្រប់រូបចាប់តាំងពីកើតមកគឺ ជាប់ជាមួយនឹងកម្មសិទ្ធិនៃសិទ្ធិទាំងអស់របស់មនុស្ស ដោយមិនគិតពីទីតាំងនៃការរស់នៅ។

ភេទ ពូជសាសន៍ សាសនា វប្បធម៌ ប្រវត្តិសាស្ត្រ មិនអាចដកហូតបានដោយសារសិទ្ធិរបស់ប្រជាពលរដ្ឋមិនអាចយកចេញពីខ្លួនប្រាណគេបានឡើយ។ គ្មានបុគ្គលណាម្នាក់អាចបំបែក និងអន្តរនិស្សរ ដោយសារសិទ្ធិទាំងអស់នោះរួមមាន សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម សិទ្ធិវប្បធម៌ គឺមានសារៈសំខាន់ស្មើគ្នា ហើយគ្មានសិទ្ធិណាមួយទទួលបានជោគជ័យពេញលេញ ដោយគ្មានសិទ្ធិដទៃទៀតចូលរួមនោះឡើយ។

សិទ្ធិទាំងនេះត្រូវអនុវត្តស្មើគ្នាទាំងអស់ ហើយការអនុវត្តសិទ្ធិទាំងនេះត្រូវផ្តល់ឱ្យមានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តដែលជះឥទ្ធិពលជីវភាពរស់នៅរបស់ពួកគេ។ សិទ្ធិទាំងនេះ ត្រូវបានការពារ និងពង្រឹងឱ្យកាន់តែប្រសើរឡើងដោយវិធានច្បាប់ តាមរយៈការទាមទារឱ្យស្ថាប័នមានសមត្ថកិច្ចទទួលខុសត្រូវការអនុវត្តស្របច្បាប់តាមច្បាប់អន្តរជាតិ។

## ១.៦. គោលការណ៍ទូទៅនៃសិទ្ធិមនុស្ស

សិទ្ធិមនុស្សពិតជាមានសារៈសំខាន់ណាស់ដល់មនុស្សជាតិទូទាំងពិភពលោក។ ដូច្នេះហើយ ទើបគេកំណត់គោលការណ៍ទូទៅជារួមមួយចំនួនដូចខាងក្រោម៖

### ១.៦.១. សាកលភាព និង ភាពមិនអាចដកហូតបាន

មនុស្សយើង កើតមកបានយកនូវសិទ្ធិមកពីកំណើតម្ល៉េះ ដូចនេះហើយទើបគេមិនអាចដកហូតបាន។ សិទ្ធិមនុស្ស គឺមានលក្ខណៈសាកលភាព និងមិនអាចដកហូតបាន ដូច្នេះគ្រប់មនុស្សទាំងអស់ គ្រប់ទីកន្លែងទាំងអស់នៅលើពិភពលោកនេះ គឺទទួលបានសិទ្ធិរបស់ខ្លួនទាំងអស់នេះ។ សាកលភាពនៃសិទ្ធិមនុស្ស គឺត្រូវទទួលបានទាំងអស់គ្នានៅជុំវិញពិភពលោកយើងនេះ។ យោងតាមមាត្រា១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបានចែងថា "គ្រប់មនុស្សជាតិទាំងអស់មានសេរីភាព និងភាពស្មើគ្នាក្នុងកិត្តិយស សេចក្តីថ្លៃថ្នូរ និងសិទ្ធិទាំងអស់តាំងពីកំណើត"។

### ១.៦.២. ភាពបំបែកមិនបាន

សិទ្ធិមនុស្ស គឺជាសិទ្ធិមិនអាចបំបែកពីគ្នាបាន។ សិទ្ធិមនុស្ស រួមមានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ និងសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម សិទ្ធិវប្បធម៌......។ល។ សិទ្ធិមនុស្សទាំងអស់នេះ គឺវាភ្ជាប់នឹងកិត្តិយស សេចក្តីថ្លៃថ្នូររបស់មនុស្សម្នាក់ៗដែលមានជាប់តាំងពីកំណើត។ ជាការពិតណាស់ សិទ្ធិមនុស្សទាំងនេះ ស្ថិតក្នុងស្ថានភាពស្មើគ្នាទាំងអស់ ហើយក៏គ្មានសិទ្ធិណាមួយស្ថិតនៅក្នុងលំដាប់ខ្ពស់ទាបនោះដែរ។ ការកម្ទេចសិទ្ធិណាមួយ ស្មើនឹងរារាំងទាំងស្រុងដល់ការចូលរួមនៃសិទ្ធិដទៃទៀត។ ដូច្នេះ សិទ្ធិមនុស្សគ្រប់រូបត្រូវបានភ្ជាប់

ទៅនឹងស្តង់ដានៃជីវភាពរស់នៅមួយគ្រប់គ្រាន់ មិនអាចខ្វះបាននូវសិទ្ធិណាមួយឡើយដូចជា សិទ្ធិទទួលបានសុខភាព ឬសិទ្ធិទទួលបានការអប់រំ។

### ១.៦.៣ អន្តរនិស្សរភាព និង អន្តរទំនាក់ទំនង

សិទ្ធិមនុស្ស គឺជាសិទ្ធិនីមួយៗដែលត្រូវតែភ្ជាប់នឹងការទទួលបានកិត្តិយស សេចក្តីថ្លៃថ្នូររបស់មនុស្សម្នាក់ៗ តាមរយៈសេចក្តីសោមនស្សនៃសេចក្តីត្រូវការចាំបាច់ការអភិវឌ្ឍផ្នែករាង្គកាយ ចិត្តសាស្ត្រ និងស្មារតី។

ការបំពេញបន្ថែមនៃសិទ្ធិមួយ គឺត្រូវការពឹងផ្អែកលើទាំងស្រុង ឬមួយផ្នែក អាស្រ័យលើការបំពេញបន្ថែមផ្នែកដទៃទៀត។ ឧទាហរណ៍៖ ការបំពេញបន្ថែមសិទ្ធិទទួលបានសុខភាព អាចត្រូវការពឹងផ្អែកលើស្ថានភាពជាក់ស្តែងផ្សេងទៀតដែលជួយបំពេញបន្ថែមទៅលើសិទ្ធិទទួលបានការអភិវឌ្ឍន៍ សិទ្ធិទទួលបានការអប់រំ ឬសិទ្ធិទទួលបានព័ត៌មាន។

### ១.៦.៤. សមភាព និងមិនមានការរើសអើង

ក្នុងនាមជាមនុស្សជាតិ ហើយព្រមទាំងមានគុណធម៌នៃសេចក្តីថ្លៃថ្នូរមានជាប់ពីកំណើតរបស់មនុស្សម្នាក់ៗគ្រប់រូប។ ហេតុដូចនេះហើយទើប បុគ្គលគ្រប់រូបមានភាពស្មើគ្នាទាំងអស់ គ្មាននណាម្នាក់ ត្រូវរងនូវការរើសអើងដោយសារតែពូជសាសន៍ ពណ៌សម្បុរ ជាតិសាសន៍ យេនឌ័រ អាយុ ភាសា ភេទ សាសនា និន្នាការនយោបាយ ឬទស្សនៈ ជាតិ សង្គម ឬទីតាំងដើមកំណើត ពិការភាព ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀត ដែលបានកំណត់ដោយលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ។

### ១.៦.៥. សិទ្ធិចូលរួម និងបញ្ជ្រាបចូល

គ្រប់ពលរដ្ឋទាំងអស់ មានសិទ្ធិចូលរួមក្នុងការផ្តល់ព័ត៌មាន និងទទួលព័ត៌មានដែលទាក់ទងនឹងដំណើរការសម្រេចចិត្តដែលជះឥទ្ធិពលដល់ជីវភាពរស់នៅ និងសុខមាលភាពសង្គម។ គោលការណ៍ទាំងអស់ត្រូវផ្អែកលើសិទ្ធិ តម្រូវជាចាំបាច់ឱ្យមានកម្រិតខ្ពស់នៃការចូលរួមពីគ្រប់សហគមន៍ សង្គមស៊ីវិល ក្រុមជនជាតិភាគតិច ស្ត្រី យុវជន ជនជាតិដើមភាគតិច និងក្រុមជនជាតិដើមភាគតិចផ្សេងទៀត។

### ១.៦.៦. គណនេយ្យភាព និងនីតិរដ្ឋ

រដ្ឋ និងស្ថាប័នសមត្ថកិច្ចដទៃទៀត ត្រូវចាត់វិធានការតាមដានអង្កេតពីសិទ្ធិមនុស្ស។ នៅក្នុងការអនុវត្តស្ថាប័នទាំងនេះត្រូវគោរពប្រតិបត្តិតាមវិធានច្បាប់ និងបទដ្ឋានដែលមានចែងនៅក្នុងឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ។ ស្ថាប័នមានសមត្ថកិច្ច ដែលខកខានក្នុងការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្ស ត្រូវចាត់ការតាមនីតិវិធីសមស្រប ដើម្បីប្រឈមមុខនឹងតុលាការ សមត្ថកិច្ច ឬយកមកវិនិច្ឆ័យទោសឱ្យស្របតាមវិធាន និងនីតិវិធីដែលកំណត់ដោយច្បាប់។

គ្រប់បុគ្គលឯកជន ប្រព័ន្ធផ្សព្វផ្សាយ សង្គមស៊ីវិល និងសហគមន៍អន្តរជាតិ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងចាត់ចែង ទទួលខុសត្រូវសម្រាប់កាតព្វកិច្ចរបស់ខ្លួនដើម្បីការពារសិទ្ធិមនុស្ស។

**១.៧. ទ្រឹស្តីសិទ្ធិមនុស្ស**

គេបានប្រទះឃើញទស្សនៈស្តីពីសិទ្ធិមនុស្សមួយចំនួន ចេញពីទ្រឹស្តីនៃរដ្ឋទំនើបដំបូងគេជាច្រើនដែលនៅក្នុងនោះមានដូចជាៈ

**១.៧.១. ទ្រឹស្តីអាទិទេពស្តីអំពីសិទ្ធិមនុស្ស**

ជាទ្រឹស្តីដែលជឿទៅលើអាទិទេព គឺអាទិទេពជាអ្នកបង្កើតមនុស្សមក ដោយបានភ្ជាប់មកនូវសិទ្ធិមួយចំនួនមកជាមួយពីធម្មជាតិផងដែរ។ សិទ្ធិដែលមានមកជាមួយនោះរួមមាន សិទ្ធិមានជីវិត សិទ្ធិមានសេរីភាព និងសិទ្ធិស្វែងរកសុភមង្គល ដែលជាសិទ្ធិចម្បងនៅក្នុងសង្គម។ ទ្រឹស្តីនេះ ជាទ្រឹស្តីដែលពឹងផ្អែកលើកម្លាំងក្រៅខ្លួនយ៉ាងខ្លាំង ដែលតម្រូវឱ្យមនុស្សជឿលើតែអាទិទេព។ អ្នកសិក្សាភាគច្រើនគេមិនជឿលើទស្សនៈបែបអាទិទេពនិយមនោះទេ។

**១.៧.២. ទ្រឹស្តីសិទ្ធិពីធម្មជាតិស្តីអំពីសិទ្ធិមនុស្ស**

ជាទ្រឹស្តីមួយដែលពេញនិយមនៅបច្ចិមប្រទេស ក្នុងអំឡុងពេលនោះមានការបំផុសឱ្យមានសិទ្ធិមនុស្សឡើង។ ទស្សនៈវិទូ John Locke ជាអ្នកទីមួយនៃទស្សនៈវិទូស្តីពីសិទ្ធិមនុស្ស។ ពេលនោះគាត់ជាអ្នកគាំទ្រដ៏សំខាន់មួយរូបក្នុងចំណោមអ្នកគាំទ្រដទៃទៀតចំពោះទ្រឹស្តីពីធម្មជាតិនៃសិទ្ធិមនុស្ស។ គាត់បានពន្យល់ទ្រឹស្តីនេះដោយផ្អែកលើទ្រឹស្តីមួយដែល John Locke បានសរសេរ គឺទ្រឹស្តីកិច្ចសន្យាសង្គម "The Theory of Social Contract" អ្វីដែលសំខាន់នោះ គឺដោយមានហេតុផលថា តាមធម្មជាតិរបស់មនុស្ស គឺកើតមកមានភ្ជាប់នូវសិទ្ធិមកជាមួយតាំងពីកំណើត គឺសិទ្ធិរស់រានមានជីវិត សិទ្ធិមានសេរីភាព និងសិទ្ធិមានទ្រព្យសម្បត្តិ។ ម្យ៉ាងទៀត នៅក្នុងទ្រឹស្តីរបស់ John Locke បានលើកឡើងពីហេតុផលថា នៅក្នុងសភាពធម្មជាតិមនុស្សមានសេរីភាពបំផុត។ នៅក្នុងសង្គមបែបធម្មជាតិ មនុស្សមានការភ័យខ្លាចណាស់ ព្រោះអ្នកណាខ្លាំងមានប្រៀបជាងអ្នកដទៃ គឺអ្នកនោះឈ្នះ ធ្វើបែបនេះជាការអនុវត្តច្បាប់ព្រៃ។ ដូចនេះ មនុស្សមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីការពារទ្រព្យសម្បត្តិ សន្តិសុខ សុវត្ថិភាពពីធម្មជាតិ និងយុត្តិធម៌សម្រាប់ខ្លួនបានឡើយ។ ដូច្នេះហើយ បានជាមនុស្សត្រូវវិលត្រឡប់មករស់នៅក្នុងសង្គមតាមរយៈកិច្ចសន្យាសង្គម។ តាមរយៈកិច្ចសន្យាសង្គមនេះ មនុស្សត្រូវលះបង់នូវសេរីភាព ពីធម្មជាតិខ្លះ ហើយងាកមករស់នៅក្នុងសង្គមមួយដែលមានច្បាប់ការពារត្រឹមត្រូវ នោះគឺកិច្ចសន្យាសង្គម។

### ១.៧.៣. ទ្រឹស្តីទំនើបនៃសិទ្ធិមនុស្ស

ទ្រឹស្តីទំនើបនេះ មានលក្ខណៈល្អប្រសើរជាងទ្រឹស្តីខាងលើ ដោយបានពន្យល់ពេញ លក្ខណៈពីតម្រូវការរបស់មនុស្សនាពេលបច្ចុប្បន្ននេះ។ គេសង្កេតឃើញនៅក្នុងទ្រឹស្តីនេះ គេបានកំណត់ចង្កោមនៃសិទ្ធិសំខាន់ៗរបស់មនុស្សយើងមានប្រាំ (៥) ធំៗ៖

#### ១.៧.៣.១. សិទ្ធិនយោបាយ

សិទ្ធិនយោបាយ ជាសិទ្ធិមួយសំខាន់ក្នុងចំណោមសិទ្ធិសំខាន់ៗទាំងប្រាំ(៥) ព្រោះសិទ្ធិនេះបានធានា និងធ្វើឱ្យរីកចម្រើនដល់សិទ្ធិទាំងបួន(៤) ផ្សេងទៀត។ សិទ្ធិនេះ ជាសិទ្ធិបុគ្គលក្នុងការស្វែងយល់ និងចូលរួមនៅក្នុងកិច្ចការរបស់រដ្ឋាភិបាលទាក់ទងដោយផ្ទាល់ ដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមប្រកបដោយលក្ខណៈប្រជាធិបតេយ្យ ដែលធានាបានដល់សេរីភាព សមធម៌ យុត្តិធម៌ និងការចូលរួមចំណែកពីគ្រប់ស្រទាប់មនុស្សក្នុងសង្គម។

សិទ្ធិនយោបាយនេះមានលក្ខណៈពីរ(២)យ៉ាង៖

- ទីមួយ (១)៖ ទាក់ទងទៅនឹងបុគ្គល ដូចជាសិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត សេរីភាពក្នុងការបញ្ចេញមតិ។
- ទីពីរ (២)៖ ទាក់ទងទៅនឹងសមូហភាព ដូចជាសិទ្ធិបង្កើតគណបក្សនយោបាយ សេរីភាពក្នុងការប្រមូលផ្តុំការចូលរួមនៅក្នុងការគ្រប់គ្រងរដ្ឋ និងសង្គម សេរីភាពសារព័ត៌មាន។

#### ១.៧.៣.២. សិទ្ធិពលរដ្ឋ ឬសិទ្ធិស៊ីវិល

ជាសិទ្ធិរបស់បុគ្គល ដែលត្រូវបានការពារកុំឱ្យមានការបំពារបំពានពីរដ្ឋាភិបាលលើអាយុជីវិត ការរស់រានមានជីវិត សេរីភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ សិទ្ធិនេះមានជាអាទិ៍ សេរីភាពក្នុងការនិយាយស្តី សេរីភាពក្នុងការគិតគូរសព្វបែបយ៉ាង សិទ្ធិស្វែងរកយុត្តិធម៌ សិទ្ធិធ្វើជាម្ចាស់លើទ្រព្យសម្បត្តិផ្ទាល់ខ្លួន សិទ្ធិចុះកិច្ចសន្យាឱ្យមានសុពលភាព សិទ្ធិក្នុងការធ្វើដំណើរឆ្លាយផិត និងសិទ្ធិនានាស្របតាមនីតិត្រឹមត្រូវដែលបានបញ្ញត្តិ។ល។

#### ១.៧.៣.៣. សិទ្ធិសេដ្ឋកិច្ច

សំដៅដល់សិទ្ធិទាំងឡាយណា ដែលពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ច ជីវភាពរស់នៅរបស់មនុស្សនៅក្នុងសង្គម។ សិទ្ធិនេះរួមមាន សិទ្ធិធ្វើការងារ, សិទ្ធិប្រកបរបរស្របច្បាប់, សិទ្ធិទទួលបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា, សិទ្ធិស្វែងរកការងារដែលសមស្របនឹងសមត្ថភាពរបស់ខ្លួន....។ល។

**១.៧.៣.៤. សិទ្ធិសង្គម**

ជាសិទ្ធិ ក្នុងការទាមទារឱ្យមានការលើកកម្ពស់ស្តង់ដានៃជីវភាពរស់នៅ។ សិទ្ធិទាំងឡាយណា ដែលពាក់ព័ន្ធនឹងដំណើរការនៃការរស់នៅរបស់ប្រជាជននៅក្នុងសង្គម និងសុខមាលភាពសង្គម និងមានលក្ខណៈជាសមូហភាព។ សិទ្ធិនេះរួមមាន សិទ្ធិទទួលបានសេវាសុខភាព និងការព្យាបាលជម្ងឺ សិទ្ធិទទួលបាននូវបរិ-ស្ថានស្អាត បរិស្ថានការងារល្អ សិទ្ធិទទួលបានការអប់រំ សិទ្ធិបង្កើតសហជីពការពារកម្មករនិយោជិត សិទ្ធិរស់នៅក្នុងបរិស្ថានល្អ សិទ្ធិទទួលបាននិរភ័យសង្គម និងសិទ្ធិទទួលការបែងចែកត្រឹមត្រូវពីសង្គម....។ល។

**១.៧.៣.៥. សិទ្ធិវប្បធម៌**

សិទ្ធិ ពាក់ព័ន្ធនឹងតម្រូវការរបស់មនុស្សរបស់មនុស្សខាងផ្នែក បញ្ញា ស្មារតី សោភ័ណភាព ជំនឿ និងវប្បធម៌ប្រពៃណីរបស់មនុស្ស ដូចជាសិទ្ធិសេរីភាពក្នុងការទំនាក់ទំនងគ្នាក្នុងភាសាតែមួយ សេរីភាពខាងជំនឿសាសនា ការសំដែងសិល្បៈតាមរយៈការប្រើប្រាស់សម្លៀកបំពាក់ សិទ្ធិសេរីភាពក្នុងការបង្ហាញចេញ.....។ល។

សាកលភាពនៃសិទ្ធិទាំងប្រាំ(៥) មានន័យថាសិទ្ធិទាំងនេះត្រូវបានគេទទួលស្គាល់ដោយច្បាប់អន្តរជាតិ គឺកាតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងកាតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

ជាអាទិភាពរបស់មនុស្ស គឺកើតមកត្រូវការសិទ្ធិមានជីវិត សិទ្ធិរស់រានមានជីវិត។ មានន័យថា គ្មាននរណាម្នាក់ត្រូវបានគេដកហូតជីវិតបានឡើយ។ ដើម្បីបញ្ជាក់ថា មានជីវិតពេលកើតមក ត្រូវមានជីវិត មានដង្ហើមអាចដកចេញចូលបាន មានចលនា គឺមានមាត់សម្រាប់និយាយ មានជើងសម្រាប់ដើរ មានភ្នែកសម្រាប់មើល មានត្រចៀកសម្រាប់ស្តាប់ ការបញ្ចេញមតិយោបល់នូវអ្វីដែលបានមើលឃើញ យល់ដឹង និងរួចផុតពីការរើសអើងក្នុងសង្គម។

សិទ្ធិរស់រានមានជីវិត សំដៅដល់ការរស់នៅចាប់ពីកើតរហូតដល់ស្លាប់តាមធម្មជាតិរបស់មនុស្ស។ សិទ្ធិនេះ សំដៅដល់មនុស្សគ្រប់រូបរួចផុតពីការធ្វើទុក្ខបុកម្នេញគ្រប់ប្រភេទ ពីសង្គមដែលពួកគេរស់នៅ។

តម្លៃរបស់មនុស្សគឺ សេចក្តីថ្លៃថ្នូរ ហើយសេចក្តីថ្លៃថ្នូររបស់មនុស្ស គឺស្ថិតនៅលើសីលធម៌ដែលបុគ្គលម្នាក់ៗមាន។ ដើម្បីឱ្យមនុស្សមានសេចក្តីថ្លៃថ្នូរ មនុស្សត្រូវការសិទ្ធិមួយចំនួនទៀតដូចជា សិទ្ធិពលរដ្ឋ សិទ្ធិទទួលបានការបណ្តុះបណ្តាលអប់រំ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិធ្វើដំណើរ សិទ្ធិទទួលសេវាសុខា-ភិបាល.....។ល៕

# ជំពូកទី២
# បទដ្ឋានគតិយុត្តិអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស

# ជំពូកទី២

# បទដ្ឋានគតិយុត្តិអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស

## ២.១. ធម្មនុញ្ញសហប្រជាជាតិ

ក្រោយវិនាសសកម្មសង្គ្រាមលោកលើកទី២ ផុតរលត់ទៅនៅឆ្នាំ១៩៤៥ អ្នកដឹកនាំសំខាន់ៗនៅលើសកលលោកបានរួមគ្នាបង្កើតអង្គការសហប្រជាជាតិមួយ ដែលអាចជួយការពារសន្តិភាពពិភពលោក និងបញ្ចៀសមនុស្សជាតិឱ្យចាកផុតពីសង្គ្រាម ក៏ដូចជាចាកផុតពីអំពើឃោរឃៅ។

សិទ្ធិមនុស្សត្រូវបានគេយកចិត្តទុកដាក់ និងចាត់ទុកជាគោលដៅចម្បងរបស់អង្គការសហប្រជាជាតិ ដូចមានចែងក្នុងមាត្រា៥៥ និង មាត្រា៥៦នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ជាមួយនឹងទស្សនមួយដល់ការបង្កើតលក្ខខណ្ឌនានានៃស្ថេរភាព និងសុខមាលភាពដែលចាំបាច់ដល់ទំនាក់ទំនងជាមិត្តភាព និងសន្តិភាពរវាងប្រជាជាតិនានាដោយឈរលើមូលដ្ឋាននៃការគោរពគោលការណ៍សិទ្ធិស្មើគ្នា និងសិទ្ធិស្វ័យសម្រេចរបស់ប្រជាជនអង្គការសហប្រជាជាតិ ត្រូវលើកស្ទួយដល់៖

- កម្រិតជីវភាពរស់នៅកាន់តែខ្ពស់ ការមានការងារធ្វើពេញលេញ និងលក្ខខណ្ឌនៃវឌ្ឍនភាព និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម
- ការដោះស្រាយបញ្ហាអន្តរជាតិលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងសុខាភិបាល និងបញ្ហាពាក់ព័ន្ធដទៃទៀត និងកិច្ចសហប្រតិបត្តិជាអន្តរជាតិលើការអប់រំ និងវប្បធម៌
- ការគោរព និងការប្រតិបត្តិជាសកលនៃសិទ្ធិមនុស្ស និងសេរីភាពសារវន្តដោយគ្មានការបែងចែក ដូចជាពូជសាសន៍ ភេទ ភាសា ឬសាសនាឡើយ។

ក្នុងមុខងារជាសមាជិកនៃអង្គការសហប្រជាជាតិ សមាជិកទាំងអស់ប្តេជ្ញានឹងចាត់វិធានការរួមគ្នា ឬដោយឡែកពីគ្នាក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាតិ ដើម្បីធ្វើឱ្យសម្រេចពីគោលបំណងនានាដូចមានចែងក្នុងមាត្រា៥៥ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

## ២.២. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស(UDHR)

"មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ[1]។

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨។ មហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាស សេចក្តីប្រកាសជាសកលនេះថាជា "បទដ្ឋានរួមនៃសមិទ្ធផលសម្រាប់ប្រជាជន និងប្រជាជាតិទាំងអស់" សេចក្តីប្រកាសជា

[1] មាត្រា១, សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, អនុម័តនៅថ្ងៃទី១០ ធ្នូ ១៩៤៨។

សកលនេះ ចែងពីការយល់ឃើញជារួមមួយអំពីសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដែលរដ្ឋជាសមាជិកបានប្តេជ្ញាដោយខ្លួនឯងថានឹងសម្រេចឱ្យបាននៅក្នុងធម្មនុញ្ញសហប្រជាជាតិ។ សេចក្តីប្រកាសនេះ ទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត ព្រមទាំងសិទ្ធិស្មើគ្នា និងមិនអាចលក់ដូរបានរបស់មនុស្សគ្រប់រូប ដោយគ្មានការបែងចែកឡើយ។ នាពេលកន្លងជាច្រើនឆ្នាំមកនេះ សេចក្តីប្រកាសនេះបានទទួលនូវកម្លាំងខាងសីលធម៌ដ៏ធំមហិមា។

សេចក្តីប្រកាសជាសកល ក៏ទទួលស្គាល់នូវសិទ្ធិជាមូលដ្ឋានរបស់មនុស្សរួមមាន៖

- សិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខរបស់មនុស្ស
- សិទ្ធិទទួលបានជីវភាពរស់នៅសមរម្យ
- សិទ្ធិស្វែងរក និងសុំជ្រកកោននៅក្នុងប្រទេសដទៃ ជៀសផុតពីការធ្វើទុក្ខបុកម្នេញ
- សិទ្ធិក្នុងការអប់រំ
- សេរីភាពខាងគំនិតស្មារតី និងសាសនា
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម និងការមើលងាយ មើលថោក។ល។

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាមូលដ្ឋានគ្រឹះសម្រាប់តាក់តែងនូវសន្ធិសញ្ញាអន្តរជាតិ ដែលត្រូវបានបញ្ចូលក្នុងឯកសារច្បាប់អន្តរជាតិសំខាន់ចំនួនពីរ៖

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាសន្ធិសញ្ញាអន្តរជាតិមួយក្នុងចំណោមសន្ធិសញ្ញាអន្តរជាតិពីរ ដែលត្រូវបានព្រាងឡើង ដើម្បីផ្តល់នូវភាពតាមផ្លូវច្បាប់ដល់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨។ ចេតនាដើម គឺចង់ព្រាងសន្ធិសញ្ញាសិទ្ធិមនុស្សតែមួយប៉ុណ្ណោះ ក៏ប៉ុន្តែដោយសារតែនិន្នាការនយោបាយខុសគ្នាក្នុងសហគមន៍អន្តរជាតិនាពេលនោះទើបដំណោះស្រាយដែលអាចចេញរួច គឺការព្រមព្រៀងគ្នាព្រាងសន្ធិសញ្ញាចំនួនពីរស្របគ្នា។ ហេតុដូច្នេះកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាកញ្ចក់ឆ្លុះជាមួយនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ឯកសារទាំងពីរនេះ ធ្វើតាមទម្រង់ដូចគ្នា និងមានបទបញ្ញត្តិរួមដូចគ្នាជាច្រើន។ កតិកាសញ្ញាទាំងពីរនេះ បូករួមនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សជារឿយៗ ត្រូវបានហៅថា "ធម្មនុញ្ញអន្តរជាតិស្តីពីសិទ្ធិមនុស្ស"។

ដោយមិនគិតពី ការបែងចែកសិទ្ធិមនុស្សជាពីរ(២) កតិកាសញ្ញាដាច់ពីគ្នា និងការអនុម័តជាបន្តបន្ទាប់នូវសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលគ្របដណ្តប់លើវិស័យផ្សេងគ្នា។ អង្គការសហប្រជាជាតិ តែងតែបានសង្កត់ធ្ងន់លើពាក្យ **សកលភាព ភាពទាក់ទងគ្នា** និង**ភាពពុំនាក់អាស្រ័យគ្នា** នៃសិទ្ធិមនុស្សទាំងអស់។ និយាយម្យ៉ាងទៀត សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនសំខាន់ជាងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក៏មិនសំខាន់ជាងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរ។ មនុស្សទាំងអស់ មានសិទ្ធិទទួលបានសិទ្ធិមនុស្សទាំងអស់ស្មើគ្នា។

ទំនាក់ទំនងស្អិតរមួតរវាងសិទ្ធិទាំងពីរប្រភេទនេះ នៅពេលខ្លះមានលក្ខណៈច្បាស់លាស់ ទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានបញ្ញត្តិពីសិទ្ធិស្វ័យសម្រេច ការមិនរើសអើង និងសមភាព ព្រមទាំង សិទ្ធិសហជីព និងការការពារគ្រួសារ។

## ២.៣. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងបានចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើកតិកាសញ្ញានេះ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០ ហើយបានផ្តល់សច្ចាប័ន នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ និងចូលជាធរមាននៅប្រទេសកម្ពុជា នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២[2]។

គោលការណ៍ទូទៅនៅក្នុងកតិកាសញ្ញានេះរួមមានៈ

- សិទ្ធិស្វ័យសម្រេចរបស់ប្រជាជនទាំងអស់ ដើម្បីធ្វើសេចក្តីសម្រេចពីឋានៈនយោបាយរបស់ខ្លួន ដោយសេរី និងដើម្បីចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- គោលការណ៍នៃការមិនរើសអើង ក្នុងការអនុវត្តសិទ្ធិតាមកតិកាសញ្ញា
- គោលការណ៍សមភាពរវាងបុរស និងស្ត្រី ក្នុងការអាស្រ័យសិទ្ធិទាំងនេះ។

សិទ្ធិភាគច្រើននៅក្នុងកតិកាសញ្ញានេះ គឺជាសិទ្ធិដាច់ខាត ហើយត្រូវតែអនុវត្តភ្លាម និងទាំងស្រុងខណៈដែលសិទ្ធិទាំងនេះចូលជាធរមាន។

សិទ្ធិដែលមានចែងក្នុងកតិសញ្ញានេះរួមមានៈ

[2] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ និងពិធីសារបន្ថែម, ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា, បោះពុម្ពផ្សាយ ២០០៩។

- **សិទ្ធិមានជីវិត** រួមមានគោលការណ៍ណែនាំពីពេលវេលា និងរបៀបនៃការដាក់ទោសប្រហារជីវិត

- **សេរីភាពរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀត** ដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប ព្រមទាំងសេរីភាពរួចផុតពី ទាសភាព ភាពជាខ្ញុំកញ្ជះគេ និងការងារដោយបង្ខំ

- **សិទ្ធិមានសេរីភាព និងសន្តិសុខបុគ្គល** រួមមានសេរីភាពរួចផុតពីការចាប់ខ្លួនតាមទំនើងចិត្ត និងសិទ្ធិការពារមួយចំនួន ក្នុងកំឡុងពេលនៃការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ពន្ធនាគារតាមច្បាប់

- **សេរីភាពនៃការដើរហើរ** រួមមានសិទ្ធិចាកចេញពីប្រទេសណាមួយ និងសិទ្ធិរបស់ជនបរទេស ទទួលបាននីតិវិធីត្រឹមត្រូវ មុននឹងត្រូវបណ្តេញចេញពីប្រទេសណាមួយ

- **សិទ្ធិទទួលបានភាពស្មើគ្នាចំពោះមុខច្បាប់ និងតុលាការ និងសិទ្ធិទទួលបានសវនាការប្រកបដោយភាពយុត្តិធម៌ជាមូលដ្ឋាន** រួមមាន ការសន្មត់ជាមុនថាគ្មានទោស សិទ្ធិទទួលបានសវនាការមួយប្រកបដោយភាពយុត្តិធម៌ពីតុលាការមួយឯករាជ្យ សិទ្ធិការពារខ្លួន សិទ្ធិមានមេធាវី និងសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍

- **សិទ្ធិក្នុងការទទួលស្គាល់ថាជា មនុស្សនៅចំពោះមុខច្បាប់**

- **សិទ្ធិមានជីវិតឯកជន និងទទួលបានការការពារពីការវាយប្រហារលើកិត្តិយស ឬកិត្តិស័ព្ទរបស់ខ្លួន**

- **សេរីភាពនៃគំនិត មនសិការ និងសាសនា សេរីភាពនៃការបញ្ចេញមតិ និងយោបល់** តែត្រូវហាមឃាត់ចំពោះការឃោសនាឱ្យមានសង្គ្រាម និងការតស៊ូមតិឱ្យមានការស្អប់ជាតិ ពូជសាសន៍ ឬសាសនា

- **សិទ្ធិជួបប្រជុំដោយសន្តិវិធី** ជួនកាលហៅថា សេរីភាពនៃការជួបប្រជុំ ព្រមទាំងសេរីភាពសមាគម រួមទាំងសិទ្ធិបង្កើត និងចូលរួមសហជីព

- **សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងបង្កើតគ្រួសារ និងការការពារសិទ្ធិកុមារ**

- **សិទ្ធិប្រជាធិបតេយ្យ** រួមមាន សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត និងសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ

- **សិទ្ធិរបស់ជនភាគតិច។**

### ២.៣.១. ពិធីសារបន្ថែមលើកតិកាសញ្ញាពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គល

ដើម្បីធ្វើឱ្យប្រសើរឡើង នូវការសម្រេចទិសដៅនៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងការអនុវត្តន៍បទបញ្ញត្តិនៃកតិកាសញ្ញា វាជាការសមស្របក្នុងការធ្វើឱ្យគណៈកម្មាធិការសិទ្ធិមនុស្ស អាចទទួល និងពិនិត្យបណ្តឹង ដូចចែងក្នុងពិធីសារនេះ ពីបុគ្គលទាំងឡាយដែលអះអាងថា ជាជនរងគ្រោះនៃការរំលោភសិទ្ធិណាមួយដូចចែងក្នុងកតិកាសញ្ញា។ ពិធីសារបន្ថែមលើកតិកាសញ្ញានេះ ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាសមាជិក ដោយសេចក្តីសម្រេចចិត្តរបស់

មហាសន្និបាតលេខ ២២០០A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានថ្ងៃទី២៣ ខែមីនា ឆ្នាំ ១៩៧៦។

ពិធីសារបន្ថែមលើកតិកាសញ្ញានេះ មានខ្លឹមសារជារួមដូចជា៖

- រដ្ឋភាគីនៃកតិសញ្ញា ដែលនឹងក្លាយជាភាគីនៃពិធីសារបន្ថែមនេះ ត្រូវទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិនិត្យរាល់នូវបណ្តឹង ពីបុគ្គលដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដែលពួកគេអះអាងថាជាជនរងគ្រោះនៃការរំលោភពីរដ្ឋភាគី ទៅលើសិទ្ធិណាមួយរបស់ពួកគេដូចមានចែងក្នុងកតិកាសញ្ញា
- គណៈកម្មាធិការ ត្រូវត្រួតពិនិត្យនូវបណ្តឹងដែលទទួលបានស្របតាមពិធីសារនេះ ដោយយកមកគិតនូវរាល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ដែលផ្តល់មកឱ្យខ្លួនដោយបុគ្គល និងដោយរដ្ឋភាគីពាក់ព័ន្ធ ប៉ុន្តែគណៈកម្មាធិការ មិនត្រូវបានពិនិត្យបណ្តឹងណាមួយពីបុគ្គលណាម្នាក់ទេ លើកលែងតែ បញ្ហាដដែល មិនមានការពិនិត្យតាមនីតិវិធី នៃការស៊ើបអង្កេត ឬការដោះស្រាយអន្តរជាតិផ្សេងទៀត ឬបុគ្គលនោះ បានប្រើអស់នូវការដោះស្រាយដែលមាននៅក្នុងប្រទេស
- រដ្ឋភាគីនៃពិធីសារនេះ អាចស្នើសុំធ្វើវិសោធនកម្ម និងបញ្ជូនសេចក្តីស្នើសុំធ្វើវិសោធនកម្មជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិតាមនីតិវិធី
- ពិធីសារនេះ បានចែងអំពីការសុំចូលជាសមាជិក និងការប្រកាសដកខ្លួនចេញពីពិធីសារដោយរដ្ឋដែលបានឱ្យសច្ចាប័ន ឬបានចូលជាសមាជិកនៃកតិកាសញ្ញា។

### ២.៣.២. ពិធីសារបន្ថែមលើកតិកាសញ្ញាពាក់ព័ន្ធនឹងការលុបចោលទោសប្រហារជីវិត

ពិធីសារនេះ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៩ និងចូលជាធរមានកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩១។ ក្នុងពិធីសារបន្ថែមលើកតិកាសញ្ញាពាក់ព័ន្ធនឹងការលុបចោលទោសប្រហារជីវិតមានជំនឿថា ការលុបបំបាត់ទោសប្រហារជីវិត នាំឱ្យសេចក្តីថ្លៃថ្នូររបស់មនុស្សកាន់តែប្រសើរឡើង និងនាំឱ្យសិទ្ធិមនុស្ស មានការអភិវឌ្ឍន៍ជាលំដាប់។

ពិធីសារបន្ថែមលើកតិកាសញ្ញានេះ មានខ្លឹមសារជារួមដូចជា៖

- ក្នុងរដ្ឋភាគីនៃពិធីសារនេះ គ្មានជនណាម្នាក់ស្ថិតក្រោមដែនសមត្ថកិច្ចរដ្ឋ ត្រូវប្រហារជីវិតឡើយពោលគឺ ទោសប្រហារជីវិតត្រូវបានលុបបំបាត់ចោលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន លែកលែងតែលក្ខខណ្ឌលើកឡើងនៅពេលឱ្យសច្ចាប័ន ឬចូលជាសមាជិក ដែលមានចែងអំពីការដាក់ទោសប្រហារជីវិតក្នុងពេលមានសង្គ្រាមចំពោះទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតខាងយោធា ដែលប្រព្រឹត្តឡើងក្នុងពេលមានសង្គ្រាម។ ប៉ុន្តែរដ្ឋភាគីដែលស្នើលក្ខខណ្ឌបែបនេះ នៅពេលឱ្យសច្ចាប័ន ឬចូលជា

សមាជិកត្រូវផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវបទបញ្ញត្តិពាក់ព័ន្ធក្នុងច្បាប់ជាតិរបស់ខ្លួនដែលអនុវត្តក្នុងពេលសង្គ្រាម

- ពិធីសារនេះ បានចែងអំពីការសុំចូលជាសមាជិក និងការប្រកាសដកខ្លួនចេញពីពិធីសារដោយរដ្ឋដែលបានឱ្យសច្ចាប័ន ឬបានចូលជាសមាជិកនៃកតិកាសញ្ញា
- ពិធីសារបន្ថែមនេះ មានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញមានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ។

## ២.៤. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ហើយកតិកាសញ្ញានេះបានចូលជាធរមានតាមច្បាប់អន្តរជាតិនៅថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៧៦។

គោលការណ៍ទូទៅនៅក្នុងកតិកាសញ្ញានេះរួមមាន ៖

- គោលការសិទ្ធិស្វ័យសម្រេច ប្រជាជាតិកំណត់ដោយសេរីនូវឋានៈនយោបាយ និងកិច្ចខិតខំអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី
- គោលការណ៍សមភាពគ្នា ដោយគ្មានការរើសអើងផ្អែកពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ភាសា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀត ក្នុងការអាស្រ័យលើសិទ្ធនេះ
- គោលការណ៍មិនបំផ្លិចបំផ្លាញ ឬរិតត្បិត សិទ្ធិ ឬសេរីភាព ដែលទទួលស្គាល់ដោយកតិសញ្ញានេះ
- គោលការណ៍ទទួលស្គាល់សិទ្ធិក្នុងវិស័យការងារ បណ្តុះបណ្តាល អប់រំ ចូលរួមសហជីព និងទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវ ជីវភាពរស់នៅសមស្របតាមការជ្រើសរើសរបស់ខ្លួន ហើយថែមទាំងមានកម្រិតសុខភាព ខាងរាយកាយ និងស្មារតីខ្ពស់បំផុត
- គោលការណ៍ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ទទួលបានសន្តិសុខសង្គម រួមទាំងការធានារ៉ាប់រងសង្គម។

សិទ្ធិដែលមានចែងក្នុងកតិសញ្ញានេះរួមមាន៖

- សិទ្ធិធ្វើការងារ សិទ្ធិទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ និងអំណោយផល និងសិទ្ធិទទួលបានការសម្រាកលំហែ
- សិទ្ធិសហជីព

- សិទ្ធិទទួលបានសន្តិសុខសង្គម
- សិទ្ធិគ្រួសាររួមទាំងអាពាហ៍ពិពាហ៍ និងការគាំពារស្ត្រី និងកុមារ
- សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ រួមមានចំណីអាហារ សម្លៀកបំពាក់ និងលំនៅដ្ឋាន និងការកែលំអកម្រិតជីវភាពជាបន្តបន្ទាប់
- សិទ្ធិទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្ត
- សិទ្ធិទទួលបានការអប់រំ រួមទាំងការអប់រំមិនបង់ថ្លៃ និងជាកាតព្វកិច្ចនៅបឋមសិក្សា
- សិទ្ធិវប្បធម៌។

### ២.៤.១. ពិធីសារបន្ថែមលើកតិកាសញ្ញាពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គល

ពិធីសារបន្ថែមលើកតិកាសញ្ញានេះ មានខ្លឹមសារជារួមដូចជាៈ

- រដ្ឋភាគីនៃកតិសញ្ញា ដែលនឹងក្លាយជាភាគីនៃពិធីសារបន្ថែមនេះ ត្រូវទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការក្នុងការទទួល និងពិនិត្យរាល់នូវបណ្តឹងពីបុគ្គលដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួនដែលពួកគេអះអាងថាជាជនរងគ្រោះនៃការរំលោភពីរដ្ឋភាគីនោះ ទៅលើសិទ្ធិណាមួយនៃសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ដូចមានចែងក្នុងកតិកាសញ្ញានេះ។

- គណៈកម្មាធិការ ត្រូវត្រួតពិនិត្យនូវបណ្តឹងដែលទទួលបានស្របតាមពិធីសារនេះ ដោយយកមកគិតនូវរាល់ព័ត៌មានជាលាយលក្ខណ៍អក្សរដែលផ្តល់មកឱ្យខ្លួនដោយបុគ្គល និងដោយរដ្ឋភាគីពាក់ព័ន្ធ ប៉ុន្តែគណៈកម្មាធិការ មិនទទួលពិនិត្យបណ្តឹងណាមួយពីបុគ្គលណាម្នាក់ទេ លើកលែងតែមានការបញ្ជាក់ច្បាស់ថា បានប្រើប្រាស់អស់នូវដំណោះស្រាយទាំងប៉ុន្មានដែលមាននៅក្នុងស្រុក ឬការប្រើប្រាស់ដំណោះស្រាយទាំងនោះ បានអូសបន្លាយរយៈពេលយូរហួសហេតុពេក និងមានលក្ខខណ្ឌផ្សេងៗទៀត។

- នីតិវិធីក្នុងការដោះស្រាយបណ្តឹងតាមដំណាក់កាលនីមួយៗ

- រដ្ឋភាគីនៃពិធីសារនេះ អាចស្នើសុំធ្វើវិសោធនកម្ម និងបញ្ជូនសេចក្តីស្នើសុំធ្វើវិសោធនកម្មជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិតាមនីតិវិធី។

- ពិធីសារនេះ បានចែងអំពីការសុំចូលជាសមាជិក និងការប្រកាសដកខ្លួនចេញពីពិធីសារដោយរដ្ឋដែលបានឱ្យសច្ចាប័ន ឬបានចូលជាសមាជិកនៃកតិកាសញ្ញា។

## ២.៥. អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ បានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥។ សន្ធិសញ្ញានេះបានចូលជាធរមានតាមច្បាប់អន្តរជាតិនៅថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៦៩។ អនុសញ្ញានេះ គឺជាសន្ធិសញ្ញាដែលចាស់ជាងគេ ក្នុងចំណោមសន្ធិសញ្ញា

សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗទាំងអស់ ហើយ១ឆ្នាំបន្ទាប់មកទៀតទើបមានកតិកាសញ្ញាសំខាន់ពីរទៀតត្រូវបានអនុម័ត គឺកតិកាសសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិតកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

រាល់សន្ធិសញ្ញាសិទ្ធិមនុស្សមានបញ្ញត្តិហាមឃាត់ពីការរើសអើង រួមទាំងការរើសអើងដោយឈរលើមូលដ្ឋានពូជសាសន៍ និងដើមកំណើតជនជាតិ។ យោងតាមកតិកាសញ្ញា នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលបានចែងថា បុគ្គលទាំងអស់ មានសិទ្ធិទទួលបានសិទ្ធិមនុស្ស ដោយគ្មានការបែងចែកនៃប្រភេទណាមួយឡើង ដូចជាជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា គំនិតយោបាយ ឬគំនិតផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ដើមកំណើត ឬឋានៈផ្សេងទៀត។ អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ គឺពង្រឹងពីបញ្ញត្តិហាមឃាត់នេះ។ អនុសញ្ញានេះមានចែងពីគោលការណ៍ណែនាំបន្ថែមទៀត ដល់រដ្ឋភាគី ពីវិធានការនានាដែលគួរធ្វើ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងពូជសាសន៍។ អនុសញ្ញានេះ បានកើតឡើងពីការឆ្លើយតបរបស់សហគមន៍អន្តរជាតិចំពោះរបបអាប៉ាថេតនៅអាហ្វ្រិចខាងត្បូង ទីដែលជនភាគតិចស្បែកសបានប៉ុនប៉ងដាក់ការគ្រប់គ្រងរបស់ខ្លួនលើជនភាគច្រើនស្បែកខ្មៅនៅក្នុងប្រទេស បណ្តាលឱ្យមានការរំលោភសិទ្ធិមនុស្សយ៉ាងច្រើនលើសលុប។

អនុសញ្ញានេះ ឱ្យនិយមន័យយ៉ាងទូលំទូលាយពីការរើសអើងពូជសាសន៍ដោយរួមបញ្ចូល ការបែងចែកណាមួយ ការផាត់ចេញណាមួយ ការដាក់កំហិតណាមួយ ឬការចូលចិត្តណាមួយដោយឈរលើមូលដ្ឋានពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត ឬដើមកំណើតជាតិ ឬជនជាតិដែលមានបំណង ឬមានអានុភាពបដិសេធ ឬធ្វើឱ្យខូចខាតដល់ការទទួលស្គាល់ ការទទួលបាន ឬការអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងវិស័យដទៃទៀតនៃជីវភាពសាធារណៈ ដោយឈរលើគោលការណ៍ស្មើភាពគ្នា។

តាមរយៈនិយមន័យនេះ ការរើសអើងពូជសាសន៍ រង្វិលជុំវិញការរើសអើងប្រឆាំងនឹងនិគមជនជាតិភាគតិច ប្រជាជនដើមភាគតិច និងប្រជាជននៃជាតិទៀត ហើយនិយមន័យនេះក៏បានរួមបញ្ចូលទាំងវណ្ណៈសង្គម ជនភាគតិច ខាងសាសនា និងខាងភាសាផងដែរ។

## ២.៦. អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

អនុសញ្ញានេះ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ និងចូលជាធរមាននៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៨១ ស្របតាមបទបញ្ញត្តិមាត្រា២៧[3] ពោលគឺអនុសញ្ញាសិទ្ធិមនុស្សមួយនេះ ដែលត្រូវបានប្រទេសនានាបានផ្តល់សច្ចាប័នច្រើនជាងគេ គិតត្រឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ គឺមានប្រទេសចំនួន១៨៩ ប្រទេស បានក្លាយជារដ្ឋភាគីនៃអនុសញ្ញា (CEDAW) ដោយយើងដឹងថាសមាជិកអង្គការសហប្រជាជាតិ មានសមាជិកប្រមាណជា១៩៣ប្រទេសប៉ុណ្ណោះ។ ដោយឡែកប្រទេសកម្ពុជា បានចុះហត្ថលេខាលើអនុសញ្ញា (CEDAW) នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី១៥ ខែតុលា ឆ្នាំដដែល ដោយឥតលក្ខខ័ណ្ឌ (រាល់មាត្រាទាំងអស់ នៃអនុសញ្ញានេះត្រូវបានប្រទេសកម្ពុជាយកមកអនុវត្ត)។

អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ហៅកាត់ជាភាសាអង្គ្លេសថា (CEDAW) ត្រូវបានគេចាត់ទុកថាជា «ច្បាប់អន្តរជាតិស្តីពីសិទ្ធិ» សម្រាប់ស្ត្រី។ អនុសញ្ញានេះ គឺជាឯកសារយ៉ាងក្បោះក្បាយទាក់ទងនឹងការរំលោភបំពានសិទ្ធិមនុស្ស ដែលកើតមានលើមូលដ្ឋានការរើសអើងលើយេនឌ័រ។ អនុសញ្ញានេះបញ្ជាក់បន្ថែមជាវិជ្ជមានមកលើគោលការណ៍សមភាព ដែលតម្រូវឱ្យរដ្ឋជាភាគីចាត់«វិធានការសមរម្យទាំងឡាយ ដើម្បីធានាការអភិវឌ្ឍន៍ និងវឌ្ឍនភាពរបស់ស្ត្រី ក្នុងគោលបំណងធានាឱ្យពួកគេអាចប្រើ និងទទួលផលប្រយោជន៍ពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅលើមូលដ្ឋានសមភាពជាមួយបុរស»។

អនុសញ្ញា (CEDAW) មាន៣០មាត្រា ហើយរដ្ឋដែលត្រូវអនុវត្តតែ ១៦មាត្រាប៉ុណ្ណោះ ពីមាត្រា១ ដល់មាត្រា១៦។ ដោយឡែកមាត្រា១៧ ដល់មាត្រា៣០ គឺគ្រាន់តែជានីតិរដ្ឋបាលរបស់គណកម្មាធិការ មាន ២៣រូប សម្រាប់ធ្វើកិច្ចការ ហើយនិងនីតិវិធីផ្សេងៗ ដូចជារបៀបរបបនៃការសរសេររបាយការណ៍តាមកាលកំណត់របស់រដ្ឋភាគីតែប៉ុណ្ណោះ។ សម្រាប់ខ្លឹមសារសង្ខេបនៃ ៣០មាត្រានេះ មានបីសំខាន់៖

១. រដ្ឋភាគី (កាតព្វកិច្ចរបស់រដ្ឋភាគី ក្រោយពីខ្លួនបានឱ្យសច្ចាប័នហើយ ខ្លួនត្រូវធ្វើអ្វីខ្លះ?)

២. វិធានការសមស្របនានាដែលត្រូវចាត់ឡើង ដើម្បីលុបបំបាត់នូវការរើសអើងដែលមានចែងក្នុងអនុ-សញ្ញានេះ

៣. កិច្ចការរដ្ឋបាលរបស់គណកម្មាធិការ និងការងារផ្សេងៗទៀតដែលបម្រើផ្ទៃក្នុងឱ្យគណកម្មាធិការ។

[3] អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ចូលជាធរមាននៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៨១

យើងឃើញថាមានចំណុចជាច្រើន ដែលបានចែងទាក់ទងទៅនឹងការរើសអើងទៅលើស្ត្រីភេទនៅក្នុង អនុសញ្ញា CEDAW ដូចនេះតាមអ្វីដែលយើងបានពិនិត្យទៅលើឯកសារ ឃើញថាមានការរើសអើងជាច្រើន ទៅលើសិទ្ធិស្ត្រី ទាក់ទងទៅនឹងការរំលោភបំពាន សិទ្ធិសេរីភាព អំពើហិង្សាទៅលើផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ផ្លូវសេដ្ឋកិច្ច។ ទាក់ទងទៅនឹងសេរីភាពផ្សេងៗ ស្ត្រីត្រូវបានគេរំលោភបំពាន ប៉ុន្តែក៏ដូចជាបានកំណត់ផងដែរ ទាក់ទងនឹងការផ្តល់ជាអនុសាសន៍ ក៏ដូចជាការផ្តល់នូវការងារមួយដែលជាកាតព្វកិច្ចរបស់រដ្ឋដែលជាភាគីគួរធ្វើអ្វីខ្លះ? និងទប់ស្កាត់រាល់ការរើសអើងទៅលើស្ត្រីនៅក្នុងប្រទេសរបស់ខ្លួន។

**២.៦.១. ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ**

ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចចិត្តលេខ:A.៥៤/៤ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៩ និងបើកឱ្យចុះហត្ថលេខា នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៩ ក្នុងឱកាសសិទ្ធិមនុស្សអន្តរជាតិ និងចូលជាធរមាននៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០។

ពិធីសារបន្ថែមលើអនុសញ្ញា (CEDAW) គឺជាមធ្យោបាយដើម្បីដាក់ឱ្យរដ្ឋទទួលខុសចំពោះការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីធានាថានឹងមានការបានទទួលផលប្រយោជន៍សិទ្ធិដែលមានកំណត់ក្នុង អនុសញ្ញា (CEDAW)។ ពិធីសារនេះ គឺជាសទ្ធិសញ្ញានៃសិទ្ធិរបស់ខ្លួន ដូច្នេះ រដ្ឋដែលជាភាគីរបស់ អនុសញ្ញា (CEDAW) ត្រូវតែចុះហត្ថលេខា ទទួលស្គាល់ ឬចុះសច្ចាប័ន លើពិធីសារបន្ថែមលើអនុសញ្ញា (CEDAW) ដើម្បីឱ្យមានការពិចារណាលើញត្តិ ឬពាក្យបណ្តឹងពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិស្ត្រីភេទ។ ពិធីសារបន្ថែមលើអនុសញ្ញា (CEDAW) មាននីតិវិធីពីរសំខាន់ៗ ដែលអាចឱ្យការរំលោភសិទ្ធិស្ត្រីត្រូវបានយកមកពិចារណាក្នុងថ្នាក់អន្តរជាតិ៖

១. នីតិវិធិប្រាស្រ័យទាក់ទង៖ នីតិវិធីនេះផ្តល់មធ្យោបាយឱ្យបុគ្គល ឬក្រុម ដើម្បីដាក់ញត្តិ ឬពាក្យបណ្តឹងដោយផ្ទាល់ទៅកាន់គណៈកម្មាធិការ (មាត្រា២ នៃ ពិធីសារបន្ថែមលើអនុសញ្ញា CEDAW )។

២. នីតិវិធីស៊ើបអង្កេត៖ នីតិវិធីនេះអនុញ្ញាតឱ្យគណកម្មាធិការ ធ្វើការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ឬជាប្រព័ន្ធ ក្នុងប្រទេសដែលជាភាគីរបស់ពិធីសារបន្ថែមលើអនុសញ្ញា CEDAW (មាត្រា៨ នៃ ពិធីសារបន្ថែមលើអនុសញ្ញា CEDAW)។

បើយើងធៀបតំបន់អាស៊ាន គឺមាន១១ប្រទេស សុទ្ធតែជារដ្ឋភាគីនៃអនុសញ្ញា (CEDAW) ប៉ុន្តែមានតែ៥ប្រទេសប៉ុណ្ណោះដែលបានក្លាយខ្លួនជារដ្ឋភាគីនៃពិសារបន្ថែម ដោយមូលហេតុយន្តការមួយដែលមានពីរនីតិវិធីនេះឯង។

## ២.៧. អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

អនុសញ្ញានេះ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ និងចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ ស្របតាមបទបញ្ញត្តិនៃមាត្រា២៧(១)[4]។ ដោយឡែកប្រទេសកម្ពុជា បានក្លាយជារដ្ឋភាគីនៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩២។ តាមរដ្ឋធម្មនុញ្ញ មាត្រា៣១[5] ធានាថា អនុសញ្ញានេះ គឺជាផ្នែកមួយនៃច្បាប់កម្ពុជា។ មាត្រា៣៨ ហាមឃាត់ជាពិសេស ចំពោះការធ្វើទារុណកម្ម និងការព្យាបាទដទៃទៀត ហើយប្រកាសថា ចំលើយសារភាព ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម មិនអាចធ្វើជាភស្តុតាងបញ្ជាក់អំពីពិរុទ្ធភាពបានឡើយ។

អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ហៅកាត់ជាភាសាអង្គ្លេសថា (SPT) គឺជាសន្ធិសញ្ញាមួយដែលត្រូវបានហាមឃាត់ជាដាច់ខាតតាមមាត្រា៧[6] នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ និងផ្ដល់ការការពារបន្ថែម ដើម្បីការការពារជនទាំងឡាយដែលត្រូវបានដកហូតសេរីភាព ឱ្យរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

អនុសញ្ញា (SPT) មាន ៣៣មាត្រា ហើយរដ្ឋដែលត្រូវអនុវត្តតែ ១៥មាត្រាប៉ុណ្ណោះ ពីមាត្រា២ ដល់មាត្រា១៦ នៃអនុសញ្ញតម្រូវឱ្យរដ្ឋភាគីនីមួយៗចាត់វិធានការដ៏មានប្រសិទ្ធិភាព ដើម្បីបង្កាការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នៅលើទឹកដីណាមួយក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ ដោយឡែកមាត្រា១៧ ដល់មាត្រា៣៣ គឺគ្រាន់តែជានីតិរដ្ឋបាលរបស់គណៈកម្មាធិការ មាន១០រូប សម្រាប់ធ្វើកិច្ចការ ហើយនិងនីតិវិធីផ្សេងៗ ដូចជារបៀបរបបនៃការសរសេររបាយការណ៍តាមកាលកំណត់របស់រដ្ឋភាគីតែប៉ុណ្ណោះ។

[4] អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧។

[5] មាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[6] គ្មានជននាម្នាក់ត្រូវរងទារុណ្ណកម្ម ឬប្រព្រឹត្តិកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឲ្យថោកទាបឡើយ។ ជាពិសេស ហាមយកជនណាម្នាក់ មកធ្វើការពិសោធន៍ខាងវិជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីបីសាមីខ្លួនឡើយ។

## ២.៧.១. ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

ពិធីសារបន្ថែមនេះ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០០២ នាសម័យប្រជុំលើកទី៥៧ និងចូលជាធរមាននៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦។ ដោយឡែក ប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគី នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧។

ពិធីសារបន្ថែមលើអនុសញ្ញា (SPT) ហៅកាត់ជាភាសាអង់គ្លេសថា (OPCAT) គឺជាមធ្យោបាយដើម្បីដាក់ឱ្យរដ្ឋទាំងឡាយមានការទទួលខុសត្រូវចម្បងក្នុងការអនុវត្តន៍ មាត្រាទាំងនេះដែលត្រូវពង្រឹងការការពារជនទាំងឡាយ ដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន និងការគោរពឱ្យបានពេញលេញនូវសិទ្ធិមនុស្ស គឺជាការទទួលខុសត្រូវរួមមួយ ដែលមនុស្សគ្រប់រូបត្រូវតែអនុវត្ត ហើយស្ថាប័នអន្តរជាតិនានា ដែលមានភារកិច្ចប្រតិបត្តិ ត្រូវជួយបន្ថែម និងពង្រឹងវិធានការជាតិ។ ពិធីសារនេះ មានគោលបំណងបង្កើតប្រព័ន្ធត្រួតពិនិត្យជាទៀងទាត់មួយ ដោយស្ថាប័នជាតិ និងអន្តរជាតិនានាដែលឯករាជ្យ នៅកន្លែងឃុំឃាំងជនទាំងឡាយ ដែលត្រូវបានដកហូតសេរីភាព ដើម្បីបង្ការការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អនុស្សធម៌ ឬបន្ថោកបន្ទាប។ ប្រព័ន្ធដែលត្រូវបង្កើតនោះមានពីរ រួមមានៈ

១. អនុគណៈកម្មាធិការបង្ការអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អនុស្សធម៌ ឬបន្ថោកបន្ទាប នៃគណៈកម្មាធិការប្រឆាំងទារុណកម្មៈ អនុគណៈកម្មាធិការបង្ការ ត្រូវបំពេញការងាររបស់ខ្លួន ក្នុងក្របខណ្ឌនៃធម្មនុញ្ញសហប្រជាជាតិ ហើយត្រូវអនុវត្តស្របតាមគោលបំណង និងគោលការណ៍ផ្សេងៗនៃធម្មនុញ្ញនេះ ក៏ដូចជាលិខិតបទដ្ឋានរបស់អង្គការសហប្រជាជាតិ ស្តីពីការប្រព្រឹត្តលើជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន និងត្រូវអនុវត្តតាមគោលការណ៍រក្សាការសំងាត់ ភាពឥតលំអៀង ភាពមិនប្រកាន់និន្នាការសកលភាព និងគោលការណ៍សត្យានុម័ត។

២. យន្តការបង្ការថ្នាក់ជាតិៈ រដ្ឋភាគីនីមួយៗត្រូវរក្សាចាត់តាំង ឬបង្កើតយន្តការឯករាជ្យថ្នាក់ជាតិមួយ ឬច្រើនដើម្បីបង្ការការធ្វើទារុណកម្មនៅថ្នាក់ជាតិ។ យន្តការដែលបានបង្កើតដោយអង្គភាពវិមជ្ឈការនានា អាចត្រូវបានចាត់តាំងជាយន្តការបង្ការថ្នាក់ជាតិ ដើម្បីគោលបំណងនៃពិសារនេះ ប្រសិនបើយន្តការទាំងនេះស្របទៅនឹងបទបញ្ញត្តិនៃពិធីសារនេះ។

## ២.៨. អនុសញ្ញាស្តីពីសិទ្ធិកុមារ

អនុសញ្ញានេះ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ និងចូលជាធរមាននៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៨៩ ស្របតាមមាត្រា៤៩[7]។ ដោយឡែកប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ តាមរយៈការចូលជាសមាជិកនេះ ព្រះរាជាណាចក្រកម្ពុជាប្តេជ្ញាខ្លួនការពារ និងបំពេញតាមសិទ្ធិនានារបស់កុមារទាំងអស់នៅកម្ពុជា។ លើសពីនេះ អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាសទ្ធិសញ្ញាសិទ្ធិមនុស្សមួយ ដែលទទួលបានការផ្តល់សច្ចាប័នច្រើនជាងគេបំផុត ហើយមានអនុភាពចងជាកាតព្វកិច្ចតាមផ្លូវច្បាប់ចំពោះរដ្ឋភាគីទាំងអស់។

អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាសិទ្ធិសញ្ញាអន្តរជាតិដែលមានចែងពីបទដ្ឋានអប្បបរមាជាសកល និងពីគោលការណ៍សីលធម៌សម្រាប់កុមារនៅក្នុងសង្គម។ អនុសញ្ញានេះ គឺជាសេចក្តីថ្លែងលម្អិតមួយពីសិទ្ធិទាំងឡាយដែលកុមារគ្រប់ទិសទីត្រូវទទួលបាន ហើយរួមបញ្ចូលសិទ្ធិពលរដ្ឋ នយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ដែលពាក់ព័ន្ធនឹងកុមារ។ គោលបំណងរបស់អនុសញ្ញា គឺបង្កើតជាបទដ្ឋានសម្រាប់ការពារកុមារប្រឆាំងនឹងការទុកចោលមិនយកចិត្តទុកដាក់ ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការរើសអើងដែលខ្លួនជួបប្រទះក្នុងកម្រិតផ្សេងៗជារៀងរាល់ថ្ងៃនៅគ្រប់ប្រទេស។

អនុសញ្ញាស្តីពីសិទ្ធិកុមារមាន៥៤មាត្រា ដែលនិយាយអំពីនរណាជាកុមារ (មាត្រា១) សិទ្ធិដែលពួកគេទទួលបាន (សិទ្ធិរស់រានមានជីវិត សិទ្ធិអភិវឌ្ឍន៍ សិទ្ធិទទួលបាននូវការការពារ សិទ្ធិចូលរួម) និងការទទួលខុសត្រូវនៃរដ្ឋាភិបាល (ឧត្តមប្រយោជន៍កុមារ «មាត្រា៣» ការមិនរើសអើង «មាត្រា២» សិទ្ធិមានជីវិត សិទ្ធិរស់រានមានជីវិត និងសិទ្ធិអភិវឌ្ឍន៍ «មាត្រា៦» ការគោរពទស្សនៈកុមារ «មាត្រា១២»)។ សិទ្ធិទាំងអស់ គឺពាក់ព័ន្ធគ្នា មានសារសំខាន់ដូចគ្នា ហើយមិនអាចយកចេញពីកុមារបាននោះទេ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ មានពិធីសារបន្ថែមចំនួនពីរដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីខែឧសភា ឆ្នាំ២០០០។ ពិធីសារមួយ គឺសំដៅប្រឆាំងនឹងការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឯពិធីសារបន្ថែមមួយទៀត គឺសំដៅដល់ការដាក់កំហិត និងបញ្ញត្តិពីការប្រើប្រាស់ទាហានក្រោមអាយុ១៨ឆ្នាំ។ ពិធីសារបន្ថែម គឺជាឯកសារបន្ថែមលើសន្ធិសញ្ញាគោលដែលរដ្ឋនីមួយៗអាចជ្រើសរើស ដើម្បីចូលជាសមាជិកប្រសិនបើរដ្ឋនោះយល់ព្រមទទួលកាតព្វកិច្ចបន្ថែមតាមពិធីសារនោះដោយមិនគិតដល់អនុសញ្ញាដើមឡើយ។

[7] អនុសញ្ញាស្តីពីសិទ្ធិកុមារ ចូលជាធរមាននៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៨៩

### ២.៨.១. ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ

ពិធីសារនេះ ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខាឱ្យសច្ចាប័ន និងសុំចូលជាសមាជិកតាមសេចក្តីសម្រេចចិត្តលេខ:A/RES/៥៤.២៦៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០ របស់មហាសន្និបាតអង្គការសហប្រជាជាតិ និងចូលជាធរមាននៅថ្ងៃទី១២ ខែកម្ភៈ ឆ្នាំ២០០២ ស្របតាមមាត្រា១០[8]។ ហើយប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីនៃពិធីសារនេះ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៦។

ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារគឺ ដើម្បីពង្រឹងបន្ថែមនូវការអនុវត្តសិទ្ធិដែលទទួលស្គាល់ក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលចាំបាច់ត្រូវបង្កើនការការពារកុមារមិនឱ្យចូលពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ។ ពិធីសារនេះដែលបានតម្លើងអាយបុគ្គល ដែលអាចជ្រើសរើសឱ្យចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធ និងចូលរួមក្នុងអរិភាព និងចូលរួមចំណែកយ៉ាងមានប្រសិទ្ធិភាពដល់ការអនុវត្តគោលការណ៍ដែលត្រូវគិតគូរជាចម្បងដល់ឧត្តមភាពប្រយោជន៍របស់កុមារ នៅគ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងកុមារ។

ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារមាន១៣មាត្រា ដែលបានចែងយ៉ាងច្បាស់អំពីសិទ្ធិការការពារពិសេសដែលកុមារទទួលបាន និងការធានាថាមិនឱ្យកុមារអាយុក្រោម១៨ឆ្នាំមានការពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ។

### ២.៨.២. ពិសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ

ពិធីសារនេះ ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខាឱ្យសច្ចាប័ន និងសុំចូលជាសមាជិកដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចចិត្តលេខ:A/RES/៥៤.២៦៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០០០ និងចូលជាធរមាននៅថ្ងៃទី១៨ ខែកមរា ឆ្នាំ២០០២ ស្របតាមមាត្រា១៤[9] ។ ហើយប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីនៃពិធីសារនេះនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០២។

ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារមាន១៧មាត្រា ដែលបានចែងយ៉ាងច្បាស់អំពីកាតព្វកិច្ចរបស់រដ្ឋភាគី និងចាត់វិធានការចាំបាច់ ដើម្បីពង្រឹងសហប្រតិបត្តិការអន្តរជាតិតាមការព្រមព្រៀងពហុភាគី ថ្នាក់តំបន់ និងទ្វេភាគី ដើម្បីបង្ការ ស្វែងរក ស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោសជនដែលទទួលខុសត្រូវ

[8] ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ចូលជាធរមាននៅថ្ងៃទី១២ ខែកម្ភៈ ឆ្នាំ២០០២

[9] ពិសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ ចូលជាធរមាននៅថ្ងៃទី១៨ ខែកមរា ឆ្នាំ២០០២

ចំពោះអំពើពាក់ព័ន្ធការលក់កុមារ ពេស្យាកម្មកុមារ រូបភាព ឬសម្ភារៈអាសអាភាសកុមារ និងទេសចរណ៍ផ្លូវភេទកុមារ។

រដ្ឋភាគី ត្រូវដាក់បទល្មើសទាំងនោះ ជាបទល្មើសអាចផ្តន្ទាទោសបានយ៉ាងពេញលេញតាមច្បាប់ព្រហ្មទណ្ឌ ដោយស្ថិតក្រោមគោលការណ៍គតិយុត្តិនៃរដ្ឋភាគី កាតព្វកិច្ចទទួលខុសត្រូវរបស់នីតិបុគ្គល អាចមានខាងព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬខាងរដ្ឋបាល។

## ២.៩. អនុសញ្ញាស្តីពីសិទ្ធិជនពិការ

អនុសញ្ញាស្តីពីសិទ្ធិជនពិការ ត្រូវបានអនុម័តនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ ដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិ និងចូលជាធរមាន នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៨ ស្របតាមមាត្រា៤៥ (១)[10]។ ដោយឡែកប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។

អនុសញ្ញានេះមាន ៥០មាត្រា ដែលបានចែងយ៉ាងច្បាស់អំពីកាតព្វកិច្ចរបស់រដ្ឋភាគី ដោយលើកស្ទួយសិទ្ធិជនពិការនិងធានាឱ្យជនពិការទទួលបានពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ និងដើម្បីលើកស្ទួយការការពារសេចក្តីថ្លៃថ្នូរដែលមានពីកំណើតមក និងមានបទបញ្ញត្តិលម្អិតអំពីការអនុវត្ត និងការឃ្លាំមើលថ្នាក់ជាតិរួមមានការប្រមូលស្ថិតិ និងទិន្នន័យដទៃទៀត និងមុខងារនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីសម្រាប់ជាប្រយោជន៍ដល់ជនពិការ។

### ២.៩.១. ពិសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ

ពិធីសារនេះមាន ១៨មាត្រា ដែលបាននិយាយអំពីសមត្ថកិច្ចរបស់រដ្ឋភាគី (រដ្ឋភាគីនៃពិធីសារនេះ «រដ្ឋភាគី» ទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការសិទ្ធិជនពិការ «គណៈកម្មាធិការ» ក្នុងការទទួលបណ្តឹងដែលធ្វើដោយបុគ្គល ឬក្នុងនាមបុគ្គល ឬក្រុមបុគ្គលដែលស្ថិតក្រោដែនសមត្ថកិច្ចរបស់រដ្ឋភាគីដែលបុគ្គលនោះអះអាងថា ជាជនរងគ្រោះពីការរំលោភដោយរដ្ឋភាគីទៅលើបទបញ្ញត្តិនៃអនុសញ្ញានេះ[11]) និងគណៈ-កម្មាធិការសិទ្ធិជនពិការក្នុងការសហការពិនិត្យព័ត៌មាន និងផ្តល់សេចក្តីសង្កេតចំពោះព័ត៌មានពាក់ព័ន្ធរួមជាមួយនឹងការផ្តល់យោបល់ ឬអនុសាសន៍ ដោយបញ្ជាក់ច្បាស់អំពីវិធានការនានាដែលបានចាត់ឡើង ឆ្លើយតបទៅនឹងការស៊ើបអង្កេត។

[10] អនុសញ្ញាស្តីពីសិទ្ធិជនពិការ ចូលជាធរមាននៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៨

[11] ពិសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ

## ២.១០. អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន

អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន ត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥១ ដោយសន្និសីទនៃបុណ្ណទូតសហប្រជាជាតិ ស្ដីពីឋានៈនៃជនភៀសខ្លួន និងនិបេតិកជនកោះប្រជុំសន្និសីទ ស្របតាមសេចក្ដីសម្រេចលេខ៤២៩ (V) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥០ និងចូលជាធរមាននៅថ្ងៃទី២២ ខែមេសា ឆ្នាំ ១៩៥៤ យោងតាមមាត្រា៤៣[12]។ ដោយឡែកប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។

អនុសញ្ញានេះមាន៤៦មាត្រា ដែលបានចែងយ៉ាងច្បាស់អំពីសិទ្ធិ និងផលប្រយោជន៍របស់ជនភៀសខ្លួន ដែលរដ្ឋនៃភាគីធានាឱ្យជនភៀសខ្លួនប្រើប្រាស់សិទ្ធិ និងសេរីភាពជាមូលដ្ឋាន និងត្រូវអនុវត្តតាមបទបញ្ញត្តិនៃអនុសញ្ញានេះ ចំពោះជនភៀសខ្លួនទាំងអស់ដោយមិនប្រកាន់រើសអើង មានជាអាទិ៍ ពូជសាសន៍ សាសនា ឬប្រទេសដើមកំណើត។ ភៀសខ្លួនទាំងអស់ ទទួលបាននូវផលប្រយោជន៍ជាច្រើនពីសំណាក់រដ្ឋភាគី ដែលជាប្រទេសខ្លួនកំពុងស្នាក់នៅស្របតាមច្បាប់មានដូចជា ជំនួយសង្គ្រោះជាសាធារណៈ ច្បាប់សន្តិសុខសង្គម សេរីភាពក្នុងការដើរហើរជាដើម។

### ២.១០.១. ពិធីសារពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន

ពិធីសារបន្ថែមពាក់ព័ន្ធឋានៈជនភៀសខ្លួន បានទទួលការកត់សម្គាល់ដោយមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចតាមសេចក្ដីសម្រេចចិត្តលេខ១១៨៦(XLI) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ១៩៦៦ និងបានទទួលការកត់សម្គាល់ដោយមហាសន្និបាតតាមសេចក្ដីសម្រេចចិត្តលេខ(XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងចូលជាធរមាននៅថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៦៧ ដោយអនុលោមតាមមាត្រា៨។

ពិធីសារបន្ថែមនេះបានបញ្ជាក់យ៉ាងច្បាស់អំពីរដ្ឋភាគី សន្យាអនុវត្តអនុសញ្ញា ចាប់តាំងពីមាត្រា២ រហូតដល់មាត្រា៣៤ នៃអនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន ដូចមានចែងនៅក្នុងអនុសញ្ញានេះ[13]។ ១១មាត្រានៃពិធីសារបន្ថែម បានបញ្ជាក់បន្ថែមអំពីកិច្ចសហប្រតិបត្តិការនៃអាជ្ញាធរជាតិជាមួយនឹងអង្គការសហប្រជាជាតិ និងកិច្ចការទូទៅរបស់រដ្ឋជាមួយឧត្តមស្នងការអង្គការសហប្រជាជាតិ ពាក់ព័ន្ធនឹងការជួយសម្រួលគ្នាទៅវិញទៅមកដែលទាក់ទងនឹងជនភៀសខ្លួន ការអនុវត្តច្បាប់ និងបទបញ្ញត្តិផ្សេងៗ។

[12] អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន ចូលជាធរមាននៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៥៤

[13] មាត្រា១ កថាខណ្ឌ១ ពិធីសារបន្ថែមពាក់ព័ន្ធឋានៈជនភៀសខ្លួន ច្បាប់សិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០០៨។

## ២.១១. អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍

អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខាផ្តល់សច្ចាប័ន ឬចូលជាសមាជិកដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ២៦០A(III) ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១ ស្របតាមបទបញ្ញត្តិនៃមាត្រា១៣។ ដោយឡែកប្រទេសកម្ពុជាបានក្លាយជាសមាជិកនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០។

សេចក្តីប្រកាសដែលបានធ្វើឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ៩៦ (I) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ ចែងថា អំពើប្រល័យពូជសាសន៍ គឺជាបទឧក្រិដ្ឋមួយដែលបានកំណត់ក្នុងច្បាប់អន្តរជាតិ អំពើនេះផ្ទុយទៅនឹងស្មារតី និងបំណងប្រាថ្នារបស់អង្គការសហប្រជាជាតិ ហើយត្រូវផ្តន្ទាទោសដោយពិភពនៃអារ្យប្រទេស។ នៅគ្រប់សម័យកាលនៃប្រវត្តសាស្ត្រ អំពើប្រល័យពូជសាសន៍ បានបង្កឱ្យមានការបាត់បង់ដ៏ធំធេងដល់ជីវិតមនុស្សជាតិ។ ដើម្បីរំដោះមនុស្សជាតិឱ្យរួចផុតពីហានិភ័យដ៏គួរឱ្យស្អប់ខ្ពើមនេះ គឺតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិ។

អនុសញ្ញានេះមានសរុប១៩មាត្រា ដែលរដ្ឋភាគីទាំងអស់បញ្ជាក់អះអាងថា អំពើប្រល័យពូជសាសន៍ ទោះជាបានប្រព្រឹត្តនៅក្នុងពេលមានសន្តិភាព ឬនៅពេលមានសង្គ្រាមក្តី គឺជាឧក្រិដ្ឋកម្មមួយដែលបានកំណត់ក្នុងច្បាប់អន្តរជាតិ ហើយរដ្ឋភាគីទាំងអស់មានភារកិច្ចធ្វើការទប់ស្កាត់ និងផ្តន្ទាទោស[14]។

[14] មាត្រា១ នៃអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍។

# ជំពូកទី៣
# សិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

# ជំពូកទី៣
# សិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

## ៣.១. សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

### ៣.១.១. ដើមកំណើតសិទ្ធិមនុស្សនៅកម្ពុជា

សេចក្តីប្រកាសអំពីសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្តីប្រកាសអំពីសិទ្ធិមនុស្ស បោះពុម្ពផ្សាយដោយការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងឱកាសខួបលើកទី៦០ នៃការអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សកាលពីឆ្នាំ១៩៤៨ និងខួបលើកទី១៥នៃការអនុម័តរដ្ឋធម្មនុញ្ញនៃព្រះរាជជាណាចក្រកម្ពុជា កាលពីឆ្នាំ១៩៩៣។

សេចក្តីប្រកាសនេះ មានសុពលភាពស្របច្បាប់នៅកម្ពុជា យោងតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញរួមមានសេចក្តីថ្លែងការណ៍មួយ អំពីសិទ្ធិជាមូលដ្ឋាននៅក្នុងនោះ មានសិទ្ធិមានជីវិតរស់នៅ សេរីភាពរបស់បុគ្គល សន្តិសុខ សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា រួមប្រជុំគ្នា និងបង្កើតសមាគមរួមទាំងការបង្កើតគណបក្សនយោបាយ និងសហជីព ដំណើរការតុលាការត្រឹមត្រូវ និងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំឱ្យមានការដកហូតកម្មសិទ្ធិតាមតែទំនើងចិត្ត ឬការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសងជំងឺចិត្តដ៏ត្រឹមត្រូវ និងសេរីភាពដោយគ្មានការប្រកាន់ការរើសអើងពូជសាសន៍ ជនជាតិ ជំនឿ សាសនា ឬភេទឡើយ។ ចំពោះបុគ្គលដែលត្រូវបានរំលោភបំពាន មានសិទ្ធិប្តឹងទៅតុលាការ ដើម្បីកាត់សេចក្តី និងធ្វើឱ្យគេគោរពតាមសិទ្ធិដែលបានចែង[15]។

### ៣.១.២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា។ រាល់ច្បាប់ និងឯកសារគតិយុត្តទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវអនុលោមទៅតាមរដ្ឋធម្មនុញ្ញ បើពុំនោះសោត ច្បាប់ និងឯកសារគតិយុត្តិទាំងនោះនឹងអធម្មនុញ្ញភាព។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី២៤ កញ្ញា ឆ្នាំ១៩៩៣។ គិតមកដល់ត្រឹមខែមីនា ឆ្នាំ២០២១ មានវិសោធនកម្ម ០៨លើក (ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ១៩៩៤, ថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩, ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០១, ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៤, ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០០៥, ថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៦, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ និងថ្ងៃទី០១ ខែតុលា

[15] ច្បាប់សិទ្ធិមនុស្សកម្ពុជា, ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, បោះពុម្ពផ្សាយ ២០១២។

ឆ្នាំ២០១៤) ត្រូវបានប្រកាសឱ្យប្រើប្រាស់។ ដោយឡែក ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម នស/រកម/០៧០៤/០០១ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៤ ហើយបានធ្វើវិសោធនកម្មចំនួនមួយមាត្រា គឺមាត្រា៦។

### ៣.១.២.១. អំពីព្រះមហាក្សត្រ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែមិនកាន់អំណាច។ ថ្វីត្បិតតែទ្រង់មិនកាន់អំណាចដោយផ្ទាល់ ប៉ុន្តែទ្រង់ជាព្រះប្រមុខរដ្ឋ។ ដូច្នេះ ព្រះអង្គពុំមានអំណាចពិតប្រាកដឡើយ ព្រោះថារាល់ការតែងតាំង ការដកហូត និងឡាយព្រះហស្តលេខាលើច្បាប់ សន្ធិសញ្ញាផ្សេងៗ គឺត្រូវតែមានការស្នើរសុំពីស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិ។

តួនាទី និងភារកិច្ចរបស់ព្រះមហាក្សត្រ ដើម្បីធានានូវអព្យាក្រឹត គឺព្រះមហាក្សត្រ ត្រូវតែគង់នៅពីលើនយោបាយ។ ម្យ៉ាងវិញទៀត តួនាទីដ៏ខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់ គឺមានន័យថាជាតួនាទីដែលបានផ្តល់ឱ្យព្រះមហាក្សត្រនូវអំណាចសម្របសម្រួលមួយដ៏សំខាន់។

យើងពិនិត្យឃើញថា ព្រះមហាក្សត្រព្រះអង្គទ្រង់មានព្រះរាជកិច្ចពីរ(២)យ៉ាងគឺៈ

- **ព្រះរាជកិច្ច ជាអធិបតីៈ** គឺព្រះអង្គជានិមិត្តរូប និងគង់ជាអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងជាអធិបតីនៃសមាជជាតិ។ល។
- **ព្រះរាជកិច្ច ជារដ្ឋបាលៈ** គឺចង់មានន័យថា ព្រះអង្គឡាយព្រះហស្តលេខាលើច្បាប់ សន្ធិសញ្ញាផ្សេងៗ និងការតែងតាំង ដកហូតជាដើម។

### ៣.១.២.២. អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋ

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពនិងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិឋានៈ សង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុង

ច្បាប់[16]។

សិទ្ធិមនុស្ស ត្រូវបានបែងចែកជាពីរ (២)ក្រុម សំខាន់ៗ។

❖ ក្រុមទីមួយ គឺសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមានដូចជា៖

- សិទ្ធិក្នុងការរស់រានមានជីវិត
- សេរីភាពក្នុងការនិយាយស្ដី សេរីភាពក្នុងការទទួលព័ត៌មាន និងការចែករំលែកព័ត៌មាន (សេរីភាពនៃការបញ្ចេញមតិ)
- សេរីភាពក្នុងការជួបជុំ និងសេរីភាពធ្វើបាតុកម្មដោយសន្តិវិធីជាមួយអ្នកដទៃ (សេរីភាពជួបជុំ)
- សេរីភាពក្នុងការបង្កើត ឬចូលរួមក្នុងក្រុមដែលពេញចិត្ត (សេរីភាពក្នុងការបង្កើត និងចូលរួមក្នុងសមាគម)
- សេរីភាពចាកផុតពីការធ្វើទារុណកម្ម ឬត្រូវបានគេប្រើប្រាស់ដូចជាទាសករ
- សិទ្ធិក្នុងការប្រកួតប្រជែងក្នុងការបោះឆ្នោត និងចូលរួមក្នុងជីវភាពនយោបាយ និងក្នុងការដឹកនាំកិច្ចការសាធារណៈ សិទ្ធិក្នុងការជ្រើសរើសអ្នកដែលយើងចង់ឱ្យដឹកនាំប្រទេស ឬសមាគមន៍
- សិទ្ធិក្នុងការមានភាពស្មើគ្នាចំពោះមុខច្បាប់
- សិទ្ធិជនភាគតិចក្នុងការនិយាយភាសារបស់ពួកគេ
- និងរួមជាមួយនឹងសិទ្ធិដទៃទៀត។

❖ ក្រុមទីពីរ គឺសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានដូចជា៖

- សិទ្ធិក្នុងការធ្វើការដោយមានលក្ខខណ្ឌការងារល្អ
- សិទ្ធិក្នុងការទទួលបានប្រាក់ឈ្នួល ស្មើគ្នាដូចអ្នកដទៃសម្រាប់ការងារដូចគ្នា
- សិទ្ធិក្នុងការបង្កើត និងចូលរួមសហជីព
- សិទ្ធិក្នុងទទួលបានរបបសន្តិសុខសង្គម (ការជួយពីរដ្ឋាភិបាល)
- សិទ្ធិទទួលបានកម្រិតជីវភាពរស់នៅសមរម្យ សិទ្ធិទទួលបានស្បៀងអាហារ សម្លៀកបំពាក់ និងលំនៅដ្ឋានសមរម្យ
- សិទ្ធិក្នុងការទទួលបានការអប់រំ
- សិទ្ធិក្នុងការទទួលបានការការពារសម្រាប់ការបង្កើតថ្មី
- និងសិទ្ធិដទៃទៀត។

[16] មាត្រា៣១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤

**៣.១.២.៣. អំពីរបបនយោបាយ**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ដោយអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

**៣.១.២.៤. អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច**

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីអោយការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ រដ្ឋយកចិត្តទុកដាក់ លើវិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ជាពិសេសរដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាព នៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នា ក្នុងការកសាងជីវិត។ រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតបង់ថ្លៃ ហើយប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួន(៩)ឆ្នាំ។

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានាដោយ រដ្ឋបានយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និងព្យាបាលជម្ងឺ ដោយរដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការ ពិនិត្យរោគ ដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរពេទ្យសម្ភពសាធារណៈ។ រដ្ឋក៏បានយកចិត្តទុកដាក់ចំពោះកុមារ និងមាតាផងដែរ ដោយបានរៀបចំអោយមានទារកដ្ឋាន និងជួយឧបត្ថម្ភស្ត្រីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង។ លើសពីនេះ រដ្ឋជួយឧបត្ថម្ភជនពិការ និងគ្រួសាយុទ្ធជន ដែលបានបូជាជីវិត ដើម្បីប្រទេសជាតិ។

រដ្ឋក៏បានចាត់ចែងអោយមានរបបសន្តិសុខសង្គម ដល់កម្មករ និងនិយោជិកផងដែរ។

**៣.១.២.៥. អំពីអំណាចតុលាការ**

អំណាចតុលាការ ជាអំណាចឯករាជ្យ ដែលធានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ហើយគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។ អំណាចតុលាការ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។

ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ ចៅក្រម ជាអ្នកមានសិទ្ធិជម្រះក្តី ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។

## ៣.២. សិទ្ធិមនុស្ស និងការអនុវត្តជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា

### ៣.២.១. សិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា

#### ៣.២.១.១. ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

ជុំវិញទាក់ទងទៅនឹងសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា អង្គការសហប្រជាជាតិ បានរក្សាទុកការិយាល័យមួយ ដែលបានផ្តោតជាសំខាន់លើការការពារ និងការលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៣មកម្ល៉េះ។ ការិយាល័យមួយនេះ ផ្តោតសំខាន់ទៅលើសិទ្ធិមនុស្សជាចម្បង ដែលគេស្គាល់ថាជា "ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស(ការិយាល័យOHCHR)"។ ការិយាល័យនេះអនុវត្តអាណត្តិជាសាកលរបស់ឧត្តមស្នងការ ក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្ស។ ការិយាល័យ(OHCHR) ធ្វើការជាមួយរដ្ឋាភិបាល អង្គភាពយុត្តិធម៌ និងអង្គភាពនីតិបញ្ញត្តិ សង្គមស៊ីវិល និងតួអង្គជាតិ និងអន្តរជាតិផ្សេងទៀត ដើម្បីគាំទ្រដល់ការបង្រួបបង្រួមសន្តិភាព និងការអភិវឌ្ឍដែលមានការចូលរួមរបស់កម្ពុជា។ ការិយាល័យប្រចាំកម្ពុជា គឺជាទីភ្នាក់ងារដ៏សំខាន់មួយរបស់អង្គការសហប្រជាជាតិ ក្នុងការបំពេញការងារដោយទទួលខុសត្រូវក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងការលើកស្ទួយនីតិរដ្ឋ និងអនុលោមភាពទៅនឹងបទដ្ឋានសិទ្ធិមនុស្ស ដែលកម្ពុជាបានផ្តល់សច្ចាប័ន។ ទីភ្នាក់ងារ នេះគឺជាផ្នែកមួយនៃលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ ជាអង្គការអន្តររដ្ឋាភិបាល ដែលមានរដ្ឋជាសមាជិកចំនួន១៩២។

ការិយាល័យ(OHCHR) មានទីស្នាក់ការកណ្តាល នៅទីក្រុងហ្សឺណែវ ប្រទេសស្វ៊ីស។ ទីភ្នាក់ងារនេះមានការិយាល័យមួយទៀត នៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក និងមានការិយាល័យប្រចាំតំបន់ និងប្រចាំប្រទេសផ្សេងៗ ហើយទីប្រឹក្សាសិទ្ធិមនុស្ស ត្រូវបានចាត់តាំងឱ្យធ្វើជាសមាជិកនៃ ក្រុមប្រទេសអង្គការសហប្រជាជាតិ និងបេសកកម្មរក្សាសន្តិភាពរបស់អង្គការ សហប្រជាជាតិនៅជុំវិញពិភពលោក។ ការិយាល័យ OHCHR ប្រចាំកម្ពុជា រក្សាទុកការិយាល័យកណ្តាលមួយនៅក្រុងភ្នំពេញ និងការិយាល័យប្រចាំតំបន់មួយនៅខេត្តបាត់ដំបង[17]។

ការិយាល័យ OHCHR មានកម្មវិធីចំនួនបួន ក្នុងប្រទេសកម្ពុជា៖

- កម្មវិធីដីធ្លី និងលំនៅដ្ឋាន
- កម្មវិធីនីតិរដ្ឋ

[17] https://cambodia.ohchr.org/kh/about-us/who-we-are (ចូលទស្សនាថ្ងៃទី ០៨ សីហា ២០២១)

- កម្មវិធីសង្គមស៊ីវិល និងសេរីភាពមូលដ្ឋាន
- កម្មវិធីគាំទ្រកំណែទម្រង់ពន្ធនាគារ

**៣.២.១.២. ប្រវត្តិការិយាល័យ**(OHCHR)**ប្រចាំកម្ពុជា**

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បាននិងកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជាចាប់តាំងពីខែតុលា ឆ្នាំ១៩៩៣។ កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ បានផ្តល់ដល់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា "អ៊ុនតាក់" នូវអាណត្តិមួយ ដើម្បីឃ្លាំមើលស្ថានភាពសិទ្ធិមនុស្ស ក្នុងអំឡុងពេលអន្តរកាល (ឆ្នាំ១៩៩១-១៩៩៣)។ បន្ទាប់ពីការងាររបស់អ៊ុនតាក់ បានចប់សព្វគ្រប់ហើយ កិច្ចព្រមព្រៀងនេះបានផ្តល់អាណត្តិដល់អង្គការសហប្រជាជាតិ ដើម្បីបន្តការងារសិទ្ធិមនុស្សនៅក្នុងប្រទេសនេះទៀតកម្មវិធីការិយាល័យបានអភិវឌ្ឍចេញពីអាណាត្តិនេះ។

**៣.២.១.៣. តួនាទី និងភារកិច្ចរបស់ការិយាល័យ**(OHCHR)**ប្រចាំកម្ពុជា**

ចាប់តាំងពីឆ្នាំ១៩៩៣មក ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបាននិងកំពុងបន្តកិច្ចខិតខំប្រឹងប្រែងនេះលើវិស័យដូចខាងក្រោម៖

- គាំទ្រការអភិវឌ្ឍនូវក្របខណ្ឌច្បាប់ និងស្ថាប័នដែលការពារការអនុវត្តសិទ្ធិមនុស្ស អនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា

- ឃ្លាំមើលការអនុវត្តច្បាប់ និងសកម្មភាពនានារបស់ស្ថាប័នរដ្ឋ ដែលទទួលបន្ទុកគោរព និងលើកកម្ពស់សិទ្ធិ ធ្វើសេចក្តីរាយការណ៍ពីវិស័យដែលមានបញ្ហាដល់រដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យមានវិធានការកែតម្រូវ និងរួមគ្នាស្វះស្វែងរកដំណោះស្រាយ

- គាំទ្រកិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាល ជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ និងយន្តការរបស់ក្រុមប្រឹក្សានេះ និងលើកស្ទួយការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

- គាំទ្រសមត្ថភាពរបស់តួអង្គសង្គមស៊ីវិល (អង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាល សមាគមស្ត្រី ប្រព័ន្ធផ្សព្វផ្សាយ សហជីពកម្មករ និងស្ថាប័នដទៃទៀត) ដើម្បីឃ្លាំមើល និងតស៊ូមតិ ដើម្បីសិទ្ធិមនុស្ស និងការពារសកម្មភាពរបស់ពួកគេទាំងនោះ តាមរយៈការជំរុញឱ្យមានបរិយាកាសមួយគោរពគ្នាទៅវិញទៅមក កិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល។

បន្ថែមពីនេះ ការិយាល័យ OHCHR ក៏បានផ្តល់សេវាដូចខាងក្រោម ជូនដល់រដ្ឋាភិបាល សង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងៗទៀតរួមមាន៖

- ការវាយតម្លៃជាបន្តនូវស្ថានភាពសិទ្ធិមនុស្ស ដែលត្រូវបានផ្លាស់ប្តូរព័ត៌មានជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីជួយឲ្យឱ្យការវាយតម្លៃនេះមានលក្ខណៈប្រសើរឡើង

- ការវិភាគផ្នែកច្បាប់នូវសេចក្តីព្រាងច្បាប់នានា និងផ្តល់យោបល់លើអនុលោមភាពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ
- ការគាំទ្រ ការផ្តល់យោបល់ និងការបណ្តុះបណ្តាល ដើម្បីជួយរដ្ឋាភិបាលក្នុងការធ្វើរបាយការណ៍ទៅអង្គភាពត្រួតពិនិត្យសន្ធិសញ្ញាអន្តរជាតិ និងដើម្បីជំរុញឱ្យអនុវត្ត អនុសាសន៍របស់អង្គភាពទាំងនោះ
- ការបណ្តុះបណ្តាល និងការណែនាំស្តីពីបញ្ហាសិទ្ធិមនុស្ស ច្បាប់ជាតិ និងការប្រើប្រាស់យន្តការសិទ្ធិមនុស្សអន្តរជាតិ
- កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីការពារបុគ្គល ឬក្រុមជាក់លាក់ដែលសិទ្ធិរបស់ពួកគេកំពុងស្ថិតនៅក្រោមការគំរាមកំហែង
- ការផ្តល់ជំនួយក្នុងទ្រង់ទ្រាយតូចដល់តួអង្គសង្គមស៊ីវិល និងសហគមន៍ដើម្បីជួយពួកគេដោះស្រាយបញ្ហាសិទ្ធិមនុស្ស[18]។

## ៣.២.២. ស្ថានភាព និងការអនុវត្តជាក់ស្តែងនៃសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា

យើងសង្កេតឃើញថា បញ្ហាសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាហាក់បីដូចមានការប្រែប្រួលជាច្រើនដំណាក់កាលទៅតាមទិដ្ឋភាពជាក់ស្តែងនៅក្នុងសង្គម។ ក្នុងការប្រែប្រួលនៃសិទ្ធិមនុស្សនេះផងដែរ សុទ្ធសឹងតែមានការផ្លាស់ប្តូរក្រោមរូបភាពជាច្រើន ទាំងចំណុចល្អ និងចំណុចអាក្រក់។

ចំណុចខាងក្រោមនេះ គឺជាស្ថានភាព និងការអនុវត្តជាក់ស្តែងសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាដោយរាប់ចាប់ពីឆ្នាំ ២០១៧ ដល់ ឆ្នាំ២០២០[19]៖

### ៣.២.២.១. ស្ថានភាពសិទ្ធិមនុស្សក្នុងឆ្នាំ២០១៧

អំឡុងឆ្នាំ២០១៧ យើងឃើញថាកម្ពុជា មានការរិតត្បិតផ្នែកសិទ្ធិមនុស្សទាក់ទងទៅនឹង ការបំបិទលំហសង្គមស៊ីវិល ការបង្ក្រាបធ្ងន់ធ្ងរលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ការរីករាលដាលនៃការដាក់កំហិតសិទ្ធិខ្លួនឯងតាមប្រព័ន្ធអ៊ីនធឺណិត ការរិតត្បិតខ្លាំងលើសេរីភាពខាងសមាគម ការរារាំងសេរីភាពខាងការជួបប្រជុំ ការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ទំនាស់ដីធ្លីនៅតែមិនទាន់ត្រូវបានដោះស្រាយឱ្យបានទូលំទូលាយ ការគាបសង្កត់លើសិទ្ធិរបស់កម្មករ ការអភិវឌ្ឍបានបន្តធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅតែពុំត្រូវបានការពារ[20]។

---

[18] https://cambodia.ohchr.org/kh/about-us/who-we-are (ចូលទស្សនាថ្ងៃទី ០៨ សីហា ២០២១)

[19] https://cchrcambodia.org/ (ចូលទស្សនថ្ងៃទី ០៨ សីហា ២០២១)

[20] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៧

**ក. ការបំបិទលំហសង្គមស៊ីវិល**

សេរីភាពខាងការបញ្ចេញមតិត្រូវបានរឹតត្បិត ដោយរដ្ឋាភិបាលបង្ក្រាបលើការរិះគន់នានាមកលើខ្លួន ដែលបានធ្វើឱ្យមានការធ្លាក់ចុះជាខ្លាំងនូវសេរីភាពខាងការបញ្ចេញមតិ។ យោងតាមគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ការរឹតត្បិតលើសេរីភាពបញ្ចេញមតិអាចធ្វើទៅបានលុះត្រាតែស្ថិតនៅក្រោមកាលៈទេសៈកំណត់ណាមួយរួមមាន ការការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬកេរ្តិ៍ឈ្មោះអ្នកដទៃ។ ប៉ុន្តែ ច្បាប់ដែលមានលក្ខណៈរឹតត្បិតបច្ចុប្បន្ន កំពុងគ្រប់គ្រងលើសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជាយ៉ាងខ្លាំង ដែលមិនស្របទៅតាមការអនុវត្តជាសកល[21]។

**ខ. ការបង្ក្រាបធ្ងន់ធ្ងរលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន**

សេរីភាពផ្នែកខាងសារព័ត៌មានត្រូវបានធ្លាក់ចុះ ដោយសារតែមានការបិទសិទ្ធិសេរីភាពសារព័ត៌មានក្នុងការចុះផ្សាយនៃនិន្នាការនយោបាយផ្សេងៗ ដែលរដ្ឋាភិបាលមិនអនុញ្ញាតិ ហើយថែមទាំងបិទស្ថានីយវិទ្យុក្នុងស្រុកចំនួន១៥ នាខែសីហា ដោយផ្អែកលើមូលដ្ឋានរដ្ឋបាលមិនច្បាស់លាស់។ ទង្វើរទាំងនេះ បានសបញ្ជាក់យ៉ាងច្បាស់នូវការរឹតត្បិតដែលកាន់តែខ្លាំងឡើងទៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកសារព័ត៌មានមិនអាចរាយការណ៍ព័ត៌មានដែលពួកគេបានជួបប្រទះបណ្តាលឱ្យប៉ះពាល់ថែមទៀតទៅលើសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា[22]។

**គ. ការរីករាលដាលនៃការដាក់កំហិតសិទ្ធិខ្លួនឯងតាមប្រព័ន្ធអ៊ីនធឺណិត**

កាលដំបូងឡើយ អ៊ីនធឺណិតត្រូវបានគេចាត់ទុកថាមានលំហសេរីភាពខ្លាំងជាងសារព័ត៌មានបោះពុម្ពផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយនានា។ ប៉ុន្តែកាន់តែលំបាកខ្លាំងឡើងៗ សម្រាប់ប្រជាពលរដ្ឋកម្ពុជាក្នុងការបញ្ចេញមតិរបស់ខ្លួន ដោយសេរីនៅលើប្រព័ន្ធអ៊ីនធឺណិត ដោយពុំមានការព្រួយបារម្ភពីទោសព្រហ្មទណ្ឌ។ បន្ទាប់មក និន្នាការនៃការកើនឡើងនៃការដាក់កំហិតសិទ្ធិខ្លួនឯង និងការតាមដានទៅលើប្រព័ន្ធអ៊ីនធឺណិតមានការកើនឡើង ដោយសារតែមានការបញ្ចេញមតិផ្ទាល់ខ្លួនរិះគន់ទៅរដ្ឋាភិបាល តាមគ្រប់រូបភាពនៅលើប្រព័ន្ធអ៊ីនធឺណិតអំពីការអនុវត្តផែនការរបស់រដ្ឋាភិបាល ដូចនេះរាល់ការបញ្ចេញមតិពីគ្រប់មជ្ឈដ្ឋាននៅលើប្រព័ន្ធអ៊ីនធឺណិត ត្រូវបានត្រួតពិនិត្យពីសំណាក់រដ្ឋាភិបាល ដែលអំណាចនេះទទួលបានពីច្បាប់ស្តីពីទូរគមនាគមន៍ឆ្នាំ២០១៦។ ដូចនេះ រដ្ឋាភិបាលអាចធ្វើការត្រួតពិនិត្យ និងដាក់ទោសព្រហ្មទណ្ឌលើទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិចដែលចាត់ទុកថាបង្កអសន្តិសុខ លើសពីនេះ រដ្ឋាភិបាលបានចេញសេចក្តី

[21] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៧

[22] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៧

ប្រកាសជាច្រើនលើកអំពីផែនការ ការប្រើប្រាស់នគរបាលដើម្បីពង្រីកការត្រួតពិនិត្យបន្ថែមទៀតលើមាតិកាដែលបង្ហោះនៅលើបណ្តាញអ៊ីនធឺណិត[23]។

**ឃ. ការរារាំងសេរីភាពខាងការជួបប្រជុំ**

ក្នុងឆ្នាំ២០១៧ សេរីភាពខាងផ្នែកជួបប្រជុំមានការរឹតត្បិតខ្លាំង ទោះបីជាមានចែងក្នុងច្បាប់កម្ពុជាក្តី ក៏សេរីភាពមូលដ្ឋាននេះនៅតែរងការរឹតត្បិតដោយគ្មានមូលដ្ឋាន រហូតពេលខ្លះឈានដល់អំពើហិង្សា។ ជាក់ស្តែងយើងឃើញមានការបង្ក្រាបទៅលើក្រុមអ្នកតវ៉ា ដោយកម្លាំងនគរបាល និងកងសន្តិសុខខណ្ឌ ដែលខណៈពួកគាត់បានចូលរួមប្រមូលផ្តុំដោយអហិង្សាក្នុងការតវ៉ារឿងអយុត្តិធម៌ ការអនុវត្តនេះស្តែងឱ្យឃើញពីការរំលោភលើច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីដែលចែងថាបុគ្គលដែលរៀបចំការជួបប្រជុំនៅទីសាធារណៈត្រូវជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានជាមុនសិន ពោលគឺពុំតម្រូវឱ្យស្នើសុំការអនុញ្ញាតជាមុននោះឡើយ[24]។

**ង. ការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌**

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅតែពុំទទួលបានការការពារឱ្យបានពេញលេញនៅឡើយនៅកម្ពុជា ការចាប់ខ្លួនជារឿយៗធ្វើឡើងតាមសំណើររបស់អ្នកនយោបាយដែលមានឥទ្ធិពល។ នៅពេលដែលបុគ្គលជាប់ពាក់ព័ន្ធរឿងក្តីនៅក្នុងប្រព័ន្ធយុត្តិធម៌ ជារឿយៗខ្វះការអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ពេលជំនុំជម្រះ ដោយមានការធ្វេសប្រហែស និងមិនអើពើលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយនិងនីតិវិធីមូលដ្ឋានមួយចំនួនរបស់តុលាការ។ សិទ្ធិមានវត្តមានក្នុងពេលជំនុំជម្រះ និងសិទ្ធិទទួលបានមេធាវីពុំត្រូវបានគោរពឱ្យបានខ្ជាប់ខ្ជួនឡើយ ហើយសិទ្ធិបង្ហាញភ័ស្តុតាងជារឿយៗត្រូវបានអនុវត្តក្នុងលក្ខខណ្ឌរឹតត្បិត។ បន្ថែមលើនេះ ភាគច្រើននៃសំណុំរឿងឧទ្ធរណ៍ សាលាឧទ្ធរណ៍គ្រាន់តែប្រកាសតម្កល់ សេចក្តីសម្រេចរបស់សាលាដំបូង ឬបញ្ជូនឱ្យជំនុំជម្រះក្តីសារជាថ្មីដោយពុំបានផ្តល់នូវហេតុផលឡើយ។ ជាចុងក្រោយ សិទ្ធិរបស់ចុងចោទ ដែលជាអនីតិជនដែលទទួលបានការការពារពិសេសក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជា ជារឿងៗពុំទទួលបានការគោរពពេញលេញឡើយ[25]។

**ច. សិទ្ធិសង្គម និងសេដ្ឋកិច្ច**

នៅកម្ពុជា សិទ្ធិដីធ្លីនៅពុំទាន់ត្រូវបានការពារពេញលេញនៅឡើយ ដែលជាហេតុនាំឱ្យមានទំនាស់ដីធ្លី។ ទោះជារដ្ឋាភិបាលកម្ពុជា បានខិតខំពិនិត្យមើលសម្បទានដីសេដ្ឋកិច្ចយ៉ាងណាក៏ដោយ ក៏ការរំលោភសិទ្ធិដីធ្លីនិងការបណ្តេញចេញដោយបង្ខំបានបន្តកើតឡើងនាពេលកន្លងមក។ ខណៈចំនួននៃករណីទំនាស់ដីធ្លី និង

[23] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៧

[24] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៧

[25] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៧

ការតវ៉ាបានធ្លាក់ចុះក្នុងឆ្នាំ២០១៧ ករណីទំនាស់ដីធ្លីជាច្រើននៅពុំទាន់ត្រូវបានដោះស្រាយ ដែលបន្សល់ទុកប្រជាពលរដ្ឋជាច្រើនគ្រួសារ គ្មានផ្ទះសម្បែង ឬរបរចិញ្ចឹមជីវិត។

ក្រឡេកមកមើល សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាវិញ ទោះបីជាច្បាប់កម្ពុជាមិនបានចែងពីការហាមប្រាម ឬការរើសអើងជាក់លាក់ណាមួយលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក្តី ក៏ពួកគេត្រូវជំនះនឹងការរឹតត្បឹតផ្នែកច្បាប់ដែលរារាំងពួកគេពីការទទួលបានសិទ្ធិពេញលេញរបស់ខ្លួនដែរ។ ឧទាហរណ៍ មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញចែងថាអាពាហ៍ពិពាហ៍ធ្វើឡើងតាមគោលការណ៍ស្ម័គ្រចិត្ត "ប្តីមួយប្រព័ន្ធមួយ" ដែលនេះជាការហាមប្រាមយ៉ាងច្បាស់ចំពោះអ្នកស្រឡាញ់ភេទដូចគ្នាពីការទទួលបានសិទ្ធិរៀបអាពាហ៍ពិពាហ៍ ដែលជារឿយៗពួកគេពុំមានលក្ខណៈស្របតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់នេះនោះទេ[26]។

**ឆ. សិទ្ធិរបស់កម្មករ**

ចាប់តាំងពីការអនុម័តវិសោធនកម្មច្បាប់ស្តីពីសហជីពឆ្នាំ២០១៦ ដែលរឹតត្បិតសិទ្ធិក្នុងការធ្វើកូដកម្ម ធ្វើឱ្យសហជីពត្រូវបានប្រឈមមុខនឹងបញ្ហា។ ការណ៍នេះ ជារឿយៗនាំទៅរកការតវ៉ារបស់កម្មករនិយោជិតដើម្បីទាមទារលក្ខខណ្ឌការងារល្អប្រសើរដូចជា ថ្ងៃឈប់សម្រាកបន្ថែម និងបញ្ឈប់ការកាត់ប្រាក់ឈ្នួលនៅថ្ងៃសុំច្បាប់ពេលមានជម្ងឺជាដើម។ សិទ្ធិសេរីភាពខាងការជួបប្រជុំរបស់កម្មករត្រូវបានរំលោភ ព្រោះការតវ៉ានានារបស់ពួកគាត់ត្រូវបានរារាំង ហើយអ្នកចូលរួមព្រមទាំងអ្នករៀបចំនឹងត្រូវប្រឈមការយាយី ឬព្យួរការងារដោយសារការចូលរួមរបស់ពួកគាត់[27]។

**៣.២.២.២. ស្ថានភាពសិទ្ធិមនុស្សក្នុងឆ្នាំ ២០១៨**

នៅឆ្នាំ ២០១៨ ស្ថានភាពសិទ្ធិមនុស្សបានធ្លាក់ដុនដាបខ្លាំងនៅកម្ពុជា នៅមុនការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ មានការអនុម័តច្បាប់មួយចំនួនដែលមានលក្ខណៈរឹតត្បិតក្នុងគោលបំណងបំបិទសំឡេងជំទាស់។ ការជំនុំជម្រះ និងការកាត់ទោសតក់ក្រហល់ទៅលើបុគ្គលដែលរិះគន់រដ្ឋាភិបាល ព្រមទាំងបរិយាកាសអាប់អួនៅជុំវិញការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បាននាំឱ្យការចូលរួមរបស់សាធារណជនក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យមានការធ្លាក់ចុះ។ រយៈពេលនេះ ត្រូវបានកត់សំគាល់ឃើញមានភាពតានតឹងផ្នែកនយោបាយដែលកំពុងតែមាន និងការកាត់បន្ថយបន្ថែមទៀតនូវបរិយាកាសនយោបាយ និងលំហសិទ្ធិពលរដ្ឋ រួមទាំងការបិទ និងការព្យួរសកម្មភាពសិទ្ធិមនុស្ស និងអង្គការមិនមែនរដ្ឋាភិបាល និងអង្គ-

[26] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៧

[27] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៧

ការខាងប្រព័ន្ធផ្សព្វផ្សាយ និងការទាមទារតំឡើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករបម្រើការក្នុងវិស័យឧស្សាហកម្ម វាយនភណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង[28]។

**ក. សេរីភាពខាងបញ្ចេញមតិ**

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើវិសោធនកម្ម ដើម្បីបញ្ចូលមាត្រា៤៣៧ ស្ទួន ស្ដីអំពី "ការប្រមាថព្រះមហាក្សត្រ"។ បទបញ្ញត្តិនេះ គឺសំដៅលើការប្រមាថលើអង្គព្រះមហាក្សត្រ ហាមប្រាមការបរិហារ ជេរប្រមាថ ឬការគំរាមកំហែងព្រះមហាក្សត្រតាមរូបភាពណាមួយ ដូចជាតាមរយៈ វិចារ កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់ព្រះកិត្តិនាមរបស់អង្គព្រះមហាក្សត្រ។ បញ្ញត្តិស្ដីពីការប្រមាថព្រះមហាក្សត្រនេះ ត្រូវបានអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិរិះគន់ជាច្រើន ទោះបីជាសេរីភាពខាងការបញ្ចេញមតិត្រូវតែស្របគ្នាជាមួយការការពារសិទ្ធិ និងកិត្តិយសរបស់បុគ្គលដទៃក្តី បញ្ញត្តិទាក់ទងនឹងការប្រមាថព្រះមហាក្សត្រនេះ រឹតបន្តឹងយ៉ាងខ្លាំងលើសេរីភាពខាងបញ្ចេញមតិ[29]។

**ខ. ការបំបិទបណ្ដាញផ្សព្វផ្សាយព័ត៌មានឯករាជ្យ**

ខណៈមានការបិទបណ្ដាញព័ត៌មានឯករាជ្យទ្រង់ទ្រាយធំក្នុងឆ្នាំ ២០១៧ ការបង្ក្រាបទៅលើអ្នកសារព័ត៌មានក៏បន្តកើតឡើងនៅក្នុងឆ្នាំ ២០១៨ ផងដែរ។ នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានចេញផ្សាយក្រមសីលធម៌សម្រាប់អ្នកសារព័ត៌មានដែលបានអំពាវនាវឱ្យអ្នកសារព័ត៌មាន ប្រកាន់គោលជំហរចេញផ្សាយព័ត៌មាន ប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ និងតម្លាភាពក្នុងអំឡុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។ ខ្លឹមសារនៃក្រមសីលធម៌នោះ មានគោលបំណងហាមប្រាមអ្នកសារព័ត៌មានរាយការណ៍ព័ត៌មានដែលនាំទៅរកការបាត់ទំនុកចិត្តលើការបោះឆ្នោត។

តាមរយៈរបាយការណ៍ស្តីពីសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០១៨ ប្រទេសកម្ពុជាបានធ្លាក់ចុះ ១០ថ្នាក់ ទាបជាងឆ្នាំ ២០១៧ ដែលស្ថិតក្នុងលេខរៀងទី ១៤២ ក្នុងចំណោមប្រទេសដែលត្រូវបានវាយតម្លៃចំនួន ១៨០[30]។

**គ. ការកើនឡើងនូវការចាប់ពិរុទ្ធលើបណ្ដាញអ៊ីនធឺណិត**

និន្នាការសំខាន់មួយនៅក្នុងឆ្នាំ២០១៨ គឺការបន្តកើនឡើងនូវការត្រួតពិនិត្យលើបណ្ដាញអ៊ីនធឺណិត។ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ក្រសួងចំនួន៣ បានចេញប្រកាសអន្តរក្រសួងស្ដីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា។

---

[28] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៨

[29] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៨

[30] https://rsf.org/en/ranking (ចូលទស្សនានៅថ្ងៃទី ០៨ សីហា ២០២១)

ប្រកាសនេះ ផ្តល់អំណាចដល់រដ្ឋាភិបាលយ៉ាងទូលំទូលាយ និងមិនច្បាស់លាស់ដែលផុតពីដែនកំណត់ដែលច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុញ្ញាត។ តាមរយៈការបង្កើតអង្គភាពពិសេសមួយ រដ្ឋាភិបាលនឹងអាចប្រឆាំង ទប់ស្កាត់ នូវការផ្សព្វផ្សាយនានា ដែលមានចេតនាបង្កជាចលាចលបណ្តាលឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ ប្រពៃណីជាតិ[31]។

**ឃ. សេរីភាពខាងការជួបប្រជុំ**

មុនការបោះឆ្នោតក្នុងខែកក្កដា ឆ្នាំ២០១៨ សេរីភាពខាងការជួបប្រជុំបន្តរងការប៉ះពាល់។ ការធ្វើបាតុកម្មដោយសន្តិវិធី ជារឿយៗត្រូវបានអាជ្ញាធរបំបែក ហើយពេលខ្លះឈានដល់ការប្រើអំពើហិង្សា[32]។

**ង. ការយាយីចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌**

ការប្រើប្រាស់ប្រព័ន្ធតុលាការ ដើម្បីបង្ក្រាបទៅលើបុគ្គលដែលសម្តែងការមិនពេញចិត្តរបស់ពួកគេចំពោះរដ្ឋាភិបាលនៅតែកើតមានឡើងជាច្រើន។ អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន មេដឹកនាំសហជីព តំណាងសហគមន៍ និងបុគ្គលផ្សេងទៀតដែលអនុវត្តសេរីភាពជាមូលដ្ឋានរបស់ខ្លួន ជារឿយៗប្រឈមនឹងការយាយីផ្នែកតុលាការ។ សន្ទស្សន៍នីតិរដ្ឋឆ្នាំ២០១៧-២០១៨ នៃគម្រោងយុត្តិធម៌ពិភពលោក ដែលវាយតម្លៃពីការប្រតិបត្តិនូវនីតិរដ្ឋសម្រាប់ប្រទេសនៅទូទាំងពិភពលោក បានផ្តល់ចំណាត់ថ្នាក់ដល់កម្ពុជាក្នុងលេខរៀងទី១១២ ក្នុងចំណោមប្រទេសចំនួន១១៣ តួលេខនេះបានសបញ្ជាក់យ៉ាងច្បាស់អំពីភាពទាន់ខ្សោយនៃវិស័យជំនុំជម្រះនៅកម្ពុជា[33]។

**ច. សិទ្ធិសង្គមកិច្ច វប្បធម៌ និងសេដ្ឋកិច្ច**

ការចាប់យកដីធ្លីខុសច្បាប់ និងការបណ្តេញចេញដោយបង្ខំនៅតែបន្តកើតមានឡើង ដែលនេះជាករណីរំលោភសិទ្ធិមនុស្សដ៏រាលដាលមួយក្នុងចំណោមករណីរំលោភសិទ្ធិមនុស្សផ្សេងទៀតនៅកម្ពុជា។ នៅចន្លោះខែមេសា ឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨ មានការប៉ាន់ប្រមាណថា៣៣% នៃករណីទំនាស់ដីធ្លីនៅកម្ពុជា

---

[31] ប្រកាសអន្តរក្រសួងស្តីពី ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី២៥ ឧសភា ២០១៨។

[32] របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០១៨។

[33] https://worldjusticeproject.org/sites/default/files/documents/WJP_ROLI_2017-18_Online-Edition_0.pdf (សន្ទស្សន៍នីតិរដ្ឋឆ្នាំ២០១៧-២០១៨ នៃគម្រោងយុត្តិធម៌ពិភពលោក, បានចូលទស្សនានៅថ្ងៃទី១០ សីហា ២០២១)

បាននាំឱ្យមានការរំលោភបំពានទៅលើសេរីភាពមូលដ្ឋានរួមទាំងវិធានការច្បាប់ និងការឃុំខ្លួនតាមអំពើចិត្ត[34] ។ គិតត្រឹមខែសីហា ឆ្នាំ២០១៨ ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ បានទទួលពាក្យបណ្តឹង ចំនួន១,១៣១ ទាក់ទងនឹងទំនាស់ដីធ្លី។ យោងតាមតួលេខក្រសួង ក្នុងចំណោមពាក្យបណ្តឹងទាំងនោះ ៣,៩៦០ករណី ត្រូវបានដោះស្រាយ ២,៨៥៤ពាក្យបណ្តឹង ត្រូវបានច្រានចោល ៨៥៨ពាក្យបណ្តឹង ត្រូវបាន ដកទៅវិញ ១,៤៥៩ពាក្យបណ្តឹង ដែលកំពុងដំណើរការដែលជិតទទួលបានដំណោះស្រាយ[35]។

**ឆ. សិទ្ធិកម្មករ**

នៅក្នុងខែមិថុនា ឆ្នាំ២០១៨ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ក្នុងគោលបំណងធ្វើឱ្យ ប្រសើរដល់ជីវភាពរស់នៅរបស់កម្មករនិយោជិត និងធ្វើឱ្យបរិយាកាសធុរកិច្ច និងវិនិយោគមានភាពទាក់ទាញ បន្ថែមទៀត។ ទោះបីមានការបង្កើតច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់អនុវត្តនៅទូទាំងប្រទេសសម្រាប់ កម្មករនិយោជិតដែលជាការវិវឌ្ឍវិជ្ជមានក្តី ច្បាប់នេះខកខានគោរពតាមបទដ្ឋានអន្តរជាតិ។ វិសាលភាពនៃ ច្បាប់នេះនៅតែពុំទាន់គ្រប់គ្រាន់នៅឡើយ ព្រោះច្បាប់នេះអនុវត្តតែលើ សហគ្រាស ឬស្ថាប័ន និងបុគ្គលដែល ស្ថិតនៅក្រោមច្បាប់ការងារ ដែលពុំបានរាប់បញ្ចូលកម្មករនិយោជិតក្នុងវិស័យផ្សេងទៀត។ ម៉្យាងទៀតនិយម ន័យនៃ ប្រាក់ឈ្នួលអប្បបរមា ដែលច្បាប់នេះបានចែង ពុំបានពិចារណាដល់អនុសាសន៍របស់ អង្គការពល កម្មអន្តរជាតិឡើយ។ ខ្លឹមសារដែលមិនច្បាស់លាស់នៃបទប្បញ្ញត្តិទាំងនេះអាចនាំឱ្យមានការអនុវត្តប្រាក់ ឈ្នួលអប្បបរមាតាមអំពើចិត្តចំពោះកម្មករនិយោជិតក្នុងវិស័យផ្សេងទៀត។ ម៉្យាងទៀតរដ្ឋាភិបាល កម្ពុជាពុំ ទាន់បានបង្ហាញអំពីរបៀបនៃការកំណត់ប្រាក់ឈ្នួលអប្បបរមា ដែលមានការប្រែប្រួលតាំងពីនៅគណៈកម្ម ការប្រឹក្សាការងារបច្ចុប្បន្នរហូតដល់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដែលទើបតែបង្កើតឡើងនោះទេ។ តែយ៉ាងណាក្តី រដ្ឋាភិបាលបានធ្វើឱ្យប្រសើរលើចំណុចមួយចំនួនទាក់ទងនឹងសិទ្ធិកម្មករកាត់ដេរ ក្នុងនោះរួម ទាំងប្រព័ន្ធសុខុមាលភាពសង្គម[36]។

[34] របាយការណ៍ប្រចាំឆ្នាំទីពីរនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន, (សមាគមអាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព, ចុះថ្ងៃទី១៩ កញ្ញា ២០១៨, ៣០-៣១)។

[35] https://vodkhmer.news/2018/10/25/over-1000-cases-of-land-disputes-unsolved/
(ចូលទស្សនាថ្ងៃទី ១០ សីហា ២០២១)។

[36] របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តម ស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០១៨។

### ២.២.២.៣. ស្ថានភាពសិទ្ធិមនុស្សក្នុងឆ្នាំ ២០១៩

នៅក្នុងអំឡុងឆ្នាំ២០១៩ យើងបានកត់សម្គាល់ឃើញមានភាពតានតឹងផ្នែកនយោបាយបន្តមាននៅក្នុងបរិបទនៃការបោះឆ្នោតជាតិ ដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៨ រួមទាំងការរឹតត្បិតលើការអនុវត្តសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ បញ្ហាផ្នែកសិទ្ធិមនុស្សសំខាន់ៗរួមមានការធ្វើទារុណកម្មដោយរដ្ឋាភិបាល ការឃុំខ្លួនតាមអំពើចិត្តដោយរដ្ឋាភិបាល ការជ្រៀតជ្រែកតាមអំពើចិត្តនៅក្នុងជីវិតឯកជនរបស់ពលរដ្ឋ រួមទាំងការលួចស្តាប់តាមប្រព័ន្ធអេឡិចត្រូនិចជាទូទៅ ការជ្រៀតជ្រែកនៅក្នុងសិទ្ធិធ្វើការប្រមូលផ្តុំដោយសន្តិភាព និងសេរីភាពក្នុងការចងក្រងគ្នាជាក្រុម សមាគម។ ទន្ទឹមនឹងនេះ ក៏ឃើញមានការវិវឌ្ឍន៍វិជ្ជមានផងដែរ រួមទាំងការអនុម័តក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា និងកំណើនសេដ្ឋកិច្ច រួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច[37]។

#### ក. សិទ្ធិសេរីភាពខាងការជួបប្រជុំ

ការិយាល័យ OHCHR បានបន្តឃ្លាំមើលការប្រមូលផ្តុំគ្នាជាសាធារណៈ ដែលការប្រមូលផ្តុំគ្នាជាច្រើនត្រូវបានធ្វើឡើងទាក់ទងនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ធ្វើឱ្យមានកង្វល់ទាក់ទងនឹងសិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការជួបប្រជុំ ដោយសារការរារាំងពីសំណាក់អាជ្ញាធរពាក់ព័ន្ធ។ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៩ រដ្ឋាភិបាលមិនបានអនុញ្ញាតឱ្យមានការដង្ហែរក្បួនទាក់ទងនឹងសំណើរសុំជួបប្រជុំដោយសន្តិវិធី ដើម្បីប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិឡើយ ដូច្នេះវាគឺជាការបំបិតសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីទាំងស្រុង។

#### ខ. សិទ្ធិសង្គមកិច្ច វប្បធម៌ និងសេដ្ឋកិច្ច

សម្រាប់សិទ្ធិសង្គម វប្បធម៌ និងសេដ្ឋកិច្ច កម្ពុជាទទួលបានការរីកចម្រើនខ្លះដែល ប៉ុន្តែនៅមានបញ្ហាមួយចំនួនទៀតដែលគួរមានការកែលម្អ ដូចជាបញ្ហាដីធ្លីជាដើម។ យើងដឹងហើយថា បញ្ហាដីធ្លី តែងតែមានការទាមទារពីសំណាក់ប្រជាពលរដ្ឋកម្ពុជាជារឿយៗ ដែលរដ្ឋាភិបាលមិនទាន់ឆ្លើយតបបាន។

ច្បាប់ហាមប្រាមការរើសអើង ការព្រងើយកន្តើយ ការកេងប្រវ័ញ្ច ឬការបោះបង់ជនពិការ ទាំងពិការរាងកាយ ទាំងពិការផ្នែកសតិបញ្ញា ប៉ុន្តែយើងនៅជួបប្រទះការរើសអើងជាច្រើនពីសង្គម ជាពិសេសក្នុងការទទួលការងារជំនាញ។ ជនពិការ ត្រូវបានគាំពាដោយរដ្ឋាភិបាល ក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ជាពិសេសការបណ្តុះបណ្តាល ហើយពុំមានច្បាប់ណាមួយដែលកម្រិតពីសិទ្ធិរបស់ជនពិការឡើយ។

[37] ស្ថានទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា, របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០១៩

សិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមក្នុងកិច្ចការនានារបស់ពលរដ្ឋត្រូវបានលើកស្ទួយ ប៉ុន្តែរដ្ឋាភិបាលមិនបានចូលរួមខិតខំប្រឹងប្រែង ដើម្បីជួយដល់ជនពិការឱ្យចូលរួមកាន់តែច្រើនក្នុងនាមជាពលរដ្ឋឡើយ[38]។

**គ. សិទ្ធិកម្មករ**

ច្បាប់អនុញ្ញាតកម្មករផ្នែកឯកជន បង្កើត និងចូលរួមសហជីព តាមការជ្រើសរើសរបស់ខ្លួនគេផ្ទាល់ សិទ្ធិក្នុងការធ្វើកូដកម្ម និងសិទ្ធិក្នុងការចរចាអនុសញ្ញារួម ប៉ុន្តែច្បាប់នេះមានភាពស្មុគស្មាញ និងមានការរឹតត្បិតក្នុងការអនុវត្តដល់កម្មករ ។

កម្មករនៅតែជួបឧបសគ្គនានា នៅក្នុងការអនុវត្តសិទ្ធិរបស់គេ ក្នុងការចូលរួមក្នុងសមាគមដោយសេរីដោយមានការរារាំងពីអាជ្ញាធរមូលដ្ឋាន។

ការរើសអើងទាក់ទងនឹងការងារនៅតែបន្តមាន ដោយច្បាប់ហាមការរើសអើងក្នុងការងារ ដោយសារពូជសាសន៍ ពណ៌សម្បុរ ភេទ ពិការភាព សាសនានា គំនិតនយោបាយ កំណើត ប្រភពដើមក្នុងសង្គម ឬសមាជិកក្នុងសហជីពទេ។ ប៉ុន្តែច្បាប់មិនបានហាមឱ្យបានច្បាស់នូវការរើសអើងដោយផ្អែកលើចំណង់ផ្លូវភេទ អត្តសណ្ឋាណជេនឌ័រ អាយុ ភាសា ឬជម្ងឺឆ្លងទេ ដូច្នេះវាជាមូលហេតុ នៃការរាំងស្ទះនូវសិទ្ធិកម្មករ។

**ឃ. សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**

នៅឆ្នាំ ២០១៩ ទាក់ទងទៅនឹងបញ្ហាសិទ្ធបញ្ចេញមតិ សិទ្ធិជួបប្រជុំ នៅតែមានការរិតត្បិតនៅកម្ពុជានៅឡើយ ដោយសារមានការចាប់ខ្លួនដោយគ្មានមូលហេតុច្បាស់លាស់ ក្នុងការបញ្ចេញមតិជាសាធារណៈ។

រដ្ឋធម្មនុញ្ញ ផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការជ្រើសរើសរដ្ឋាភិបាលរបស់ខ្លួន តាមរយៈការបោះឆ្នោតជាទៀងទាត់ដោយសេរី និងយុត្តធម៌ ដោយផ្អែកលើសិទ្ធិបោះឆ្នោតជាសកល និងស្មើភាព។ តែតាមច្បាប់រដ្ឋាភិបាលអាចរំលាយគណបក្សនយោបាយ និងហាមបុគ្គលមិនឱ្យកាន់មុខតំណែងដឹកនាំក្នុងគណបក្ស និងមានជីវិតនយោបាយ នេះជាការរឹតត្បិតក្នុងសិទ្ធិពលរដ្ឋ និងនយោបាយ។

**២.២.២.៤. ស្ថានភាពសិទ្ធិមនុស្សក្នុងឆ្នាំ ២០២០**

ក្នុងឆ្នាំ២០២០នេះ ស្ថានភាពសិទ្ធិមនុស្សមានការរួមតូចនៃលំហពលរដ្ឋ និងភាពតានតឹងផ្នែកនយោបាយនៅតែបន្តមាន។ ការិយាល័យ OHCHR បានបន្តផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងវិស័យសំខាន់ៗមួយចំនួន រួមមានការពង្រឹងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ និងការពារសេរីភាពជាមូលដ្ឋាន និងសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌។ ការិយាល័យ ក៏បានលើកឡើងផងដែរអំពីផលប៉ះពាល់ខាងសិទ្ធិមនុស្ស ដោយសារការរាតត្បាតនៃជម្ងឺកូរ៉ូណាថ្មី (ជម្ងឺកូវីដ-១៩)[39]។

[38] ស្ថានទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា, របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០១៩

[39] ស្ថានទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា, របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ ២០២០

នៅក្នុងបរិបទនេះ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងស្ថានភាពអាសន្ន បានចូលជាធរមាន ដោយបានធ្វើឡើងឆ្លើយតបទៅនឹងជម្ងឺកូវីដ-១៩ ដោយគ្មានការពិគ្រោះយោបល់ជាសាធារណៈ សេចក្តីព្រាងច្បាប់ផ្តល់អំណាចដល់រដ្ឋាភិបាលក្នុងការប្រកាសភាពអាសន្នដល់ទៅបី (៣)ខែ ដែលអាចពន្យាពេលបី(៣)ខែទៀត ដោយមិនចាំបាច់ពិនិត្យឡើងវិញ។ សេចក្តីព្រាងច្បាប់នេះ អនុញ្ញាតផងដែរ ឱ្យដាក់រឹតត្បិតលើសិទ្ធិសេរីភាព ក្នុងការដើរហើរ និងការជួបជុំ សិទ្ធិទទួលបានព័ត៌មាន សិទ្ធិឯកជន និងសិទ្ធិការងារក្នុងចំណោមសិទ្ធិដទៃទៀត [40] ។ ប៉ុន្តែសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុញ្ញាតិដោយស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំការិយាល័យអង្គការសហប្រជាជាតិ ដោយបញ្ជាក់ថាច្បាប់នេះ ត្រូវបានអនុញ្ញាតិដោយឧបករណ៍សិទ្ធិមនុស្សជាតិ និងអន្តរជាតិ ដែលហៅថារដ្ឋធម្មនុញ្ញ។ ក្នុងការដាក់ច្បាប់ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងស្ថានភាពអាសន្នបចូលជាធរមាន ធ្វើឱ្យមានកង្វល់ជាច្រើនពីអ្នកកាន់អាណត្តិនីតិវិធីពិសេសមួយចំនួនដោយលើកឡើងថា ច្បាប់នេះអាចប្រឈមនឹងហានិភ័យនៃ ការរំលោភសិទ្ធិឯកជន ការបំបិទសេរីភាពបញ្ចេញមតិ និងដាក់ទោសព្រហ្មទណ្ឌដល់ការជួបប្រជុំដោយសន្តិវិធី។

**ក. សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ**

ការិយាល័យ (OHCHR) បានទទួលនូវរបាយការណ៍អំពីការរឹតត្បិតហួសហេតុលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធីនៅក្នុងបរិបទជម្ងឺកូវីដ-១៩។ ការិយាល័យ បានចងក្រងឯកសារទាក់ទងនឹងការចាប់ខ្លួនបុគ្គលមួយចំនួនដោយសារតែការអត្ថាធិប្បាយជាសាធារណៈ និងការបង្ហោះលើបណ្តាញសង្គមទាក់ទងនឹងជម្ងឺកូវីដ-១៩ ដែលក្នុងនោះ យ៉ាងហោចណាស់ក៏មានមនុស្ស១៤ នាក់ដែរ ដែលត្រូវបានចោទប្រកានពីបទល្មើសនេះ រួមទាំងការផ្សាយព័ត៌មានក្លែងក្លាយ ឬព័ត៌មានមិនពិត ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ និងការធ្វើផែនការប្រឆាំងនឹងរដ្ឋាភិបាល។[41]

**ខ. សិទ្ធិសេរីភាពខាងការសិក្សាអប់រំ និងពិធីវប្បធម៌**

រដ្ឋាភិបាលពុំមានរឹតត្បិតសេរីភាពផ្នែកការសិក្សាអប់រំ ឬពិធីវប្បធម៌ឡើយ ជាផ្លូវការ ឬជាចំហឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកធ្វើការក្នុងផ្នែកសិក្សាអប់រំច្រើនមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងនយោបាយ ដោយសារខ្លាចប៉ះពាល់អ្នកនយោបាយ។

---

[40] https://www.ohchr.org/EN/NewsEvents/Pages/COVID19Guidance.aspx
(បានចូលទស្សនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១)។

[41] របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងអគ្គលេខាធិកា, សម័យប្រជុំថ្ងៃទី១៤ ខែកញ្ញា ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០

**គ. សេរីភាពបង្កើតអង្គការ ឬសមាគម**

ការិយាល័យ (OHCHR) បានបន្តចូលរួមជាមួយរដ្ឋាភិបាល លើសំណើរដែលស្នើសុំកែប្រែច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល។ ក្រសួងមហាផ្ទៃបានបើកវេទិកាពិគ្រោះយោបល់ចំនួន៥ ស្តីពីច្បាប់នេះ ដែលមានលក្ខណៈរឹតត្បឹតលើអង្គការមិនមែនរដ្ឋាភិបាល (NGOs)។ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល តម្រូវអោយគ្រប់អង្គការ សមាគមទាំងអស់មានអព្យាក្រឹតភាពផ្នែកនយោបាយដែលការនេះមិនត្រឹមតែរឹតត្បិតលើសិទ្ធិក្នុងការចូលរួមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរឹតត្បិតសិទ្ធិនៃអង្គការទាំងនោះនៅក្នុងការសំដែងមតិដោយសេរីថែមទៀតផង[42]។

**ឃ. សិទ្ធិកម្មករ**

ទាក់ទងទៅនឹងជនភៀសខ្លួន ច្បាប់បានអនុញ្ញាតឱ្យជនភៀសខ្លួនធ្វើការ និងបើកមុខរបរជំនួញ។ ប៉ុន្តែជនភៀសខ្លួនមិនទទួលបាននូវប័ណ្ណស្នាក់នៅដល់ជនភៀសខ្លួននោះទេ ដែលធ្វើឱ្យមានការពិបាកក្នុងការអនុវត្តសិទ្ធិនេះ[43]។

**ង. សិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច**

ស្ថានភាពសិទ្ធិដីធ្លី និងលំនៅដ្ឋាននៅតែជាបញ្ហាប្រឈម ដោយសារតែការបណ្តេញចេញដោយបង្ខំ កង្វះបទដ្ឋានត្រឹមត្រូវស្តីពីការតាំងទីលំនៅថ្មី និងរយៈពេលវែង ស្មុគស្មាញ មិនច្បាស់លាស់ និងការចំណាយប្រាក់ច្រើនក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។ ការបែងចែក ការលក់ និងការប្រើប្រាស់ដីធ្លីបានបន្តដំណើរការតាមប្រព័ន្ធវិនិយោគ ដែលមានវិសមភាពរចនាសម្ព័ន្ធដែលជះឥទ្ធិពលមិនសមាមាត្រទៅលើបុគ្គលដែលរស់នៅក្នុងភាពក្រីក្រ និងក្នុងស្ថានភាពងាយរងគ្រោះ។ មិនមានច្បាប់ ឬគោលនយោបាយរដ្ឋថ្មី ទាក់ទងនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ត្រូវបានបង្កើតឡើង ឬអនុម័តឡើយ។

យោងតាមការបកស្រាយ ខាងលើមក យើងឃើញថាសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាមិនទាន់មានភាពរឹងមាំនៅឡើយ និងមានភាពខ្វះចន្លោះជាច្រើនទៀតដែល ទាមទារឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់បន្ថែមទៀតក្នុងការពង្រឹងវិស័យសិទ្ធិមនុស្សនៅកម្ពុជា។ ប៉ុន្តែ យើងក៏ឃើញថារដ្ឋាភិបាលកំពុង និងបន្តការគាំទ្រសិទ្ធិមនុស្សនៅកម្ពុជាឱ្យមានភាពល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំផងដែរ។ យើងសង្ឃឹមថា នាពេលអនាគតប្រទេសកម្ពុជា នឹងប្រែក្លាយទៅជាប្រទេសមួយដែលមានការឱ្យតម្លៃទៅលើសិទ្ធិមនុស្សពេញលេញ ដូចប្រទេសជឿនលឿនដទៃទៀតឆាប់ៗខាងមុខនេះ។

---

[42] របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០២០។

# ជំពូកទី៤
# យន្តការការពារសិទ្ធិមនុស្សនៅកម្ពុជា

# ជំពូកទី៤
# យន្តការការពារសិទ្ធិមនុស្សនៅកម្ពុជា

## ៤.១. ការរំលោភសិទ្ធិមនុស្ស

ការរំលោភសិទ្ធិមនុស្ស ជាទង្វើទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់ជីវិតរស់នៅ សេចក្តីថ្លៃថ្នូរ កិត្តិយស និងបាត់បង់ផលប្រយោជន៍ជនណាម្នាក់ដោយការបំពានច្បាប់ និងក្រមសីលធម៌។ ហើយការរំលោភបំពាននេះ វាធ្វើឱ្យមនុស្សរស់នៅក្នុងភាពអយុត្តិធម៌ ខូចចិត្ត អស់សង្ឃឹមក្នុងជីវិត គ្មានទីពឹង និងបាត់បង់ឱកាសក្នុងការអភិវឌ្ឍខ្លួន។

## ៤.២. យន្តការការពារសិទ្ធិមនុស្សថ្នាក់ជាតិ

### ៤.២.១. គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និងអង្កេតព្រឹទ្ធសភា

គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និងអង្កេតព្រឹទ្ធសភា បានបង្កើតឡើងនៅឆ្នាំ១៩៩៩ នៅពេលដែលព្រឹទ្ធសភាកម្ពុជាត្រូវបានបង្កើតឡើង។ គណៈកម្មការសិទ្ធិមនុស្ស ជាគណៈកម្មការមួយក្នុងចំណោមគណៈកម្មការជំនាញទាំង១០ របស់ព្រឹទ្ធសភា ដែលមានទីតាំងនៅក្នុងព្រឹទ្ធសភា។

តួនាទីសំខាន់ៗរបស់គណៈគណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និងអង្កេតព្រឹទ្ធសភាមានដូចខាងក្រោម៖

- គាំទ្រលើកស្ទួយ និងការពារសិទ្ធិជនគ្រប់រូបឱ្យមានសេចក្តីថ្លៃថ្នូរ និងឱ្យមានសិទ្ធិស្មើគ្នា
- តាមដានការអនុវត្តសិទ្ធិមនុស្ស ឱ្យស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ
- តួនាទីជាក់លាក់ក្នុងវិស័យសិទ្ធិ រួមមានការទទួលពាក្យបណ្តឹងបុគ្គល ឬសមាគមន៍
- ពិនិត្យ និងស្វែងរកដំណោះស្រាយ និងចុះស្រាវជ្រាវ ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា
- ផ្តួចផ្តើមការធ្វើច្បាប់ឱ្យស្របតាមបទដ្ឋានសិទ្ធិមនុស្ស
- ផ្សព្វផ្សាយ និងអប់រំអំពីសិទ្ធិមនុស្ស។

គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និងអង្កេតព្រឹទ្ធសភាមានសមាជិកចំនួនប្រាំ (៥) រូប ដែលនៅក្នុងនោះមានដូចជា៖

- ប្រធាន (១ រូប)
- អនុប្រធាន (១ រូប)
- លេខាធិការ (១ រូប)

- សមាជិក (២ រូប)

### ៤.២.២. គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និងអង្កេតរដ្ឋសភា

គណៈកម្មការនេះ បានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៣ នៅពេលដែលរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងម្ល៉េះ។ គណៈកម្មការសិទ្ធិមនុស្ស គឺជាគណៈកម្មការមួយក្នុងចំណោមគណៈកម្មការទាំងដប់ (១០) របស់រដ្ឋសភាដែលមានទីតាំងនៅក្នុងរដ្ឋសភា។

តួនាទីសំខាន់ៗរបស់គណគណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និងអង្កេតរដ្ឋសភាមានដូចខាងក្រោម៖

- ពិនិត្យសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្ស
- ទទួលពាក្យបណ្តឹង និងអន្តរាគមន៍ករណីរំលោភសិទ្ធិមនុស្សពីប្រជាពលរដ្ឋ ដើម្បីជម្រុញឱ្យមានដំណោះស្រាយពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ
- ពិគ្រោះ និងផ្តល់យោបល់ផ្នែកច្បាប់ដល់ជនរងគ្រោះ។

គណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹង និងអង្កេតរដ្ឋសភាមានសមាជិកចំនួនប្រាំពីរ(៧)រូប ដែលនៅក្នុងនោះមានដូចជា៖

- ប្រធាន (១ រូប)
- អនុប្រធាន (១ រូប)
- លេខាធិការ (១ រូប)
- សមាជិក (៤ រូប)

### ៤.២.៣. គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជានៃរាជរដ្ឋាភិបាល

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គឺជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកការពារ និងលើកស្ទួយ វិស័យសិទ្ធិមនុស្ស និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។ គណៈកម្មាធិការនេះផ្ទាល់ ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០១០០/ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០០។

តួនាទីសំខាន់ៗរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជានៃរាជរដ្ឋាភិបាលមានដូចខាងក្រោម៖

- ស៊ើបអង្កេត និងដោះស្រាយគ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងករណីរំលោភសិទ្ធិមនុស្ស
- ប្រមូលចងក្រងព័ត៌មាននានាទាក់ទងទៅនឹងសិទ្ធិមនុស្ស
- អប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីបញ្ហាសិទ្ធិមនុស្ស
- រៀបចំរបាយការណ៍អំពីស្ថានភាពសិទ្ធិមនុស្ស និងការអនុវត្តកាតព្វកិច្ចរបស់ប្រទេសកម្ពុជាទៅអង្គការសហប្រជាជាតិ

- ជួយធ្វើអន្តរាគមន៍ ឱ្យមានដំណោះស្រាយ ចំពោះពាក្យបណ្តឹងរបស់ជនរងគ្រោះទៅស្ថាប័នពាក់ព័ន្ធ។

### ៤.២.៤. អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី

អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លា ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦។

តួនាទី និងសមត្ថភាពសំខាន់ៗរបស់អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លាមានដូចខាងក្រោម៖

- ដោះស្រាយ និងអន្តរាគមន៍ករណីទំនាស់ដីធ្លា ដែលមានលក្ខណៈធំដុំ និងស្មុគស្មាញ (ដីដែលគ្មានកម្មសិទ្ធិ)។
- បន្ថែមពីលើសមត្ថកិច្ចដោះស្រាយដោយគណៈកម្មការសុរិយោដី និងតុលាការ (ដីមានកម្មសិទ្ធិ)។

ចំណាត់កាលរបស់អាជ្ញាធរនេះ ធ្វើឡើងដោយយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ។ អាជ្ញាធរនេះមានការិយាល័យស្ថិតនៅក្នុងអគារទីស្តីការគណៈរដ្ឋមន្ត្រី ប៉ុន្តែឥឡូវបានផ្ទេរទៅក្រសួងរៀបចំដែនដីនគរូបណីយកម្ម និងសំណង់វិញ។

### ៤.២.៥. ក្រសួង ស្ថាប័នពាក់ព័ន្ធនានា

ក្រសួង និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀតមិនមានសមត្ថកិច្ចផ្ទាល់ក្នុងកិច្ចការសិទ្ធិមនុស្សទេ ប៉ុន្តែមានតួនាទីពាក់ព័ន្ធមួយចំនួនទៅតាមប្រភេទវិស័យ និងជំនាញប៉ុណ្ណោះ។

#### ៤.២.៥.១. ក្រសួងយុត្តិធម៌

ស្ថាប័ននេះ មានតួនាទីធ្វើច្បាប់ ផ្សព្វផ្សាយច្បាប់ ឬកិច្ចការដទៃទៀតអាចជួយបានដោយប្រយោលលើការលើកកម្ពស់សិទ្ធិមនុស្ស ទទួលបានការកាត់ក្តីដោយយុត្តិធម៌។

#### ៤.២.៥.២. ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ អាចជួយបានដោយប្រយោល ចំពោះការលើកកម្ពស់សិទ្ធិការងារសហជីព ក្រសួងកិច្ចការនារីអាចចូលរួមចំណែកក្នុងការការពារក្នុងការលើកស្ទួយសិទ្ធិស្ត្រី និងកុមារ។

### ៤.២.៦. តុលាការឧទ្ធរណ៍ និងតុលាការកំពូល

ជាស្ថាប័ន ដោះស្រាយពាក្យបណ្តឹងទូទៅរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់។ ក្នុងករណីមានប្រជាពលរដ្ឋណាម្នាក់ ដែលមានជាប់ពាក់ព័ន្ធនឹងរឿងក្តីណាមួយ។ (ឧទាហរណ៍៖ រឿងឃាតកម្ម លួច ទំនាស់បុគ្គល ទំនាស់ដីធ្លី) មិនសុខចិត្តនឹងសេចក្តីសម្រេច (សាលក្រម) នៅតុលាការសាលាដំបូងរាជធានី ខេត្ត គេមានសិទ្ធិប្តឹងឧទ្ធរណ៍ ឬប្តឹងទាស់នឹងសាលក្រមនេះ ទៅតុលាការថ្នាក់លើដូចជាទៅឧទ្ធរណ៍ ឬនឹងទៅតុលាការកំពូល (ប្រសិនមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ឧទ្ធរណ៍)។

## ៤.៣. យន្តការការពារសិទ្ធិមនុស្សថ្នាក់ក្រោមជាតិ

យន្តការការពារសិទ្ធិមនុស្សថ្នាក់ក្រោមជាតិ សំដៅលើក្រុមប្រឹក្សា គណៈអភិបាលរាជធានី ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ដែលបានចូលរួមក្នុងការការពារសិទ្ធិមនុស្ស។

## ៤.៤. យន្តការការពារសិទ្ធិមនុស្សថ្នាក់អន្តរជាតិ

សមត្ថភាពរបស់បុគ្គលទាំងអស់មានសិទ្ធិប្តឹងចំពោះការរំលោភសិទ្ធិនៅក្នុងផ្ទៃរាបនៃអន្តរជាតិ ដែលនាំមកនូវអត្ថន័យពិតប្រាកដចំពោះសិទ្ធិដែលមានក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។

ក្នុងការការពារសិទ្ធិ គេមាននីតិវិធីបី(៣)សំខាន់ៗសម្រាប់នាំបណ្តឹងពីការរំលោភបទបញ្ញត្តិសម្រាប់សន្ធិសញ្ញាសិទ្ធិមនុស្សនៅចំពោះមុខស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស៖

- ការប្តឹងចំពោះរដ្ឋទៅរដ្ឋ
- ការទំនាក់ទំនងជាលក្ខណៈបុគ្គល
- ការស៊ើបអង្កេត

មាននីតិវិធីជាច្រើនទៀតសម្រាប់ប្តឹង ដែលយោងទៅលើប្រព័ន្ធស្ថាប័នសិទ្ធិមនុស្សតាមរយៈនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

## ៤.៥. ស្ថាប័នបង្កើតដោយធម្មនុញ្ញសហប្រជាជាតិ

### ៤.៥.១. ក្រុមប្រឹក្សាសិទ្ធិមនុស្ស

ក្រុមប្រឹក្សាសិទ្ធិមនុស្ស ជាស្ថាប័នអន្តររដ្ឋាភិបាលមួយក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ ទទួលខុសត្រូវក្នុងការពង្រឹងនូវការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ហើយនិងដោះស្រាយស្ថានភាពនៃការរំលោភបំពានសិទ្ធិមនុស្ស ព្រមទាំងធ្វើអនុសាសន៍នានាស្តីពីស្ថានភាពទាំងអស់។

ស្ថាប័ននេះ មានរដ្ឋសមាជិកអង្គការសហប្រជាជាតិចំនួនសែសិបប្រាំពីរ(៤៧) ដែលត្រូវបានជ្រើសតាំងដោយមហាន្និបាតអង្គការសហប្រជាជាតិ (រដ្ឋជាសមាជិកនៅអាមេរិកឡាទីន និងតំបន់ការាប៊ីនចំនួនប្រាំបី(៨)អាសនៈ រដ្ឋជាសមាជិកនៅទ្វីបអ៊ឺរ៉ុបខាងលិច និងរដ្ឋផ្សេងទៀតចំនួនប្រាំពីរ(៧)អាសនៈ រដ្ឋជាសមាជិកទ្វីប អ៊ឺរ៉ុបខាងកើតចំនួនប្រាំមួយ(៦)អាសនៈ។

### ៤.៥.២. យន្តការពិនិត្យរបាយការណ៍រដ្ឋភាគីជាសកលតាមកាលកំណត់

យន្តការនេះ ជាដំណើរការតែមួយគត់ដែលពាក់ព័ន្ធនឹងការពិនិត្យមើលរបាយការណ៍សិទ្ធិមនុស្សរបស់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់ចំនួនមួយរយកៅសិបបី(១៩៣) រដ្ឋជារៀងរាល់បួន(៤)ឆ្នាំម្តង។

ប្រទេសកម្ពុជា បានយល់ព្រមទទួលយកអនុសាសន៍ទាំងអស់ចំនួនកៅសិបមួយ (៩១) របស់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ។

### ៤.៥.៣. នីតិវិធីពិសេស

ស្ថាប័ននេះ ជាយន្តការមួយដែលដោះស្រាយស្ថានភាពសិទ្ធមនុស្សទាំងឡាយតាមប្រទេសជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សទាំងឡាយតាមវិស័យ។ បច្ចុប្បន្នមានអាណត្តិការងារទាក់ទងបញ្ហាសិទ្ធិមនុស្សតាមវិស័យចំនួនសាមសិបប្រាំមួយ(៣៦) និងអាណត្តិការងារទាក់ទងនឹងស្ថានភាពសិទ្ធិមនុស្សតាមប្រទេសជាក់លាក់ចំនួនដប់ពីរ(១២)។

អាណត្តិការងារទាំងនេះ ក៏មានលក្ខណៈជាបុគ្គល "ហៅថាអ្នករាយការណ៍ពិសេស" និងមានលក្ខណៈជា "អ្នកជំនាញឯករាជ្យមួយរូប" ឬមានលក្ខណៈជា "ក្រុមការងារ"។ អ្នកអនុវត្តអាណាត្តិការងារទាំងនេះ មានឋានៈឯករាជ្យ ហើយក៏មិនទទួលបៀវត្សរ៍សម្រាប់ការងាររបស់ពួកគេឡើយ។

### ៤.៥.៤. គណៈកម្មាធិការសិទ្ធិមនុស្ស

មានស្ថាប័នសិទ្ធិមនុស្សចំនួនដប់(១០) ដែលចាំឃ្លាំងមើលការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ៖

#### ៤.៥.៤.១. គណៈកម្មាធិការសិទ្ធិមនុស្ស(ICCPR)

កតិកាសញ្ញាបានបង្កើតគណៈកម្មាធិការអន្តរជាតិមួយ ដែលមានសុទ្ធតែអ្នកជំនាញការឯករាជ្យ ហើយត្រូវបានស្គាល់ជាទូទៅជា គណៈកម្មាធិការសិទ្ធិមនុស្ស ដើម្បីឃ្លាំមើលការរីកចម្រើន និងផ្តល់ប្រឹក្សាយោបល់ទៀងទាត់ដល់រដ្ឋភាគី។ រដ្ឋភាគីទាំងអស់ ត្រូវបានតម្រូវឱ្យរាយការណ៍ជាទៀងទាត់ ទៅគណៈកម្មាធិការនេះពីការចាត់វិធានការរបស់ខ្លួន ដើម្បីអនុវត្តកតិកាសញ្ញា។ បន្ទាប់មក របាយការណ៍ត្រូវបានយកមកពិភាក្សាជាមួយរដ្ឋាភិបាលសាមី រួចទើបផ្តល់អនុសាសន៍ដល់រដ្ឋនោះ[44]។

#### ៤.៥.៤.២. គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ICESCR)

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចសហប្រជាជាតិ ដែលត្រូវបានផ្តល់ការទទួលខុសត្រូវតាមកត្តិសញ្ញាដាក់ឱ្យតាមដានការអនុវត្តកតិកាសញ្ញា បានបង្កើតគណៈកម្មាធិការអន្តរជាតិមួយនៃអ្នកជំនាញការឯករាជ្យ ហើយដែលគេស្គាល់ថាជា គណៈកម្មាធិការសិទ្ធិសង្គមកិច្ច និងវប្បធម៌ ដើម្បីតាមដានការរីកចំរើនរបស់រដ្ឋ

[44] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងពិធីសារបន្ថែម***, (ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ២០០៩), ១២។

ភាគីចំពោះការប្តេជ្ញាចិត្តរបស់ពួកគេ។ រដ្ឋភាគីទាំងអស់ ត្រូវតែធ្វើរបាយការណ៍ជាទៀងទាត់ទៅគណៈកម្មាធិការស្តីពីដំណាក់ការនានាដែលខ្លួនបានប្រកាន់យកដើម្បីអនុវត្តកតិកាសញ្ញានេះ[45]។

**៤.៥.៤.៣. គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍**(CERD)

យោងតាមអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ គណៈកម្មាធិការអន្តរជាតិមួយ ដែលមានអ្នកជំនាញការឯករាជ្យហើយដែលគេស្គាល់ជាទូទៅថា គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ ត្រូវបានបង្កើតឡើង ដើម្បីតាមដានការវិវត្តន៍របស់រដ្ឋភាគីក្នុងការបំពេញតាមការប្តេជ្ញាចិត្តរបស់ខ្លួន។ គ្រប់រដ្ឋភាគី តម្រូវឱ្យធ្វើរបាយការណ៍ជាទៀងទាត់តាមការកំណត់ជូនគណៈកម្មាធិការពីវិធានការដែលខ្លួនប្រកាន់យក ដើម្បីអនុវត្តអនុសញ្ញានេះ។ របាយការណ៍នេះ ត្រូវធ្វើជាទៀងទាត់រៀងរាល់ពីរ(២)ឆ្នាំម្តង ទោះបីរដ្ឋជាច្រើនមានធ្វើរបាយការណ៍តាមអនុសញ្ញារៀងរាល់បួន(៤)ឆ្នាំម្តងតាមសន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀតក៏ដោយ[46]។

**៤.៥.៤.៤. គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ**(CEDAW)

តាមរយៈសន្ធិសញ្ញា គណៈកម្មាធិការអន្តរជាតិមួយនៃអ្នកជំនាញការឯករាជ្យ ដែលស្គាល់ជាទូទៅថា គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ(CEDAW) ត្រូវបានបង្កើតឡើង ដើម្បីឃ្លាំមើលការរីកចម្រើន ដែលអនុវត្តដោយរដ្ឋនានា ក្នុងការបំពេញនូវការប្តេជ្ញាចិត្តរបស់ពួកគេ។ រដ្ឋទាំងអស់ចាំបាច់ត្រូវរាយការណ៍ជូនគណៈកម្មាធិការ តាមការកំណត់ ពីការចាត់វិធានការអនុវត្តអនុសញ្ញានេះ។ បន្ទាប់មក គណៈកម្មាធិការផ្តល់ប្រសាសន៍ដល់រដ្ឋាភិបាលសម្រាប់ចាត់វិធានការបន្ថែមទៀត[47]។

**៤.៥.៤.៥. គណៈកម្មាធិការស្តីពីប្រឆាំងទារុណកម្ម**(CAT)

ដើម្បីជួយដល់រដ្ឋគីក្នុងការបំពេញការប្តេជ្ញាចិត្តនេះ អនុសញ្ញានេះបង្កើតគណៈកម្មាធិការអន្តរជាតិមួយនៃក្រុមអ្នកជំនាញការឯករាជ្យដែលហៅថា គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម ដើម្បីឃ្លាំមើលការរីក

[45] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ***កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងពិធីសារបន្ថែម,*** (ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ២០០៩), ០៨។

[46] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ***អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍,*** (ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ២០០៩), ០៩។

[47] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ***អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងពិធីសារបន្ថែម,*** (ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ២០១០), ១៣។

ចម្រើនរបស់រដ្ឋភាគីនានា ហើយណែនាំដល់រដ្ឋភាគីទាំងនោះ អំពីវិធានការបន្ថែមទៀត ដែលរដ្ឋភាគីអាចចាត់ដើម្បីអនុវត្តអនុសញ្ញានេះឱ្យមានប្រសិទ្ធភាព។

រដ្ឋភាគីទាំងអស់ ត្រូវធ្វើរបាយការណ៍តាមការកំណត់ ផ្ញើទៅគណៈកម្មាធិការនេះ អំពីវិធានការនានាដែលបានចាត់ឡើង ដើម្បីអនុវត្តអនុសញ្ញានេះ។ រដ្ឋភាគីខ្លះ ក៏បានអនុញ្ញាតឱ្យគណៈកម្មាធិការនេះ ពិចារណាលើបណ្តឹងរបស់បុគ្គលទាំងឡាយ ដែលអះអាងថាសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន ឬបានអនុញ្ញាតឱ្យគណៈកម្មការនេះ ធ្វើទស្សនកិច្ចប្រទេសនោះ នឹងធ្វើការស៊ើបអង្កេត[48]។

**៤.៥.៤.៦. អនុគណៈកម្មាធិការបង្ការទារុណកម្ម**(SPT)

អនុគណៈកម្មាធិការបង្ការទារុណកម្មមានអាណត្តិមួយ ដើម្បីទស្សនកិច្ចទៅកាន់រដ្ឋភាគីទាំងអស់ក្នុងគោលបំណង ដើម្បីពង្រឹង ប្រសិនជាចាំបាច់នូវការការពារបុគ្គលទាំងឡាយដែលត្រូវគេដកហូតសេរីភាពប្រឆាំងនឹងការធ្វើទារុណកម្ម និងទម្រង់ឯទៀតនៃការប្រព្រឹត្តអំពើឃោរឃៅអមនុស្សធម៌។ រដ្ឋភាគីទាំងអស់មានកាតព្វកិច្ចស្របតាមពិធីសារបន្ថែម អនុញ្ញាតឱ្យអនុគណៈកម្មការ(SPT) ចូលដោយគ្មានការរឹតត្បិត ក្នុងកន្លែងឃុំឃាំងទាំងអស់ និងផ្តល់ព័ត៌មានទាំងឡាយដែលពាក់ព័ន្ធតាមការស្នើសុំ ដល់អនុគណៈកម្មការ(SPT)។ អនុគណៈកម្មាធិការបង្ការទារុណកម្ម ធ្វើការសម្ភាសដោយផ្ទាល់ជាមួយបុគ្គលទាំងឡាយដែលត្រូវបានជាដកហូតសេរីភាព និងជាមួយអ្នកឯទៀតដែលអនុគណៈកម្មាធិការបង្ការនេះ ជឿថាអាចផ្តល់ព័ត៌មានពាក់ព័ន្ធបាន។

**៤.៥.៤.៧. គណៈកម្មាធិការស្តីពីសិទ្ធិកុមារ**(CRC)

យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ គណៈកម្មការអន្តរជាតិមួយដែលមានអ្នកជំនាញការឯករាជ្យ ហើយដែលគេស្គាល់ជាទូទៅថាជា គណៈកម្មាធិការសិទ្ធិកុមារ ឬ(CRC) ត្រូវបានបង្កើតឡើង ដើម្បីតាមដានការវិវត្តន៍របស់រដ្ឋភាគី ក្នុងការបំពេញតាមការប្តេជ្ញាចិត្តរបស់ខ្លួន។ គ្រប់រដ្ឋភាគី តម្រូវឱ្យធ្វើរបាយការណ៍ជាទៀងទាត់តាមកាលកំណត់ជូនគណៈកម្មាធិការ(CRC) ពីវិធានការដែលខ្លួនប្រកាន់យក ដើម្បីអនុវត្តអនុសញ្ញានេះ[49]។

[48] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ***អនុសញ្ញាស្តីពីការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទោកបន្ទាប និងពិធីសារបន្ថែម***, (ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ២០០៧), ០៤។

[49] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ***អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម***, (ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ២០០៩), ១៣។

**៤.៥.៤.៨. គណៈកម្មាធិការស្ដីពីសិទ្ធិពលករទេសន្តរប្រវេសន៍**(CMW)

អនុសញ្ញាអន្តរជាតិស្ដីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ បានបង្កើតគណៈកម្មាធិការមួយនៃអ្នកជំនាញការឯករាជ្យ ដើម្បីតាមឃ្លាំមើលការអនុវត្តអនុសញ្ញានេះដោយរដ្ឋភាគី[50]។ គណៈកម្មាធិការស្ដីពីសិទ្ធិពលករទេសន្តប្រវេសន៍(CMW) មានសមាជិកជាអ្នកជំនាញការចំនួនដប់បួន(១៤)រូប បោះឆ្នោតដោយរដ្ឋភាគី ហើយបម្រើការងារក្នុងសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ។ គណៈកម្មាធិការនេះ បើកសម័យប្រជុំរបស់ខ្លួនពីរ(២)ដង ក្នុង ១ឆ្នាំ នៅទីក្រុងហ្សឺណែវ។

អនុលោមតាមមាត្រា៧៣ រដ្ឋភាគីត្រូវដាក់របាយការណ៍តាមកាលកំណត់របស់ខ្លួន គណៈកម្មាធិការ ពីវិធានការដែលរដ្ឋភាគីបានធ្វើ ដើម្បីធ្វើឱ្យបទបញ្ញត្តិនៃអនុសញ្ញាស្ដីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេនេះមានប្រសិទ្ធភាព។ គណៈកម្មាធិការពិនិត្យរបាយការណ៍បែបនេះ រួចហើយផ្ដល់អនុសាសន៍ ដើម្បីឱ្យចាត់វិធានការបន្ថែមទៀតដោយរដ្ឋភាគីពាក់ព័ន្ធ។

រដ្ឋភាគីមួយ អាចសម្រេចផ្ដល់ឱ្យគណៈកម្មាធិការនូវសមត្ថកិច្ចទទួល និងពិចារណាលើបណ្ដឹងរវាងរដ្ឋ និង/ឬបណ្ដឹងពីបុគ្គល ឬក្រុមតំណាង ដែលអះអាងថា សិទ្ធិរបស់គេតាមអនុសញ្ញានេះត្រូវបានរំលោភបំពានដោយរដ្ឋភាគីនោះ។

**៤.៥.៤.៩. គណៈកម្មាធិការស្ដីពីសិទ្ធិជនពិការ**(CRPD)

អនុសញ្ញាស្ដីពីសិទ្ធិជនពិការ និងពិធីសារបន្ថែមនេះ មានបទបញ្ញត្តិលម្អិតអំពីការអនុវត្ត និងការឃ្លាំមើលថ្នាក់ជាតិ រួមមានការប្រមូលស្ថិតិ និងទិន្នន័យដទៃទៀត និងមុខងារនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការជួយដល់ប្រទេសកំពុងអភិវឌ្ឍ ដើម្បីសម្រេចតាមនិយមន័យដែលជាបំណងប្រាថ្នារបស់អនុសញ្ញានេះ សម្រាប់ជាប្រយោជន៍ដល់ជនពិការ។ ទន្ទឹមនឹងទិសដៅដែលបានកំណត់ក្នុងអនុសញ្ញានេះ មានតម្លៃ និងចាំបាច់ បរទេសជាច្រើននឹងត្រូវប្រឈមមុខពុះពារគ្រប់ឧបសគ្គដ៏ធំធេង ដើម្បីបំពេញនូវការបន្តប្តេជ្ញាចិត្តរបស់ខ្លួនស្របតាមបទបញ្ញត្តិនៃអនុសញ្ញានេះ។ ដើម្បីជួយរដ្ឋនានាក្នុងការអនុវត្តអនុសញ្ញានេះឱ្យមានប្រសិទ្ធភាព គណៈកម្មាធិការអន្តរជាតិមួយនៃអ្នកជំនាញការដែលស្គាល់ថាជា គណៈកម្មការទទួលបន្ទុកសិទ្ធិជនពិការ និងត្រូវបង្កើតឡើងនៅពេលដែលអនុសញ្ញាស្ដីពីសិទ្ធិជនពិការចូលជាធរមាន។

រដ្ឋភាគីនីមួយៗ បានតម្រូវឱ្យដាក់ជូនរបាយការណ៍មួយតាមការកំណត់ទៅគណៈកម្មាធិការនេះ ដោយកំណត់ពីវិធានការដែលត្រូវមាន ដើម្បីអនុវត្តអនុសញ្ញានេះ។ បន្ទាប់មកគណៈកម្មាធិការត្រូវផ្ដល់ការណែនាំ និងអនុសាសន៍ជំនាញ ចំពោះការចាត់វិធានការបន្តទៅទៀត ដើម្បីពង្រឹងការបន្តប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល

[50] មាត្រា ៧២, អនុសញ្ញាស្ដីពីអនុសញ្ញាអន្តរជាតិស្ដីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ។

ចំពោះគោលដៅទាំងឡាយដែលបានកំណត់ដោយអនុសញ្ញានេះ[51]។

**៤.៥.៤.១០. គណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ**(CED)

ការរីកដាល ឬការអនុវត្តជាប្រព័ន្ធនៃការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងច្បាប់អន្តរជាតិ ដែលកំពុងអនុវត្តនឹងត្រូវមានវិបាកដូចមានចែងក្នុងច្បាប់អន្តរជាតិជាធរមាន។ ការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ គ្មានករណីលើកលែងទេ ទោះបីរដ្ឋភាគីនោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ រាប់ទាំងប្រទេសស្ថិតនៅក្នុងស្ថានភាពមានសង្គ្រាម ឬការគំរាមកំហែងដោយសង្គ្រាម អស្ថេរភាពនយោបាយផ្ទៃក្នុង ឬភាពមានអាសន្នជាសាធារណៈណាក៏ដោយ មិនអាចយកមកធ្វើជាយុត្តិកម្មចំពោះការបាត់ខ្លួនដោយបង្ខំបានឡើយ។

អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ក៏ដូចជាសន្ធិសញ្ញាសិទ្ធិមនុស្សនានាដែរ បានបង្កើតស្ថាប័នសន្ធិសញ្ញាមួយដើម្បីតាមឃ្លាំមើលការអនុវត្តអនុសញ្ញានេះគណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ ត្រូវបានកើនឡើងពីស្ថាប័នរបស់អ្នកជំនាញការឯករាជ្យសម្រាប់តាមឃ្លាំមើលការអនុវត្តអនុសញ្ញាដោយរដ្ឋភាគី។ រដ្ឋភាគីទាំងអស់ ត្រូវដាក់របាយការណ៍ជាទៀងទាត់របស់ខ្លួនជូនគណៈកម្មាធិការនេះ ពីវិធានការនានាក្នុងការអនុវត្តន៍សិទ្ធិ ដូចមានចែងនៅក្នុងអនុសញ្ញានេះ។

ទន្ទឹមនឹងនោះ រដ្ឋភាគីត្រូវដាក់ជូនរបាយការណ៍បឋមរបស់ខ្លួនទៅគណៈកម្មាធិការពីរ(២)ឆ្នាំ បន្ទាប់ពីបានផ្តល់សច្ចាប័ន។ គណៈកម្មាធិការនឹងពិនិត្យរបាយការណ៍នីមួយៗរបស់រដ្ឋភាគី និងផ្តល់ជាសំណើ ឬអនុសាសន៍ទូទៅលើរបាយការណ៍នោះ តាមតែខ្លួនយល់ថាសមស្របហើយបញ្ជូនទៅរដ្ឋភាគីសាម៉ីវិញ។ គណៈកម្មាធិការ ជាទូទៅកោះប្រជុំរបស់ខ្លួននៅទីក្រុងហ្សឺណែវពីរ(២)ដងរៀងរាល់ឆ្នាំ។

**៤.៥.៥. តួនាទី និងសមាសភាព**

**៤.៥.៥.១. តួនាទី**

គណៈកម្មាធិការទាំងអស់ខាងលើមានតួនាទីដូចជា៖

- ពិនិត្យរបាយការណ៍របស់រដ្ឋភាគី
- ធ្វើការផ្សព្វផ្សាយសេចក្តីពន្យល់ទូទៅ
- ពិនិត្យពាក្យបណ្តឹងលក្ខណៈបុគ្គល

[51] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ***អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែម***, (ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យប្រចាំនៅកម្ពុជា, ២០០៧), ០៤។

**៤.៥.៥.២. សមាសភាព**

សមាសភាពរបស់គណៈកម្មធិការ គឺជាអ្នកជំនាញឯករាជ្យឃ្លាំមើលការអនុវត្តសន្ធិសញ្ញាស្ដីពីមនុស្សអន្តរជាតិសំខាន់ៗ ដែលត្រូវបានបង្កើតឡើងអនុលោមតាមបទប្បញ្ញតិនានានៃសន្ធិសញ្ញាដែលពួកគេឃ្លាំមើល។

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយអំពី សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជាកន្លងមក យើងខ្ញុំបានយល់ដឹងយ៉ាងច្បាស់អំពីសញ្ញាណទូទៅនៃសិទ្ធិមនុស្ស ដែលមានព្រមទាំងនិយមន័យ ប្រភព ទ្រឹស្ដី និងគោលការណ៍ទូទៅជារួមនៃសិទ្ធិមនុស្ស។ បន្ថែមពីនេះ យើងខ្ញុំក៏បានទទួលចំណេះដឹងទាក់ទងទៅលើបទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិជាច្រើនដែលពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្សមានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធម្មនុញ្ញសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ អនុសញ្ញា និងពិធីសារបន្ថែមនានា ដែលវាជាគ្រឹះដ៏សំខាន់នៃការប្រតិបត្តិសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា និងជាចំណុចគួរឱ្យចាប់អារម្មណ៍ដល់ជនគ្រប់រូប ដែលមានបំណង់ចង់សិក្សាស្វែងយល់ឱ្យស៊ីជម្រៅទាក់ទងទៅនឹងសិទ្ធិមនុស្ស ជាពិសេសកាតព្វកិច្ចរបស់រដ្ឋភាគី និងស្ថាប័នដែលពាក់ព័ន្ធក្នុងវិស័យសិទ្ធិមនុស្សនេះផ្ទាល់។ លើសពីនេះ យើងខ្ញុំបានលើកយកសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា និងយន្តការការពារសិទ្ធិមនុស្សមកសិក្សាដោយបានលើកយកការអនុវត្ត និងស្ថានភាពសិទ្ធិមនុស្សជាក់ស្ដែងនៅកម្ពុជាមកធ្វើការស្រាវជ្រាវផងដែរ។

ជាការពិតណាស់ សិទ្ធិមនុស្សពិតមានសារៈក្នុងជីវភាពប្រចាំថ្ងៃ ដែលជនគ្រប់រូបទាមទារ និងត្រូវការជាចាំបាច់ ដោយមិនអាចខ្វះបាន មិនថា ប្រុស ស្រី ក្មេង ឬចាស់ សូម្បីតែកូនក្មេងទើបតែកើតក៏ត្រូវការសិទ្ធិក្នុងការរស់នៅ ដើម្បីការពារខ្លួនរបស់ពួកគេពីការរំលោភបំពានផ្សេងៗ និងទទួលបានអត្ថប្រយោជន៍ពីសិទ្ធិដែលមានពីកំណើតផងដែរ។ ទាំងនេះ បានបង្ហាញយ៉ាងច្បាស់អំពីសារៈសំខាន់នៃសិទ្ធិចំពោះមនុស្សជាតិ មូលហេតុនេះ ទើបយើងសង្កេតឃើញថាមានស្ថាប័នជាតិ និងអន្តរជាតិជាច្រើនបានចូលរួមគាំទ្រ ផ្សព្វផ្សាយ និងលើកស្ទួយទៅលើវិស័យសិទ្ធិមនុស្ស ដើម្បីធានាដល់ជនគ្រប់ៗរូបទទួលបានសិទ្ធិស្មើៗគ្នាដោយមិនប្រកាន់ពីដើមកំណើត ឬពូជសាសនសន៍ ជនជាតិដើម ពណ៌សម្បុរ ភេទ និន្នាការនយោបាយ ពិការភាព ភាសាជំនឿ សាសនា វប្បធម៌ ប្រវត្តសាស្ត្រ គំនិតយោបល់ ឬសង្គមឋានៈផ្សេងទៀត និងត្រូវបានជៀសឱ្យឆ្ងាយពីការរំលោភសិទ្ធិនានាដែលអាចកើតមានឡើយ ដោយមានគណៈកម្មាធិការសិទ្ធិមនុស្សគ្រប់ផ្នែក សម្រាប់ធ្វើការឃ្លាំមើលការអនុវត្តសិទ្ធិ និងទទួលពាក្យបណ្ដឹងក្នុងការដោះស្រាយរឿងក្ដីដោយនីតិវិធីទាក់ទងទៅនឹងសិទ្ធិមនុស្សផងដែរ។

សរុបសេចក្ដីមកយើងឃើញថា សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា គឺជាវិថីដ៏វែងឆ្ងាយមួយដែលទាមទារឱ្យមានការកែលម្អជារឿយៗ ដើម្បីឱ្យដំណើរការអនុវត្តនៃសិទ្ធិមនុស្សកម្ពុជាកាន់តែមានតម្លាភាព គុណភាព និងប្រសិទ្ធិភាពខ្ពស់ ដំណើរការបានរលូន ដែលអាចឱ្យជនគ្រប់រូបជឿជាក់បានថា ប្រទេសកម្ពុជាពិតជាប្រទេសដែលបានអនុវត្តសិទ្ធិមនុស្សពេញលេញបរិបូរណ៍ ស្របតាមបទប្បញ្ញត្តិដែលបានចែងក្នុងបទដ្ឋាន

គតិយុត្តិពិតប្រាកដ និងមិនមានការរំលោភសិទ្ធិសេរីភាពទៅលើជនណាម្នាក់តាមគ្រប់រូបភាពឡើយ។ រដ្ឋាភិបាល គឺជាតួអង្គយ៉ាងសំខាន់ក្នុងកិច្ចការសិទ្ធិមនុស្សនេះ គ្រប់យន្តការក្នុងទិសដៅអភិវឌ្ឍប្រទេសឱ្យមានភាពល្អប្រសើរ ក្លាយជាប្រទេសនីតិរដ្ឋ ត្រូវពិនិត្យឱ្យបានច្បាស់លាស់មុនអំពីផលប៉ះពាល់ទៅនឹងសិទ្ធិមនុស្ស មុនធ្វើការដាក់ចេញនូវផែនការណ៍អនុវត្ត ដើម្បីធានាដល់សិទ្ធិប្រជាពលរដ្ឋ និងសុខមាភាពរស់នៅ។

# អនុសាសន៍

ស្របតាមការស្រាវជ្រាវ ក្នុងរយៈពេល៣ខែកន្លងមកនេះទៅលើប្រធានបទស្តីពី សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ក្នុងនាមយើងខ្ញុំជាអ្នកស្រាវជ្រាវពិតជាមានសេចក្តីរីករាយ សោមនស្សយ៉ាងខ្លាំង ព្រោះបានទទួលនូវចំណេះដឹង និងបានស្វែងយល់បន្ថែមទាក់ទងទៅនឹងសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា និងបានស្វែងរកឃើញនូវបញ្ហាប្រឈមមួយចំនួន ដែលបានរារាំងដល់ការអនុវត្តសិទ្ធិមនុស្សនៅក្នុងប្រទេស កម្ពុជាឱ្យមានប្រសិទ្ធិភាព។ ពីព្រោះតែ មានចំណុចមួយចំនួនក៏មិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ ដោយសារវានៅមានចន្លោះប្រហោងមួយចំនួនដែលរដ្ឋាភិបាលកម្ពុជា និងស្ថាប័នដែលពាក់ព័ន្ធគួរយកចិត្តទុកដាក់ និងកែលម្អទៅលើចំណុចខ្វះខាតទាំងអស់នោះ។ ដើម្បីកែលម្អចំណុចខ្វះខាតទាំងនោះ ក្នុងនាមយើងខ្ញុំជាអ្នកស្រាវជ្រាវសូមចូលរួមចំណែកជាមតិយោបល់ និងគំនិតខ្លះៗដើម្បីលើកស្ទួយវិស័យសិទ្ធិមនុស្សនៅកម្ពុជាឱ្យមានតម្លាភាព វឌ្ឍនភាព និងនិរន្តន៍ភាព ដែលចំណុចទាំងនោះមានដូចខាងក្រោម៖

- អ្នកការពារសិទ្ធិមនុស្ស គឺចាំបាច់ត្រូវតែទទួលបានការគាំទ្រ និងផ្តល់លទ្ធភាពដោយសកម្មភាពសន្តិភាព របស់អ្នកការពារសិទ្ធិមនុស្ស ទោះបីជាសកម្មភាពនោះធ្វើឡើងដោយជាបុគ្គលក្តី ឬជាក្រុមក្តី
- អ្នកការពារសិទ្ធិមនុស្ស នៅពេលដែលចង់ធ្វើអ្វីមួយដែលជាប្រយោជន៍សាធារណៈ អាជ្ញធរគួរជួយសម្របសម្រួល និងគាំទ្រទៅដល់សកម្មជាពសិទ្ធិមនុស្ស
- សូមឱ្យមានការលុបបំបាត់ការរើសអើងក្នុងវិស័យអប់រំកុមារ
- លើកកម្ពស់ និងគាំទ្រទៅលើការប្រឆាំងនឹងវប្បធម៌ហិង្សា
- ពិនិត្យមើលនិទទន្ធភាព ដើម្បីនានាដល់នីតិរដ្ឋប្រទេស
- មនុស្សគ្រប់រូបគួរតែមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិពេញលេញបូរិបូណ៌ ដោយគ្មានការរឹតត្បិតពីសំណាក់បុគ្គល ឬក្រុម ឬស្ថាប័នណាមួយឡើយ
- សូមឱ្យមានការធានា លើកកម្ពស់ និងគោរពការពារសិទ្ធិ អ្នកការពារសិទ្ធិមនុស្ស អ្នកសារពត៌មាន ធានាដោយអង្គការ ឬបុគ្គល ដើម្បីឱ្យពួកគេទទួលបាននូវសិទ្ធិសេរីភាពក្នុងការបំពេញការងារ
- រដ្ឋាភិបាលគួរពិនិត្យទៅលើអាជ្ញាធរមូលដ្ឋាន ក្នុងការលុបបំបាត់រាល់នូវសកម្មភាព បង្ក្រាបទាំងឡាយ ដែលមានចេតនាបង្កហិង្សា របួសស្នាមទៅលើក្រុមធ្វើបាតុកម្ម ប្តឹងតវ៉ា និងដោះស្រាយដោយសន្តិវិធីជូនក្រុមអ្នកតវ៉ា
- រដ្ឋាភិបាល គួរតែបង្កើតនូវអង្គភាពសម្រាប់ពិគ្រោះយោបល់ជាសាធារណៈទាក់ទងនឹងសិទ្ធិមនុស្ស ឱ្យបានច្រើន ដើម្បីបង្កឱ្យមានភាពងាយស្រួលដល់ប្រជាពលរដ្ឋរបស់ខ្លួន ក្នុងការស្វែងរកសេវាកម្មពិគ្រោះយោបល់ និងស្វែងយល់កាន់តែច្បាស់នូវសិទ្ធិរបស់ពួកគេ។

# ឯកសារយោង

## ១. ច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤។
- ច្បាប់សិទ្ធិមនុស្សកម្ពុជា អង្គការសហប្រជាជាតិ ២០១២។

## ២. អនុសញ្ញា

- អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ១៩៩០ និងដាក់ចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣។
- អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ដោយសេចក្តីសម្រេចចិត្តលេខ ២១០៦A (XX) ចុះថ្ងៃទិ២១ ខែធ្នូ ឆ្នាំ១៩៦៥ របស់មហាសន្និបាទអង្គការសហប្រជាជាតិ។
- អនុសញ្ញា ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ តាមសម្រេចចិត្តលេខ៣៤/១៨០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ របស់មហាសន្និបាទអង្គការសហប្រជាជាតិ។
- អនុសញ្ញាប្រឆាំងទារុណ្ឌកម្ម និងការប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក បានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចចិត្តលេខ៣៩/៤៦ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤។
- អនុសញ្ញា ស្តីពីសិទ្ធិកុមារ តាមសេចក្តីសម្រេចចិត្តលេខ៤៤/២៥ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ របស់អង្គការសហប្រជាជាតិ។
- អនុសញ្ញា ស្តីពីសិទ្ធិជនពិការ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៦។
- អនុសញ្ញា ពាក់ព័ន្ធឋានៈជនភៀសខ្លួន ត្រូវបានអនុម័តនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥១ ដោយសន្និសីទនៃបុណ្ណទូតសហប្រជាជាតិ ស្តីពីឋានៈជនភៀសខ្លួន តាមសេចក្តីសម្រេចចិត្តលេខ៤២៩ (V) ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៥០។
- អនុសញ្ញា ស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ២៦០A(III) ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨។

- អនុសញ្ញាអន្តរជាតិ ស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ២០០៦ និងចូលជាធរមានតាមច្បាប់អន្តរជាតិកាលពីថ្ងៃ ទី២៣ ខែធ្នូ ២០១០។

## ៣. ពិធីសារ

- ពិធីសារពាក់ព័ន្ធឋានៈជនភៀសខ្លួន ដែលអនុម័តយល់ព្រមពីក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច តាមសេចក្ដីសម្រេចចិត្តលេខ១១៨៦ (XLI) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៦៦ និងដោយមហាសន្និបាត តាមសេចក្ដីសម្រេចចិត្តលេខ (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦

## ៤. ពិធីសារបន្ថែម

- ពិធីសារបន្ថែមទី១ លើ កតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតលេខ ២២០០A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
- ពិធីសារបន្ថែម លើកតិកាសញ្ញាពាក់ព័ន្ធនឹងការលុបចោលទោសប្រហារជីវិត ដោយសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៤៤/១២៨ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៩
- ពិធីសារបន្ថែម លើកតិកាសញ្ញាពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្ដឹងបុគ្គល ដោយសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតលេខ ២២០០A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
- ពិធីសារបន្ថែម លើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្ដីសម្រេចចិត្តលេខ:A.៥៤/៤ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៩
- ពិធីសារបន្ថែម លើអនុសញ្ញាប្រឆាំងទារុណ្ណកម្ម និងការប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ត្រូវបានអនុម័តកាលពីថ្ងៃទិ១៨ ខែធ្នូ ឆ្នាំ២០០២ នាសម័យប្រជុំលើកទី៥៧ នៃមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្ដីសម្រេចចិត្តលេខA/RES/៥៧/១៩៩
- ពិធីសារបន្ថែម លើអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្ដីសម្រេចចិត្តលេខ A/RES/៥៤/២៦៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០
- ពិធីសារបន្ថែម លើអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជំលោះប្រដាប់អាវុធ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្ដីសម្រេចចិត្តលេខ A/RES/៥៤/

២៦៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០

- ពិធីសារបន្ថែម លើអនុសញ្ញាស្តីពីសិទ្ធិជនពិការ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៦

## ៤. សេចក្តីប្រកាស

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយសេចក្តីសម្រេចចិត្ត នៃមហាសន្និបាតអង្គការសហប្រជាជាតិលេខ២១៧ A(III) នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨

## ៤. កតិកាសញ្ញា

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ២២០០A (XXI) នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ២២០០A (XXI) នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦

## ៥. ឯកសារពិគ្រោះ

- សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន រៀបរៀងដោយសាស្ត្រាចារ្យ សួន ងួនអ៊ី
- សំណួរ និងចម្លើយ សិទ្ធិមនុស្ស រៀបរៀង និងបោះពុម្ពផ្សាយក្រោមជំនួយឧបត្ថម្ភរបស់សហភាពអឺរ៉ុប បោះពុម្ពផ្សាយឆ្នាំ២០១៩

## ៦. របាយការណ៍

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៧
- របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០១៧
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឆ្នាំ២០១៨
- របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០១៨
- ស្ថានទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា, របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០១៩
- របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០១៩
- ស្ថានទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា, របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០២០

- របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០២០

## ៧. គេហទំព័រ

- គេហទំព័រផ្លូវការរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា https://cambodia.ohchr.org/kh
- គេហទំព័រផ្លូវការរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា https://cchrcambodia.org/
- គេហទំព័រផ្លូវការរបស់ស្ថានទូតសហរដ្ឋអាមេរិកនៅកម្ពុជា https://kh.usembassy.gov/km/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១៖ ច្បាប់សិទ្ធិមនុស្សកម្ពុជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សកម្ពុជា បោះពុម្ពឆ្នាំ ២០១២
- ឧបសម្ព័ន្ធទី២៖ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- ឧបសម្ព័ន្ធទី៣៖ សំណួរ និងចម្លើយ សិទ្ធិមនុស្ស រៀបរៀង និងបោះពុម្ពផ្សាយក្រោមជំនួយឧបត្ថម្ភរបស់សហភាពអឺរ៉ុប
- ឧបសម្ព័ន្ធទី៤៖ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាក្នុងឆ្នាំ ២០១៧ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
- ឧបសម្ព័ន្ធទី៥៖ របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការឆ្នាំ២០១៧
- ឧបសម្ព័ន្ធទី៦៖ ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាក្នុងឆ្នាំ ២០១៨ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
- ឧបសម្ព័ន្ធទី៧៖ របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការឆ្នាំ២០១៨
- ឧបសម្ព័ន្ធទី៨៖ របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០១៩ នៃស្ថានទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា
- ឧបសម្ព័ន្ធទី៩៖ របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការឆ្នាំ២០១៩
- ឧបសម្ព័ន្ធទី១០៖ របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០២០ នៃស្ថានទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា
- ឧបសម្ព័ន្ធទី១១៖ របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការឆ្នាំ២០២០។

# ឧបសម្ព័ន្ធទី១ ៖

# ច្បាប់សិទ្ធិមនុស្សកម្ពុជា ការិយាល័យឧត្តមស្នងការ
# អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

## ការិយាល័យឧត្តមស្នងការ
## អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

# ច្បាប់សិទ្ធិមនុស្សកម្ពុជា

### សេចក្តីប្រកាសសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា
### និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលធានាការពារដោយរដ្ឋធម្មនុញ្ញ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
*កម្ពុជា*

២០១២

# មាតិកា


បុព្វកថា

**ក. <u>សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា</u>**

១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (សម្រង់) ---------------------------------- ៣

ជំពូកទី២ អំពីព្រះមហាក្សត្រ ---------------------------------- ៤

ជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ -------------------- ៤

ជំពូកទី៤ អំពីរបបនយោបាយ ---------------------------------- ១០

ជំពូកទី៦ អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច ---------------------- ១០

ជំពូកទី១១ អំពីអំណាចតុលាការ ------------------------------ ១១

២- កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា (សម្រង់) ---- ១៥

៣- កិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាច
រំលោភបាននៃទឹកដី អព្យាក្រិត្យភាព និងឯកភាពជាតិរបស់កម្ពុជា ---------- ១៨

៤- សេចក្តីថ្លែងការណ៍ស្តីពីការស្តារ និងការកសាងប្រទេសកម្ពុជាឡើងវិញ (សម្រង់) --- ២០

**ខ. <u>សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ</u>**

៥- ធម្មនុញ្ញសហប្រជាជាតិ (ដកស្រង់ពីបុព្វកថា) ------------------------ ២៥

៦- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ------------------------------ ២៧

៧- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ------------- ៣៧

៧-ក- ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច
និងវប្បធម៌ពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គល -------------------- ៥៣

៨- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ --------------- ៦៥

៨-ក- ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
ពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គល ------------------------ ៨៩

៨-ខ- ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
ពាក់ព័ន្ធនឹងការលប់ចោលទោសប្រហារជីវិត ------------------------ ៩៥

៩- អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ --------- ៩៩

១០- អនុសញ្ញាស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ---------- ១១៧

១០-ក-ពិធីសារបន្ថែមលើអនុសញ្ញាស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ-១៣៥

១១- អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ------------------------ ១៤៣

១១-ក- ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ---------- ១៦១

១២- អនុសញ្ញាស្ដីពីសិទ្ធិកុមារ -------------------------------------- ១៧៧

១២-ក-ពិធីសារបន្ថែមលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ------------------------------ ២០៧

១២-ខ-ពិធីសារបន្ថែមលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ ------------------------------ ២១៧

១២-គ-ពិធីសារបន្ថែមលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងនីតិវិធីបណ្ដឹង ---------- ២២៩

១៣- អនុសញ្ញាស្ដីពីសិទ្ធិជនពិការ ------------------------------------ ២៤៧

១៣-ក-ពិធីសារបន្ថែមលើអនុសញ្ញាស្ដីពីសិទ្ធិជនពិការ ------------------------ ២៩៣

១៤- អនុសញ្ញាអន្តរជាតិស្ដីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ---------------------------------- ៣០១

១៥- អនុសញ្ញាអន្តរជាតិស្ដីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ------------ ៣៧៩

១៦- អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន ------------------------------ ៤២១

១៦-ក-ពិធីសារពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន ------------------------------ ៤៤១

១៧- អនុសញ្ញាស្ដីពីការបង្ការ និងការផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ----- ៤៤៥


**គ. <u>ឧបសម្ព័ន្ធ</u>**


១៦- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ពាក់ព័ន្ធនឹងការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាដោយតុលាការកម្ពុជា -------------------------------------------- ៤៥៣

# ច្បាប់សិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា
# សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា
# និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ

## បុព្វកថា

អត្ថបទទាំងឡាយដែលបានដាក់បញ្ចូលក្នុងកម្រងច្បាប់នេះ តំណាងឱ្យឯកសារជាមូលដ្ឋាន នៃច្បាប់សិទ្ធិមនុស្សកម្ពុជាដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ការការពារសិទ្ធិមនុស្សក្រោមរដ្ឋធម្មនុញ្ញ ត្រូវបានធ្វើឡើងតាមវិធីពីរយ៉ាងគឺ : ទីមួយអនុលោមតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស រដ្ឋធម្មនុញ្ញបញ្ចូលសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សដែលអាចរកឃើញភាគច្រើននៅក្នុងជំពូកទី៣នៃរដ្ឋធម្មនុញ្ញ ហើយទីពីរគឺ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ដែលបានបញ្ចូលដោយផ្ទាល់នូវលិខិតុបករណ៍សិទ្ធិមនុស្សសំខាន់ៗមួយចំនួនទៅក្នុងច្បាប់កម្ពុជា ។

*ក- សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា*

កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ដែលបានបញ្ចប់ជាផ្លូវការនូវជម្លោះកម្ពុជា បានបង្កើតបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាមូលដ្ឋានមួយសំរាប់សន្តិភាពជាអមតៈនៅកម្ពុជា ។ មាត្រា១៥ នៃកិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាចែងថា :

*“ជនគ្រប់រូបនៅកម្ពុជា និងជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ត្រូវមានសិទ្ធិ និងសេរីភាពដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ” ។*

ហត្ថលេខីទាំងអស់បានធ្វើការប្តេជ្ញាចិត្តមួយដ៏ជាក់លាក់ ដើម្បីធានាការគោរពសិទ្ធិមនុស្ស នៅកម្ពុជា គាំទ្រសិទ្ធិប្រជាពលរដ្ឋខ្មែរ ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ហើយចាត់វិធានការដ៏មានប្រសិទ្ធភាព “ដើម្បីធានាថា នយោបាយ និងការប្រព្រឹត្តពីអតីតកាល មិនអនុញ្ញាតឱ្យវិលត្រឡប់មកវិញទៀយ” ។

កិច្ចព្រមព្រៀងនេះក៏បានចែងអំពីការដាក់បញ្ចូលនូវសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ទៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ។ ឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងនេះចែងថា :

“ ប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្មនៅកម្ពុជា ទាមទារឱ្យមានវិធានការពិសេស

ដើម្បីធានាការការពារសិទ្ធិមនុស្ស ។ ហេតុដូច្នេះ រដ្ឋធម្មនុញ្ញត្រូវរួមមានសេចក្តីថ្លែងការណ៍មួយ អំពីសិទ្ធិជាមូលដ្ឋាននៅក្នុងនោះ មានសិទ្ធិមានជីវិតរស់នៅ សេរីភាពរបស់បុគ្គល សន្តិសុខ សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា រួមប្រជុំគ្នា និងបង្កើតសមាគមរួមទាំងការបង្កើតគណបក្សនយោបាយ និងសហជីព ដំណើរការតុលាការត្រឹមត្រូវ និងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំឱ្យមានការដកហូតកម្មសិទ្ធិតាមតែទំនើងចិត្ត ឬការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសងជម្ងឺចិត្តដ៏ត្រឹមត្រូវ និងសេរីភាពដោយគ្មានការប្រកាន់រើសអើងពូជសាសន៍ ជនជាតិ ជំនឿ សាសនា ឬភេទឡើយ ។ រដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់នូវការអនុវត្តន៍ច្បាប់ឧក្រិដ្ឋ ទៅលើឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអតីតកាល ។ សេចក្តីប្រកាសត្រូវសមស្របទៅនឹងប្រការទាំងឡាយនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ ។ បុគ្គលដែលត្រូវគេរំលោភបំពាន មានសិទ្ធិប្តឹងទៅតុលាការ ដើម្បីកាត់សេចក្តី និងធ្វើឱ្យគេគោរពសិទ្ធិទាំងអស់នេះ ។”

ស្របតាមបទបញ្ញត្តិនេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា បញ្ចូលសេចក្តីប្រកាសមួយស្តីពីសិទ្ធិជាមូលដ្ឋាន ក្នុងជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ។ បទបញ្ញត្តិមួយចំនួនទៀតនៃរដ្ឋធម្មនុញ្ញក៏មានចែងផងដែរ អំពីការការពារសិទ្ធិមនុស្ស ហើយត្រូវបានបញ្ចូលក្នុងក្រមច្បាប់នេះ ។

*ខ- សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ*

កិច្ចព្រមព្រៀងទីក្រុងប៉ារីស បានបញ្ចូលការប្តេជ្ញាចិត្តមួយដ៏ជាក់លាក់ ក្នុងការផ្តល់សច្ចាប័នសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ។ អាស្រ័យហេតុនេះ កម្ពុជាបានក្លាយជាភាគីនៃសន្ធិសញ្ញាទាំងឡាយខាងក្រោមនេះ :

អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (២៨ ធ្នូ ១៩៨៣)
កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (២៦ សីហា ១៩៩២)
កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (២៦ សីហា ១៩៩២)
អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (១៤ វិច្ឆិកា ១៩៩២)
អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប (១៤ វិច្ឆិកា ១៩៩២) និងពិធីសារបន្ថែមនៃអនុសញ្ញានេះ (២៩ មេសា ២០០៧)
អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៤ វិច្ឆិកា ១៩៩២) និងពិធីសារបន្ថែមពីរនៃអនុសញ្ញានេះ ។

ម្យ៉ាងវិញទៀត កម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិកម្មករទេសន្តរប្រវេសន៍

និងសមាជិកគ្រួសារទាំងអស់របស់ពួកគេ  អនុសញ្ញាស្តីពីសិទ្ធិជនពិការនិងពិធីសារបន្ថែមនៃអនុសញ្ញានេះ ព្រមទាំងពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីអោយពាក់ព័ន្ធនឹងនីតិវិធីបណ្តឹងបុគ្គល ។ ការចុះហត្ថលេខាលើសន្ធិសញ្ញានេះ  បង្ហាញអំពីចេតនារបស់រដ្ឋាភិបាល  ក្នុងការផ្តល់សច្ចាប័ននៅពេលដ៏ខ្លីខាងមុខ  ។

មាត្រា៣១  នៃរដ្ឋធម្មនុញ្ញ  ធានាការពារសន្ធិសញ្ញានីមួយៗទាំងនេះថាជាផ្នែកមួយនៃច្បាប់ជាតិ ហើយមាត្រា៤៨  ផ្តល់ការការពារបន្ថែមទៀត  ទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារ  ។

ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នមួយដែលបានបង្កើតឡើង ដើម្បីធានាការគោរពរដ្ឋធម្មនុញ្ញ ។ នៅក្នុងសេចក្តីសំរេចរបស់ខ្លួន  ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានបញ្ជាក់ជាថ្មីអំពីការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានានៅក្នុងច្បាប់កម្ពុជា ហើយបានរំលឹកចៅក្រមថា ក្នុងការសំរេចករណីរឿងផ្សេងៗ ចៅក្រមត្រូវយកច្បាប់កម្ពុជាទាំងអស់មកពិចារណា “រួមទាំងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល  និងច្បាប់ឯទៀតដែលនៅជាធរមាន  ព្រមទាំងអនុសញ្ញាអន្តរជាតិទាំងអស់ដែលកម្ពុជាបានទទួលស្គាល់.....”

អាស្រ័យហេតុនេះ  សិទ្ធិជនគ្រប់រូបនៅកម្ពុជា  គួរត្រូវបានគោរពយ៉ាងពេញលេញដោយច្បាប់កម្ពុជា  ក្រោមរដ្ឋធម្មនុញ្ញ  ស្របតាមគោលការណ៍នីតិរដ្ឋ  ។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស  បានកំណត់ឱ្យអង្គការសហប្រជាជាតិបន្តឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា  បន្ទាប់ពីសម័យអន្តរកាល  ហើយបច្ចុប្បន្ន  មុខងារនេះបាននឹងកំពុងបំពេញដោយតំណាងពិសេសរបស់លោកអគ្គលេខាធិការ  ស្របតាមអាណត្តិដែលផ្តល់ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស  ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានរក្សាទុកការិយាល័យមួយប្រចាំនៅកម្ពុជាតាំងពីឆ្នាំ១៩៩៣ ដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល ។  ការិយាល័យប្រចាំនៅកម្ពុជា គឺជាការិយាល័យមួយក្នុងចំណោមការិយាល័យប្រចាំតំបន់ឯទៀត ដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស  បានរក្សាទុកនៅក្នុងប្រទេសនានាជុំវិញពិភពលោក  ។

*ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា*

*ខែវិច្ឆិកា  ឆ្នាំ២០០៧*

# ក–សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

## ១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញ

នៃព្រះរាជាណាចក្រកម្ពុជា

សភាធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ/លេខ.../២៤ កញ្ញា ១៩៩៣/រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

**យើង**

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជា

យោងតាមមាត្រាទី១៣៥ និង១៣៦ នៃជំពូក១៤ ស្តីអំពីអន្តរប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា អនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ។

## ត្រាស់បង្គាប់

មាត្រា ១ : ប្រកាសឱ្យប្រើជាផ្លូវការភ្លាមនូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មនុញ្ញ បានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា គ.ស ១៩៩៣ ។

មាត្រា ២ : សភាធម្មនុញ្ញបានត្រឡប់ទៅជារដ្ឋសភានៃកម្ពុជាចាប់ពីពេលនេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកញ្ញា គ.ស ១៩៩៣

**នរោត្តម សីហនុ**

# បុព្វកថា

## យើងប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភ ធំទូលាយថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោក វិនាសអន្តរាយ ទ្រុឌទ្រោម ឱនថយមហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់អធ្ឋះមោះមុត ប្តូរផ្តាច់ រួបរួមគ្នាពង្រឹង ឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា "កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើង រីកចំរើនលូតលាស់ សម្បូររុងរឿង ជានិច្ចនិរន្តរ៍ ។

### ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :.......

[ នេះគ្រាន់តែជាសម្រង់រដ្ឋធម្មនុញ្ញនៃជំពូក និងមាត្រាដែលចារឹកទុកពីបទប្បញ្ញត្តិ ទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្សប៉ុណ្ណោះ]

### ជំពូកទី២: អំពីព្រះមហាក្សត្រ

មាត្រា ៨ :

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តភាពជាតិ ។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យនិងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋនិងការគោរពសន្ធិសញ្ញាអន្តរជាតិ។

### ជំពូកទី ៣: អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

មាត្រា ៣១ :

ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

មាត្រា ៤៨ :

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារ ក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើអោយខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខមាលភាពរបស់កុមារ ។

មាត្រា ៤៩ :

ប្រជាពលករដ្ឋខ្មែរគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិ ត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

មាត្រា ៥០ :

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធស្របច្បាប់របស់ឯកជន ។

## ជំពូកទី ៤: អំពីរបបនយោបាយ

មាត្រា ៥១ : -ថ្មី

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

## ជំពូកទី ៦: អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច

មាត្រា ៦៥ :

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំ ប្រកបដោយគុណភាព នៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីអោយការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ លើវិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

មាត្រា ៦៦ :

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាព នៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នា ក្នុងការកសាងជីវិត ។

មាត្រា ៦៨ :

រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សា នៅសាលារៀនសាធារណៈសំរាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិច ប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយ និងលើកតំកើងសាលាបាលី និងពុទ្ធិកសិក្សា ។

មាត្រា ៧២ :

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និងព្យាបាលជម្ងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគ ដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ។

មាត្រា ៧៣ :

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា ។ រដ្ឋរៀបចំអោយមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង ។

មាត្រា ៧៤ :

រដ្ឋជួយឧបត្ថម្ភជនពិការ និងគ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

មាត្រា ៧៥ :

រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គម ដល់កម្មករ និងនិយោជិក ។

## ជំពូកទី ១១ ថ្មី: អំពី អំណាចតុលាការ

មាត្រា ១២៨ : - ថ្មី (មាត្រា១០៩ ចាស់)

អំណាចតុលាការ ជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការ គ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំនុំជម្រះគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

មាត្រា ១២៩ : -ថ្មី (មាត្រា១១០ ចាស់)

ការជំនុំជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេ ដែលមានសិទ្ធិជំនុំជម្រះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

មាត្រា ១៣០ : - ថ្មី (មាត្រា១១១ ចាស់)

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ។

មាត្រា ១៣១ : - ថ្មី (មាត្រា១១២ ចាស់)

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

មាត្រា ១៣២ : - ថ្មី (មាត្រា១១៣ ចាស់)

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ :១៣១ /០០៣ /២០០៧
ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧

**សេចក្តីសម្រេច**
លេខ :០៩២/០០៣/២០០៧ កបធ.ច
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជសារ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ វេលាម៉ោង ១៤ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ព្រះរាជសាររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ បានធ្វើឡើងត្រឹមត្រូវតាមមាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។
- យល់ឃើញថា មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋបានចែងថា " ចំពោះបទឧក្រិដ្ឋ និងបទឧក្រិដ្ឋតម្រូវឱ្យធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានព្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមា ឬព្យួរទោសបានឡើយ ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើស មិនត្រូវទទួលរង

ទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្ដាមាត្រាមុនៗក្នុងរយៈពេល ៥ ឆ្នាំក្រោយពីការកាត់ទោសរបស់ខ្លួន " ។

- យល់ឃើញថា មាត្រា ៨ នេះ កែប្រែតែមាត្រា ៧០ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល **ពុំមានប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍កុមារឡើយ** ។ បទបញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋខាងលើនេះ ពុំមានអធម្មនុញ្ញភាពទេ ។
- យល់ឃើញថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់ ។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

**សម្រេច**

**មាត្រា ១.** មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

# ឧបសម្ព័ន្ធទី២ ៖
# សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

# សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

## អារម្ភកថា

*" មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាព ក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ " ( មាត្រា ២)*

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សត្រូវបានអនុម័ត ដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

មហាសន្និបាត អ.ស.ប បានប្រកាសជាសាធារណៈថា សេចក្តីប្រកាសជាសកលនេះគឺជា " ឧត្តមគតិរួមដែល ប្រជាពលរដ្ឋគ្រប់ៗប្រទេស និងប្រជាជាតិទាំងអស់ត្រូវធ្វើឱ្យ-បានសម្រេច" ។ សេចក្តីប្រកាសជាសកលនេះចែងអំពី ទស្សនៈរួមមួយ ស្តីអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន-ទាំងឡាយ ដែលរដ្ឋជាសមាជិកបានប្តេជ្ញាចិត្តអនុវត្តបញ្ញត្តិ

នៃធម្មនុញ្ញសហប្រជាជាតិឱ្យបានសំរេច ។ សេចក្តីប្រកាសនេះ ទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាពគ្នា និងសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់មនុស្សជាតិទាំងអស់ ដោយគ្មានការបែងចែក ។ រយៈពេលច្រើនឆ្នាំកន្លងមក សេចក្តីប្រកាសនេះបានទទួលកំលាំងខាងសីលធម៌មួយដែលមិនអាចវាស់វែងបាន ។

សេចក្តីប្រកាសជាសាកលនេះ ភ្ជាប់កាតព្វកិច្ចខាងផ្លូវច្បាប់ក្នុងប្រទេសកម្ពុជា ដោយបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ មាត្រា ៣១ ។

បទបញ្ញត្តិនៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ត្រូវបានបកប្រែបញ្ចូលដោយផ្ទាល់ទៅក្នុងឯកសារច្បាប់ចំនួនពីរគឺ ៖ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ កតិកាសញ្ញាទាំងនេះ រួមទាំងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀត ចែងលំអិតអំពី

របៀបដែលរដ្ឋនានាត្រូវអនុវត្តសិទ្ធិ និងសេរីភាពទាំងឡាយ ដែលមានចែងក្នុងសេចក្តីប្រកាស ។

សន្ធិសញ្ញាអន្តរជាតិដទៃទៀត បានកើតចេញពីសេចក្តី-ប្រកាសជាសាកល រួមមានអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់-រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាស្តីពីការ-បំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ អនុស-ញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប និង អនុសញ្ញាស្តីពីសិទ្ធិកុមារ ។ ប្រទេសកម្ពុជាគឺជាភាគីនៃ សន្ធិសញ្ញាទាំងនេះ ហើយដែលបានដាក់បញ្ចូលទៅក្នុងច្បាប់ ជាតិតាមរយៈរដ្ឋធម្មនុញ្ញ ។

ពាក្យពេចន៍នៅក្នុងសេចក្តីប្រកាសជាសកលចែងថា បុគ្គលគ្រប់ៗរូប និងអង្គការសង្គមទាំងអស់ត្រូវ *"ខិតខំប្រឹង-ប្រែង បណ្តុះបណ្តាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះ*

*តាមរយៈការបង្រៀន និងការអប់រំ ហើយនិងខំប្រឹងប្រែង ធានាឱ្យមានការទទួលស្គាល់ និងការអនុវត្តជាសាកល ជាក់ស្តែងនូវសិទ្ធិនិងសេរីភាព ដោយវិធានការជាតិ និងអន្តរ-ជាតិ ដែលមាន លក្ខណៈរីកចម្រើនជាលំដាប់ " ។*

ដើម្បីរំលឹកនូវថ្ងៃអនុម័តសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ត្រូវបានគេកំណត់យកដើម្បីប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិនៅប្រទេសកម្ពុជា និងនៅទូទាំងពិភពលោក ។

# សេចក្ដីប្រកាសជាសកល
# ស្ដីពីសិទ្ធិមនុស្ស

អនុម័តនិងប្រកាសដោយសេចក្ដីសម្រេចចិត្តនៃមហាសន្និបាត លេខ ២១៧ A (III) នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨

## បុព្វកថា

*ដោយយល់ឃើញថា* ការទទួលស្គាល់សេចក្ដីថ្លៃថ្នូរ ជាប់ពីកំណើតរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ហើយ និងការទទួលស្គាល់សិទ្ធិស្មើភាពគ្នានិងសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន ជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាព ក្នុងពិភពលោក ។

*ដោយយល់ឃើញថា* ការមិនទទួលស្គាល់និងការប្រមាថ មើលងាយសិទ្ធិមនុស្ស បាននាំទៅកាន់អំពើព្រៃផ្សៃសាហាវ យង់ឃ្នង ធ្វើឱ្យក្ដៅក្រហាយដល់សតិសម្បជញ្ញៈមនុស្សជាតិ

និង *ដោយយល់ឃើញថា* ការកើតឡើងនូវពិភពលោកមួយ ដែលមនុស្សជាតិត្រូវមានសេរីភាពក្នុងការនិយាយស្តី និង ជំនឿរួចផុតពីភាពភ័យខ្លាចនិងទុគ៌តភាព ត្រូវបានប្រកាស ថាជាសេចក្តីប្រាថ្នាដ៏ខ្ពស់បំផុតរបស់មនុស្សទូទៅ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ដែលសិទ្ធិមនុស្សត្រូវ តែបានការពារដោយនីតិរដ្ឋ ដើម្បីជៀសវាង កុំឱ្យមនុស្សបង្ខំ ចិត្តជាចុងក្រោយបង្អស់ បះបោរប្រឆាំងទល់នឹងអំណាច ផ្តាច់ការ និងការគាបសង្កត់ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ដែលត្រូវលើកស្ទួយ ការពង្រីកទំនាក់ទំនងជាមិត្តភាព រវាងប្រជាជាតិនានា ។

*ដោយយល់ឃើញថា* ប្រជាពលរដ្ឋទាំងអស់នៃសហ-ប្រជាជាតិ បានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហ-ប្រជាជាតិ នូវជំនឿរបស់ខ្លួនទៅលើសិទ្ធិមូលដ្ឋាននៃមនុស្ស លើសេចក្តីថ្លៃថ្នូរ លើតម្លៃរបស់មនុស្សនិងលើសមភាពនៃ

សិទ្ធិរវាងបុរសនិងស្ត្រី ហើយប្តេជ្ញាលើកស្ទួយវឌ្ឍនភាព សង្គមនិងកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើងក្នុង សេរីភាពកាន់តែទូលំទូលាយ ។

*ដោយយល់ឃើញថា* ក្នុងកិច្ចសហប្រតិបត្តិការជាមួយ អង្គការសហប្រជាជាតិ រដ្ឋជាសមាជិកទាំងអស់សន្យានិងធានា គោរពសិទ្ធិសកល និងសេរីភាពមូលដ្ឋានឱ្យបានសម្រេច ។

*ដោយយល់ឃើញថា* ទស្សនៈរួមមួយស្តីអំពីសិទ្ធិ និង សេរីភាពទាំងនេះ មានសារសំខាន់បំផុត ដើម្បីបំពេញនូវការ សន្យាខាងលើ

## ***អាស្រ័យហេតុនេះមហាសន្និបាតប្រកាសថា :***

*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនេះ* ជាឧត្តមគតិ រួមដែលប្រជាពលរដ្ឋគ្រប់ៗប្រទេស និង ប្រជាជាតិទាំងអស់ ត្រូវធ្វើឱ្យបានសម្រេច ដើម្បីឱ្យបុគ្គលគ្រប់ៗរូបនិងអង្គការ

សង្គមទាំងអស់ ដោយរក្សាខ្ជាប់ជានិច្ចក្នុងស្មារតីរបស់ខ្លួននូវសេចក្តីប្រកាសនេះ ខិតខំប្រឹងប្រែងបណ្តុះបណ្តាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះតាមរយៈការបង្រៀន និងការអប់រំ ហើយនិងខំប្រឹងប្រែងធានាឱ្យមានការទទួលស្គាល់ និងការអនុវត្តជាសកលជាក់ស្តែងនូវសិទ្ធិនិងសេរីភាព ដោយវិធានការជាតិនិងអន្តរជាតិ ដែលមានលក្ខណៈរីកចម្រើនជាលំដាប់ ទាំងក្នុងចំណោមប្រជាពលរដ្ឋនៃរដ្ឋសមាជិក ទាំងក្នុងចំណោមប្រជាពលរដ្ឋដែនដី ដែលស្ថិតនៅក្រោមអំណាចនៃរដ្ឋទាំងនោះផង ។

**មាត្រា ១**

មនុស្សទាំងអស់កើតមកមានសេរីភាពនិងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរនិងសិទ្ធិ ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីភាតរភាពជាបងប្អូន ។

## មាត្រា ២

១. មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិនិងសេរីភាពទាំងអស់ ដែលបានប្រកាសក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។

២. លើសពីនេះ មិនត្រូវធ្វើការប្រកាន់បែងចែកណាមួយ ដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងយុត្តាធិការ ឬខាងអន្តរជាតិរបស់ប្រទេសឬដែនដីដែលបុគ្គលណាម្នាក់រស់នៅ ទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យក្តី ស្ថិតក្រោមអាណាព្យាបាលក្តី ឬគ្មានស្វ័យគ្រប់គ្រងក្តី ឬស្ថិតក្រោមការដាក់កម្រិតផ្សេងទៀតណាមួយនៃអធិបតេយ្យភាពក្តី ។

## មាត្រា ៣

បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

## មាត្រា ៤

គ្មានជនណាម្នាក់ត្រូវស្ថិតក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើដាច់ថ្លៃឡើយ។ ទាសភាព និងទាសពាណិជ្ជកម្ម ត្រូវហាមឃាត់ ទោះតាមទម្រង់ណាក៏ដោយ។

## មាត្រា ៥

គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មកាចសាហាវ ឥតមនុស្សធម៌ ឬថោកទាបបានឡើយ។

## មាត្រា ៦

មនុស្សម្នាក់ៗ មានសិទ្ធិឱ្យទទួលស្គាល់ពីបុគ្គលិក

លក្ខណៈឥតិយុត្តរបស់ខ្លួន នៅគ្រប់ទីកន្លែង។

**មាត្រា ៧**

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមាន-សិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។ មនុស្សគ្រប់រូប មានសិទ្ធិទទួលការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណា ដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឱ្យមានការរើសអើង។

**មាត្រា ៨**

មនុស្សគ្រប់រូប មានសិទ្ធិរកដំណោះស្រាយជាក់ស្តែងមួយនៅចំពោះមុខសាលាជំរះក្តីជាតិ ដែលមានសមត្ថកិច្ចចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួនដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់។

## មាត្រា ៩

គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន ដោយបំពានឡើយ ។

## មាត្រា ១០

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យនិងមិនលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិកាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ ។

## មាត្រា ១១

១. ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោសរហូតដល់ពិរុទ្ធភាព ត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីការពារសិទ្ធិជនជាប់ចោទ ពីបទល្មើសព្រហ្មទណ្ឌ ។

២. គ្មានជនណាម្នាក់ត្រូវបានផ្ដន្ទាទោសពីបទល្មើស ព្រហ្មទណ្ឌ ដោយបានប្រព្រឹត្ត ឬភ្លាំងភ្លាត់ប្រព្រឹត្ត ដែលអំពើ-នេះមិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិ ។ មិនត្រូវផ្ដន្ទា-ទោសឱ្យធ្ងន់ជាងទោសដែលបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេលបទល្មើសបានកើតឡើងឡើយ ។

**មាត្រា ១២**

គ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែក-តាមអំពើចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ការឆ្លើយឆ្លង ឬការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ ។ ជនគ្រប់រូប មានសិទ្ធិទទួលការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់ទាំងនេះ ។

**មាត្រា ១៣**

១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋមួយ ។

២. មនុស្សគ្រប់រូប មានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ ។

## មាត្រា ១៤

១. មនុស្សគ្រប់រូប មានសិទ្ធិស្វែងរកនិងទទួលកន្លែងជ្រកកោនក្នុងប្រទេសដទៃទៀត ក្នុងករណីមានការធ្វើទុក្ខបុកម្នេញមកលើខ្លួន ។

២. សិទ្ធិសុំជ្រកកោននេះមិនអាចលើកមកសំអាងបានទេ ក្នុងករណីមានការចោទប្រកាន់ពីបទល្មើស នៃនីតិរូប ឬពីការប្រព្រឹត្តណាដែលផ្ទុយពីគោលបំណង និងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិ ។

## មាត្រា ១៥

១. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិមួយ ។

២. គ្មានជនណាម្នាក់អាចត្រូវដកហូតសញ្ជាតិ ឬរារាំងសិទ្ធិប្តូរសញ្ជាតិរបស់ខ្លួន ដោយរំលោភបានឡើយ ។

**មាត្រា ១៦**

១. បុរសនិងស្ត្រី មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារ ដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ ។ បុរសនិងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ក្នុងចំណងអាពាហ៍ពិពាហ៍ និងក្នុងពេលរំលាយអាពាហ៍ពិពាហ៍ ។

២. អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញ ពីអនាគតប្តីប្រពន្ធ ។

៣. គ្រួសារជាធាតុធម្មជាតិ និងជាធាតុមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ ។

### មាត្រា ១៧

១. មនុស្សគ្រប់រូប ទោះជាបុគ្គលក្តី សមូហភាពក្តី មាន-សិទ្ធិជាម្ចាស់កម្មសិទ្ធិ។

២. គ្មានជនណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិដោយបំពានឡើយ ។

### មាត្រា ១៨

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះ រាប់បញ្ចូលទាំង-សេរីភាពផ្លាស់ប្តូរសាសនា ឬជំនឿ ព្រមទាំងសេរីភាពសម្តែង-សាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯង ឬ ជារួម ជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្តជាទម្លាប់ ការគោរពបូជា ព្រមទាំងតាមការប្រារព្ធពិធីសក្ការៈផ្សេងៗ។

### មាត្រា ១៩

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និង-

ការសម្តែងមតិ ។ សិទ្ធិនេះ រាប់បញ្ចូលទាំង សេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួល និងការផ្សព្វផ្សាយពត៌មាននិងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ ។

## មាត្រា ២០

១. មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬការបង្កើតសមាគមដោយសន្តិវិធី ។

២. គ្មានជនណាម្នាក់ ត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសមាគមណាមួយឡើយ ។

## មាត្រា ២១

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី ។

២. មនុស្សគ្រប់រូប មានសិទ្ធិចូលបម្រើមុខងារសា-ធារណៈនៃប្រទេសរបស់ខ្លួន ក្នុងល័ក្ខខ័ណ្ឌសមភាព។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ ជាមូលដ្ឋានអំណាចនៃការដឹកនាំកិច្ចការសាធារណៈ។ ឆន្ទៈនេះ ត្រូវសម្តែងចេញតាម-រយៈការបោះឆ្នោតយ៉ាងទៀងទាត់ តាមពេលកំណត់ និងពិតប្រាកដ មានលក្ខណៈសកល ស្មើភាព និងបោះឆ្នោតដោយសម្ងាត់ ឬតាមនីតិវិធីសមមូល ដែលធានាសេរីភាពនៃការ-បោះឆ្នោត។

**មាត្រា ២២**

ក្នុងឋានៈជាសមាជិកនៃសង្គម មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសន្តិសុខសង្គម និងមានបុព្វសិទ្ធិ ទទួលបានសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចាំបាច់សម្រាប់សេចក្តីថ្លៃថ្នូរ និងការរីកចំរើនដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួន តាមរយៈការខិតខំរបស់ជាតិ និងកិច្ចសហប្រតិបត្តិ-ការអន្តរជាតិ ស្របតាមការរៀបចំ និងតាមធនធានរបស់

ប្រទេសនីមួយៗ។

**មាត្រា ២៣**

១. មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ ជ្រើសរើសការ-ងារដោយសេរី និងធ្វើការងារក្នុងល័ក្ខខ័ណ្ឌ ត្រឹមត្រូវនិងពេញចិត្ត ព្រមទាំងការពារប្រឆាំងនឹងភាពអត់ការងារធ្វើ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា ដោយគ្មានការរើសអើង។

៣. អ្នកធ្វើការងារ មានសិទ្ធិទទួលបានលាភការដោយសមធម៌និងពេញចិត្ត ដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួន និងគ្រួសារ ឱ្យសមស្របនឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស និងត្រូវបានបំពេញបន្ថែមទៀត តាមមធ្យោបាយផ្សេងៗនៃការការ-ពារផ្នែកសង្គមប្រសិនបើចាំបាច់។

៤. មនុស្សគ្រប់រូប មានសិទ្ធិបង្កើត និងចូលរួមសហជីព

ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

## មាត្រា ២៤

មនុស្សគ្រប់រូប មានសិទ្ធិឈប់សម្រាកនិងលំហែកំសាន្ត រួមបញ្ចូលទាំងកម្រិតម៉ោងការងារសមហេតុផល និងការឈប់សម្រាកដោយបានប្រាក់បៀវត្សតាមពេលកំណត់។

## មាត្រា ២៥

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាពនិងសុខុមាលភាពរបស់ខ្លួននិងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គម កិច្ចចាំបាច់ផ្សេងៗទៀត។ មនុស្សគ្រប់រូបមាន សិទ្ធិទទួលបានការគាំពារ នៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយឬពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាព ដែលបណ្ដាលមកពី កាលៈទេសៈផុតពីឆន្ទៈរបស់ខ្លួន។

២. មាតុភាព និងកុមារភាព មានសិទ្ធិទទួលជំនួយ និង-ការថែទាំពិសេស ។ កុមារគ្រប់រូប ទោះកើតពីឪពុកម្ដាយមានខាន់ស្លា ឬឥតខាន់ស្លាក្ដី ត្រូវបានទទួលការពារខាងសង្គមកិច្ចដូចគ្នា ។

## មាត្រា ២៦

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ ។ ការអប់រំត្រូវឥតបង់ថ្លៃ យ៉ាងហោចណាស់ សម្រាប់ការអប់រំបឋមសិក្សា និងអប់រំមូលដ្ឋាន ។ ការអប់រំបឋមសិក្សាគឺជាកាតព្វកិច្ច ។ ការអប់រំខាងបច្ចេក ទេសនិងវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានជាទូទៅ ។ ការអប់រំឧត្ដមសិក្សា ត្រូវបើកឱ្យចូលរៀនស្មើភាពគ្នាដោយឈរលើមូលដ្ឋានសមត្ថភាព ។

២. ការអប់រំត្រូវសំដៅទៅរកការរីកលូតលាស់ពេញ-លេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការពង្រឹងការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ។ ការអប់រំនេះ

ត្រូវលើកកំពស់ការយល់ដឹងការអត់ឱន អធ្យាស្រ័យគ្នានិង មិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមសាសនា ទាំងអស់ ព្រមទាំងការអភិវឌ្ឍន៍សកម្មភាពរបស់សហ-ប្រជាជាតិ ក្នុងការថែរក្សាសន្តិភាព។

៣. មាតាបិតា មានសិទ្ធិជាអាទិភាព ក្នុងការជ្រើសរើស ប្រភេទនៃការអប់រំសម្រាប់បុត្រធីតារបស់ខ្លួន។

**មាត្រា ២៧**

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមដោយសេរី ក្នុងជីវ-ភាពវប្បធម៌របស់សហគមន៍ រីករាយនឹងសិល្បៈ និងចូលរួម-ចំណែកក្នុងវឌ្ឍនភាពវិទ្យាសាស្ត្រ និងបានទទួលផល-ប្រយោជន៍ពីលទ្ធផលវឌ្ឍនភាពនេះ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការការពារផ-លប្រយោជន៍ខាងសីលធម៌ និងសម្ភារៈ ដែលបានមកពី ផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈ ដែល-

ជាស្នាដៃរបស់ខ្លួន។

**មាត្រា ២៨**

មនុស្សគ្រប់រូប មានសិទ្ធិចូលរួមគ្រប់គ្រងសណ្តាប់ធ្នាប់សង្គមនិងអន្តរជាតិ ដែលសិទ្ធិនិងសេរីភាព ចែងក្នុងសេចក្តីប្រកាសនេះ អាចត្រូវសម្រេចឱ្យបានដោយពេញលេញ។

**មាត្រា ២៩**

១. មនុស្សគ្រប់រូប មានករណីយកិច្ចចំពោះសហគមន៍ដែលជាកន្លែងតែមួយគត់ អាចបង្កើតបានការរីកចម្រើនដោយសេរីនិងពេញបរិបូរណ៍នូវបុគ្គលិកលក្ខណៈរបស់ខ្លួន។

២. ក្នុងការប្រើសិទ្ធិនិងសេរីភាពរបស់ខ្លួន មនុស្សគ្រប់រូបត្រូវស្ថិតនៅត្រឹមកម្រិតដែលច្បាប់បានកំណត់តែប៉ុណ្ណោះ ក្នុងគោលបំណងធានាការទទួលស្គាល់ និងការគោរពសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ និង ដើម្បីបំពេញសេចក្តីត្រូវការយ៉ាងត្រឹមត្រូវខាងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ និង-

សុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យ ។

៣. គ្មានករណីណាមួយ ដែលសិទ្ធិនិងសេរីភាពទាំងនេះ អាចយកទៅប្រើប្រាស់ផ្ទុយនឹងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិឡើយ ។

**មាត្រា ៣០**

គ្មានបទបញ្ញត្តិណាមួយនៃសេចក្តីប្រកាសនេះ អាចត្រូវ-បានបកស្រាយ ដែលបណ្តាលឱ្យរដ្ឋណាមួយ ក្រុមណាមួយ ឬបុគ្គលណាម្នាក់ មានសិទ្ធិបែបណាមួយដើម្បីធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយ សំដៅបំផ្លិចបំផ្លាញនូវសិទ្ធិនិងសេរី-ភាពទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីប្រកាស-នេះឡើយ ។

# ឧបសម្ព័ន្ធទី៣ ៖
# សំណួរ និងចម្លើយ សិទ្ធិមនុស្ស
# រៀបរៀងសហភាពអឺរ៉ុប


សំណួរ & ចម្លើយ
សិទ្ធិមនុស្ស ៨
សហភាពអឺរ៉ុប
សហភាពអឺរ៉ុប

សៀវភៅនេះត្រូវបានរៀបរៀង និងបោះពុម្ពផ្សព្វផ្សាយក្រោមជំនួយឧបត្ថម្ភរបស់សហភាពអឺរ៉ុប។ ទស្សនៈនិងបទបង្ហាញនានាក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ហើយវាមិនមែនជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ ។

បោះពុម្ពឆ្នាំ២០១៩
Published in 2019

សំណួរ & ចម្លើយ

១

# តើអ្វីជាសិទ្ធិមនុស្សរបស់ខ្ញុំ ?

សិទ្ធិមនុស្សគឺជាសិទ្ធិ និងសេរីភាពដែលខ្ញុំមាន និងទទួលបាន ដោយសារតែខ្ញុំជាមនុស្ស។ ឧទាហរណ៍សិទ្ធិទទួលបានការអប់រំ សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ សិទ្ធិសេរីភាពដើរហើរក្នុងប្រទេស សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន សិទ្ធិសេរីភាពជួបជុំ សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈរបស់រដ្ឋ។ល។

សេរីភាព និងសិទ្ធិដែលខ្ញុំមាននេះធ្វើឲ្យខ្ញុំអាចរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ក្នុងភាពជាមនុស្សមួយរូប។

សិទ្ធិមនុស្សខ្លះគឺជាសេរីភាព។ នេះមានន័យថា ខ្ញុំអាចប្រើសិទ្ធិទាំងនេះដោយគ្មានអ្នកណាមួយបញ្ឈប់ខ្ញុំបានឡើយ ។ ឧទាហរណ៍ ខ្ញុំមានសិទ្ធិដើរហើរ មានន័យថា ខ្ញុំអាចចេញចូលប្រទេសខ្ញុំនៅពេលណាក៏បានតាមដែលខ្ញុំចង់។

សិទ្ធិមនុស្សខ្លះទៀត តម្រូវឲ្យរដ្ឋាភិបាលត្រូវតែធ្វើអ្វីមួយ ដើម្បីធ្វើឲ្យប្រាកដថា ខ្ញុំទទួលបានសិទ្ធិរបស់ខ្ញុំ។ ឧទាហរណ៍ ខ្ញុំមានសិទ្ធិទទួលបានការអប់រំ មានន័យថា រដ្ឋាភិបាលត្រូវតែបង្កើតគោលនយោបាយមួយដែលតម្រូវឲ្យកុមារត្រូវតែទទួលបានការអប់រំនៅបឋមសិក្សាដោយមិនគិតថ្លៃ។

សំណួរ & ចម្លើយ

២



# ហេតុអ្វីបានជាសិទ្ធិមនុស្ស សំខាន់សម្រាប់ជីវិតរបស់ខ្ញុំ ?

សិទ្ធិមនុស្សសំខាន់សម្រាប់ជីវិតខ្ញុំ ពីព្រោះសិទ្ធិមនុស្សជួយខ្ញុំឲ្យរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។ សិទ្ធិមនុស្ស អាចឲ្យខ្ញុំចូលរួមក្នុងសកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌នានា។

សិទ្ធិមនុស្សការពារមិនឲ្យគេធ្វើបាប ឬរំលោភបំពានមកលើរូបខ្ញុំ។ សិទ្ធិមនុស្សធានាអោយខ្ញុំទទួលបានអ្វីៗជាច្រើន ដូចជាយុត្តិធម៌ និងភាពត្រឹមត្រូវ លក្ខខណ្ឌការងារល្អ ការអប់រំល្អ មានកម្រិតជីវភាពរស់នៅសមរម្យនិងទទួលបានកិច្ចគាំពារសុខភាព។ សិទ្ធិមនុស្សធានាថាខ្ញុំអាចប្រើជំនាញ និងទេពកោសល្យរបស់ខ្ញុំដោយសេរី និងបញ្ចេញគំនិតរបស់ខ្ញុំផងដែរ។

សំណួរ & ចម្លើយ

៣



# ហេតុអ្វីបានជាសិទ្ធិមនុស្ស សំខាន់សម្រាប់សង្គមរបស់ខ្ញុំ ?

សិទ្ធិមនុស្សជួយកសាងសង្គមមួយដែលយើងគោរព និងជួយគ្នាទៅវិញទៅមក។ សិទ្ធិមនុស្សជានាំឲ្យមានសន្តិភាពតាមរយៈការជួយបញ្ចៀសការគាបសង្កត់ និងតាមរយៈការពង្រឹងយុត្តិធម៌។ សិទ្ធិមនុស្សធ្វើឲ្យបុគ្គលគ្រប់រូបមានការអភិវឌ្ឍតាមរយៈការលើកកម្ពស់សមភាព សេចក្តីថ្លៃថ្នូរ និងការទទួលបានសេវា និងទំនិញចាំបាច់ជាមូលដ្ឋាន។

សំណួរ & ចម្លើយ
៤



# តើអ្នកណាខ្លះមានសិទ្ធិមនុស្ស ?

បុគ្គលគ្រប់រូបមានសិទ្ធិមនុស្សដូចៗគ្នា  មិនថាក្មេងស្រី ក្មេងប្រុស បុរស ស្ត្រី ទោះចាស់ ឬក្មេង ក្រ ឬមាន ជាអ្នកមាន ឬគ្មានអំណាច ជាមនុស្សសំខាន់ ឬក៏អត់ ទោះបីអ្នកនោះមាន គំនិតខុសគ្នា ជំនឿ ឬសាសនាផ្សេងគ្នា ឬនិយាយភាសាផ្សេងគ្នា ឬមកពីប្រទេសផ្សេងក៏ដោយ។

សំណួរ & ចម្លើយ

៥



# តើសិទ្ធិមនុស្សនីមួយៗ មានទំនាក់ទំនងគ្នាឬទេ ?

សិទ្ធិមនុស្សនីមួយៗមានទំនាក់ទំនងគ្នា និងពឹងផ្អែកគ្នាទៅវិញទៅមកដែរ។ នេះមានន័យថា នៅពេលដែលខ្ញុំអាចអនុវត្តសិទ្ធិមួយជាក់លាក់ សិទ្ធិនោះនឹងជួយឲ្យខ្ញុំទទួលបានប្រយោជន៍ពីសិទ្ធិផ្សេងៗទៀតដែរ។ ទន្ទឹមគ្នានេះដែរ ប្រសិនបើសិទ្ធិណាមួយរបស់ខ្ញុំត្រូវបានគេរំលោភបំពាននោះ សិទ្ធិផ្សេងៗទៀតរបស់ខ្ញុំ ក៏អាចនឹងត្រូវរងផលប៉ះពាល់ដែរ។

ឧទាហរណ៍ ខ្ញុំមានសិទ្ធិចូលរួមក្នុងការពិភាក្សាអំពីផែនការអភិវឌ្ឍន៍សហគមរបស់ខ្ញុំ។ ដើម្បីឲ្យខ្ញុំអាចអនុវត្តសិទ្ធិ (ចូលរួមក្នុងការពិភាក្សា) នេះបាន ខ្ញុំក៏ត្រូវការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដែលរួមមានសិទ្ធិសេរីភាពទទួលបានព័ត៌មាន និងសិទ្ធិសេរីភាពក្នុងការនិយាយស្តីនៅក្នុងកិច្ចប្រជុំពិភាក្សានោះផងដែរ។

សំណួរ & ចម្លើយ

៦



# តើសិទ្ធិមនុស្សជាក់លាក់អ្វីខ្លះដែលខ្ញុំមាន ?

សិទ្ធិមនុស្ស ត្រូវបានបែងចែកជាពីរក្រុមសំខាន់ៗ។ ក្រុមទីមួយ គឺសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមានដូចជា៖

- សិទ្ធិរបស់ខ្ញុំក្នុងការរស់រានមានជីវិត
- សេរីភាពរបស់ខ្ញុំក្នុងការនិយាយស្តី សេរីភាពក្នុងការទទួលបានព័ត៌មាន និងការចែករំលែកព័ត៌មាន (សេរីភាពនៃការបញ្ចេញមតិ)
- សេរីភាពរបស់ខ្ញុំក្នុងការជួបជុំ និងសេរីភាពធ្វើបាតុកម្មដោយសន្តិវិធីជាមួយអ្នកដទៃ (សេរីភាពជួបជុំ)
- សេរីភាពរបស់ខ្ញុំក្នុងការបង្កើត ឬចូលរួមក្នុងក្រុមដែលខ្ញុំពេញចិត្ត (សេរីភាពក្នុងការបង្កើត និងចូលរួមក្នុងសមាគម)
- សេរីភាពរបស់ខ្ញុំចាកផុតពីការធ្វើទារុណកម្ម ឬត្រូវបានគេប្រើប្រាស់ដូចជាទាសករ
- សិទ្ធិរបស់ខ្ញុំក្នុងការប្រកួតប្រជែងក្នុងការបោះឆ្នោត និងចូលរួមក្នុងជីវភាពនយោបាយ និងក្នុងការដឹកនាំកិច្ចការសាធារណៈ សិទ្ធិរបស់ខ្ញុំក្នុងការជ្រើសរើសអ្នកដែលខ្ញុំចង់ឲ្យដឹកនាំប្រទេស ឬសហគមន៍របស់ខ្ញុំ

- សិទ្ធិរបស់ខ្ញុំក្នុងការមានភាពស្មើគ្នាចំពោះមុខច្បាប់
- សិទ្ធិជនភាគតិចក្នុងការនិយាយភាសារបស់ពួកគេ
- និងរួមជាមួយនឹងសិទ្ធិដទៃទៀត។

ក្រុមទីពីរ គឺសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានដូចជា៖

- សិទ្ធិរបស់ខ្ញុំក្នុងការធ្វើការដោយមានលក្ខខណ្ឌការងារល្អ
- សិទ្ធិរបស់ខ្ញុំក្នុងការទទួលបានប្រាក់ឈ្នួល ស្មើគ្នាដូចអ្នកដទៃសម្រាប់ការងារដូចគ្នា
- សិទ្ធិរបស់ខ្ញុំក្នុងការបង្កើត និងចូលរួមក្នុងសហជីព
- សិទ្ធិរបស់ខ្ញុំក្នុងការទទួលបានរបបសន្តិសុខសង្គម (ការជួយពីរដ្ឋាភិបាល)
- សិទ្ធិទទួលបានកម្រិតជីវភាពរស់នៅសមរម្យ សិទ្ធិទទួលបានស្បៀងអាហារ សម្លៀកបំពាក់ និងលំនៅដ្ឋានសមរម្យ
- សិទ្ធិរបស់ខ្ញុំក្នុងការទទួលបានកិច្ចគាំពារសុខភាព
- សិទ្ធិរបស់ខ្ញុំក្នុងការទទួលបានការអប់រំ
- សិទ្ធិរបស់ខ្ញុំក្នុងការទទួលបានការការពារសម្រាប់ការបង្កើតថ្មីរបស់ខ្ញុំ
- និងសិទ្ធិដទៃទៀត។

សំណួរ & ចម្លើយ
៧



# តើអ្នកណាខ្លះត្រូវគោរពសិទ្ធិមនុស្សរបស់ខ្ញុំ ?

រដ្ឋមានទំនួលខុសត្រូវមុនគេបង្អស់ក្នុងការគោរពសិទ្ធិមនុស្សរបស់ខ្ញុំ។ ទោះជាដូច្នេះក្តី មនុស្សគ្រប់រូប រួមទាំងបុគ្គល វិស័យឯកជន (អ្នករកស៊ី និងអ្នកជំនួញ)និងអ្នកផ្សេងៗទៀតមានកាតព្វកិច្ចគោរពសិទ្ធិមនុស្សទាំងអស់របស់ខ្ញុំ។ ហើយខ្ញុំក៏មានកាតព្វកិច្ចត្រូវគោរពសិទ្ធិអ្នកដទៃផងដែរ។

សំណួរ & ចម្លើយ ៨



# តើរដ្ឋាភិបាលត្រូវធ្វើដូចម្តេចខ្លះ ដើម្បីការពារសិទ្ធិមនុស្ស ?

ច្បាប់សិទ្ធិមនុស្សអន្តរជាតិតម្រូវឲ្យរដ្ឋាភិបាលធានាការពារសិទ្ធិមនុស្ស ហើយរដ្ឋាភិបាលមានកាតព្វកិច្ចបីសំខាន់ៗ៖

ក. កាតព្វកិច្ច**គោរព**សិទ្ធិមនុស្សរបស់ខ្ញុំដែលមានន័យថារដ្ឋមិនត្រូវធ្វើអ្វីមួយរំលោភបំពានសិទ្ធិរបស់ខ្ញុំ។ ឧទាហរណ៍ រដ្ឋមិនត្រូវធ្វើអ្វីមួយ ក្នុងការរារាំងខ្ញុំមិនឲ្យទៅសាលារៀនឡើយ ។

ខ. កាតព្វកិច្ច **ការពារ**សិទ្ធិមនុស្សរបស់ខ្ញុំ មានន័យថា រដ្ឋត្រូវបង្ការ និងទប់ស្កាត់អ្នកដទៃកុំឲ្យមកជ្រៀតជ្រែករំខានដល់ការអនុវត្តសិទ្ធិរបស់ខ្ញុំ។ ឧទាហរណ៍ ប្រសិនជាមាននរណាម្នាក់ធ្វើបាបខ្ញុំ រដ្ឋត្រូវផ្តន្ទាទោសបុគ្គលនោះទៅតាមច្បាប់ និងផ្តល់សំណងដល់ខ្ញុំ។

គ. កាតព្វកិច្ច**បំពេញ** មានន័យថា រដ្ឋចាំបាច់ត្រូវចាត់វិធានការសមស្រប រួមទាំងការបង្កើតច្បាប់ និងគោលនយោបាយផ្សេងៗដើម្បីឲ្យខ្ញុំអាចអនុវត្តសិទ្ធិរបស់ខ្ញុំបាន។ ឧទាហរណ៍ រដ្ឋត្រូវបង្កើតគោលនយោបាយមួយតម្រូវឲ្យកុមារត្រូវតែទៅរៀនយ៉ាងហោចណាស់ចប់បឋមសិក្សាដោយមិនគិតថ្លៃ។

សំណួរ & ចម្លើយ
៩



# តើការរំលោភសិទ្ធិមនុស្ស កើតឡើងនៅពេលណា ?

ការរំលោភសិទ្ធិមនុស្សកើតឡើង នៅពេលដែលរដ្ឋាភិបាលមិនបំពេញកាតព្វកិច្ចណាមួយរបស់ខ្លួន គឺកាតព្វកិច្ចគោរព ការពារ និងបំពេញ ។

ការរំលោភសិទ្ធិមនុស្សអាចកើតមានក្នុងរូបភាពផ្សេងៗ។ សិទ្ធិរបស់ខ្ញុំអាចត្រូវបានរំលោភបំពាន ដោយសារតែច្បាប់។ ឧទាហរណ៍ ប្រសិនជាច្បាប់អនុញ្ញាតឲ្យគេចាប់ខ្ញុំដាក់ពន្ធនាគារ ដោយគ្រាន់តែខ្ញុំរិះគន់រដ្ឋាភិបាល។

សិទ្ធិរបស់ខ្ញុំ ក៏អាចត្រូវបានរំលោភបំពានផងដែរ នៅពេលដែលនរណាម្នាក់ធ្វើអ្វីមួយមិនគប្បីចំពោះខ្ញុំ។ ឧទាហរណ៍ នៅពេលដែលនគរបាល ឬនរណាម្នាក់វាយ ឬប្រព្រឹត្តមិនគប្បីមកលើខ្ញុំ ហើយរដ្ឋាភិបាលមិនបានធ្វើអ្វីដើម្បីការពារខ្ញុំ ឬដាក់ទោសជនល្មើស។

សិទ្ធិរបស់ខ្ញុំត្រូវបានរំលោភបំពានផងដែរ ពីព្រោះរដ្ឋាភិបាលឧកខានមិនបានធ្វើអ្វីមួយ។ ឧទាហរណ៍ ដូចជាមិនបង្កើតគោលនយោបាយមួយ ដែលតម្រូវឲ្យកុមារគ្រប់រូបត្រូវតែទៅរៀនយ៉ាងហោចណាស់ចប់បឋមសិក្សាដោយឥតបង់ថ្លៃ។

សំណួរ & ចម្លើយ

១០



# តើមានអ្វីកើតឡើង ប្រសិនជារដ្ឋាភិបាលប្រទេសខ្ញុំ មិនគោរពសិទ្ធិមនុស្សរបស់ខ្ញុំ ?

ប្រសិនជារដ្ឋាភិបាលខ្ញុំ មិនគោរពសិទ្ធិមនុស្សរបស់ខ្ញុំ មានន័យថារដ្ឋាភិបាល រំលោភច្បាប់សិទ្ធិមនុស្សជាតិ និងអន្តរជាតិហើយ។ នៅពេលមានករណីនេះកើតឡើង ខ្ញុំត្រូវប្ដឹងទៅស្ថាប័នមួយចំនួន ដូចជាតុលាការនៅក្នុងប្រទេសរបស់ខ្ញុំ ដើម្បីទទួលបានដំណោះស្រាយដូចជាសំណងជាដើម។ ក្នុងករណីខ្លះ ប្រទេសផ្សេងៗទៀត ឬអង្គការសហប្រជាជាតិអាចនិយាយថា រដ្ឋាភិបាលប្រទេសខ្ញុំ មិនគោរពសិទ្ធិមនុស្ស។

សំណួរ & ចម្លើយ

១១

# តើខ្ញុំគួរកត់ចំណាំព័ត៌មានអ្វីខ្លះ ប្រសិនជាសិទ្ធិរបស់ខ្ញុំត្រូវបានគេរំលោភបំពាន ?

ប្រសិនជាមាននរណាម្នាក់បានរំលោភសិទ្ធិខ្ញុំ ខ្ញុំត្រូវរក្សាទុកព័ត៌មានសំខាន់ចាំបាច់មួយចំនួន (ប្រសិនបើមិនអាចចាំបានទាំងអស់) ដូចនេះខ្ញុំអាចប្តឹង ឬរាយការណ៍ទៅអាជ្ញាធរ ឬអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការទាក់ទងនឹងសិទ្ធិមនុស្សនៅពេលក្រោយ។

ព័ត៌មានសំខាន់ៗមានដូចជា ព័ត៌មានទាក់ទងនឹងបុគ្គលដែលខ្ញុំគិតថា បានរំលោភសិទ្ធិរបស់ខ្ញុំ ព័ត៌មានអំពីសកម្មភាពដែលជននេះបានធ្វើចំពោះខ្ញុំ (ពេលវេលា និងទីកន្លែងដែលហេតុការណ៍នោះបានកើតឡើង) តើករណីនេះកើតឡើងដោយរបៀបណា ហើយប្រសិនជាអាចប្រាប់ពីមូលហេតុដែលនាំឲ្យមានការរំលោភបំពាននោះ។ យកល្អ គួរតែចងចាំ និងកត់ត្រាទុកឲ្យបានច្បាស់ ពីព័ត៌មានលម្អិតឲ្យបានច្រើនតាមដែលអាចរកបានអំពីហេតុការណ៍នេះ។

សំណួរ & ចម្លើយ ១៣



# តើគេអាចដកយកសិទ្ធិមនុស្សរបស់ខ្ញុំចេញពីខ្ញុំឬទេ ?

មនុស្សគ្រប់រូបមានសិទ្ធិមនុស្សជាប់មកពីកំណើត ហើយគ្មាននរណាម្នាក់អាចដកហូតសិទ្ធិរបស់ខ្ញុំបានឡើយ។ ប៉ុន្តែសិទ្ធិមនុស្សមួយចំនួន អាចត្រូវបានរដ្ឋាភិបាលរឹតត្បិតទៅតាមស្ថានភាពជាក់ស្តែង។ ឧទាហរណ៍ សិទ្ធិសេរីភាពរបស់ខ្ញុំ អាចត្រូវបានរឹតត្បិតប្រសិនជាតុលាការរកឃើញថា ខ្ញុំមានទោស (មានពិរុទ្ធភាព) ពីបទល្មើសអ្វីមួយ ហើយត្រូវជាប់ឃុំក្នុងពន្ធនាគារ។

សំណួរ & ចម្លើយ ១៤



# តើរដ្ឋាភិបាលអាចរឹតត្បិតសិទ្ធិមនុស្សរបស់ខ្ញុំ បានដោយរបៀបណា ?

រដ្ឋាភិបាល មិនអាចកំណត់លក្ខខណ្ឌណាមួយតាមដែលខ្លួនចង់បានលើសិទ្ធិរបស់ខ្ញុំបានឡើយ។ ដើម្បីអាចរឹតត្បិតសិទ្ធិមនុស្សបាន រដ្ឋាភិបាលត្រូវបង្កើតច្បាប់មួយដែលចែងអំពីស្ថានភាពដែលសិទ្ធិអាចត្រូវបានរឹតត្បិត ហើយនិងដោយផ្អែកលើលក្ខខណ្ឌច្បាស់លាស់។ ការរឹតត្បិតត្រូវតែក្នុងករណីចាំបាច់ដើម្បីការពារសិទ្ធិមនុស្ស ឬសេរីភាពរបស់អ្នកដទៃ ឬដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព សីលធម៌សាធារណៈ។

ឧទាហរណ៍ ខ្ញុំមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដែលខ្ញុំអាចនិយាយ ចែករំលែក ឬផ្សព្វផ្សាយគំនិតរបសខ្ញុំ។ ប៉ុន្តែរដ្ឋាភិបាលអាចនឹងបង្កើតច្បាប់ដើម្បីដាក់កម្រិតអំពីអ្វីដែលខ្ញុំអាចនិយាយ ដូចជាការហាមឃាត់មិនឲ្យនិយាយភាសាញុះញង់ឲ្យមនុស្សរើសអើងប្រឆាំងជនភាគតិចក្រុមណាមួយ។

សំណួរ & ចម្លើយ
១៥



# តើសិទ្ធិមនុស្សទាំងអស់សុទ្ធតែអាចរឹតត្បិតបានឬ ?

សិទ្ធិមនុស្សមួយចំនួនអាចរឹតត្បិតបាន និងខ្លះទៀតមិនអាចរឹតត្បិតបានទេ ទោះជាស្ថិតក្នុងស្ថានភាពណាក៏ដោយ។ ឧទាហរណ៍ សិទ្ធិមួយចំនួនដែលមិនអាចរឹតត្បិតបានរួមមានដូចជា៖

- ខ្ញុំមិនអាចត្រូវគេធ្វើទារុណកម្ម ឬធ្វើទង្វើឃោរឃៅមកលើខ្ញុំឡើយ ឬក៏ឲ្យធ្វើជាទាសករ ឬកញ្ជះដាច់ថ្លៃឡើយ។
- ខ្ញុំមិនត្រូវជាប់ពន្ធនាគា ដោយសារតែសកម្មភាពដែលមិនមានច្បាប់ចែងថា ខុសច្បាប់ឡើយ។

សំណួរ & ចម្លើយ ១៦

# ហេតុអ្វីបានជាក្រុមមនុស្សមួយចំនួន ទទួលបានការការពារបន្ថែម ?



ក្រុមមនុស្សខ្លះអាចតម្រូវឲ្យមានការការពារច្រើនជាងក្រុមមនុស្សខ្លះទៀត។ ប៉ុន្តែនេះមិនមានន័យថា ពួកគេមានសិទ្ធិមនុស្សច្រើនជាងខ្ញុំនោះទេ។ ជាទូទៅ ពួកគេជាក្រុមមនុស្សដែលងាយរងគ្រោះ ដូចជា ជនពិការ ជនជាតិដើមភាគតិច។ ក្រុមមនុស្សដទៃទៀត រងគ្រោះដោយសារវិសមភាព (ភាពមិនស្មើគ្នា) ក្នុងសង្គម ដូចជា ស្ត្រី ឬកុមារ។ ព្រោះតែក្រុមមនុស្សទាំងនេះស្ថិតក្នុងស្ថានភាពមិនស្មើគ្នាជាមួយអ្នកដទៃ បាត់បង់ឱកាស និងងាយរងគ្រោះ។ ដូចនេះ បើមិនមានការការពារបន្ថែមនោះទេ នឹងរឹតតែធ្វើឲ្យពួកគេកាន់តែបាត់បង់ឱកាសថែមទៀត។

ដោយហេតុនេះហើយ ទើបត្រូវការឲ្យមានការការពារបន្ថែម ដើម្បីឲ្យពួកគេអាចរស់នៅដោយសេចក្តីថ្លៃថ្នូរ និងស្មើមុខស្មើមាត់ជាមួយអ្នកដទៃទៀតនៅក្នុងសង្គម។ ឧទាហរណ៍ ប្រសិនជារដ្ឋាភិបាលមានបុគ្គលិកភេទប្រុសច្រើនជាងបុគ្គលិកភេទស្រី រដ្ឋាភិបាលអាចកំណត់ចំនួនជាក់លាក់ (កូតា) សម្រាប់បុគ្គលិក

ភេទស្រី ដូចនេះនឹងមានស្ត្រីច្រើនថែមទៀត ត្រូវបានជ្រើសរើសឲ្យធ្វើការក្នុងក្របខ័ណ្ឌរដ្ឋ។

តាមធម្មតា ការការពារបន្ថែមនេះ នឹងត្រូវដកវិញ នៅពេលណាដែលក្រុមមនុស្សទាំងនេះលែងជាជនងាយរងគ្រោះទៀត ហើយពួកគេអាចអនុវត្តសិទ្ធិរបស់ខ្លួនដូចអ្នកដទៃនៅក្នុងសង្គម។

សំណួរ & ចម្លើយ

១៧



# តើអ្វីទៅជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ?

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាឯកសារអន្តរជាតិមួយ ដែលមានចែងអំពីសិទ្ធិមនុស្ស មានជាអាទិ៍ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជាសិទ្ធិរបស់មនុស្សគ្រប់រូប។ សេចក្តីប្រកាសនេះ ជាមូលដ្ឋានគ្រឹះនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយសេចក្តីប្រកាសនេះត្រូវអនុម័ត និងដាក់ឲ្យប្រើប្រាស់ដោយអង្គការសហប្រជាជាតិតាំងពីឆ្នាំ១៩៤៨។ សូមមើលឧបសម្ព័ន្ធ ២ ស្តីពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

សំណួរ & ចម្លើយ ២០

# តើអង្គការសហប្រជាជាតិការពារសិទ្ធិរបស់ខ្ញុំយ៉ាងណាដែរនៅកម្ពុជា ?

អង្គការសហប្រជាជាតិនៅកម្ពុជាមានវិធីសាស្រ្តផ្សេងៗ ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា។ យន្តការសំខាន់បំផុតមានពីរគឺ៖

**១. អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា៖** អ្នករាយការណ៍ពិសេស ឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងធ្វើទស្សនកិច្ចនៅកម្ពុជាពីរដងក្នុងមួយឆ្នាំ ដើម្បីវាយតម្លៃស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដោយជួបប្រជុំ និងធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកផ្សេងៗទៀត ដើម្បីធ្វើឲ្យប្រសើរឡើងដល់ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ បន្ទាប់មកអ្នករាយការណ៍ពិសេសធ្វើរបាយការណ៍ដែលផ្សាយជាសាធារណៈអំពីទស្សនកិច្ចទាំងនេះ។ អ្នករាយការណ៍ពិសេសទទួលពាក្យបណ្តឹងផងដែរពីបុគ្គលទាំងឡាយ ដែលអះអាងថា ខ្លួនជាជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ហើយអ្នករាយការណ៍ពិសេសនឹងលើកយកបញ្ហាទាំងនេះទៅពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជា។

សំណួរ & ចម្លើយ
១៨



# តើអ្វីទៅជាច្បាប់សិទ្ធិមនុស្សអន្តរជាតិ ?

ច្បាប់សិទ្ធិមនុស្សអន្តរជាតិសំដៅដល់ច្បាប់ និងបទដ្ឋាននានា ដែលចែងអំពីសិទ្ធិជាក់លាក់ ដែលអនុវត្តចំពោះមនុស្សគ្រប់រូប។ ជាធម្មតា ច្បាប់ទាំងនេះ ត្រូវបានបញ្ចូលនៅក្នុងសន្ធិសញ្ញា (កិច្ចព្រមព្រៀងផ្លូវច្បាប់រវាងរដ្ឋ និងរដ្ឋ)។ សន្ធិសញ្ញាទាំងនេះ អនុវត្តចំពោះប្រទេសទាំងឡាយណាដែលផ្តល់សច្ចាប័នទទួលយកសន្ធិសញ្ញានេះ។

ទោះជាយ៉ាងណាក៏ដោយ ច្បាប់សិទ្ធិមនុស្សអន្តរជាតិមួយចំនួនត្រូវអនុវត្តគ្រប់ប្រទេសទាំងអស់ទូទាំងពិភពលោក មិនថាប្រទេសនោះទទួលស្គាល់ ឬមិនទទួលស្គាល់សន្ធិសញ្ញានោះឡើយ ដូចជាការហាមឃាត់ការធ្វើទារុណកម្មជាដើម។ នេះគេហៅថា ច្បាប់ប្រពៃណី។

បច្ចុប្បន្ននេះ មានសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗចំនួន៩។ សូមមើលឧបសម្ព័ន្ធ ១ សម្រាប់បញ្ជីឈ្មោះសន្ធិសញ្ញាទាំង ៩ នេះ។

សំណួរ & ចម្លើយ
១៩

# តើច្បាប់ ឬសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ អនុវត្តនៅកម្ពុជាដែរ ឬទេ ?

ចាំ/បាទ កម្ពុជាបានទទួលស្គាល់ច្បាប់ ឬសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ ចំនួន ៨ ក្នុងចំណោមច្បាប់ ឬសន្ធិសញ្ញាទាំងអស់ចំនួន៩។ នេះមានន័យថា តាមផ្លូវច្បាប់ កម្ពុជាត្រូវអនុវត្តតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដើម្បីធានាថា មនុស្សគ្រប់រូបអាចទាមទារ និងអនុវត្តសិទ្ធិមនុស្សរបស់ខ្លួន។

២. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ឬដែលគេស្គាល់ថាជាការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (អ.ស.ប) ប្រចាំកម្ពុជា៖ មានវត្តមាននៅកម្ពុជាតាំងពីឆ្នាំ១៩៩៣។ ការិយាល័យសិទ្ធិមនុស្ស អ.ស.ប ធ្វើការកសាងសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលក្នុងការអនុវត្តបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនៅកម្ពុជា។ ការិយាល័យសិទ្ធិមនុស្ស អ.ស.ប ធ្វើការផងដែរជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាងសមត្ថភាពពួកគេ និងផ្តល់ការជួយឧបត្ថម្ភ និងផ្តល់ប្រឹក្សាយោបល់ដល់បុគ្គលទាំងឡាយដែលអះអាងថា សិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន។

# ឧបសម្ព័ន្ធទី៤ ៖
# ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាក្នុងឆ្នាំ ២០១៧
# នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាក្នុងឆ្នាំ២០១៧

## សេចក្តីផ្តើម

អ្នកនយោបាយជំទាស់ អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិល សហជីព ក្រុមសហគមន៍ ព្រមទាំងប្រជាពលរដ្ឋបានប្រឈមឧបសគ្គជាច្រើនតាមរយៈច្បាប់ តុលាការ និងការអនុវត្តក្រៅប្រព័ន្ធច្បាប់ ដែលបានរឹតត្បិតលំហនៃសង្គមស៊ីវិលយ៉ាងខ្លាំង និងការរម្លាយគណបក្សជំទាស់បានដោយជោគជ័យ។

ការកើនឡើងនូវការអនុម័តច្បាប់និងការអនុវត្តច្បាប់ដែលមានលក្ខណៈរឹតត្បិត និងការបង្ក្រាបលើក្រុមដែលមាននិន្នាការជំទាស់ក្រោមហេតុផលទប់ស្កាត់ផែនការធ្វើ "*បដិវត្តន៍ពណ៌*" បានធ្វើឱ្យការអនុវត្តសិទ្ធិមនុស្សមូលដ្ឋានរបស់ពលរដ្ឋកម្ពុជានិងការចូលរួមក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យធ្លាក់ចុះ។[1] រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមដែលមាននិន្នាការជំទាស់ផ្នែកនយោបាយមួយចំនួនបានប្រឈមការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌក្រោមហេតុផលនយោបាយ។[2]

ដូចឆ្នាំកន្លងទៅដែរ ការរំលោភបំពានលើសិទ្ធិដីធ្លី សិទ្ធិសង្គមកិច្ច និងសេដ្ឋកិច្ចនៅតែបន្តកើតមានរាលដាល។ ក្រុមពលរដ្ឋដែលពុំសូវត្រូវបានគេគិតគូរនិងសហគមន៍ភាគតិចនៅតែពុំមានតំណាងរបស់ខ្លួនក្នុងឆាកនយោបាយ និងកង្វះខាតកិច្ចការពារផ្នែកច្បាប់ប្រឆាំងនឹងការរើសអើង។

## ការបំបិទលំហសង្គមស៊ីវិល

### *<u>សេរីភាពខាងការបញ្ចេញមតិត្រូវបានរឹតត្បិត</u>*

នៅមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០១៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៨ រដ្ឋាភិបាលបង្ក្រាបលើការរិះគន់នានាមកលើខ្លួន ដែលបានធ្វើឱ្យមានការធ្លាក់ចុះជាខ្លាំងនូវសេរីភាពខាងការបញ្ចេញមតិ ជាពិសេស គឺការកំណត់ការបរិហារកេរ្តិ៍ជាគោលដៅនៃការចោទប្រកាន់នានា។ យោងតាមគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ការរឹតត្បិតលើសេរីភាពបញ្ចេញមតិអាចធ្វើទៅបានលុះត្រាតែស្ថិតនៅក្រោមកាលៈទេសៈកំណត់ណាមួយរួមមាន ការការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬ

---

[1] បែន សុខហ៊ាន, អែនជ្រូ ណាជេមសុន(Andrew Nachemson) និងសន ថឺថុន(Shaun Turton) "កង្វល់របស់រដ្ឋាភិបាលទៅនឹងបដិវត្តន៍ពណ៌ បង្ហាញពីការយល់ខុស" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ https://www.phnompenhpost.com/national-post-depth-politics/governments-preoccupation-colour-revolution-reveals-misunderstandings

[2] ម.ស.ម.ក អាដហុក អេសស៊ី និង អាយស៊ីអឹនអិល "របាយការណ៍ប្រចាំឆ្នាំលើកទី១ នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន" ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ ទំព័រទី៧ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

កេរ្តិ៍ឈ្មោះរបស់អ្នកដទៃ។[3] ប៉ុន្តែច្បាប់ដែលមានលក្ខណៈរឹតត្បិតបច្ចុប្បន្នកំពុងគ្រប់គ្រងលើសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជាយ៉ាងខ្លាំង ដែលមិនស្របទៅតាមការអនុវត្តល្អៗជាសកល។ ការណ៍នេះនាំឱ្យបុគ្គលមួយចំនួនប្រឈមនឹងទោសព្រហ្មទណ្ឌចំពោះការសន្ទនាជាលក្ខណៈឯកជន ដែលក្រោយមកត្រូវបានគេចេញផ្សាយជាសាធារណៈដោយពុំមានការយល់ព្រមពីបុគ្គលនោះ។

នៅខែមករា ឆ្នាំ២០១៧ សកម្មជនរបស់គណបក្សសម្ព័ន្ធដើម្បីលទ្ធិប្រជាធិបតេយ្យត្រូវបានគេរាំងការផ្សព្វផ្សាយសារនយោបាយតាមឧគ្ឃោសនាសព្ទ ដោយថាសកម្មភាពរបស់គាត់ប៉ះពាល់ដល់គណបក្សផ្សេងទៀត និងត្រូវបានស្នើឱ្យចុះកិច្ចសន្យាថានឹងមិនធ្វើសកម្មភាពដដែលនេះបន្តទៀត។[4] ក្នុងខែសីហា ឆ្នាំ២០១៧ អ្នកសារព័ត៌មានពីរនាក់របស់កាសែត ឌឹ ខេមបូឌាដេលី គឺលោក អួន ភាព និង លោកហ្សូមបើ ផេតធឺ (Zsombor Peter) ត្រូវបានចោទប្រកាន់ពីបទ «*ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ*» ពាក់ព័ន្ធនឹងការចុះផ្សាយព័ត៌មានអំពីការបោះឆ្នោតនៅខេត្តរតនៈគិរី។[5] អ្នកទាំងពីរនាក់ប្រឈមនឹងការជាប់ពន្ធនាគាររយៈពេលពីរឆ្នាំប្រសិនបើរកឃើញពិរុទ្ធភាព។ ខណៈដែលកំពុងអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិជាមូលដ្ឋានរបស់ខ្លួន អង្គការសង្គមស៊ីវិលត្រូវបានបង្ខំដោយគ្មានមូលដ្ឋានច្បាប់ឱ្យដកចេញផ្ទាំងបដាទាមទារការដោះលែងអ្នកការពារសិទ្ធិមនុស្សចំនួន៦រូប ។[6]

ការរឹតត្បិតខ្លាំងៗឡើងលើសេរីភាពបញ្ចេញមតិ បាននាំឱ្យមានការដាក់កំហិតសិទ្ធិខ្លួនឯង[7] ដែលរារាំងដល់តួអង្គសង្គមស៊ីវិលពីការផ្តល់ព័ត៌មានដោយសេរីដល់ពលរដ្ឋកម្ពុជា។

ការធ្វើទុក្ខបុកម្នេញលើសមាជិកគណបក្សជំទាស់ ដូចជាករណីដែលបានកើតឡើងកាលពីឆ្នាំកន្លងទៅបានកើនឡើងកាន់តែខ្លាំងក្នុងឆ្នាំ២០១៧ ដោយសារថាសមាជិកគណបក្សជំទាស់មួយចំនួនប្រឈមការចោទប្រកាន់ព្រហ្មទណ្ឌដោយសារការរិះគន់រដ្ឋាភិបាល។ ឧទាហរណ៍លោក សម រង្ស៊ី អតីតមេដឹកនាំគណបក្ស

---

[3] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ៧/១៩ "ការលុបបំបាត់បទបរិហារកេរ្តិ៍លើសាសនា" ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ កថាខណ្ឌទី១២ http://ap.ohchr.org/documents/e/hrc/resolutions/a_hrc_res_7_19.pdf

[4] នៀម ឆេង "សកម្មជនគណបក្សសម្ព័ន្ធដើម្បីលទ្ធិប្រជាធិបតេយ្យជាប់ឃុំដោយសារនយោបាយ" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ http://www.phnompenhpost.com/national/ldp-activist-detained-political-messages

[5] ផាក់ ស៊ាងលី "អតីតអ្នករាយការណ៍កាសែតខេមបូឌាដេលីត្រូវបានចោទប្រកាន់ពីបទញុះញង់" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧ https://www.phnompenhpost.com/national/former-cambodia-daily-reporters-charged-incitement

[6] សេចក្តីថ្លែងការណ៍រួម "អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិសម្តែងការសោកស្តាយចំពោះការរុះរើបដាអំពាវនាវឱ្យមានការដោះលែងអ្នកការពារសិទ្ធិមនុស្សទាំង៥ និងអ្នកស្រីទេព វន្នី, ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ https://cchrcambodia.org/index_old.php?title=JOINT-STATEMENT-Cambodian-and-international-CSOs-condemn-removal-of-banners-calling-for-the-release-of-human-rights-defenders-FreeThe5KH-FreeTepVanny&url=media/media.php&p=press_detail.php&prid=658&id=5&lang=khm

[7] ម.ស.ម.ក អាដហុក អេស៊ី អាយស៊ីអឹនអិល "របាយការណ៍ប្រចាំឆ្នាំលើកទី១ នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន, ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ទំព័រទី ii, https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=124&id=5&lang=khm

សង្គ្រោះជាតិត្រូវបានកាត់ទោសពីបទបរិហារកេរ្តិ៍ បន្ទាប់ពីលោកបានចោទលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថាបានសូកប៉ាន់សកម្មជនម្នាក់អោយវាយប្រហារគណបក្សសង្គ្រោះជាតិ។[8]

ក្រៅពីគណបក្សជំទាស់ មេដឹកនាំសង្គមស៊ីវិលនិងសកម្មជនមួយចំនួនក៏ធ្លាប់ទទួលរងការរឹតត្បិតទៅលើសេរីភាពបញ្ចេញមតិរបស់ពួកគាត់ផងដែរ ដែលជាហេតុនាំឱ្យមានការដាក់កំហិតខ្លួនឯងកើនឡើង។ របាយការណ៍នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក បង្ហាញថា ២០% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលបានស្ទង់មតិនៅចុងឆ្នាំ២០១៧ បានឆ្លើយថា « តែងតែ » គិតថាចាំបាច់ត្រូវតែដាក់កំហិតសិទ្ធិខ្លួនឯងនៅពេលពួកគាត់ថ្លែងជាសាធារណៈ ដែលកើនឡើង ៨% ជាងឆ្នាំមុន។ លើសពីនេះ ជាង ៤៣% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពបានលើកឡើងថាពួកគាត់ជឿថាការសន្ទនាជាលក្ខណៈឯកជនរបស់ពួកគាត់ត្រូវបានរដ្ឋាភិបាលតាមដាន បើទោះជាមានការធានាដោយច្បាប់ជាតិក៏ដោយ។[9]

## ការបង្ក្រាបធ្ងន់ធ្ងរលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ដឹ ខេមបូឌាដេលី ជាកាសែតឯករាជ្យដែលល្បីល្បាញខាងការចេញផ្សាយព័ត៌មានបែបស៊ើបអង្កេត បានបង្ខំចិត្តបញ្ឈប់ប្រតិបត្តិការបន្ទាប់ពីមានបញ្ហាចម្រូងចម្រាសក្នុងការបង់ពន្ធនូវទឹកប្រាក់ចំនួន ៦,៣ លានដុល្លារអាមេរិកក្នុងខែកញ្ញា។[10] សេរីភាពសារព័ត៌មានបានធ្លាក់ចុះថែមទៀតតាមរយៈសេចក្តីសម្រេចរបស់រដ្ឋាភិបាលក្នុងការបិទស្ថានីយវិទ្យុក្នុងស្រុកចំនួន១៥ នាខែសីហា ដោយផ្អែកលើមូលដ្ឋានផ្នែករដ្ឋបាលមិនច្បាស់លាស់។[11] ជាលទ្ធផលនៃការបង្ក្រាបនេះ បានធ្វើឱ្យមានការលំបាកខ្លាំងឡើងក្នុងការចូលទៅកាន់ប្រព័ន្ធផ្សព្វផ្សាយនៃនិន្នាការនយោបាយផ្សេង ព្រោះប្រភពព័ត៌មាននិងសោតទស្សន៍ដែលនៅសេសសល់ស្ទើរតែទាំងអស់គាំទ្ររដ្ឋាភិបាល ។

ការបង្ក្រាបលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យនេះ បានបង្ហាញកាន់តែច្បាស់ថែមទៀតតាមរយៈការចាប់ និងឃុំខ្លួនលោក យាង សុធារិន្ទ និងលោក អ៊ួន ឈិន អតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី[12]ពីបទក្បត់ជាតិដោយសាររងការចោទថាបានដំឡើងបន្ទប់ថតសំឡេង និងផលិតកម្មវិធីព័ត៌មានឱ្យទៅវិទ្យុអាស៊ីសេរី ដែលបានបង្ខំចិត្តបិទការិយាល័យរបស់ខ្លួននៅកម្ពុជានៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ ដោយសារពាក់ព័ន្ធនឹងបញ្ហាពន្ធនិងអាជ្ញាប័ណ្ណ។[13]

---

[8] ម៉ៃ ទិត្យថារ៉ា "លោក សម រង្ស៊ី ត្រូវតុលាការពិន័យ១លានដុល្លារពីបទបរិហារកេរ្តិ៍" *ខ្មែរថាមស៍* ថ្ងៃទី១ ខែមករា ឆ្នាំ២០១៨, http://www.khmertimeskh.com/5098996/rainsy-fined-1m-defamation/

[9] ម.ស.ម.ក "គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន" ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព, ឧបសម្ព័ន្ធ៤ កថា.ទី ៥,៩ https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=124&id=5&lang=khm

[10] សេល សាន, សុវណ្ណារិទ្ធ កែវ និង ចូសស៊ូ លីប៉េស "កាសែតខេមបូឌាដេលីត្រូវបានបិទចំពេលដែលរដ្ឋាភិបាលគំរាមបិទដោយសារបំណុលពន្ធ" ហ្វ្រេសញូអាស៊ី ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧, https://www.rfa.org/english/news/cambodia/closure-09052017175036.html

[11] ម៉ិច ដារ៉ា និង អាណាថ បាលីហ្គា (Ananth Baliga) "រដ្ឋាភិបាលបិទស្ថានីយវិទ្យុចំនួន១៥", *ភ្នំពេញប៉ុស្តិ៍* https://www.phnompenhpost.com/national/government-closes-15-radio-stations

[12] គីម សារុំ សាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេច ដោយបដិសេធលើសំណើសុំនៅក្រៅឃុំរបស់អតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី http://www.phnompenhpost.com/national/court-upholds-decision-deny-bail-rfa-duo

[13] ម៉ិច ដារ៉ា និង អាណាថ បាលីហ្គា "វិទ្យុអាស៊ីសេរីបញ្ជាក់ពីការបិទការិយាល័យវិទ្យុ", *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ https://www.phnompenhpost.com/national/rfa-confirms-office-closure

សន្ទស្សន៍សេរីភាពខាងការបញ្ចេញមតិពិភពលោកក្នុងឆ្នាំ២០១៧ ដែលធ្វើការវាយតម្លៃពីកម្រិតនៃសេរីភាពដែលអ្នកសារព័ត៌មានទទួលបាន បានទម្លាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជា ៤ ថ្នាក់ ចាប់តាំងពីឆ្នាំ២០១៦មក ដោយស្ថិតនៅលេខរៀងទី១៣២ក្នុងចំណោមប្រទេសចំនួន ១៨០ ដែលបានវាយតម្លៃ។[14] មានការសន្និដ្ឋានថាចំណាត់ថ្នាក់នេះអាចនឹងធ្លាក់ចុះថែមទៀតនៅឆ្នាំ២០១៨ ប្រសិនបើការបង្រ្កាបលើអ្នកជំទាស់នៅតែបន្ត។

ជារួម ការរឹតត្បិតដែលកាន់តែខ្លាំងឡើងទៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងនេះ បានធ្វើឱ្យប៉ះពាល់ថែមទៀតលើសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ អ្នកសារព័ត៌មានមិនអាចរាយការណ៍ព័ត៌មាននៅពេលដែលពួកគេព្រួយបារម្ភពីការឃុំខ្លួននិងការផ្តន្ទាទោសដោយអយុត្តិធម៌បានឡើយ។ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានលើកឡើងទាក់ទងនឹងបញ្ហានេះតាមរយៈរបាយការណ៍ប្រចាំឆ្នាំ២០១៧របស់ខ្លួនដោយបញ្ជាក់ថា ៦៧% នៃអ្នកសារព័ត៌មានដែលខ្លួនបានសម្ភាសន៍មិនជឿថាពួកគេមានសេរីភាពពេញលេញក្នុងការពិភាក្សាគ្រប់ប្រធានបទដែលពាក់ព័ន្ធនោះទេ។[15] ម្យ៉ាងទៀត ៨៣% យល់ស្របថាសេរីភាពសារព័ត៌មានបានធ្លាក់ចុះនៅក្នុងឆ្នាំនេះ។[16]

## ការរីករាលដាលនៃការដាក់កំហិតសិទ្ធិខ្លួនឯងតាមប្រព័ន្ធអ៊ីនធឺណិត

និន្នាការនៃការកើនឡើងនៃការដាក់កំហិតសិទ្ធិខ្លួនឯងនិងការតាមដាននៅលើប្រព័ន្ធអ៊ីនធឺណិត មានការកើនឡើង នេះយោងតាមឯកសារដែលបានចងក្រងតាំងពីពាក់កណ្តាលឆ្នាំ២០១៥។ កាលដំបូងឡើយ អ៊ីនធឺណិតត្រូវបានគេចាត់ទុកថាមានលំហសេរីភាពខ្លាំងជាងសារព័ត៌មានបោះពុម្ពផ្សាយនិងប្រព័ន្ធផ្សព្វផ្សាយនានា ប៉ុន្តែកាន់តែលំបាកខ្លាំងឡើងៗសម្រាប់ប្រជាពលរដ្ឋកម្ពុជាក្នុងការបញ្ចេញមតិរបស់ខ្លួនដោយសេរីនៅលើប្រព័ន្ធអ៊ីនធឺណិតដោយពុំមានការព្រួយបារម្ភពីទោសព្រហ្មទណ្ឌ។ ស្ថាប័នសមាជិកសភាអាស៊ានសម្រាប់សិទ្ធិមនុស្ស (APHR) បានសម្តែងការព្រួយបារម្ភទៅលើរបៀបនៃការគ្រប់គ្រងនិងការដាក់ទោសធ្ងន់ធ្ងរដែល «*រាលដាល និងក្លាយទៅជារឿងធម្មតា*» ចំពោះការបរិហារកេរ្តិ៍នៅលើប្រព័ន្ធអ៊ីនធឺណិតដែលកើតឡើងក្នុងឆ្នាំ២០១៧ ។[17]

នៅឆ្នាំ២០១៧ ទាំងពលរដ្ឋសាមញ្ញនិងសមាជិកគណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយធ្លាប់ត្រូវបានចាប់ខ្លួននិងផ្តន្ទាទោសចំពោះការបញ្ចេញមតិរិះគន់រដ្ឋាភិបាលនៅលើប្រព័ន្ធអ៊ីនធឺណិត។ ឧទាហរណ៍ស្ត្រីម្នាក់ឈ្មោះ សំ សុខា ត្រូវបានផ្តន្ទាទោសពីបទ «ប្រមាថអ្នករាជការសាធារណៈនិងញុះញង់ឱ្យមានការរើសអើង» ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលពីរឆ្នាំចំពោះការបង្ហោះវីដេអូដែលបង្ហាញពីសកម្មភាពអ្នកស្រី

---

[14] អង្គការអ្នកកាសែតគ្មានព្រំដែន "អង្គការអ្នកកាសែតគ្មានព្រំដែន ចេញផ្សាយរបាយការណ៍ស្តីពីការវាយប្រហារសេរីភាពសារព័ត៌មាននៅកម្ពុជា" ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨, https://rsf.org/en/news/rsf-publishes-report-media-freedom-under-attack-cambodia

[15] CCIM "ការប្រឈមសម្រាប់សារព័ត៌មានឯករាជ្យ" ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ទំព័រទី២ https://www.ccimcambodia.org/wp-content/uploads/2018/02/Challenges-for-Independent-Media-2017-English.pdf

[16] *ដូចខាងលើ*

[17] ស្ថាប័នសភាអាស៊ានដើម្បីសិទ្ធិមនុស្ស "ការផុតរលត់នៃលទ្ធិប្រជាធិបតេយ្យ៖ ការវាយប្រហារលើសមាជិកសភា និងការគំរាមកំហែងស្ថាប័នកម្ពុជា" ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ទំព័រទី១៤ https://aseanmp.org/wp-content/uploads/2017/03/APHR_Cambodia-MPs-Report_Mar-2017.pdf

យកស្បែកជើងគប់ស្លាកគណបក្សប្រជាជនកម្ពុជានៅលើបណ្ដាញហ្វេសប៊ុក។[18] ទោះបីជាត្រូវបានទីភ្នាក់ងារជនភៀសខ្លួនអង្គការសហប្រជាជាតិទទួលស្គាល់អ្នកស្រីក្នុងឋានៈជាជនភៀសខ្លួនក្ដី ក៏អ្នកស្រី សំ សុខា នៅតែត្រូវបានបញ្ជូនត្រលប់ពីប្រទេសថៃមកវិញនៅពេលដែលអ្នកស្រីបានគេចខ្លួនពីកម្ពុជាក្នុងខែកុម្ភៈ ឆ្នាំ២០១៨។[19]

ច្បាប់ស្ដីពីទូរគមនាគមន៍ឆ្នាំ២០១៦ ផ្ដល់អំណាចដល់រដ្ឋាភិបាលដើម្បីធ្វើការត្រួតពិនិត្យ និងដាក់ទោសព្រហ្មទណ្ឌលើទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិចដែលចាត់ទុកថាបង្ក *"អសន្តិសុខជាតិ"*។[20] នេះជាការបង្កើនសមត្ថភាពក្នុងការត្រួតពិនិត្យមាតិកាលើប្រព័ន្ធអ៊ីនធឺណិតរបស់រដ្ឋាភិបាល ដែលបានរឹតត្បិតបន្ថែមទៀតទៅលើសេរីភាពមូលដ្ឋានរបស់បុគ្គលដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួន និងរារាំងការពិភាក្សាផ្នែកនយោបាយដោយសេរី។ លើសពីនេះ រដ្ឋាភិបាលបានចេញសេចក្ដីប្រកាសជាច្រើនលើកអំពីផែនការប្រើប្រាស់នគរបាលដើម្បីពង្រីកការត្រួតពិនិត្យបន្ថែមទៀតលើមាតិកាដែលបង្ហោះនៅលើបណ្ដាញអ៊ីនធឺណិត។[21] ការថយចុះស្វ័យភាពនៅលើប្រព័ន្ធអ៊ីនធឺណិតនេះត្រូវបានលើកឡើងតាមរយៈរបាយការណ៍អំពីសេរីភាពនៅលើអ៊ីនធឺណិតឆ្នាំ២០១៧ ដែលជាការត្រួតពិនិត្យប្រចាំឆ្នាំទូទាំងពិភពលោករបស់អង្គការហ្វ្រីដឹមហៅស៍ (Freedom House)[22] ដែលបានបង្ហាញក្ដីបារម្ភណ៍ជាក់លាក់ទៅលើចំនួនដែលមិនធ្លាប់មាននៃពលរដ្ឋកម្ពុជាដែលប្រឈមការចោទប្រកាន់ពីបទព្រហ្មទណ្ឌពាក់ព័ន្ធនឹងការបង្ហោះលើបណ្ដាញហ្វេសប៊ុក។[23]

**ការរឹតត្បិតខ្លាំងលើសេរីភាពខាងសមាគម**

នៅក្នុងខែកុម្ភៈ និងខែកក្កដា ឆ្នាំ២០១៧ រដ្ឋាភិបាលបានប្រញាប់ប្រញាល់អោយរដ្ឋសភាធ្វើវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយដោយពុំមានការប្រឹក្សាយោបល់ពេញលេញ។ ការធ្វើវិសោធនកម្មមាត្រាមួយចំនួននៃច្បាប់ស្ដីពីគណបក្សនយោបាយនេះ បានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់អ្នកនយោបាយជំទាស់។ វិសោធនកម្មនេះផ្ដល់អំណាចទូលំទូលាយហួសហេតុដល់រដ្ឋាភិបាលក្នុងការរំលាយគណបក្សនយោបាយដោយ

---

18 ម៉ិច ដារ៉ា និង អាណាថ បាលីហ្គា (Ananth Baliga) និងអេរីន ហេនលី(Erin Handley) "ធ្វើបត្យាប័ន "អ្នកគប់ស្បែកជើង" សំ សុខា ប្រឈមនឹងការផ្ដន្ទាទោសជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ" *ភ្នំពេញប៉ុស្ដិ៍* ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨ https://www.phnompenhpost.com/national/extradited-shoe-thrower-sam-sokha-faces-two-year-prison-sentence

19 អាណាថ បាលីហ្គា និងឃួត សុភ័ក្រ ចរិយា " អ្នកគប់ស្បែកជើងដាក់ស្លាកគណបក្សប្រ.ជ ត្រូវបានបញ្ជូនត្រឡប់ពីប្រទេសថៃមកកម្ពុជាវិញ" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ https://www.phnompenhpost.com/national/shoe-thrower-sam-sokha-deported-thailand

20 ច្បាប់ស្ដីពីទូរគមនាគមន៍ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៦ មាត្រា៨០ http://www.sithi.org/admin/upload/law/20150127_TelecommunicaitonDraftLaw_En%20edited-2.pdf

21 ម៉ិច ដារ៉ា "នគរបាលចាប់ផ្ដើមពិនិត្យមាតិកាព័ត៌មានលើហ្វេសប៊ុក មាននិន្នាការញុះញង់បង្កអស្ថិរភាព" *ភ្នំពេញប៉ុស្ដិ៍*, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ https://www.phnompenhpost.com/national/cambodias-facebook-crackdown-police-are-monitoring-site-enemies-and-rebel-movements

22 របាយការណ៍ជាក់លាក់សម្រាប់កម្ពុជា https://freedomhouse.org/report/freedom-net/2017/cambodia

23 លីអូនី គីជូស្គី (Leonie Kijewski) "កម្ពុជាឃើញថាសេរីភាពអ៊ីនធឺណិតរួមតូចក្នុងឆ្នាំ២០១៧" *ភ្នំពេញប៉ុស្ដិ៍*, ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ http://www.phnompenhpost.com/national/kingdom-sees-internet-freedom-shrink-2017

ផ្អែកលើលក្ខខណ្ឌដែលមានខ្លឹមសារមិនច្បាស់លាស់ដូចជាពាក្យ« *ញុះញង់* » ឬ « *សន្តិសុខជាតិ* »។[24] មាត្រា៦ ថ្មី (ពីរ)(៦) គណបក្សនយោបាយអាចត្រូវបានព្យួរ ឬរំលាយចំពោះការប្រើប្រាស់ "*សារជាសំឡេង រូបភាព ឯកសារជាសំណេរ ឬសកម្មភាពណាមួយរបស់ជនដែលត្រូវបានផ្តន្ទាទោសដោយបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដើម្បីប្រយោជន៍របស់គណបក្ស*។[25] នេះក៏រឹតត្បិតផងដែរចំពោះការបង្កើតគណបក្សនយោបាយ ដូចជាការចុះឈ្មោះគណបក្សនយោបាយអាចនឹងត្រូវបដិសេធនៅពេលដែលគណបក្សនយោបាយណាមួយត្រូវបានគេចាត់ទុកថាមិនគោរពតាមលក្ខខណ្ឌដូចបានលើកឡើងខាងលើ។ ចំណុចមួយនៃវិសោធនកម្មនេះក៏ហាមប្រាមបុគ្គលដែលជាប់ទោសព្រហ្មទណ្ឌពីការកាន់តួនាទីជាថ្នាក់ដឹកនាំគណបក្សនយោបាយផងដែរ។[26]

វិសោធនកម្មនេះ បូករួមទាំងការយាយីផ្នែកតុលាការខ្លាំងឡើងទៅលើលោក សម រង្ស៊ី បាននាំឱ្យលោកលាលែងពីតួនាទីជាប្រធានគណបក្សសង្គ្រោះជាតិ។[27] លើសពីនេះទៀត ប្រធានថ្មីរបស់គណបក្សសង្គ្រោះជាតិ គឺលោក កឹម សុខា ត្រូវបានចាប់ខ្លួនកាលពីខែកញ្ញា ហើយត្រូវបានចោទប្រកាន់ពីបទក្បត់ជាតិក្រោមមាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (បទសន្ទិដ្ឋិភាពជាមួយបរទេស) ដែលជាការរំលោភលើអភ័យឯកសិទ្ធិសភារបស់លោក។ ភ្លាមៗបន្ទាប់ពីការចាប់ខ្លួនលោក កឹម សុខា នៅខែកញ្ញា ឆ្នាំ២០១៧ ទីស្តីការគណៈរដ្ឋមន្ត្រីបានបញ្ចេញវីដេអូមួយដើម្បីផ្តល់យុត្តិកម្មលើការចាប់ខ្លួននិងការចោទប្រកាន់ពីបទក្បត់ជាតិ ដោយផ្អែកលើសុន្ទរកថាកាលពីឆ្នាំ២០១២ របស់លោក កឹម សុខា ដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើអ៊ីនធឺណិត។[28] ទោះបីជាមានការស្នើឱ្យដោះលែងរូបលោកពីសំណាក់អង្គការសង្គមស៊ីវិលក្តី លោកនៅតែស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ហើយរាល់សំណើសុំនៅក្រៅឃុំត្រូវបានបដិសេធក្នុងឆ្នាំ២០១៧ ។

ជាទិដ្ឋភាពទូទៅ ឆ្នាំ២០១៧ជាឆ្នាំដែលគេមើលឃើញភាពផុតរលត់នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ៖ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ តុលាការកំពូលបានចេញសាលដីកាសម្រេចរំលាយគណបក្សសង្គ្រោះជាតិ ដោយសំអាងលើការចោទប្រកាន់ថាគណបក្សនេះបានចូលរួមសកម្មភាព *«បដិវត្តន៍ពណ៌»* ដែលគាំទ្រដោយសហរដ្ឋអាមេរិកដើម្បីផ្តួលរំលំរដ្ឋាភិបាលបច្ចុប្បន្ន ព្រមទាំងបានហាមប្រាមមន្ត្រីនិងសមាជិកសភារបស់គណបក្សនេះចំនួន១១៨នាក់ពីការចូលរួមក្នុងសកម្មភាពនយោបាយរយៈពេល ៥ ឆ្នាំ ។[29] បន្ទាប់ពី

---

[24] សេចក្តីថ្លែងការណ៍រួម "អង្គការសង្គមស៊ីវិលសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយក្នុងដំណើរការបង្កើតច្បាប់ដ៏ប្រញាប់ប្រញាល់" ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ https://bit.ly/2Rc1pC4

[25] ដូចខាងលើ

[26] ដូចខាងលើ ទំព័រទី២ និងទី៣

[27] សន ធើថុន(Shaun Turton) "សម រង្ស៊ី លាលែងពីគណបក្សសង្គ្រោះជាតិ" *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ https://www.phnompenhpost.com/national/sam-rainsy-resigns-cnrp

[28] ខៃ សុណាង "ប្រធានគណបក្សប្រឆាំងនៅកម្ពុជាលោកកឹម សុខា ត្រូវបានចាប់ខ្លួន ដោយចោទប្រកាន់ពីបទក្បត់ជាតិ" *វិទ្យុអាស៊ីសេរី* ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៧ https://www.rfa.org/english/news/cambodia/kemsokha-arrest-09022017163633.html

[29] បែន សុខហ៊ាន, ម៉ិច ដារ៉ា, អាណាន បាលីហ្គា (Ananth Baliga) "មរណៈភាពនៃប្រជាធិបតេយ្យ៖ គណបក្សសង្គ្រោះជាតិត្រូវបានរំលាយដោយតុលាការកំពូល" ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧, https://www.phnompenhpost.com/national-post-depth-politics/death-democracy-cnrp-dissolved-supreme-court-ruling

ការរំលាយគណបក្សសង្គ្រោះជាតិ គណបក្សប្រជាជនកម្ពុជាបានឈ្នះការបោះឆ្នោតដោយស្ទើរតែគ្មានគូប្រជែង។ អាសនៈសភារបស់គណបក្សសង្គ្រោះជាតិត្រូវបានចែកទៅឱ្យគណបក្សតូចៗ[30] ដែលទទួលបានសំឡេងគាំទ្រតិចជាង ៥% ក្នុងការបោះឆ្នោតឆ្នាំ២០១៣។[31] ការបង្ក្រាបលើគណបក្សជំទាស់នេះបាននាំឱ្យមានការចាត់ទុកស្ថានភាពនយោបាយនៅកម្ពុជាថាជា «*របបផ្តាច់ការ*» ពីសំណាក់អង្គភាពព័ត៌មានសេដ្ឋកិច្ច ( EIU ) តាមរយៈរបាយការណ៍ពីសន្ទស្សន៍នៃលទ្ធិប្រជាធិបតេយ្យឆ្នាំ២០១៧។[32]

ទោះបីជាមានសំណើពីអង្គការសង្គមស៊ីវិលអោយធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដ៏ចម្រូងចម្រាសក្តី ច្បាប់នេះនៅតែពុំមានការផ្លាស់ប្តូរនិងបន្តគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សេរីភាពមូលដ្ឋានដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតូបករណ៍សិទ្ធិមនុស្សផ្សេងៗទៀត។ អង្គការសង្គមស៊ីវិលមួយចំនួនធ្លាប់រងផលប៉ះពាល់ខ្លាំងពីច្បាប់ដែលមានលក្ខណៈរឹតត្បិតនេះ ដែលបញ្ចូលនូវលក្ខខណ្ឌតម្រូវថ្មីមួយឱ្យអង្គការសង្គមស៊ីវិលទាំងអស់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមកាលបរិច្ឆេទកំណត់ត្រឹមខែកញ្ញា ឆ្នាំ២០១៧។[33]

អង្គការសង្គមស៊ីវិលបានលើកឡើងពីការបន្តការជ្រៀតជ្រែកក្នុងសកម្មភាពរបស់ពួកគេពីសំណាក់អាជ្ញាធរមូលដ្ឋាន។ អង្គការសង្គមស៊ីវិលចំនួនបី (អង្គការសមធម៌កម្ពុជា វិទ្យាស្ថានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងអង្គការមាតាធម្មជាតិ )[34] ហើយនិងបន្ទប់ស្ថានការណ៍( ជាសម្ព័ន្ធក្រុមអង្គការសង្គមស៊ីវិលដែលឃ្លាំមើលការបោះឆ្នោត)[35] ត្រូវបានបិទ ព្យួរ ឬលុបឈ្មោះចេញពីបញ្ជីអង្គការ។ នេះបង្ហាញឱ្យឃើញពីភាពម៉ឺងម៉ាត់នៃច្បាប់នេះដែលរឹតត្បិតសកម្មភាពនិងសេរីភាពអង្គការសង្គមស៊ីវិលនៅកម្ពុជា ដែលបានរារាំងអង្គការសង្គមស៊ីវិលពីការប្រើប្រាស់ធនធានរបស់ខ្លួនអោយបានត្រឹមត្រូវដើម្បីលើកកម្ពស់សិទ្ធិមនុស្ស។

សកម្មភាពរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាក៏ធ្លាប់ទទួលរងការតិះទៀនផងដែរដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើឱ្យមានការស៊ើបអង្កេតលើភាពស្របច្បាប់របស់អង្គការនេះទាក់ទងនឹងការចោទ

---

[30] នៀម ឆេងនិង អាណាន់ បាលីកា "បញ្ជីឈ្មោះសមាជិករដ្ឋសភាថ្មីដែលត្រូវបានអនុម័ត" *សារព័ត៌មានភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ អាចរកបានតាមរយៈ https://www.phnompenhpost.com/national-politics/list-new-national-assembly-members-approved

[31] បែន សុខហ៊ាន និង នៀម ឆេង " ការរម្លាយគណបក្សសង្គ្រោះជាតិ ធ្វើឱ្យគណបក្សសំឡេងភាគតិចទទួលអាសនៈរដ្ឋសភា" *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ https://www.phnompenhpost.com/national-politics/cnrp-gone-minor-parties-take-their-national-assembly-seats

[32] សន្ទស្សន៍ប្រជាធិបតេយ្យនៃអង្គភាពព័ត៌មានសេដ្ឋកិច្ច ថ្ងៃទី៤ ខែកុម្ភៈឆ្នាំ២០១៨ https://www.eiu.com/topic/democracy-index

[33] គង់ មេត្តានិង លីអូនី គីជូស្គី ( Leonie Kijewski ) "អង្គការសង្គមស៊ីវិលមួយចំនួនតូចគោរពតាមច្បាប់" *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៧ អាចរកបានតាមរយៈ https://www.phnompenhpost.com/national/few-ngos-compliant-law

[34] "រដ្ឋាភិបាលបញ្ជាអោយក្រុមអង្គការដែលទទួលបានការឧបត្ថម្ភមូលនិធិពីសហរដ្ឋអាមេរិកចាកចេញ ដែលជាការវិវត្តថ្មីមួយប្រឆាំងអាមេរិក" *សំឡេងសហរដ្ឋអាមេរិក* ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ http://bit.ly/2ipecoA ។ បែន សុខហ៊ាន និង គង់ មេត្តា "អង្គការសិទ្ធិដីធ្លីត្រូវបានព្យួរ" ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧, *ភ្នំពេញប៉ុស្តិ៍,* http://bit.ly/2x0YCBA.

[35] អេរីន ហេនលី( Erin Handley ) "អ្នកអង្កេតការណ៍បោះឆ្នោតរងការព្រមានពាក់ព័ន្ធនឹងអព្យាក្រឹតភាពនៃច្បាប់" *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៧ http://bit.ly/2tHq2yT.

ប្រកាន់ថាបម្រើផលប្រយោជន៍ឱ្យបរទេស។[36] បន្ទាប់ពីការស៊ើបអង្កេតពីក្រសួងមហាផ្ទៃបានបង្ហាញថាពុំបានប្រព្រឹត្តកំហុសឆ្គងឡើយ អង្គការនេះត្រូវបានអនុញ្ញាតឱ្យបន្តការងាររបស់ខ្លួនដើម្បីលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា។[37]

## ការរារាំងសេរីភាពខាងការជួបប្រជុំ

មានការរឹតត្បិតខ្លាំងលើសេរីភាពខាងការជួបប្រជុំក្នុងឆ្នាំ២០១៧។ ទោះបីជាមានចែងក្នុងក្របខ័ណ្ឌច្បាប់កម្ពុជាក្តី ក៏សេរីភាពមូលដ្ឋាននេះនៅតែរងការរឹតត្បិតដោយគ្មានមូលដ្ឋាន ហេតុពេលខ្លះឈានដល់អំពើហិង្សា។ ក្នុងឱកាសនៃពិធីបង្ហាញរថពាសដែកក្នុងខែមករា ឆ្នាំ២០១៧ មន្រ្តីកងរាជអាវុធលើផ្ទៃប្រទេសបានទទួលស្គាល់ថារថពាសដែកបំពាក់ដោយអាវុធឧស្ម័នបង្ហូរទឹកភ្នែករបស់កងរាជអាវុធហត្ថទាំងនោះ អាចនឹងត្រូវប្រើប្រាស់ដើម្បីទប់ទល់នឹងក្រុមអ្នកតវ៉ា។[38] នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ កងសន្តិសុខខណ្ឌបានបង្ក្រាបយ៉ាងហិង្សាទៅលើអ្នកតវ៉ា ក្នុងនោះនគរបាលបានដេញតាមអ្នកតវ៉ាម្នាក់ចូលទៅក្នុងផ្សារទំនើបនិងបានវាយដំគាត់ ខណៈគាត់បានចូលរួមការប្រមូលផ្តុំអហិង្សាគាំទ្រអ្នកស្រី ទេព វ៉ាន់នី ជាសកម្មជនដីធ្លីដ៏លេចធ្លោម្នាក់នៅថ្ងៃសវនាការរបស់អ្នកស្រី។[39]

ខណៈកំពុងអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន ជារឿយៗអ្នកតវ៉ាត្រូវបានឃុំខ្លួនដោយគ្មានមូលដ្ឋានត្រឹមត្រូវ ដោយមានភ្ជាប់នូវលក្ខខណ្ឌតម្រូវឱ្យពួកគាត់ចុះហត្ថលេខាលើកិច្ចសន្យាដើម្បីជាថ្នូរទទួលបានការដោះលែង។ នៅខែវិច្ឆិកា ឆ្នាំ២០១៧ អាជ្ញាធរស្រុកក្នុងខេត្តរតនៈគីរីបានសួរចម្លើយអ្នកភូមិចំនួន១៥នាក់បន្ទាប់ពីពួកគាត់ចូលរួមបាតុកម្មប្រឆាំងនឹងក្រុមហ៊ុនរុករករ៉ែមាសកាណាដា ដែលមានការសង្ស័យថាការតវ៉ានោះគឺជារឿងនយោបាយ។ អ្នកទាំង១៥ នាក់ នោះត្រូវបានតម្រូវឱ្យចុះកិច្ចសន្យាថានឹងមិនធ្វើការតវ៉ាជាថ្មី បើពុំមានការអនុញ្ញាតជាមុនទេនោះ។[40] ការអនុវត្តនេះរំលោភលើច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលចែងថាបុគ្គលដែលរៀបចំការជួបប្រជុំនៅទីសាធារណៈត្រូវជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានប្រាំថ្ងៃជាមុន។ ពុំតម្រូវឱ្យស្នើសុំការអនុញ្ញាតជាមុននោះឡើយ។

---

[36] បែន សុខហ៊ាន និង លីអូនី គីជូស្គី (Leonie Kijewski) "នាយករដ្ឋមន្រ្តីចោទថាអង្គការដែលបង្កើតឡើងដោយលោក កឹម សុខា បម្រើផលប្រយោជន៍បរទេស ហើយថា «ត្រូវតែបិទ» *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ https://www.phnompenhpost.com/national-politics/pm-accuses-kem-sokha-founded-ngo-serving-foreign-interests-says-it-must-close

[37] ប្រាក់ ចាន់ថុល "នាយករដ្ឋមន្ត្រីកម្ពុជាសម្រេចមិនបិទអង្គការសិទ្ធិមនុស្សដែលបង្កើតឡើងដោយគូបដិបក្ខ" ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៧ https://www.reuters.com/article/us-cambodia-politics/cambodian-pm-pulls-back-on-threat-to-shut-rights-group-founded-by-rival-idUSKBN1DW0CI

[38] ម៉ិច ដារ៉ា និង សន ប៊ីជុន (Shaun Turton) "ការបង្ហាញរថពាសដែករបស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស" *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ http://www.phnompenhpost.com/national/military-police-machines

[39] អាណាន់ បាលីហ្គា (Ananth Baliga) និងឡាយ សាមៀន "សកម្មជន ទេព វ៉ាន់នី ជាប់ពន្ធនាគាររយៈពេល៣០ខែ ខណៈដែលសន្តិសុខដេញវាយដំបុរសម្នាក់ក្នុងផ្សារទំនើប", *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧, https://www.phnompenhpost.com/national/activist-vanny-gets-30-months-while-security-guards-beat-man-city-mall

[40] ផាក់ ស៊ាងលី "អ្នកភូមិត្រូវបានសួរចម្លើយទាក់ទងនឹងការតវ៉ាប្រឆាំងនឹងក្រុមហ៊ុនរ៉ែ", *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ https://www.phnompenhpost.com/national/villagers-questioned-over-protest-against-mining-company

យោងតាមរបាយការណ៍ប្រចាំឆ្នាំលើកទីមួយនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបង្ហាញថាកម្មវិធីសាធារណៈចំនួន៦០ ដែលរៀបចំដោយសង្គមស៊ីវិលត្រូវបានរារាំងដោយខុសច្បាប់ពីសំណាក់នគរបាលនៅចន្លោះខែមេសា ឆ្នាំ២០១៦ និងខែមីនា ឆ្នាំ២០១៧[41]។

## សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

*ការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌*

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅតែពុំទទួលបានការការពារឱ្យបានពេញលេញនៅឡើយនៅកម្ពុជា។ ការចាប់ខ្លួនជារឿយៗធ្វើឡើងតាមសំណើរបស់អ្នកនយោបាយដែលមានឥទ្ធិពល ដែលបង្ហាញពីនយោបាយូបនីយកម្មលើប្រព័ន្ធច្បាប់ និងប្រព័ន្ធអនុវត្តច្បាប់ក្នុងប្រទេសកម្ពុជាតរៀងមក។ នៅពេលដែលបុគ្គលជាប់ពាក់ព័ន្ធរឿងក្តីនៅក្នុងប្រព័ន្ធយុត្តិធម៌ ជារឿយៗកង្វះការអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ពេលជំនុំជម្រះ។ មានការធ្វេសប្រហែស និងមិនអើពើលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយនិងនីតិវិធីមូលដ្ឋានមួយចំនួនរបស់តុលាការ។ ដូចបានកត់សម្គាល់ក្នុងរបាយការណ៍របស់ ម.ស.ម.ក ស្តីពី «សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងប្រទេសកម្ពុជា ៖ ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍» ដែលធ្វើឡើងពេញមួយឆ្នាំ២០១៧ បានបង្ហាញថា ការសន្មត់ទុកជាមុនថាគ្មានទោសមិនត្រូវបានគោរពឱ្យបានពេញលេញនោះទេ ហើយពុំមានការពិចារណាគ្រប់ជ្រុងជ្រោយចំពោះការចោទប្រកាន់ផ្អែកតាមការសារភាព ដែលជារឿយៗបង្កើតជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោស ហើយដែលការសារភាពនោះធ្វើឡើងក្រោមការគំរាមកំហែងនិងអំពើហិង្សា។ សិទ្ធិមានវត្តមានក្នុងពេលជំនុំជម្រះនិងសិទ្ធិទទួលបានមេធាវីពុំត្រូវបានគោរពឱ្យបានខ្ជាប់ខ្ជួនឡើយ ហើយសិទ្ធិបង្ហាញភ័ស្តុតាងជារឿយៗត្រូវបានអនុវត្តក្នុងលក្ខខណ្ឌរឹតត្បិត។ បន្ថែមលើនោះ ភាគច្រើននៃសំណុំរឿងឧទ្ធរណ៍សាលាឧទ្ធរណ៍គ្រាន់តែប្រកាសតម្កល់សេចក្តីសម្រេចរបស់សាលាដំបូង ឬបញ្ជូនឱ្យជំនុំជម្រះក្តីសារជាថ្មីដោយពុំបានផ្តល់នូវហេតុផលឡើយ។ ជាចុងក្រោយ សិទ្ធិរបស់ចុងចោទដែលជាអនីតិជនដែលទទួលបានការការពារពិសេសក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់កម្ពុជា ជារឿយៗពុំទទួលបានការគោរពពេញលេញឡើយ។[42]

ករណីមួយក្នុងចំណោមករណីដែលបានចេញផ្សាយជាទូទៅនោះ គឺការដាក់ពន្ធនាគារសកម្មជនបឹងកក់អ្នកស្រី ទេព វន្នី។ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ អ្នកស្រីត្រូវបានផ្តន្ទាទោសពីបទ «*ហិង្សាដោយចេតនា*

[41] ម.ស.ម.ក, អាដហុក, មជ្ឈមណ្ឌលសាមគ្គីភាព និង ICNL, "របាយការណ៍ប្រចាំឆ្នាំលើកទី១ នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន" ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ទំព័រទី i,
https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=124&id=5&lang=khm

[42] ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា៖ ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍" ខែមិថុនា ឆ្នាំ ២០១៨ ទំព័រទី០៥
https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=127&id=5&lang=khm

[47] ករណីនេះបានបង្ហាញពីវប្បធម៌និទណ្ឌភាពក្នុងប្រទេសកម្ពុជាឱ្យកាន់តែច្បាស់ថែមទៀត។ ការណ៍នេះអាចនាំអោយជនមានអំណាចធ្វើការបំបិទសំឡេងអ្នកមាននិន្នាការជំទាស់ដោយពុំមានការផ្ដន្ទាទោស ដែលនោះជាការរំលោភសិទ្ធិរបស់ពួកគេ ។

## សិទ្ធិសង្គម និងសេដ្ឋកិច្ច

*<u>ទំនាស់ដីធ្លីនៅតែមិនទាន់ត្រូវបានដោះស្រាយឱ្យបានទូលំទូលាយ</u>*

នៅកម្ពុជា សិទ្ធិដីធ្លីនៅពុំទាន់ត្រូវបានការពារពេញលេញនៅឡើយដែលជាហេតុនាំឱ្យមានទំនាស់ដីធ្លី។ ទោះជារដ្ឋាភិបាលកម្ពុជាបានខិតខំពិនិត្យមើលសម្បទានដីសេដ្ឋកិច្ចយ៉ាងណាក៏ដោយ ក៏ការរំលោភសិទ្ធិដីធ្លីនិងការបណ្ដេញចេញដោយបង្ខំបានបន្តកើតឡើងនាពេលកន្លងមក។ ឧទាហរណ៍ ពលរដ្ឋចំនួន៤០០គ្រួសារដែលរស់នៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពក្នុងខេត្តព្រះវិហារ បានស្វះស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាលនានា និងអង្គការសហប្រជាជាតិក្នុងករណីទំនាស់ដីធ្លីជាមួយរដ្ឋាភិបាល។ ពេលធ្វើការប្រមូលផលកសិកម្មនៅឆ្នាំ១៩៩៣ ពួកគាត់ត្រូវបានរារាំងការសាងសង់ផ្ទះនិងត្រូវបានបង្ខំឱ្យឈប់ប្រមូលផលដំណាំ។ តំណាងសហគមន៍ត្រូវបានតុលាការកោះហៅទាក់ទងនឹងការព្យាយាមបន្តរស់នៅលើដីរបស់ខ្លួន។[48] នៅថ្ងៃទី០៨ ខែធ្នូ ពលរដ្ឋចំនួន១១គ្រួសារមកពីសហគមន៍បុរីកីឡាត្រូវបានសាលារាជធានីភ្នំពេញកំណត់ឱសានវាទឱ្យចាកចេញពីដីធ្លីរបស់ពួកគាត់ ស្របពេលកំពុងមានទំនាស់ដែលអូសបន្លាយជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ផានអ៊ីម៉ិច។ ពុំមានការផ្ដល់សំណង ឬសាងសង់លំនៅដ្ឋានសមរម្យនៅលើទីតាំងនោះជូនគ្រួសារពលរដ្ឋទាំងនោះឡើយ។[49]

រដ្ឋាភិបាលថែមទាំងបានចាត់វិធានការផ្លូវច្បាប់លើអង្គការសង្គមស៊ីវិលដែលធ្វើការជាមួយសហគមន៍មូលដ្ឋានដើម្បីការពារសិទ្ធិដីធ្លីរបស់ពួកគាត់ទៀតផង។ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ សាលាឧទ្ធរណ៍បានតម្កល់ការផ្តន្ទាទោសសកម្មជនអង្គការមោតាធម្មជាតិចំនួន ៣ រូប ដោយសារ «គំរាមថានឹងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដែលភ្ជាប់នូវបញ្ហាអ្វីមួយ»។ ករណីនេះគឺទាក់ទងនឹងហេតុការណ៍ក្នុងឆ្នាំ២០១៥ នៅពេលដែលអ្នកទាំង៣នាក់នោះ គាំទ្រសហគមន៍ធ្វើការតវ៉ាប្រឆាំងនឹងសកម្មភាពបូមខ្សាច់នៅឃុំអណ្ដូងទឹក។[50]

---

[47] "អ្នកនយោបាយបង់បាត់ជីវិតនៅកម្ពុជា៖ ១០១ East ស៊ើបអង្កេតករណីឃាតកម្មដែលស្ថិតក្នុងការសង្ស័យលើសកម្មជននយោបាយនៅកម្ពុជា" Al Jazeera, ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ , https://www.aljazeera.com/programmes/101east/2017/01/cambodia-deadly-politics-170111105925039.html

[48] ផាក់ ស៊ាងលី "អ្នកភូមិស្វែងរកជំនួយពីសង្គមស៊ីវិល, អង្គការសហប្រជាជាតិ អោយជួយដោះស្រាយជម្លោះ" *ភ្នំពេញប៉ុស្តិ៍*, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧, https://www.phnompenhpost.com/national/villagers-seek-ngos-uns-help-dispute

[49] សេចក្ដីថ្លែងការណ៍រួម "អង្គការសង្គមស៊ីវិលសូមអំពាវនាវដល់សាលារាជធានីភ្នំពេញទម្លាក់ចោលឱសានវាទចំពោះប្រជាពលរដ្ឋជាច្រើនគ្រួសារនៅបុរីកីឡា និងសូមផ្ដល់សំណងសមរម្យជូនពួកគាត់ដោយកុំពន្យារពេល" ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ https://cchrcambodia.org/index_old.php?title=CSOs-Call-on-Phnom-Penh-Municipality-to-Drop-Its-Ultimatum-to-Borei-Keila-Families-and-Provide-Proper-Compensation-Without-Delay&url=media/media.php&p=press_detail.php&prid=682&id=5&lang=khm

[50] ទូច សុខា "បណ្ដឹងសារទុក្ខសកម្មជនមាតាធម្មជាតិត្រូវបានច្រានចោល", ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧, https://www.phnompenhpost.com/national/mother-nature-activists-appeal-rejected សេចក្ដីថ្លែងការណ៍រួម "អង្គការសង្គមស៊ីវិលអំពាវនាវឱ្យសាលាឧទ្ធរណ៍បដិសេធសេចក្ដីសម្រេចផ្តន្ទាទោសមិនត្រឹមត្រូវលើសកម្មជនរបស់អង្គការមោតាធម្មជាតិ" ថ្ងៃទី២៩ ខែមក

ខណៈចំនួននៃករណីទំនាស់ដីធ្លី និងការតវ៉ាបានធ្លាក់ចុះក្នុងឆ្នាំ២០១៧ (ធៀបទៅនឹងឆ្នាំ២០១៦) ករណីទំនាស់ដីធ្លីជាច្រើននៅពុំទាន់ត្រូវបានដោះស្រាយ ដែលបន្សល់ទុកប្រជាពលរដ្ឋជាច្រើនគ្រួសារគ្មានផ្ទះសម្បែងឬរបរចិញ្ចឹមជីវិត ។[51]

## សិទ្ធិរបស់កម្មករ

ចាប់តាំងពីការអនុម័តវិសោធនកម្មច្បាប់ស្តីពីសហជីពនៅឆ្នាំ២០១៦ ដែលរឹតត្បិតសិទ្ធិក្នុងការធ្វើកូដកម្ម ធ្វើឱ្យសហជីពត្រូវបានប្រឈម។ ការណ៍នេះជារឿយៗនាំទៅរកការតវ៉ារបស់កម្មករនិយោជិតដើម្បីទាមទារលក្ខខណ្ឌការងារល្អប្រសើរដូចជា ថ្ងៃឈប់សម្រាកបន្ថែម និងបញ្ឈប់ការកាត់ប្រាក់ឈ្នួលនៅថ្ងៃសុំច្បាប់ពេលមានជម្ងឺជាដើម។[52]

សិទ្ធិសេរីភាពខាងការជួបប្រជុំរបស់កម្មករត្រូវបានរំលោភ ព្រោះការតវ៉ានានារបស់ពួកគាត់ត្រូវបានរារាំង ហើយអ្នកចូលរួមព្រមទាំងអ្នករៀបចំប្រឈមការយាយីឬព្យួរការងារដោយសារការចូលរួមរបស់ពួកគាត់។ ឧទាហរណ៍ សមាជិកសហជីពចំនួន១០នាក់ត្រូវបានរោងចក្រ សៅលែន( Southland )ផ្អាកការងារនៅខែមិថុនា បន្ទាប់ពីធ្វើកូដកម្ម។[53] នៅខែកុម្ភៈ ឆ្នាំ២០១៧ តំណាងកម្មករមិនអាចរៀបចំប្រជុំក្នុងភោជនីយដ្ឋានមួយបានដោយសារម្ចាស់ហាងត្រូវបាននគរបាលប្រាប់មិនអនុញ្ញាតឱ្យមានការប្រជុំនេះ។[54]

លើសពីនេះទៀតក្រុមអង្គការដែលធ្វើការងារផ្នែកលើកកម្ពស់សិទ្ធិការងារ និងមេដឹកនាំសហជីពមួយចំនួនបានប្រឈមនឹងការចោទប្រកាន់ព្រហ្មទណ្ឌកាន់តែខ្លាំងឡើង។នៅខែធ្នូ ឆ្នាំ២០១៧ សហជីពដែលមានសម្ព័ន្ធភាពជាមួយរដ្ឋាភិបាលបានដាក់ពាក្យបណ្តឹងប្រឆាំងនឹងអតីតប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីលោកបានអំពាវនាវឱ្យសហគមន៍អន្តរជាតិដាក់ទណ្ឌកម្មលើរដ្ឋាភិបាលកម្ពុជាដោយសាររំលាយគណបក្សសង្គ្រោះជាតិ។[55]

---

រា ឆ្នាំ២០១៧, https://cchrcambodia.org/index_old.php?title=CSOs-call-on-Appeal-Court-to-overturn-wrongful-conviction-of-Mother-Nature-activists&url=media/media.php&p=press_detail.php&prid=649&id=5&lang=khm

[51] ឃី សុវុទ្ធី "ជម្លោះដីធ្លីបានធ្លាក់ចុះក្នុងឆ្នាំ២០១៧", *ខ្មែរថាមស៍*, ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨, https://www.khmertimeskh.com/5099139/disputes-land-fall-2017/

[52] សែន ដាវីដ "កម្មកររោងចក្រចំនួន១៥០នាក់តវ៉ា" *ខ្មែរថាមស៍*, ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧, https://www.khmertimeskh.com/5081520/150-garment-workers-protest/

[53] យុន ស៊ីនាថ, "កម្មកររោងចក្រតវ៉ានៅមុខក្រសួង" *ភ្នំពេញប៉ុស្ត៍*, ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧, https://www.phnompenhpost.com/national/garment-workers-protest-ministry

[54] ម.ស.ម.ក, អាដហុក, មជ្ឈមណ្ឌលសាមគ្គីភាព និង ICNL "របាយការណ៍ប្រចាំឆ្នាំលើកទី១ នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន" ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ទំព័រទី២៤, https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=124&id=5&lang=khm

[55] យូហូវ លីប៉េស ( Joshua Lipes ) "សហជីពគាំទ្ររដ្ឋាភិបាលប្ដឹងលោក ជា មុន្នី ទាក់ទងនឹងការអំពាវនាវឱ្យអន្តរជាតិដាក់ទណ្ឌកម្មលើកម្ពុជា" *វិទ្យុអាស៊ីសេរី*, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧, https://www.rfa.org/english/news/cambodia/sanctions-12192017170117.html

# ឧបសម្ព័ន្ធទី៥ ៖

# របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០១៧

សំណៅកែសម្រួលមិនទាន់ផ្សព្វផ្សាយ

ចែកចាយ៖ ទូទៅ
១៧ សីហា ២០១៧

អត្ថបទដើម៖ ភាសាអង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីសាមសិបប្រាំមួយ**
១១-២៩ កញ្ញា ២០១៧
របៀបវារៈចំណុច២ និងចំណុច១០
**របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ**

**ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

# តួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុង ការជួយឧបត្ថម្ភដល់រដ្ឋាភិបាល និង ប្រជាជនកម្ពុជា ដើម្បីលើកស្ទួយ និង ការពារសិទ្ធិមនុស្ស*

## របាយការណ៍របស់អគ្គលេខាធិការ

*សេចក្តីសង្ខេប*

របាយការណ៍នេះ រួមបញ្ចូលសេចក្តីបរិយាយលម្អិតអំពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) ប្រចាំកម្ពុជា ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៧។

នៅក្នុងអំឡុងពេលនេះ បានសម្គាល់ឃើញការបន្តមានភាពតានតឹងផ្នែកនយោបាយ ការធ្លាក់ចុះនៃលំហសង្គមស៊ីវិល ប៉ុន្តែក៏សម្គាល់ឃើញមានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងការសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រផងដែរ។ នៅខាងចុងនៃរយៈពេលនេះ មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ប្រកបដោយសន្តិភាពនិងរៀបរយ។ ការិយាល័យឧត្តមស្នង

ការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តកម្មវិធីរបស់ខ្លួនខាងសហប្រតិបត្តិការផ្នែកបច្ចេកទេសក្នុងវិស័យសំខាន់ៗមួយចំនួន សម្រាប់ការការពារសិទ្ធិមនុស្ស ជាពិសេស ការគាំទ្រដល់សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ និងសេរីភាពជាមូលដ្ឋានទាំងអស់ដែលពាក់ព័ន្ធ ការពង្រឹងនីតិរដ្ឋ និងការលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

---------------------------------

* របាយការណ៍នេះ កំពុងត្រូវបានដាក់បញ្ជូនយឺត ដើម្បីទុកពេលវេលាច្រើនជាអតិបរមាសម្រាប់រដ្ឋជាសមាជិក ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដាក់ស្នើព័ត៌មានទាំងឡាយដែលពាក់ព័ន្ធ។

# I. សេចក្តីផ្តើម

១. របាយការណ៍នេះ ត្រូវបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយអនុលោមតាមសេចក្តីសម្រេចចិត្តលេខ៣០/២៣ និងបរិយាយអំពីសកម្មភាពរបស់ការិយាល័យឧត្តមស្នងការអង្គការសហ-ប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យOHCHR) ប្រចាំកម្ពុជា ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ។

២. អាណត្តិខាងដើម ត្រូវបានកំណត់ដោយសេចក្តីសម្រេចចិត្តលេខ១៩៩៣/៦ របស់គណៈកម្ម-ការសិទ្ធិមនុស្សថា ការងាររបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំកម្ពុជា ត្រូវបានដឹកនាំដោយសេចក្តីសម្រេចចិត្តលេខ(៣០/២៣)ដែលមានរយៈពេលពីរឆ្នាំ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលរយៈពេលពីរឆ្នាំនេះមានចែងនៅក្នុងអនុស្សារណៈយោគយល់គ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជា[1] និងអាណត្តិសកលរបស់ឧត្តមស្នងការ ដូចដែលមានចែងក្នុងសេចក្តីសម្រេចចិត្តលេខ៤៨/១៤១ របស់មហាសន្និបាត និងសេចក្តីប្រកាសទីក្រុងវីយែន និងកម្មវិធីសកម្មភាពដែលបន្តមានពីមហាសន្និបាតពិភពលោកឆ្នាំ១៩៩៣ ស្តីពីសិទ្ធិមនុស្ស ស្ថិតក្រោមគោលការណ៍សំខាន់ៗដែលមានវិសាលភាពទូលំទូលាយ នៃធម្មនុញ្ញសហប្រជាជាតិ។ អាណត្តិនេះត្រូវបានឲ្យដឹងតាមរយៈសេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សអន្តរជាតិស្តីពីកម្ពុជា ព្រមទាំងការប្តេជ្ញាចិត្តជាសកលក្រោមរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

៣. កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សរបស់កម្ពុជា បានបន្តមានក្នុងសន្ទុះប្រមាណជា ៧ ភាគរយនៅក្នុងអំឡុងឆ្នាំ២០១៦ ហើយសន្ទុះស្ទើរតែដូចគ្នានេះ ត្រូវបានគេរំពឹងថានឹងមានសម្រាប់ឆ្នាំ២០១៧។ [2] កម្ពុជាបានចាកផុតពីឋានៈជាប្រទេសដែលមានប្រាក់ចំណូលទាបកម្រិតមធ្យម

---

[1] អនុស្សរណៈបច្ចុប្បន្ននេះ ត្រូវបានចុះហត្ថលេខាក្នុងខែធ្នូ ឆ្នាំ២០១៦ គ្របដណ្តប់រយៈពេលចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

[2] សូមមើលធនាគារអភិវឌ្ឍន៍អាស៊ី *ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៧៖ ការចាកផុតបញ្ហាប្រឈមខាងប្រាក់ចំណូលមធ្យមកម្រិតទាប* (មេសា ២០១៧) អាចរកបានពី www.adb.org/sites/default/files/publication/237761/ado-2017.pdf និង ទិដ្ឋភាពទូទៅរបស់កម្ពុជា គិតត្រឹមខែមេសា ២០១៧ (ធនាគារពិភពលោក) អាចរកបានពី www.worldbank.org/en/country/cambodia/overview.

(LMIC) នៅក្នុងឆ្នាំ២០១៦។ សន្ទស្សន៍ពហុវិមាត្រនៃភាពក្រីក្រនិងសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស បានបង្ហាញពីការកាត់បន្ថយភាពក្រីក្រយ៉ាងច្រើន [3] បើទោះជានៅមានបញ្ហាប្រឈមដែលរួមមានវិសមភាពនៃប្រាក់ចំណូល ការបែងចែក ឬគម្លាតទីក្រុង-ជនបទ និងភាពងាយរងគ្រោះដែលជាភាពអសកម្មតិចតួចក្តី។ ប្រជាជនប្រហែលជា ៤,៥ លាននាក់ (ច្រើនជាង ២៨ ភាគរយនៃប្រជាជនសរុប) បានចាកផុតពីភាពក្រីក្រក្នុងកម្រិតមួយផិតផើយ ហើយដែលអាចចាត់ថា "ជិតក្រ ឬក្បែរក្រ"។[4] ការដោះស្រាយ "ខ្លឹមនៃភាពក្រីក្រនិងភាពងាយរងគ្រោះ ត្រូវបានកំណត់ដោយរដ្ឋាភិបាលនៅឆ្នាំ២០១៧ ថា ជាបញ្ហាមួយក្នុងចំណោមបញ្ហាប្រឈមពហុវិស័យធំៗនៅថ្ងៃខាងមុខ។ [5] រួមគ្នាជាមួយសមាជិកដទៃទៀត នៃក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ការិយាល័យOHCHR បានចាប់ផ្តើមធ្វើ "ការសិក្សាអំពីភាពងាយរងគ្រោះ" សំដៅគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន។

៤. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ បានឃើញកម្រិតនៃភាពតានតឹងផ្នែកនយោបាយកើតមានស្របគ្នាទៅនឹងចំណាត់ការរបស់តុលាការប្រឆាំងនឹងសមាជិកគណបក្សប្រឆាំង។ មានចំណាត់ការរបស់តុលាការយ៉ាងហោចណាស់ក៏ ២៣ ដែរ ដែលត្រូវបានចាត់ ដោយបានដំណើរការឡើងវិញ ឬបានបន្តធ្វើឡើងប្រឆាំងនឹងតួអង្គគណបក្សប្រឆាំងនៅថ្នាក់ជាតិ និងនៅថ្នាក់មូលដ្ឋាន ដែលនាំឲ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌថ្មីចំនួន ១០ ករណី។ សកម្មភាពនេះគឺផ្ទុយទៅនឹងស្មារតីដែលខួបទីម្ភៃប្រាំនៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយទូលំទូលាយនៃវិវាទនៅកម្ពុជា (កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស) បានប្រារព្ធធ្វើនៅខែតុលាឆ្នាំ២០១៦។ កិច្ចព្រមព្រៀងនេះ បានត្រួសត្រាយផ្លូវសម្រាប់សន្តិភាពដ៏យូរអង្វែងនៅក្នុងប្រទេសកម្ពុជា និងបានបង្កើតជាផែនគ្រឹះនៃរដ្ឋធម្មនុញ្ញកម្ពុជា។ នៅក្នុងសេចក្តីថ្លែងការណ៍នាឱកាសនោះ រាជរដ្ឋាភិបាលកម្ពុជា បានអះអាងជាថ្មី អំពីការប្រាថ្នាចង់បានអធិបតេយ្យភាព បូរណភាពទឹកដី និងសិទ្ធិស្វ័យសម្រេច ដោយរំលេចឲ្យឃើញអំពីការរងទុក្ខវេទនារបស់ប្រជាជនកម្ពុជា បណ្តាលមកពីសង្គ្រាមក្នុងរយៈកាលកន្លងមក។ ទស្សនៈនេះ ដែលក្រោយមក ត្រូវបានបង្កើតទៅជាឯកសារផ្លូវការដែលហៅថា ក្រដាសពណ៌ស ដែលចេញនៅខែមេសាឆ្នាំ២០១៧[6] និងដែលបានធ្វើម្តងទៀត នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះទាំងមូល។ នៅក្នុងឱកាសរំលឹកខួបនេះ អង្គការសង្គមស៊ីវិលបានសង្កត់ធ្ងន់អំពីបទប្បញ្ញត្តិសំខាន់ៗនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទាក់ទងនឹងសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ហើយនិងភាពផុយស្រួយនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដោយសារតែកង្វះប្រសិទ្ធភាពនៃការបែងចែកអំណាចក្នុងរដ្ឋាភិបាល។

៥. ក្នុងរយៈពេលមួយឆ្នាំពេញនេះ ការិយាល័យOHCHR បានបន្តសកម្មភាពសហប្រតិបត្តិការផ្នែកបច្ចេកទេសជាច្រើនជាមួយតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គណៈកម្មាធិការសិទ្ធិ

---

[3] សូមមើលកម្មវិធីអភិវឌ្ឍសហប្រជាជាតិ *របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ២០១៦ ៖ ការអភិវឌ្ឍមនុស្សសម្រាប់គ្រប់គ្នា* (ទីក្រុងញូវយ៉ក ២០១៦)

[4] សូមមើលទិដ្ឋភាពទូទៅរបស់កម្ពុជា (កំណត់ជើងទំព័រលេខ ២ ខាងលើ)

[5] សូមមើលរបាយការណ៍ប្រជុំនៃបណ្តាញក្រុមការងារបច្ចេកទេសក្នុងខែកុម្ភៈ ដែលអាចរកបានពី www.cdc-crdb.gov.kh/cdc/twg_network/twg_network_february_2017/documents/twgreport.pdf.

[6] សូមមើល www.mfaic.gov.kh/wp-content/uploads/2017/04/Ministry-of-Foreign-Affair-201704-388.pdf.

# ឧបសម្ព័ន្ធទី៦ ៖
# ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាក្នុងឆ្នាំ ២០១៨
# នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

# ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាក្នុងឆ្នាំ២០១៨

## សេចក្តីផ្តើម

នៅក្នុងឆ្នាំ២០១៨ ស្ថានភាពសិទ្ធិមនុស្សបានធ្លាក់ដុនដាបខ្លាំងនៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ។ នៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មានការអនុម័តច្បាប់មួយចំនួនដែលមានលក្ខណៈរឹតត្បិតក្នុងគោលបំណងបំបិទសំឡេងជំទាស់។ ក្នុងពេលជាមួយគ្នានេះ លំហសម្រាប់អង្គការសង្គមស៊ីវិលក៏ត្រូវបានបំបិទចំពេលមានការចោទប្រកាន់នានាជុំវិញ"*បដិវត្តន៍ពណ៌*"។ ការជំនុំជម្រះនិងការកាត់ទោសតក់ក្រហល់ទៅលើបុគ្គលដែលរិះគន់រដ្ឋាភិបាល ព្រមទាំងបរិយាកាសអាប់អួនៅជុំវិញការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បាននាំឱ្យការចូលរួមរបស់សាធារណជនក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យធ្លាក់ចុះ។

## សេរីភាពខាងការបញ្ចេញមតិ

*ការបង្កើតបទប្បញ្ញត្តិចំពោះការប្រមាថព្រះមហាក្សត្រ*

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រុមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើវិសោធនកម្មដើម្បីបញ្ចូលមាត្រា ៤៣៧ ស្ទួន ស្តីអំពី «*ការប្រមាថព្រះមហាក្សត្រ*»។[1] បទប្បញ្ញត្តិនេះគឺសំដៅទៅលើការប្រមាថលើអង្គព្រះមហាក្សត្រ ហាមប្រាមការបរិហារ ជេរប្រមាថ ឬការគំរាមកំហែងព្រះមហាក្សត្រតាមរូបភាពណាមួយ ដូចជាតាមរយៈ« *វាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់ព្រះកិត្តិនាមរបស់អង្គព្រះមហាក្សត្រ*»។ ជនដែលរកឃើញថាមានពិរុទ្ធភាពក្រោមមាត្រា៤៣៧ ស្ទួន នេះ នឹងប្រឈមទោសជាប់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.000.000 (ពីរលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល។

បញ្ញត្តិស្តីពីការប្រមាថព្រះមហាក្សត្រនេះ ត្រូវបានអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ («អង្គការ») រិះគន់ជាច្រើន។[2] ទោះបីជាសេរីភាពខាងការបញ្ចេញមតិត្រូវតែស្របគ្នាជាមួយការការពារសិទ្ធិនិងកិត្តិយសរបស់បុគ្គលដទៃក្តី បញ្ញត្តិទាក់ទងនឹងការប្រមាថព្រះមហាក្សត្រនេះ រឹតបន្តឹងយ៉ាងខ្លាំងលើសេរីភាពខាងការបញ្ចេញមតិ។ ការផ្តន្ទាទោសលើកទីមួយក្រោមបញ្ញត្តិនេះបានធ្វើឡើងនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨។ អ្នកស្រី បាន

---

[1] Andrew Nachemson មិុច ដារ៉ា «គណៈរដ្ឋមន្ត្រីអនុម័តវិសោធនកម្មច្បាប់ ដែលមានភាពចម្រូងចម្រាស» សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី០២ កុម្ភៈ ២០១៨ https://www.phnompenhpost.com/national-politics/updated-lese-majeste-law-among-changes-cambodias-constitution-and-penal-code

[2] សេចក្តីថ្លែងការណ៍រួម "អង្គការសង្គមស៊ីវិលសូមអំពាវនាវឱ្យច្រានចោលនូវសេចក្តីព្រាងវិសោធនកម្មលើរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌខណៈដែលមានការដាក់ទណ្ឌកម្មស្របច្បាប់លើសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋកម្ពុជា" ថ្ងៃទី២១ កុម្ភៈ ឆ្នាំ២០១៨ <http://www.licadho-cambodia.org/pressrelease.php?perm=431>

សំភី អតីតសមាជិកគណបក្សសង្គ្រោះជាតិ ("គ.ស.ជ") ត្រូវបានកាត់ទោសដាក់ពន្ធនាគាររយៈពេលមួយឆ្នាំ ដោយសារបានប្រមាថព្រះមហាក្សត្រតាមរយៈការបង្ហោះហ្វេសប៊ុក។[3] មានបុគ្គលបីនាក់ផ្សេងទៀតក៏ត្រូវបាន ចោទប្រកាន់ក្រោមបទប្បញ្ញត្តិថ្មីនេះដែរ។

## ការបំបិទបណ្ដាញផ្សព្វផ្សាយព័ត៌មានឯករាជ្យ

ខណៈមានការបិទបណ្ដាញព័ត៌មានឯករាជ្យទ្រង់ទ្រាយធំក្នុងឆ្នាំ២០១៧ ការបង្ក្រាបទៅលើអ្នកសារព័ត៌មានក៏បន្តកើតមានឡើងក្នុងឆ្នាំ២០១៨ ផងដែរ។ ក្នុងខែមីនា ឆ្នាំ២០១៨ អ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីពីររូប ដែលជាប់ពន្ធនាគារក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ទាក់ទងនឹងការចោទប្រកាន់ពីបទចារកម្ម[4]ត្រូវបានផ្ដន្ទាទោសពីបទផលិតវីដេអូអាសអាភាស[5]។ ទោះបីជាអ្នកទាំងពីរត្រូវបានដោះលែងបន្ទាប់ពីការបោះឆ្នោត[6]នៅខែកក្កដាក្ដី តែករណីនេះបានបង្ហាញពីអវិភាពខ្លាំងឡើងទៅលើអ្នកសារព័ត៌មាន។

នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៨ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ដែលមជ្ឈដ្ឋានមួយចំនួនចាត់ទុកថាជាសារព័ត៌មានឯករាជ្យចុងក្រោយគេនៅកម្ពុជាចាប់តាំងពីការបិទកាសែត ដឹ ខេមបូឌា ដេលី[7] ត្រូវបានលក់ទៅឱ្យលោក ស៊ីវ៉ាកុម៉ា ហ្គាណាផាធី[8](Sivakumar S Ganapathy) ជាអ្នកជំនួយមានទ្រព្យស្ដុកស្ដម្ភជនជាតិម៉ាឡេស៊ី។ ការណ៍នេះបាននាំឱ្យមានអន្តរាគមន៍ភ្លាមៗក្នុងការកែប្រែអត្ថបទព័ត៌មាន តម្រូវឱ្យដកចេញអត្ថបទមួយដែលចេញផ្សាយពីក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយម្ចាស់កាសែតថ្មីរូបនេះ និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ លោក កៃ គឹមសុង ជានិពន្ធនាយកសារព័ត៌មានភ្នំពេញប៉ុស្តិ៍ដែលបម្រើការងារជាយូរមកហើយនោះ ត្រូវបានបណ្ដេញចេញពីតួនាទីទាក់ទងនឹងវិវាទក្នុងការចេញផ្សាយអត្ថបទព័ត៌មាន។[9]

---

[3] ប្រាក់ ចាន់ថុល "កម្ពុជាដាក់ពន្ធនាគារស្ត្រីចំណាស់អាយុ៧០ឆ្នាំពីបទប្រមាថព្រះមហាក្សត្រ" សារព័ត៌មាន*រ៉យទើ* ថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០១៨https://www.reuters.com/article/us-cambodia-crime/cambodia-jails-70-year-old-in-first-conviction-for-royal-insult-idUSKCN1MF0HH

[4] ម៉ិច ដារ៉ា and Yesenia Amaro "អតីតបុគ្គលិកវិទ្យុអាស៊ីសេរីដែលរងការចោទប្រកាន់ពីបទ "ចារកម្ម"ត្រូវបានបញ្ជូនទៅពន្ធនាគារព្រៃស សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២០ វិច្ឆិកា ២០១៧ https://www.phnompenhpost.com/national/ex-rfa-reporters-provisionally-charged-espionage-sent-prey-sar

[5] នៀម ឆេង " អ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីត្រូវបានតុលាការសាកសួរ" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៨ https://www.phnompenhpost.com/national/rfa-journalists-questioned

[6] Joshua Lipes " តុលាការដោះលែងអតីតបុគ្គលិកវិទ្យុអាស៊ីសេរីពីរនាក់ក្រោយការបោះឆ្នោត" *វិទ្យុអាស៊ីសេរី* ថ្ងៃទី២១ ខែសីហា ២០១៨ https://www.rfa.org/english/news/cambodia/bail-08212018150345.html

[7] Julia Wallace, Mike Ives "សារព័ត៌មានឯករាជ្យត្រូវបានលក់ទៅអោយអ្នកជំនួយ ប្រជាជនកម្ពុជាបារម្ភពីការបំបិទសេរីភាពសារព័ត៌មាន កាសែត *ញូវយ៉ក ថាមស៍* ថ្ងៃទី០៧ ខែឧសភា ២០១៨ https://www.nytimes.com/2018/05/07/world/asia/cambodia-phnom-penh-post-sale.html

[8] "កាសែតភ្នំពេញប៉ុស្តិ៍របស់កម្ពុជា ត្រូវបានលក់ទៅឱ្យលោក ស៊ីវ៉ាកូម៉ា ហ្គាណាផាធី" សារព័ត៌មាន *Al Jazeera* ថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០១៨<https://www.aljazeera.com/news/2018/05/cambodia-phnomh-penh-post-sold-malaysian-sivakumar-180505140010847.html>

[9] បុគ្គលិកជាន់ខ្ពស់នៃសារព័ត៌មានភ្នំពេញប៉ុស្តិ៍ត្រូវបានបណ្ដេញចេញពីតួនាទីទាក់ទងនឹងវិវាទក្នុងរឿងចេញផ្សាយអត្ថបទព័ត៌មាន សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ https://www.phnompenhpost.com/national/post-senior-staff-out-dispute-over-article>

នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ("គ.ជ.ប") បានចេញផ្សាយក្រមសីលធម៌សម្រាប់អ្នកសារព័ត៌មាន ដែលបានអំពាវនាវឱ្យអ្នកសារព័ត៌មានប្រកាន់គោលជំហរចេញផ្សាយព័ត៌មានប្រកបដោយវិជ្ជាជីវៈ ត្រឹមត្រូវ និងតម្លាភាពក្នុងអំឡុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅខែកក្កដា[10]។ តាមខ្លឹមសារនៃក្រមសីលធម៌នោះ អ្នកសារព័ត៌មានត្រូវបានហាមប្រាមការរាយការណ៍ព័ត៌មានដែលនាំទៅរកការ "*បាត់ទំនុកចិត្តលើការបោះឆ្នោត*"[11]។

តាមរយៈរបាយការណ៍ស្តីពីសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០១៨ ប្រទេសកម្ពុជាបានធ្លាក់ចុះ១០ថ្នាក់ ទាបជាងឆ្នាំ២០១៧ ដោយស្ថិតក្នុងលេខរៀងទី១៤២ ក្នុងចំណោមប្រទេសដែលត្រូវបានវាយតម្លៃចំនួន១៨០[12]។

## **ការកើនឡើងនូវការចាប់ពិរុទ្ធលើបណ្តាញអ៊ីនធឺណិត**

និន្នាការសំខាន់មួយនៅក្នុងឆ្នាំ២០១៨ គឺការបន្តកើនឡើងនូវការត្រួតពិនិត្យលើបណ្តាញអ៊ីនធឺណិត។ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ក្រសួងចំនួន៣ បានចេញប្រកាសអន្តរក្រសួងស្តីពី «ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា»("ប្រកាស")។[13] ប្រកាសនេះផ្តល់អំណាចដល់រដ្ឋាភិបាលយ៉ាងទូលំទូលាយ និងមិនច្បាស់លាស់ដែលផុតពីដែនកំណត់ដែលច្បាប់សិទ្ធិមនុស្សអន្តរជាតិអនុញ្ញាត។ តាមរយៈការបង្កើតអង្គភាពពិសេសមួយ រដ្ឋាភិបាលនឹងអាច «*ប្រឆាំង ទប់ស្កាត់*» នូវការផ្សព្វផ្សាយនានា ដែលមាន «*ចេតនាបង្កជាចលាចលបណ្តាលឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ ប្រពៃណីជាតិ* »។[14] គេហទំព័រនានាក៏ត្រូវបានតម្រូវថែមទៀតឱ្យចុះបញ្ជីជាមួយក្រសួងព័ត៌មាន[15] បើពុំដូច្នោះទេអាចប្រឈមនឹងការបិទ។ ខណៈពុំមានការត្រួតពិនិត្យរបស់តុលាការផងនោះ ប្រកាសនេះបង្កការរឹតត្បិតតាមអំពើចិត្តទៅលើសេរីភាពខាងការបញ្ចេញមតិ។ រដ្ឋាភិបាលព្រមទាំងបានបញ្ជា

---

[10] សុទ្ធ គឹមសឿន " គជប អនុម័តក្រមសីលធម៌ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៨ ខែឧសភា ២០១៨ https://www.phnompenhpost.com/national/nec-warns-press-elections>

[11] គ.ជ.ប ចេញសេចក្តីថ្លែងការណ៍ទាក់ទងនឹងសិទ្ធិ និងបម្រាមសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន សារព័ត៌មាន*ហ្វ្រេសញ៉ូវ* ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ http://en.freshnewsasia.com/index.php/en/9114-2018-05-24-14-08-40.html>

[12] សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០១៨ អ្នករាយការណ៍គ្មានព្រំដែន https://rsf.org/en/ranking

[13] ម៉ិច ដារ៉ា ហោ គឹមសាយ «ក្រសួង៣បង្កើតក្រុមការងារត្រួតពិនិត្យគេហទំព័រដើម្បីស្វែងរក "ព័ត៌មានមិនពិត" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ https://www.phnompenhpost.com/national/three-ministries-set-web-monitoring-group-look-out-fake-news>

[14] ប្រកាសអន្តរក្រសួងស្តីពី ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជាថ្ងៃទី២៨ខែឧសភា ឆ្នាំ២០១៨ http://safenetvoice.org/wp-content/uploads/2018/06/20180604_Inter-Ministerial_Prakas_On_Social-Media.pdf>

[15] Adrian Shalbaz «សេរីភាពនៅលើបណ្តាញអ៊ីនធឺណិត ឆ្នាំ២០១៨ ការកើនឡើងនូវការគ្រប់គ្រងអ៊ីនធឺណិតតាមបែបផ្តាច់ការ អង្គការសិទ្ធិលំនៅដ្ឋាន (Freedom House) ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៨ https://freedomhouse.org/report/freedom-net/freedom-net-2018/rise-digital-authoritarianism>

ឱ្យគ្រប់បណ្ដាញគមនាគមន៍ក្នុងស្រុក និងអន្តរជាតិនៅកម្ពុជា ធ្វើប្រតិបត្តិការតាមរយៈមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យ ("DMC") បង្កើតឡើងដោយទូរគមនាគមន៍កម្ពុជាគ្រប់គ្រងដោយរដ្ឋ។[16]

នៅមុនថ្ងៃបោះឆ្នោតពីរបីថ្ងៃ យ៉ាងហោចណាស់មានគេហទំព័រព័ត៌មានឯករាជ្យចំនួន១៥ត្រូវបិទពីសំណាក់ក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិតកម្ពុជាតាមការបញ្ជាពីរដ្ឋាភិបាល។[17] អ្នកដែលព្យាយាមចូលទៅកាន់គេហទំព័រទាំងនេះនឹងទទួលបានសារប្រាប់ថាគេហទំព័រ "Error"។[18]

## សេរីភាពខាងការជួបប្រជុំ

មុនការបោះឆ្នោតក្នុងខែកក្កដា ឆ្នាំ២០១៨ សេរីភាពខាងការជួបប្រជុំបន្តរងការប៉ះពាល់។ មន្ត្រី ប្រ.ជ បានគំរាមចាត់វិធានការបន្តបន្ទាប់ដើម្បីបញ្ឈប់បុគ្គលទាំងឡាយណាដែលអំពាវនាវឱ្យធ្វើពហិកាការបោះឆ្នោតដោយអះអាងថាការអំពាវនាវនេះពុំត្រឹមត្រូវតាមច្បាប់កម្ពុជា។[19]

ការធ្វើបាតុកម្មដោយសន្តិវិធី ជារឿយៗត្រូវបានអាជ្ញាធររំបែក ហើយពេលខ្លះឈានដល់ការប្រើអំពើហិង្សា។ នៅខែមីនា ឆ្នាំ២០១៨ កងកម្លាំងសន្តិសុខ និងមន្ត្រីនគរបាលបានរារាំងអ្នកសារព័ត៌មាន អ្នកគាំទ្រ គ.ស.ជ និងសកម្មជនសិទ្ធិមនុស្សពីការចូលរួមសវនាការឧទ្ធរណ៍លើករណីលោក កឹម សុខា ដោយបានដាក់របាំងបិទផ្លូវឆ្ពោះទៅកាន់តុលាការ។ អ្នកគាំទ្រម្នាក់របស់ គ.ស.ជ ត្រូវបានកម្លាំងសន្តិសុខទះកំផ្លៀងខណៈកំពុងកាន់សារគាំទ្រលោក កឹម សុខា។ អ្នកគាំទ្រ គ.ស.ជ និងមន្ត្រីជាច្រើននាក់ទៀតត្រូវបានរារាំងការផ្ដល់សម្ភាសន៍ទៅអ្នកសារព័ត៌មានអំពីព្រឹត្តិការណ៍នេះ។[20] រដ្ឋាភិបាលនៅតែបន្តអះអាងថានោះជាការប៉ុនប៉ងធ្វើ *«បដិវត្តន៍ពណ៌»* នៅពេលធ្វើការរឹតត្បិតលើសេរីភាពមូលដ្ឋាន រួមទាំងសេរីភាពខាងការជួបប្រជុំនោះ។[21]

---

[16] ម៉ិច ដារ៉ា «ការភ្ជាប់ប្រព័ន្ធទូរគមនាគមន៍ តម្រូវឱ្យឆ្លងកាត់តាមបណ្ដាញរដ្ឋ» សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១៨ https://www.phnompenhpost.com/national/ministrys-plan-net-sparks-fears

[17] ស៊ុន ណារិន និង អួន ឆេងប៉រ « រដ្ឋាភិបាលបញ្ជាក់ថាបានរាំងខ្ទប់គេហទំព័រព័ត៌មានឯករាជ្យចំនួន១៥នៅអំឡុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ» *សំឡេងសហរដ្ឋអាមេរិក* ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨ <https://www.voacambodia.com/a/government-confirm-blocking-fifteen-independent-news-sites-over-poll-disruption/4503739.html>

[18] ស៊ុន ណារិន និង អួន ឆេងប៉រ « រដ្ឋាភិបាលបញ្ជាក់ថាបានរាំងខ្ទប់គេហទំព័រព័ត៌មានឯករាជ្យចំនួន១៥នៅអំឡុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ» *សំឡេងសហរដ្ឋអាមេរិក* ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨ <https://www.voacambodia.com/a/government-confirm-blocking-fifteen-independent-news-sites-over-poll-disruption/4503739.html>

[19] បែន សុខហ៊ាន « នាយករដ្ឋមន្ត្រីហ៊ុន សែន ព្រមានចាត់វិធានការលើការចែកចាយខិតប័ណ្ណពហិការបោះឆ្នោត» សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ <https://www.phnompenhpost.com/national/hun-sen-warns-dispersing-election-boycott-leaflet>

[20] នៀម ឆេង Ananth Baliga «សាលាឧទ្ធរណ៍សម្រេចបន្តឃុំខ្លួនលោក កឹម សុខា ខណៈកម្លាំងសន្តិសុខវាយដំលើអ្នកគាំទ្រអតីតមេដឹកនាំរូបនេះនៅខាងក្រៅអគារតុលាការ» សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៧ មីនា ឆ្នាំ២០១៨ <https://www.phnompenhpost.com/national/kem-sokhas-detention-upheld-guards-scuffle-ex-leaders-supporters-outside-courthouse>

[21] ម៉ិច ដារ៉ា Daphne Chen «ទីស្ដីការគណៈរដ្ឋមន្ត្រី ចេញសៀវភៅនិយាយពីបដិវត្តន៍ពណ៌» សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ <https://www.phnompenhpost.com/national-politics/government-unit-publishes-132-page-treatise-threat-colour-revolution>

តាមរបាយការណ៍មួយដែលគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក បានកត់ត្រាករណីរំលោភសិទ្ធិជួបប្រជុំ ពីខែមេសា ឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨ បានបង្ហាញថាមានការហាមប្រាមលើការជួបប្រជុំចំនួន២៦ ករណី។ ភាគច្រើននៃករណីទាំងនោះពាក់ព័ន្ធនឹងការរំលាយ គ.ស.ជ និងលោក កឹម សុខា ដែលនេះបង្ហាញពីចេតនារបស់រដ្ឋាភិបាលក្នុងការបង្ក្រាបលើអ្នកមាននិន្នាការជំទាស់ផ្នែកនយោបាយ។[22]

**សេរីភាពខាងសមាគម**

ក្នុងខែកុម្ភៈ ឆ្នាំ២០១៨ មានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីដាក់បញ្ចូលបទប្បញ្ញត្តិមួយចំនួនដែលតម្រូវឱ្យគណបក្សនយោបាយត្រូវ *«តម្កល់ផលប្រយោជន៍ជាតិជាធំ»*។ បទញត្តិថ្មីទាំងនេះមានខ្លឹមសារគួរឱ្យព្រួយបារម្ភទាក់ទងនឹងសេរីភាពខាងសមាគម។ មាត្រា ៤២ (២) និងមាត្រា ៤៩ (២) ហាមប្រាម «សកម្មភាពណាមួយ» ទោះ *«ដោយផ្ទាល់ក្តីឬដោយប្រយោលក្តី»* នាំឱ្យប៉ះពាល់ដល់*«ផលប្រយោជន៍»* របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរ។ បន្ថែមលើនេះ មាត្រា ៥៣ (៣) ចែងថា *«ព្រះរាជាណាចក្រកម្ពុជាប្រឆាំងដាច់ខាតការជ្រៀតជ្រែកពីបរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួនទោះបីក្រោមរូបភាពណាក៏ដោយ» ។*[23]
វិសោធនកម្មទាំងនេះ ត្រូវបានអនុម័តដោយពុំមានការពិគ្រោះយោបល់ពេញលេញ ដែលអ្នកជំនាញអង្គការសហប្រជាជាតិលើកឡើងថា ធ្វើឱ្យប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យ។[24]

អង្គការសង្គមស៊ីវិលក៏បានលើកឡើងពីក្តីបារម្ភចំពោះការដាក់ទោសទណ្ឌហួសហេតុលើនីតិបុគ្គលតាមរយៈបញ្ញត្តិប្រមាថព្រះមហាក្សត្រដូចលើកឡើងខាងលើផងដែរ។ បន្ថែមលើការទទួលខុសត្រូវទាំងស្រុងចំពោះបទល្មើសប្រព្រឹត្តឡើងដោយតំណាងអង្គភាព នីតិបុគ្គលនោះប្រឈមនឹងទោសពិន័យជាប្រាក់ដោយពុំសមាមាត្រ ឬអាចឈានដល់ការរំលាយស្ថាប័ន។ ទាក់ទងនឹងខ្លឹមសារទូលំទូលាយនៃបទប្បញ្ញត្តិនេះ អង្គការសង្គមស៊ីវិលអាចត្រូវបានរារាំងការអនុវត្តនូវសេរីភាពជាមូលដ្ឋានរបស់ពួកគេ។[25]

មានការលើកឡើងថា មានអង្គការមួយចំនួនស្ថិតក្រោមការឃ្លាំមើលនិងបំភិតបំភ័យពីសំណាក់អាជ្ញាធរនៅពេលធ្វើសកម្មភាពនានា។[26]

---

[22] របាយការណ៍ប្រចាំឆ្នាំទីពីរនៃគម្រោងឃ្លាំមើលសេរីភាពជាមូលដ្ឋាន ដែលអនុវត្តរួមគ្នាដោយ ម.ស.ម.ក សមាគមអាដហុក និង មជ្ឈមណ្ឌលសាមគ្គីភាពថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ <https://cchrcambodia.org/admin/media/report/report/english/FFMP_Second%20Annual%20Report_EN.pdf >

[23] សេចក្តីថ្លែងការណ៍របស់អង្គការសង្គមស៊ិវិល «អង្គការសង្គមស៊ីវិលសូមអំពាវនាវឱ្យប្រានចោលនូវសេចក្តីព្រាងវិសោធនកម្មលើរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ» ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ <http://www.licadho-cambodia.org/pressrelease.php?perm=431>

[24] អ្នកជំនាញអង្គការសហប្រជាជាតិលើកឡើងថា វិសោធនកម្មរដ្ឋធម្មនុញ្ញនៅកម្ពុជាប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យ *ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប* ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ <https://www.ohchr.org/EN/NewsEvents/Pages /DisplayNews .aspx?NewsID=22674&LangID=E>

[25] របាយការណ៍ប្រចាំឆ្នាំទីពីរនៃគម្រោងឃ្លាំមើលសេរីភាពជាមូលដ្ឋាន ដែលអនុវត្តរួមគ្នាដោយ ម.ស.ម.ក សមាគមអាដហុក និង មជ្ឈមណ្ឌលសាមគ្គីភាព ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ <https://cchrcambodia.org/admin/media/report/report/english/FFMP_Second%20Annual%20Report_EN.pdf >

[26] ប្រភពខាងលើ ទំព័រ ២០

## សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

*ការយាយីផ្នែកប្រព័ន្ធតុលាការទៅលើអ្នករិះគន់*

ការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីបង្ក្រាបទៅលើបុគ្គលដែលសម្ដែងការមិនពេញចិត្តរបស់ពួកគេចំពោះរដ្ឋាភិបាលនៅតែកើតមានឡើងជាច្រើន។ អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន មេដឹកនាំសហជីព តំណាងសហគមន៍ និងបុគ្គលផ្សេងទៀតដែលអនុវត្តសេរីភាពជាមូលដ្ឋានរបស់ខ្លួន ជារឿយៗប្រឈមនឹងការយាយីផ្នែកតុលាការ។

នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ តុលាការកំពូលបានតម្កល់សាលដីកាកាត់ទោសសកម្មជនបរិស្ថាន ៣នាក់របស់អង្គការមាតាធម្មជាតិដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីអង្គការ។[27] អ្នកទាំង៣នាក់នោះត្រូវបានចាប់ខ្លួនក្នុងឆ្នាំ២០១៥ ដោយសារពួកគាត់បានចូលរួមក្នុងយុទ្ធនាការដោយសន្តិវិធីប្រឆាំងនឹងការបូមខ្សាច់នៅក្នុងខេត្តកោះកុង។ ការជំនុំជម្រះនោះប្រព្រឹត្តទៅដោយពុំគោរពដល់សិទ្ធិជំនុំជម្រះដោយយុត្តិធម៌ឱ្យបានពេញលេញ។ យោងតាមចៅក្រមជំនុំជម្រះការតម្កល់សាលដីកាកាត់ទោសនេះពីព្រោះមេធាវីការពារក្ដីមិនអាចបង្ហាញពីភាពគ្មានទោសរបស់ជនត្រូវចោទដែលនេះជាការត្រឡប់ដាក់បន្ទុករកភស្តុតាងលើកូនក្តីទៅវិញ។[28]

នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ អ្នកការពារសិទ្ធិមនុស្សចំនួន៤ រូប នៃសមាគមអាដហុក ការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា និងមន្ត្រី គ.ជ.ប មួយរូប ត្រូវបានរកឃើញពិរុទ្ធភាពពីបទសូកប៉ាន់សាក្សីពាក់ព័ន្ធនឹងករណីលោក កឹម សុខា ។[29] អ្នកទាំងនោះត្រូវបានកាត់ទោសដាក់ពន្ធនាគាររយៈពេល ៥ ឆ្នាំ ដោយរួមបញ្ចូលទាំងរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ហើយរយៈពេលទោសដែលនៅសល់ទាំងប៉ុន្មានត្រូវព្យួរ។ ការកាត់ទោសនោះត្រូវបានអង្គការសង្គមស៊ីវិលរិះគន់ជាខ្លាំងថាមិនយុត្តិធម៌ និងធ្វើឡើងក្រោមហេតុផលនយោបាយ។[30]

ម្យ៉ាងទៀត ការដោះលែងពីពន្ធនាគារ ជារឿយៗអាចប្រឈមនឹងការគំរាមបញ្ជូនទៅពន្ធនាគារវិញ។ អ្នកស្រី ទេព វន្នី និងសកម្មជនបឹងកក់ប្រាំរូបផ្សេងទៀតត្រូវបានរកឃើញពិរុទ្ធភាពពីបទ *«គំរាមសម្លាប់»* និងទទួលទោសព្យួរ។ លោក កឹម សុខា ត្រូវបានដោះលែងពីពន្ធនាគារ ហើយក្រោយមកត្រូវដាក់ឱ្យស្ថិតក្នុងការឃុំខ្លួនក្នុងផ្ទះ ដោយពុំអាចចាកចេញទៅទីណាបានក្រៅពីផ្ទះរបស់លោក ព្រមទាំងត្រូវបានរារាំងពីការចូលរួម

---

[27] តុលាការកំពូល តំកល់សាលដីកាផ្តន្ទាទោសលើសកម្មជនចលនាមាតាធម្មជាតិ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ <http://www.licadho-cambodia.org/flashnews.php?perm=251>

[28] ប្រភពខាងលើ

[29] នៀម ឆេង « មន្ត្រីអាដហុក ត្រូវបានតុលាការកាត់ឱ្យជាប់ពន្ធនាគារ ៥ ឆ្នាំ» សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍*ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៨ <https://www.phnompenhpost.com/national/adhoc-5-free-despite-being-sentenced-five-years-jail>

[30] សេចក្តីថ្លែងការណ៍រួម សហគមន៍ និងក្រុមអង្គការសង្គមស៊ីវិលសូមធ្វើការថ្កោលទោសចំពោះការផ្តន្ទាទោសដែលមិនត្រឹមត្រូវចំពោះបុគ្គលិកអង្គការអាដហុកបួនរូបនិងមន្ត្រី គ.ជ.ប មួយរូប» ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ <https://cchrcambodia.org/media/files/press_release/701_jsaanoce_en.pdf>

នយោបាយ។[31] សន្ទស្សន៍នីតិរដ្ឋឆ្នាំ២០១៧-២០១៨ នៃគម្រោងយុត្តិធម៌ពិភពលោក ដែលវាយតម្លៃពីការប្រតិបត្តិនូវនីតិរដ្ឋសម្រាប់ប្រទេសនៅទូទាំងពិភពលោក បានផ្តល់ចំណាត់ថ្នាក់ដល់កម្ពុជាក្នុងលេខរៀងទី១១២ ក្នុងចំណោមប្រទេសចំនួន១១៣។[32]

## វប្បធម៌និទណ្ឌភាព

និទណ្ឌភាពនៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភខ្លាំងនៅកម្ពុជា។ ករណីពាក់ព័ន្ធនឹងបទល្មើសប្រព្រឹត្តទៅលើអ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មានកម្រមានការទទួលខុសត្រូវ។ ក្នុងខែមេសា ឆ្នាំ២០១៨ សាលាឧទ្ធរណ៍បានច្រានចោលសំណើរបស់សកម្មជនបឹងកក់ពីររូបដែលស្នើឱ្យបើកការស៊ើបអង្កេតឡើងវិញក្នុងករណីវាយប្រហារទៅលើប្រជាពលរដ្ឋបឹងកក់ក្នុងឆ្នាំ២០១៣ នៅវត្តភ្នំ ក្នុងរាជធានីភ្នំពេញពីសំណាក់ក្រុមសន្តិសុខដែលស្លៀកពាក់ស្រដៀងឯកសណ្ឋាននគរបាល។[33] ទោះបីជាសាលាដំបូងរាជធានីភ្នំពេញបានចោទប្រកាន់បណ្តោះអាសន្នទៅលើបុគ្គលមិនស្គាល់ឈ្មោះមួយចំនួនពីបទហិង្សាដោយចេតនា និងបានសាកសួរប្រជាពលរដ្ឋរស់នៅតំបន់បឹងកក់មួយចំនួន និងមន្ត្រីខណ្ឌដូនពេញក្តី ចៅក្រមស៊ើបសួរបានទម្លាក់ចោលការចោទប្រកាន់ទាំងនោះ។[34]

ក្នុងឆ្នាំ២០១៨ ករណីនិទណ្ឌភាពជាច្រើននៅពុំទាន់ដោះស្រាយបានអស់នៅឡើយ។ ខែកក្កដាជាខួបគម្រប់ពីរឆ្នាំនៃឃាតកម្មលើលោកបណ្ឌិត កែម ឡី អ្នកវិភាគនយោបាយដែលត្រូវខ្មាន់កាំភ្លើងបាញ់សម្លាប់ទាំងកណ្តាលថ្ងៃ បន្ទាប់ពីលោកបានធ្វើអត្ថាធិប្បាយតាមវិទ្យុអំពីរបាយការណ៍ចម្រូងចម្រាសរបស់អង្គការគ្លូបល វីតណេស (Global Witness) ដែលលើកឡើងអំពីការប្រព្រឹត្តអំពើពុករលួយនៅក្នុងជួរថ្នាក់ដឹកនាំកម្ពុជា។[35] ចាប់តាំងពីឆ្នាំ១៩៩៤ អ្នកសារព័ត៌មានចំនួន១៣ នាក់ ត្រូវបានធ្វើឃាតនៅកម្ពុជា ហើយ១១ករណីក្នុងចំណោមករណីទាំងនេះ ពុំទាន់បានកាត់ទោសជនណាម្នាក់ពីបទឃាតកម្មនៅឡើយ។ ចំណែកករណីពីរទៀតនោះ បើទោះជាមានការជំនុំជម្រះក្តី ក៏ជនដៃដល់មួយចំនួនមិនត្រូវបាននាំមកកាត់ទោសនៅឡើយដែរ។[36]

## សិទ្ធិសង្គម និងសេដ្ឋកិច្ច

*សិទ្ធិដីធ្លី*

---

[31] នៀម ឆេង «លោក កឹម សុខា បាននៅក្រៅឃុំ តែសេរីភាពត្រូវបានរឹតបន្តឹង» សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៨ <https://www.phnompenhpost.com/national/release-sokha-bail-amounts-house-arrest>

[32] សន្ទស្សន៍នីតិរដ្ឋឆ្នាំ២០១៧-២០១៨ នៃគម្រោងយុត្តិធម៌ពិភពលោក <https://worldjusticeproject.org/sites/default/files/documents/WJP_ROLI_2017-18_Online-Edition_0.pdf>

[33] គឹម សារុំ « ឧទ្ធរណ៍បដិសេធបណ្តឹងទាស់របស់អ្នកបឹងកក់ ដែលប្តឹងសន្តិសុខខណ្ឌ» សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៨ <https://www.phnompenhpost.com/national/court-rejects-activists-appeal-reopen-case>

[34] ប្រភពខាងលើ <https://www.phnompenhpost.com/national/court-rejects-activists-appeal-reopen-case>

[35] យុទ្ធនាការលុបបំបាត់និទណ្ឌភាពរបស់ ម.ស.ម.ក ដែលលើកឡើងពីករណីនិទណ្ឌភាពលើបុគ្គលមួយចំនួន < https://www.cchrcambodia.org/our_work/campaigns/impunity-2017/Img/profile/22-Kem-Ley-en.png

[36] សេចក្តីថ្លែងការណ៍រួម អង្គការសង្គមស៊ីវិលសូមអំពាវនាវឱ្យអាជ្ញាធរបង្កើនការប្រយុទ្ធប្រឆាំងទៅនឹងនិទណ្ឌភាពនៅកម្ពុជា https://cchrcambodia.org/index_old.php?title=JOINT-STATEMENT-CSOs-call-on-authorities-to-step-up-the-fight-against-endemic-impunity-in-Cambodia&url=media/media.php&p=press_detail.php&prid=702&id=5>

ការចាប់យកដីធ្លីខុសច្បាប់ និងការបណ្តេញចេញដោយបង្ខំនៅតែបន្តកើតមានឡើង ដែលនេះជាករណីរំលោភសិទ្ធិមនុស្សដ៏រាលដាលមួយក្នុងចំណោមករណីរំលោភសិទ្ធិមនុស្សផ្សេងទៀតនៅកម្ពុជា។ នៅចន្លោះខែមេសា ឆ្នាំ២០១៧ ដល់ខែមីនា ឆ្នាំ២០១៨ មានការប៉ាន់ប្រមាណថា ៣៣% នៃករណីទំនាស់ដីធ្លីនៅកម្ពុជាបាននាំឱ្យមានការរំលោភបំពានទៅលើសេរីភាពមូលដ្ឋាន រួមទាំងវិធានការច្បាប់ និងការឃុំខ្លួនតាមអំពើចិត្ត។[37]

ឧទាហរណ៍ សហគមន៍បុរីកីឡាក្នុងរាជធានីភ្នំពេញដែលពាក់ព័ន្ធក្នុងករណីទំនាស់ដីធ្លីដ៏អូសបន្លាយជាមួយក្រុមហ៊ុន ផានអ៊ីម៉ិច ត្រូវបានរារាំងម្តងហើយម្តងទៀតពីការតស៊ូមតិទាមទារសិទ្ធិរបស់ខ្លួនចាប់តាំងពីក្រុមហ៊ុនបានបណ្តេញប្រជាពលរដ្ឋចំនួន៣០០គ្រួសារចេញពីដីធ្លីរបស់ពួកគាត់ដោយបង្ខំក្នុងឆ្នាំ២០១២។ នៅពេលតវ៉ាដើម្បីទាមទារសំណងសមរម្យនៅឆ្នាំនេះ ប្រជាពលរដ្ឋនៅតំបន់បុរីកីឡាបានប្រឈមការកាត់ទោស និងអំពើហិង្សា។[38] ស្រដៀងគ្នា ក្នុងខែមីនា ឆ្នាំ២០១៨ នគរបាលខេត្តបានបញ្ឈប់កម្មវិធីដែលរៀបចំដោយសម្ព័ន្ធសហគមន៍កសិករកម្ពុជា ដោយបានរារាំងការជួបប្រជុំ និងការយាយីលើអ្នកចូលរួម។[39] ក្នុងខែមេសា ឆ្នាំ២០១៨ ប្រធានសម្ព័ន្ធសហគមន៍កសិករកម្ពុជា ព្រមទាំងតំណាងមួយចំនួនមកពីអង្គការធ្វើការងារផ្នែកសិទ្ធិដីធ្លី ត្រូវបានចោទប្រកាន់តាមរយៈការចេញផ្សាយរបស់កាសែត ហ្វ្រេសញូវ ដែលគាំទ្ររដ្ឋាភិបាលជុំវិញការធ្វើសកម្មភាព «បដិវត្តន៍ពណ៌»។[40]

គិតត្រឹមខែសីហា ឆ្នាំ២០១៨ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានទទួលពាក្យបណ្តឹងចំនួន១,១៣១ ទាក់ទងនឹងទំនាស់ដីធ្លី។ យោងតាមតួលេខក្រសួង ក្នុងចំណោមពាក្យបណ្តឹងទាំងនោះ ៣,៩៦០ករណី ត្រូវបានដោះស្រាយ ២,៨៥៤ពាក្យបណ្តឹង ត្រូវបានច្រានចោល ៨៥៨ពាក្យបណ្តឹង ត្រូវបានដកទៅវិញ និង១,៤៥៩ពាក្យបណ្តឹង កំពុងដំណើរការដែលជិតទទួលបានដំណោះស្រាយ។[41]

## សិទ្ធិកម្មករ

នៅក្នុងខែមិថុនា ឆ្នាំ២០១៨ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ក្នុងគោលបំណងធ្វើឱ្យប្រសើរដល់ជីវភាពរស់នៅរបស់កម្មករនិយោជិត និងធ្វើឱ្យបរិយាកាសធុរកិច្ច និងវិនិយោគមានភាពទាក់ទាញ

---

[37] របាយការណ៍ប្រចាំឆ្នាំទីពីរនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ដែលអនុវត្តរួមគ្នាដោយ ម.ស.ម.ក សមាគមអាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ទំព័រ៣០-៣១ <https://cchrcambodia.org/admin/media/report/report/english/FFMP_Second%20Annual%20Report_EN.pdf >

[38] ប្រភពខាងលើ

[39] សុទ្ធ គឹមសឿន « អាជ្ញាធរចុះបិទវេទិកាសាធារណៈ នៅតំបន់ដែលមានវិវាទដីធ្លី» សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍*ថ្ងៃទី១៦ មីនា ឆ្នាំ២០១៨ <https://www.phnompenhpost.com/national/ccfc-event-blocked-yet-again>

[40] Andrew Nachemson «សារព័ត៌មានហ្វ្រេស ញូវ ចេញផ្សាយអត្ថបទព័ត៌មានដែលសរសេរដោយអ្នកគាំទ្រ ចោទប្រកាន់លើអង្គការសង្គមស៊ីវិលថាមានផែនការប្រឆាំងរដ្ឋាភិបាល» សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍*ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ <https://www.phnompenhpost.com/national/fresh-news-editorial-accuses-orgs-anti-government-plot>

[41] ខុត សុគន្ធ "ទំនាស់ដីធ្លីជាង១០០០ករណី នៅពុំទាន់ដោះស្រាយ" សំឡេងសហរដ្ឋអាមេរិក ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៨ <https://www.vodhotnews.com/2018/10/25/83753/over-1000-cases-of-land-disputes-unsolved/>

# ឧបសម្ព័ន្ធទី៧ ៖
# របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០១៨

អង្គការសហប្រជាជាតិ A/HRC/37/64

**មហាសន្និបាត**

ចែកចាយ៖ ទូទៅ
២ កុម្ភៈ ២០១៨
ឯកសារដើម៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីសាមសិបប្រាំពីរ**
ថ្ងៃទី២៦ ខែកុម្ភៈដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨
របៀបវារៈទី២ និងទី១០
**របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យ ឧត្តមស្នងការ និងអគ្គលេខាធិការ**

**ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

# តួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយដល់រដ្ឋាភិបាលនិងប្រជាជនកម្ពុជា ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស

## របាយការណ៍របស់អគ្គលេខាធិការ


*សេចក្តីសង្ខេប*

ដាក់បញ្ចូលស្របតាមសេចក្តីសម្រេចចិត្តលេខ៣៦/៣២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍នេះបង្ហាញពីតួនាទីនិងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ។

រយៈពេលនេះត្រូវបានកត់សម្គាល់ឃើញមានភាពតានតឹងផ្នែកនយោបាយដែលកំពុងបន្តមាន និងការកាត់បន្ថយបន្ថែមទៀតនូវបរិយាកាសនយោបាយ និងលំហសិទ្ធិពលរដ្ឋ រួមទាំងការបិទ និងការព្យួរសកម្មភាពសិទ្ធិមនុស្ស និងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការខាងប្រព័ន្ធផ្សព្វផ្សាយ ការចាប់ខ្លួនមេដឹកនាំគណបក្សសង្គ្រោះជាតិ និងការរំលាយគណបក្សនេះ ដែលជាគណបក្សប្រឆាំងដ៏ធំមួយ។ ទន្ទឹមនឹងនេះ ក៏ឃើញមានវឌ្ឍនភាពវិជ្ជមានបានកើតឡើងផងដែរ ដូចជាការដាក់បញ្ចូលគោលនយោបាយទាក់ទងនឹងមនុស្សវ័យចំណាស់ និងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើកុមារ និងការតំលើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករបំរើការក្នុងវិស័យឧស្សាហកម្ម វាយនភណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បន្តកម្មវិធីសហប្រតិបត្តិការផ្នែកបច្ចេកទេសរបស់ខ្លួនក្នុងវិស័យសំខាន់ៗ រួមមានការពង្រឹងនីតិរដ្ឋ និងការការពារសេរីភាពមូលដ្ឋាន និងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌និងសិទ្ធិរបស់ប្រជាជនជាប់ឃុំ។

## I. សេចក្តីផ្តើម

១. របាយការណ៍នេះ ត្រូវបានបញ្ជូនស្របតាមសេចក្តីសម្រេចចិត្តលេខ៣៦/៣២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ របាយការណ៍នេះ បង្ហាញពីតួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា(OHCHR) ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្សក្នុងរយៈពេលចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៧។ របាយការណ៍នេះ ធ្វើបច្ចុប្បន្នភាពរបាយការណ៍របស់អគ្គលេខាធិការដាក់ជូនសម័យប្រជុំលើកទីសាមសិបប្រាំមួយ(A/HRC/36/32) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលើប្រធានបទដូចគ្នា។

២. នៅអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានបន្តសកម្មភាពសហប្រតិបត្តិការផ្នែកបច្ចេកទេសជាច្រើនជាមួយតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាដែលជាស្ថាប័នមួយរបស់រដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ និងតួអង្គរដ្ឋាភិបាលនានា សង្គមស៊ីវិល និងដៃគូដទៃទៀត។ ការិយាល័យ OHCHR បន្តឃ្លាំមើលបរិយាកាសសិទ្ធិមនុស្ស រួមទាំងសិទ្ធិក្នុងការចូលរួម និងក្នុងការជួបប្រជុំដោយសន្តិវិធី សវនាការ និងកន្លែងឃុំខ្លួនផ្សេងៗ។

៣. ការិយាល័យ OHCHR បានបន្តធ្វើការយ៉ាងជិតស្និទ្ធផងដែរជាមួយប្រព័ន្ធអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដើម្បីគាំទ្រដល់ការបញ្ជ្រាបសិទ្ធិមនុស្សតាមរយៈការដឹកនាំក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសផ្នែកក្រុមវិស័យសិទ្ធិមនុស្ស គាំទ្រឲ្យមានការបញ្ចូលវិស័យសិទ្ធិមនុស្សទៅក្នុងការវាយតម្លៃជារួមសម្រាប់ប្រទេសសំដៅរៀបចំដំណាក់កាលបន្ទាប់នៃក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិឆ្នាំ២០១៩-២០២៣ និងជួយដល់អង្គការសហប្រជាជាតិក្នុងការវាយតម្លៃវឌ្ឍនភាព និងគាំទ្រដល់ការលើកកម្ពស់សិទ្ធិមនុស្សនៅប្រទេសកម្ពុជា។

## II. ការពារលំហប្រជាធិបតេយ្យ និងលំហសិទ្ធិរបស់ពលរដ្ឋ

៤. រយៈពេលនៃការធ្វើរបាយការណ៍នេះ ឃើញមានការរីករាលដាននៅតែបន្តនូវភាពតានតឹងផ្នែកនយោបាយ និងការកាត់បន្ថយលំហសិទ្ធិរបស់ពលរដ្ឋ។ ក្នុងខែកក្កដា សភាបានអនុម័តវិសោធនកម្មបន្ថែមលើច្បាប់ស្តីពីគណបក្សនយោបាយ ដែលក្នុងចំណោមបទប្បញ្ញត្តិផ្សេងៗ មានអនុញ្ញាតឲ្យមានការព្យួរសកម្មភាពរបស់គណបក្សនយោបាយមួយចំនួនដោយផ្អែកលើហេតុផលផ្សេងៗ។

៥. ក្នុងខែកញ្ញា មេដឹកនាំគណបក្សសង្គ្រោះជាតិ លោក កឹម សុខា ត្រូវបានចាប់ខ្លួនពីបទក្បត់ជាតិពាក់ព័ន្ធនឹងមតិយោបល់ដែលថ្លែងកាលពីឆ្នាំ២០១៣នៅប្រទេសអូស្ត្រាលីស្តីពីយុទ្ធសាស្ត្រយោបាយរបស់លោក ដើម្បីប្រកួតប្រជែងជាមួយរដ្ឋាភិបាល។ សភាបានកំណត់ថាបទល្មើសដែលបានចោទប្រកាន់នេះ គឺជាបទល្មើសជាក់ស្តែង ដែលអនុញ្ញាតឲ្យដំណើរការសំណុំរឿងនេះដោយមិនចាំបាច់លើកអភ័យឯកសិទ្ធសភាររបស់គាត់ឡើយ។ នៅថ្ងៃទី៤ ខែកញ្ញា ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានសម្តែងកង្វល់យ៉ាងខ្លាំងចំពោះការចាប់ខ្លួនលោក កឹម សុខា

ដោយកត់សម្គាល់ថា ការណ៍នេះហាក់ដូចជាត្រូវបានអនុវត្តដោយគ្មានការគោរពចំពោះកិច្ចធានាតាមនីតិវិធីត្រឹមត្រូវ រួមទាំងអភ័យឯកសិទ្ធិសភារបស់លោក សុខា។ នៅថ្ងៃទី១៦ ខែវិច្ឆិកា បន្ទាប់ពីមានបណ្ដឹងដែលបានផ្ដួចផ្ដើមគំនិតដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តុលាការកំពូលបានបញ្ជាឲ្យរំលាយគណបក្សសង្គ្រោះជាតិ និងហាមឃាត់សមាជិកជាន់ខ្ពស់ចំនួន ១១៨ រូប នៃគណបក្សនេះ ដោយរួមបញ្ចូលទាំងសមាជិកសភាទាំងអស់របស់គណបក្សនេះ មិនឲ្យធ្វើសកម្មភាពនយោបាយអស់រយៈពេល ៥ ឆ្នាំ។

៦. ក្នុងខែតុលា រដ្ឋសភាបានអនុម័តវិសោធនកម្មច្បាប់ដាក់ចេញនូវវិធីសាស្ត្រសម្រាប់ការបែងចែកអាសនៈរបស់គណបក្សមួយដែលបានរំលាយក្នុងចំណោមគណបក្សដទៃទៀតនៅថ្នាក់ជាតិ និងថ្នាក់ឃុំសង្កាត់។ នៅថ្នាក់ជាតិ ការរំលាយគណបក្សសង្គ្រោះជាតិបានអនុញ្ញាតឲ្យមានការផ្ទេរអាសនៈរបស់គណបក្សនេះទៅឲ្យគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច និងគណបក្សប្រឆាំងមួយចំនួនដែលមិនមានអាសនៈនៅក្នុងការបោះឆ្នោតជាតិ ឆ្នាំ២០១៣។ នៅថ្នាក់មូលដ្ឋានឃុំទាំងអស់ដែលកាលពីពេលកន្លងមកដឹកនាំដោយគណបក្សសង្គ្រោះជាតិ ត្រូវបានដាក់ឲ្យនៅក្រោមការគ្រប់គ្រងរបស់គណបក្សប្រជាជនកម្ពុជាវិញ។ ក្រោយការវិវត្តទាំងនេះ សមាជិកមួយចំនួនធំនៃគណបក្សដែលបានរំលាយនេះ រួមទាំងសមាជិកសភាជាងពាក់កណ្ដាលបានចាកចេញពីប្រទេស ខណៈដែលអ្នកដទៃទៀតបានចូលរួមជាមួយគណបក្សកាន់អំណាច។ អតីតសមាជិកខ្លះនៃគណបក្សសង្គ្រោះជាតិ បានឲ្យការិយាល័យ OHCHR ដឹងថាពួកគេត្រូវបានគំរាមកំហែងពីសំណាក់នគរបាល ហើយអ្នកខ្លះទៀតត្រូវបានគំរាមចាប់ខ្លួន។

៧. រដ្ឋាភិបាលបានចោទប្រកាន់តួអង្គសង្គមស៊ីវិលនានា ក្នុងនោះមានទាំងប្រព័ន្ធផ្សព្វផ្សាយផងដែរ ថាបានរៀបចំ "បដិវត្តន៍ពណ៌" ហើយជាលទ្ធផលបានកាត់បន្ថយសកម្មភាពរបស់ពួកគេ។ ជាអាទិ៍ ក្នុងខែសីហា រដ្ឋាភិបាលបានដកហូតអាជ្ញាប័ណ្ណស្ថានីយ៍វិទ្យុឯករាជ្យមួយចំនួន ដែលភាគច្រើនចាក់ផ្សាយកម្មវិធីសម្លេងប្រជាធិបតេយ្យ វិទ្យុអាស៊ីសេរី និងវិទ្យុសម្លេងសហរដ្ឋអាមេរិក។ ការកំណត់ឲ្យបង់ពន្ធអាករសរុបចំនួន ៦,៣ លានដុល្លារ លើកាសែតឌឹខេមបូឌាដេលី ដែលជាកាសែតប្រចាំថ្ងៃជាភាសាអង់គ្លេស ដែលជារឿយៗរិះគន់រដ្ឋាភិបាល ត្រូវបានបង្ខំឲ្យបិទការិយាល័យ។ ក្នុងខែវិច្ឆិកា អតីតអ្នកកាសែតពីរនាក់នៃវិទ្យុអាស៊ីសេរី ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទចារកម្មហើយត្រូវប្រឈមនឹងការជាប់ពន្ធនាគារពី៧ ទៅ ១៥ ឆ្នាំ ប្រសិនជាត្រូវបានផ្ដន្ទាទោស។

៨. លើសពីនេះទៅទៀត រដ្ឋាភិបាលបានបញ្ជាឲ្យបិទការិយាល័យនៃវិទ្យាស្ថានជាតិប្រជាធិបតេយ្យនៅកម្ពុជាដោយចោទប្រកាន់ថា ឯកសារមួយចំនួនដែលវិទ្យាស្ថាននេះបានប្រើប្រាស់សម្រាប់បណ្ដុះបណ្ដាលត្រូវបានលាតត្រដាងថាមានការឃុបឃិតគ្នាជាមួយគណបក្សសង្គ្រោះជាតិ ដើម្បីធានាឲ្យគណបក្សនេះទទួលបានជោគជ័យក្នុងការបោះឆ្នោតឆ្នាំ២០១៨។ នៅខែកញ្ញា រដ្ឋាភិបាលបានផ្អាកសកម្មភាពរយៈពេល ៣០ ថ្ងៃ របស់អង្គការសមធម៌កម្ពុជា ដែលជាអង្គការមួយធ្វើការក្នុងវិស័យសិទ្ធិដីធ្លី។ អាជ្ញាធរមិនបានបញ្ជាក់ច្បាស់ថាតើអង្គការនេះអាចបន្តសកម្មភាពរបស់ខ្លួនឡើងវិញបាន ឬយ៉ាងណា នៅពេលដែលការផ្អាកនេះបានបញ្ចប់។ ដូចគ្នានេះដែរ នៅក្នុងខែកញ្ញា ក្រសួងមហាផ្ទៃបានលុបចេញពីបញ្ជីនូវអង្គការមាតាធម្មជាតិដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយខាងបរិស្ថាន ហើយ សមាជិកពីររូបរបស់អង្គការនេះ ចាប់ពីពលនោះមកបានស្ថិតក្នុងការឃុំខ្លួនជាបណ្ដោះអាសន្នពីបទចោទពាក់ព័ន្ធនឹងការប៉ុនប៉ងថតយកសកម្មភាពបូមខ្សាច់ដែលសង្ស័យថាបានធ្វើឡើងដោយខុសច្បាប់។

៩. ភាគច្រើនទូទៅ បទបញ្ជារដ្ឋបាលដែលក្រសួងមហាផ្ទៃបានចេញ តម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានរយៈបីថ្ងៃជាមុននៃសកម្មភាពទាំងអស់ត្រូវបានអមដោយវត្តមាននគរបាលជាច្រើននាក់ ដែលរាប់ទាំងនភ្នាក់ងារគរបាលសម្ងាត់ នៅមុនពេលនិងនៅក្នុងអំឡុងពេលធ្វើសកម្មភាព ឬព្រឹត្តិការណ៍ផ្សេងៗ។ ការិយាល័យ OHCHR បានទទួលរបាយការណ៍ជាច្រើន អំពីការបំភិតបំភ័យរបស់អង្គការសង្គមស៊ីវិល ហើយដែលបង្កឲ្យមានការភ័យខ្លាចក្នុងចំណោមបុគ្គលិករបស់អង្គការទាំងនោះ។[1]

១០. នៅថ្ងៃទី១៨ ខែធ្នូ អ្នកនាំពាក្យរងនៃអគ្គលេខាធិការបានថ្លែងថា អគ្គលេខាធិការមានកង្វល់អំពីការបន្តមានការរួមតូចនៃលំហប្រជាធិបតេយ្យសម្រាប់គណបក្សនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិលនៅមុនការបោះឆ្នោតជាតិ ឆ្នាំ២០១៨ ហើយថាកិច្ចសន្ទនាបែបប្រជាធិបតេយ្យក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ គឺជារឿងសំខាន់ចាំបាច់ដើម្បីឈានទៅរកសង្គមមួយដែលមានសន្តិភាពនិង ស្ថិរភាពច្រើនថែមទៀតនៅក្នុងប្រទេសកម្ពុជា។

១១. ការិយាល័យ OHCHR បានរៀបចំសិក្ខាសាលាដើម្បីបណ្តុះបណ្តាលនិងលើកកម្ពស់ការយល់ដឹងដើម្បីជួយដល់ការងាររបស់សង្គមស៊ីវិល ក្នុងការពង្រឹងការគោរពសេរីភាពក្នុងការជួបជុំគ្នាដោយសន្តិភាព។ ការិយាល័យ OHCHR បានបន្តផ្សព្វផ្សាយច្បាប់ឆ្នាំ២០០៩ ស្តីពីបាតុកម្មដោយសន្តិវិធី និងគោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់នេះ។ ការិយាល័យ OHCHR បានដឹកនាំផងដែរនូវសិក្ខាសាលាបណ្តុះបណ្តាលចំនួន៣ស្តីពីច្បាប់ ដែលមានសិក្ខាកាមចូលរួមចំនួន១១៤ នាក់ មកពីសង្គមស៊ីវិល និងអង្គការសហគមន៍មូលដ្ឋាន សកម្មជនដីធ្លី និងសហជីពកម្មករ មកពីខេត្តបន្ទាយមានជ័យ កោះកុង កំពត និងខេត្តកែប។ ការិយាល័យ OHCHR ត្រូវបានដៃគូអញ្ជើញចូលរួម ថ្លែងសន្ទរកថាក្នុងវគ្គបណ្តុះបណ្តាលជំនាញឯកទេស ក្នុងវគ្គបណ្តុះបណ្តាលទូលំទូលាយ ដូចជាបទប្បញ្ញត្តិច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ក៏ដូចជាការឃ្លាំមើលសិទ្ធិមនុស្ស ដល់អ្នកចូលរួមសង្គមស៊ីវិលចំនួន ១២១ នាក់ ។

១២. ការិយាល័យ OHCHR បានបន្តជួយពង្រឹងសមត្ថភាពសិទ្ធិមនុស្សរបស់អង្គការសង្គមស៊ីវិលកម្ពុជា ដើម្បីតាមឃ្លាំមើលវឌ្ឍនភាពក្នុងការគោរពសិទ្ធិមនុស្ស។ ការិយាល័យ OHCHR បានរៀបចំវគ្គបណ្តុះបណ្តាលចំនួនពីរស្តីពីវិធីសាស្ត្រតាមឃ្លាំមើលសិទ្ធិមនុស្ស ការស្វែងរកការពិត និងការរាយការណ៍ និងផ្តល់សន្តិសុខ និងការពារដល់សកម្មជនសិទ្ធិមនុស្សចំនួន៧៧ នាក់ មកពីរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ ព្រះវិហារ កំពង់ធំ បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ចាម និងសៀមរាប។ សិក្ខាកាមបានផ្តល់សារសំខាន់នៃការបណ្តុះបណ្តាលដល់ការងារប្រចាំថ្ងៃរបស់ពួកគេ ជាពិសេស សារៈសំខាន់នៃការផ្ទៀងផ្ទាត់ព័ត៌មាន ការវិភាគអង្គហេតុ ការរៀបចំចងក្រងឯកសារជាប្រព័ន្ធ និងការយល់ដឹងអំពីហានិភ័យ។

1 សូមមើល www.voacambodia.com/a/un-secretary-general-concerned-by-deteriorating-democratic-space-in-cambodia/4168302.html (www.voacambodia.com/a/អគ្គលេខាធិការ អ.ស.ប មានកង្វល់អំពីការធ្លាក់ចុះនៃលំហប្រជាធិបតេយ្យនៅកម្ពុជា/4168302.html.)

១៣. ការិយាល័យ OHCHR បានបន្តតាមឃ្លាំមើលការជួបជុំជាសាធារណៈ។ ជាអាទិ៍ ក្នុងខែកក្កដា ការិយាល័យ OHCHR បានឃ្លាំមើលការប្រមូលផ្តុំមួយរបស់សកម្មជនសិទ្ធិមនុស្សប្រមាណជា ៣០ នាក់ ដែលបានជួបជុំគ្នានៅមុខសាលាដំបូងរាជធានីភ្នំពេញ ដើម្បីគាំទ្រសកម្មជនដីធ្លី ទេព វន្នី នៅពេលដែលមានសំណុំរឿងក្តីមួយ ប្រឆាំងនឹងគាត់។ ការិយាល័យ OHCHR ក៏បានឃ្លាំមើលការប្រមូលផ្តុំដែលបានលុបចោល បានគ្រោងធ្វើសម្រាប់ខែកញ្ញា ដោយគណបក្សសង្គ្រោះជាតិ ដើម្បីរំលឹកវិញ្ញាណក្ខន្ធជនរងគ្រោះនៃការវាយប្រហារដោយគ្រាប់បែក ឆ្នាំ១៩៩៧។ ការិយាល័យ OHCHR បានបន្តសង្កេតការណ៍ការប្រមូលផ្តុំមួយរបស់សមាជិកសភា និងអ្នកគាំទ្រប្រមាណជា ២០០ នាក់ អំពាវនាវឲ្យមានការដោះលែង លោក កឹម សុខា ដែលសវនាការរបស់គាត់ បានធ្វើឡើងនៅសាលាឧទ្ធរណ៍។

១៤. ការិយាល័យ OHCHR ក៏បានបំពេញបេសកកម្មចំនួនប្រាំ នៅតាមសហគមន៍ជាតិពន្ធុវៀតណាមមួយចំនួននៅរាជធានីភ្នំពេញ និងនៅខេត្តកណ្តាល កំពង់ឆ្នាំង សៀមរាប និងកំពង់ធំដើម្បីស្វែងយល់អំពីបញ្ហាប្រឈមដែលពួកគេបាននិងកំពុងជួបប្រទះទាក់ទងនឹងស្ថានភាពផ្លូវច្បាប់ ការចូលរៀន និងសេវាកម្មមូលដ្ឋានផ្សេងទៀត និងការរើសអើង។

## III. ការលើកស្ទួយនីតិរដ្ឋ

១៥. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានបន្តគាំទ្រដំណើរការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីពង្រឹងនីតិរដ្ឋ និងបានបន្តធ្វើការជាមួយក្រសួងយុត្តិធម៌ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី។

១៦. រួមជាមួយអង្គការអប់រំ វិទ្យាសាស្រ្ត និងវប្បធម៌ នៃសហប្រជាជាតិ(UNESCO) និងអង្គការសង្គមស៊ីវិល ការិយាល័យ OHCHR បានចូលរួមក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដែលក្រសួងព័ត៌មានបានដឹកនាំរៀបចំចាប់តាំងពីឆ្នាំ ២០១៤ រហូតមក។ ការិយាល័យ OHCHR បានចូលរួមក្នុងសម័យប្រជុំចំនួនបីនៃក្រុមការងារបច្ចេកទេសផ្តល់យោបល់ផ្លូវច្បាប់លើសេចក្តីព្រាងនេះ ហើយបានរួមចំណែកធ្វើឲ្យអត្ថបទនេះកាន់តែស្របច្រើនថែមទៀតទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេស សេរីភាពក្នុងការបញ្ចេញមតិ។

១៧. នៅក្នុងខែវិច្ឆិកា ការិយាល័យ OHCHR បានចែករំលែកជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវសេចក្តីព្រាងឯកសារពិភាក្សាមួយស្តីពីការកែទម្រង់ជាសក្តានុពលនៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍សម្រាប់ជនជាតិដើមភាគតិច។ ការិយាល័យ OHCHR បានរៀបចំឯកសារនេះ នៅក្នុងបរិបទនៃលទ្ធភាពពិនិត្យឡើងវិញនូវច្បាប់ភូមិបាល ឆ្នាំ២០០១។ ឯកសារនេះ រួមបញ្ចូលទាំងសេចក្តីវិភាគអំពីបទដ្ឋាន និងនីតិវិធីជាតិបច្ចុប្បន្ន និងមានការផ្តល់មតិយោបល់ ដើម្បីធ្វើឲ្យដំណើរការនេះកាន់តែមានភាពងាយស្រួល ឆាប់រហ័ស និងមានតម្លៃសមរម្យសម្រាប់ជនជាតិដើមភាគតិច។ សេចក្តីព្រាងនេះ ត្រូវបានពិភាក្សាជាមួយក្រសួងពាក់ព័ន្ធនានានៅថ្នាក់បច្ចេកទេស ព្រមទាំងជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា មុនពេលធ្វើបញ្ចប់ និងធ្វើបទបង្ហាញផ្លូវការដល់រាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ២០១៨ ។

១៨. នៅក្នុងខែធ្នូ ការិយាល័យ OHCHR និងសហព័ន្ធសហជីពអន្តរជាតិ(ITUC) បានរៀបចំសន្និសីទច្បាប់ នៅរាជធានីភ្នំពេញ ដោយមានសិក្ខាកាមប្រមាណជា ៨០ នាក់ តំណាងឲ្យរដ្ឋាភិបាលកម្ពុជា អង្គការពលកម្មអន្តរជាតិ(ILO) សហជីពកម្មករក្នុងស្រុក សហព័ន្ធសហជីពអន្តរជាតិ និងក្រុមហ៊ុនឯកជន និងស្ថានទូតនានា ដើម្បីពិនិត្យឡើងវិញលើវឌ្ឍនភាពទាក់ទងនឹងការចរចានិងការកំណត់ប្រាក់ឈ្នួលអប្បបរមា ការចុះបញ្ជីសហជីពកម្មករ និងការចរចាជាសមូហភាព និងការដោះស្រាយវិវាទ។ គោលបំណងនៃសន្និសីទនេះ គឺដើម្បីជម្រុញឲ្យមានការព្រមព្រៀងគ្នាមួយរវាងអ្នកពាក់ព័ន្ធលើវិធានការច្បាប់ដែលមានប្រសិទ្ធភាព ស្របតាមអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ និងបទដ្ឋាន សិទ្ធិមនុស្សនិងអនុសាសន៍ផ្សេងៗទៀត។

១៩. ការិយាល័យ OHCHR បានបន្តដើរតួនាទីជាអ្នកសម្រួលដៃគូម្ចាស់ជំនួយនៃក្រុមការងារបច្ចេកទេសស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលមានក្រសួងយុត្តិធម៌ជាសហប្រធាន។ ជាផ្នែកមួយនៃសកម្មភាពដែលបានគ្រោងទុកដែលត្រូវបានត្រួតពិនិត្យដោយប្រើប្រាស់សូចនាករតាមដានរួមនៃក្រុមការងារបច្ចេកទេស ការិយាល័យ OHCHR និងក្រសួងយុត្តិធម៌បានសហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងបណ្តាញជំនួយផ្នែកច្បាប់អាស៊ីអាគ្នេយ៍ បានរៀបចំសិក្ខាសាលាស្តីពីការអនុវត្តល្អក្នុងតំបន់ ក្នុងការអភិវឌ្ឍគោលនយោបាយជំនួយផ្នែកច្បាប់នាខែសីហា ។ សិក្ខាសាលានេះបានជួយកំណត់នូវលក្ខណៈវិនិច្ឆ័យជាមូលដ្ឋានដែលគួរតែត្រូវបានបញ្ចូលក្នុងគោលនយោបាយជំនួយផ្នែកច្បាប់ ដែលនឹងត្រូវព្រាងនៅឆ្នាំ២០១៨ ដើម្បីជួយធានាថាជំនួយបែបនេះត្រូវបានផ្តល់លក្ខណៈជាប្រព័ន្ធដល់អ្នកទាំងឡាយដែលត្រូវការជំនួយនេះ។

២០. ដើម្បីឆ្លើយតបទៅនឹងតម្រូវការជំនួយផ្នែកច្បាប់បន្ទាន់ ការិយាល័យ OHCHR បានផ្តល់ជំនួយដល់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកទាំងឡាយដែលបានដាក់ពាក្យបណ្តឹងទាក់ទងទៅនឹងសិទ្ធិសេដ្ឋកិច្ច និងសង្គម ជាពិសេស សិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន និង ក្នុងករណីបណ្តឹងឧទ្ធរណ៍ជាអាទិភាពចំនួន ១៥២ ករណី ដើម្បីជួយដល់ជនជាប់ឃុំឲ្យទទួលបានសាលក្រមស្ថាពរ។

២១. ជាផ្នែកមួយនៃកម្មវិធីកេរ្តិ៍ដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យ OHCHR រួមគ្នាជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំកិច្ចសន្ទនាផ្នែកច្បាប់ជាបន្តបន្ទាប់ ក្នុងឆ្នាំ២០១៧។ កិច្ចប្រជុំខែវិច្ឆិកា ដែលមានវត្តមានអ្នកចូលរួមចំនួនច្រើនបំផុតនៃមេធាវីជាតិនៃកម្រងឯកសារទាំងមូល បានផ្តោតលើការកសាងយុទ្ធសាស្ត្រការពារក្តី និងការធ្វើជាតំណាងប្រកបដោយប្រសិទ្ធភាពនៃដើមបណ្តឹងរដ្ឋប្បវេណី។

២២. ការិយាល័យ OHCHR បានឃ្លាំមើលដំណើរការនីតិវិធីរបស់តុលាការនៅក្នុងករណីជាច្រើន ដោយធ្វើការកំណត់អំពីភាពចន្លោះប្រហោងក្នុងការអនុវត្តបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ប្រសិនជាតម្រូវឲ្យមានការជួយឧបត្ថម្ភផ្នែកបច្ចេកទេសបន្ថែមទៀត ជាពិសេស ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ជាក់ស្តែង ការិយាល័យ OHCHR បានឃ្លាំមើលករណីនិទណ្ឌភាពពីអតីតកាលនិងបច្ចុប្បន្នដែលជនល្មើសមិនត្រូវបានចាប់ខ្លួន ឬផ្តន្ទាទោស។ ស្ថានភាពនេះរួមចំណែកដល់ការបាត់បង់ជំនឿលើប្រព័ន្ធយុត្តិធម៌ និងក្នុងករណីបទល្មើសដែលគេអះអាងថាអាជ្ញាធរមូលដ្ឋានជាអ្នកប្រព្រឹត្ត បានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិអំណាចរបស់តុលាការ។

២៣. និទណ្ឌភាពចំពោះករណីនៃយុត្តិធម៌ដោយហ្វូងមនុស្សនៅតែជាបញ្ហាកង្វល់ដដែល។ អំពើហឹង្សាដោយហ្វូងមនុស្សប្រឆាំងជនដែលគេអះអាងថាជាចោរ ជាទូទៅគឺជាប្រតិកម្មភ្លាមៗចំពោះឧប្បត្តិហេតុចោរកម្ម ហើយការចោទប្រកាន់ធម្មតាៗគឺគ្រប់គ្រាន់ដើម្បីញុះញង់ឲ្យហ្វូងមនុស្សប្រើអំពើហិង្សាធ្វើមនុស្សស្លាប់ ដោយមានអន្តរាគមន៍ប្រតិកម្មតិចតួច ឬគ្មានទាល់តែសោះពីនគរបាល។ ការស៊ើបអង្កេតកម្របានឡើងឡើងបន្ទាប់ពីឧប្បត្តិហេតុទាំងនេះ ហើយជាទូទៅករណីបែបនេះត្រូវបានបិទតាំងពីដំណាក់កាលដំបូង ដោយចាត់ទុកថាបានដោះស្រាយរួចហើយ។

២៤. ការិយាល័យ OHCHR បានបន្តធ្វើការផងដែរ លើករណីឃាតកម្មលើមនុស្សដែលត្រូវបានចោទប្រកាន់ពីអំពើអាបធ្មប់។ ការសម្លាប់ទាក់ទងនឹងអំពើអាបធ្មប់ ត្រូវបានគេរាយការណ៍ថា បានកើតមានជាញឹកញាប់នៅមុនទស្សវត្សរ៍ ឆ្នាំ១៩៦០ ហើយថ្មីៗបំផុតនេះ ក្នុងទស្សវត្សរ៍ ឆ្នាំ១៩៨០ និងទសវត្សរ៍ ឆ្នាំ១៩៩០។ ក្នុងឆ្នាំ២០១៧ ករណីចំនួននៃការរំលោភសិទ្ធិមនុស្សបានរាយការណ៍ទាក់ទងនឹងអាបធ្មប់មានការថយចុះ ប៉ុន្តែករណីនេះនៅតែជាក្តីកង្វល់ជាពិសេសនៅតំបន់ជនបទដាច់ស្រយាលក្នុងប្រទេស។ ជាទូទៅនគរបាលមានឆន្ទៈក្នុងការស៊ើបអង្កេតករណីទាំងនេះ ប៉ុន្តែបុគ្គលដែលគេអះអាងថាជាជនដៃដល់ កម្រនឹងត្រូវបានគេចាប់ខ្លួនណាស់ ដោយសារនគរបាលខ្វះខាតធនធាន និងខ្លាចមានការសងសឹកពីប្រជាជនក្នុងមូលដ្ឋាន។ ក្នុងករណីជាច្រើន នគរបាល និងអាជ្ញាធរមូលដ្ឋាន បានពិភាក្សាជាមួយការិយាល័យ OHCHR ពីលទ្ធភាពគាំទ្រការលើកកម្ពស់ការយល់ដឹងអំពីការចោទប្រកាន់អំពើអាបធ្មប់ និងការបង្ការអំពើហិង្សាដោយហ្វូងមនុស្ស ដែលការិយាល័យ OHCHR ដែលនឹងបន្តតាមដានជាមួយក្រសួងមហាផ្ទៃ។

២៥. ជាផ្នែកមួយនៃការអនុវត្តអនុសាសន៍ជុំទីពីរ នៃការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ស្តីពីកំណែទម្រង់វិស័យយុត្តិធម៌[2] ការិយាល័យ OHCHR បានរៀបចំកិច្ចប្រជុំជាបន្តបន្ទាប់ជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានការចូលរួមពីចៅក្រម ព្រះរាជអាជ្ញា និងប្រធានលេខាធិការដ្ឋានរដ្ឋបាល ដើម្បីពិភាក្សាអំពីការសម្របសម្រួលរវាងមុខងាររដ្ឋបាល និងមុខងារជុំនំជម្រះក្តីរបស់ពួកគេ ជាពិសេសនៅក្នុងបរិបទនៃច្បាប់ស្តីពីការរៀបចំតុលាការ។ ក្នុងអំឡុងពេលជួបប្រជុំទាំងនេះ តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រសួងយុត្តិធម៌ បានផ្តល់ការណែនាំ និងការឆ្លើយតបបញ្ហាមួយចំនួនដែលបានជួបប្រទះ។

២៦. ការិយាល័យ OHCHR បានបន្តគាំទ្រការធ្វើឲ្យប្រសើរឡើងដល់ការគ្រប់គ្រងករណី និងសិទ្ធិទទួលបានព័ត៌មានតុលាការ ដោយពង្រីកមូលដ្ឋានទិន្នន័យសំណុំរឿងព្រហ្មទណ្ឌក្នុងសាលាដំបូងចំនួនប្រាំមួយ និងសម្រួលដល់សិក្ខាសាលាចំនួនពីរ ស្តីពីការចុះបញ្ជីករណី ដែលបានប្រព្រឹត្តទៅនៅខេត្តព្រះសីហនុ ក្នុងខែកក្កដា និងខែសីហា និងនៅរាជធានីភ្នំពេញ ក្នុងខែវិច្ឆិកា។ ការិយាល័យ OHCHR បានគាំទ្រដល់ការបញ្ចូលមេរៀនថ្មីមួយ ដើម្បីរាយការណ៍អំពីករណីអំពើហិង្សាលើស្ត្រីដែលជាផ្នែកមួយនៃការធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ។ ករណីជាច្រើន បាននិងកំពុងចុះបញ្ជីកាន់តែកើនឡើងនៅក្នុងតុលាការចំនួន១២ ដែលប្រព័ន្ធទិន្នន័យត្រូវបានបង្កើតឡើង ថ្វីបើបញ្ហាប្រឈមនៅតែមានក្នុងការធានាឲ្យការថតចម្លងរបស់គេ បានទាន់ពេលវេលា។

[2] សូមមើលរបាយការណ៍ A/HRC/26/16 កថាខណ្ឌ ១១៨.២៤, ១១៨.៧៩ និង១១៨.៨១–១១៨.៩០។

២៧. ក្នុងខែតុលា ដោយសហការជាមួយក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការិយាល័យ OHCHR បានធ្វើសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់តំបន់មួយ សម្រាប់ចៅក្រមនៅខេត្តព្រះវិហារស្តីពីការអនុវត្តរូបមន្តថ្មីសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន។ សិក្ខាសាលានេះ បានផ្តោតលើសារសំខាន់នៃការផ្តល់ហេតុផលស្របច្បាប់ នៅពេលសម្រេចលើករណីស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ស្របតាមគោលការណ៍ណែនាំស្តីពីការឃុំខ្លួនបណ្តោះអាសន្នដែលចេញដោយក្រសួងយុត្តិធម៌នៅឆ្នាំ២០១៤។ សិក្ខាសាលាថ្នាក់តំបន់នឹងបន្តធ្វើនៅឆ្នាំ២០១៨ គ្របដណ្តប់លើតុលាការច្រើនថែមទៀត។

## IV. គាំទ្រកំណែទម្រង់ពន្ធនាគារ

អគ្គនាយកដ្ឋានពន្ធនាគារ បានបន្តការអនុញ្ញាតឲ្យការិយាល័យ OHCHR ធ្វើទស្សនកិច្ចនៅពន្ធនាគារចាប់ពីខែកក្កដា ដល់ខែធ្នូ។ ទោះជាយ៉ាងណាក៏ដោយ ការិយាល័យ OHCHR នៅតែរក្សាការហាមឃាត់ ដូចដែលបានកំណត់ក្នុងឆ្នាំ២០១៦ ជំទាស់នឹងការធ្វើសម្ភាសន៍ជាសម្ងាត់ជាមួយជនជាប់ឃុំ។ ការសំខាន់ចាំបាច់សម្រាប់ការិយាល័យ OHCHR ក្នុងការធ្វើសម្ភាសន៍គ្រប់ជ្រុងជ្រោយជាសម្ងាត់ជាមួយជនជាប់ឃុំ ដើម្បីធានានូវគុណភាព និងសុវត្ថិភាពនៃទំនាក់ទំនងអន្តរកម្មរបស់ខ្លួន។

២៩. ការិយាល័យ OHCHR បានធ្វើទស្សនកិច្ចចំនួនប្រាំបួន លើកទៅកាន់ពន្ធនាគារចំនួនប្រាំមួយនៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ហើយដែលបន្ទាប់ពីនោះ ការិយាល័យOHCHR បានផ្តល់អនុសាសន៍ទៅថ្នាក់គ្រប់គ្រងពន្ធនាគារសាមី និងបានលើកបញ្ហាជាទូទៅដែលកើតមានចំពោះពន្ធនាគារច្រើនរួម ជាមួយក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានពន្ធនាគារ។ ការិយាល័យOHCHR បានធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីទទួលបន្ទុកសំណុំរឿង ដើម្បីកំណត់ករណីអាទិភាពសម្រាប់ការដោះលែង។

៣០. "យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ដែលមានរយៈពេល៦ ខែ" ដែលបានប្រកាសបើកក្នុងខែមករា និងបន្តជាថ្មីក្នុងខែមិថុនា បាននាំឲ្យមានការកើនឡើងយ៉ាងខ្លាំងនូវចំនួនជនជាប់ឃុំ។[3] នៅក្នុងប្រព័ន្ធមួយដែលមានសមត្ថភាពលើសចំណុះរួចហើយនោះ បញ្ហានេះបានដាក់សម្ពាធបន្ថែមទៀតទៅលើកន្លែងឃុំឃាំង និងបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ថានភាពរស់នៅនិងសុខភាពរបស់ជនជាប់ឃុំ ក៏ដូចជាបរិយាកាសការងាររបស់បុគ្គលិកពន្ធនាគារផងដែរ។ ចំនួនជនជាប់ឃុំគ្មានសាលក្រម នៅតែមានកម្រិតខ្ពស់ ដោយមានជនជាប់ឃុំត្រឹមតែ ២៥ ភាគរយប៉ុណ្ណោះ ដែលមានសាលក្រមស្ថាពរ គិតត្រឹមខែធ្នូ។

៣១.ក្នុងខែសីហា ព្រះរាជក្រឹត្យមួយត្រូវបានចេញ ដើម្បីលុបចោលអនុក្រឹត្យស្តីពីការបង្កើតយន្តការ បង្ការថ្នាក់ជាតិ ដែលបង្កើតឡើងក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត មកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (OP-CAT)។ ព្រះរាជក្រឹត្យនេះ ចែងអំពីការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធយន្តការបង្ការទារុណកម្ម ប៉ុន្តែការអនុវត្តនឹងត្រូវរង់ចាំការអនុម័តបទប្បញ្ញត្តិបន្ថែម។ កង្វល់នៅតែមានអំពីការប្រព្រឹត្តទៅប្រកបដោយឯករាជ្យនៃយន្ត

[3] ចំនួនជនជាប់ឃុំសរុបមានការកើនឡើងប្រមាណជា ៣០ ភាគរយ ចាប់ពីខែធ្នូ ឆ្នាំ២០១៦ ដល់ខែធ្នូ ឆ្នាំ២០១៧។

ការនេះទាក់ទងនឹងក្របខណ្ឌច្បាប់ ការជ្រើសរើសសមាជិក តួនាទី និងភារកិច្ច និងមូលនិធិរបស់យន្តការនេះ។

៣២. ការិយាល័យ OHCHR បានធ្វើបទបង្ហាញសិទ្ធិមនុស្សចំនួនពីរលើក សម្រាប់មន្ត្រីនគរបាល និងកងរាជអាវុធហត្ថថ្នាក់មូលដ្ឋានជាង ១០០ នាក់ នៅខេត្តក្រចេះក្នុងខែកក្កដា និងនៅខេត្តត្បូងឃ្មុំក្នុងខែកញ្ញា។ ការធ្វើបទបង្ហាញនេះ បានផ្តោតលើការបង្ការទារុណកម្ម សិទ្ធិនៅពេលចាប់ខ្លួន និងការប្រើប្រាស់កម្លាំងដោយមន្ត្រីអនុវត្តច្បាប់។ ការិយាល័យ OHCHR បានផ្តល់ឱកាសឲ្យមន្ត្រីមូលដ្ឋាន រៀបចំកិច្ចសន្ទនាមួយជាមួយព្រះរាជអាជ្ញា។

៣៣. ការិយាល័យ OHCHR បានបន្តសហការជាមួយគ្រូបង្គោលមកពីអគ្គនាយកដ្ឋានពន្ធនាគារ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់មន្ត្រីពន្ធនាគារនៃបណ្ឌិត្យសភានគរបាលកម្ពុជាដើម្បីកែលម្អដល់ការបណ្តុះបណ្តាលមន្ត្រីពន្ធនាគារ។ ដូច្នេះ ក្នុងខែសីហា និងខែវិច្ឆិកា ការិយាល័យ OHCHR បានសហការរៀបចំទស្សនកិច្ចសិក្សារួមគ្នាចំនួនពីរ ទៅកាន់ពន្ធនាគារចំនួនពីរសម្រាប់មន្ត្រីពន្ធនាគារដែលធ្វើកម្មសិក្សាចំនួន ៩៤ នាក់ និងគ្រូបង្គោលរបស់ពួកគេចំនួន ២០ នាក់ ហើយដែលសកម្មភាពនេះអនុញ្ញាតឲ្យពួកគេសិក្សាស្វែងយល់ពីបរិបទមុខវិជ្ជា នៅក្នុងបរិយាកាស់ជាក់ស្តែងក្នុងពន្ធនាគារ ។ ក្នុងខែវិច្ឆិកា ការិយាល័យ OHCHR បានផ្តល់វគ្គបណ្តុះពណ្តាលមួយស្តីពីការបង្ការទារុណកម្មនិងវិធីសាស្រ្តផ្អែកលើសិទ្ធិមនុស្ស ក្នុងការគ្រប់គ្រងពន្ធនាគារសម្រាប់មន្ត្រីថ្មីចំនួន ៤៧ នាក់។ ការិយាល័យ OHCHR បានធ្វើការផងដែរ ជាមួយគ្រូបង្គោល ដើម្បីពិនិត្យឡើងវិញនូវមេរៀនទាក់ទងនឹងសិទ្ធិមនុស្សនៃកម្មវិធីសិក្សារបស់ពួកគេ មុនពេលចងក្រងមេរៀនជ្រើសសម្រាំងមួយចំនួន ដើម្បីបោះពុម្ព និងផ្សព្វផ្សាយ។

៣៤. ដើម្បីជួយជនជាប់ឃុំដែលមានជំងឺទទួលបានការថែទាំផ្នែកវេជ្ជសាស្រ្ត ដោយគ្មានការប្រើប្រាស់ឧបករណ៍រឹតត្បិតសេរីភាពបន្ថែមនៅតាមមន្ទីរពេទ្យនៅខាងក្រៅកន្លែងឃុំឃាំង ការិយាល័យ OHCHR នៅតែបន្តធ្វើការជាមួយអាជ្ញាធរជាតិ និងអាជ្ញាធរខេត្ត និងអាជ្ញាធរពន្ធនាគារ ដើម្បីរៀបចំប្រព័ន្ធសន្តិសុខក្នុងបន្ទប់សុវត្ថិភាពនៅមន្ទីរពេទ្យបង្អែកខេត្តត្បូងឃ្មុំ។

៣៥. រួមជាមួយនឹងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ(ICRC) និងការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាកម្មគម្រោង (UNOPS) ការិយាល័យ OHCHR បានធ្វើការតស៊ូមតិដើម្បីធ្វើបញ្ចប់សេចក្តីណែនាំបន្ថែមសម្រាប់រៀបចំ បទដ្ឋានអប្បបរមាសម្រាប់ការសាងសង់ និងការជួសជុលពន្ធនាគារ ដែលបានកំណត់នៅក្នុងច្បាប់ឆ្នាំ២០១១ ស្តីពី ពន្ធនាគារ ហើយដែលបានទន្ទឹងរង់ចាំជាយូរមកហើយ ។ ដោយធ្វើការជាមួយគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ(ICRC) ការិយាល័យOHCHR បានបន្តតាមដាននៅខែតុលាជាមួយអគ្គនាយកដ្ឋានពន្ធនាគារលើសេចក្តីព្រាងចុងក្រោយនៃច្បាប់ និងគោលការណ៍ណែនាំបច្ចេកទេសរបស់ការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាកម្មគម្រោង (UNOPS) ស្តីពីការរៀបចំផែនការកសាងពន្ធនាគារ។

៣៦. ក្រៅពីនេះទៀត ការិយាល័យ OHCHR បានគាំទ្រកិច្ចប្រជុំចំនួនពីរ សម្រាប់មន្ត្រីនគរបាលមូលដ្ឋាន តុលាការ និងពន្ធនាគារខេត្តប៉ៃលិននៅក្នុងខែកក្កដា និងខេត្តកំពង់ស្ពឺនៅក្នុងខែតុលា ដើម្បីពិភាក្សាអំពីវិះរកដំណោះស្រាយដែលអាចធ្វើបានចំពោះបញ្ហាការលើកកម្ពស់ការផ្តល់យុត្តិធម៌នៅថ្នាក់មូលដ្ឋា

ន។ ការិយាល័យ OHCHR បានតស៊ូមតិប្រកបដោយជោគជ័យជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរជាតិ ដើម្បីធានាការដោះលែងមនុស្សចំនួន ១០ នាក់ ដែលត្រូវបានឃុំខ្លួនហួសនីតិវិធី ។

## V. ការពារសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

៣៧. កំណើនសេដ្ឋកិច្ចបានបន្តកើនឡើងកម្រិតខ្ពស់បំផុតស្មើរតែ ៧% ក្នុងរយៈពេលធ្វើរបាយការណ៍នេះ[4] ហើយភាពក្រីក្របានបន្តថយចុះ បើទោះជាមានចំនួនប្រជាជនជិត ១/៣ នៅតែរស់នៅក្បែរបន្ទាត់ភាពក្រីក្រក៏ដោយ ហើយហានិភ័យអាចវិលមករកភាពក្រីក្រវិញបាន។ ជាលទ្ធផលវាមានសារៈសំខាន់សម្រាប់កំណើនសេដ្ឋកិច្ច ដែលត្រូវអមដោយគោលនយោបាយផ្អែកលើសិទ្ធិ ដើម្បីបង្កើតលទ្ធផលនៃការអភិវឌ្ឍមនុស្សប្រកបដោយចីរភាព។ ការិយាល័យ OHCHR ស្វាគមន៍វិធានការវិជ្ជមានមួយចំនួនដែលរដ្ឋាភិបាលបានចាត់ក្នុងវិស័យនេះ មានជាអាទិ៍ ការអនុម័ត ផែនការសកម្មភាព ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ២០១៧-២០២១ ។ ម្យ៉ាងវិញទៀត និងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលបានបញ្ចូលការពង្រឹងការការពារផ្អែកសង្គមដល់កម្មករនៅក្នុងវិស័យក្រៅផ្លូវការ។ រដ្ឋាភិបាលក៏បានដាក់ចេញនូវគម្រោងទូទាត់ប្រាក់ឈ្នួលជាកញ្ចប់ សម្រាប់កម្មករនិយោជិតស្រ្តីដែលមានផ្ទៃពោះ ហើយបានប្រកាសពីផែនការបង្កើនប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនៅក្នុងវិស័យវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើងមកត្រឹម ១១% នៅឆ្នាំ២០១៨។ រដ្ឋាភិបាល ក៏បានផ្អាកការរៀបចំសេចក្តីព្រាងច្បាប់ដ៏ប្រទាំងប្រទិសមួយស្តីពីការដោះស្រាយវិវាទការងារ។

៣៨. តាមរយៈកម្មវិធីសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ការិយាល័យ OHCHR បានបន្តធ្វើការលើបញ្ហាពាក់ព័ន្ធនឹងសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ និងលើបទដ្ឋានសមរម្យនៃការរស់នៅ ដើម្បីជួយបង្ការការបណ្តេញចេញដោយបង្ខំ និងដើម្បីលើកកម្ពស់ភាពស្ថិតស្ថេរនៃការកាន់កាប់អចលនទ្រព្យ និងការយល់ដឹងកាន់តែប្រសើរឡើងថែមទៀត អំពីតួនាទីរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្សរួមទាំងទាក់ទងនឹងសហគមន៍ជនជាតិដើម។

៣៩. ការិយាល័យ OHCHR បានបន្តជួយដល់បុគ្គលទាំងឡាយដែលជាកម្មវត្ថុនៃការតាំងទីលំនៅថ្មី ដោយសារតែការឈូសឆាយដីសម្រាប់ការសាងសង់សំណង់ថ្មី និងចំការ។ នៅខែតុលា និងខែធ្នូ ការិយាល័យ OHCHR ក្នុងភាពជាដៃគូជាមួយអាជ្ញាធរខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋាន បានរៀបចំសិក្ខាសាលាចំនួនពីរ នៅខេត្តព្រះសីហនុ និងខេត្តកំពត ស្តីពីសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ដោយផ្តោតលើការបណ្តេញចេញ និងនីតិវិធីតាំងទីលំនៅថ្មី និងការទទួលខុសត្រូវរបស់សហគ្រាសធុរកិច្ចនៅក្នុងបរិបទនេះ។

៤០. ជាផ្នែកមួយនៃដំណើរការតាំងទីលំនៅថ្មី ឬដើម្បីផ្តល់ដីធ្លីដល់ប្រជាជនក្រីក្រ និងអតីតយុទ្ធជនគ្មានដីធ្លី រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានសង្គមកិច្ចដល់បុគ្គលនិងគ្រួសារដែលជាកម្មវត្ថុនៃការតាំងលំនៅថ្មី។ ក្នុងខែធ្នូ ការិយាល័យ OHCHR បានបញ្ចប់ការសិក្សាវាយតំលៃអំពីផលប៉ះពាល់នៃសម្បទានបែបនេះទៅលើការចិញ្ចឹមជីវិតរបស់ប្រជាជននៅតាមតំបន់ជនបទ សម្រាប់ការ

[4] ក្រុមធនាគារពិភពលោក *កម្ពុជាកំពុងឡើងខ្សែសង្វាក់តម្លៃផលិតកម្ម បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា* ខែតុលា ឆ្នាំ២០១៧ ទំព័រ ៧។

បោះពុម្ពផ្សាយនៅឆ្នាំ២០១៨។ ការសិក្សានេះ អាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការតស៊ូមតិជាមួយអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ សម្រាប់ភាពល្អប្រសើរនៃសម្បទានដីសង្គមកិច្ចដែលមានស្រាប់ និងមុនពេលបង្កើតសម្បទានថ្មី។

៤១. ការិយាល័យ OHCHR បានបន្តធ្វើការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ អាជ្ញាធរមូលដ្ឋាននិងអង្គការសង្គមស៊ីវិលនានា ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ជនជាតិដើមភាគតិច ក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព និងដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់សហគមន៍ទាំងឡាយ ដែលគេអះអាងថាបានរំលោភសិទ្ធិដីធ្លី។

៤២. ក្នុងខែសីហា ការិយាល័យ OHCHR បានគាំទ្រសហគមន៍ជនជាតិដើមក្នុងខេត្តមណ្ឌលគិរី ក្នុងការអនុម័តលក្ខន្តិកៈសហគមន៍របស់ខ្លួន ជាជំហានដ៏សំខាន់មួយក្នុងដំណើរការឈានទៅទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ព្រឹត្តិការណ៍មួយបានធ្វើឡើងដើម្បីកត់សម្គាល់ជាផ្លូវការនូវការអនុម័តលក្ខន្តិកៈសហគមន៍ មានអ្នកចូលរួមជាង ១០០ នាក់ ក្រោមអធិបតីភាពរបស់អភិបាលខេត្ត។ ការិយាល័យ OHCHR បានសហការប្រកបដោយផ្លែផ្កាជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងអាជ្ញាធរខេត្តកោះកុង សម្រាប់ការចេញ (ក្នុងខែតុលា) នៃការចុះបញ្ជីអត្តសញ្ញាណជនជាតិដើមភាគតិចនៃសហគមន៍ចំនួន ៤ នៅជ្រលងអារ៉ែង ជាទីតាំងបានកើតមានទំនាស់ដីធ្លីច្រើនជាងគេនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ បទពិសោធន៍នេះ ត្រូវបានថាថតវីដេអូ ដើម្បីផលិតជាខ្សែវីដេអូ សម្រាប់ជួយផ្សព្វផ្សាយដល់សហគមន៍ផ្សេងៗអំពីដំណើរការឈានទៅទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពអំពីរបៀបដែលពួកគេអាចប្រើប្រាស់ និងអាចទទួលបានប្រយោជន៍ពីបទពិសោធន៍នេះ។ ខ្សែវីដេអូនេះ ត្រូវបានប្រកាសបើកឲ្យប្រើប្រាស់ជាផ្លូវការក្នុងខែធ្នូ។

៤៣. លើសពីនេះទៀត នៅក្នុងខែតុលា និងខែវិច្ឆិកា ការិយាល័យ OHCHR បានរៀបចំសិក្ខាសាលាថ្នាក់តំបន់ចំនួនពីរ ស្តីពីដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធដីសមូហភាព សម្រាប់អាជ្ញាធរមូលដ្ឋានចំនួន១៤០ នាក់ និងតំណាងជនជាតិដើមចំនួន ២០ នាក់។ ក្នុងខែសីហា ការិយាល័យ OHCHR បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីបទដ្ឋានជាតិ និងបទដ្ឋានអន្តរជាតិទាក់ទងនឹងសិទ្ធិជនជាតិដើមភាគតិច សម្រាប់តំណាងជនជាតិដើមភាគតិចជង ប្រមាណជា ៣៥ នាក់ មកពីខេត្តពោធិសាត់។

៤៤. ការិយាល័យ OHCHR បាននិងកំពុងធ្វើការ ដើម្បីជួយដល់រដ្ឋាភិបាល និងសហគ្រាសធុរកិច្ច ដើម្បីផ្តល់នូវដំណោះស្រាយសមស្របសម្រាប់ករណីរំលោភសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន។ ក្នុងខែសីហា ការិយាល័យ OHCHR បានធ្វើជាដៃគូជាមួយក្រុមសម្រុះសម្រួលឯករាជ្យនៃអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សហគមន៍ជនជាតិដើមភាគតិចព្នង (ប៊ូនង) មកពីភូមិប៊ូស្រា ខេត្តមណ្ឌលគិរី ដែលរងផលប៉ះពាល់ដោយសម្បទានដីសេដ្ឋកិច្ច នៅក្នុងអំឡុងពេលមុនរយៈសម្រុះសម្រួលនៃដំណោះស្រាយទំនាស់ ដែលក្រុមហ៊ុនទទួលយក។ ការជួយឧបត្ថម្ភគាំទ្រនេះ រួមមានការផ្តល់ការបណ្តុះបណ្តាលស្តីពីសិទ្ធិស្របច្បាប់លើដីធ្លី វិធានការសម្រុះសម្រួល ជំនាញធ្វើបទបង្ហាញ ជំនាញចរចារ និងការថ្លឹងថ្លែងអំពីជម្រើសផ្សេងៗ។

៤៥. ក្នុងខែវិច្ឆិកា ការិយាល័យ OHCHR និងមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ បានបើកដំណើរការកម្មវិធី "តុសន្តិភាព" សម្រាប់សហគមន៍រុនតាឯក នៅក្នុងខេត្តសៀមរាបដែលមានទំនាស់ជាមួយអាជ្ញាធរអប្សរាដែលទទួលខុសត្រូវក្នុងការការពារ និងគ្រប់គ្រងតំបន់អង្គរ ទាក់ទងនឹងបញ្ហាដីធ្លី។

៤៦. ការិយាល័យ OHCHR បានបន្តលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានសាធារណៈស្តីពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃផ្សេងទៀត តាមរយៈការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុដល់គេហទំព័រឈ្មោះ Open Development Cambodia។ ការគាំទ្រនេះ បានជួយពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពទិន្នន័យទម្រង់និងផែនទីសម្បទានដីសេដ្ឋកិច្ចនៅលើគេហទំព័រប្រភពបើកចំហ រួមទាំងព័ត៌មានស្តីពីសម្បទានដែលត្រូវបានដកហូត និងកាត់បន្ថយ។ ឧបករណ៍នេះ នឹងត្រូវប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ការតស៊ូមតិ ដោយអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ដែលរងផលប៉ះពាល់ ដើម្បីទាមទារដីធ្លីរបស់ពួកគេមកវិញ។ ការិយាល័យ OHCHR បានគាំទ្រផងដែរដល់ Open Development Cambodia ក្នុងការរៀបចំតាក់តែង និងបើកឲ្យប្រើប្រាស់ជាផ្លូវការនូវផែនទីទាក់ទងអន្តរកម្មនៃសម្បទានដីសង្គមកិច្ចដែលមានស្រាប់។

៤៧. ការិយាល័យ OHCHR បានបន្តពង្រីកការយកចិត្តទុកដាក់របស់ខ្លួនលើវិស័យធុរកិច្ច និងសិទ្ធិមនុស្ស ដោយធ្វើការដោយផ្ទាល់ជាមួយអាជ្ញាធរជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល តំណាងសហគមន៍ និងតួអង្គធុរកិច្ច ដើម្បីបង្កើនការយល់ដឹងរបស់ពួកគេ អំពីគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងការអនុវត្តគោលការណ៍ណែនាំនេះនៅកម្ពុជា។ ក្នុងភាពជាដៃគូជាមួយវេទិកាកម្ពុជាស្តីពីការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) ការិយាល័យ OHCHR បានរៀបចំ និងផ្តល់ការបណ្តុះបណ្តាលចំនួនប្រាំវគ្គ និងការពិភាក្សាមិត្តជួយមិត្តក្នុងចំណោមក្រុមហ៊ុនឯកជនលើការអនុម័ត និងការអនុវត្តគោលនយោបាយស្តីពីការយកចិត្តទុកដាក់ត្រឹមត្រូវនៅកម្ពុជា ដែលមានសិក្ខាកាមចូលរួមជាង១២០ នាក់ ដែលជាតំណាងក្រុមហ៊ុនធុរកិច្ចឯកជន អាជ្ញាធរមូលដ្ឋាន អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនសហគមន៍។ លើសពីនេះទៅទៀត ការិយាល័យ OHCHR បានចាក់ផ្សាយកម្មវិធីពិភាក្សាអន្តរកម្មតាមវិទ្យុ អំពីប្រធានបទពាក់ព័ន្ធចំនួនប្រាំមួយ ដែលមានវាគ្មិនជាភ្ញៀវកិត្តិយសមួយចំនួនមកសមាគមមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ រដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងក្រុមហ៊ុនធុរកិច្ច និងអ្នកជំនាញជាបុគ្គលផ្សេង។ ទោះជាយ៉ាងណាក៏ដោយ ការចាក់ផ្សាយតាមវិទ្យុអំពីកម្មវិធី ពិភាក្សាត្រូវបានរារាំង ដោយហេតុថាអាជ្ញាប័ណ្ណស្ថានីយវិទ្យុផ្សាយរបស់ដៃគូ បានត្រូវដកហូតវិញ។ រហូតដល់រកបានស្ថានីយវិទ្យុផ្សាយបន្ត កម្មវិធីវិទ្យុអាចបន្តបានតែនៅតាមអនឡាញដែលទស្សនិកជនមានកំណត់ សម្រាប់អ្នកដែលប្រើប្រាស់អ៊ីនធឺណិត។

៤៨. ការិយាល័យ OHCHR បានចុះបញ្ជីផលប៉ះពាល់អវិជ្ជមាននៃដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ដទៃទៀត ដែលអះអាងថាបានបាត់បង់ដីធ្លីដោយសារតែជម្លោះដីធ្លី ឬការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាលដែលមិនមានលក្ខណៈស៊ីសង្វាក់គ្នា។ ការិយាល័យ OHCHR បានទទួលញត្តិជាលក្ខណៈបុគ្គល និងជាក្រុម ដែលបានស្នើសុំអន្តរាគមន៍ និងការផ្តល់យោបល់ផ្នែកច្បាប់ លើជម្លោះ និងកង្វល់របស់ពួក

គេ។ ការិយាល័យនេះបានធ្វើដំណើរទស្សនកិច្ចនៅតាមមូលដ្ឋានដើម្បីបញ្ជាក់ការពិត ធ្វើការជាមួយអាជ្ញាធរពាក់ព័ន្ធ សម្របសម្រួលកិច្ចពិភាក្សាក្នុងចំណោមភាគីនានា បានឃ្លាំមើលការងារយន្តការដោះស្រាយវិវាទនិងផ្តល់យោបល់អំពីច្បាប់ និងនីតិវិធី ដល់សហគមន៍ និងអង្គការសង្គមស៊ីវិលដែលគាំទ្រដល់សហគមន៍ទាំងនោះ។

## VI. គាំទ្រការចូលរួមជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិ

៤៩. ការិយាល័យ OHCHR បានជួយរៀបចំដំណើរទស្សនកិច្ចមួយដល់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដែលដំណើរទស្សនកិច្ចនេះ អ្នករាយកាណ៍ពិសេសបានស្នើសុំតាំងពីខែធ្នូមកម្លេះ។ ដោយពុំមានការឆ្លើយតបពីរាជរដ្ឋាភិបាល អ្នករាយការណ៍ពិសេស ក្រោយមកក៏បានស្នើសុំធ្វើដំណើរទស្សនកិច្ចនៅខែមីនាឆ្នាំ២០១៨នេះ។

៥០. រដ្ឋាភិបាលមិនទាន់បានដាក់របាយការណ៍ហួសកាលកំណត់ទៅគណៈកម្មាធិការ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ គណៈកម្មាធិការសិទ្ធិជនពិការ និងគណៈកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ ព្រមទាំងការឆ្លើយតបទៅបញ្ជីនៃបញ្ហារបស់គណៈកម្មាធិការប្រឆាំងទារុណកម្ម។ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានបន្តគាំទ្រផ្នែកបច្ចេកទេសរបស់ខ្លួនដល់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងមហាផ្ទៃនិងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដើម្បីតាមដានវឌ្ឍនភាពក្រោមអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។ ការិយាល័យ OHCHR ក៏បានផ្តល់ជំនួយដល់អង្គការសង្គមស៊ីវិលលើការចូលរួមជាមួយយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។

៥១. ចំពោះករណីនេះ ដោយមានការគាំទ្រពីកម្មវិធីកសាងសមត្ថភាពស្ថាប័នសន្ធិសញ្ញារបស់ការិយាល័យ OHCHR ការិយាល័យបានរៀបចំវគ្គបណ្តុះបណ្តាលពីរជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដោយមានការចូលរួមពីតំណាងក្រសួង និងស្ថាប័នដទៃទៀត ដែលទទួលខុសត្រូវអនុវត្តអនុសាសន៍របស់ស្ថាប័នសន្ធិសញ្ញា ដើម្បីបង្កើនសមត្ថភាពមន្ត្រីធ្វើការងារពាក់ព័ន្ធនឹងការធ្វើសេចក្តីព្រាងរបាយការណ៍ទៅស្ថាប័នសន្ធិសញ្ញា។ ដើម្បីបន្តពង្រឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅថ្នាក់មូលដ្ឋាន ការិយាល័យOHCHR បានគាំទ្រវគ្គបណ្តុះបណ្តាលដោយក្រុមប្រឹក្សាសកម្មភាពជនពិការរបស់មន្ត្រីមូលដ្ឋានរបស់ខ្លួននៅខេត្តកោះកុងក្នុងខែវិច្ឆិកា។

៥២. នៅចុងខែមិថុនា ការិយាល័យ OHCHR បានសហការរៀបចំសិក្ខាសាលាមួយជាមួយអង្គការសង្គមស៊ីវិលផ្សេងៗ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីតាមដានអនុសាសន៍ដែលទទួលបានពីការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់[5]។ សិក្ខាកាមបានវាយតម្លៃពីវិសាលភាពនៃការអនុវត្តអនុសាសន៍ទាំងអស់ ដែលបង្ហាញអំពីវឌ្ឍនភាពដែលសម្រេចបាន ហើយបានកំណត់នូវអនុសាសន៍ផ្សេងៗដែលតម្រូវឲ្យមានសកម្មភាព ឬវិធានការបន្ថែម។ សិក្ខាសាលានេះបានជួយអង្គការសង្គមស៊ីវិលកំណត់ និងផ្តល់អាទិភាពលើវិស័យ ឬអនុសាសន៍មួយ

---

5 សកម្មភាពនេះ បើទោះជាស្ថិតនៅក្រៅរយៈពេលធ្វើរបាយការណ៍នេះក្តី មិនត្រូវបានគេរាយការណ៍នៅក្នុងរបាយការណ៍លើកមុនរបស់អគ្គលេខាធិការ (A/HRC/36/32) ដោយសារតែសកម្មភាពនេះបានកើតឡើងបន្ទាប់ពីការសរសេរបញ្ចប់របាយការណ៍នោះ។

ចំនួន ដែលជាមូលដ្ឋានសម្រាប់ការដាក់បញ្ជូនរបាយការណ៍របស់ខ្លួនមុនពេលពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់របស់ប្រទេសកម្ពុជាដែលនឹងត្រូវធ្វើនៅឆ្នាំ ២០១៩។

## VII. បញ្ជ្រាបសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ

៥៣. ការសម្របសម្រួលសកម្មភាពក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្សក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ គឺជាទំនួលខុសត្រូវចំបងរបស់ ការិយាល័យ OHCHR ។ ការិយាល័យនេះបានបន្តធ្វើជាប្រធានក្រុមវិស័យសិទ្ធិមនុស្ស ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៤ ហើយមានសមាជិក ១៤ រូប មកពីក្រុមប្រចាំប្រទេសកម្ពុជារបស់អង្គការសហប្រជាជាតិ ដែលកោះប្រជុំប្រចាំខែដើម្បីពិនិត្យមើលឡើងវិញនូវកង្វល់សិទ្ធិមនុស្សដែលកំពុងលេចឡើង សម្របសម្រួលគំនិតផ្តួចផ្តើមរបស់អន្តរទីភ្នាក់ងារ ដើម្បីដោះស្រាយបញ្ហាទាំងនោះ ផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធដល់យន្តការសិទ្ធិមនុស្សអន្តរជាតិ និងឆ្លើយតបទៅនឹងសំណើសុំនូវលទ្ធផលពីគំនិតផ្តួចផ្តើមសិទ្ធិមនុស្សនៅក្នុងតំបន់ និងបានមកពីទូទាំងពិភពលោក។

៥៤. បន្ទាប់ពីសន្និសីទថ្នាក់ជាតិ ឆ្នាំ២០១៥ ស្តីពីស្ថានភាពជនរស់នៅតាមចិញ្ចើមផ្លូវ ក្រុមការងារសិទ្ធិមនុស្សបានបន្តសម្របសម្រួលទស្សនកិច្ចអន្តរទីភ្នាក់ងារទៅកាន់មជ្ឈមណ្ឌលសង្គមកិច្ចដ៏ធំមួយនៅរាជធានីភ្នំពេញ ដែលគេស្គាល់ថាជាមណ្ឌលសំចត។ ការដាក់មនុស្សច្រើនលើសចំណុះនៅក្នុងមណ្ឌលនោះនៅតែជាបញ្ហាធ្ងន់ធ្ងរខណៈដែលយុទ្ធនាការប្រឆាំងគ្រឿងញៀននៅតែបន្តធ្វើ។ ក្រុមការងារសិទ្ធិមនុស្ស បានកោះប្រជុំជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីលើកទឹកចិត្តឲ្យបន្តការងារជាថ្មីរបស់ក្រុមការងារបច្ចេកទេស ក្នុងការអនុវត្តអនុសាសន៍ដែលបានអនុម័ត នាសន្និសីទ ឆ្នាំ២០១៥។[6] ដោយមានផែនការបើកមជ្ឈមណ្ឌលស្តារនីតិសម្បទាចិត្តសង្គមថ្មីមួយ សម្រាប់ជនដែលមានពិការភាពផ្លូវចិត្តនៅឆ្នាំ២០១៨ នៅខេត្តកណ្តាល ប្រធានក្រុមការងារសិទ្ធិមនុស្ស បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការដាក់មជ្ឈមណ្ឌលនេះឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាក់ព័ន្ធ គឺក្រសួងសុខាភិបាល និងធានាថាមជ្ឈមណ្ឌលនេះនឹងមិនក្លាយជាកន្លែងឃុំឃាំងតាមព្រឹត្តន័យឡើយ។

៥៥. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានរួមចំណែកក្នុងការរៀបចំតាក់តែងសេចក្តីព្រាងស្តីពីការពិនិត្យវាយតម្លៃជាទូទៅនៃប្រទេស និងការសិក្សារបស់ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសក្នុងខែតុលា ដើម្បីប្រមើលមើលអំពីស្ថានភាពនៃការអភិវឌ្ឍន៍របស់ប្រទេសក្នុងឆ្នាំ២០៣០ និងពិនិត្យមើលតួនាទីរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ទាក់ទងទៅនឹងទស្សនៈវិស័យនោះ។ ការិយាល័យ OHCHR បានលើកទឹកចិត្តឲ្យការដាក់បញ្ចូលសិទ្ធិមនុស្ស និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សនៅក្នុងការវាយតម្លៃទូទៅរបស់ប្រទេស។

---

[6] ក្រុមការងារបច្ចេកទេសទទួលបន្ទុកបុគ្គលស្ថិតនៅតាមចិញ្ចើមផ្លូវ ត្រូវបានបង្កើតឡើង បន្ទាប់សន្និសីទឆ្នាំ២០១៥ ដែលដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងគោលបំណងកៀរគរអាជ្ញាធររដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ឱ្យចូលរួមក្នុងការងារសង្គម។

# ឧបសម្ព័ន្ធទី៨ ៖

# របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០១៩

# នៃស្ថានទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា

# របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០១៩

## សេចក្តីសង្ខេបរួម

ប្រទេសកម្ពុជាជាប្រទេសប្រកាន់របបរាជានិយមអាស្រ័យធម្មនុញ្ញដែលមានរដ្ឋាភិបាលមួយកើតចេញតាមរយៈការបោះឆ្នោតសភា។គណបក្សប្រជាជនកម្ពុជា(CPP) បានទទួលបានអាសនៈសភាទាំងអស់នៅក្នុងការបោះឆ្នោតជាតិ កាលពីខែកក្កដា ដោយបានហាមប្រាមគណបក្សប្រឆាំងធំជាងគេ កាលពីឆ្នាំ ២០១៧។ នៅមុនពេលទួលជ័យជំនះនេះ លោកនាយករដ្ឋមន្រ្តី ហ៊ុន សែនបានកាន់តំណែងនេះអស់រយៈពេល ៣៣ ឆ្នាំមកហើយ។ អ្នកសង្កេតការណ៍អន្តរជាតិ ដោយរួមទាំងរដ្ឋាភិបាលបរទេស និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងជាតិ បានរិះគន់ការបោះឆ្នោតនេះ ថាគ្មានភាពសេរី និងយុត្តិធម៌ ហើយមិនតំណាងអោយឆន្ទៈរបស់ប្រជាជនកម្ពុជាទេ។

នគរបាលជាតិកម្ពុជារក្សាសន្តិសុខផ្ទៃក្នុង។ កងយោធពលខេមរភូមិន្ទទទួលខុសត្រូវលើសន្តិសុខខាងក្រៅ ហើយក៏មានការទទួលខុសត្រូវផ្នែកសន្តិសុខផ្ទៃក្នុងខ្លះដែរ។ នគរបាលជាតិស្ថិតនៅក្រោមក្រសួងមហាផ្ទៃ ចំណែកកងយោធពលខេមរភូមិន្ទស្ថិតនៅក្រោមក្រសួងការពារជាតិ។ អាជ្ញាធរស៊ីវិលគ្រប់គ្រងលើកងកម្លាំងសន្តិសុខ ដែលជាញឹកញាប់ គំរាមប្រើកម្លាំងប្រឆាំងនឹងអ្នកដែលប្រឆាំងនឹងនាយករដ្ឋមន្រ្តី ហ៊ុន សែន ហើយជាទូទៅ ត្រូវបានគេមើលឃើញថា ជាសាខាប្រដាប់អាវុធរបស់គណបក្សគ្រប់គ្រងប្រទេស CPP ។

បញ្ហាផ្នែកសិទ្ធិមនុស្សសំខាន់ៗរួមមានការធ្វើទារុណកម្មដោយរដ្ឋាភិបាល ការឃុំខ្លួនតាមអំពើចិត្តដោយរដ្ឋាភិបាល ការជ្រៀតជ្រែកតាមអំពើចិត្តនៅក្នុងជីវិតឯកជនរបស់ពលរដ្ឋ រួមទាំងការលួចស្តាប់តាមប្រព័ន្ធអេឡិចត្រូនិចជាទូទៅ អ្នកទោសនយោបាយ តុលាការគ្មានឯករាជ្យ ការចាប់ពិរុទ្ធ និងការអនុវត្តច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងការបរិហារកេរ្តិ៍ដោយរើសមុខ ការជ្រៀតជ្រែកនៅក្នុងសិទ្ធិធ្វើការប្រមូលផ្តុំដោយសន្តិភាព និងសេរីភាពក្នុងការចងក្រងគ្នាជាក្រុម សមាគម ការរឹតត្បិតក្នុងការចូលរួមទាក់ទងនឹងនយោបាយ អំពើពុករលួយជាទូទៅ ដោយរួមទាំងនៅក្នុងប្រព័ន្ធតុលាការ និងការប្រើកម្លាំងពលកម្មកុមារទាំងបង្ខំ។

វប្បធម៌និទណ្ឌភាពជាទូទៅនៅតែមាន។ មានសេចក្តីរាយការណ៍ដែលគួរឲ្យទុកចិត្តមកថា មន្ត្រីរដ្ឋាភិបាល រួមទាំងនគរបាsលផង បានប្រព្រឹត្តបទរំលោភដោយមាននិទណ្ឌភាព ហើយក្នុងករណីភាគច្រើន រដ្ឋាភិបាលអន្តរាគមន៍តិចតួច ឬមិនធ្វើអន្តរាគមន៍សោះ។ មន្ត្រីរដ្ឋាភិបាល និងសមាជិកគ្រួសាររបស់គេ ជាទូទៅ គេចផុតពីការកាត់ទោស។

ផ្នែកទី១៖ការគោរពភាពថ្លៃថ្នូររបស់មនុស្សរួមទាំងសេរីភាពរួចផុតពី៖

គេនៅក្នុងតម្លៃក្រោមទីផ្សារ។ ដោយគិតមកត្រឹមខែមិថុនាអង្គការNGO ក្នុងស្រុកមួយបាននិយាយថាគេបានឮករណីថ្មីចំនួន ៣៥ ទាក់ទងនឹងការចាប់យកដី និងការបណ្តេញចេញ ដែលមានទៅលើគ្រួសារចំនួន ២៥១៦។

ច. ការជ្រៀតជ្រែកតាមអំពើចិត្តក្នុងភាពឯកជនគ្រួសារ គេហដ្ឋានឬក្នុងការឆ្លើយឆ្លងគ្នា

ថ្វីបើច្បាប់មានចែងអំពីភាពឯកជននៃលំនៅដ្ឋាន និងការឆ្លើយឆ្លងគ្នា ហើយហាមឃាត់ការឆែកឆេរខុសច្បាប់ក្តី តែអង្គការមិនមែនរដ្ឋាភិបាល បានរាយការណ៍ថា ជាទម្លាប់ នគរបាលធ្វើការឆែកឆេរ និងរឹបអូសដោយគ្មានដីកាពីតុលា។ ជាធម្មតា រដ្ឋាភិបាលបញ្ចេញសារឆ្លើយឆ្លងផ្ទាល់ខ្លួន ហើយថតការនិយាយឆ្លើយឆ្លងតាមទូរស័ព្ទរបស់មេដឹកនាំបក្សប្រឆាំង និងមេដឹកនាំសង្គមស៊ីវិល ហើយបញ្ចេញទៅដល់ប្រព័ន្ធផ្សព្វផ្សាយដែលត្រូវគ្នាជាមួយរដ្ឋាភិបាល។  កាលពីខែកញ្ញា សមាជិក ២ នាក់នៃគណបក្សសង្គ្រោះជាតិត្រូវបានចាប់ខ្លួនហើយចោទពីបទញុះញង់ និងបរិហារកេរ្តិ៍ បន្ទាប់ពីបង្ហោះសារតាមហ្វេសប៊ុករិះគន់រដ្ឋាភិបាល។ ក្រោយមក នគរបាលបានអានខ្លាំងៗក្នុងតុលាការ នូវកិច្ចសន្ទនាសម្ងាត់របស់ពួកគេ។ តាមសេចក្តីរាយការណ៍មកថា អាជ្ញាធរមូលដ្ឋានបានចូលនិងឆែកឆេរអង្គការសហគមន៍ និងការិយាល័យសហជីព។

## ផ្នែកទី២៖ការគោរពសេរីភាពពលរដ្ឋដែលរួមមាន

ក. សេរីភាពបញ្ចេញមតិនិងសេរីភាពសារព័ត៌មាន

រដ្ឋធម្មនុញ្ញមានចែងពីសេរីភាពបញ្ចេញមតិ រួមទាំងសេរីភាពផ្នែកសារព័ត៌មាន។ តែតាំងពីឆ្នាំ ២០១៧ មក រដ្ឋាភិបាលបានធ្វើយុទ្ធនាការជាបន្តបន្ទាប់ ដើម្បីលុបបំបាត់សារព័ត៌មានឯករាជ្យ និងសម្លេងប្រឆាំងនៅក្នុងប្រទេស ហើយធ្វើការរឹតត្បិតច្រើនជាងមុន ទៅលើសេរីភាពក្នុងការបញ្ចេញមតិ។ មនុស្សជាច្រើន និងស្ថាប័ននានា បាននិយាយពីការត្រូវធ្វើការពិនិត្យចាប់ពិរុទ្ធខ្លួនឯង។

<u>សេរីភាពក្នុងការបញ្ចេញមតិ៖</u> រដ្ឋធម្មនុញ្ញ អនុញ្ញាតមានការបញ្ចេញមតិដោយសេរី លើកលែងតែក្នុងករណីដែលប៉ះពាល់ដល់សន្តិសុខសាធារណៈ។ រដ្ឋធម្មនុញ្ញក៏ប្រកាសផងដែរថាព្រះមហាក្សត្រ “មិនអាចត្រូវគេរំលោភបាន” ហើយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ដែលអនុលោមតាមច្បាប់បរិហាកេរ្តិ៍ បញ្ជាក់ជាថ្មីនូវដែនកំណត់ទាំងនេះ ហើយហាមប្រាមមិនឲ្យអ្នកបោះពុម្ព និងនិពន្ធនាយកផ្សព្វផ្សាយរឿងណា ដែលប្រមាថនិងបរិហាកេរ្តិ៍ព្រះមហាក្សត្រ ថ្នាក់ដឹកនាំរដ្ឋាភិបាល និងស្ថាប័នសាធារណៈ ។

ច្បាប់បោះឆ្នោតមានចំណុចតម្រូវឱ្យអង្គការសង្គមស៊ីវិលមានភាព "អព្យាក្រឹត" នៅក្នុងអំឡុងពេលនៃយុទ្ធនាការនយោបាយហើយហាមពួកគេមិនឱ្យ "ប្រមាថ" គណបក្សនយោបាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ ថ្វីបើច្បាប់ទាក់ទងនឹងយុទ្ធនាការ តម្រូវអង្គភាពសារព័ត៌មានធ្វើការផ្សាយឱ្យបានស្មើភាព សម្រាប់គណបក្សនិមួយៗដែលចូលរួមក្នុងការបោះឆ្នោតក្តី តែគេគ្មានឃើញមានភស្តុតាងបង្ហាញពីការអនុវត្តច្បាប់នេះឡើយ ហើយអង្គភាពសារព័ត៌មានផ្សាយឱ្យគណបក្សប្រជាជនកម្ពុជា ច្រើនជាងគណបក្សដទៃទាំងអស់។

រដ្ឋាភិបាល បានប្រើក្រមព្រហ្មទណ្ឌ ដើម្បីកាត់ទោសពលរដ្ឋ ពីបទបទបរិហារកេរ្តិ៍ ផ្សាយព័ត៌មានមិនពិត និងញុះញង់ ដែលអាចនាំដល់ការដាក់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ។ ថៅក្រមក៏អាចបញ្ជាឱ្យបង់ការផាកពិន័យផងដែរ ដែលអាចនាំឱ្យមានការចាប់ដាក់ពន្ធនាគារ បើមិនបង់ទេ។ នគរបាល និងតុលាការបានបកស្រាយក្នុងលក្ខណៈទូលំទូលាយពាក្យថា "ញុះញង់" ហើយដែលនាំឱ្យមានការចាប់ខ្លួនចំនួន ៤០ ករណី ទាក់ទងនឹងការបង្ហោះសារតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ។

នៅខែកុម្ភៈ ឆ្នាំ ២០១៨ រដ្ឋាភិបាលបានចេញច្បាប់ ដោយដាក់ទោសព្រហ្មទណ្ឌចំពោះការប្រមាថព្រះមហាក្សត្រ ហើយពលរដ្ឋចំនួនយ៉ាងតិច ៣ នាក់ត្រូវបានចាប់ខ្លួន។ នៅថ្ងៃទី ៩ ខែមករាឈ្មោះ អេង ជលសា បានជាប់ទោសពន្ធនាគារចំនួន ៣ ឆ្នាំដោយសារការបង្ហោះក្នុងហ្វេសប៊ុក ដែលគេគិតថា ប្រមាថព្រះមហាក្សត្រ។ រដ្ឋាភិបាលបានប្រើច្បាប់បរិហារកេរ្តិ៍ព្រហ្មទណ្ឌ ទៅលើមនុស្សដែលគេគិតថា ជាអ្នកប្រឆាំង។ នៅខែកញ្ញា លោក សម រង្ស៊ី បានជាប់ចោទពីបទធ្វើការបរិហារកេរ្តិ៍ជាសាធារណៈ ហើយញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ នៅពេលលោកចោទប្រកាន់លោក ហ៊ុន សែន ថាបានប្រើស្តេច ធ្វើជាចំណាប់ខ្មាំង និងជាអាយ៉ង។

<u>សារព័ត៌មានរួមទាំងសារព័ត៌មានតាមអ៊ិនធ័រណែត៖</u> រដ្ឋាភិបាលកងកម្លាំងយោធា និងគណបក្សនយោបាយកាន់អំណាចបានបន្តមានឥទ្ធិពលលើប្រព័ន្ធផ្សព្វផ្សាយ មានប្រភពព័ត៌មានតិចតួច។ កាសែតចំនួន៣ដែលបោះពុម្ពច្រើនជាងគេ ហើយគាំទ្រគណបក្សប្រជាជន មិនដែលរិះគន់រដ្ឋាភិបាលពីបញ្ហាសិទ្ធិមនុស្ស ឬបញ្ហាដែលមានលក្ខណៈនយោបាយទេ។

នៅឆ្នាំ ២០១៧ រដ្ឋាភិបាលបានបិទវិទ្យុ FM ចំនួន ៣២ នៅតាមខេត្តចំនួន ២០ ដែលជាការប៉ះពាល់ដល់ស្ថានីយដែលផ្សាយបន្តនូវព័ត៌មានឯករាជ្យ ពីវិទ្យុអាស៊ីសេរី វិទ្យុវ៉ីអូអេ និងវិទ្យុសម្លេងប្រជាធិបតេយ្យ។

កាលពីខែឧសភា ឆ្នាំ ២០១៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) បានចេញក្រមប្រតិបត្តិមួយសម្រាប់ការបោះឆ្នោតខែកញ្ញា ឆ្នាំ ២០១៨ ដោយប្រាប់អ្នកសារព័ត៌មានថា ពួកគេនឹងប្រឈមការដាក់ពិន័យចំនួនរហូតដល់ ៣០ លានរៀល (៧ ៥០០ ដុល្លា) បើសិនជាគេសម្ភាសន៍អ្នកបោះឆ្នោត នៅជិតស្ថានីយ៍បោះឆ្នោត ឬបើគេ

បោះពុម្ពផ្សាយព័ត៌មាន ដែលអាចប៉ះពាល់ដល់ស្ថិរភាពនយោបាយ ឬបណ្តាលឲ្យសាធារណជនបាត់បង់ទំនុកចិត្តលើការបោះឆ្នោត។

<u>អំពើហិង្សានិងការយាយី៖</u> ហិង្សានិងការគំរាមកំហែងលើអ្នកសារព័ត៌មាន នៅមានច្រើននៅឡើយ។ នៅថ្ងៃទី ៣០ ខែមករា ស៊ីម ឈីវឈាន ដែលជាអ្នកយកព័ត៌មានឲ្យសមាគមសារព័ត៌មានកម្ពុជាដើម្បីសេរីភាព ត្រូវបានគេវាយសន្លប់ ក្នុងពេលដែលគាត់កំពុងយកព័ត៌មានស្តីពីការនេសាទខុសច្បាប់នៅខេត្តសៀមរាប។ នៅថ្ងៃទី ៤ កុម្ភៈ មនុស្សប្រុសចំនួន ២០ នាក់បានគប់ដុំថ្ម និងវាយឈ្មោះ សន សិទ្ធីស្លាប់។ គិតមកដល់ខែតុលា គេមិនទាន់ដឹងពីមូលហេតុនៃការវាយសម្លាប់នោះទេ តែសិទ្ធី បានធ្វើការឲ្យទូរទស្សន៍តាមអ៊ិនធ័រណែត BTBP អស់រយៈពេល១ ឆ្នាំ ទាក់ទងនឹងបញ្ហាសង្គម។

គិតមកដល់ខែតុលា អតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី ២ នាក់ ដែលត្រូវបានចាប់ខ្លួននៅឆ្នាំ ២០១៧ ពីបទក្បត់ជាតិ (ជាការចោទដែលអ្នកសង្កេតការណ៍បាននិយាយថា មានហេតុផលនយោបាយ) ដែលនៅពេលក្រោយមកអាជ្ញាធរបានបន្ថែមបទចោទចែកចាយរូបអាសអាភាស មិនទាន់មានការបញ្ចប់សវនាការនៅឡើយទេ បន្ទាប់ពីដំណើរការក្តីប៉ុន្មានដងមកហើយ។ នៅថ្ងៃទី ៣ តុលា តុលាការបានបញ្ជូនករណីពួកគេត្រឡប់ទៅឲ្យចៅក្រមស៊ើបអង្កេតវិញដើម្បីប្រមូលភស្តុតាងបន្ថែម។ NGO និងអ្នកសង្កេតការណ៍បាននិយាយថា ករណីប្រឆាំងនឹងពួកគេមានលក្ខណៈនយោបាយ ហើយបានហៅការកាត់ក្តីយូរ និងការដកយកលិខិតឆ្លងដែនថា ជាការគំរាមកំហែងរបស់រដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយ។

<u>ការចាប់ពិរុទ្ធឬការដាក់កំហិតលើសេចក្តីក្នុងអត្ថបទ៖</u> ច្បាប់ហាមការចាប់ពិរុទ្ធមុនបោះពុម្ពផ្សាយ ហើយគ្មានប្រព័ន្ធចាប់ពិរុទ្ធផ្លូវការទេ។ តែរដ្ឋាភិបាលបានប្រើមធ្យោបាយផ្សេងទៀត ដើម្បីធ្វើការចាប់ពិរុទ្ធលើប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាល ឬគណបក្សប្រជាជន។ ប្រព័ន្ធផ្សព្វផ្សាយឯកជនបានសារភាពថា បានធ្វើការចាប់ពិរុទ្ធលើខ្លួនឯងខ្លះ ដោយខ្លាចរដ្ឋាភិបាលធ្វើការសងសឹក។ អ្នកសារព័ត៌មានអះអាងថា ម្ចាស់កាសែតប្រាប់កុំឲ្យគេសរសេរពីរឿង ដែលធ្វើឲ្យរដ្ឋាភិបាលខឹង ហើយបាននិយាយថា ខ្លួនបានធ្វើការពិនិត្យចាប់ពិរុទ្ធលើខ្លួនឯង ដោយសារក្នុងពេលថ្មីៗនេះ មានការចោទប្រកាន់ព្រហ្មទណ្ឌលើអ្នកសារព័ត៌មាន។

<u>ច្បាប់បរិហារកេរ្តិ៍៖</u> រដ្ឋាភិបាលប្រើច្បាប់បរិហារកេរ្តិ៍មួលបង្កាច់ បកអាក្រាតដើម្បីធ្វើការរឹតត្បិតលើការនិយាយគ្នាជាសាធារណៈលើបញ្ហាដែលរដ្ឋាភិបាលគិតថាមានភាពរសើប ឬប្រឆាំងនឹងផលប្រយោជន៍របស់ខ្លួន។នៅខែធ្នូ ឆ្នាំ ២០១៨ លោក សម រង្ស៊ី ត្រូវបានតុលាការដាក់ទោសពីបទបរិហារកេរ្តិ៍ ហើយត្រូវបានបង្គាប់ឲ្យបង់ជំងឺចិត្តចំនួន ១ លានដុល្លា ទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន បន្ទាប់ពីគាត់បានចោទលោកនាយករដ្ឋមន្ត្រីពីបទទទួលសំណូក។ លោក រង្ស៊ី

បានរស់នៅនិរទេសតាំងពីឆ្នាំ ២០១៤ ដោយលោកបានគេចចេញពីប្រទេស ដើម្បីគេចពីការចោទប្រកាន់លើកមុន មកលើរូបលោកពីបទបរិហារកេរ្តិ៍។

<u>សន្តិសុខជាតិ៖</u> រដ្ឋាភិបាល បានបន្តលើកឡើងពីកង្វល់សន្តិសុខជាតិ ធ្វើជាហេតុផលនៃការរឹតត្បិតលើសិទ្ធិ របស់ពលរដ្ឋដែលរិះគន់មន្ត្រី និងនយោបាយរដ្ឋាភិបាល។

សេរីភាពអ៊ីនធឺណែត

មានការនិយាយដ៏គួរឲ្យទុកចិត្តបានថា ស្ថាប័នរដ្ឋធ្វើការតាមដានការឆ្លើយឆ្លងគ្នាតាមអ៊ិនធ័រណែត។ច្បាប់ស្តីពីទូរគមនាគមន៍ត្រូវបានរិះគន់ជាទូទៅ ដោយសកម្មជនសិទ្ធិមនុស្ស និងសកម្មជនសំខាន់ៗក្នុងសង្គមស៊ីវិលថា ផ្តល់ឲ្យរដ្ឋាភិបាលនូវអំណាចទូលំទូលាយក្នុងការលួចស្តាប់ការពិភាក្សាជាសាធារណៈតាមអ៊ិនធ័រណែត ដោយប្រើឧបករណ៍ទាក់ទងគ្នាជាឯកជន។ ច្បាប់នេះផ្តល់ឲ្យរដ្ឋាភិបាល មានអំណាចតាមផ្លូវច្បាប់ ក្នុងការតាមដានគ្រប់ការសន្ទនាតាមទូរស័ព្ទ សារតាមទូរស័ព្ទ អ៊ីម៉េល សកម្មភាពតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងការឆ្លើយឆ្លងរបស់បុគ្គល ដោយគ្មានការយល់ព្រមឬដឹងពីពួកគេ។ មតិសម្តែងដែលត្រូវបានគេគិតថា រំលោភលើន័យសន្តិសុខជាតិដែលកំណត់ដោយរដ្ឋាភិបាល អាចនាំដល់ការចាប់ដាក់ពន្ធនាគារ រហូតដល់ ១៥ឆ្នាំ។

រដ្ឋាភិបាល មានអំណាចបិទទំព័រផ្សព្វផ្សាយសង្គម ឬគេហទំព័រ ដែលផ្សព្វផ្សាយព័ត៌មានដែលបំផ្លាញការការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាតិជាមួយប្រទេសដទៃ សេដ្ឋកិច្ច សណ្តាប់ធ្នាប់សង្គម ការរើសអើង ឬប្រពៃណី ឬវប្បធម៌ជាតិ។ ឧទាហរណ៍ ៣ ថ្ងៃ មុនការបោះឆ្នោតជាតិ ឆ្នាំ ២០១៨ រដ្ឋាភិបាលបានបញ្ជាឲ្យក្រុមហ៊ុនទូរគមនាគមន៍ក្នុងស្រុក បិទគេហទំព័រព័ត៌មានឯករាជ្យមួយចំនួន ដែលរួមមានវិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរ វិទ្យុអាស៊ីសេរីជាភាសាខ្មែរ និងសម្លេងប្រជាធិបតេយ្យ។

“ក្រុមសង្គ្រាមតាមប្រព័ន្ធអ៊ិនធ័រណែត” នៅក្នុងអង្គភាពប្រតិកម្មរហ័សនិង សារព័ត៌មានរបស់ទីស្តីការគណៈរដ្ឋមន្ត្រី មាននាទីតាមដាន និងប្រឆាំងនឹងព័ត៌មាន “មិនត្រឹមត្រូវ” ពីផ្នែកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយសង្គម។ លោកនាយករដ្ឋមន្ត្រីតែងតែគំរាមថា អ្នកជំនាញខាងអ៊ិនធ័រណែតរបស់លោក អាចរកឃើញទូរស័ព្ទរបស់អ្នកដែលបង្ហោះសារបរិហារកេរ្តិ៍តាមហ្វេសបុក តែក្នុងរយៈពេល ៤ នាទី។

សេរីភាពខាងការសិក្សាអប់រំនិងពិធីវប្បធម៌

ជាទូទៅរដ្ឋាភិបាលពុំមានរឹតត្បិតសេរីភាពផ្នែកការសិក្សាអប់រំឬពិធីវប្បធម៌ឡើយ ជាផ្លូវការ ឬជាចំហឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកធ្វើការក្នុងផ្នែកសិក្សាអប់រំ ច្រើនមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងនយោបាយដោយសារខ្លាចប៉ះពាល់អ្នកនយោបាយ។ មានគ្រូជាច្រើនធ្វើការចាប់ពិរុទ្ធលើខ្លួនឯង ឬសម្តែងមតិជាលក្ខណៈមិនបញ្ចេញឈ្មោះ។

ខ. សេរីភាពប្រមូលផ្តុំគ្នានិងសេរីភាពបង្កើតអង្គការ/សមាគម

រដ្ឋាភិបាលធ្វើការរឹតត្បិតលើសេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធី និងការចងក្រងគ្នាជាក្រុម ជាសមាគម។

សេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធី

រដ្ឋធម្មនុញ្ញមានចែងសេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធីប៉ុន្តែពេលខ្លះរដ្ឋាភិបាលមិនបានគោរពសិទ្ធិនេះទេ។

គិតមកត្រឹមខែតុលា មានសមាជិកគណបក្សសង្គ្រោះជាតិចំនួនជាង ១៥០ នាក់ត្រូវបានឃុំខ្លួន ឬត្រូវបានកោះហៅចូលតុលាការ ដើម្បីសាកសួរទាក់ទងនឹងការចូលរួមរបស់គេ នៅក្នុងការជួបជុំក្រៅផ្លូវការ ដើម្បីហូបបាយ។ NGO បាននិយាយថា នៅក្នុងពេលសាកសួរនោះ រដ្ឋាភិបាលបានចោទប្រកាន់មន្ត្រីបក្សប្រឆាំងថា បានរំលោភលើដីការបស់តុលាការកំពូលឆ្នាំ ២០១៧ ដែលបានរំលាយនិងហាមប្រាមគណបក្សសង្គ្រោះជាតិ។

ច្បាប់ស្តីពីអង្គការ សមាគមតម្រូវឲ្យអង្គការ សមាគមទាំងអស់ចុះបញ្ជី ហើយតម្រូវឲ្យមានការប្រាប់ជាមុននូវការតវ៉ា ការដើរក្បួន ឬបាតុកម្ម តែអាជ្ញាធរមិនបានអនុវត្តបានខ្ជាប់ខ្ជួនលើការទាមទារនេះទេ។ ខមួយចែងពីការត្រូវជម្រាបប្រាប់ចំនួន ៥ ថ្ងៃមុនការធ្វើបាតុកម្មដោយសន្តិវិធីភាគច្រើន ចំណែកខមួយទៀតចែងពីការតម្រូវឲ្យជូនដំណឹងចំនួន ១២ ម៉ោងមុនសម្រាប់ការប្រមូលផ្តុំគ្នា ដោយមិនមានការគ្រោងទុកនៅលើទីកន្លែងឯកជន ឬសម្រាប់ការតវ៉ានៅកន្លែងកំណត់ ហើយកម្រិតចំនួនអ្នកចូលរួមត្រឹម ២០០ នាក់។ តាមច្បាប់អាជ្ញាធរខេត្តនិងអាជ្ញាធរក្រុងមានអំណាចសម្រេចចេញការអនុញ្ញាតឲ្យធ្វើបាតុកម្ម។ តាមភាពជាក់ស្តែង ពិសេសនៅភ្នំពេញ មន្ត្រីអាជ្ញាធរថ្នាក់ក្រោមបដិសេធសំណើសុំបើសិនជាថ្នាក់ជាតិ មិនផ្តល់ការអនុញ្ញាតច្បាស់លាស់សម្រាប់ការប្រមូលផ្តុំគ្នានោះទេ។ តាមធម្មតាអាជ្ញាធរគ្រប់លំដាប់ថ្នាក់មិនផ្តល់ការអនុញ្ញាតដល់ក្រុមដែលរិះគន់គណបក្សដឹកនាំប្រទេសទេ។

របាយការណ៍ដែលគួរឲ្យទុកចិត្តបានបានអោយដឹងថារដ្ឋាភិបាលរាំងមិនឲ្យសមាគមឬអង្គការមិនមែនរដ្ឋាភិបាលរៀបចំពិធីជាសាធារណៈទាក់ទងនឹងសិទ្ធិមនុស្សដោយលើកហេតុផលថាក្រុមទាំងនោះមិនបានទទួលការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន តែច្បាប់មិនតម្រូវឲ្យមានការយល់ព្រមជាមុនសម្រាប់ធ្វើពិធីបែបនេះទេ ។ អាជ្ញាធរលើកហេតុផលពីតម្រូវការឲ្យមាន“ស្ថិរភាព” និង “សន្តិសុខសាធារណៈ:” ដែលជាពាក្យមិនមាននិយាយ

នៅក្នុងច្បាប់ ហើយដូច្នេះ ត្រូវបានបកស្រាយតាមចិត្ត សម្រាប់ការមិនផ្តល់ការអនុញ្ញាត។អាជ្ញាធររដ្ឋាភិបាលពេលខ្លះ ថែមទាំងលើកឡើងពីខនៅក្នុងច្បាប់អង្គការ ដើម្បីរារាំងអង្គការ សមាគមមិនឲ្យរៀបចំពិធីជាសាធារណៈ ឬបំបែកការប្រជុំឬការរៀនសូត្រ ដែលគេគិតថា ប្រឆាំងនឹងរដ្ឋាភិបាល។NGO និងសហជីពខ្លះបានត្អូញត្អែរថា នគរបាលតាមដានសកម្មភាពរបស់ពួកគេយ៉ាងយកចិត្តទុកដាក់ ហើយគំរាមអ្នកចូលរួម ដោយបាន
បញ្ជូននគរបាលពាក់ឯកសណ្ឋានឲ្យទៅឈរនៅក្រៅការិយាល័យរបស់ពួកគេ នៅក្នុងពេលគេបើកការប្រជុំ។

ទោះបីជាមានការរឹតត្បិតទាំងនេះក្តី ក៏ផ្នែកសារព័ត៌មានបានរាយការណ៍ពីការតវ៉ាដោយគ្មានការអនុញ្ញាត ជាសាធារណៈជាច្រើន ដែលភាគច្រើនទាក់ទងនឹងដីធ្លី ឬជម្លោះដីធ្លី។ ក្នុងករណីយ៉ាងតិចមួយនគរបាលបានបំបែកហ្វូងអ្នកតវ៉ា ដែលនាំឲ្យអ្នកតវ៉ាម្នាក់របួសធ្ងន់ បន្ទាប់ពីនគរបាលបាញ់។ នៅក្នុងករណីផ្សេងទៀត នគរបាលបានចាប់ខ្លួន និងចោទប្រកាន់បាតុករខ្លះ ពីបទចូលទៅក្នុងដីឯកជន ហើយធ្វើការតវ៉ាដោយគ្មានការអនុញ្ញាតត្រឹមត្រូវ។

បើយោងតាមរបាយការណ៍របស់ NGO មួយ ដោយគិតមកត្រឹមខែមិថុនា មាន ៧១ ករណីនៃការរំលោភលើសេរីភាពនៃការប្រមូលផ្តុំគ្នា។ NGO ផ្នែកសិទ្ធិមនុស្សមួយទៀតបាននិយាយថា មាន៩៩ ករណីនៃរដ្ឋាភិបាល រំលោភលើសេរីភាពនៃការជួបជុំគ្នា នៅក្នុងរយៈពេលពីខែមេសា ឆ្នាំ ២០១៨ ដល់ខែមិនា ឆ្នាំ ២០១៩។

នៅថ្ងៃទី ១០ កក្កដា អាជ្ញាធរបានឃុំខ្លួនមនុស្ស ៧ នាក់ពេលគេគោរពវិញ្ញាណក្ខន្ធលោក កែម ឡី ដែលជាអ្នករិះគន់រដ្ឋាភិបាល នៅខួបលើកទី៣ នៃការបាញ់សម្លាប់លោក។ អាជ្ញាធរមិនអនុញ្ញាតឲ្យ NGO ធ្វើការជួបជុំគ្នានៅក្រៅ ឬដាក់កម្រងផ្កានៅក្រៅហាងសាំងកាល់តិចបូកគោ ជាទីដែលលោកត្រូវបានគេបាញ់សម្លាប់។

## សេរីភាពបង្កើតអង្គការ/សមាគម

រដ្ឋធម្មនុញ្ញ មានចែងអំពីសេរីភាពបង្កើតអង្គការ/សមាគមតែរដ្ឋាភិបាល មិនបានគោរពសិទ្ធិនេះឲ្យបានជាប់លាប់ទេ ពិសេសទាក់ទងនឹងសិទ្ធិរបស់កម្មករ (សូមមើលត្រង់ផ្នែក៧.ក) ។ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលតម្រូវឲ្យគ្រប់អង្គការ សមាគមទាំងអស់មានអព្យាក្រិតភាពផ្នែកនយោបាយ ដែលការនេះមិនត្រឹមតែរឹតត្បិតលើសិទ្ធិក្នុងការចូលរួមតែប៉ុណ្ណោះទេ តែថែមទាំងរឹតត្បិតសិទ្ធិនៃអង្គការទាំងនោះ នៅក្នុងការសម្តែងមតិដោយសេរីទៀតផង។

បញ្ញត្តិដែលចែងមិនច្បាស់នៅក្នុងច្បាប់មួយចំនួនហាមប្រាមសកម្មភាពណាទាំងអស់ដែលអាច “ធ្វើឲ្យខូចដល់សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ” ឬប៉ះពាល់ដល់ “សន្តិសុខជាតិ សាមគ្គីជាតិ ប្រពៃណី និងវប្បធម៌នៃសង្គមជាតិកម្ពុជា”។ អង្គការសង្គមស៊ីវិល បានសម្តែងកង្វល់ចំពោះបទបញ្ញត្តិដែលចែងមិនច្បាស់ ថាបានបង្កើតឲ្យ

មានការប្រឈមខ្លាំងនឹងការរឹតត្បិតតាមចិត្ត លើសិទ្ធិរបស់អង្គការសមាគម។ យោងតាមអ្នករិះគន់ច្បាប់អង្គការ និងច្បាប់សហជីព (មើលផ្នែក៧.ក) ចែងពីដំណើរការចុះបញ្ជីស្មុគស្មាញ និងច្រើនជំហាន ហើយខ្វះការការពារផ្នែករដ្ឋបាលដែលជាការធ្វើឲ្យដំណើរការនៃការចុះបញ្ជីរងលក្ខណៈនយោបាយ។ច្បាប់នេះថែមទាំងកំណត់ឲ្យមានការធ្វើរបាយការណ៍យ៉ាងតឹងតែងស្តីពីថវិកានិងសកម្មភាព រួមទាំងការត្រូវបង្ហាញសំណើសុំថវិកាដែលបានទទួលថវិកា កិច្ចព្រមព្រៀងលើថវិកាជំនួយ កិច្ចព្រមព្រៀងផ្នែកហិរញ្ញវត្ថុគណនេយ្យធនាគាររបស់អង្គការសមាគម។

គណៈកម្មាធិការសហប្រតិបត្តិការសំរាប់កម្ពុជា(CCC) ដែលជារបស់បណ្តុំនៃអង្គការ NGO ក្នុងស្រុក បាននិយាយនៅឆ្នាំ ២០១៨ ថា ជាទូទៅ អង្គការ NGO ខ្វះការណែនាំពីរដ្ឋាភិបាល ស្តីពីការគោរពតាមលក្ខខណ្ឌទាមទារ។

គ. សេរីភាពសាសនា

ចំពោះសេចក្តីរៀបរាប់លម្អិតស្តីពីសេរីភាពសាសនាសូមមើល *របាយការណ៍ស្តីពីសេរីភាពសាសនា* តាមគេហទំព័រwww.state.gov/religiousfreedomreport/។

ឃ. សេរីភាពដើរហើរ

ច្បាប់មានចែងអំពីសេរីភាពដើរហើរនៅក្នុងប្រទេសការធ្វើដំណើរនៅបរទេសការធ្វើអន្តោប្រវេសន៍និងមាតុភូមិនិវត្តន៍ហើយជាទូទៅក្នុងការអនុវត្តជាក់ស្តែងរដ្ឋាភិបាលបានគោរពសិទ្ធិទាំងនេះ។

<u>និរទេស</u>៖ អ្នករិះគន់រដ្ឋាភិបាល និងអ្នកនយោបាយនៃគណបក្សប្រឆាំងខ្លះបាននិរទេសខ្លួនឯងទៅបរទេស។ នៅក្នុងករណីខ្លះ រដ្ឋាភិបាលចាត់វិធានការរាំងខ្ទប់មិនឲ្យអ្នកធ្វើនិរទេសខ្លួនត្រឡប់មកវិញ។

ជនភៀសខ្លួនក្នុងប្រទេស

មិនមាន។

ការការពារជនភៀសខ្លួន

ការចាប់បញ្ជូនជនភៀសខ្លួនត្រឡប់វិញ៖

នៅខែធ្នូ រដ្ឋាភិបាលបានបណ្តេញចេញនូវអ្នកស្រុកភ្នំវៀតណាមម៉ុងតាញ៉ា ចំនួន ៤ នាក់ ឲ្យត្រឡប់ទៅប្រទេសវៀតណាមវិញ បន្ទាប់ពីមានម្នាក់បានសុំត្រឡប់ទៅវិញ ហើយ ៣ នាក់ទៀតត្រូវបានប្រកាសថា មិនអាចទទួលបានឋានៈជាអ្នកស្វែងរកសិទ្ធិជ្រកកោន។

លទ្ធភាពទទួលបានការជ្រកកោន៖

ច្បាប់ប្រទេសកម្ពុជា មានចែងអំពីការផ្តល់សិទ្ធិជ្រកកោន ឬឋានៈជាជនភៀសខ្លួន ហើយរដ្ឋាភិបាល បានរៀបចំប្រព័ន្ធមួយ សម្រាប់ផ្តល់កិច្ចការពារដល់ជនភៀសខ្លួន។រ ដ្ឋាភិបាល មិនបានផ្តល់លទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធនេះដល់អ្នកសុំសិទ្ធិជ្រកកោន និងជនភៀសខ្លួនទាំងអស់ទេ ហើយក៏គ្មានតម្លាភាពដែរ។ អ្នកស្វែងរកសិទ្ធិជ្រកកោនដែលចូលក្នុងប្រទេសដោយគ្មានឯកសារ ឬស្នាក់នៅហួសទិដ្ឋាការកំណត់ អាចនឹងរកការចាប់បញ្ជូនចេញវិញ។

សេរីភាពក្នុងការដើរហើរ៖ សេរីភាពក្នុងការដើរហើរ សម្រាប់អ្នកដែលត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងប្រទេស ក្នុងនាមជាជនភៀសខ្លួន ច្រើនតែរកការរឹតត្បិត ដោយសារគេខ្វះឯកសារចាំបាច់សម្រាប់ការធ្វើដំណើរ (សូមមើលខាងក្រោម)។

ការងារ៖ ច្បាប់អនុញ្ញាតឲ្យជនភៀសខ្លួនធ្វើការ និងបើកមុខរបរជំនួញ។ តែជនភៀសខ្លួនមិនទទួលបាននូវប័ណ្ណស្នាក់នៅទេ ដែលជាការធ្វើឲ្យគេមានការពិបាកក្នុងការអនុវត្តសិទ្ធិនេះ។

លទ្ធភាពទទួលបានការបំរើផ្នែកសេវាសាធារណៈជាមូលដ្ឋាន៖ អ្នកដែលបានទទួលឋានៈជាជនភៀសខ្លួន ត្រូវការប័ណ្ណស្នាក់នៅ។ តែជាក់ស្តែង គេទទួលបានប័ណ្ណជនភៀសខ្លួន ដែលមិនត្រូវបានគេទទួលស្គាល់ ហើយពិបាកធ្វើឲ្យគេទទួលបានការបំរើផ្នែកសេវាសាធារណៈជាមូលដ្ឋាន។

ជនគ្មានប្រទេស [ជនគ្មានរដ្ឋ]

ប្រទេសកម្ពុជា មានអ្នករស់នៅដែលជាជនគ្មានប្រទេស។ គ្មានទិន្នន័យថ្មី ដែលគួរឲ្យទុកចិត្តបាន ស្តីពីចំនួន ឬប្រជាសាស្ត្រនៃអ្នកគ្មានរដ្ឋទេ តែអង្គការ UNHCR បាននិយាយថា ពួកគេភាគច្រើនជាអាណិកជនវៀតណាម។ រដ្ឋាភិបាល មិនបានអនុវត្តច្បាប់ ឬគោលនយោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសដល់ជនទាំងនោះ

ឲ្យទទួលបានសញ្ជាតិឡើយ(សូមមើលផ្នែកទី ៦ ស្តីពីកុមារ)។ ហេតុផលដែលច្រើនមានជាងគេ ចំពោះភាពគ្មានប្រទេសគឺ កង្វះឯកសារត្រឹមត្រូវពីប្រទេសកំណើត។ នៅថ្ងៃទី ២១ សីហា ប្រព័ន្ធផ្សាយក្នុងស្រុកបាននិយាយថា រដ្ឋាភិបាល បានបដិសេធសំណើមួយរបស់វៀតណាម ដែលសុំឲ្យផ្តល់សញ្ជាតិកម្ពុជាដល់អ្នកទាំងនោះ។

បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ បុគ្គលដែលគ្មានភស្តុតាងសញ្ជាតិច្រើន មិនសូវបានទទួលបានការងារផ្លូវការ ការសិក្សា ការចុះបញ្ជីអាពាហ៍ពិពាហ៍ លទ្ធភាពតាមផ្លូវតុលាការ និងកម្មសិទ្ធិដីធ្លីទេ។

## ផ្នែកទី៣. សេរីភាពក្នុងការចូលរួមក្នុងដំណើរការនយោបាយ

រដ្ឋធម្មនុញ្ញ ផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការជ្រើសរើសរដ្ឋាភិបាលរបស់ខ្លួន តាមរយៈការបោះឆ្នោតជាទៀងទាត់ ដោយសេរី និងយុត្តិធម៌ ដោយផ្អែកលើសិទ្ធិបោះឆ្នោតជាសាកល និងស្មើភាព។ តែតាមច្បាប់ រដ្ឋាភិបាលអាចរំលាយគណបក្សនយោបាយ និងហាមបុគ្គលមិនឲ្យកាន់មុខតំណែងដឹកនាំក្នុងគណបក្ស និងមានជីវិតនយោបាយ។ វិសោធនកម្មទាំងនោះ ថែមទាំងរឹតត្បិតគណបក្ស មិនឲ្យប្រើជាសម្លេងឯកសារជារូបភាព ឬជាសំណេរ ដែលបានមកពីជនល្មើស ដែលតុលាការបានដាក់ទោស។

គិតមកត្រឹមខែតុលា មានមន្ត្រីគណបក្សសង្គ្រោះជាតិចំនួនតែ ៩ នាក់ប៉ុណ្ណោះ ក្នុងចំណោម ១១៨ នាក់ ដែលត្រូវបានហាមពីសកម្មភាពនយោបាយ បានដាក់ពាក្យ ហើយបានទទួលសិទ្ធិធ្វើនយោបាយឡើងវិញ។ អ្នកឯកទេសក្នុងស្រុក និងសមាជិកគណបក្សប្រឆាំង បានត្អូញត្អែរថា ដំណើរការ “ផ្តល់នីតិសម្បទា”នោះធ្វើតាមតែចិត្តនឹកឃើញ ធ្វើឲ្យគេយល់ខុសថា អ្នកនយោបាយមកពីគណបក្សប្រឆាំងនោះ បានធ្វើខុស ហើយធ្វើឲ្យលោកនាយករដ្ឋមន្ត្រីអាចជ្រើសរើសគូប្រឆាំងនយោបាយរបស់គាត់បាន។ ការហាមប្រាមពីដើមមក លើការធ្វើសកម្មភាពនយោបាយ ដែលមានឡើង បន្ទាប់ពីការរំលាយគណបក្សប្រឆាំងនេះដោយតុលាការកំពូលនៅឆ្នាំ ២០១៧ ។ ការហាមប្រាមនេះត្រូវបានអ្នកសង្កេតការណ៍មួយចំនួនរិះគន់ថា បណ្តាលមកពីភាពលំអៀងផ្នែកនយោបាយ ដោយបានកត់សម្គាល់ថាឃើញថា ការសម្រេចធ្វើការហាមប្រាមនេះមានឡើង មុនពេលមេដឹកនាំរបស់បក្សនេះរងការដាក់ទោសដោយតុលាការ ពីបទក្បត់ជាតិ។ ជាមួយនឹងការរំលាយគណបក្សនេះ មន្ត្រីជាប់ឆ្នោតចំនួន ៥០០៧ នាក់របស់គណបក្សនេះ ក៏ត្រូវបានដកពីតំណែង ហើយជំនួសដោយមន្ត្រីរបស់គណបក្ស

ប្រជាជន។ ជាលទ្ធផល គណបក្សប្រជាជន គ្រប់គ្រងគ្រប់លំដាប់ថ្នាក់ទាំងអស់ នៃរដ្ឋាភិបាល រាប់ពីក្រុមប្រឹក្សាស្រុកខេត្តដល់សភាជាតិ។

ការបោះឆ្នោតនិងការចូលរួមផ្នែកនយោបាយ

<u>ការបោះឆ្នោតជាតិថ្មីៗកន្លងទៅ៖</u>ការបោះឆ្នោតជាតិក្នុងពេលថ្មីៗបំផុតដែលត្រូវបានធ្វើនៅខែកក្កដា ឆ្នាំ ២០១៨ មានការចូលរួមនៃគណបក្សនយោបាយចំនួន ២០ ដោយគ្មានការចូលរួមគណបក្ស CNRP ដែលជាគណបក្សប្រឆាំងធំជាងគេ។  គណបក្សប្រឆាំងទាំង ១៩ ដែលចូលប្រកួតប្រជែង មានការគាំទ្រតិច ហើយមានច្រើនទើបនឹងបង្កើតថ្មី។

ដោយសារមានការធ្លាក់ចុះនៃអង្គភាពសារព័ត៌មានឯករាជ្យ អង្គភាពសារព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋាភិបាល ធ្វើការផ្សព្វផ្សាយលើសលុប នៅមុនពេលបោះឆ្នោត ពិសេស នៅតំបន់ជនបទ ដែលអ្នកបោះឆ្នោតភាគច្រើនមិនសូវទទួលបានព័ត៌មានពីផ្នែកសារព័ត៌មានឯករាជ្យ។

សន្លឹកឆ្នោតចំនួនប្រហែល ៦០០ ០០០ សន្លឹកយកជាការមិនបាន ក្នុងការបោះឆ្នោតលើកមុន ចំនួនសន្លឹកឆ្នោតយកជាការមិនបានមាន ១០០ ០០០ សន្លឹក។ អ្នកសង្កេតការណ៍និយាយថា នេះគឺជាសញ្ញានៃការតវ៉ា ដោយសារពួកគេរងសម្ពាធឲ្យទៅបោះឆ្នោត ដោយគ្មានគណបក្ស CNRP ឈរឈ្មោះ។ អ្នកបោះឆ្នោតជាច្រើន សុខចិត្តគូសចោល ជាជាងបោះឲ្យគណបក្សប្រឆាំងណាមួយ។ បើតាមតួលេខរបស់រដ្ឋាភិបាល មនុស្សចំនួនជិត ៧ លាននាក់ ដែលត្រូវជាចំនួន ៨៣% នៃអ្នកមានសិទ្ធិបោះឆ្នោត បានចេញទៅបោះឆ្នោត។ គណបក្សកាន់អំណាច CPP បានទទួលចំនួន ៤,៨ លានសម្លេង ដោយឈ្នះកៅអីទាំង ១២៥ នៅក្នុងរដ្ឋសភា។ ស្ថិតិរបស់រដ្ឋាភិបាល មិនអាចបញ្ជាក់បានទេ ដោយសារខ្វះអ្នកសង្កេតការណ៍ឯករាជ្យ។

អាជ្ញាធរគិតថា សន្លឹកឆ្នោតប្រមាណ ៦ សែនសន្លឹក មិនត្រូវយកជាការបាន ចំណែកនៅក្នុងការបោះឆ្នោតក្នុងឆ្នាំ ២០១៣ មានតែ ១ សែនសន្លឹកទេ។

អ្នកសង្កេតការណ៍ឯករាជ្យភាគច្រើន ចាត់ទុកដំណើរការបោះឆ្នោតទាំងមូលថា មានកំហុសឆ្គងធ្ងន់ធ្ងរ។ ស្ថានទូតភាគច្រើននៅកម្ពុជា មិនព្រមធ្វើជាអ្នកសង្កេតការណ៍ផ្លូវការ នៅក្នុងការបោះឆ្នោតនេះទេ។ អង្គការសង្កេតការណ៍បោះឆ្នោតដែលមានមែនរបស់រដ្ឋ ដោយរួមមានទាំងមជ្ឈមណ្ឌល Carter Center និង Asian Network for Free Elections ក៏បានសម្រេចចិត្តមិនមកធ្វើការតាមដានការបោះឆ្នោតនេះដែរ ពីព្រោះអង្គការទាំងនោះចាត់ទុកថា ការបោះឆ្នោតនេះខ្វះភាពត្រឹមត្រូវជាមូលដ្ឋាន។ គជប បានចោទសហគមន៍អន្តរជាតិថា

មានភាពលំអៀង ដោយនិយាយថា សហគមន៍អន្តរជាតិគាំទ្រ គជប
តែនៅពេលណាមានការចូលរួមការបោះឆ្នោតរបស់គណបក្ស CNRP តែប៉ុណ្ណោះ។ ទោះបីជាមានឈ្មោះថា ឯករាជ្យក្តី តែរដ្ឋាភិបាលបានដាក់កាមេរ៉ាថតនៅ គជប ដែលធ្វើឲ្យគេអាចតាមដានការងាររបស់គជបបាន។ ដោយគ្មានអ្នកសង្កេតការណ៍ឯករាជ្យដែលគួរអោយទុកចិត្តបាន លទ្ធផលឆ្នោតក៏គេមិនអាចធ្វើការផ្ទៀងផ្ទាត់បញ្ជាក់ដោយឯករាជ្យបានផងដែរ។

<u>គណបក្សនយោបាយនិងការចូលរួមនយោបាយ៖</u> គិតមកត្រឹមខែកក្កដា រដ្ឋាភិបាលបានបញ្ជាក់ថា មានគណបក្សនយោបាយចំនួន ៤៤ បានចុះបញ្ជីការជាមួយក្រសួងមហាផ្ទៃ។ លោកលែងតែគណបក្សប្រជាជន គណបក្សនយោបាយនានា បានរងការរើសអើងតាមផ្លូវច្បាប់ ការអនុវត្តច្បាប់មិនស្មើភាព ការគំរាមកំហែង និងការផ្សាយព័ត៌មានដោយមានលំអៀង។ កត្តាទាំងអស់នេះនាំឲ្យគណបក្ស CPP យកផ្តាច់មុខនូវអំណាចនយោបាយ។ អ្នកកាន់មុខតំណែងជាច្រើននៅក្នុងរដ្ឋាភិបាលត្រូវតែជាសមាជិកនៃគណបក្ស CPP។ បន្ទាប់ពីការរំលាយ CNRP រដ្ឋាភិបាល បានបន្តគាបសង្កត់លើសម្លេងប្រឆាំង។ គិតមកត្រឹមខែមិថុនា NGO ក្នុងស្រុកមួយបាននិយាយថា មានករណីគំរាមកំហែងចំនួន ២៩ ដល់សកម្មជននយោបាយ។

<u>ការចូលរួមរបស់ស្ត្រីនិងក្រុមជនជាតិភាគតិច៖</u> គ្មានច្បាប់ដែលដាក់កំហិតព្រំដែន លើការចូលរួមរបស់ស្ត្រី និងជនជាតិភាគតិច នៅក្នុងដំណើរការនយោបាយទេ តែវប្បធម៌ប្រពៃណីកម្រិតការចូលរួមរបស់ស្ត្រីនៅក្នុងនយោបាយ និងរដ្ឋាភិបាល។ ទោះបីជាគណបក្សCPP បានសន្យាម្តងហើយម្តងទៀតថា នឹងបង្កើនតំណាងរបស់ស្ត្រីក្តី តែចំនួនបេក្ខជនជាស្ត្រី ដែលជាប់ឆ្នោតនៅក្នុងការបោះឆ្នោតជាតិនៅខែកក្កដាឆ្នាំ ២០១៨ មានការថយចុះពី ២០% មកត្រឹម ១៥%។ ការបោះឆ្នោតថ្នាក់មូលដ្ឋាន នៅឆ្នាំ ២០១៧ ឃើញមានជាលើកដំបូង នូវការចូលរួមនៃគណបក្សប្រជាធិបតេយ្យជនជាតិដើមកម្ពុជា។

ផ្នែកទី៤៖ អំពើពុករលួយ និងកង្វះតម្លាភាពក្នុងរដ្ឋាភិបាល

ច្បាប់មានចែងអំពីទោសព្រហ្មទណ្ឌ សម្រាប់អំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីនានា។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះ ប្រកបដោយប្រសិទ្ធភាពឡើយ ហើយមន្ត្រីជាញឹកញាប់តែងតែប្រព្រឹត្តអំពើពុករលួយដោយមាននិទណ្ឌភាព។

<u>អំពើពុករលួយ៖</u> ក្រមព្រហ្មទណ្ឌបានកំណត់អំពើពុករលួយនានា ហើយកំណត់ច្បាស់នូវទោស ចំពោះការប្រព្រឹត្តអំពើទាំងនេះ។ ច្បាប់ប្រឆាំងអំពើពុករលួយ ចែងពីមូលដ្ឋានច្បាប់សម្រាប់ឲ្យក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គ

ភាពប្រឆាំងអំពើពុករលួយ ទទួលនិងស៊ើបអង្កេតបណ្ដឹង ទាក់ទងនឹងអំពើពុករលួយ។អង្គភាពប្រឆាំងអំពើពុករលួយ មិនសហការឲ្យបានញឹកញាប់ ជាមួយសង្គមស៊ីវិលហើយត្រូវបានគេមើលឃើញថា គ្មានប្រសិទ្ធភាពក្នុងការប្រយុទ្ធ ប្រឆាំងនឹងអំពើពុករលួយ។ ផ្ទុយទៅវិញ អង្គភាពប្រឆាំងអំពើពុករលួយ មានភាពសកម្មនៅក្នុងការដឹកនាំការស៊ើប អង្កេតទៅលើសមាជិកនៃគណបក្សប្រឆាំង ដែលជាការនាំឲ្យគេនាំគ្នាយល់ថា អង្គភាពនេះ បម្រើផលប្រយោជន៍របស់ គណបក្សកាន់អំណាច។ អង្គភាពនេះមិនដែលស៊ើបអង្កេតសមាជិកជាន់ខ្ពស់នៃគណបក្សកាន់អំណាចទេ ទោះបីមាន ការចោទប្រកាន់ជាច្រើនពីបទពុករលួយ ក្នុងលំដាប់ថ្នាក់ជាន់ខ្ពស់នៃគណបក្ស និងរដ្ឋាភិបាលក្ដី។ឧទាហរណ៍ យោងតាមរបាយការណ៍ស៊ើបអង្កេត ចេញខែកក្កដា ឆ្នាំ ២០១៨ របស់ទូរទស្សន៍ Aljazeera អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារកម្ពុជា បានរំលោភ លើច្បាប់សារជីវកម្មអូស្រ្តាលី ហើយបានគេចពន្ធអូស្រ្តាលី តែអាជ្ញាធរកម្ពុជា មិនបានធ្វើការស៊ើបអង្កេត ឬកាត់ទោសគាត់ទេ។ មន្ត្រីរាជការត្រូវមានការយល់ព្រមពីប្រធាន មុនពេលឆ្លើយសំណួររបស់ស្ថាប័ននីតិបញ្ញត្តិ ទាក់ទងនឹងការចោទប្រកាន់ស្ដីពីអំពើពុករលួយ។

អំពើពុករលួយមានលក្ខណៈរាលដាល នៅក្នុងសង្គមនិងរដ្ឋាភិបាល។ មានសេចក្ដីរាយការណ៍មកថា នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងចៅក្រមជម្រះក្ដី បានទទួលសំណូកពីអ្នករកស៊ី ទាំងស្របច្បាប់ ទាំងខុសច្បាប់។ពលរដ្ឋតែងតែត្អូញត្អែរជាសាធារណៈ អំពីអំពើពុករលួយ។ បៀវត្សរ៍មិនគ្រប់គ្រាន់រួមចំណែកឲ្យ មាន“អំពើពុករលួយដើម្បីរស់” ក្នុងចំណោមមន្ត្រីថ្នាក់ទាប ចំណែកវប្បធម៌និទណ្ឌភាព ធ្វើឲ្យអំពើពុករលួយ រីកសាយ ក្នុងចំណោមមន្ត្រីជាន់ខ្ពស់។

យោងតាមការវាស់ស្ទង់ដែលមានឈ្មោះថា 2016 Global Corruption Barometer តុលាការ គឺជាវិស័យ ដែលពុករលួយជាងគេ នៅក្នុងរយៈពេល ៤ ឆ្នាំជាប់គ្នា ដែលបន្ទាប់មកមានស្ថាប័នអ្នកអនុវត្តច្បាប់។

<u>ការប្រកាសទ្រព្យសម្បត្តិ៖</u> រាជការ រួមទាំងមន្ត្រីតែងតាំងនិង មន្ត្រីជាប់ឆ្នោតផងតាមច្បាប់ ត្រូវប្រកាសទ្រព្យសម្បត្តិ របស់គេ។ អង្គភាពប្រឆាំងអំពើពុករលួយ(ACU) ទទួលខុសត្រូវក្នុងការទទួលយកសេចក្ដីប្រកាស ចំណែកការពិន័យចំពោះការមិនគោរពតាម មានការជាប់ពន្ធនាគាររាប់ពី ១ ខែទៅ ១ ឆ្នាំ។ ការប្រកាសទ្រព្យសម្បត្តិ របស់មន្ត្រីជាន់ខ្ពស់មិនត្រូវបានឲ្យដឹង ដល់សាធារណៈទេ ហើយនៅបិទជិតក្នុងស្រោមសំបុត្រ រហូតទាល់តែមានការប្ដឹង ទាក់ទងនឹងអំពើពុករលួយ។ មានតែសេចក្ដីប្រកាសទ្រព្យសម្បត្តិតែមួយគត់ ត្រូវបានបើកមើល គឺការប្រកាសរបស់អតីតប្រធានគណបក្ស CNRP កឹម សុខា ។

ផ្នែកទី៥៖ ឥរិយាបថរបស់រដ្ឋាភិបាល ចំពោះការស៊ើបអង្កេតរបស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលលើ ការចោទប្រកាន់ ពីបទរំលោភសិទ្ធិមនុស្ស

មានរបាយការណ៍ជាច្រើន អំពីកង្វះការសហការ ហើយនៅក្នុងករណីមួយចំនួន មានការបំភិតបំភ័យដោយមន្ត្រីរដ្ឋាភិបាល លើអ្នកស៊ើបអង្កេតសិទ្ធិមនុស្ស។ រដ្ឋាភិបាលបានគម្រាមប្តឹង NGO ចំនួន ២ ទាក់ទងនឹងការចេញរបាយការណ៍ ស្តីពីផលអវិជ្ជមាននៃកម្ចីខ្នាតតូច លើអ្នកទទួលកម្ចី។

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិ រងកំណើននៃការឃាយី គំរាមកំហែង ការតាមដាន និងការសម្លុតពីមន្ត្រីមូលដ្ឋាន និងអ្នកដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល។ អង្គការសង្គមស៊ីវិល និងអង្គការពលកម្មបាននិយាយថា នគរបាល បានឆ្មក់ចូលការិយាល័យរបស់គេ ។

មានអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារផ្នែកសិទ្ធិមនុស្ស ប្រមាណជា ២៥ នៅក្នុងប្រទេស និងមានចំនួនប្រហែល ១០០ ទៀតដែលផ្តោតការយកចិត្តទុកដាក់លើវិស័យផ្សេងទៀត ដែលមាននៅក្នុងបញ្ហាសិទ្ធិមនុស្ស ប៉ុន្តែមានតែអង្គការមួយចំនួនតូចប៉ុណ្ណោះ ដែលធ្វើសកម្មភាព ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ឬស៊ើបអង្កេតការរំលោភសិទ្ធិមនុស្ស។

<u>អង្គការសហប្រជាជាតិនិងអង្គការអន្តរជាតិដទៃទៀត</u>៖ រដ្ឋាភិបាល ជាទូទៅបានអនុញ្ញាតឲ្យតំណាងអង្គការសហប្រជាជាតិមកធ្វើទស្សនកិច្ច។ តែរដ្ឋាភិបាល ច្រើនតែមិនព្រមជួបប្រជុំថ្នាក់ខ្ពស់ ជាមួយតំណាងនៃអង្គការសហប្រជាជាតិ ហើយមិនឲ្យពួកគេជួបជាមួយមន្ត្រីបក្សប្រឆាំង ដោយរួមទាំងលោក កឹម សុខា ផងដែរ។ នៅខែឧសភា អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា លោកស្រី Rhona Smith បានមកធ្វើទស្សនកិច្ច នៅកម្ពុជាចំនួន ១០ ថ្ងៃ។ នៅក្នុងការប្រជុំរបស់លោកស្រី ជាមួយអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋសភាជាតិ គជប គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និង NGO លោកស្រីបានលើកពីកង្វល់ជ្រាលជ្រៅលើការរឹតត្បិតលើផ្នែកសារព័ត៌មាន ការចូលរួមផ្នែកនយោបាយ សេរីភាពក្នុងការបញ្ចេញមតិ ការឃុំខ្លួនយ៉ាងយូរលើលោក កឹម សុខា និងច្បាប់ស្តីពីគណបក្សនយោបាយ។ អ្នកនាំពាក្យរបស់រដ្ឋាភិបាល តែងតែរិះគន់តំណាងពិសេសនៃអង្គការសហប្រជាជាតិ ជាសាធារណៈចំពោះការនិយាយរបស់គេ ស្តីពីបញ្ហានានាផ្នែកសិទ្ធិមនុស្ស។

<u>ស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាល</u>៖ រដ្ឋាភិបាល មានស្ថាប័នសិទ្ធិមនុស្សចំនួន ៣ ដែលរួមមានគណៈកម្មាធិការដាច់ដោយឡែក ទទួលបន្ទុកការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង នៅក្រោមព្រឹទ្ធសភា និងរដ្ឋសភា ព្រមទាំងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលស្ថិតនៅក្រោមខុទ្ទកាល័យនាយករដ្ឋមន្ត្រី។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ប្រគល់របាយការណ៍របស់រដ្ឋាភិបាល ដើម្បីចូលរួមក្នុងដំណើរការពិនិត្យសិទ្ធិមនុស្ស ជាអន្តរជាតិ ដូចជាការពិនិត្យទៀងទាត់ជាសកល និងបានឆ្លើយតបចំពោះរបាយការណ៍របស់ស្ថាប័នរដ្ឋាភិបាលនិងអង្គការអន្តរជាតិ ប៉ុន្តែមិនបានធ្វើការស៊ើបអង្កេត ស្ថានភាពសិទ្ធិមនុស្សដោយឯករាជ្យឡើយ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស ដែលគួរឱ្យទុកចិត្តបានចាត់ទុកថា គណៈកម្មាធិការរបស់រដ្ឋាភិបាលថា មានប្រសិទ្ធភាពការងារនៅមានកម្រិត

ហើយបានរិះគន់តួនាទីរបស់ស្ថាប័ននេះ នៅក្នុងការនិយាយការពារ ការបង្ក្រាបរបស់រដ្ឋាភិបាល ទៅលើសង្គមស៊ីវិល និងគណបក្សប្រឆាំង។

អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ បានបន្តធ្វើការស៊ើបអង្កេត និងដាក់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើយង់ឃ្នង ដែលត្រូវបានប្រព្រឹត្តពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។ ECCC គឺជាតុលាការកូនកាត់ ដោយមានបុគ្គលិក និងចៅក្រមជាតិ និងអន្តរជាតិ ហើយគ្រប់គ្រងដោយច្បាប់ក្នុងស្រុករបស់កម្ពុជាផង និងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិផង។ នៅថ្ងៃទី ២៨ មិថុនា សហចៅក្រមស៊ើបអង្កេតកម្ពុជា និងអន្តរជាតិ បានផ្តល់អនុសាសន៍ដោយឡែក និងផ្ទុយគ្នាថាតើគួរដំណើរការលើករណី យឹម ទិត ឬអត់។ ដូចក្នុងករណីប្រឆាំងនឹងឈ្មោះ មាស មុត និងអៅ អាន នៅឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្តល់យោបល់ឲ្យធ្វើការចោទប្រកាន់ ចំណែកភាគីខាងកម្ពុជាអះអាងថា តុលាការខ្វះយុត្តាធិការក្នុងការធ្វើការចោទប្រកាន់។ គិតមកដល់ខែតុលា ECCC  មិនបានប្រកាសថា ខ្លួននឹងដំណើរការលើករណីណាមួយក្នុងចំណោមករណីចុងក្រោយទាំង ៣ នេះទេ។ នៅថ្ងៃទី៤ ខែសីហា នួន ជា បានស្លាប់ក្នុងអាយុ ៩៣ ឆ្នាំ ក្នុងពេលដែលតុលាការពិចារណាលើបណ្តឹងឧទ្ធរណ៍ លើការដាក់ទោសលើគាត់កាលពីខែវិច្ឆិកា ឆ្នាំ ២០១៨ ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។

## ផ្នែកទី៦៖ ការរើសអើងការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្សស្ត្រី

ការរំលោភសេពសន្ថវៈនិងហិង្សាក្នុងគ្រួសារ៖ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាធំ។ ច្បាប់ដាក់ទោសព្រហ្មទណ្ឌ ចំពោះអំពើរំលោភសេពសន្ថវៈ និងការបំពារបំពាន។ អំពើរំលោភសេពសន្ថវៈ ត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារពី ៥ ឆ្នាំទៅ ៣០ ឆ្នាំ។ អំពើរំលោភសេពសន្ថវៈប្តី/ប្រពន្ធ មិនត្រូវបានចែងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌឡើយ ប៉ុន្តែអាចធ្វើការចោទប្រកាន់ថាជា “អំពើរំលោភសេពសន្ថវៈ” “ការបង្ករបួសស្នាម” ឬ “ការបំពារបំពានមិនសមរម្យ” បាន។ កម្រមានការចោទប្រកាន់ ពីបទរំលោភសេពសន្ថវៈប្តី/ប្រពន្ធតាមក្រមព្រហ្មទណ្ឌនិងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារណាស់។ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារកំណត់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែមិនមានចែងជាក់លាក់អំពីការដាក់ទោសឡើយ។ គេអាចប្រើក្រមព្រហ្មទណ្ឌដើម្បីដាក់ទោសចំពោះបទល្មើសហិង្សាក្នុងគ្រួសារ ដោយដាក់ទោសពន្ធនាគារ ចាប់ពី ១ ឆ្នាំរហូតដល់ ១៥ ឆ្នាំ។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិបានរាយការណ៍ថាអំពើហិង្សាប្រឆាំងស្ត្រី មានដូចជាអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ កើតមានជាទូទៅ។ អំពើហិង្សាក្នុងគ្រួសារ និងការរំលោភផ្លូវភេទ ច្រើនតែមិនត្រូវបានគេរាយការណ៍អស់ ដោយសារជនរងគ្រោះខ្លាចការសងសឹកដោយជនល្មើស ការរើសអើងនៅក្នុងសង្គម និងការដែលគេមិនទុកចិត្តប្រព័ន្ធតុលាការ។ នៅក្នុងចំណោមមន្ត្រីតុលាការ មានចំនួននារីតិចតួច។ ១៤% នៃចៅក្រម

១២% នៃព្រះរាជអាជ្ញា ២០% នៃមេធាវី។ អង្គការ NGO បាននិយាយថា អាជ្ញាធរមិនសូវប្រឹងប្រែងខ្លាំងក្នុងការអនុវត្តច្បាប់គ្រួសារទេ ហើយជៀសវាងការពាក់ព័ន្ធក្នុងជម្លោះក្នុងគ្រួសារ។ មានតែ ២០% នៃករណីអំពើហិង្សាក្នុងគ្រួសារ ដែលត្រូវបានតាមដានពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៦ បានឈានដល់ដំណើរការក្តីព្រហ្មទណ្ឌ។

ការរំលោភផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ ជាញឹកញាប់ បណ្តាលអោយស្លាប់៖ អង្គការ NGO មួយបាននិយាយថា មានការសម្លាប់ចំនួន ១០ ករណី នៅក្នុងការសង្កេតពីខែមករា ដល់ខែមិថុនា លើករណីអំពើហិង្សាក្នុងគ្រួសារចំនួន ៣៩ និងករណីរំលោភផ្លូវភេទចំនួន ១៨។ នៅក្នុងចំណោមករណីទាំង ៥៧ នេះ អាជ្ញាធរបានចាប់ខ្លួនជនល្មើសបានតែ ២៣ នាក់ទេ។ យោងតាមរបាយការណ៍ឆ្នាំ ២០១៧ របស់អង្គការ NGO ផ្នែកសិទ្ធិមនុស្ស ទាំងអាជ្ញាធរទាំងសាធារណជនជាទូទៅ មិនចាត់ទុកអំពើហិង្សាក្នុងគ្រួសារ ថាជាបទល្មើសព្រហ្មទណ្ឌទេ។

នៅខែកក្កដា ឆ្នាំ ២០១៧ ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារី បានចាប់ផ្តើមអនុវត្តក្រមអាកប្បកិរិយាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងហិង្សាទៅលើនារី។ ក្រមនេះហាមប្រាមការបោះពុម្ពព័ត៌មាន ដែលរួមទាំងរូបនៃជនរងគ្រោះ ការបង្ហាញពីការស្លាប់ របួស ឬភាពអាក្រាតរបស់ជនរងគ្រោះ ការប្រើពាក្យប្រមាថទៅលើស្ត្រី។ ក្រសួងកិច្ចការនារី ថែមទាំងបានប្រកាសពីប្រព័ន្ធធ្វើសេចក្តីរាយការណ៍ នៅក្នុងជួររដ្ឋាភិបាល ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាព នៅក្នុងការឆ្លើយតបរបស់រដ្ឋាភិបាល ចំពោះហិង្សាទៅលើស្ត្រី។ ក្រសួងកិច្ចការនារី ថែមទាំងបានធ្វើការសម្របសម្រួល ជាមួយអង្គការ NGOមួយចំនួន និងផ្នែកសារព័ត៌មានខ្លះ ដើម្បីធ្វើកម្មវិធីតាមវិទ្យុ និងទូរទស្សន៍ ស្តីពីបញ្ហាទាក់ទងនឹងស្ត្រី។

<u>ការបៀតបៀនផ្លូវភេទ៖</u>ក្រមព្រហ្មទណ្ឌដាក់ទោសព្រហ្មទណ្ឌ ចំពោះការបៀតបៀនផ្លូវភេទដោយដាក់ពន្ធនាគារពី ៦ ថ្ងៃទៅ ៣ ខែ និងពិន័យជាទឹកប្រាក់ចំនួនពី ១០០០០០ រៀលទៅ ៥០០០០០ រៀល (២៥ទៅ១២៥ ដុល្លារអាមេរិក)។ ការសិក្សាមួយដែលត្រូវបានធ្វើដោយអង្គការ CARE International បានរកឃើញថា ជិត១ ភាគ ៣ នៃកម្មការិនីរោងចក្រកាត់ដេរ ធ្លាប់ត្រូវបានគេបៀតបៀនផ្លូវភេទ នៅកន្លែងធ្វើការរបស់គេ នៅក្នុងរយៈពេល ១២ ខែចុងក្រោយនេះ។

<u>ការបង្ខិតបង្ខំក្នុងការកំណត់ចំនួនប្រជាជន៖</u> គ្មានសេចក្តីរាយការណ៍ពីរំលូតកូនដោយបង្ខំ ការធ្វើមិនឲ្យមានកូនដោយមិនទៅតាមការស្ម័គ្រចិត្តទេ។

<u>ការរើសអើង៖</u> រដ្ឋធម្មនុញ្ញ ចែងអំពីសិទ្ធិស្មើភាពគ្នាសម្រាប់ស្ត្រី ការទទួលបានប្រាក់កម្រៃស្មើគ្នា ចំពោះការងារដូចគ្នា និងឋានៈស្មើគ្នាក្នុងអាពាហ៍ពិពាហ៍។ ជាទូទៅ ស្ត្រីមានសិទ្ធិលើទ្រព្យសម្បត្តិស្មើភាពគ្នា មានសិទ្ធិតាមផ្លូវច្បាប់ដូចគ្នាក្នុងការដាក់ពាក្យបណ្តឹងលែងលះ និងសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ និងការងារមួយចំនួន។ ប៉ុន្តែប្រពៃណី

វប្បធម៌ និងការទទួលខុសត្រូវក្នុងការមើលកូន បានកម្រិតលទ្ធភាពរបស់ស្ត្រី ក្នុងការឈានទៅដល់ការទទួលបានមុខតំណែងខ្ពស់នៅក្នុងការងារ ឬបានការងារធ្វើ (សូមមើលផ្នែក ៧ ឃ)។

**កុមារ**

ការចុះសំបុត្រកំណើត៖ តាមច្បាប់សញ្ជាតិ កូនអាចទទួលបានតាមរយៈកំណើតពីឪពុកម្តាយ ដែលមិនមែនជាជនជាតិខ្មែរ ក្នុងករណីដែលឪពុកម្តាយទាំងពីរនោះ បានកើតនិងរស់នៅដោយស្របច្បាប់ នៅក្នុងប្រទេសកម្ពុជា ឬករណីដែលឪពុក/ម្តាយណាម្នាក់ ទទួលបានសញ្ជាតិកម្ពុជា តាមរយៈមធ្យោបាយផ្សេងទៀតតាមផ្លូវច្បាប់។ ជនជាតិខ្មែរដើមត្រូវបានចាត់ទុកថាជាពលរដ្ឋ។ ក្រសួងមហាផ្ទៃ បានគ្រប់គ្រងប្រព័ន្ធចុះបញ្ជីកំណើត តាមបែបទំនើប ប៉ុន្តែទារកទាំងអស់ មិនសុទ្ធតែត្រូវបានចុះបញ្ជីភ្លាមៗឡើយ ពិសេសដោយសារកង្វះការយល់ដឹង ពីសារៈសំខាន់នៃការចុះបញ្ជីកំណើត និងអំពើពុករលួយច្រើន របស់អាជ្ញាធរមូលដ្ឋាន។ ចាប់ពីខែមករាមក អាជ្ញាធរ លែងយកប្រាក់ចំពោះការចុះបញ្ជីកំណើត។

ការខកខានមិនបានចុះបញ្ជីកំណើត នាំឱ្យមានការរើសអើងរួម ទាំងក្នុងការមិនផ្តល់សេវាសាធារណៈផងដែរ។ កុមារជនជាតិភាគតិច និងកុមារដែលគ្មានសញ្ជាតិច្រើន ត្រូវបានផាត់ចេញពីដំណើរការចុះបញ្ជីកំណើត។ អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់សេវាចំពោះសហគមន៍ ដែលត្រូវបានគេផាត់ចេញបានរាយការណ៍ថាជារឿយៗកុមារដែលគ្មានសំបុត្រកំណើត និងសៀវភៅគ្រួសារបាត់បង់លទ្ធភាពទទួលបានការអប់រំនិងការថែទាំសុខភាព។ អង្គការមិនមែនរដ្ឋាភិបាលទាំងនោះ ក៏បានបញ្ជាក់ផងដែរថា អ្នកទាំងនេះច្រើនតែគ្មានលទ្ធភាព ក្នុងការទទួលបានការងារធ្វើការ មានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ការចូលរួមបោះឆ្នោត ឬការប្រើប្រាស់ប្រព័ន្ធច្បាប់។

ការអប់រំ៖ ការអប់រំរហូតដល់ថ្នាក់ទី៩ គឺឥតមានបង់ថ្លៃឡើយប៉ុន្តែមិនមែនជាកាតព្វកិច្ចត្រូវតែរៀនទេ។ កុមារជាច្រើនបានឈប់រៀន ដើម្បីជួយគ្រួសារក្នុងការងារកសិកម្មលក្ខណៈគ្រួសារ ធ្វើការងារនៅក្នុងសកម្មភាពផ្សេងទៀត។ អ្នកខ្លះទៀតចូលរៀននៅអាយុច្រើន ឬមិនចូលរៀនសោះតែម្តង។ រដ្ឋាភិបាលមិនបដិសេធក្មេងស្រីក្នុងការទទួលបានការអប់រំស្មើភាពគ្នាទេ។ ប៉ុន្តែជារឿយៗគ្រួសារដែលមានធនធានមានកម្រិត ផ្តល់អាទិភាពដល់ក្មេងប្រុស ជាងក្មេងស្រី ពិសេសនៅតំបន់ជនបទ។ បើយោងតាមរបាយការណ៍អង្គការអន្តរជាតិ បន្ទាប់ពីកម្រិតបឋមសិក្សា ចំនួនក្មេងស្រីចុះឈ្មោះចូលរៀនធ្លាក់ចុះយ៉ាងខ្លាំង នៅតំបន់ក្រុង ចំណែកការចូលរៀនរបស់ក្មេងប្រុស នៅក្រោយថ្នាក់បឋមសិក្សា មានចំនួនធ្លាក់ចុះច្រើនគួរសមនៅតំបន់ជនបទ។

ការរំលោភធ្វើបាបកុមារ៖ បើតាមអ្នកសង្កេតការណ៍ ការរំលោភធ្វើបាបកុមារច្រើនកើតមាន ហើយការប្តឹងប្រឆាំងនឹងជនប្រព្រឹត្តកម្រមានណាស់។ បើយោងតាមរបាយការណ៍របស់អង្គការ UNICEF ស្តីពីហិង្សាលើកុមារ

កុមារកម្ពុជាម្នាក់ក្នុងចំណោម ២ នាក់ធ្លាប់រងហិង្សាខ្លាំង។ ការរំលោភផ្លូវភេទលើកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរនៅឡើយ ហើយសេចក្តីរាយការណ៍ ស្តីពីបទល្មើសនេះ ឃើញមានច្រើនឡើងៗ នៅក្នុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ ការរំលោភសេពសន្ថវៈលើកុមារ នៅតែជាបញ្ហាធ្ងន់ធ្ងរមួយនៅឡើយ។

<u>ការឆាប់រៀបអាពាហ៍ពិពាហ៍ និងការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍៖</u> អាយុគ្រប់ការ តាមច្បាប់សម្រាប់ក្មេងប្រុស និងក្មេងស្រីគឺ ១៨ ឆ្នាំ តែកុមារអាយុត្រឹម ១៦ ឆ្នាំអាចរៀបការដោយស្របច្បាប់បាន បើមានការយល់ព្រមពីឪពុកម្តាយ។ ឪពុកម្តាយ សមាជិកសហគមន៍ និងអ្នកនយោបាយ មិនចាត់ទុកអាពាហ៍ពិពាហ៍កុមារថា ជាបញ្ហាទេ ។

<u>ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ៖</u> ការរួមភេទជាមួយកុមារអាយុក្រោម១៥ឆ្នាំ គឺជាអំពើខុសច្បាប់។ រដ្ឋាភិបាល បានបន្តផ្អាក់ផ្ទះបន ដើម្បីរកមើល និងប្រមូលជនរងគ្រោះដោយសារការជួញដូរផ្លូវភេទ ជាកុមារ ថ្វីបើភាគច្រើននៃការជួញដូរផ្លូវភេទលើកុមារមានការលាក់បាំង មាននៅតាមកន្លែងបម្រើផ្លូវភេទ “ដោយមិនផ្ទាល់” ដូចជាតាមបៀរហ្គាដិន កន្លែងម៉ាស្សា កន្លែងកែសម្ផស្ស ខារ៉ាអូខេ និងកន្លែងមិនមែនធ្វើពាណិជ្ជកម្មនានា។ នគរបាលបន្តស៊ើបអង្កេតលើករណីជួញដូរកុមារនៅតាមផ្ទះបន ឬក្នុងករណីដែលជនរងគ្រោះមកប្តឹងដោយផ្ទាល់ តែមិនធ្វើការលើករណីស្មុគស្មាញខ្លាំងទេ ឧទាហរណ៍ ការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ិនធ័រណែត។ រដ្ឋាភិបាល មិនអនុញ្ញាតឲ្យមានការប្រើបច្ចេកទេសស៊ើបអង្កេតសម្ងាត់ នៅក្នុងការស៊ើបអង្កេតលើការជួញដូរទេ ដែលជាការធ្វើឲ្យនគរបាល ច្រើនមិនអាចចាប់អ្នកប្រព្រឹត្តិការជួញដូរលើកុមារទទួលខុសត្រូវបានទេ។

ប្រទេសកម្ពុជា នៅតែជាគោលដៅទេសចរណ៍ផ្លូវភេទលើកុមារ។ រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ដើម្បីកាត់ទោសទាំងអ្នកទេសចរផ្លូវភេទ ទាំងពលរដ្ឋដែលកេងប្រវ័ញ្ចកុមារក្នុងពេស្យាចារ។ ច្បាប់ដាក់ទោសជាប់ពន្ធនាគារចាប់ពី ២ ទៅ ២០ ឆ្នាំចំពោះការកេងប្រវ័ញ្ច ជួញដូរផ្លូវភេទលើកុមារ។ច្បាប់នេះក៏ហាមប្រាមផងដែរនូវការផលិត និងការមានរូបអាសអាភាសកុមារ តែច្បាប់មិនហាមឃាត់ដោយដាក់ទោសព្រហ្មទណ្ឌ ចំពោះការផ្តល់កុមារ សម្រាប់ការសំដែងភាពអាសអាភាស។

បើយោងតាមអង្គការផ្នែកសិទ្ធិមនុស្សក្នុងស្រុកមួយ ជនប្រព្រឹត្តដែលមានខ្សែរយៈក្នុងរដ្ឋាភិបាល មិនត្រូវចាប់ឲ្យទទួលខុសត្រូវ នៅក្រោមច្បាប់ឡើយ ហើយអ្នកជំនាញក្នុងស្រុក បានសម្តែងកង្វល់អំពីការខកខានរបស់រដ្ឋាភិបាល ក្នុងការដាក់ទោសឲ្យបានសមស្រប ទៅលើជនបរទេសដែលទិញការរួមភេទជាមួយកុមារ។ អំពើពុករលួយដែលរាលដាលនៅគ្រប់ផ្នែកទាំងអស់ ក្នុងរដ្ឋាភិបាលដាក់កំហិតព្រំដែនយ៉ាងខ្លាំង លើលទ្ធភាពរបស់មន្ត្រីម្នាក់ៗ ក្នុងការចាប់ឲ្យជនប្រព្រឹត្តការជួញដូរផ្លូវភេទលើកុមារ ទទួលខុសត្រូវ ហើយរដ្ឋាភិបាលមិនធ្វើការស៊ើបអង្កេត ឬកាត់ទោសមន្ត្រីដែលឃុបឃិតឡើយ។

កុមារផ្លាស់ទីលំនៅ៖ រដ្ឋាភិបាលបានផ្ដល់សេវាមានកម្រិត និងមិនគ្រប់គ្រាន់ ដល់កុមាររស់នៅតាមចិញ្ចើមថ្នល់ នៅមជ្ឈមណ្ឌលស្ដារនីតិសម្បទា។ កុមារផ្លាស់ទីលំនៅនៅតែជាបញ្ហាធ្ងន់ធ្ងរ និងកំពុងកើនឡើងខ្លាំង ពិសេសដោយការធ្វើចំណាកស្រុកចេញទៅធ្វើការនៅបន្តមាន ហើយកុមារក្នុងចំនួនច្រើនត្រូវបានទុកចោល។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ បានវាយតម្លៃថា មានកុមារតាមចិញ្ចើមផ្លូវ ក្នុងចំនួនប្រហែលជាពី ១២០០ ទៅ ១៥០០ នាក់នៅក្នុងរាជធានីភ្នំពេញដែលគ្មានទំនាក់ទំនងគ្រួសារហើយកុមារប្រមាណជាពី ១៥០០០ ទៅ ២០០០០ នាក់បានធ្វើការងារនៅតាមចិញ្ចើមផ្លូវប៉ុន្តែបានត្រឡប់ទៅផ្ទះវិញនៅពេលយប់។

កុមារនៅតាមមណ្ឌល អង្គការ៖ អង្គការNGO និងអ្នកសង្កេតការណ៍ដទៃទៀតបានចោទថា មជ្ឈមណ្ឌលកុមារកំព្រាឯកជនជាច្រើន គ្មានការគ្រប់គ្រងល្អទេ ហើយមានកុមារអត់កំព្រាច្រើន ដើម្បីទាក់ទាញអំណោយពីជនបរទេស។ បើយោងតាមអង្គការ UNICEF និងការស្រាវជ្រាវមួយដែលធ្វើដោយសាកលវិទ្យាល័យ Columbia មានកុមារក្នុងចំនួនពី ៣៦០០០ ទៅ ៤៩០០០ នាក់រស់នៅតាមផ្ទះដែលផ្ដល់ការថែទាំ ឬមជ្ឈមណ្ឌលកុមារកំព្រា។ ប្រហែល ៨០% នៃកុមារទាំងនេះ មានយ៉ាងហោចណាស់ក៏ឪពុក ឬក៏ម្ដាយដែរ។ ការថែទាំឲ្យស្នាក់នៅតាមផ្ទះនាំឲ្យមានការលួតលាស់ ឬលទ្ធផលសុខភាពទាបសម្រាប់កុមារ ហើយធ្វើឲ្យពួកគេប្រឈមនឹងការកេងប្រវ័ញ្ច នៅពេលអនាគត។ គ្មានកម្មវិធីការពារកុមារ ដែលដំណើរការ ឬទ្រទ្រង់ដោយរដ្ឋ សម្រាប់ផ្ដល់ជម្រើសមានសុវត្ថិភាពចំពោះកុមារទេ។

ការចាប់ជម្រិតកុមារឆ្លងដែន៖ ប្រទេសកម្ពុជា មិនមែនជាហត្ថលេខីនៃអនុសញ្ញាក្រុងឡាអេ ឆ្នាំ ១៩៨០ ស្ដីពីទិដ្ឋភាពស៊ីវិលនៃការចាប់ជម្រិតកុមារឆ្លងដែនឡើយ។ សូមមើលរបាយការណ៍ប្រចាំឆ្នាំ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកស្ដីពីការចាប់កុមារឆ្លងដែន តាមរយៈ travel.state.gov/content/travel/en/International-Parent-Child-Abduction/for-providers/legal-reports-and-data.html ។

ការប្រឆាំងនឹងសាសនាជ្វីស(Anti-Semitism)
មានសហគមន៍អណិកជនកាន់សាសនាជ្វីសតូចមួយ នៅក្នុងរាជធានីភ្នំពេញ ហើយមិនមានរបាយការណ៍អំពីទង្វើប្រឆាំងនឹងសាសនានេះឡើយ។

## ការជួញដូរមនុស្ស

សូមចូលមើល *របាយការណ៍ស្ដីពីការជួញដូរមនុស្ស* របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅគេហទំព័រ www.state.gov/j/tip/rls/tiprpt/។

# ជនពិការ

ច្បាប់ហាមប្រាមការរើសអើង ការព្រងើយកន្តើយ ការកេងប្រវ័ញ្ច ឬការបោះបង់ជនពិការ ទាំងពិការរាងកាយ  ទាំងពិការផ្នែកសតិបញ្ញា។ ច្បាប់នេះ មិននិយាយពីការបង្កលក្ខណៈងាយស្រួលដល់ជនពិការ ក្នុងការធ្វើដំណើរទេ។  ក្រសួងសង្គមកិច្ច ជាអ្នកទទួលខុសត្រូវរួមក្នុងការការពារសិទ្ធិរបស់ជនពិការ ថ្វីបើច្បាប់កំណត់ដាក់ភារកិច្ចដោយឡែកជាក់លាក់ ចំពោះក្រសួងដទៃទៀត ដែលរួមមានក្រសួងសុខាភិបាល អប់រំ សាធារណការនិងដឹកជញ្ជូន និងក្រសួងការពារជាតិ។ រដ្ឋាភិបាល ស្នើដល់គ្រប់ស្ថានីយ៍ទូរទស្សន៍ទាំងអស់ មានកម្មវិធីបកប្រែជាភាសាសញ្ញា អមកម្មវិធីផ្សាយរបស់គេ។ មកដល់ត្រឹមខែមិថុនា មានស្ថានីយ៍ទូរទស្សន៍ធំៗពីរ ដែលមួយជាទូរទស្សន៍រដ្ឋ និងមួយទៀតជាទូរទស្សន៍ឯកជន មានការបកប្រែភាសាជាភាសាសញ្ញា នៅក្នុងកម្មវិធីផ្សាយព័ត៌មានរបស់គេ។

ជនពិការ ជួបប្រទះការរើសអើងជាច្រើនពីសង្គម ជាពិសេសក្នុងការទទួលការងារជំនាញ។

កុមារដែលមានភាពពិការខ្លះៗ បានចូលរៀននៅសាលាធម្មតា។ បើយោងតាមក្រសួងអប់រំ កុមារពិការចំនួន ១៩ ០០០ នាក់ បានរៀននៅសាលាបឋមសិក្សា ក្នុងឆ្នាំសិក្សា ២០១៥ -២០១៦។ ក្រសួងបានធ្វើការលើការបណ្តុះបណ្តាលគ្រូស្តីពីវិធីបញ្ចូលសិស្សពិការ ឲ្យរៀនជាមួយសិស្សមិនពិការ។

កុមារដែលពិការខ្លាំង បានរៀននៅសាលាដោយឡែក ដែលឧបត្ថម្ភដោយអង្គការ NGO នៅភ្នំពេញ។ ការសិក្សា សម្រាប់ពួកគេគ្មាននៅក្រៅភ្នំពេញទេ។

ពុំមានការកម្រិតតាមច្បាប់ណាមួយ ចំពោះសិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមក្នុងកិច្ចការនានារបស់ពលរដ្ឋឡើយ ប៉ុន្តែរដ្ឋាភិបាល មិនបានចូលរួមខិតខំប្រឹងប្រែង ដើម្បីជួយដល់ជនពិការ ឲ្យចូលរួមកាន់តែច្រើនក្នុងនាមជាពលរដ្ឋឡើយ។

សញ្ជាតិ/ពូជសាសន៍/ជាតិពន្ធុភាគតិច

អ្នកជំនាញបានទទួលស្គាល់ថា មានប្រតិកម្មមិនល្អទៅលើតួនាទីសេដ្ឋកិច្ច កាន់តែច្រើនឡើងរបស់ជនជាតិចិន និងចំនួនកាន់តែច្រើនឡើងនៃជនជាតិចិន នៅក្នុងប្រទេស។ កាសែតជាភាសាខ្មែរមានចុះច្រើន

ផ្នែកទី៧៖សិទ្ធិកម្មករ

ក. សិទ្ធិបង្កើតអង្គការ/សមាគម និងសិទ្ធិចរចាអនុសញ្ញារួម

ច្បាប់អនុញ្ញាតអ្នកធ្វើការផ្នែកឯកជន បង្កើតនិងចូលរួមសហជីព តាមការជ្រើសរើសរបស់ខ្លួនគេផ្ទាល់ សិទ្ធិក្នុងការធ្វើកូដកម្ម និងសិទ្ធិក្នុងការចរចាអនុសញ្ញារួម។ ច្បាប់ដាក់កំហិតព្រំដែនលើសិទ្ធិក្នុងការធ្វើកូដកម្ម សម្រួលអន្តរាគមន៍របស់រដ្ឋាភិបាល នៅក្នុងកិច្ចការផ្ទៃក្នុងរបស់សហជីព ផាត់មិនឲ្យកម្មករប្រភេទខ្លះ ចូលរួមក្នុងសហជីព ហើយអនុញ្ញាតឲ្យភាគីទី៣ ស្វែងរកការរំលាយសហជីព ដោយទន្ទឹមនឹងនោះ ធ្វើការដាក់ពិន័យតិចតួចលើថៅកែ ចំពោះការប្រព្រឹត្តមិនត្រឹមត្រូវជាមួយកម្មករ។

ច្បាប់ដ៏ស្មុគស្មាញស្តីពីការចុះបញ្ជីសហជីព មានន័យថា ការទាមទារឲ្យមានការអនុញ្ញាតជាមុន ចំពោះការបង្កើតសហជីព។ លក្ខខណ្ឌទាមទារ ក្នុងការចុះបញ្ជីសហជីព រួមមានការដាក់បញ្ចូលធម្មនុញ្ញ ការស្រង់ឈ្មោះមន្ត្រី និងសមាជិកគ្រួសាររបស់គេ ហើយផ្តល់សេចក្តីលម្អិតទាក់ទងនឹងធនាគារ ទៅក្រសួងការងារ។ ច្បាប់ហាមមិនឲ្យសហជីពដែលមិនបានចុះបញ្ជីការដំណើរការទេ។ ច្បាប់ក៏បញ្ជាក់ផងដែរថា មានតែសហជីពដែលមាន “ឋានៈតំណាងកម្មករភាគច្រើន” គឺសហជីពធំជាងគេនៅកន្លែងធ្វើការមួយ ទើបអាចធ្វើជាតំណាងកម្មករបាន នៅក្នុងការចរចាអនុសញ្ញារួម។ មន្ត្រីរាជការ គ្រូបង្រៀន អ្នកធ្វើការនៅតាមសហគ្រាសរដ្ឋ និងអ្នកធ្វើការផ្នែកធនាគារ ផ្នែកថែទាំសុខភាព និងវិស័យក្រៅផ្លូវការ អាចបង្កើតបានតែ “សមាគម” ទេ មិនអាចបង្កើតសហជីពបានទេ។ ការនេះ ធ្វើឲ្យគេអាចការពារកម្មករ បានតិចជាងសហជីព។ ច្បាប់ថែមទាំងហាមប្រាមកម្មករ ដែលត្រូវបានតុលាការដាក់ទោស មិនធ្វើជាអ្នកដឹកនាំសហជីពឬផ្នែករដ្ឋបាលសហជីពទេ ហើយរឹតត្បិតកម្មករមិនចេះអក្សរ និងអ្នកស្ថិតនៅក្រោមអាយុ ១៨ ឆ្នាំមិនឲ្យកាន់តំណែងដឹកនាំក្នុងសហជីព។

តាមសេចក្តីរាយការណ៍មកថា និយោជកខ្លះ មិនព្រមចុះហត្ថលេខា ទទួលស្គាល់សហជីពជាផ្លូវការទេ ដោយគ្មាននរណាធ្វើអ្វីពួកគាត់ ឬមិនព្រមបន្តកុងត្រារយៈពេលខ្លី ដល់កម្មករដែលបានចូលរួមនៅក្នុងសហជីព (ប្រហែល ៨០% នៃកម្មករនៅក្នុងវិស័យកម្មន្តសាលផ្លូវការ ធ្វើការតាមកុងត្រារយៈពេលខ្លី)។ និយោជក និងមន្ត្រីអាជ្ញាធរមូលដ្ឋាន ជាញឹកញាប់ មិនព្រមផ្តល់ឯកសារចាំបាច់សំរាប់ចុះបញ្ជីការសហជីពទេ។ សកម្មជនការងារបាននិយាយថា ធនាគារជាច្រើនមិនបើកគណនីឲ្យសហជីពដែលមិនទាន់ចុះបញ្ជីទេ ថ្វីបើតាមច្បាប់ សហជីពមិនអាចចុះបញ្ជីបានទេរហូតទាល់តែគេបានផ្តល់ព័ត៌មានលម្អិតស្តីពីធនាគារសិន។ អាជ្ញាធរការងារថ្នាក់ខេត្ត

តាមសេចក្តីរាយការណ៍មក បានទុកចោលដោយគ្មានកំណត់ថ្ងៃ នូវពាក្យសុំចុះបញ្ជីការ ដោយសួររកឯកសារបន្ថែម ឬអោយដាក់ពាក្យមកសារជាថ្មី ដោយសារមានកំហុសបន្តិចបន្តួច នៅក្នុងរយៈពេលដាក់ពាក្យម្តងៗ ដែលកំណត់ត្រូវមានរយៈពេល ៣០ ថ្ងៃ។ តែមានភស្តុតាងបង្ហាញថា ការធ្វើដូច្នេះមានការថយចុះ នៅត្រឹមពាក់កណ្តាលឆ្នាំ ពិសេសសម្រាប់សហជីពក្នុងវិស័យកាត់ដេរ សម្លៀកបំពាក់និងស្បែកជើង។

កម្មករបាននិយាយពីឧបសគ្គនានា នៅក្នុងការអនុវត្តសិទ្ធិរបស់គេ ក្នុងការចូលរួមក្នុងសមាគមដោយសេរី។ មានសេចក្តីរាយការណ៍ពីការរំខានរបស់រដ្ឋាភិបាល ទៅលើមេដឹកនាំកម្មករឯករាជ្យ ដោយរួមទាំងការចោទប្រកាន់តាមផ្លូវច្បាប់មិនសមរម្យ។ មេដឹកនាំកម្មករលេចធ្លោមួយចំនួន ដែលមានទំនាក់ទំនងជាមួយគណបក្សប្រឆាំង ឬសហជីពឯករាជ្យបានរងការចោទប្រកាន់ ឬស្ថិតនៅក្រោមការតាមមើលរបស់តុលាការ។ នៅថ្ងៃទី ២៨ ឧសភា សាលាឧទ្ធរណ៍បានលើកលែងការចោទប្រកាន់ លើមេដឹកនាំសហជីពល្បីៗចំនួន ៦ រូប ដែលបានរងការចោទប្រកាន់ព្រហ្មទណ្ឌ ពីបទចូលរួមក្នុងការតវ៉ាសុំឡើងប្រាក់ខែដោយអហិង្សា នៅឆ្នាំ ២០១៤។ តែនៅខែកក្កដា តុលាការ បានចោទប្រកាន់ប្រធានទើបជាប់ឆ្នោតថ្មី នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ទាក់ទងនឹងការតវ៉ា នៅឆ្នាំ ២០១៦។

មានសេចក្តីរាយការណ៍ថា មានជាបន្តនូវទម្រង់ដទៃទៀតនៃការយាយី។ នៅក្នុងឆមាសទី ១ NGO និងសហជីពខ្លះ បានត្អូញត្អែពីរឿងនគរបាលតាមដានសកម្មភាពរបស់គេ ហើយគំរាមកំហែងអ្នកចូលរួម ដោយបញ្ជូននគរបាលស្លៀកពាក់ឯកសណ្ឋានទៅឈរនៅក្រៅការិយាល័យរបស់គេ ក្នុងពេលប្រជុំ (សូមមើលចំណុច ២.ខ)។

អង្គការពលកម្មអន្តរជាតិ (ILO) បានកត់សម្គាល់ពីការរើសអើងទៅលើសហជីពដោយនិយោជក តាមរយៈការជ្រៀតជ្រែក និងការបណ្តេញសមាជិកនៃសហជីពឯករាជ្យ ព្រមទាំងតាមរយៈការបង្កើតសហជីពដែលគាំទ្រដោយនិយោជក។ ទោះបីជាច្បាប់ផ្តល់ការការពារដល់មេដឹកនាំសហជីពក្តី តែមានរោងចក្រជាច្រើនបានបញ្ចប់ការងាររបស់មន្ត្រីសហជីព ប្រកបដោយជោគជ័យ មុនពេលសហជីពអាចទទួលបានការចុះបញ្ជីជាផ្លូវការ។

ច្បាប់មានចែងថាកម្មករអាចធ្វើកូដកម្មបាន តែបន្ទាប់ពីបំពេញបានតាមលក្ខខណ្ឌទាមទារមួយចំនួនតែប៉ុណ្ណោះ ដូចជាការចុះបញ្ជីបានត្រឹមត្រូវនៃសហជីព ដូចការដែលវិធីសាស្ត្រដោះស្រាយវិវាទដទៃទៀត មិនបានទទួលជោគជ័យ (ដូចជាការចរចារ ការផ្សះផ្សា ឬការដោះស្រាយដោយអាជ្ញាកណ្តាលជាដើម) ការបញ្ចប់រយៈពេលរង់ចាំ ៦០ ថ្ងៃ បន្ទាប់ពី

មានលេចឡើងនូវជម្លោះការបោះឆ្នោតដោយសម្ងាត់ របស់សមាជិកសហជីព និងការជូនដំណឹងជាមុន រយៈពេលប្រាំពីរថ្ងៃ ទៅកាន់និយោជក និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(MOLVT) ។អ្នកធ្វើកូដកម្មត្រូវមានទោសព្រហ្មទណ្ឌ បើគេបិទផ្លូវ មាត់ច្រកចូល ឬប្រព្រឹត្តអ្វីផ្សេងទៀត ដែលអាជ្ញាធរមូលដ្ឋានចាត់ទុកថាប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ នៅពេលសហជីពបានបោះឆ្នោតសម្រេចចិត្តឲ្យធ្វើកូដកម្មហើយ ដែលទាមទារឲ្យមានការយល់ព្រមដោយសម្លេងភាគច្រើននៃសមាជិកសហជីព ដោយមាន៥០% នៃសមាជិកសហជីពបានគ្រប់កូរ៉ុំ តុលាការអាចចេញសេចក្តីសម្រេចប្រឆាំងនឹងការធ្វើកូដកម្ម ហើយតម្រូវឲ្យចាប់ផ្តើមឡើងវិញនូវការចរចាជាមួយនិយោជក។

មានរបាយការណ៍គួរអោយជឿទុកចិត្តថា កម្មករត្រូវបានបណ្តេញចេញពីការងារដោយសារហេតុផលមិនសមរម្យ បន្ទាប់ពីបានរៀបចំ ឬចូលរួមក្នុងកូដកម្ម។សហជីពផ្តើមកូដកម្មដោយមិនបានបំពេញបានតាមការទាមទារខាងលើនេះទេ ដែលជាការមួយមានភាពខុសច្បាប់ បើតាមបច្ចេកទេស។ នេះបើយោងតាមកម្មវិធីរោងចក្រល្អនៅកម្ពុជា (BFC)។ តែការចូលរួមនៅក្នុងកូដកម្មខុសច្បាប់ មិនអាចជាហេតុផលដែលអាចទទួលយកបានដោយស្របច្បាប់ សម្រាប់ការបណ្តេញកម្មករពីការងារឡើយ។ ក្នុងករណីមួយចំនួននិយោជកមិនបន្តកុងត្រារយៈពេលខ្លី ដល់សមាជិកសហជីពដែលសកម្មទេ ហើយក្នុងករណីខ្លះទៀត និយោជកបានគាបសង្កត់កូដករ ឬបុគ្គលិកសហជីពឲ្យទទួលយកសំណង ហើយលាលែងពីការងាររបស់ខ្លួន ។ចលនាសហជីពជាទូទៅ បានមើលឃើញថា រដ្ឋាភិបាលមិនបានដោះស្រាយអ្វីឲ្យមានប្រសិទ្ធភាពទេចំពោះការបណ្តេញចេញបែបនេះ។

គណៈកម្មាធិការដោះស្រាយបាតុកម្មកូដកម្ម របស់ក្រសួងការងារបាននិយាយថា នៅក្នុងឆមាសទី ១ មានកម្មករចំនួន ១៦ ៥៨៥ នាក់បានធ្វើបាតុកម្ម និងកូដកម្មចំនួន ២៦ ដង។ នៅក្នុងអំឡុងពេលដូចគ្នា ក្នុងឆ្នាំ ២០១៨ មានកូដកម្មចំនួន ២៨ ដែលមានការចូលរួមនៃកម្មករចំនួន ៤ ៦១៧ នាក់។ របាយការណ៍នោះនិយាយថាក្នុងចំណោមករណីទាំង ២៦ មាន ១៦ ករណីត្រូវបានដោះស្រាយបានដោយជោគជ័យ ហើយ ១០ករណីទៀតត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅក្នុងឆ្នាំនេះ រដ្ឋាភិបាលបានរឹតត្បិតលើសិទ្ធិកម្មករ ក្នុងការធ្វើការប្រមូលផ្តុំគ្នា។ នៅថ្ងៃទី ២ មករា នគរបាលបានរុះរើការរបស់តាំងជាសាធារណៈ របស់ក្រុមសមាគម និងសហជីព ដែលធ្វើការរំលឹកការបង្ក្រាបដោយហិង្សារបស់រដ្ឋាភិបាល ទៅលើកូដកម្ម ឆ្នាំ ២០១៤។ អាជ្ញាធរក្រុងភ្នំពេញ ពីដំបូង បានបដិសេធសំណើរបស់សហជីព និងសមាគម

ចំនួន ១២ ដើម្បីធ្វើការអបអរទិវាសិទ្ធនារី ៨ មិនា នៅពហុកីឡាដ្ឋានជាតិ តែក្រោយមក រដ្ឋាភិបាលបានអនុញ្ញាតឲ្យក្រុមទាំងនេះធ្វើនៅពហុកីឡដ្ឋានជាតិ តែបានដាក់ពង្រាយនគរបាលប្រឆាំងកូដកម្មយ៉ាងច្រើន ដើម្បីការពារកុំឲ្យពួកគេចេញពីកន្លែងនោះ។

ដំណោះស្រាយវិវាទជាមួយកម្មករមានភាពមិនស៊ីចង្វាក់គ្នា មួយភាគធំដោយសារមន្ត្រីរដ្ឋាភិបាលចាត់ទុកជម្លោះ ថា ជាវិវាទ "បុគ្គល" ជាជាងវិវាទ "សមូហភាព"។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដោះស្រាយតែវិវាទសមូហភាពទេ។ សហជីពបាននិយាយថា មានភាពជឿនលឿនក្នុងលទ្ធភាពរបស់ "សហជីពមានតំណាងភាគតិច" ក្នុងការធ្វើតំណាងកម្មករ នៅក្នុងវិវាទសមូហភាព។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលឯករាជ្យ បានកត់សម្គាល់ឃើញថា ខ្លួនបានទទួលករណីចំនួន ៦៨ នៅក្នុងរយៈពេល ៧ ខែដំបូង ហើយចំនួននេះកើនពីចំនួន ២៨ នៅក្នុងរយៈពេលដូចគ្នា កាលពីឆ្នាំកន្លងទៅ ។ ការនេះ បង្ហាញពីលទ្ធភាពរបស់សហជីពតំណាងភាគតិច ក្នុងការធ្វើជាតំណាងឲ្យកម្មករ នៅក្នុងវិវាទ។

គ្មានតុលាការឯកទេសក្នុងការដោះស្រាយវិវាទការងារទេ។ វិវាទការងារដែលត្រូវបានគេកំណត់ថា ជាវិវាទ "បុគ្គល" អាចយកទៅអោយតុលាការដោះស្រាយ ថ្វីបើប្រព័ន្ធតុលាការមានភាពលំអៀង និងគ្មានតម្លាភាពក្ដី។ ច្បាប់តម្រូវឲ្យមានការធ្វើសេចក្ដីរាយការណ៍លម្អិតច្រើន និងដាក់ការរឹតត្បិតច្រើនលើសហជីពកម្មករ។ តំណាងសហជីពបារម្ភថា គេមិនអាចបំពេញបានតាមការទាមទារជាច្រើនក្នុងច្បាប់។

ខ. ការហាមការងារដោយបង្ខំ ឬដោយការតម្រូវ

ច្បាប់ហាមប្រាមគ្រប់ទម្រង់ទាំងអស់ នៃការងារដោយបង្ខំ ឬដោយការតម្រូវ។

រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះ ឲ្យមានប្រសិទ្ធភាពទេ។ មន្ត្រីនានាបាននិយាយពីការលំបាកនៅក្នុងការបញ្ជាក់ពីស្ថានភាពការងារ និងប្រាក់ខែ នៅក្នុងវិស័យក្រៅផ្លូវការក្នុងផ្នែកនេសាទ កសិកម្ម សំណង់ និងការងារបម្រើតាមផ្ទះ។ ពិន័យដែលកំណត់ដោយច្បាប់ ចំពោះការបង្ខំឲ្យធ្វើពលកម្មគឺមានភាពតឹងតែង ដោយរួមមានទាំងការដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ តែវាមិនគ្រប់គ្រាន់ធ្វើឲ្យគេរាងចាលទេ។
ថ្វីបើរដ្ឋាភិបាលប្រឹងប្រែងក្នុងការទាញការចាប់អារម្មណ៍ទៅលើការងារដោយបង្ខំនៅក្នុងប្រទេសក្ដី តែប្រសិទ្ធភាពនៃការខិតខំទាំងនេះនៅមិនច្បាស់។ លើសពីនេះទៀត មានភស្ដុតាងខ្លះដែលបង្ហាញថា និយោជក ពិសេសម្ចាស់ឡឥដ្ឋរំលោភលើច្បាប់ហាមប្រាមលើពលកម្មដោយបង្ខំឬទាសភាពបំណុលពលកម្ម ។ អាជ្ញាធរមូលដ្ឋានខ្លះធ្វើមិនដឹងមិនឮ

ចំពោះការរំលោភទាំងនេះ។ ភាគច្រើននៃកម្មករឡូត៍ឥដ្ឋ មិនអាចទទួលបានការថែទាំសុខភាពដោយឥតគិតថ្លៃក្រោមមូលនិធិសន្តិសុខជាតិសង្គមទេ ពីព្រោះកន្លែងទាំងនោះមិនបានចុះបញ្ជីជាសមាជិកនៃមូលនិធិនេះទេ។

បំណុលដែលជំពាក់ភាគីទី ៣ នៅតែជាបញ្ហាសំខាន់មួយ នៅក្នុងការជំរុញឲ្យមានពលកម្មដោយបង្ខំ។ បើយោងតាមរបាយការណ៍ខែសីហា របស់អង្គការលីកាដូ ប្រជាជនកម្ពុជាចំនួន ២ លាននាក់ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ ហើយក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ បំណុលមានការកើនឡើងយ៉ាងច្រើន ដែលជាការនាំឲ្យមានច្រើននៃពលកម្មកុមារ និងពលកម្មបំណុល។ យោងតាមការសិក្សាអង្កេតនៅឆ្នាំ ២០១៧ មាន៤៨% នៃកម្មករសំណង់ចំនួន ១០១០ នៅភ្នំពេញ ជំពាក់បំណុលគេក្នុងនោះ ៧៥% នៃពួកគេជំពាក់សហគ្រាសមីក្រូហិរញ្ញវត្ថុ ឬធនាគារហើយមាន ២៥% ជំពាក់លុយសមាជិកគ្រួសារ។

ដោយសារក្រុមហ៊ុនសំណង់ និងឡូឥដ្ឋភាគច្រើន មានលក្ខណៈក្រៅប្រព័ន្ធ ហើយគ្មានការចុះបញ្ជី កម្មករនៅក្នុងវិស័យទាំងនេះមិនសូវទទួលបានអត្ថប្រយោជន៍ច្រើនទេ។ សម្រាប់ពួកគេ គ្មានការកំណត់ប្រាក់បៀវត្សរ៍អប្បបរមាទេ  ខ្វះការធានារ៉ាប់រង ហើយធ្វើការនៅចុងសប្តាហ៍ និងថ្ងៃបុណ្យ ដោយមានថ្ងៃឈប់សម្រាកតិច។

ការបង្ខំឲ្យធ្វើការ ដែលតាមធម្មតា ទាក់ទងនឹងការងារលើសម៉ោង នៅតែជាបញ្ហានៅតាមរោងចក្រ ដែលផលិតរបស់សម្រាប់នាំចេញ។ សហជីព និងកម្មករបាននិយាយថា អ្នកគ្រប់គ្រងខ្លះបញ្ឈប់កម្មករពីការងារ បើសិនជាគេមិនព្រមធ្វើការលើសម៉ោង។

កុមារក៏ប្រឈមនឹងការបង្ខំឲ្យធ្វើពលកម្មដែរ (សូមមើលផ្នែក ៧.គ)។

សូមមើលផងដែរនូវរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ដែលមានចំណងជើងថា *របាយការណ៍ស្តីពីការជួញដូរមនុស្ស* ដែលមានអាស័យដ្ឋាន www.state.gov/trafficking-in-persons-report/

គ. ការហាមឃាត់ពលកម្មកុមារ និងអាយុអប្បបរមាដែលអាចធ្វើការបាន

ច្បាប់បានកំណត់ថា អាយុ ១៥ ឆ្នាំគឺជាអាយុអប្បបរមាសម្រាប់បំពេញការងារ និងអាយុ ១៨ ឆ្នាំជាអាយុអប្បបរមា សម្រាប់បំពេញការងារដែលមានគ្រោះថ្នាក់។ ច្បាប់អនុញ្ញាតឲ្យកុមារអាយុចន្លោះពី ១២ ទៅ ១៥ ឆ្នាំធ្វើ “ការងារស្រាល” ដែលមិនមានគ្រោះថ្នាក់ដល់សុខភាព និងមិនប៉ះពាល់ដល់ការសិក្សារបស់គេ។ បទបញ្ញាសម្រាប់

អនុវត្តមាននិយាយច្រើនពីសកម្មភាព ដែលត្រូវបានចាត់ទុកថាជា "ការងារធ្ងន់"។ សកម្មភាពទាំងនេះរួមមានកសិកម្ម ការធ្វើឥដ្ឋ នេសាទ ថ្នាំជក់ និងផលិតកម្មដំឡូង។ ច្បាប់កំណត់ព្រំដែនកុមារដែលស្ថិតក្នុងអាយុពី ១២ ដល់ ១៥ ឆ្នាំ ធ្វើការយ៉ាងច្រើនត្រឹម ៤ ម៉ោងនៅថ្ងៃរៀន និង យ៉ាងច្រើនត្រឹម ៧ ម៉ោងនៅថ្ងៃអត់រៀន ហើយហាមប្រាមការធ្វើការពីម៉ោង ៨ យប់ដល់ម៉ោង ៦ ព្រឹក។

នៅខែឧសភា ឆ្នាំ ២០១៨ ក្រសួងការងារ បានចេញបទបញ្ជាមួយដែលកំណត់ច្បាស់ពីពាក្យថា ការងារតាមផ្ទះ ហើយបានកំណត់អាយុអប្បបរមាសម្រាប់ការងារតាមផ្ទះ គឺ ១៨ ឆ្នាំ។ តែបទបញ្ជានេះមិនបានកំណត់ពីសិទ្ធិអ្នកធ្វើការតាមផ្ទះឲ្យបងប្អូនទេ។ ថ្វីបើបទបញ្ជានេះ ផ្តល់ការការពារទាក់ទងនឹងអាយុអប្បបរមាសម្រាប់អ្នកធ្វើការតាមផ្ទះក្តី តែក្រមពលកម្ម មិនអនុវត្តសម្រាប់កុមារនៅក្រៅការងារក្នុងប្រព័ន្ធឡើយ ដូច្នេះកុមារដែលចូលរួមក្នុងទម្រង់ដទៃទៀតនៃការងារក្រៅប្រព័ន្ធ មិនត្រូវបានការពារនៅក្រោមច្បាប់ស្តីពីអាយុអប្បបរមាឡើយ។

ច្បាប់ការងារចែងពីការពិន័យជាប្រាក់ចំនួនរហូតដល់ ៦០ ដងនៃប្រាក់ឈ្នួលប្រចាំថ្ងៃបច្ចុប្បន្ន ចំពោះជនដែលរំលោភលើបញ្ញត្តិរបស់ជាតិស្តីពីពលកម្មកុមារ តែវាមិនគ្រប់គ្រាន់ធ្វើឲ្យគេខ្លាចនឹងប្រព្រឹត្តល្មើស ហើយការពិន័យនេះកម្រត្រូវបានដាក់ណាស់។

នាយកដ្ឋានពលកម្មកុមារ ដែលស្ថិតនៅក្រោមក្រសួងការងារ មានអធិការមិនគ្រប់គ្រាន់ក្នុងការចាប់បង្ខំឲ្យគេអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ។ អធិការកិច្ចលើពលកម្មកុមារផ្តុំនៅទីក្រុងភ្នំពេញ និងនៅតាមរោងចក្រក្នុងវិស័យផ្លូវការនៅតាមខេត្ត ដែលផលិតទំនិញសម្រាប់នាំចេញ ជាជាងតំបន់ជនបទ ដែលមានចំនួនកុមារធ្វើពលកម្មលើសលុប។ លើសពីនេះទៀត គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ បានិយាយថា អធិការការងារ មិនធ្វើអធិការកិច្ចនៅតាមកន្លែងបដិសណ្ឋារកិច្ច ឬកន្លែងក្លឹបរាត្រី នៅពេលយប់ទេ ពីព្រោះខ្វះថវិកាសម្រាប់ឲ្យអធិការធ្វើការលើសម៉ោង។ នៅឆ្នាំ ២០១៨ រដ្ឋាភិបាលបានធ្វើការពិន័យលើក្រុមហ៊ុនចំនួន ១០ ពីបទរំលោភលើបទដ្ឋានពលកម្មកុមារ ។ ចំនួននេះតិចជាងពលកម្មកុមារ ដែលមានជាទូទៅនៅក្នុងប្រទេសច្រើន។

ការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ ធ្វើឲ្យអាជ្ញាធរមូលដ្ឋាន ខ្វះសមត្ថភាពនៅក្នុងការពង្រឹងការអនុវត្តបទបញ្ញាទាំងនេះ ពិសេសនៅតាមតំបន់ជនបទ និងនៅក្នុងវិស័យដែលមានការប្រឈមខ្លាំង។

កុមាររងាយរងនឹងពលកម្មកុមារក្នុងទម្រង់អាក្រក់បំផុត ដូចជានៅក្នុងការងារកសិកម្ម កន្លែងធ្វើឥដ្ឋក្បឿង និងការជួញដូរផ្លូវភេទ (សូមមើលផ្នែក ៦ ស្តីពីកុមារ) ។ នៅថ្ងៃទី ៩ មិនា កុមារីអាយុ ៩ ឆ្នាំម្នាក់បានដាច់ដៃនៅក្នុងពុម្ពម៉ាស៊ីនធ្វើឥដ្ឋ នៅស្រុកខ្សាច់កណ្តាល ក្នុងខេត្តកណ្តាល។ គ្មានការប្តឹងព្រហ្មទណ្ឌប្រឆាំងនឹងម្ចាស់ឡឥដ្ឋនោះទេ។ ការមិនសូវទទួលបានការសិក្សាជាមូលដ្ឋាន និងការគ្មានកំណត់ថាចាំបាច់ត្រូវឲ្យរៀនដល់ត្រឹមណានោះ រួមចំណែកធ្វើឲ្យកុមាររងាយរងការកេងប្រវ័ញ្ច។ កុមារមកពីគ្រួសារក្រីក្រងាយរងគ្រោះ ដោយសារគ្រួសារអ្នកមានខ្លះតាមសេចក្តីរាយការណ៍មកថា ធ្វើជាចិត្តល្អហើយជួលកុមារឲ្យបំរើការងារក្នុងផ្ទះ តែបែរជារំលោភធ្វើបាបនិងកេងប្រវ័ញ្ចទៅវិញ។ កុមារក៏រងផងដែរនូវការបង្ខំអោយដើរសុំទាន។

ពលកម្មកុមារនៅតាមរោងចក្រសម្លៀកបំពាក់ សម្រាប់ការនាំចេញមានការថយចុះច្រើននៅក្នុងពេលប៉ុន្មានឆ្នាំនេះ។ អ្នកវិភាគខ្លះគិតថា ការនេះបណ្តាលមកពីការគោរពសង្កត់នៃកម្មវិធីតំរូវឲ្យមានការកែលម្អចាំបាច់របស់កម្មវិធីរោងចក្រល្អនៅកម្ពុជា(BFC)។ តាំងពីឆ្នាំ ២០១៥ មក BFC បានរកឃើញកុមារធ្វើពលកម្មចំនួនមិនដល់ ២០ នាក់ទេ ក្នុងមួយឆ្នាំ ក្នុងចំណោមរោងចក្រប្រមាណ ៥៥០។ នៅក្នុងរបាយការណ៍សរុបចុងក្រោយរបស់ខ្លួន រយៈពេលពីថ្ងៃទី ១ ខែឧសភា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៨ BFC បានរកឃើញករណីចំនួន ១០ ដែលក្នុងនោះ កុមារអាយុក្រោម ១៥ ធ្វើការនៅតាមរោងចក្រ។ តែ BFC និងអង្គការផ្សេងទៀតបានសម្តែងកង្វល់ថា ពលកម្មកុមារនិងការរំលោភផ្សេងទៀតប្រហែលអាចមានច្រើននៅតាមរោងចក្រផលិតស្បែកជើង និងសម្ភារៈសម្រាប់ការធ្វើដំណើរសម្រាប់ការនាំចេញ ពីព្រោះផ្នែកទាំងនេះមិនស្ថិតនៅក្រោមអាណត្តិតាមដានមើលរបស់ BFC ទេ។

សូមចូលមើលផងដែរនូវលទ្ធផលរកឃើញស្តីពីទំរង់អាក្រក់បំផុតនៃពលកម្មកុមាររបស់ក្រសួងការងារសហរដ្ឋអាមេរិក តាមគេហទំព័រ http://www.dol.gov/agencies/ilab/resources/reports/child-labor/findings/។

**ឃ. ការរើសអើងទាក់ទងនឹងការងារ**

ច្បាប់ហាមការរើសអើងក្នុងការងារ ដោយសារពូជសាសន៍ ពណ៌សម្បុរ ភេទ ពិការភាព សាសនានា គំនិតនយោបាយ កំណើត ប្រភពដើមក្នុងសង្គម ឬសមាជិកភាពក្នុងសហជីពទេ។ ច្បាប់មិនហាមច្បាស់នូវការរើសអើងដោយផ្អែកលើចំណង់ផ្លូវភេទ អត្តសញ្ញាណជេនឌ័រ អាយុ ភាសា ឬជំងឺឆ្លងទេ។ រដ្ឋធម្មនុញ្ញចែងថា ពលរដ្ឋទាំងពីរភេទទទួលបានប្រាក់បៀវត្សស្មើគ្នា ចំពោះការងារស្មើគ្នា។

ជាទូទៅ រដ្ឋាភិបាលមិនពង្រឹងការគោរពចំពោះច្បាប់ទាំងនេះទេ។ តាមច្បាប់ ទណ្ឌកម្មចំពោះការរើសអើងក្នុងការងាររួមមានការពិន័យជាប្រាក់ សំណងប៉ះប៉ូវរដ្ឋប្បវេណី និងរដ្ឋបាល។ ទណ្ឌកម្មទាំងនេះមិនគ្រប់គ្រាន់សម្រាប់រារាំងការរើសអើងឡើយ។

បើយោងតាមរបាយការណ៍របស់ BFC កាលពីខែមិនា ឆ្នាំ ២០១៨ កម្មករចំនួន ៣៨% ដែលបានអង្កេតទៅលើមានអារម្មណ៍មិនល្អ "ជាញឹកញាប់" ឬ "នៅពេលខ្លះ"  ដោយសារអាកប្បកិរិយានៅក្នុងរោងចក្រ ហើយ ៤០% នៃកម្មករមិនជឿថា មានប្រព័ន្ធច្បាស់លាស់ និងត្រឹមត្រូវ សម្រាប់ឲ្យគេរាយការណ៍ពីការយាយីផ្លូវភេទ នៅក្នុងរោងចក្ររបស់គេទេ។

**ង.លក្ខខណ្ឌការងារដែលអាចទទួលយកបាន**

ក្រសួងការងារគឺជាអ្នកទទួលខុសត្រូវ ក្នុងការពង្រឹងការអនុវត្តច្បាប់ការងារ តែរដ្ឋាភិបាលមិនបានពង្រឹងការអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពទេ។ ការពិន័យកម្រត្រូវបានវាយតម្លៃណាស់ ហើយមានមិនគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាទេ។ រដ្ឋាភិបាលពង្រឹងការអនុវត្តលើបទដ្ឋាននានា ដោយអន្លើដោយសារខ្វះខាត ខ្វះបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវនិងបរិក្ខារចាំបាច់ ហើយនិងការមានអំពើពុករលួយ។ មន្ត្រីរបស់ក្រសួងការងារ បានសារភាពពីភាពអសមត្ថភាព នៅក្នុងការធ្វើអធិការកិច្ចពេញលេញលើម៉ោងការងារ ហើយពឹងទាំងស្រុងលើ BFC ឲ្យធ្វើការងារនេះ នៅតាមរោងចក្រដេរសម្លៀកបំពាក់នាំចេញ។

តែក្រសួងការងារ បានបើកការបណ្តុះបណ្តាល និងធ្វើការប្រឡងអធិការកិច្ចការងារចំនួនជាង ៦០០ នាក់ នៅក្នុងឆ្នាំនេះ ហើយបាននិយាយថា អធិការកិច្ចម្នាក់ៗត្រូវជាប់តេស្តទើបអាចធ្វើការបាន។

របួសនៅក្នុងការងារ និងបញ្ហាសុខភាពនៅតែកើតមានច្រើន។ នៅថ្ងៃទី ២៣ មិថុនា អាគារមួយរបស់ចិនបានរលំ នៅទីក្រុងព្រះសីហនុ បណ្តាលឲ្យស្លាប់កម្មករចំនួន ២៦ នាក់ ហើយ ២៦ នាក់ទៀតរបួស។ ជនរងគ្រោះទាំងនោះ

និងគ្រួសាររបស់គេមិនបានទទួលសំណងពេញលេញ ពីមូលនិធិជាតិសន្តិសុខសង្គមទេ ពីព្រោះក្រុមហ៊ុនសំណង់មិនបានចុះបញ្ជី។

គ្មានការធ្វើអធិការកិច្ចគ្រប់គ្រាន់នៅការដ្ឋានសំណង់ ដោយរដ្ឋាភិបាលទេ។ សុវត្ថិភាពការងារ និងច្បាប់ស្តីពីសុខភាពសម្រាប់ឧស្សាហកម្មសំណង់ ចែងពីការដាក់ពិន័យ ដែលគ្មានភាពធ្ងន់ធ្ងរគ្រប់គ្រាន់សម្រាប់រារាំងការរំលោភទេ។

ច្បាប់មិនបានកំណត់បៀវត្សអប្បបរមាសំរាប់វិស័យណាមួយទេ លើកលែងតែវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង។ វាមានច្រើនជាងការប៉ាន់ប្រមាណជាផ្លូវការ សម្រាប់កម្រិតចំណូលនៃអ្នកក្រ។

តាមច្បាប់ បទដ្ឋានសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ ត្រូវតែគ្រប់គ្រាន់សម្រាប់សុខុមាលភាពរបស់កម្មករ។ អធិការកិច្ចការងារ វាយតម្លៃប្រាក់ពិន័យ ដោយយោងទៅតាមរូបមន្តស្មុគស្មាញ ផ្អែកលើភាពធ្ងន់ធ្ងរ និងរយៈពេលនៃកំហុស ព្រមជាមួយនឹងចំនួនកម្មករដែលទទួលរង។ អធិការរបស់ក្រសួងការងារមានអំណាចវាយតម្លៃប្រាក់ពិន័យទាំងនេះ នៅនឹងកន្លែង ដោយមិនបាច់មានការសហការពីនគរបាលទេ តែគ្មានបទបញ្ញត្តិជាក់ច្បាស់ណាមួយសម្រាប់ការពារកម្មករ ដែលតវ៉ាពីស្ថានភាពប៉ះពាល់ដល់សុខភាព ឬគ្មានសុវត្ថិភាពទេ។ ចំនួនអធិការមានមិនគ្រប់សម្រាប់ធ្វើការពង្រឹងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាព។ នៅខែមិថុនា រដ្ឋាភិបាលបានបញ្ជាឲ្យមន្ត្រីថ្នាក់ខេត្ត ធ្វើអធិការកិច្ចនៅកន្លែងឡឥដ្ឋ ដើម្បីរកមើលក្រែងមានពលកម្មកុមារ ឬការធ្វើពលកម្មក្រោមការជួបបំណុល ហើយបានធ្វើយុទ្ធនាការមួយដើម្បីលុបបំបាត់ពលកម្មកុមារ នៅតាមកន្លែងឡឥដ្ឋ នៅដំណាច់ឆ្នាំ។

ការដួលសន្លប់ជាច្រើន នៅតែជាបញ្ហាមួយនៅឡើយ។ NSSF បាននិយាយថា កម្មករចំនួន ៤១៧ នាក់បានដួលសន្លប់នៅក្នុងរោងចក្រចំនួន ៥ នៅក្នុងរយៈពេល ៦ ខែដំបូង។ ចំនួននេះថយចុះពីចំនួន ១៣៥០ នាក់ ដែលបានដួលសន្លប់ នៅក្នុងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៨។ អ្នកសង្កេតការណ៍ បាននិយាយពីការធ្វើការលើសម៉ោងជ្រុល សុខភាពទ្រុឌទ្រោម ការដេកមិនគ្រប់ ខ្យល់ចេញចូលមិនល្អ កង្វះអាហារូបត្ថម្ភត្រឹមត្រូវរបស់កម្មករ ថ្នាំសម្លាប់សត្វចង្រៃ ត្រូវបានបាញ់នៅក្នុងវាលស្រែក្បែរខាង ហើយចំហាយជាតិពុលចេញមកពីសកម្មភាពផលិតកម្មក៏មានចំណែកធ្វើឲ្យកម្មករសន្លប់ច្រើនគ្នាផងដែរ។

ការគោរពតាមបទដ្ឋានសុវត្ថិភាពការងារ និងសុខភាពនៅតែជាបញ្ហាប្រឈមមួយ ដែលកាន់តែមានច្រើនឡើង នៅក្នុងវិស័យនាំចេញសំលៀកបំពាក់ ដោយសារនីតិវិធី និងគោលនយោបាយរបស់ក្រុមហ៊ុនមិនសមស្រប ហើយនិងការទទួលខុសត្រូវ និងតួនាទីគ្រប់គ្រងមិនត្រូវបានកំណត់ច្បាស់។

NSSF បាននិយាយថា នៅក្នុងឆមាសទី ១ មានកម្មករចំនួន ២៤ នាក់បានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ នៅក្នុងពេលធ្វើដំណើរទៅនិងមកពីកន្លែងការងារ។ នៅក្នុងអំឡុងពេលដូចគ្នា ក្នុងឆ្នាំ ២០១៨ មានតែ ៨ នាក់ទេ។ គ្រោះថ្នាក់ទាំងនោះបណ្តាលឲ្យមនុស្សរបួសចំនួន ៩២០ នាក់ ដោយក្នុងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៨ មានតែ ៦២ នាក់ទេ។ ការធ្វើដំណើរដោយគ្មានសុវត្ថិភាពរបស់កម្មករ គឺជាកង្វល់មួយធំ សម្រាប់អ្នកពាក់ព័ន្ធនៅក្នុងឧស្សាហកម្មកាត់ដេរ។ នៅថ្ងៃទី ៤ ខែមេសា កម្មករ ៤ នាក់បានដាច់ដៃ នៅក្នុងគ្រោះថ្នាក់ ពេលឡានរបស់គេបុកជាមួយឡានមួយទៀត។

កម្មករ និងអង្គការពលកម្មនានាមានកង្វល់ផងដែរថា ការប្រើកុងត្រារយៈពេលខ្លី ពិសេសនៅក្នុងវិស័យកាត់ដេរ ដែលច្រើនគ្មានកំណើននៃផលិតភាព អនុញ្ញាតឲ្យក្រុមហ៊ុន គេចផុតពីលក្ខខណ្ឌទាមទារខ្លះតាមច្បាប់ និងលើប្រាក់បៀវត្ស។ កុងត្រារយៈពេលខ្លី ថែមទាំងអនុញ្ញាតឲ្យថៅកែ មានសេរីភាពច្រើន ក្នុងការបញ្ចប់ការងាររបស់អ្នករៀបចំបង្កើតសហជីព និងនារីមានផ្ទៃពោះ ដោយគ្រាន់តែមិនបន្តកុងត្រាជូនពួកគេ។ ច្បាប់កំណត់រយៈពេលឲ្យអនុវត្តកុងត្រាបែបនេះច្រើនបំផុតត្រឹមតែ ២៤ ខែ តែសារាចរណ៍ថ្មីៗ អនុញ្ញាតឲ្យនិយោជក បន្តរយៈពេលនៃការអនុវត្តបែបនេះដល់ ៤ ឆ្នាំ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអង្គការ ILO បានជំទាស់នឹងការបកស្រាយច្បាប់នេះ ដោយកត់សម្គាល់ឃើញថា ក្រោយរយៈពេល ២៤ ខែ កម្មករត្រូវតែទទួលបាន “កុងត្រាដែលមានរយៈពេលមិនកំណត់ព្រំដែន” អចិន្ត្រៃយ៍ (សូមមើលផ្នែក ៧.ក)។

ច្បាប់មានចែងអំពីរយៈពេលធ្វើការប្រចាំសប្តាហ៍ តាមបទដ្ឋានស្របច្បាប់ចំនួន៤៨ម៉ោង មិនឲ្យលើសពី ៨ ម៉ោងក្នុងមួយថ្ងៃឡើយ។ ច្បាប់កំណត់អត្រា ១៣០ ភាគរយនៃប្រាក់ឈ្នួលធ្វើការនៅពេលថ្ងៃសម្រាប់វេនការងារ នៅពេលយប់ និង ១៥០ ភាគរយសម្រាប់ការងារបន្ថែមម៉ោងដែលត្រូវកើនឡើងដល់ ២០០ ភាគរយប្រសិនបើការងារលើសម៉ោងនោះកើតមានឡើងនៅពេលយប់ នៅថ្ងៃអាទិត្យ ឬនៅថ្ងៃឈប់សម្រាក។ និយោជិក ត្រូវបានអនុញ្ញាតឲ្យធ្វើការលើសម៉ោងយ៉ាងច្រើន ២ ម៉ោងក្នុងមួយថ្ងៃ។ ច្បាប់ហាមការធ្វើការលើសម៉ោងជ្រុល ចែងថា ការធ្វើការលើស

ម៉ោងទាំងអស់ត្រូវតែទៅតាមការស្ម័គ្រចិត្ត ហើយចែងពីការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល។ អ្នកធ្វើការនៅផ្នែកដឹកជញ្ជូនតាមទឹក និងអាកាសមិនទទួលបានប្រាក់ឧបត្ថម្ភសន្តិសុខសង្គម និងប្រាក់ចូលនិវត្តន៍ទេ ហើយត្រូវបានលើកលែងពីការកំណត់ព្រំដែនម៉ោងការងារ ដែលត្រូវបានចែងដោយច្បាប់។

កម្មករបានរាយការណ៍ថា មានការងារលើសម៉ោងច្រើនហួសកម្រិតហើយជួនកាល គេតម្រូវឲ្យធ្វើជាចាំបាច់ទៀតផង។ មានច្រើនគ្នាបានត្អូញត្អែរថា ថៅកែបង្ខំឲ្យគេធ្វើការ ១២ ម៉ោងក្នុងមួយថ្ងៃ ថ្វីបើច្បាប់កំណត់ត្រឹម ១០ ម៉ោងក្តី ដោយរួមទាំងម៉ោងលើសផង។ ជាញឹកញាប់ កម្មករប្រឈមនឹងការបណ្តេញចេញ ការពិន័យ ឬការបាត់បង់ប្រាក់បំណាច់ បើសិនជាគេមិនព្រមធ្វើការថែមម៉ោង៕

# ឧបសម្ព័ន្ធទី៩ ៖
# របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០១៩

**សំណៅកែសម្រួលមិនទាន់ផ្សព្វផ្សាយ**

ចែកចាយ៖ ទូទៅ
ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩
អត្ថបទដើម៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីសែសិបពីរ**
ថ្ងៃ៩-២៧ ខែកញ្ញា ឆ្នាំ២០១៩
របៀបវារៈ ចំណុចទី២ និងទី១០
**របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ**

**ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និង ការកសាងសមត្ថភាព**

# តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយឧបត្ថម្ភ ដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស

**របាយការណ៍របស់អគ្គលេខាធិការ***

*សេចក្តីសង្ខេប*

ដោយបានដាក់បញ្ជូនស្របតាមសេចក្តីសម្រេចចិត្តលេខ ៣៦/៣២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍នេះបរិយាយអំពីតួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩។

នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ បានកត់សម្គាល់ឃើញមានភាពតានតឹងផ្នែកនយោបាយបន្តមាននៅក្នុងបរិបទនៃការបោះឆ្នោតជាតិ ដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ រួមទាំងការរឹតត្បិតលើការអនុវត្តសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ទន្ទឹមនេះ ក៏ឃើញមានការវិវឌ្ឍន៍វិជ្ជមានផងដែរ រួមទាំងការអនុម័តក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា និងកំណើនសេដ្ឋកិច្ច រួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច។

ការិយាល័យ OHCHR បានបន្តអនុវត្តកម្មវិធីរបស់ខ្លួនផ្នែកសហប្រតិបត្តិការបច្ចេកទេសជាមួយដៃគូផ្សេងៗនៅកម្ពុជា ក្នុងវិស័យសំខាន់ៗជាច្រើន រួមមាន ការពង្រឹងនីតិរដ្ឋ និងការការពារសេរីភាពជាមូលដ្ឋាន សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងសិទ្ធិជនជាប់ឃុំ ។

* របាយការណ៍នេះ ត្រូវបានដាក់បញ្ជូនបន្ទាប់ពីថ្ងៃផុតកំណត់ ដើម្បីឆ្លុះបញ្ចាំងពីស្ថានការណ៍វិវត្តថ្មីៗបំផុត។

# I. សេចក្ដីផ្ដើម

១. របាយការណ៍នេះត្រូវបានដាក់បញ្ជូនស្របតាមសេចក្ដីសម្រេចចិត្តលេខ៣៦/៣២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ក្នុងរបាយការណ៍នេះ អគ្គលេខាធិការបានលើកឡើងអំពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩។ របាយការណ៍នេះ ធ្វើបច្ចុប្បន្នភាពលើរបាយការណ៍របស់អគ្គលេខាធិការលេខ (A/HRC/37/64) ដែលបានបង្ហាញជូនសម័យប្រជុំលើកទីសាមសិបប្រាំពីរ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលើប្រធានបទដូចគ្នានេះ។

២. ក្នុងអំឡុងពេលទាំងមូលនៃការធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានបន្តអនុវត្តសកម្មភាពផ្នែកបច្ចេកទេសជាមួយស្ថាប័នតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតំណាងរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត។ ការិយាល័យ OHCHR បានបន្តឃ្លាំមើលបរិយាកាសសិទ្ធិមនុស្ស រួមទាំង សិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន សិទ្ធិចូលរួម សេរីភាពជាមូលដ្ឋាន ការជំនុំជម្រះក្ដី និងកន្លែងឃុំឃាំងផ្សេងៗ។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ដោយវត្តមានរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នាយករដ្ឋមន្ត្រីកម្ពុជា និងឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស រដ្ឋាភិបាល និងការិយាល័យ OHCHR បានបន្តអនុស្សរណៈនៃការយោគយល់គ្នា សម្រាប់ការអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្សសម្រាប់ឆ្នាំ២០១៩-២០២០។

៣- ការិយាល័យ OHCHR បានបន្តធ្វើការយ៉ាងជិតស្និទ្ធផងដែរ ជាមួយប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា ដើម្បីគាំទ្រដល់ការបញ្ជ្រាបសិទ្ធិមនុស្សនៅក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ឆ្នាំ២០១៦-២០១៨ និងឆ្នាំ២០១៩-២០២៣ ដឹកនាំក្រុមវិស័យសិទ្ធិមនុស្ស និងគាំទ្រសកម្មភាពរួម រាប់ទាំង តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដើម្បីលើកកំពស់សិទ្ធិមនុស្សនៅកម្ពុជា។

# II. ការលើកកម្ពស់ការចូលរួម និងការការពារលំហពលរដ្ឋ

៤. ភាគច្រើនក្នុងឆ្នាំ២០១៨ អាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋាន បានអនុវត្តសេចក្ដីណែនាំចុះខែតុលា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃដែលតម្រូវឱ្យអង្គការសង្គមស៊ីវិលជូនដំណឹង ៣ ថ្ងៃ មុនការអនុវត្តផែនការសកម្មភាពរបស់ពួកគេ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨ ស្ថាប័នសភាបានអនុម័តវិសោធនកម្មច្បាប់នានា រួមមាន ច្បាប់រដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ ដោយរាប់បញ្ចូលទាំង បទបញ្ញត្តិទាក់ទងនឹងច្បាប់ស្ដីពីការប្រមាទព្រះមហាក្សត្រ។ អ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិមនុស្សនៅកម្ពុជា និងអ្នករាយការណ៍ពិសេសស្ដីពីការលើកម្ពស់ និងការពារសិទ្ធិសេរីភាពបញ្ចេញមតិ និងគំនិត បានលើកឡើងនៅក្នុងសេចក្ដីប្រកាសនៅ

ថ្ងៃទី២០ កុម្ភៈឆ្នាំ២០១៨ ថា “បទបញ្ញត្តិទាក់ទងនឹងច្បាប់ស្តីពីការប្រមាទព្រះមហាក្សត្រគឺមិនស្របទៅតាមកាតព្វកិច្ចរបស់កម្ពុជាស្ថិតនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយសារបទបញ្ញត្តិទាំងនោះ បានធ្វើឱ្យការអនុវត្តសេរីភាពបញ្ចេញមតិស្របច្បាប់ក្លាយជាបទឧក្រិដ្ឋ។[1]

៥. ថ្ងៃទី ៨ មេសា ឆ្នាំ២០១៨ លោក សម រង្ស៊ី ដែលជាអ្នកដឹកនាំមួយរូបនៃអតីតគណបក្សជំទាស់ដ៏ធំមួយ គឺគណបក្សសង្គ្រោះជាតិ ដែលបច្ចុប្បន្នលោកកំពុងនិរទេសខ្លួនឯងតាំងពីឆ្នាំ២០១៥ បានចែករំលែកវីដេអូនៅលើហ្វេសប៊ុក ដោយអំពាវនាវឱ្យប្រជាពលរដ្ឋកម្ពុជាធ្វើពហិកាការបោះឆ្នោតជាតិ។ ថ្ងៃទី៨ ខែឧសភា ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានសរសេរលិខិតទៅកាន់ក្រសួងមហាផ្ទៃស្នើសុំឱ្យចាត់វិធានការណ៍ផ្លូវច្បាប់ ដោយសំអាងហេតុផលថា ការអំពាវនាវឱ្យធ្វើពហិការការបោះឆ្នោតគឺប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ តាមរយៈការហាមឃាត់អ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យបោះឆ្នោតបាន។ អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សនៅកម្ពុជា បានលើកឡើងពីសេចក្តីពន្យល់របស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ២៥ (ឆ្នាំ១៩៩៦) ស្តីពីការចូលរួមក្នុងកិច្ចការសាធារណៈ និងសិទ្ធិក្នុងការបោះឆ្នោត ដោយបានកត់សម្គាល់ថា “ការរិតត្បឹតទៅលើការអំពាវនាវឱ្យពិហាការការបោះឆ្នោតដែលមិនមែនជាកាតព្វកិច្ចគឺមិនស្របតាមសិទ្ធិសេរីភាពបញ្ចេញមតិទេ ដោយសារតែការរិតត្បឹតនោះរារាំងដល់ការពិភាក្សាដេញដោលរឿងនយោបាយ” (A/HRC/39/73/Add.1, para. 57)។

៦. ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៨ ក្រុមការងារស្តីពីការឃុំខ្លួនដោយបំពាន បញ្ចេញមតិយោបល់ថា ការឃុំខ្លួនលោក កឹម សុខា ដែលជាអ្នកដឹកនាំអតីតគណបក្សសង្គ្រោះជាតិ ដែលត្រូវបានចាប់ខ្លួនពីបទចោទ “ក្បត់ជាតិ” ក្នុងខែកញ្ញា ឆ្នាំ២០១៧ គឺជាការឃុំខ្លួនដោយបំពាន (A/HRC/WGAD/2018/9)។

៧. ថ្ងៃទី ១០ ឧសភា ២០១៨ សាលាឧទ្ធរណ៍បានរក្សាតម្កល់ទុកនូវទោសពីបទ “ប៉ះបោរ” និងការកាត់ទោសពាក់ព័ន្ធផ្សេងៗទៀតដែលសម្រេចដោយតុលាការដំបូង ក្នុងឆ្នាំ២០១៥ ប្រឆាំងសមាជិក ១១ រូប របស់អតីតគណបក្សសង្គ្រោះជាតិ។ ក្នុងកំណត់បង្ហាញសន្និសីទសារព័ត៌មានសង្ខេប អ្នកនាំពាក្យរបស់ឧត្តមស្នងការបានបង្ហាញការខកចិត្តទៅលើសេចក្តីសម្រេចនោះ ដោយបង្ហាញកង្វល់ពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការយល់ឃើញពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលក្នុងអំឡុងពេលកាត់ក្តី។[2]

៨. ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន និងក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍ បានអនុម័តប្រកាសអន្តរក្រសួងស្តីពី “ការគ្រប់គ្រងទៅលើការបោះពុម្ពផ្សាយនៅលើវេបសាយ និងប្រព័ន្ធផ្សព្វផ្សាយសង្គមដែលដំណើរការដោយអ៊ីនធឺណិត”

[1] សូមមើល www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=22674&LangID=E

[2] សូមមើល https://cambodia.ohchr.org/sites/default/files/180511%20Briefing%20note%20on%20Cambodia_ENG.pdf

ដែលអនុញ្ញាតឱ្យមានការបិទវេបសាយ និងទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមនានា ដែលមានផ្ទុកមាតិការដែលគេចាត់ទុកថាបង្កឱ្យមានការញុះញ៉ង់ ចលាចល ឬការរើសអើង ឬប៉ះពាល់ដល់សន្តិសុខជាតិ រួមនឹងហេតុផលផ្សេងៗទៀត។ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានបង្ហាញក្តីកង្វល់ថា កថាខណ្ឌមួយចំនួននៃសេចក្តីប្រកាសនោះ មានភាពស្រពេចស្រពិល ហើយមានការគ្របដណ្តប់ជ្រុលហួសហេតុ ហើយបានលើកឡើងពីបញ្ហាថាតើ ហេតុផលមួយចំនួន ដូចជា បង្កចលាចល គឺស្ថិតនៅក្រៅលក្ខណ្ឌដែលត្រូវបានអនុញ្ញាតឱ្យមានការរឹតត្បិតសេរីភាពបញ្ចេញមតិ (A/HRC/39/73/Add.1, paras. 72–73)។

៩. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងអ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការពារសិទ្ធិសេរីភាពនៃគំនិត និងសម្តែងមតិ និងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពជួបជុំដោយសន្តិវិធី និងចងក្រងសមាគម បានបង្ហាញកង្វល់របស់ពួកគេអំពីសេរីភាពប្រព័ន្ធផ្សព្វផ្សាយមុននឹងការបោះឆ្នោតមកដល់ នៅក្នុងសេចក្តីថ្លែងការណ៍ ចេញផ្សាយថ្ងៃទី១៥ មិថុនា ២០១៨។ កង្វល់នេះទាក់ទងនឹងក្រមសីលធម៌របស់ប្រព័ន្ធផ្សព្វផ្សាយដែលចេញដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងខែឧសភា ដែលហាមឃាត់ការបោះពុម្ពផ្សាយពីទស្សនៈដែលនាំឱ្យមានការភាន់ច្រឡំ ឬនាំឱ្យបាត់បង់ទំនុកចិត្តក្នុងការបោះឆ្នោត។ អ្នករាយការណ៍ពិសេសបានថ្លែងថា "ការហាមឃាត់ទាំងនេះ ប្រើពាក្យពេចន៍ក្នុងន័យទូលាយ និងមិនច្បាស់លាស់ដែលអាចនាំឱ្យមានការរឹតត្បិតលក្ខណៈទូលំទូលាយលើប្រព័ន្ធផ្សព្វផ្សាយ ដែលអាចមិនស្របទៅនឹងបទដ្ឋានអន្តរជាតិ"។[3]

១០. ការបោះឆ្នោតបានប្រព្រឹត្តទៅនៅថ្ងៃ២៩ កក្កដា ២០១៨ ដោយគ្មានវត្តមានគណបក្សសង្គ្រោះជាតិ ដែលត្រូវបានរំលាយដោយតុលាការកំពូលកាលពីខែវិច្ឆិកា ឆ្នាំ២០១៧។ គណបក្សសង្គ្រោះជាតិបានទទួលសំឡេងឆ្នោតប្រមាណ ៤៤ ភាគរយ សម្រាប់ការបោះឆ្នោតក្នុងឆ្នាំ២០១៣ និង ក្នុងការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ២០១៧។ ថ្ងៃទី២៧ កក្កដា អ្នកនាំពាក្យរបស់អគ្គលេខាធិការ [អង្គការសហប្រជាជាតិ] បានរំលឹកឡើងវិញថា "ដំណើរការនយោបាយដែលមានបរិយាប័ន្ន និងពហុនិយមនៅតែមានសារៈសំខាន់សម្រាប់ការពារការរីកចម្រើននានា ដែលប្រទេសកម្ពុជាបានបង្កើងក្នុងការបង្រួបបង្រួមសន្តិភាព។ អគ្គលេខាធិការបានអំពាវនាវដល់ភាគីទាំងអស់ឱ្យកាត់បន្ថយភាពតានតឹង និងការបែកខ្ញែកគ្នាដោយសារនយោបាយ។ លោកបានអំពាវនាវដល់រដ្ឋាភិបាលប្រកាន់យកបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងជាពិសេសដើម្បីធ្វើឱ្យប្រាកដដល់ការធានាដល់តួអង្គសង្គមស៊ីវិល និងគណបក្សនយោបាយក្នុងការអនុវត្តសិទ្ធិទាក់ទងប្រជាធិបតេយ្យរបស់ពួកគេ។[4]

[3] សូមមើល www.ohchr.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=23205&LangID=E

[4] សូមមើល www.un.org/sg/en/content/sg/statement/2018-07-27/statement-attributable-spokesman-secretary-general-cambodia

១១. ថ្ងៃ១៥ សីហា គណៈកម្មាធិការជាតិបានប្រកាសលទ្ធផលបោះឆ្នោត៖ ចំនួនអ្នកបានបោះឆ្នោតផ្លូវការគឺជាង ៨៣,០២ ភាគរយ ហើយគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកំពុងកាន់អំណាចទទួលបានសំឡេង ៧៦,៨៥ ភាគរយ គឺទទួលបានអសនៈទាំង ១២៥ នៅក្នុងរដ្ឋសភា។ លទ្ធផលនេះគឺដូចនឹងការបោះឆ្នោតខែកុម្ភៈ ឆ្នាំ២០១៨ ដែលគណបក្សកាន់អំណាចនេះឈ្នះអសនៈទាំង ៥៨ នៅក្នុងព្រឹទ្ធសភា (សមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ និងសមាជិករដ្ឋសភា)។ គណបក្សប្រជាជនមានសមាជិកភាគច្រើននៅក្រុមប្រឹក្សាឃុំ/សង្កាត់ និងរដ្ឋសភាបន្ទាប់ពីមានការបែងចែកអសនៈរបស់គណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយនៅចុងឆ្នាំ ២០១៧ ទៅឱ្យមន្ត្រីដែលមិនបានជាប់ឆ្នោត។ សម្រាប់ការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌ កាលពីថ្ងៃ២៥ ឧសភា ឆ្នាំ២០១៩ គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងឆ្នោត ៩៦%។

១២. ថ្ងៃ១៧ សីហា ការិយាល័យ OHCHR បានចេញផ្សាយ កំណត់សន្និសីទសារពត៌មានសង្ខេប ដោយលើកឡើង (ក្នុងចំណោមរឿងផ្សេងៗទៀត) ថា៖

> "យើងមានការបារម្ភណ៍អំពីបរិយាកាសស្ថានភាពសិទ្ធិមនុស្សជុំវិញការបោះឆ្នោតដែលបានធ្វើឡើងថ្មីៗនេះនៅកម្ពុជា ដោយគ្មានវត្តមានគណបក្សជំទាស់ដ៏សំខាន់ដែលត្រូវបានរំលាយ គឺគណបក្សសង្គ្រោះជាតិ។ វាបានធ្វើឱ្យប្រជាពលរដ្ឋមួយភាគធំមិនមានតំណាងដែលពួកគេបានជ្រើសរើស ដែលវាបង្ករឱ្យមានកង្វល់អំពីសិទ្ធិចូលរួមកិច្ចការនយោបាយរបស់ពួកគេ។ មានសេចក្តីរាយការណ៍មកថា ប្រជាពលរដ្ឋត្រូវបានគេគម្រាមគំហែង ឬទិញឱ្យទៅបោះឆ្នោត ហើយសង្គមស៊ីវិលបានជួបប្រទះការធ្វើទុក្ខបុកម្នេញនៅពេលជិតបោះឆ្នោត។ គេហទំព័រចំនួន ១៧ ដែលគេចូលចិត្តចូលមើល ត្រូវបានបិទក្នុងអំឡុងពេលថ្ងៃបោះឆ្នោត។ វាថែមទាំងមានការការរឹតត្បឹតទៅលើសេរីភាពបញ្ចេញមតិរបស់អ្នកបោះឆ្នោត និងអ្នកនយោបាយជំទាស់ដែលបានអំពាវនាវឱ្យធ្វើពិហាការការបោះឆ្នោត ឬក៏បានប្រកាសពីបំណងរបស់ពួកគេមិនទៅបោះឆ្នោត ដោយរួមមាន ការគំរាមគំហែង ការផាកពិន័យ និងវិធានការផ្លូវច្បាប់"។[5]

អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានកត់សម្គាល់ថា ការរំលាយគណបក្សសង្គ្រោះជាតិ និងការហាមឃាត់សមាជិកជាន់ខ្ពស់ចំនួន ១១៨ រូប របស់គណបក្សនេះមិនឱ្យធ្វើសកម្មភាពនយោបាយរយៈពេលប្រាំឆ្នាំ គឺវាពិតជាបានបង្កើតឱ្យមានសំណួរអំពីភាពពិតប្រាកដនៃការបោះឆ្នោតនេះ (A/HRC/39/73/Add.1, para. 87)។

១៣. កាលពីខែកញ្ញា ឆ្នាំ ២០១៨ លោក គឹម សុខា ត្រូវបានដោះលែងពីពន្ធនាគារ ហើយត្រូវបានដាក់ក្នុងការឃុំខ្លួនក្នុងផ្ទះក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងរបស់តុលាការ។ ប៉ុន្មានសប្តាហ៍ក្រោយមក អ្នកវិភាគនយោបាយ គឺលោក គឹម សុខ ត្រូវបានដោះលែងនៅ

[5] សូមមើល https://cambodia.ohchr.org/sites/default/files/Briefing%20Note%20on%20election%20Eng.pdf

ពេលបានបម្រើទោសចប់រយៈពេល ១៨ ខែ ពីបទបរិហារកេរ្តិ៍ និងញុះញង់ សកម្មជនដីធ្លី គឺអ្នកស្រី ទេព វ៉ាន្នី ត្រូវបានលើកលែងទោស និងដោះលែងចេញពីពន្ធនាគារ អតីតអ្នកយកព័ត៌មានពីររូបរបស់វិទ្យុអាស៊ីសេរី ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ ហើយសមាជិកចំនួន ១៤ រូប របស់អតីតគណបក្សប្រឆាំង ដែលបានចាញ់បណ្តឹងឧទ្ធរណ៍របស់ពួកគេប្រឆាំងនឹងការផ្តន្ទាទោសពីបទកុបកម្មកាលពីខែឧសភា ឆ្នាំ ២០១៨ ក៏ត្រូវបានលើកលែងទោស និងដោះលែងពីពន្ធនាគារដែរ។ រយៈពេលជិតពីរឆ្នាំកន្លះក្រោយពីការចាប់ខ្លួនពួកគេមក នៅថ្ងៃទី ២៦ ខែកញ្ញា បុគ្គលិក ៥ រូប របស់សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគមអាដហុក) ក៏ត្រូវបានផ្តន្ទាទោសពីបទសូកប៉ាន់សាក្សី និងសមគំនិតសូកប៉ាន់សាក្សី ហើយទោសជាប់ពន្ធនាគារមួយចំនួនទៀតត្រូវបានព្យួរ។

១៤. កាលពីខែវិច្ឆិកា ឆ្នាំ ២០១៨ ក្រសួងមហាផ្ទៃ បានដកយកចេញនូវលក្ខខណ្ឌតម្រូវដែលបានលើកឡើងខាងលើចំពោះអង្គការសង្គមស៊ីវិល ដែលត្រូវជូនដំណឹង ៣ ថ្ងៃជាមុន មុនពេលធ្វើសកម្មភាព។ ក្រសួងក៏បានប្តេជ្ញាចិត្តក្នុងការរៀបចំវេទិកាពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ជារៀងរាល់ ៦ ខែ ម្តង ឬនៅពេលចាំបាច់ ហើយបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីដោះស្រាយកង្វល់របស់សង្គមស៊ីវិល រាប់បញ្ចូលទាំង ការទាក់ទងនឹងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ កាលពីខែធ្នូ ឆ្នាំ ២០១៨ សភាជាតិ បានធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដើម្បីអនុញ្ញាតឱ្យបុគ្គលទាំងឡាយដែលត្រូវបានហាមឃាត់មិនឱ្យធ្វើសកម្មភាពនយោបាយដោយសាលដីកាតុលាការកំពូល កាលពីឆ្នាំ ២០១៧ ដើម្បីស្វែងរកសិទ្ធិនយោបាយរបស់ពួកគេពីព្រះមហាក្សត្រ តាមរយៈនាយករដ្ឋមន្ត្រី។ ក្នុងខែដដែលនោះ ក្រសួងការបរទេស បានចេញសេចក្តីថ្លែងការលើកឡើងអំពីបញ្ហាផ្សេងៗ និងធ្វើការប្តេជ្ញាទាក់ទងនឹងភាពជាដៃគូរជាមួយអង្គការសង្គមស៊ីវិល និងការការពារដីធ្លី និងសិទ្ធិសហជីព សារព័ត៌មាន និងសេរីភាពសារព័ត៌មាន និងសិទ្ធិដីធ្លី។[6] នៅថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៩ ក្រសួងមហាផ្ទៃ បានរៀបចំវេទិកាមួយដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលជាច្រើន ដែលវេទិកានេះត្រូវបានរៀបចំឡើងបន្ទាប់ពីវេទិការលើកទី១ ដែលបានរៀបចំឡើងកាលពីខែមិថុនា ឆ្នាំ ២០១៨។

១៥. ការិយាល័យ OHCHR បន្តទទួលព័ត៌មានពីអង្គការសង្គមស៊ីវិលថា សកម្មភាពរបស់ពួកគេត្រូវបានតាមដានឃ្លាំមើលដោយយកទុកដាក់ពីសំណាក់នគរបាល ទោះបីជាមានដកចេញនូវលក្ខខណ្ឌតម្រូវឱ្យជូនដំណឹង ៣ ថ្ងៃមុន ក៏ដោយ។ បន្ថែមលើនេះទៀត បេសសកម្ម និងសិក្ខាសាលាទាំងឡាយរបស់ការិយាល័យ OHCHR ក៏ត្រូវបានតាមដានឃ្លាំមើលពីសំណាក់នគរបាលផងដែរ។ ការិយាល័យ OHCHR បានទទួលព័ត៌មានថា សមាជិកជាង ១៤៥ នាក់ របស់អតីតគណបក្សប្រឆាំង ត្រូវបានកោះហៅឱ្យចូលខ្លួនមកតុលាការ ឬត្រូវបានកំពុងឃុំខ្លួននៅក្នុងឆ្នាំ២០១៩ នេះ។ ការិយាល័យ OHCHR បានកំពុងធ្វើការតាមដានលើករណីទាំងនេះ ហើយ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១៩

[6] សូមមើលគេហទំព័រ www.mfaic.gov.kh/site/detail/23386.

បានបង្ហាញកង្វល់របស់ខ្លួននៅក្នុងសេចក្តីថ្លែងការណ៍មួយចំពោះការកោះហៅឱ្យចូលខ្លួន និងការឃុំខ្លួនទៅលើអតីតសមាជិករបស់គណបក្សសង្គ្រោះជាតិកម្ពុជា។[7]

១៦. ក្នុងរយៈពេលធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានបន្តផ្តល់យោបល់ផ្នែកច្បាប់អំឡុងពេលដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។ អត្ថបទសេចក្តីព្រាងច្បាប់ ត្រូវរៀបចំបញ្ចប់ជាផ្លូវការនៅក្នុងកិច្ចប្រជុំមួយដែលត្រូវបានរៀបចំឡើងដោយក្រសួងព័ត៌មានពីថ្ងៃទី២៤ ដល់ ថ្ងៃទី២៦ ខែមករា ឆ្នាំ ២០១៨ នៅខេត្តព្រះសីហនុ ដោយមានការចូលរួមពីដៃគូរភាគីជាច្រើន ហើយត្រូវបានធ្វើឱ្យប្រសើរឡើងបន្ថែមទៀត បន្ទាប់ពីមានការចូលរួមពីអង្គការអប់រំ វិទ្យាសាស្ត្រ និងវិប្បធម៌របស់សហប្រជាជាតិ និងការិយាល័យ OHCHR កាលពីខែមិថុនា និងខែសីហា ឆ្នាំ ២០១៨។ សេចក្តីព្រាងនេះ ដែលមិនត្រូវបានអនុម័តនៅឡើយ មានភាពស្របគ្នាយ៉ាងខ្លាំងជាមួយបទដ្ឋានអន្តរជាតិ ហើយត្រូវបានរៀបចំឡើងតាមដំណើរការៀបចំសេចក្តីព្រាងដោយមានការចូលរួម។

១៧. ការិយាល័យ OHCHR បានបន្តពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលកម្ពុជា។ តាមរយៈវគ្គបណ្តុះបណ្តុះចំនួន ៦ ការិយាល័យនេះ បានបណ្តុះបណ្តាលសមាជិកសង្គមស៊ីវិលជាបុរសចំនួន ១៣៩ នាក់ ស្ត្រីចំនួន ៧៦ នាក់ អ្នកប្តូរយេនឌ័រ ចំនួន ១០នាក់ ក្នុងនោះរាប់បញ្ចូលទាំងសកម្មនៅតាមមូលដ្ឋាន សកម្មដីធ្លី និងសកម្មជនសហជីព មកពីខេត្តក្រចេះ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ព្រះវិហារ សៀបរាម កំពង់ស្ពឺ ស្វាយរៀង កំពង់ចាម និងកោះកុង។ អ្នកចូលរួម ត្រូវបានបណ្តុះបណ្តាលអំពីវិធីសាស្ត្រឃ្លាំមើលការរៀបចំដាក់របាយការណ៍ទៅកាន់យន្តការអន្តរជាតិ និងការតស៊ូមតិ។ ការិយាល័យ OHCHR បានជួយគាំទ្រវគ្គបណ្តុះបណ្តាលចំនួន៦ ដើម្បីជួយដល់អង្គការសង្គមស៊ីវិលក្នុងរៀបចំដាក់របាយការណ៍ជូនយន្តការពិនិត្យរបាយការណ៍ជាសកលតាមពេលកំណត់លើកទី៣ របស់ប្រទេសកម្ពុជា ដែលមានអ្នកចូលរួមចំនួន ៣៨៤នាក់ នៅក្នុងនោះមានស្ត្រីចំនួន ១២៣ នាក់។ ការិយាល័យ OHCHR បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២ ស្តីពីចំណេះដឹងជាមូលដ្ឋានអំពីសិទ្ធិមនុស្សដល់យុវជនចំនួន ២៥ នាក់ (ស្ត្រីចំនួន ១៥ នាក់) ដែលជាសមាជិករបស់អង្គការយុវជនមួយនៅខេត្តបាត់ដំបង និងរាជធានីភ្នំពេញ។

១៨. ដើម្បីលើកកម្ពស់កិច្ចការពារអង្គការសង្គមស៊ីវិល ដោយមានការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលទាំងនោះ ការិយាល័យ OHCHR បានរៀបចំសេចក្តីព្រាងសៀវភៅមួយអំពីកិច្ចការពារ ដែលមានដាក់បញ្ចូលព័ត៌មានជាក់ស្តែងតាមទម្រង់ដ៏សាមញ្ញមួយដើម្បីជួយដល់បុគ្គល និងអង្គការទាំងឡាយក្នុងការបង្កើតផែនការសុវត្ថិភាព និងសន្តិសុខ

[7] សូមមើលគេហទំព័រ www.facebook.com/OHCHRCambodia/photos/a.197076707104491/1732510536894426/?type=3&theater.

និងយល់ដឹងអំពីយន្តការការពារសិទ្ធិមនុស្សពាក់ព័ន្ធនៅថ្នាក់ជាតិ និងអន្តរជាតិ។ សៀវភៅនេះ នឹងផ្សព្វផ្សាយជាសាធារណៈនៅដំណាច់ឆ្នាំ ២០១៩។

១៩. ការិយាល័យ OHCHR បានបន្តឃ្លាំមើលការប្រមូលផ្តុំគ្នាជាសាធារណៈ ដែលការប្រមូលផ្តុំគ្នាជាច្រើន ត្រូវបានធ្វើឡើងទាក់ទងនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។ នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៨ អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ខេត្ត បានបង្ហាញថា ពួកគេនឹងមិនអនុញ្ញាតឱ្យមានសកម្មភាពមួយចំនួនដើម្បីប្រារព្ធទិវាសិទ្ធិមនុស្សនោះទេ។ ការិយាល័យ OHCHR បានទាក់ទងអាជ្ញាធរពាក់ព័ន្ធ និង នៅក្នុងករណីមួយចំនួន មិនទាំងអស់នោះទេ ការប្រមូលផ្តុំគ្នាត្រូវបានអនុញ្ញាតឱ្យធ្វើ។ ការិយាល័យ OHCHR បានសរសេរលិខិតទៅកាន់ក្រសួងមហាផ្ទៃលើកឡើងអំពីកង្វល់ទាក់ទងនឹងសិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការជួបប្រជុំ។ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ ២០១៩ រដ្ឋាភិបាលមិនបានអនុញ្ញាតឱ្យមានការដង្ហែរក្បួនទាក់ទងនឹងសំណើរសុំជួបប្រជុំដោយសន្តិវិធី ដើម្បីប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិឡើយ។ ការិយាល័យ OHCHR និងស្ថាប័នអង្គការសហប្រជាជាតិស្តីពីសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី (UN-Women) បានផ្ញើរលិខិតមួយច្បាប់ទៅកាន់ក្រសួងមហាផ្ទៃទាក់ទងនឹងការដង្ហែរក្បួនដែលត្រូវបានហាមឃាត់ ដោយលើកឡើងអំពីកង្វល់របស់ពួកគេ ទាក់ទងនឹងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី។

២០. នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ ២០១៨ ការិយាល័យ OHCHR បានផ្ញើរលិខិតមួយច្បាប់ទៅក្រសួងមហាផ្ទៃស្នើសុំកិច្ចអន្តរាគមទៅលើករណីមួយ ដែលក្នុងនោះគណៈកម្មាធិកាជាតិរៀបចំការបោះឆ្នោត បានបង្ហាញថា អង្គការដែលធ្វើការឃ្លាំមើលសិទ្ធិមនុស្ស អាចជាការរំលោភច្បាប់ ពីព្រោះសកម្មភាពឃ្លាំមើលរបស់អង្គការនេះ មិនមែននៅក្នុងចំណោមសកម្មភាពសង្កេតការណ៍បោះឆ្នោតដែលអនុញ្ញាតនិងទទួលស្គាល់ដោយគណៈកម្មាធិការនោះទេ។ ការិយាល័យ OHCHR បានស្នើសុំឱ្យមានការបកស្រាយបំភ្លឺជាសាធារណៈ ដែលថាការចុះបញ្ជីជាមួយគណៈកម្មាធិការរៀបចំការបោះឆ្នោត គឺចាំបាច់តម្រូវឱ្យមានសម្រាប់អង្គការទាំងនោះដែលធ្វើសកម្មភាពសង្កេតការណ៍បោះឆ្នោត និងបញ្ជាក់ឱ្យបានច្បាស់លាស់ថា ពុំមានការរឹតត្បឹតណាមួយនោះទេទៅលើការឃ្លាំមើលសិទ្ធិមនុស្សទាក់ទងនឹងការបោះឆ្នោត ។ នៅថ្ងៃទី២៥ ខែកក្កដា ការិយាល័យ OHCHR បានសរសេរលិខិតទៅកាន់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាក់ទងនឹងរបាយការណ៍បណ្តឹងប្រឆាំងនឹងសមាជិករបស់អតីតគណៈបក្សសង្គ្រោះជាតិកម្ពុជាទាក់ទងនឹងការបញ្ចេញមតិរបស់ពួកគេអំពីចេតនាមិនទៅបោះឆ្នោត។ ការិយាល័យ OHCHR បានលើកទឹកចិត្តឱ្យមានការអនុវត្តច្បាប់កម្ពុជាឱ្យស្របតាមបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដែលមិនអនុញ្ញាតិឱ្យមានការរឹតត្បឹតឡើយទៅលើការអំពាវនាវឱ្យធ្វើពហិការចំពោះការបោះឆ្នោតដែលមិនមែនជាកាតព្វកិច្ចនោះ។

២១. ការិយាល័យ OHCHR បានចងក្រងករណីចំនួន ៨៥១ អំពីបុគ្គលទាំងឡាយដែលបានអះអាងអំពីរំលោភសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយអំឡុងពេលធ្វើរបាយការណ៍នេះ

បានចូលរួមក្នុងកិច្ចប្រជុំជំនាញថ្នាក់តំបន់ ដែលរៀបចំឡើងដោយការិយាល័យ OHCHR អង្គការសុខភាពពិភពលោក (WHO) និង មូលនិធិប្រជាជនរបស់អង្គការសហប្រជាជាតិ (UNFPA)។ ការិយាល័យ OHCHR បានផ្សព្វផ្សាយសេចក្តីអត្ថាធិប្បាយស្តីពីប្រាក់ឈ្នួលអប្បបរមា ដែលត្រូវបានអនុម័តកាលពីខែមិថុនា ឆ្នាំ២០១៨។ នៅខែមីនា ឆ្នាំ២០១៨ ការិយាល័យ OHCHR បានចូលរួមចំណែកក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីបរិស្ថាន និងធនធានធម្មជាតិលើកទី១០ ដោយចូលរួមសិក្ខាសាលា និងផ្តល់យោបល់លំអិតជាលាយលក្ខណ៍អក្សរទាក់ទងនឹងសិទ្ធិមនុស្ស។

៣៣. ការិយាល័យ OHCHR បានឃ្លាំមើលកិច្ចដំណើរការនីតិវិធីតុលាការ ចំនួនជាង ៤០ ករណី ដោយបានធ្វើការកំណត់ពីចន្លោះប្រហោងក្នុងការអនុវត្តបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលទាមទារឱ្យមានតម្រូវការជំនួយបច្ចេកទេសបន្ថែមទៀត ជាពិសេសទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

៣៤. នៅឆ្នាំ២០១៨ ដោយមានកិច្ចសហការរួមគ្នាជាមួយក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ការិយាល័យ OHCHR បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់តំបន់ចំនួន ៣ សម្រាប់ចៅក្រម ដោយបានរៀបចំនៅខេត្តកំពត មណ្ឌលគិរី និងខេត្តពោធិ៍សាត់ ដើម្បីតាមដានបន្តអំពីការប្រើប្រាស់ទម្រង់ថ្មីនៃដីកាឃុំខ្លួនបណ្តោះអាសន្ន។ សិក្ខាសាលានេះ បានផ្តោតលើសារៈសំខាន់នៃការលើកសំអាងហេតុផ្នែកច្បាប់ នៅពេលដែលធ្វើការសម្រេចចិត្តលើករណីនានានៃការឃុំខ្លួនបណ្តោះអាសន្ន ស្របតាមគោលការណ៍ណែនាំស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដែលចេញដោយក្រសួងយុត្តិធម៌នៅឆ្នាំ ២០១៤។ ទោះបីជាមានការកើនឡើងនៃការប្រើប្រាស់ទម្រង់ថ្មីដោយចៅក្រមក៏ដោយ ក៏ចំនួនអ្នកជាប់ឃុំបណ្តោះអាសន្ននៅតែកើនឡើង គឺទាំងចំនួនក៏ដូចជាសមាមាត្រនៃចំនួនអ្នកជាប់ឃុំ ភាគច្រើនគឺដោយសារយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់រាជរដ្ឋាភិបាល។

៣៥. ការិយាល័យ OHCHR បានបន្តការគាំទ្ររបស់ខ្លួន ក្នុងការដំឡើងប្រព័ន្ធគ្រប់គ្រងទិន្នន័យសំណុំរឿងព្រហ្មទណ្ឌ នៅសាលាដំបូងចំនួន ៦ ថែមទៀត រួមជាមួយនឹងសាលាដំបូងចំនួន ១២ ត្រូវបានដំឡើងម៉ូឌុលថ្មីរួចរាល់ហើយដែលកំពុងតែដំណើរការប្រតិបត្តិ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យកត់ត្រានូវរាល់ព័ត៌មាននៃរឿងក្តីទាំងអស់ពីដំណាក់កាលចោទប្រកាន់ រហូតដល់ ដំណាក់កាលស៊ើបអង្កេត សវនាការ និងការអនុវត្តទោស។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ជួយបង្កើនតម្លាភាព និង ប្រសិទ្ធភាពនៅក្នុងតុលាការ ហើយក៏ជួយផងដែរ ដើម្បីចៀសវាងការឃុំខ្លួនបណ្តោះអាសន្នលើសនីតិវិធី និងការឃុំខ្លួនលើសរយៈពេលនៃការផ្តន្ទាទោស ដោយការធ្វើឱ្យប្រសើរឡើងនូវសិទ្ធិនៃការទទួលបាននូវព័ត៌មាន និងការប្រាស្រ័យទាក់ទងរវាងទីភ្នាក់ងាររដ្ឋាភិបាល។ ការិយាល័យ OHCHR បានសង្កេតឃើញមានការប្រើប្រាស់ប្រព័ន្ធទិន្នន័យកាន់តែច្រើនឡើងៗ ដោយតុលាការមួយចំនួនក៏ដូចជាសាធារណជនអាចទៅរកព័ត៌មានតាមរយៈប្រព័ន្ធនេះ ព្រមទាំងការកើនឡើងនៃ

ចំនួនសំណុំរឿងដែលត្រូវបានចុះបញ្ជី និងកត់ត្រាក្នុងប្រព័ន្ធទិន្នន័យ។ គ្រប់សាលាដំបូងទាំងអស់ នឹងមានប្រព័ន្ធគ្រប់គ្រងទិន្នន័យនេះ នៅត្រឹមដំណាច់ឆ្នាំ ២០១៩។ ក្រសួងយុត្តិធម៌ បានប្រកាសថា ខ្លួននឹងបង្កើតមជ្ឈមណ្ឌលប្រព័ន្ធគ្រប់គ្រងទិន្នន័យថ្នាក់កណ្ដាលមួយ នៅរាជធានីភ្នំពេញ ដើម្បីសម្រួលដល់ការប្រមូល និងវិភាគទិន្នន័យពីគ្រប់តុលាការទាំងអស់។

៣៦. ការិយាល័យ OHCHR បានចាប់ផ្ដើមអនុវត្តគម្រោងរួមគ្នាជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ស្ដីពីសិទ្ធិទទួលបានយុត្តិធម៌របស់ជនពិការ ដែលផ្ដល់មូលនិធិដោយអង្គការសហប្រជាជាតិនៃភាពជាដៃគូ ដើម្បីលើកកម្ពស់សិទ្ធិជនពិការ។ សិក្ខាសាលាបណ្ដុះបណ្ដាលចំនួន ២ ត្រូវបានរៀបចំឡើង សម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីមកពីខេត្ត/ក្រុងគោលដៅចំនួន ៣ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ដើម្បីណែនាំពួកគេអំពីវិធីសាស្ត្រសិទ្ធិមនុស្សទាក់ទងនឹងពិការភាព។ ការិយាល័យ OHCHR ក៏បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការចងក្រងឯកសារ និងការឃ្លាំមើលករណីរំលោភសិទ្ធិមនុស្សចំនួន ២ ផងដែរ សម្រាប់អង្គការជនពិការថ្នាក់មូលដ្ឋាន។ ជំនួយមូលនិធិចំនួន ៣ ត្រូវបានផ្ដល់ទៅឱ្យអង្គការនានាដែលទាក់ទងនឹងការផ្ដល់ជំនួយផ្នែកច្បាប់ វាយតម្លៃស្ថានភាពជនពិការក្នុងពន្ធនាគារ និងគាំទ្រដល់ជនពិការចិត្តសាស្ត្រដែលជាប់ច្រវាក់នៅក្នុងផ្ទះរបស់ពួកគេ។

៣៧. នៅក្នុងការស្ទង់មតិដែលបានធ្វើឡើងនៅឆ្នាំ២០១៨ ដែលជាផ្នែកមួយនៃកម្មវិធីកេរដំណែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា របស់ការិយាល័យ OHCHR ចៅក្រមភាគច្រើន ដែលបានចូលរួមក្នុងការស្ទង់មតិ បានចាត់ទុកថា សេចក្ដីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាស្នាដៃដ៏សំខាន់មួយនៃកម្មវិធី និងជាលិខិតុបករណ៍ដ៏មានប្រយោជន៍។ ការិយាល័យ OHCHR បានបន្តការងាររបស់ខ្លួនជាមួយនិស្សិតច្បាប់ ដើម្បីពិភាក្សាអំពីកម្មវិធីកេរដំណែល និងសិទ្ធិទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ ដោយធ្វើបទបង្ហាញចំនួន ២ និងសម្របសម្រួលវគ្គបណ្ដុះបណ្ដាលមួយ សម្រាប់និស្សិតមហាវិទ្យាល័យច្បាប់ ចំនួន ៣០ នាក់ ក្នុងឆ្នាំ ២០១៨។

៣៨. បន្ទាប់ពីធ្វើការតាមដានឃ្លាំមើល និងការតស៊ូមតិរបស់ខ្លួនជាបន្តបន្ទាប់រួចមក ការិយាល័យ OHCHR បានរៀបចំរបាយការណ៍ស្ដីពីការកាត់ទោសដោយមហាជន រួមទាំងឧប្បត្តិហេតុនៃការសម្លាប់មនុស្សដោយមហាជន ឬការវាយដំ និងសំណុំរឿងនៃការសម្លាប់មនុស្ស ការវាយដំ ការឃាយី និងការបណ្ដេញប្រជាពលរដ្ឋ ដែលត្រូវបានចោទប្រកាន់ថាបានធ្វើអំពើអាបធ្មប់។ របាយការណ៍ជាសាធារណៈដែលនឹងត្រូវផ្សព្វផ្សាយនៅខែកក្កដា ឆ្នាំ២០១៩ ដែលគូសបញ្ជាក់អំពីបញ្ហាប្រឈម ក្នុងវិស័យយុត្តិធម៌ ដើម្បីដោះស្រាយបញ្ហានៃការកាត់ទោសដោយមហាជន ក៏ដូចជាវឌ្ឍនភាពក្នុងការស៊ើបអង្កេតរបស់នគរបាល និងតុលាការ។ ការចេញផ្សាយរបាយការណ៍នេះ នឹងកត់សម្គាល់អំពីការចាប់ផ្ដើមយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ដែលដឹកនាំដោយការិយាល័យ OHCHR សហការជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដោយលើកទឹកចិត្តប្រជា

ពលរដ្ឋមិនឱ្យចូលរួមក្នុងសកម្មភាពការកាត់ទោសដោយមហាជន និងត្រូវរាយការណ៍អំពីរឿងនេះទៅនគរបាល។

៣៩. ជាផ្នែកមួយនៃការងារបង្ការទារុណកម្ម ការិយាល័យ OHCHR បានសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងទារុណកម្ម និងព្រះរាជអាជ្ញាមកពីខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ ដើម្បីរៀបចំការធ្វើបទបង្ហាញសង្ខេបថ្នាក់ស្រុក។ មន្ត្រីប្រតិបត្តិច្បាប់ក្នុងស្រុកជាង ៣០០ នាក់ត្រូវបានបណ្តុះបណ្តាល អំពីការបង្ការទារុណកម្ម ការប្រើប្រាស់កម្លាំង និងសិទ្ធិនៅពេលចាប់ខ្លួន រួមទាំងច្បាប់ជាតិ ក៏ដូចជាលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ។

## V. ការធ្វើឱ្យរីកចម្រើននូវការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈសិទ្ធិមនុស្ស

៤០. កំណើនសេដ្ឋកិច្ចបានបន្តកើនឡើងនៅកម្រិតខ្ពស់ ជាង ៧% ដែលបានធ្វើឱ្យមានផលប៉ះពាល់ជាវិជ្ជមានសម្រាប់ទទួលបានសិទ្ធិសេដ្ឋកិច្ច និងសង្គម។ ផ្អែកតាមតួលេខរបស់រដ្ឋាភិបាល អត្រាភាពក្រីក្របានធ្លាក់ចុះពី ៤៧,៨ ភាគរយក្នុងឆ្នាំ ២០០៧ មក ១៣,៥ ភាគរយ ក្នុងឆ្នាំ២០១៤។ យ៉ាងណាក៏ដោយ ចំនួនប្រជាជនដែលនៅបន្ទាត់ភាពក្រីក្រខាងលើមិនត្រឹមតែបានកើនឡើងនោះទេ ចំពោះប្រជាជននៅក្បែរភាពក្រីក្រ ក៏បានកើនឡើងផងដែរ ដែលកំពុងគូសបញ្ជាក់នូវភាពងាយរងគ្រោះរបស់មនុស្សជាច្រើនចំពោះការជះឥទ្ធិពលដល់សេដ្ឋកិច្ច និងវិស័យផ្សេងៗ។ ក្នុងខែកញ្ញា ឆ្នាំ ២០១៨ UNDP បានចេញឯកសារមួយ ស្តីពីសន្ទស្សន៍ភាពក្រីក្រពហុវិស័យ ដោយមានការវាស់វែងដ៏ស្មុគស្មាញមួយផ្អែកលើសន្ទស្សន៍ចំនួន ១០ រួមមានការអប់រំ សុខភាព និងកម្រិតជីវភាពរស់នៅដែលបានដាក់កំណត់ពីអត្រាភាពក្រីក្រទិដ្ឋភាពចំរុះនេះ នៅ ៣៥ ភាគរយ សម្រាប់កម្ពុជា និងចំណាត់ថ្នាក់កម្ពុជា បានលេខ ៥៨ ក្នុងចំណោមប្រទេសចំនួន ១០៥។[8] នៅក្នុងអំឡុងរយៈពេលនៃការធ្វើរបាយការណ៍នេះ រដ្ឋាភិបាល បានណែនាំបង្ហាញពីច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា និងបានបង្កើនប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតនៅក្នុងវិស័យវាយនភណ្ឌ និង សម្លៀកបំពាក់/ស្បែកជើងផងដែរ ត្រឹម ៧ ភាគរយ នៅក្នុងខែមករា ឆ្នាំ២០១៩ ទៅដល់ ១៨២ ដុល្លារ ក្នុង១ ខែ។

៤១. នៅក្នុងខែកញ្ញា ឆ្នាំ ២០១៨ រដ្ឋាភិបាល បានបោះពុម្ពផ្សាយ យុទ្ធសាស្ត្រចតុកោណជំហាន ៤ របស់ខ្លួន កំណត់ចេញនូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ និងដាក់អភិបាលកិច្ចជាចំនុចស្នូលរបស់យុទ្ធសាស្ត្រចតុកោណជំហាន ៤ នេះ។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ រដ្ឋាភិបាល បានបោះពុម្ពផ្សាយ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ដែលរួមបញ្ចូលនូវគោលដៅបន្ថែមមួយទៀតស្តីពីការដោះមីន។ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានគូសបញ្ជាក់ពីតថភាពដែលគោលដៅ និងសន្ទស្សន៍នានាទាក់ទងនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៦ ស្តីពី សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ ត្រូវបានកាត់បន្ថយយ៉ាងគំហុក បើប្រៀបធៀបជាមួយគោលដៅសកល។[9] នៅពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលកំពុងធ្វើសេចក្តីព្រាងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិ (ដោយច្របាច់បញ្ចូលជាមួយយុទ្ធសាស្ត្រចតុកោណជំហាន ៤ និងគោលដៅអភិវឌ្ឍ

[8] សេចក្តីប្រកាសព័ត៌មានរបស់យូអិនឌីភី នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ "ការបំភ្លឺ៖ ភាពក្រីក្រពហុវិស័យកំពុងថយចុះនៅក្នុងប្រទេសកម្ពុជា"។

[9] សូមមើល www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=24579&LangID=E

ន៍ប្រកបដោយចីរភាពប្រទេសកម្ពុជា) ដែលនឹងបង្កើតបានជាយុទ្ធសាស្ត្រអភិវឌ្ឍន៍រួមមួយរបស់រដ្ឋាភិបាល។

៤២. នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ បានបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនស្តីពីការចុះបញ្ជីដី។ យោងទៅតាមរបាយការណ៍នេះ ចាប់ពីការចាប់ផ្តើមរបស់ខ្លួន រហូតដល់ខែ ធ្នូ ឆ្នាំ២០១៩ ក្រសួងបានចេញប័ណ្ណកម្មសិទ្ធិដីធ្លីចំនួន ៥.១២៧.៨១៩ ហើយ ឬ ៧៣,២៥ ភាគរយ នៃក្បាលដីប្រមាណ ៧ លាន ដែលលើសដល់ ៣,២៥ ភាគរយ ពីគោលដៅរបស់ខ្លួនបានកំណត់ក្នុងឆ្នាំ ២០១៤-២០១៨។ យោងទៅតាមរបាយការណ៍ដដែល នៅក្នុងឆ្នាំ ២០១៨ គណៈកម្មាការសុរិយោដី បានទទួលករណីជម្លោះដីធ្លីចំនួន ៥៤៤ និងបានដោះស្រាយចំនួន ២៩២ ករណី ដែលមាន ១.៥១២ គ្រួសារ និងតំបន់ដីធ្លីមួយមាន ២៤៣,៩៦ ហិកតា ហើយនិង ១៧៦ ករណី បានត្រូវលើកបណ្តឹងចោល នៅពេលដែលករណីទាំងនោះបានត្រូវគេរកឃើញថា នៅក្រៅអាណត្តិការងាររបស់គណៈកម្មាការនោះ និង ៤៧ បណ្តឹងទៀត បានត្រូវគេដកវិញ។ ក្រសួងបានបង្កើតក្រុមការងារគណៈកម្មាការច្បាប់ដោះស្រាយជម្លោះដីធ្លីមួយចំនួន។ យោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០១៨ របស់ខ្លួននេះ នៅក្នុងឆ្នាំ ២០១៨ ក្រសួងបានទទួល ៥៧១ ករណី ដែលករណីទាំងនេះ មាន ១២៥ ករណី បានត្រូវដោះស្រាយដោយក្រុមការងារទាំងនោះរបស់ក្រសួង ហើយ ៥២ ករណី បានត្រូវដោះស្រាយត្រឹមចុងឆ្នាំ និង ៧៣ ករណីទៀត បានទទួលការឆ្លើយតបជាលាយលក្ខណ៍អក្សរ ឬត្រូវបានយោងទៅអាជ្ញាធរដែលមានការទទួលខុសត្រូវមួយផ្សេងទៀត។

៤៣. តាមរយៈកម្មវិធីសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ការិយាល័យ OHCHR បានបន្តធ្វើការលើបញ្ហាពាក់ព័ន្ធនឹងសិទ្ធិទទួលបានលំនៅឋានសមរម្យ និងលើបទដ្ឋានសមរម្យនៃការរស់នៅ ដើម្បីជួយបង្ការការបណ្តេញចេញដោយបង្ខំ និងដើម្បីលើកកម្ពស់សុវត្ថិភាពសិទ្ធិកាន់កាប់ និងការយល់ដឹងកាន់តែប្រសើរឡើងថែមទៀត អំពីតួនាទីរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស។

៤៤. នៅក្នុងខែតុលា និងខែវិច្ឆិកា ឆ្នាំ២០១៨ ការិយាល័យ OHCHR ក្នុងភាពជាដៃគូជាមួយអាជ្ញាធរខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល បានរៀបចំឡើងនូវសិក្ខាសាលាចំនួន ២ នៅក្នុងខេត្តកំពត និងក្រចេះ ស្តីពីសិទ្ធិដីធ្លី និងលំនៅឋាន ដោយផ្តោតលើនីតិវិធីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី និងលើការទទួលខុសត្រូវរបស់សហគ្រាសធុរកិច្ចក្នុងបរិបទនេះ។

៤៥. ជាផ្នែកមួយនៃដំណើរការតាំងទីលំនៅថ្មី ឬដើម្បីផ្តល់ដីធ្លីដល់ប្រជាជនក្រីក្រ និងអតីតយុទ្ធជនគ្មានដីធ្លី រាជរដ្ឋាភិបាលកំពុងបានផ្តល់ដីសម្បទានសង្គមកិច្ចដល់បុគ្គល និងគ្រួសារទាំងនោះ។ ការិយាល័យ OHCHR បានប្រើប្រាស់ការសិក្សាស្រាវជ្រាវរបស់ខ្លួនដែលបានបោះពុម្ពផ្សាយក្នុងខែឧសភា ឆ្នាំ២០១៨ មានចំណងជើងថា "ការសិក្សាវាយតំលៃលើផលប៉ះពាល់នៃសម្បទានដដីសង្គមកិច្ចមកលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

នៅតាមទីជនបទ″ ធ្វើជាមូលដ្ឋានសម្រាប់ការតស៊ូមតិជាមួយអាជ្ញាធរថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិនានាដែលពាក់ព័ន្ធ សម្រាប់ភាពល្អប្រសើរនៃសម្បទានដីសង្គមកិច្ចដែលមានស្រាប់ និងមុនពេលបង្កើតសម្បទានថ្មីនានា នៅក្នុងបណ្ដាខេត្តកំពង់ធំ មណ្ឌលគិរី កំពតត្បូងឃ្មុំ និងបាត់ដំបង។

៤៦. ជាផ្នែកមួយនៃកិច្ចការតស៊ូមតិ នៅក្នុងខែកញ្ញានិងខែធ្នូ ២០១៨ ការិយាល័យ OHCHR បានរៀបចំបេសកម្មទៅកាន់តំបន់សម្បទានសង្គមកិច្ចចំនួនពីរដែលមានទីតាំងនៅស្រុកមេមត់ខេត្តត្បូងឃ្មុំ និងបឹងល្វា នៅខេត្តកំពង់ធំ។ ទស្សនៈកិច្ចនេះបានធ្វើឱ្យ មន្ត្រីរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាននិងខេត្ត អង្គការសង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍មានឱកាសរៀនសូត្រអំពីបទពិសោធល្អៗ និងមិនល្អនៅតំបន់សប្បទានសង្គមកិច្ចដោយផ្ទាល់ពីអ្នកភូមិពាក់ព័ន្ធ។ អ្នកចូលរួមបានបង្ហាញចេត្តនាធ្វើឱ្យប្រសើឡើងនូវស្ថានភាពនៅតាមតំបន់សប្បទានសង្គមកិច្ចទាំងនេះ។

៤៧. ការិយាល័យOHCHR បន្តធ្វើការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ អាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិលសម្រាប់ការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ជនជាតិដើមភាគតិចដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពនិងដើម្បីតស៊ូមតិសម្រាប់ការកែសម្រួលនីតិវិធីការចុះបញ្ជីរដីសមូហភាព។ សហគមន៍ជនជាតិដើមភាគតិចមួយនៅខេត្តរត្តនៈគីរី និងសហគមន៍ជនជាតិដើមភាគតិចគួយចំនួនបី សហគមន៍នៅខេត្តកំពង់ធំ ត្រូវបានប្រកាសទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចដែលជាដំណាក់កាលទីមួយនៃដំណាក់កាលទាំងបី។ នៅខែមិថុនាឆ្នាំ ២០១៨ ដោយមានការគាំទ្រពីការិយាល័យ OHCHR សហគមន៍ជនជាតិដើមភាគតិចពូនង (ព្នង) មួយ នៅស្រុកកោះញែក ខេត្តមណ្ឌលគីរី ត្រូវបានបញ្ចប់ដំណាក់កាលទីពីរនៃនីតិវិធី ពោលគឺត្រូវបានចុះបញ្ជីរជានីតិបុគ្គល។ ជាងនេះទៅទៀត សហគមន៍ជនជាតិដើមភាគតិចពូនង (ព្នង) មួយសហគមន៍ទៀត នៅស្រុកស្នួលខេត្តក្រចេះ បានវិវឌ្ឍន៍នៅក្នុងដំណាក់ទីពីរដោយបានអនុម័តលក្ខន្តិកៈរបស់សហគមន៍ពួកគេនៅខែមេសាឆ្នាំ ២០១៨។

៤៨. ដោយមានគាំទ្រពីការិយាល័យ OHCHR មន្ត្រីថ្នាក់ខេត្ត ស្រុក និងឃុំត្រូវបានពង្រឹងសមត្ថភាពស្ដីពីនីតិវិធីចុះបញ្ជីរដីសមូហភាព។ ការយល់ដឹងអំពីនីតិវិធីនេះក៏ត្រូវបានពង្រឹងនៅក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចផងដែរ។ ខែវិចិកា ឆ្នាំ ២០១៨ ការិយាល័យ OHCHR បានគាំទ្រក្រសួងទាំងបីដែលពាក់ព័ន្ធការចុះបញ្ជីរដីសមូហភាពក្នុងការរៀបចំសិក្ខាសាលាដែលមានការចូលរួមពីតំណាងសហគមន៍ជនជាតិដើមភាគតិចចំនួន ១៣ សហគមន៍ មកពីខេត្តរត្តនៈគីរី និងតំណាងសហគមន៍ចំនួន ១១ ទៀតមកពីខេត្តមណ្ឌលគីរី ស្ទឹងត្រែង និងក្រចេះ។ គោលបំណងនៃសិក្ខាសាលាគឺដើម្បីពង្រឹងសមត្ថភាពសហគមន៍ជនជាតិដើមភាគតិចក្នុងការគ្រប់គ្រង និងការពារដីកម្មសិទ្ធិសមូហភាព ក៏ដូចជា វិធីដោះស្រាយវិវាទផងដែរ។

ក្នុងខែមេសា ឆ្នាំ ២០១៩ ការិយាល័យ OHCHR បានផលិតសៀវភៅណែនាំស្តីពីការចុះបញ្ជីដីសមូហភាព ដែលអាចជួយដល់អាជ្ញាធរមូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចក្នុងដំណើរការឱ្យមានប្រសិទ្ធភាព។ នៅក្នុងខែដដែលនេះ ការិយាល័យ OHCHR បានបោះពុម្ពផ្សាយឯកសារមួយឈ្មោះ "ការវាយតម្លៃលើឱកាសទទួលបានឥណទានរបស់សហគមន៍ជនជាតិដើមភាគតិចដែលមានប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅកម្ពុជា" ដែលជាលទ្ធផលបង្ហាញឱ្យឃើញថាសហគមន៍ជនជាតិដើមភាគតិចអាចទទួលបានកម្ចីរឥណទានតាមរយៈកម្ចីជាក្រុមនិងដោយមិនចាំបាច់មានទ្រព្យបញ្ចាំដែលជាប្លង់កម្មសិទ្ធិដីឯកជននោះឡើយ។

៥០. ការិយាល័យ OHCHR បានទទួលញត្តិពីបុគ្គល និងក្រុមដែលស្វែងរកកិច្ចអន្តរាគមន៍ដល់វិវាទរបស់ពួកគេ។ ការិយាល័យនេះបានធ្វើបេសកកម្មស្វែងរកការពិត ធ្វើការសហការជាមួយអាជ្ញាធរពាក់ព័ន្ធ សម្របសម្រួលកិច្ចសន្ទនារវាងភាគីនានា ឃ្លាំមើលយន្តការដោះស្រាយវិវាទ និងផ្តល់ប្រឹក្សាផ្លូវច្បាប់ និងនីតិវិធីដល់សហគមន៍និងអង្គការសង្គមស៊ីវិលដែលគាំទ្រពួកគេ។ ការិយាល័យ OHCHR ក៏ធ្វើការជួយដល់រាជរដ្ឋាភិបាល និងសហគ្រាសពាណិជ្ជកម្មដើម្បីផ្តល់នូវសំណងសមរម្យដល់ករណីដែលមានការរំលោភបំពានដល់សិទ្ធិលំនៅឋាន និងដីធ្លី។ ក្នុងខែតុលាឆ្នាំ ២០១៨ ការិយាល័យ OHCHR គាំទ្រការបង្កើតលក្ខខណ្ឌយោង និងសេចក្តីណែនាំផ្ទៃក្នុងសម្រាប់ក្រុមសម្របសម្រួលវិស័យដីធ្លីដែលមានគោលបំណងពង្រឹងក្រុម និងបង្កើតឱ្យមានកិច្ចសន្ទនារួមគ្នា និងការងារតស៊ូមតិជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៥១. នៅខែមីនា ឆ្នាំ ២០១៨ ការិយាល័យ OHCHR បានបញ្ជូនក្រុមបេសកម្មស្វែងរកការពិតមួយទៅកាន់ស្រុកស្នួល ខេត្តក្រចេះ ដើម្បីតាមដានទៅលើករណីបាតុកម្មហឹង្សាដែលពាក់ព័ន្ធទៅនឹងអ្នកដែលបានសាងសង់លំនៅឋាននៅលើដីសម្បទានសេដ្ឋកិច្ច។ បេសកម្មបានសន្និដ្ឋានថាអាជ្ញាធរបានឆ្លើយតបទៅនឹងបាតុកម្មហឹង្សាដោយប្រើប្រាស់កម្លាំងលើសលប់ រួមទាំងតាមរយៈការប្រើប្រាស់អាវុធផងដែរ។ នៅថ្ងៃទី២៦ មីនា ការិយាល័យ OHCHR បានផ្ញើលិខិតមួយច្បាប់ទៅក្រសួងមហាផ្ទៃដោយភ្ជាប់ជាមួយនូវរបាយការណ៍ដែលមានការសន្និដ្ឋាន និងអនុសាសន៍របស់ការិយាល័យផងដែរ។ ខែកញ្ញា ឆ្នាំ ២០១៨ និង ខែមេសា ឆ្នាំ ២០១៩ ការិយាល័យ OHCHR បានធ្វើបេសកម្មទៅតាមដានជាថ្មីទៀត ហើយក៏បានផ្ញើលិខិតមួយច្បាប់ទៅអភិបាលខេត្តក្រចេះស្នើសុំកិច្ចអន្តរាគមន៍ក្នុងករណីវិវាទដីធ្លី និងស្វែងរកដំណោះស្រាយសន្តិវិធីដល់ជនទទួលរងផលប៉ះពាល់ផងដែរ។

៥២. នៅខែមករា និងកុម្ភៈ ឆ្នាំ ២០១៩ ការិយាល័យ OHCHR បានបញ្ជូនក្រុមការងារបេសកម្មស្វែងរកការពិតចំនួនពីរទៅកាន់ខេត្តព្រះសីហនុ បន្ទាប់ពីមានការប៉ះទង្គិចគ្នារវាងកម្លាំងសន្តិសុខ និងបាតុករប្រឆាំងការបណ្តេញចេញដោយបង្ខំ។ ការិយាល័យ OHCHR បានធ្វើការជាមួយគ្រប់អាជ្ញាធរពាក់ព័ន្ធទាំងអស់។ ស្របជាមួយគ្នានោះ មានការផ្អាកជាបណ្តោះអាសន្ននូវផែនការបណ្តេញចេញទីពីរនៅនាទីចុងក្រោយ គឺនៅថ្ងៃតែ

មួយដែលការិយាល័យ OHCHR បានធ្វើបេសកម្មតាមដាន។ នៅក្នុងអំឡុងពេលនៃបេសកម្មស្វែងរកការពិត កងកម្លាំងសន្តិសុខបានប្រើប្រាស់កម្លាំងហួសប្រមាណប្រឆាំងបាតុករ ដែលបណ្តាលឱ្យបុរសម្នាក់ត្រូវបានបាញ់ឱ្យរបួស។ នៅថ្ងៃទី ២២ កុម្ភៈ ការិយាល័យ OHCHR បានសសេរលិខិតមួយច្បាប់ទៅក្រសួងមហាផ្ទៃបញ្ជាក់ថាកងកម្លាំងសន្តិសុខបានប្រើប្រាស់កម្លាំងហួសប្រមាណ និងវិសមាមាត្រ រួមទាំងការប្រើប្រាស់អាវុធនៅក្នុងអំឡុងពេលបាតុកម្ម។ នៅក្នុងលិខិតនេះផងដែរ ការិយាល័យបានលើកទឹកចិត្តឱ្យក្រសួងធ្វើការស៊ើបអង្កេតជាសាធារណៈមួយចំពោះការប្រើប្រាស់កម្លាំងក៏ដូចជាការបាញ់ទៅលើបុគ្គលនិងបង្កឱ្យបុគ្គលនោះទទួលរងនូវពិការភាពនូវផ្នែកណាមួយដែលជាលទ្ធផលនៃរបួស ហើយក៏ត្រូវមានសំណងសមរម្យមួយផងដែរ។

៥៣. នៅក្នុងខែមករា ២០១៩ ការិយាល័យ OHCHR បានធ្វើការឃ្លាំមើលនូវករណីបុរសម្នាក់ដែលត្រូវបានចាប់ឃុំខ្លួននៅខេត្តព្រះវិហារក្នុងបរិបទវិវាទដីធ្លី និងបានបាត់ខ្លួនពីកន្លែងឃុំខ្លួននៅថ្ងៃទី២១ មករា។ បន្ទាប់ពីការស៊ើបអង្កេតបឋម ការិយាល័យ OHCHR បានធ្វើលិខិតមួយច្បាប់ផ្ញើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៅថ្ងៃទី១៣ កុម្ភៈ ស្នើសុំការពិនិត្យទៅលើបញ្ហានេះ។ នៅថ្ងៃទី២១ មីនា ការិយាល័យ OHCHR បានធ្វើលិខិតមួយច្បាប់ទៅក្រសួងការពារជាតិដើម្បីស្នើសុំការស៊ើបអង្កេតទៅលើករណីឃាត់ខ្លួននិងការចោទប្រកាន់ស្តីពីការប្រព្រឹត្តមិនសមរម្យទៅលើបុគ្គលនោះដោយកម្លាំងយោធាមុននឹងបាត់ខ្លួន។ បន្ទាប់មកមានរបាយការណ៍ថាបុរសនោះបានបង្ហាញខ្លួននៅខេត្តព្រះសីហនុ ហើយការិយាល័យ OHCHR បានជួបជាមួយគាត់នៅថ្ងៃទី៣១ មីនា។

៥៤. ក្នុងខែឧសភា និងខែមិថុនា ឆ្នាំ២០១៨ ការិយាល័យ OHCHR បានចុះបេសកកម្មទៅក្នុងខេត្តស្ទឹងត្រែង និងខេត្តកោះកុង ដើម្បីបន្តតាមដានលើករណីការតាំងទីលំនៅថ្មីដែលមានលទ្ធផលចេញពីទំនប់វារីអគ្គីសនីសេសានក្រោម ២ និងគម្រោងនានា បានប្រតិបត្តិដោយ ក្រុមហ៊ុន Union Development Group។ នៅក្នុងករណីទាំងពីរនេះ ការិយាល័យ OHCHR បានជំរុញលើកទឹកចិត្តដល់អាជ្ញាធរ ឱ្យផ្តល់នូវសំណងត្រឹមត្រូវដល់ប្រជាជនដែលរងផលប៉ះពាល់ និងដល់ប្រជាជនដែលត្រូវបានគេអនុញ្ញាតឱ្យស្នាក់នៅលើទីតាំងថ្មី និងលើទីតាំងលំនៅថ្មីបណ្តោះអាសន្នរបស់ពួកគេ ឱ្យបានសមរម្យ ហើយនិងធ្វើឱ្យបានល្អប្រសើរឡើងនូវលក្ខខណ្ឌនៅលើទីតាំងការតាំងទីលំនៅថ្មីផ្លូវការទាំងឡាយរួមទាំង ឱកាសការចិញ្ចឹមជីវិតផងដែរ។

៥៥. ការិយាល័យ OHCHR បានបន្តតាមដានដំណើរការដោះស្រាយជម្លោះសម្បទានដីសេដ្ឋកិច្ចស្ករអំពៅ និងការងាររបស់ក្រុមការងារដែលបានបង្កើតឡើងដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ សម្រាប់គោលបំណងនេះ ការិយាល័យ OHCHR បានចុះបេសកកម្មទៅខេត្តព្រះវិហារ ក្នុងខែឧសភា ឆ្នាំ២០១៨ ទៅខេត្តកោះកុង ក្នុងខែមិថុនា ឆ្នាំ២០១៨ និងទៅខេត្តកំពង់ស្ពឺ ក្នុងខែកញ្ញា ឆ្នាំ២០១៨។ ការិយាល័យ បានបន្តជំរុញដល់រដ្ឋាភិបាលឱ្យពន្លឿនដំណើរការដោះស្រាយជម្លោះនេះ និងធ្វើការងារនៅក្នុងរបៀបដែលកាន់តែមានតម្លាភាព និងពន្លឿននូវសកម្មភាពដំណោះស្រាយទាំងឡាយ

សម្រាប់បញ្ហាកំពុងប្រឈមផ្សេងៗទៀត ដែលបានលើកឡើងដោយប្រជាជនបានទទួលរងផលប៉ះពាល់ដោយសម្បទានស្កររអំពៅទាំងនេះ។

៥៦. ការិយាល័យ OHCHR បានបន្តតាមដានដំណើរការសម្រុះសម្រួលរវាងសហគមន៍ជនជាតិដើមភាគតិចនៅក្នុងឃុំប៊ូស្រាជាមួយក្រុមហ៊ុនកៅស៊ូ Socfin ដែលបានសម្របសម្រួលដោយអង្គការសម្រុះសម្រួលឯករាជ្យ (IMG) និងបានធ្វើនៅក្នុងខេត្តមណ្ឌលគិរី។ លើសពីនេះទៀត ការិយាល័យ OHCHR បានឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុដល់អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) ដើម្បីបណ្តុះបណ្តាលដល់តំណាងសហគមន៍ក្នុងជំនាញសន្ធានកម្ម ព្រមទាំងដើរតួជាអ្នកផ្តល់យោបល់ផ្នែកច្បាប់អំឡុងពេលសម្រុះសម្រួលនោះ។ ការសម្រុះសម្រួលដែលកំពុងបន្តនេះ ផ្តល់លទ្ធផលឱ្យឃើញថា ផ្នែកខ្លះនៃដីសហគមន៍កំពុងបានវិលត្រឡប់មកសហគមន៍ជនជាតិដើមភាគតិចវិញ រួមមានព្រៃអារក្ស និងដីព្រៃកប់ខ្មោច។

៥៧. ការិយាល័យ OHCHR នៅតែបន្តលើកស្ទួយការផ្សព្វផ្សាយនូវព័ត៌មានសាធារណៈស្តីពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងៗ រួមមានផែនទីអន្តរកម្មនៃសម្បទានដីសង្គមកិច្ច តាមរយៈការឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុទៅដល់អង្គការមិនមែនរដ្ឋាភិបាលមួយហៅថា អង្គការទិន្នន័យអំពីការអភិវឌ្ឍ។ ផែនទីអន្តរកម្មនេះ ជួយឃ្លាំមើលការអភិវឌ្ឍនៅក្នុងសម្បទានដីសង្គមកិច្ចទូទាំងប្រទេស។ ការិយាល័យ OHCHR អង្គការទិន្នន័យអំពីការអភិវឌ្ឍ និង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានរៀបចំឡើងនូវសិក្ខាសាលាថ្នាក់តំបន់មួយស្តីពី សម្បទានដីសង្គមកិច្ច កាលពីខែសីហាឆ្នាំ២០១៨ ។ មន្ត្រីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា បានបង្ហាញចំណាប់អារម្មណ៍លើផែនទីអន្តរកម្មនេះ និងបានធ្វើឱ្យពួកគេមានលទ្ធភាពប្រសើរឡើងក្នុងការប្រើប្រាស់ផែនទីអន្តរកម្មទាំងនេះ។

៥៨. ការិយាល័យ OHCHR បានអនុវត្តបេសកកម្មឃ្លាំមើលចំនួន ១២ ដង ទៅដល់សហគមន៍ជនជាតិវៀតណាមភាគតិចដែលបានជ្រើសរើសនៅក្នុងក្រុងភ្នំពេញ និងខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តកំពង់ធំ ដើម្បីទទួលបានការយល់ដឹងពីការប្រឈមនានាដែលពួកគេជួបប្រទះទាក់ទងនឹង ឋានៈផ្នែកច្បាប់ ការចូលទៅសាលារៀន ការទទួលបានសុខភាពសាធារណៈរបស់ពួកគេ និងការរើសអើង។ ការិយាល័យ OHCHR បានសម្រេចជោគជ័យក្នុងការជំរុញលើកទឹកចិត្តដល់អាជ្ញាធរមូលដ្ឋានឱ្យពន្យាពេលរហូតដល់ខែឧសភាឆ្នាំ២០១៩ នូវការបណ្តេញចេញដោយបង្ខំនៅក្នុងភូមិបណ្តែតទឹកជនជាតិភាគតិចវៀតណាមក្បែរទន្លេសាប។ បេសកកម្មបន្តតាមដានមួយ ក្នុងខែកុម្ភៈ ឆ្នាំ២០១៩ បានបញ្ជាក់ថា គ្មានការតាំងទីលំនៅថ្មីបន្ថែមទៀតទេទៅលើដីគោករបស់សហគមន៍ជនជាតិវៀតណាមភាគតិចនៅក្នុងខេត្តកំពង់ឆ្នាំង។ អភិបាលរង បានយល់ព្រមពន្យាពេលលើការតាំងទីលំនៅថ្មីនោះ រហូតដល់សេវាមូលដ្ឋាននានា អាចដាក់ឱ្យប្រើប្រាស់បានសម្រាប់ប្រជាជនទាំងនោះ។

៥៩. ការិយាល័យ OHCHR បានបន្តពង្រីកការផ្តោតយកចិត្តទុកដាក់របស់ខ្លួនលើធុរកិច្ច និងសិទ្ធិមនុស្ស ដោយធ្វើការផ្ទាល់ជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល តំណាងសហគមន៍ និងតួអង្គធុរកិច្ចនានា ដើម្បីបង្កើនការយល់ដឹងរបស់ពួកគេពីគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងការអនុវត្តរបស់ពួកគេក្នុងប្រទេសកម្ពុជា។ ការិយាល័យ OHCHR បានចូលរួមក្នុងកិច្ចប្រជុំរបស់វេទិកាការទទួលខុសត្រូវខាងសង្គមរបស់សាជីវកម្ម ដែលជាវេទិកាធុរកិច្ចមួយ ដែលអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល បានបង្កើតថ្មីឡើងដើម្បីលើកកម្ពស់ការយល់ដឹង និងលើកស្ទួយការប្រើប្រាស់ឯកសារណែនាំ និងឧបករណ៍ពាក់ព័ន្ធនានា។ ការិយាល័យ OHCHR បានផ្តល់ការលើកកម្ពស់ការយល់ដឹងអំពីគោលការណ៍ណែនាំ និងការត្រួតពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្សតាមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗគ្នា ដែលបានរៀបចំតែឯង ឬបានរៀបចំឡើងរួមគ្នាជាមួយដៃគូ រាប់ទាំងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ជាផ្នែកមួយនៃការផ្តល់ជំនួយមូលនិធិរបស់ការិយាល័យទៅមជ្ឈមណ្ឌលនោះ ដើម្បីធ្វើការរបស់វាលើធុរកិច្ច និងសិទ្ធិមនុស្ស។ ជាពិសេស ការិយាល័យ OHCHR បានរៀបចំឡើងនូវវគ្គផ្សព្វផ្សាយខ្លីមួយសម្រាប់ យុវជន ដែលរួមមានសហគ្រិនវ័យក្មេង អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ (Academia) និងអង្គការសង្គមស៊ីវិល នៅក្នុងខែ មិថុនា ឆ្នាំ២០១៨ ហើយបានធ្វើបាឋកថា (Lecture) មួយទៅដល់និស្សិតកម្មវិធីថ្នាក់អនុបណ្ឌិតនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។ នៅក្នុងខែឧសភា ឆ្នាំ២០១៩ ការិយាល័យ OHCHR បានរៀបចំឡើងនូវសិក្ខាសាលាចែករំលែកបទពិសោធន៍ស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស សម្រាប់ការប្រតិបត្តិការកសិ-ពាណិជ្ជកម្មនៅប្រទេសកម្ពុជា។ សិក្ខាសាលានេះ បានទាក់ទាញតំណាងធុរកិច្ចជិត ៤០ រូប មកពីក្រុមហ៊ុនអន្តរជាតិ ក្រុមហ៊ុនកម្ពុជា និងក្រុមហ៊ុនវៀតណាម និងមានគោលបំណងសម្របសម្រួលកិច្ចសហការបន្ថែមទៀតជាមួយធុរកិច្ចទាំងនោះ លើការអនុវត្តគោលការណ៍ណែនាំទាំងនេះ។

៦០. ការិយាល័យ OHCHR បានផ្តល់ជំនួយមូលនិធិ នៅក្នុងខែមីនា ឆ្នាំ២០១៩ ដល់អង្គការ PIN ដើម្បីបោះពុម្ពផ្សាយនូវការសិក្សាស្រាវជ្រាវមួយ ស្តីពី បទពិសោធន៍អំពើហិង្សាយែនឌ័រនៅក្នុងសហគមន៍ផ្ទះជួលនៅភ្នំពេញ។

## VI. ព័ត៌មាន និងទំនាក់ទំនងសិទ្ធិមនុស្ស

៦១. ការិយាល័យ OHCHR បានបន្តការងាររបស់ខ្លួន ខាងផ្សព្វផ្សាយ និងទំនាក់ទំនងយ៉ាងទូលំទូលាយដោយប្រើប្រាស់ទម្រង់ផ្សេងៗនៃប្រព័ន្ធផ្សព្វផ្សាយជាភាសាអង់គ្លេស និងភាសាខ្មែរ។ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យ OHCHR បានចែកចាយសៀវភៅបោះពុម្ពចំនួន ៦៧.៨៧១ ក្បាល ដល់ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត។ ការិយាល័យ OHCHR ប្រើហ្វេសប៊ុក និង ធ្វីតធ័រ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការអភិវឌ្ឍន៍សិទ្ធិមនុស្ស សកម្មភាពរបស់ការិយាល័យ OHCHR និងព័ត៌មានពីយន្តការសិទ្ធិ

មនុស្សអន្តរជាតិដែលពាក់ព័ន្ធនឹងប្រទេសកម្ពុជា។ ចាប់តាំងពីខែមករា ឆ្នាំ២០១៨ អ្នកតាមដានហ្វេសប៊ុករបស់ខ្លួន បានកើនឡើង មួយភាគបី រហូតដល់ ១៥.៩៧០ នាក់។

៦២. ការិយាល័យ OHCHR បានចាក់ផ្សាយវីដេអូចំនួន ៦ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីមាត្រាជាក់លាក់នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សជាភាសាខ្មែរ និងនិទានរឿងរបស់ប្រជាជនកម្ពុជា និងពីហេតុដែលសិទ្ធិទាំងនេះមានសារៈសំខាន់ចំពោះពួកគេ។ វីដេអូទាក់ទងនឹងការចាប់ខ្លួន និងការឃុំខ្លួនដោយបំពាន ការសន្មតថាគ្មានទោស សិទ្ធិទទួលបានសញ្ជាតិ សិទ្ធិទទួលបានការអប់រំ ភារកិច្ចដល់សហគមន៍ និងសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខ។[10] ការិយាល័យ OHCHR ក៏បានផលិតខ្សែវីដេអូ និងរឿងផលប្រយោជន៍របស់មនុស្សជាភាសាខ្មែរ និងអង់គ្លេសដែលបង្ហាញពីឥទ្ធិផលមួយចំនួននៃការងាររបស់ការិយាល័យរួមមាន "ការបង្ខំឱ្យផ្លាស់ទីលំនៅ៖ រឿងរ៉ាវនៃការតាំងទីលំនៅថ្មីនៅកម្ពុជា" "នៅទីបំផុតត្រូវដោះលែងឲ្យមានសេរីភាពឡើងវិញ៖ ការិយាល័យ OHCHR ប្រចាំកម្ពុជា បានគាំទ្រការដោះលែងមនុស្ស ១៣ នាក់ ដែលបានជាប់ឃុំហួសនីតិវិធីជាច្រើនឆ្នាំបន្ទាប់ពីពួកគេបានបម្រើទោសចប់" និង "មួយជំហានឆ្ពោះទៅមុខ៖ ដំណើរការទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិចនៅកម្ពុជា"។ [11] កម្មវិធីវិទ្យុសិទ្ធិមនុស្ស ៣៦៥ របស់ការិយាល័យ OHCHR គ្រប់គ្រងតាមរយៈមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ មានកម្មវិធីវិទ្យុអន្តរកម្មចំនួន ១៥ លើប្រធានបទផ្សេងៗជាច្រើនដែលមានវាគ្មិនមកពីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ធុរកិច្ច ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអ្នកជំនាញផ្សេងទៀត។ ការិយាល័យ OHCHR បានចូលរួមក្នុងកម្មវិធីវិទ្យុដែលរៀបចំដោយអង្គការដៃគូនានាផងដែរ។

៦៣. ការិយាល័យ OHCHR បានរំលឹកខួបទិវាអន្តរជាតិ និងទិវាអង្គការសហប្រជាជាតិសំខាន់ៗ រួមមាន ទិវាសិទ្ធិនារីអន្តរជាតិ ទិវាជនជាតិដើមភាគតិចពិភពលោក ទិវាអង្គការសហប្រជាជាតិ ទិវាសិទ្ធិមនុស្ស និងទិវាពលកម្មអន្តរជាតិ។ ផលិតផលនៃប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់ទិវាសិទ្ធិនារីអន្តរជាតិ ដែលផលិតក្នុងភាពជាដៃគូជាមួយក្រុមអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា បានផ្សព្វផ្សាយដល់អ្នកចូលមើលជាងមួយលាននាក់លើហ្វេសប៊ុក។

៦៤. ការិយាល័យ OHCHR រួមជាមួយក្រុមអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា បានបើកយុទ្ធនាការរយៈពេលបីខែ ដើម្បីអបអរសាទរខួបលើកទីចិតសិបនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ យុទ្ធនាការនេះ បានចាប់ផ្តើមនៅខែកញ្ញាឆ្នាំ ២០១៨ ហើយបានបន្តរហូតដល់ចុងខែធ្នូឆ្នាំ២០១៨ ហើយរួមបញ្ចូលកម្មវិធីអប់រំសិទ្ធិមនុស្សនៅតាមសាលារៀននៅខេត្តចំនួន៣ ឯកសារតាមអនឡាញ និងតាមអហ្វឡាញ និងព្រឹត្តិការណ៍អបអរសាទរដ៏ធំមួយ ដើម្បីប្រារព្ធទិវាសិទ្ធិមនុស្ស។ សារដ៏មានសារៈ

[10] សូមមើល https://bit.ly/2HIj4zK; https://bit.ly/2HI3eFF; https://bit.ly/2wsOunn; https://bit.ly/2Mg20pm; https://bit.ly/2K67254; និង https://bit.ly/2KbCdMe

[11] សូមមើល https://bit.ly/2Ubgrh6; https://bit.ly/2mF7sCt; និង https://bit.ly/2VTdCOA

# ឧបសម្ព័ន្ធទី១០ ៖
# របាយការណ៍ស្តីពីសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ២០២០
# នៃស្ថានទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា

# របាយការណ៍ស្តីពីសិទ្ធិមនុស្ស នៅកម្ពុជា ឆ្នាំ ២០២០

## សេចក្តីសង្ខេបរួម

ប្រទេសកម្ពុជាជាប្រទេសប្រកាន់របបរាជានិយមអាស្រ័យធម្មនុញ្ញ ដែលមានរដ្ឋាភិបាលមួយកើតចេញតាមរយៈការបោះឆ្នោតសភា ។ គណបក្សប្រជាជនកម្ពុជា (CPP) បានទទួលបានអាសនៈសភាទាំង ១២៥ នៅក្នុងការបោះឆ្នោតជាតិ ឆ្នាំ ២០១៨ ដោយបានហាមប្រាមគណបក្សប្រឆាំងធំជាងគេ កាលពីឆ្នាំ ២០១៧ ហើយធ្វើឲ្យប្រទេសស្ថិតនៅក្រោមការគ្រប់គ្រងនៃគណបក្សតែមួយ ក្នុងភាពជាក់ស្តែង។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកាន់តំណែងនេះតាំងពីឆ្នាំ ១៩៨៥ មក។ អ្នកសង្កេតការណ៍អន្តរជាតិ ដោយរួមទាំងរដ្ឋាភិបាលបរទេស និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងជាតិ បានរិះគន់ការបោះឆ្នោតនេះ ថាគ្មានភាពសេរី និងយុត្តិធម៌ ហើយមិនតំណាងអោយឆន្ទៈរបស់ប្រជាជនកម្ពុជាទេ។

នគរបាលជាតិរក្សាសន្តិសុខផ្ទៃក្នុង។ កងយោធពលខេមរភូមិន្ទទទួលខុសត្រូវលើសន្តិសុខខាងក្រៅ ហើយក៏មានការទទួលខុសត្រូវផ្នែកសន្តិសុខផ្ទៃក្នុងខ្លះដែរ។ នគរបាលជាតិស្ថិតនៅក្រោមក្រសួងមហាផ្ទៃ ចំណែកកងយោធពលខេមរភូមិន្ទស្ថិតនៅក្រោមក្រសួងការពារជាតិ។ អាជ្ញាធរស៊ីវិលគ្រប់គ្រងលើកងកម្លាំងសន្តិសុខ ដែលជាញឹកញាប់ គំរាមប្រើកំលាំងប្រឆាំងនឹងអ្នកដែលប្រឆាំងនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយជាទូទៅ ត្រូវបានគេមើលឃើញថា ជាសាខាប្រដាប់អាវុធរបស់គណបក្សគ្រប់គ្រងប្រទេស CPP ។ សមាជិកកម្លាំងសន្តិសុខបានប្រព្រឹត្តល្មើសខ្លះៗ។

បញ្ហាផ្នែកសិទ្ធិមនុស្សសំខាន់ៗរួមមានការធ្វើទារុណកម្មដោយរដ្ឋាភិបាល ការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តទៅលើដ៏ឃោរឃៅ អមនុស្សធម៌ ឬដែលធ្វើឲ្យបាក់មុខ ដោយរដ្ឋាភិបាល ការឃុំខ្លួនតាមអំពើចិត្តដោយរដ្ឋាភិបាល អ្នកជាប់ឃុំឬអ្នកទោសនយោបាយ ការគ្មានតុលាការឯករាជ្យ ការជ្រៀតជ្រែកតាមអំពើចិត្តនៅក្នុងជីវិតឯកជនរបស់ពលរដ្ឋ រួមទាំងការលួចស្តាប់តាមប្រព័ន្ធអេឡិចត្រូនិចជាទូទៅ ការរឹតត្បិតធ្ងន់ធ្ងរលើសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងអ៊ិនធ័រណែត រួមទាំងការប្រើហឹង្សា ឬការគម្រាមប្រើហឹង្សា ការចាប់ខ្លួន ឬកាត់ទោសអ្នកសារព័ត៌មានដោយគ្មានហេតុផលត្រឹមត្រូវ ការចាប់ពិរុទ្ធ ការបិទគេហទំព័រ ការអនុវត្តច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងការបរិហារកេរ្តិ៍ ច្បាប់រឹតត្បិតលើអង្គការមិនមែនរដ្ឋាភិបាល (NGO) ការជ្រៀតជ្រែកនៅក្នុងសិទ្ធិធ្វើការប្រមូលផ្តុំដោយសន្តិភាព និងសេរីភាពក្នុងការចងក្រងគ្នាជាក្រុម សមាគម ការរឹតត្បិតខ្លាំងលើការចូលរួមទាក់ទងនឹងនយោបាយ ការកាត់បន្ថយលទ្ធភាពសម្រាប់ឲ្យពលរដ្ឋធ្វើការផ្លាស់ប្តូររដ្ឋាភិបាលដោយសន្តិភាព តាមរយៈការបោះឆ្នោតដោយសេរី និងយុត្តិធម៌ អំពើពុករលួយជាទូទៅ ដូចជានៅក្នុងប្រព័ន្ធតុលាការ កង្វះការស៊ើបអង្កេត និងតម្លាភាពចំពោះអំពើហឹង្សាទៅលើស្ត្រី ការជួញដូរមនុស្ស និងទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ដូចជាការបង្ខំឲ្យកុមារធ្វើពលកម្ម។

វប្បធម៌និទណ្ឌភាពជាទូទៅនៅតែមាន។ មានសេចក្តីរាយការណ៍ដែលគួរឲ្យទុកចិត្តមកថា មន្ត្រីរដ្ឋាភិបាល រួមទាំងនគរបាលផង បានប្រព្រឹត្តបទរំលោភដោយមាននិទណ្ឌភាព ហើយក្នុងករណីភាគច្រើន រដ្ឋាភិបាលអន្តរាគមតិចតួច ឬមិនធ្វើអន្តរាគមសោះ។ មន្ត្រីរដ្ឋាភិបាល និងសមាជិកគ្រួសាររបស់គេ ជាទូទៅ គេចផុតពីការកាត់ទោស។

## ផ្នែកទី១ ៖ ការគោរពភាពថ្លៃថ្នូររបស់មនុស្ស រួមទាំងសេរីភាពរួចផុតពី ៖

### ក. ការដកហូតជីវិតតាមអំពើចិត្ត និងការសំលាប់ដោយសារហេតុផលនយោបាយ ឬដោយខុសច្បាប់

យ៉ាងហោចណាស់មានសេចក្តីរាយការណ៍មួយថា រដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋាភិបាលបានធ្វើការសម្លាប់មនុស្សតាមអំពើចិត្ត ឬដោយខុសច្បាប់។ នៅថ្ងៃទី ១ មករា ទុយ ស្រស់ ដែលជាមនុស្សម្នាក់ក្នុងចំណោមមនុស្សចំនួន ៥ នាក់ ដែលត្រូវបានចាប់ខ្លួន ក្នុងជម្លោះដីធ្លី នៅខេត្តបន្ទាយមានជ័យ បានស្លាប់នៅកន្លែងឃុំឃាំងរបស់នគរបាល។ ពីរនាក់ទៀត ដែលត្រូវបានចាប់ខ្លួនជាមួយគាត់ បាននិយាយថា កងរាជអាវុធហត្ថបានវាយស្រស់ឲ្យសន្លប់ ហើយមិនព្រមយកទៅព្យាបាល។ បន្ទាប់ពីកាសែតចុះព្រោងព្រាត លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានបញ្ជាឲ្យធ្វើការស៊ើបអង្កេត ហើយមន្ត្រីនគរបាល ២ នាក់ត្រូវបានចាប់ខ្លួន។

### ខ. ការបាត់ខ្លួន

សាក្សីបាននិយាយថា នៅថ្ងៃទី ៤ ខែមិថុនា ជនប្រដាប់អាវុធមួយក្រុមបានចាប់ជំរិតសកម្មជនគាំទ្រប្រជាធិបតេយ្យថៃម្នាក់ ឈ្មោះ Wanchalearm Satsaksit នៅក្រៅអាគារស្នាក់នៅរបស់គាត់ ក្នុងក្រុងភ្នំពេញ នៅកណ្តាលថ្ងៃ។ អង្គការ NGO ផ្នែកសិទ្ធិមនុស្សមួយចំនួនបានចោទប្រកាន់រដ្ឋាភិបាលកម្ពុជាថា មិនបានខិតខំធ្វើការស៊ើបអង្កេតការបាត់ខ្លួនរបស់គាត់ទេ ហើយបានចោទថា អាជ្ញាធរថៃ និងអាជ្ញាធរកម្ពុជាបានឃុបឃិតគ្នា ក្នុងករណីនេះ។ ពីដំបូង អាជ្ញាធរបានបដិសេធជាសាធារណៈ ដោយនិយាយថា គ្មានការចាប់ជំរិតទេ ដោយអះអាងថា កំណត់ហេតុផ្លូវការបានបង្ហាញថា Wanchalearm បានចាកចេញពីប្រទេស កាលពី ៣ ឆ្នាំមុន។ នៅថ្ងៃទី ៩ មិថុនា រដ្ឋាភិបាលបានធ្វើការស៊ើបអង្កេតករណីនេះ បន្ទាប់ពីតាមសេចក្តីរាយការណ៍មកថា ស្ថានទូតថៃបានស្នើ។ នៅដំណាច់ឆ្នាំ ការស៊ើបអង្កេតរបស់នគរបាលកម្ពុជាមិនបានរកឃើញជនសង្ស័យ មូលហេតុ ឬទីកន្លែងដែលគាត់ស្ថិតនៅទេ។ អ្នកនាំពាក្យនៃឧត្តមស្នងការសិទ្ធិមនុស្សរបស់សហប្រជាជាតិនៅកម្ពុជា បានសម្តែងកង្វល់ថា ហេតុការណ៍នោះ "ប្រហែលអាចជាការបាត់ខ្លួនទាំងបង្ខំ"។ គិតមកត្រឹមខែវិច្ឆិកា ក្រុមការងាររបស់ UN ស្តីពីការបាត់ខ្លួនដោយការបង្ខំ ឬដោយស្ម័គ្រចិត្ត បានធ្វើការស៊ើបអង្កេត។

### គ. ការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មបន្ទាបបន្ថោក អមនុស្សធម៌ ឬឃោរឃៅដទៃទៀត

រដ្ឋធម្មនុញ្ញហាមប្រាមទង្វើបែបនេះ តែការវាយដំ និងទំរង់ដទៃទៀតនៃការធ្វើបាបលើរូបរាងកាយទៅលើអ្នកជាប់ឃុំរបស់នគរបាល និងអ្នកជាប់ពន្ធនាគារនៅតែមានជាបន្ត នៅក្នុងឆ្នាំនៃរបាយការណ៍។

មានរបាយការណ៍ដែលអាចទុកចិត្តបានថា យោធា និងនគរបាលស៊ីវិលបានធ្វើទារុណកម្មលើរាងកាយ និងផ្លូវចិត្ត ហើយមានពេលខ្លះ វាយដំយ៉ាងធ្ងន់ធ្ងរទៅលើជនដែលត្រូវឃុំខ្លួនដោយសារបទព្រហ្មទណ្ឌទៀតផង ជាពិសេសនៅអំឡុងពេលសួរចម្លើយ ។ នៅថ្ងៃទី ៨ ខែឧសភា ម្តាយមីងរបស់ឈ្មោះ ទិត រ៉ន បានអះអាងថា បានធ្វើទារុណកម្ម និងសម្លាប់ក្មួយគាត់ និងថា ខ្លួនរបស់ក្មួយគាត់មានស្នាមជាំ ពេលគាត់យកមក។ នៅក្នុងរបាយការណ៍ចេញនៅខែឧសភា អង្គការលើកលែងទោសអន្តរជាតិ Amnesty International បានសរសេរថា អាជ្ញាធរ "តែងតែធ្វើទារុណកម្ម និងការធ្វើបាបក្នុងទម្រង់ផ្សេងទៀត" ជាផ្នែកមួយនៃយុទ្ធនាការរបស់ប្រទេស ស្តីពី "សង្គ្រាមប្រឆាំងគ្រឿងញៀន" ។ បើយោងតាមសាក្សី ទុយ ស្រស់ ដែលជាសកម្មជនដីធ្លី បានរងការធ្វើទារុណកម្ម មុនពេលស្លាប់ (សូមមើលផ្នែក ១ក)។

ថ្វីបើច្បាប់តម្រូវឲ្យនគរបាល ព្រះរាជអាជ្ញា និងចៅក្រមធ្វើការស៊ើបអង្កេតបណ្តឹងទាំងអស់ រួមទាំងបណ្តឹងទាក់ទងនឹងបទរំលោភដោយនគរបាល តែតាមពិត មន្ត្រីរដ្ឋាភិបាល និងសមាជិកគ្រួសារមាននិទណ្ឌភាពពីបទរំលោភសិទ្ធិមនុស្ស។ ចៅក្រម និងព្រះរាជអាជ្ញាកម្រធ្វើការស៊ើបអង្កេតដោយឯករាជ្យណាស់។ថ្វីបើច្បាប់អនុញ្ញាតឲ្យមានការស៊ើបអង្កេតលើបទចោទស្តីពីការរំលោភដោយរដ្ឋាភិបាលក្តី តែតាមភាពជាក់ស្តែង គេពិនិត្យករណីបែបនោះតែក្នុងករណីដែលសាធារណជនរិះគន់ខ្លាំង ឬមានការចាប់អារម្មណ៍ពីនាយករដ្ឋមន្ត្រីតែប៉ុណ្ណោះ។ បើករណីរំលោភធ្លាក់ដល់សវនាការ ចៅក្រមកាត់ក្តីច្រើនតែចេញសាលក្រមដោយផ្អែកតែលើរបាយការណ៍ផ្ញើមករបស់នគរបាល និងការឆ្លើយរបស់សាក្សី។ ជាទូទៅ នគរបាលទទួលបានការបណ្តុះបណ្តាលជំនាញតិចតួច លើការការពារ ឬគោរពសិទ្ធិមនុស្ស។

## ស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំខ្លួន

ស្ថានភាពពន្ធនាគារមានសភាពយ៉ាប់ខ្លាំង ហើយក្នុងករណីជាច្រើន គម្រាមកំហែងដល់អាយុជីវិតថែមទៀតផង ។

**ទិដ្ឋភាពទីកន្លែង៖** ការមានអ្នកទោសកកកុញច្រើនគឺជាបញ្ហាមួយ។ យោងតាមក្រសួងមហាផ្ទៃ គិតត្រឹមខែមេសា មានអ្នកទោស និងអ្នកជាប់ពន្ធនាគារ ចំនួនប្រមាណជាង ៣៩ ០០០ នាក់ នៅក្នុងពន្ធនាគារចំនួន ២៩ ដែលត្រូវបានបង្កើតឡើងសំរាប់ដាក់អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំត្រឹមតែចំនួន ១១ ០០០ នាក់ប៉ុណ្ណោះ ។ មន្ត្រីផ្នែកពន្ធនាគារបាននិយាយថា "សង្គ្រាមប្រឆាំងនឹងគ្រឿងញៀន" របស់រដ្ឋាភិបាលបានធ្វើអោយពន្ធនាគារកាន់តែចង្អៀតខ្លាំងឡើង ដោយមានអ្នកទោសគ្រឿងញៀនប្រមាណ ២២ ០០០ នាក់។

នៅក្នុងពន្ធនាគារភាគច្រើន គ្មានការដាក់អោយនៅដាច់ពីគ្នាទេ រវាងអ្នកទោសជាមនុស្សពេញវ័យ និងអ្នកទោសជាកុមារ (រួមទាំងកុមារដែលរស់នៅជាមួយម្តាយជាអ្នកទោស) រវាងអ្នកទោសធ្ងន់ និងអ្នកទោសស្រាល ឬសំរាប់ការឃុំមុនសវនាការទេ។ បើយោងតាម NGO ដោយគិតមកត្រឹមខែមករា មានអ្នកទោសជាស្ត្រីមានផ្ទៃពោះចំនួន ៤៣ នាក់ ហើយមានកូនចំនួន ១០៣ នាក់រស់នៅជាមួយម្តាយ។ នាយកដ្ឋានពន្ធនាគារមិនបានរាយការណ៍ពីចំនួន

អ្នកទោសស្លាប់ ក្នុងពន្ធនាគារទេ។ នៅខែកុម្ភៈ ទារកអាយុ ៥ ខែម្នាក់ ដែលរស់នៅជាមួយម្តាយក្នុងពន្ធនាគារ បានស្លាប់។តុលាការបានបញ្ជូនម្តាយកុមារនេះ ដែលកាលនោះ មានផ្ទៃពោះ ៨ ខែ ទៅកន្លែងឃុំឃាំង នៅខែមិថុនា ឆ្នាំ ២០១៩ ពីបទមានគ្រឿងញៀនបន្តិចបន្តួចជាប់ខ្លួន។ នាងកំពុងរង់ចាំសវនាការ នៅពេលទារកស្លាប់។

របបអាហារសម្រាប់អ្នកជាប់ពន្ធនាគារ និងរបស់ចាំបាច់ផ្សេងៗទៀត តែនៅតែមិនគ្រប់គ្រាន់ទេ។ ជាញឹកញាប់ សមាជិកគ្រួសារធ្វើការសូកប៉ាន់ខ្លះ ដើម្បីផ្តល់បន្ថែមដល់អ្នកទោស។ អ្នកសង្កេតការណ៍បានបន្តរាយការណ៍ថា របបសំរាប់ទិញអាហារសំរាប់អ្នកទោស ពេលខ្លះ ត្រូវបានកិបកេងយកដោយអាជ្ញាធរ ដែលជាការធ្វើអោយមានកង្វះអាហារូបត្ថម្ភកាន់តែខ្លាំង និងជំងឺអ្នកទោសមានកាន់តែច្រើន។ អាជ្ញាធរមិនបានផ្តល់តួលេខចុងក្រោយស្តីពីចំនួនពន្ធនាគារដែលក្នុងនោះអ្នកទោសមានទឹកស្អាតប្រើប្រាស់ទេ ថ្វីបើ គិតមកដល់ឆ្នាំ ២០១៦ មានពន្ធនាគារតែចំនួន ១៨ ទេ ក្នុងចំណោមពន្ធនាគារចំនួន ២៩ មានផ្តល់ទឹកស្អាត។ អង្គការមិនមែនរដ្ឋាភិបាលបានចោទប្រកាន់ថា អ្នកគ្រប់គ្រងពន្ធនាគារប្រព្រឹត្តមិនស្មើគ្នាលើអ្នកទោស ដូចជាករណីផ្តល់ការអនុញ្ញាតអោយអ្នកចូលសួរសុខទុក្ខ ការប្តូរទៅបន្ទប់ល្អ និងឱកាសចេញពីបន្ទប់ នៅពេលថ្ងៃ សំរាប់អ្នកទោសដែលគ្រួសាររបស់គេមានលុយសូក។ បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលខ្មែរមួយ មានក្រុមអ្នកទោសដែលត្រូវបានចងក្រង និងដឹកនាំដោយឆ្មាំគុក ពេលខ្លះ ធ្វើការវាយដំលើអ្នកទោសដទៃទៀត។ NGO បានរាយការណ៍ថា មានការប្រើប្រាស់គ្រឿងញៀននៅក្នុងពន្ធនាគារយ៉ាងច្រើន ដែលគេអាចធ្វើទៅបានដោយសូកប៉ាន់មន្ត្រីពន្ធនាគារ។

កម្ពុជាមានមជ្ឈមណ្ឌលបន្សាបថ្នាំញៀនរបស់រដ្ឋាភិបាលចំនួន ៧ និងមាន៣ ទៀតជារបស់ឯកជន ។ អ្នកសង្កេតការភាគច្រើនបានយល់ស្របថា ភាគច្រើននៃអ្នកដែលត្រូវបានយកមកឃុំនៅទីនេះ គឺត្រូវបានឃុំដោយបង្ខំ ឬផ្ញើនៅមណ្ឌលដោយសមត្ថកិច្ច ឬសមាជិកគ្រួសារ ដោយគ្មានឆ្លងកាត់ដំណើរការក្តីត្រឹមត្រូវទេ។ យោងតាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គ្មានអ្នកដែលជាប់នៅក្នុងមណ្ឌលមានអាយុក្រោម ១៨ ឆ្នាំទេ។ អ្នកសង្កេតការណ៍បានកត់សំគាល់ឃើញថា បុគ្គលិកក្នុងមណ្ឌល ជាញឹកញាប់ ប្រើវិធីបង្ខំ ដើម្បី "គ្រប់គ្រង"ទៅលើអ្នកជាប់ក្នុងនោះ និងអោយហាត់ប្រាណយ៉ាងខ្លាំង ។

<u>រដ្ឋបាល</u>៖ អាជ្ញាធរមិនបានប្រើវិធីផ្សេងក្រៅពីការដាក់គុកទេ។ អ្នកទោសអាចដាក់បណ្តឹងស្តីពីការរំលោភបំពានទៅតុលាការ តាមរយៈមេធាវី តែអ្នកទោសមួយចំនួនធំគ្មានលទ្ធភាពរកមេធាវីតំណាងផ្លូវច្បាប់ឡើយ។ រដ្ឋាភិបាលបាននិយាយថា ខ្លួនបានស៊ើបអង្កេតលើពាក្យបណ្តឹង ហើយតាមមើលស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំឃាំង តាមរយៈអគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ដែលធ្វើរបាយការណ៍ប្រចាំឆមាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ អគ្គនាយកដ្ឋានពន្ធនាគារមិនបញ្ចេញរបាយការណ៍នេះទេ ទោះបីជាអង្គការសង្គមស៊ីវិលបានធ្វើការស្នើសុំជាញឹកញាប់ក្តី។

អ្នកទោស និងអ្នកជាប់ការឃុំឃាំងជាធម្មតា ត្រូវបានអនុញ្ញាតអោយជួបជាមួយអ្នកទៅមើល តែអង្គការសិទ្ធិមនុស្សបានអះអាងថា ពេលខ្លះ គ្រួសារត្រូវផ្តល់សំណូកដល់មន្ត្រីពន្ធនាគារដើម្បីបានសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ។ មានរបាយការណ៍គួរអោយជឿទុកចិត្តបានថា ជាញឹកញាប់ មន្ត្រីបានទាមទារប្រាក់សំណូក មុននឹងអនុញ្ញាតអោយអ្នកជាប់ពន្ធនាគារចូលរួមការជំនុំជម្រះក្តី ឬសវនាការឧទ្ធរណ៍ និងមុនពេលដោះលែងអ្នកជាប់ពន្ធនាគារដែលបានបញ្ចប់អាណត្តិជាប់ពន្ធនាគាររបស់ខ្លួនពេញលេញហើយនោះ ឬមុនពេលអនុញ្ញាតឲ្យគេចេញពីបន្ទប់ឃុំឃាំងរបស់គេ ។ NGO បាននិយាយពីការដាក់ទោសមិនស្មើគ្នា ក្នុងចំណោមអ្នកជាប់ឃុំ ដោយកត់សំគាល់ឃើញថា អ្នកទោសដែលមានលុយ ស្នាក់នៅបានស្រួលជាងអ្នកទោសគ្មានលុយ ហើយការរឹតត្បិតច្រើន ដូចជាការតាជានតឹងតែង និងការមិនអនុញ្ញាតឲ្យទទួលអំណោយពីអ្នកចូលសួរសុខទុកខ ត្រូវបានដាក់ទៅលើអ្នកទោសជាអ្នកធ្វើការការពារសិទ្ធិមនុស្ស។

<u>ការតាមដានដោយឯករាជ្យ៖</u> ដោយមានលក្ខខ័ណ្ឌជាមុន និងការដាក់កំហិត ជាទូទៅ រដ្ឋាភិបាលបន្តអនុញ្ញាតអោយក្រុមសិទ្ធិមនុស្សអន្តរជាតិ និងក្រុមសិទ្ធិមនុស្សក្នុងស្រុក ដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ចូលមើលពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ឆ្មាំពន្ធនាគារ ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា ជួនកាល ការសហការពីអាជ្ញាធរដែនដីនៅមានកម្រិត ដែលជាការធ្វើអោយមានការលំបាកសម្រាប់ចូលជួបអ្នកជាប់ឃុំដែលមិនទាន់ទទួលការជំនុំជម្រះក្តី ។

ក្រសួងមហាផ្ទៃតម្រូវអោយមេធាវី អ្នកត្រួតពិនិត្យសិទ្ធិមនុស្ស និងអ្នកសួរសុខទុក្ខដទៃទៀតសុំការអនុញ្ញាតមុននឹងចូលជួបអ្នកជាប់ពន្ធនាគារ ដោយច្រើនតែតម្រូវអោយសុំពីអង្គភាពច្រើនកន្លែង អាស្រ័យលើករណីមួយៗ ហើយក្នុងករណីខ្លះ រដ្ឋាភិបាលតំរូវអោយអង្គការមិនមែនរដ្ឋាភិបាលចុះហត្ថលេខាលើអនុស្សារណនៃការយោគយល់ជាផ្លូវការ ដោយបញ្ជាក់ពី "តួនាទី" របស់គេ ក្នុងពេលទៅមើលអ្នកទោស។

ថ្វីបើក្រុមមនុស្សក្នុងស្រុកដែលធ្វើការតាមដានដោយឯករាជ្យ អាចជួបជាលក្ខណៈឯកជនជាមួយអ្នកទោសក្តី តែអ្នកខ្លះក៏មិនអាចជួបបានទេ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយដែលជាធម្មតា ផ្តល់ការថែទាំសុខភាពដល់អ្នកទោស បាននិយាយថា ពេលខ្លះ រដ្ឋាភិបាលមិនអនុញ្ញាតអោយគេចូលមើលអ្នកទោសដែលកាត់ក្តីហើយ និងជាសមាជិកនៃគណបក្សប្រឆាំងឡើយ។ អង្គការ NGO មួយទៀតបាននិយាយថា រដ្ឋាភិបាលបានចោទខ្លួនថា មានគំនិតលំអៀងនយោបាយ ហើយប្រើការទៅមើលអ្នកទោសដើម្បីជំរុញអ្នកទោសនយោបាយអោយកាន់តែផ្តើនខ្លាំងឡើង។ តំណាងនៃការិយាល័យស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបាននិយាយថា ធម្មតា ខ្លួនអាចជួបជាលក្ខណៈឯកជននៅពេលសម្ភាសន៍អ្នកជាប់ពន្ធនាគារពិសេសណាម្នាក់។

### ឃ. ការចាប់ ឬឃុំខ្លួនតាមអំពើចិត្ត

ច្បាប់ហាមប្រាមការចាប់ឬឃុំខ្លួនតាមអំពើចិត្ត ហើយកំរិតការឃុំខ្លួនមុនសវនាការតែត្រឹម ១៨ ខែ តែពេលខ្លះ រដ្ឋាភិបាលមិនបានគោរពបំរាមទាំងនេះទេ ដូចជាបានធ្វើការឃុំខ្លួនតាមអំពើចិត្តលើអតីតប្រធានគណបក្សសង្គ្រោះជាតិ កឹម សុខា ហួសពីព្រំដែនច្បាប់កំណត់។ កឹមមកត្រឹមខែវិច្ឆិកា ឆ្នាំ ២០១៩ លោក កឹម សុខាបានចំណាយពេល ២៦ ខែ នៅក្នុងការឃុំខ្លួនមុនសវនាការ មុនពេលសវនាការដកកំហិតមួយផ្នែក ដោយបានដោះលែងគាត់ពីការឃុំខ្លួននៅក្នុងផ្ទះ តែមិនអនុញ្ញាតឲ្យគាត់ធ្វើដំណើរទៅបរទេស ឬធ្វើសកម្មភាពនយោបាយឡើយ។ លើសពីនេះទៀត នៅតែមានការចោទនៅឡើយពីបទក្បត់ជាតិ ហើយគាត់នៅតែស្ថិតនៅក្រោមការតាមដានរបស់តុលាការ។

## នីតិវិធីចាប់ខ្លួន និងការប្រព្រឹត្តទៅលើអ្នកជាប់ឃុំ

ច្បាប់តម្រូវអោយនគរបាលសុំដីកាពីចៅក្រមស៊ើបអង្កេត មុនធ្វើការចាប់ខ្លួន ប៉ុន្តែនគរបាលអាចចាប់ខ្លួនដោយគ្មានដីកាចំពោះជនណាដែលត្រូវបានប្រទះឃើញកំពុងប្រព្រឹត្តបទល្មើស ។ ច្បាប់អនុញ្ញាតអោយនគរបាលឃាត់ខ្លួនបុគ្គលណាម្នាក់ រួចធ្វើការស៊ើបអង្កេតក្នុងរយៈពេល៤៨ម៉ោង ដោយមិនរាប់បញ្ចូលពេលចុងសប្ដាហ៍ និងថ្ងៃឈប់សម្រាកផ្លូវការ មុននឹងធ្វើការចោទប្រកាន់ ឬជនសង្ស័យត្រូវបានដោះលែង ។ ក្នុងករណីបទឧក្រិដ្ឋក្នុងស្ថានភាពពិសេសដែលចែងដោយច្បាប់ នគរបាលអាចឃុំខ្លួនជនសង្ស័យរយៈពេល ២៤ ម៉ោងបន្ថែម ដោយមានការឯកភាពពីព្រះរាជអាជ្ញា ។ ទោះជាយ៉ាងនេះក្តី ជាទម្លាប់ អាជ្ញាធតែងតែឃុំខ្លួនមនុស្សហួសរយៈពេលកំណត់ មុននឹងធ្វើការចោទប្រកាន់ ។

មានវិធីនៃការធានាអោយនៅក្រៅឃុំ តែអ្នកជាប់ពន្ធនាគារជាច្រើន ជាពិសេសអ្នកដែលគ្មានតំណាងផ្នែកច្បាប់ ឬមេធាវី គ្មានឱកាសស្វែងរកការដោះលែងដោយការធានាអោយនៅក្រៅឃុំឡើយ ។ ជាធម្មតា សេចក្តីស្នើអោយនៅក្រៅឃុំត្រូវបានបដិសេធចំពោះករណីដែលត្រូវបានចាត់ទុកថា បណ្តាលមកពីហេតុផលនយោបាយ ដែលមានភាពរសើប។

<u>ការចាប់ខ្លួនតាមអំពើចិត្ត</u>៖ គិតមកដល់ខែកក្កដា អង្គការសិទ្ធិមនុស្សក្នុងស្រុកមួយ បាននិយាយថា មានករណីចាប់ខ្លួនតាមអំពើចិត្តចំនួនយ៉ាងហោចណាស់ ១៦ នាក់ ។ ចំនួននៃការចាប់ខ្លួននិងឃុំខ្លួនតាមអំពើចិត្តទំនងជាមានច្រើនជាងនេះ ពីព្រោះជនរងគ្រោះនៅតាមតំបន់ជនបទមិនប្តឹង ដោយសារមានការពិបាកធ្វើដំណើរមកការិយាល័យរបស់អង្គការ ឬមានកង្វល់ពីសុវត្ថិភាពនៃគ្រួសាររបស់គេ។ អាជ្ញាធរមិនបានចាត់វិធានដាក់ទណ្ឌកម្ម ឬវិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះការឃុំខ្លួនគេដោយខុសច្បាប់ទេ។

នៅថ្ងៃទី ២ ខែមិថុនា អាជ្ញាធរខេត្តកោះកុងបានចាប់យកកង់របស់សកម្មជនជិះកង់ចំនួន ១៨ នាក់ ហើយបានឃាត់ពួកគេមិនឲ្យធ្វើដំណើរបន្តទៀត បន្ទាប់ពីពួកគេបានផ្តើមដំណើរជិះកង់មកភ្នំពេញ ដើម្បីទាញការចាប់អារម្មណ៍លើបញ្ហាបរិស្ថានក្នុងមូលដ្ឋាន។ ដំបូង អាជ្ញាធរអះអាងថា គេត្រូវត្រួតពិនិត្យក្រែងក្រុមនោះមានមេរោគកូវីដ ១៩ តែបន្ទាប់ពីយកសំណាកពីច្រមុះរួច អាជ្ញាធរបានរឹបអូសយកកង់របស់គេ រហូតទាល់តែសកម្មជនទាំងនោះ

ព្រមបញ្ឈប់ផែនការរបស់គេ ជាជាងប្រឈមនឹងការចាប់ខ្លួនពីបទ "ញុះញង់"។ អង្គការ NGO ក្នុងស្រុក ដែលធ្វើការផ្នែកសិទ្ធិមនុស្សបានរៀបរាប់ពីសកម្មភាពរបស់អាជ្ញាធរថា មានហេតុផលនយោបាយ ដោយគូសបញ្ជាក់ថា ក្រុមនោះគ្មានបានប្រព្រឹត្តខុសច្បាប់ទេ។

ក្រសួងសង្គមកិច្ច និងបណ្តុះបណ្តាលវិជ្ជាជីវៈបាននិយាយថា នៅឆ្នាំ ២០១៩ អាជ្ញាធរបានប្រមូលមនុស្សគ្មានផ្ទះសម្បែង អ្នកសុំទាន មនុស្សឡប់សតិ និងអ្នករកស៊ីផ្លូវភេទចំនួន១០០០ នាក់ ។ អាជ្ញាធរបានដាក់ពួកគេក្នុងមណ្ឌលសង្គមកិច្ច ដោយគ្មានផ្តល់ការព្យាបាលជំងឺឬស្បៀងអាហារគ្រប់គ្រាន់ទេ។ នៅខែមេសា ក្រសួងបានទទួលស្គាល់ថាខ្លួនមិនអាចព្យាបាល ឬបញ្ចូលពួកគេឲ្យទៅរស់នៅក្នុងសង្គមជាតិជាធម្មតាបានឡើយ។

<u>ការឃុំខ្លួនមុនសវនាការ</u>៖ តាមច្បាប់ ជនជាប់ចោទអាចត្រូវបានចាប់ខ្លួន និងឃុំខ្លួនរហូតដល់រយៈ ពេល ២៤ម៉ោងមុននឹងអាចមានមេធាវី ប៉ុន្តែអ្នកជាប់ពន្ធនាគារ ជាធម្មតា ត្រូវជាប់ឃុំជាច្រើនថ្ងៃ មុននឹងអាចជួបមេធាវី ឬជួបសមាជិកគ្រួសារ ។ យោងតាមមន្ត្រីរដ្ឋាភិបាល ការឃុំខ្លួនយូរបែបនេះ ភាគច្រើនបណ្តាលមកពីសមត្ថភាពមានកម្រិតរបស់ប្រព័ន្ធតុលាការ ។ ច្បាប់អនុញ្ញាតអោយមានការឃុំខ្លួនមុនសវនាការរហូតដល់រយៈពេល ៦ ខែ ចំពោះបទល្មើសមជ្ឈិម និង ១៨ ខែ ចំពោះបទឧក្រិដ្ឋ។ តែអង្គការមិនមែនរដ្ឋាភិបាលបាននិយាយថា អាជ្ញាធរឃុំអ្នកដែលត្រូវបានចោទខ្លះ មុនសវនាការ លើសរយៈពេលអតិបរិមាដែលកំណត់ដោយច្បាប់។ ពេលខ្លះ អាជ្ញាធរឃុំមនុស្សមុនសវនាការដោយគ្មានតំណាងផ្នែកច្បាប់។ នៅខែមេសា ក្រសួងមហាផ្ទៃបាននិយាយថា បានឃុំមនុស្សមុនសវនាការចំនួន ១៣ ៧២៩ នាក់ ដែលត្រូវជាចំនួនប្រហែល ១ ភាគ ៣ នៃអ្នកទោសទាំងអស់ក្នុងពន្ធនាគារ។

<u>លទ្ធភាពរបស់អ្នកជាប់ឃុំក្នុងការចោទសួរពីភាពស្របច្បាប់នៃការឃុំខ្លួនមុនចូលតុលាការ</u>៖ សំណុំរឿងនៅគរមិនទាន់ចាត់ការ និងការពន្យារពេលយូរក្នុងការទទួលបានសាលដីកាប៉ះពាល់ដល់សិទ្ធិក្នុងការធ្វើការតតាំងនៅក្នុងតុលាការប្រឆាំងនឹងមូលដ្ឋានច្បាប់ ឬលក្ខណៈធ្វើតែតាមទំនើងចិត្តនៃការឃុំខ្លួនមនុស្ស។ នៅថ្ងៃទី ១៨ ខែឧសភា ក្រសួងយុត្តិធម៌បានផ្តើមយុទ្ធនាការដែលមានរយៈពេល ៦ ខែ ដើម្បីដោះស្រាយការកកស្ទះនៃសំណុំរឿងចំនួនជិត ៤ ម៉ឺន នៅទូទាំងប្រទេស។

## ង. ការបដិសេធមិនអោយទទួលបានការជំនុំជម្រះក្តីជាសាធារណៈដោយយុត្តិធម៌

រដ្ឋធម្មនុញ្ញបានចែងថាតុលាការមានភាពឯករាជ្យ ប៉ុន្តែ រដ្ឋាភិបាល ជាទូទៅ មិនគោរពឯករាជ្យភាពរបស់តុលាការឡើយ ។ ការសំរេចរបស់តុលាការស្ថិតក្រោមឥទ្ធិពលរបស់អ្នកនយោបាយ។ មន្ត្រីតុលាការ ដែលមានរហូតដល់ប្រធានតុលាការ ច្រើនតែមានមុខតំណែងក្នុងពេលជាមួយគ្នា នៅក្នុងគណបក្សកាន់អំណាច ហើយអ្នកសង្កេតការណ៍បាននិយាយថា មានតែអ្នកដែលមានទំនាក់ទំនងជាមួយនឹងគណបក្សប្រជាជន ឬផ្នែកប្រតិបត្តិទេ ដែលបានទទួលមុខតំណែងក្នុងតុលាការ។ ជាញឹកញាប់ លទ្ធផលនៃសវនាការហាក់ត្រូវបានកំណត់ជាមុនស្រេច។ នៅក្នុងការបន្តសវនាការក្បត់ជាតិលើមេដឹកនាំគណបក្សប្រឆាំងនយោបាយ កឹម សុខា រដ្ឋាភិបាលបានចេញសេចក្តីថ្លែងដែលផ្ទុយគ្នា ដោយពេលខ្លះទទូចថា តុលាការកាត់សេចក្តីដោយឯករាជ្យ ហើយពេលខ្លះទៀត និយាយថា សវ

នាការលើរូបលោកនឹងមានបន្ត "រាប់ឆ្នាំ" ឬថា លទ្ធផលនឹងអាស្រ័យលើកត្តាដទៃទៀត ដូចជាការដកការអនុគ្រោះពន្ធមួយផ្នែករបស់សហភាពអឺរ៉ុប។

មានអំពើពុករលួយយ៉ាងរាលដាលក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ។ តុលាការគ្មានប្រសិទ្ធិភាព ហើយមិនអាចធានាដំណើរក្តីដោយយុត្តិធម៌ត្រឹមត្រូវបានទេ។

អ្នកសង្កេតការណ៍និយាយថា សមាគមមេធាវីជាតិលំអៀងយ៉ាងខ្លាំងទៅរកសមាជិកដែលមានខ្សែស្រឡាយជាមួយគណបក្សប្រជាជន នៅក្នុងការជ្រើសរើសសមាជិក។ ចំណែកមេធាវីមកពីគណបក្សប្រឆាំងឬក្រុមផ្សេងមិនសូវមានឱកាសទេ។ ពេលខ្លះ សមាគមជ្រើសយកអ្នកដែលគ្មានសមត្ថភាព ដោយសារតែខ្សែស្រឡាយនយោបាយ។ អ្នកវិភាគដោយមិនលំអៀងបានបង្ហាញអោយឃើញថា អ្នកដាក់ពាក្យចូលជាសមាជិកនៅក្នុងសមាគមនេះបានធ្វើការសូកប៉ាន់យ៉ាងច្រើន ដើម្បីបានចូល។ នៅថ្ងៃទី ១៦ ខែតុលា លី ចាន់ថុល ដែលជាអ្នកគាំទ្រនៃគណបក្សដឹកនាំប្រទេស ហើយដែលបានជួយធ្វើសេចក្តីព្រាងច្បាប់រំលាយគណបក្សសង្គ្រោះជាតិ បានជាប់ឆ្នោតជាប្រធាននៃសមាគមនេះ។

កង្វះចៅក្រម និងបន្ទប់តុលាការបានពន្យាករណីជាច្រើន។ អង្គការ NGO ក៏ជឿផងដែរថា មន្ត្រីតុលាការច្រើនផ្តោតលើករណីដែលក្នុងនោះ គេបានទទួលលុយ។ ការពន្យារពេលរបស់តុលាការ ឬអំពើពុករលួយរបស់តុលាការច្រើនតែធ្វើអោយជនរងការចោទប្រកាន់រួចផុតពីការកាត់ទោស។ មានការចោទថា ចុងចោទដែលមានទ្រព្យឬមានអំណាច រួមទាំងសមាជិកនៃកងកំលាំងសន្តិសុខផង តាមធម្មតា បង់លុយអោយជនរងគ្រោះ និងអាជ្ញាធរ ដើម្បីអោយទំលាក់ការចោទប្រកាន់ព្រហ្មទណ្ឌ។ ការចោទនេះត្រូវបានបញ្ជាក់ដោយរបាយការណ៍របស់ NGO និងករណីដែលចុងចោទជាអ្នកមានទ្រព្យត្រូវបានគេឃើញមានសេរីភាពដើរហើរពេញលេញ បន្ទាប់ពីមានការចុះផ្សាយក្នុងសារព័ត៌មានអំពីការចាប់ខ្លួនពួកគេ ហើយក្រោយមក គេមិនឃើញសេចក្តីរាយការណ៍បន្ថែមពីការកាត់ក្តី ឬលទ្ធផលចុងក្រោយនៃករណីទាំងនោះ។ ពេលខ្លះ អាជ្ញាធរបានតឿនអោយជនរងគ្រោះ ឬគ្រួសាររបស់គេទទួលយកនូវសំណងប៉ះប៉ូវជាលុយកាក់ ជាថ្នូរនឹងការទំលាក់ចោលការចោទប្រកាន់ព្រហ្មទណ្ឌ ឬការមិនបង្ហាញមុខជាសាក្សី។

**នីតិវិធីជំនុំជម្រះក្តី**

ច្បាប់ចែងពីសិទ្ធិក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងជាសាធារណៈ តែតុលាការកម្រអនុវត្តច្បាប់លើសិទ្ធិនេះណាស់។

តាមច្បាប់ គេត្រូវប្រាប់ចុងចោទពីបទចោទប្រកាន់ទៅលើពួកគេ មានសិទ្ធិត្រូវបានគេសន្មតថា ជាជនស្លូតត្រង់នៅមុនតុលាការរកឃើញកំហុស និងមានសិទ្ធិប្តឹងឧទ្ធរណ៍ តែជារឿយៗ ចុងចោទជ្រើសរើសយកការសូកប៉ាន់ជាជាងពឹងលើដំណើរការក្តី ។ សវនាការមិនត្រូវបានធ្វើជាសាធារណៈគ្រប់ពេលទេ ហើយច្រើនតែត្រូវបានពន្យារពេល ដោយសារការិយាធិបតេយ្យក្នុងតុលាការ។ ចុងចោទមានសិទ្ធិបង្ហាញវត្តមាន ហើយពិគ្រោះយោបល់ជាមួយ

មេធាវី ប្រឈម និងចោទសួរសាក្សីប្រឆាំងនឹងខ្លួន ហើយបង្ហាញសាក្សី និងភស្តុតាងដោយខ្លួនគេ។ តុលាការអាចបើកសវនាការ និងដាក់ទោសលើជនសង្ស័យបានដោយកំបាំងមុខ តាមការអនុញ្ញាតដោយច្បាប់។ ក្នុងករណីព្រហ្មទណ្ឌ ប្រសិនបើចុងចោទគ្មានប្រាក់រកមេធាវីម្នាក់បាន តុលាការត្រូវផ្តល់តំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ចុងចោទ ។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ តុលាការតែងតែខ្វះធនធានដើម្បីផ្តល់ប្រឹក្សាផ្នែកច្បាប់ ហើយចុងចោទភាគច្រើនស្វះស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬត្រូវឡើងតុលាការដោយគ្មានតំណាងផ្នែកច្បាប់ ។ នៅក្នុងករណីគ្មានមេធាវីការពារចុងចោទក្នុងរឿងព្រហ្មទណ្ឌ តុលាការពន្យារករណីរហូតទាល់តែមេធាវីត្រូវបានរកបាន ហើយករណីបែបនេះច្រើនតែស៊ីពេលរាប់ខែ។ ការជំនុំជម្រះក្តីច្រើនតែធ្វើឡើងគ្រាន់តែបង្គ្រប់កិច្ច ហើយការសួរដេញដោលច្រើនដោយភាគីម្ខាងទៅភាគីម្ខាង ជាធម្មតា មិនបានកើតមានឡើយ ។ NGO និយាយថា សេចក្តីប្រកាសជាលាយលក្ខអក្សររបស់សាក្សី និងរបស់ជនរងការចោទ ច្រើនតែត្រូវបានគេយកធ្វើជាភស្តុតាងតែមួយគត់នៅក្នុងសវនាការ។ តុលាការផ្តល់សេវាបកប្រែដោយមិនគិតថ្លៃ។

មានការខ្វះមេធាវីច្រើនដែលមានជំនាញត្រឹមត្រូវ ពិសេសនៅក្រៅក្រុងភ្នំពេញ។ អ្នកដែលគ្មានធនធានសំរាប់រកមេធាវី បាត់បង់សិទ្ធិទទួលបានការកាត់ក្តីដែលបើកចំហជាសាធារណៈ និងដោយយុត្តិធម៌។ របាយការណ៍របស់អង្គការ International Commission of Jurists អោយដឹងថា ការត្រូវធ្វើការសូកប៉ាន់ច្រើនដើម្បីបានចូលជាសមាជិកនៃសមាគមមេធាវីធ្វើអោយមេធាវីដែលមានជំនាញ មានចំនួនតិច ដែលជាការធ្វើអោយមេធាវីបច្ចុប្បន្នមានឱកាសគ្រប់គ្រាន់ក្នុងការទទួលបានចំណូលច្រើន តាមរយៈមធ្យោបាយស្របច្បាប់ ឬមិនស្របច្បាប់។ ពេលខ្លះ អាជ្ញាធរបង្ខំអោយសារភាព ដោយការវាយដំ ឬការគំរាមកំហែង ហើយចុងចោទដែលមិនចេះអក្សរ ជាញឹកញាប់ មិនត្រូវបានប្រាប់ពីសេចក្តីនៅក្នុងចំលើយសារភាព ដែលគេត្រូវបានបង្ខំអោយចុះហត្ថលេខាទៅលើនោះទេ។ តុលាការទទួលយកការសារភាពដោយបង្ខំបែបនេះ យកធ្វើជាភស្តុតាង នៅក្នុងសវនាការ ទោះបីជាមានច្បាប់ហាមការធ្វើដូច្នេះក្តី។ បើយោងតាមអង្គការ NGO ផ្នែកសិទ្ធិមនុស្សមួយ ដែលធ្វើការសង្កេតលើសាលាឧទ្ធរណ៍ ក្នុងពេលចន្លោះពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៨ ចុងចោទចំនួន ១០ នាក់បានរងការគម្រាមកំហែង ហើយចុងចោទចំនួន ២១ នាក់ត្រូវបានគេធ្វើទារុណកម្មអោយឆ្លើយសារភាព។ មានតែសាលាឧទ្ធរណ៍មួយតែប៉ុណ្ណោះ នៅភ្នំពេញ ហើយដោយសារការពិបាកនៅក្នុងការដឹកអ្នកទោសពីពន្ធនាគារខេត្តមកសាលាឧទ្ធរណ៍នៅភ្នំពេញ ចុងចោទមានវត្តមានតែនៅក្នុងតិចជាងពាក់កណ្តាលនៃសវនាការឧទ្ធរណ៍តែប៉ុណ្ណោះ ។

## អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារមូលហេតុនយោបាយ

គិតត្រឹមខែសីហា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្នែកសិទ្ធិមនុស្សមួយបានប៉ាន់ប្រមាណថា អាជ្ញាធរបានឃុំខ្លួនអ្នកទោសនយោបាយចំនួនយ៉ាងតិច ៤០ នាក់ ដោយក្នុងចំណោមនោះ មាន ២៣ គឺជាមន្ត្រី ឬអ្នកគាំទ្រគណបក្សប្រឆាំង CNRPដែលត្រូវបានរំលាយ។ អ្នកគាំទ្រនិងសកម្មជនគណបក្សប្រឆាំងចំនួនជាង ៨០ នាក់ ដែលត្រូវបានចាប់ខ្លួននៅឆ្នាំ ២០១៩ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ពីបទចោទដែលមិនទាន់បានកាត់ក្តីនៅឡើយ ហើយអាចប្រឈមនឹងការចាប់ខ្លួនឡើងវិញ នៅគ្រប់ពេល។

នៅថ្ងៃទី ១៥ ខែមករា សនាការលើប្រធានគណបក្ស CNRP គឺលោកកឹម សុខា បានចាប់ផ្តើម។ ពីដំបូង មានអ្នកចូលរួមតិចតួច រួមទាំងអ្នកការទូតម្នាក់ និងអ្នកបកប្រែម្នាក់ពីស្ថានទូតនិមួយៗ ត្រូវបានអនុញ្ញាតឲ្យចូលសង្កេតការណ៍។ សវនាការលើលោក កឹម សុខាត្រូវបានផ្អាកដោយគ្មានកំណត់ពេល កាលពីខែមិនា ដោយសារកង្វល់លើមេរោគកូវីដ ១៩ ហើយបើគិតមកត្រឹមខែវិច្ឆិកា សវនាការនេះមិនទាន់បានបន្តនៅឡើយទេ។ នៅខែកក្កដា តុលាការបានគម្រាមលោក កឹម សុខាថា ដំណើររបស់លោកទៅតាមខេត្ត ក្រៅក្រុងភ្នំពេញ អាចត្រូវបានចាត់ទុកថាជា "សកម្មភាពនយោបាយ" ដែលត្រូវបានហាមនៅក្រោមលក្ខខ័ណ្ឌនៃការដោះលែងក្រោមការតាមដានរបស់តុលាការ ពីការឃុំខ្លួននៅក្នុងផ្ទះ។ នៅថ្ងៃទី ១៦ ខែតុលា អាជ្ញាធរមូលដ្ឋានបានបញ្ឈប់ជាបណ្តោះអាសន្ន មិនឲ្យលោក កឹម សុខាជួយអំណោយដល់អ្នករងគ្រោះដោយទឹកជំនន់ នៅខេត្តបន្ទាយមានជ័យ ដោយហៅសកម្មភាពនេះថាជា "សកម្មភាពនយោបាយ"។

## នីតិវិធីតុលាការស៊ីវិល និងដំណោះស្រាយ

ប្រទេសកម្ពុជាមានប្រព័ន្ធមួយសម្រាប់ដោះស្រាយបណ្តឹងរដ្ឋប្បវេណី ហើយប្រជាពលរដ្ឋមានសិទ្ធិដាក់ពាក្យបណ្តឹងស្វែងរកសំណងការខូចខាតចំពោះការរំលោភសិទ្ធិមនុស្ស ។ ជាទូទៅ មានទាំងដំណោះស្រាយតាមផ្លូវរដ្ឋបាល ទាំងដំណោះស្រាយតាមផ្លូវតុលាការ។ តែ NGO និយាយថា ការដែលសាធារណជនមិនទុកចិត្តលើប្រព័ន្ធតុលាការ ដោយសារតែមានអំពើពុករលួយ និងការគ្រប់គ្រងពីលើរបស់អ្នកនយោបាយ ធ្វើឲ្យមនុស្សជាច្រើនមិនហ៊ានដាក់ពាក្យបណ្តឹង ហើយអាជ្ញាធរច្រើនតែមិនអនុវត្តសាលដីកាតុលាការ។

## សំណងទ្រព្យសម្បត្តិ

ការបង្ខំយកមកដាក់ជាសមូហភាព នៅក្រោមរបបខ្មែរក្រហម និងការផ្លាស់ទីលំនៅរបស់ប្រជាជនបានធ្វើអោយកម្មសិទ្ធិដីធ្លីមានភាពមិនច្បាស់លាស់។ ច្បាប់ភូមិបាលចែងថា អ្នកដែលមានកម្មសិទ្ធិដោយសុខសាន្តលើដីឯកជន ឬដីរដ្ឋ (មិនរាប់បញ្ចូលដីសាធារណៈ ដូចជាសួនច្បារ) ឬបានរស់នៅក្នុងអាគាររដ្ឋដោយគ្មានការតវ៉ាទាមទារពីអ្នកផ្សេង ក្នុងរយៈពេល ៥ឆ្នាំ មុនការប្រកាសអោយប្រើច្បាប់នេះ នៅឆ្នាំ ២០០១ មានសិទ្ធិដាក់ពាក្យសុំកម្មសិទ្ធិលើដី/អាគារនោះជាស្ថាពរ។ តែ ប្រជាជនភាគច្រើននៅតែខ្វះការយល់ដឹងនិងមធ្យោបាយសំរាប់ទទួលបានឯកសារកម្មសិទ្ធិដីធ្លីជាផ្លូវការគ្រប់គ្រាន់។ តែពលរដ្ឋភាគច្រើនខ្វះចំណេះដឹង និងមធ្យោបាយដើម្បីទាមទារយកឯកសារកម្មសិទ្ធិផ្លូវការ។

ការិយាល័យសុរិយោដីខេត្តនិងស្រុកបន្តធ្វើតាមនិតិវិធីនៃការចុះបញ្ជីដីមុនឆ្នាំ ២០០១ ដែលមិនបញ្ចូលការសិក្សាអង្កេតបានត្រឹមត្រូវលើដី ឬឱកាសសំរាប់អោយសាធារណជនផ្តល់មតិ។ ការទិញដីទុកលក់ ដោយគ្មានប័ណ្ណកម្មសិទ្ធិច្បាស់លាស់ បានបណ្តាលអោយមានជំលោះ នៅគ្រប់ខេត្តទាំងអស់ ហើយបានបង្កើនភាពតានតឹងរវាងអ្នកភូមិក្រីក្រតាមជនបទ និងឈ្មួញទិញលក់ដី។ សហគមន៍រស់នៅតាមតំបន់ក្រុងប្រឈមនឹងការបណ្តេញចេញដោយបង្ខំ ដើម្បីយកកន្លែងសំរាប់គំរោងសាងសង់សម្រាប់លក់។

អាជ្ញាធរបានបន្តបង្ខំអោយអ្នកស្រុកផ្លាស់ទីលំ ទោះបីក្នុងប៉ុន្មានឆ្នាំមកនេះ មានការថយចុះក្តី។ អ្នកខ្លះប្រើការគំរាមកំហែងប្តឹង ឬបណ្តេញចេញ ដើម្បីសំឡុតអ្នកក្រ និងអ្នកស្ថិតក្នុងស្ថានភាពខ្សត់ខ្សោយ អោយទូទាត់

សំណាងដីរបស់គេ នៅក្នុងតំលៃក្រោមតំលៃទីផ្សារ។ ដោយគិតមកត្រឹមខែកក្កដា អង្គការNGO ក្នុងស្រុកមួយបាននិយាយថា បានលើករណីថ្មីចំនួន ៣៣ ទាក់ទងនឹងការចាប់យកដី និងការបណ្តេញចេញ ដែលមានទៅលើគ្រួសារចំនួន ១៣២៧ នៅទូទាំងប្រទេស។

## ច. ការជ្រៀតជ្រែកតាមអំពើចិត្តក្នុងភាពឯកជន គ្រួសារ គេហដ្ឋាន ឬក្នុងការឆ្លើយឆ្លងគ្នា

ថ្វីបើច្បាប់មានចែងអំពីភាពឯកជននៃលំនៅដ្ឋាន និងការឆ្លើយឆ្លងគ្នា ហើយហាមឃាត់ការឆែកឆេរខុសច្បាប់ ក្តី តែអង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថាជាទម្លាប់ នគរបាលធ្វើការឆែកឆេរ និងរឹបអូស ដោយគ្មានដីកាពីតុលា ។ ជាធម្មតា រដ្ឋាភិបាលបញ្ចេញសារឆ្លើយឆ្លងផ្ទាល់ខ្លួន ហើយថតការនិយាយឆ្លើយឆ្លងតាមទូរស័ព្ទរបស់មេដឹកនាំបក្សប្រឆាំង និងមេដឹកនាំសង្គមស៊ីវិល ហើបញ្ចេញទៅអោយប្រព័ន្ធផ្សព្វផ្សាយដែលត្រូវគ្នាជាមួយរដ្ឋាភិបាល។

NGO និងប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិបានរាយការណ៍ថា នៅឧសភា អង្គភាពប្រតិកម្មរហ័សរបស់ទីស្តីការគណរដ្ឋមន្ត្រីបានផលិតវីដេអូខ្លែងក្លាយហើយបង្ហោះក្នុងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្ខូចកេរ្តិ៍ឈ្មោះព្រះសង្ឃសកម្មជនលួន សាវ៉ាត ដែលមានឈ្មោះល្បីជាសាធារណៈ។ វីដេអូស្តីពីព្រះសង្ឃសាវ៉ាត ល្បីចំពោះការចងក្រងឯកសាររបស់ព្រះអង្គស្តីពីការរំលោភសិទ្ធិដីធ្លី មានសារសម្លេងតាមវីដេអូរបស់ព្រះអង្គដែលត្រូវបានគេកាត់តខុសភាពដើម។ រដ្ឋាភិបាលបានប្រើការសារបង្ហោះក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមយកធ្វើជាហេតុផលសម្រាប់ផ្សឹកព្រះអង្គ ហើយចោទប្រកាន់ព្រះអង្គពីបទរំលោភផ្លូវភេទ។ ក្រោយមក ព្រះអង្គបានភៀសព្រះកាយទៅក្រៅប្រទេស ហើយបានសុំសិទ្ធិជ្រកកោននយោបាយ នៅប្រទេសស្វីស។

មានការនិយាយថា អាជ្ញាធរមូលដ្ឋានបានចូល និងឆែកឆេអង្គការសហគមន៍ និងការិយាល័យសហជីព។

## ផ្នែកទី២ ៖ ការគោរពសេរីភាពពលរដ្ឋ ដែលរួមមាន

នៅខែមេសា ទី ២៩ ច្បាប់ថ្មីមួយសម្រាប់គ្រាអាសន្នបានចូលជាធរមាន។ លោកនាយករដ្ឋមន្ត្រីបានអះអាងថា ច្បាប់នេះមានភាពចាំបាច់ ដោយសារតែមានការផ្ទុះឡើងនៃមេរោគកូវីដ។ វាអនុញ្ញាតឲ្យរដ្ឋាភិបាលហាមប្រាម ឬដាក់កំហិតព្រំដែនលើសេរីភាពនៃការធ្វើដំណើរ ការប្រមូលផ្តុំគ្នា ការចែកចាយព័ត៌មាន និងលទ្ធភាពក្នុងការចាកចេញពីផ្ទះសម្បែង នៅក្នុងអំឡុងពេលនៃការប្រកាសគ្រាអាសន្ន។ NGO និងអ្នកជំនាញរបស់អង្គការសហប្រជាជាតិបានថ្កោលទោសច្បាប់នេះ ដោយលើកឡើងថា វាខ្វះយន្តការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ហើយអាចត្រូវបានគេប្រើដើម្បីបំពានលើសិទ្ធិរបស់ពលរដ្ឋ។ គិតមកត្រឹមខែវិច្ឆិកា រដ្ឋាភិបាលមិនបានប្រកាសស្ថានភាពអាសន្នទេ។

**ក. សេរីភាពក្នុងការបញ្ចេញមតិ រួមទាំងសេរីភាពផ្នែកសារព័ត៌មាន៖** រដ្ឋធម្មនុញ្ញអនុញ្ញាតអោយមានការបញ្ចេញមតិដោយសេរី ដោយរួមទាំងសេរីភាពសារព័ត៌មានផងដែរ។ តាំងពីឆ្នាំ ២០១៧ រដ្ឋាភិបាលបានធ្វើយុទ្ធនាការជាបន្តដើម្បីលុបបំបាត់សារព័ត៌មានឯករាជ្យ និងសម្លេងប្រឆាំង នៅក្នុងប្រទេស ហើយធ្វើការរឹតត្បិតខ្លាំងលើការបញ្ចេញមតិដោយសេរី។ មនុស្ស និងស្ថាប័នជាច្រើនបាននិយាយពីការត្រូវបន្ថយការនិយាយស្តីរបស់គេ។

សេរីភាពក្នុងការនិយាយស្តី៖ រដ្ឋធម្មនុញ្ញផ្តល់សេរីភាពក្នុងការសម្តែងមតិ លើកលែងតែក្នុងករណីដែលប៉ះពាល់ដល់សន្តិសុខសាធារណៈ ។ រដ្ឋធម្មនុញ្ញក៏ប្រកាសផងដែរថា ព្រះមហាក្សត្រ "មិនអាចត្រូវគេរំលោភបាន" ហើយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ដែលអនុលោមតាមច្បាប់បរិហាកេរ្តិ៍ បញ្ជាក់ជាថ្មីនូវដែនកំណត់ទាំងនេះ ។ ច្បាប់បោះឆ្នោតមានខដែលតំរូវអោយអង្គការសង្គមស៊ីវិលមានភាព "អព្យាក្រិត" នៅក្នុងអំឡុងពេលនៃយុទ្ធនាការនយោបាយ ហើយហាមពួកគេមិនអោយ "ប្រមាថ" គណបក្សនយោបាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ រដ្ឋាភិបាលបានកាត់ទោសពលរដ្ឋពីបទបទបរិហារកេរ្តិ៍ ផ្សាយព័ត៌មានមិនពិត និងញុះញង់ ដែលអាចនាំដល់ការដាក់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ។ ចៅក្រមក៏អាចបញ្ជាអោយបង់ការផាកពិន័យផងដែរ ដែលអាចនាំអោយមានការចាប់ដាក់ពន្ធនាគារ បើមិនបង់ទេ។ នគរបាលនិង តុលាការបានបកស្រាយក្នុងលក្ខណៈទូលំទូលាយពាក្យថា "ញុះញង់" ។ គិតត្រឹមខែមិថុនា អាជ្ញាធរបានធ្វើការចាប់ខ្លួនចំនួន ១៧ ករណី ទាក់ទងនឹងការបង្ហោះសារតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយមួយចំនួនធំទាក់ទងនឹងការមេរោគរាតត្បាតកូវីដ ១៩។ NGO បាននិយាយថា នគរបាលបានបង្ខំឲ្យមនុស្ស ១១ នាក់ចុះហត្ថលេខាលើការយល់ព្រមលែងបង្ហោះ "ដំណឹងក្លែងក្លាយ" ជាថ្នូរនឹងការទំលាក់ការចោទប្រកាន់។ នៅថ្ងៃទី ១២ ខែមិនា នគរបាលនៅខេត្តកំពតបានបង្ខំឲ្យក្មេងអាយុ ១៤ ឆ្នាំសុំទោសនៅក្នុងសាលាបន្ទាប់ពីសិស្សរួមថ្នាក់ម្នាក់បានបង្ហោះសារឯកជនរបស់នាង ដែលអះអាងថា មនុស្ស ៣ នាក់បានស្លាប់ដោយសារមេរោគកូវីដ នៅក្នុងក្រុងរបស់នាង។ NGO នៅខេត្តកំពតបានកត់សម្គាល់ឃើញបទរំលោភលើសេរីភាពក្នុងការសម្តែងមតិចំនួន ២៧។

សេរីភាពផ្នែកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ រួមតាំងសារព័ត៌មានតាមអ៊ិនធ័រណែត៖ រដ្ឋាភិបាល កងកំលាំងយោធា និងគណបក្សនយោបាយកាន់អំណាចបានបន្តមាន ឬមានឥទ្ធិពលលើប្រព័ន្ធផ្សព្វផ្សាយជាកាសែត និងតាមរលកធាតុអាកាស។ មានប្រភពព័ត៌មានឯករាជ្យតិចតួច។ កាសែតចំនួន ៣ ដែលបោះពុម្ពច្រើនជាងគេ ហើយគាំទ្រគណបក្សប្រជាជន មិនដែលរិះគន់រដ្ឋាភិបាលពីបញ្ហាសិទ្ធិមនុស្ស ឬបញ្ហាដែលមានលក្ខណៈនយោបាយទេ។ នៅខែមេសា ក្រសួងព័ត៌មានបានដកអាជ្ញាប័ណ្ណពីស្ថានីយវិទ្យុទិទ្ធីសែន បន្ទាប់ពីម្ចាស់ស្ថានីយបានរិះគន់ចំណាត់ការរបស់រដ្ឋាភិបាល លើមេរោគកូវីដ១៩។

គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) បានចេញក្រមប្រតិបត្តិមួយសំរាប់ការបោះឆ្នោតខែកញ្ញា ឆ្នាំ ២០១៨ ដោយប្រាប់អ្នកសារព័ត៌មានថា ពួកគេនឹងប្រឈមការដាក់ពិន័យជាប្រាក់យ៉ាងច្រើន បើសិនជាគេសម្ភាសន៍អ្នកបោះឆ្នោត នៅជិតស្ថានីយ៍បោះឆ្នោត ឬបើគេបោះពុម្ពផ្សាយព័ត៌មានដែលអាចប៉ះពាល់ដល់ស្ថិរភាពនយោបាយ ឬបណ្តាលអោយសាធារណជនបាត់បង់ទំនុកចិត្តលើការបោះឆ្នោត។

អំពើហឹង្សា និងការយាយី៖ ហិង្សា និងការគំរាមកំហែងលើអ្នកសារព័ត៌មាននៅមានច្រើននៅឡើយ។ នៅថ្ងៃទី ២៥ ខែមិថុនា អាជ្ញាធរបានចាប់ខ្លួនរស់ សុខែតពីបទ "ញុះញង់ឲ្យមានចលាចលសង្គម" បន្ទាប់ពីគាត់បានធ្វើការរិះគន់តាមហ្វេសបុក នូវការឆ្លើយតបរបស់រដ្ឋាភិបាល ចំពោះមេរោគរាតត្បាត។ នៅខែមេសា អាជ្ញាធរបានចាប់ខ្លួនសុវណ្ណរិទ្ធី ដែលជាម្ចាស់ TV FB ពីបទចោទដូចគ្នានេះ បន្ទាប់ពីគាត់បង្ហោះនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ នូវពាក្យដងស្រង់របស់

លោកនាយករដ្ឋមន្ត្រីហ៊ុន សែន ដែលប្រាប់អ្នករត់ម៉ូតូឌុប និងអ្នករត់តុកតុកឲ្យលក់យានរបស់គេទៅ បើគេគ្មានលុយ ដោយសារតែមេរោគរាតត្បាតកូវីដ ១៩។

នៅថ្ងៃទី ២៧ ខែតុលា តុលាការកំពូលបានបដិសេធបណ្តឹងរបស់អតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី ២ នាក់ ដោយអនុញ្ញាតឲ្យបន្តការស៊ើបអង្កេតលើបទចោទទាក់ទងនឹងចារកម្មលើអ្នកទាំងពីរឲ្យបន្ត។ អ្នកទាំងពីរត្រូវបានចោទនៅឆ្នាំ ២០១៧ ពីបទ "ប្រមូលព័ត៌មានខុសច្បាប់ឲ្យរដ្ឋបរទេស" ហើយនៅក្នុងឆ្នាំ ២០១៨ បានរងការចោទពីបទចែកចាយរូបភាពអាសអាភាស។ បើត្រូវបានរកឃើញកំហុសតាមការចោទទី១ ពួកគេនឹងត្រូវជាប់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ។ NGO និងអ្នកសង្កេតការណ៍បាននិយាយថា ករណីប្រឆាំងនឹងពួកគេមានលក្ខណៈនយោបាយ ហើយបានហៅការកាត់ក្តីយូរ និងការដកយកលិខិតឆ្លងដែនរបស់អ្នកសារព័ត៌មានថា ជាភស្តុតាងនៃការគម្រាមកំហែងរបស់រដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយ។

<u>ការចាប់ពិរុទ្ធ ឬការដាក់កំហិតលើសេចក្តីក្នុងអត្ថបទ</u>៖ ច្បាប់ហាមការចាប់ពិរុទ្ធមុនបោះពុម្ពផ្សាយ ហើយគ្មានប្រព័ន្ធចាប់ពិរុទ្ធផ្លូវការទេ។ តែរដ្ឋាភិបាលបានប្រើមធ្យោបាយផ្សេងទៀត ដើម្បីធ្វើការចាប់ពិរុទ្ធលើប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាល ឬគណបក្សប្រជាជន តាមរយៈការគ្រប់គ្រងលើអាជ្ញាប័ណ្ណនិងលិខិតអនុញ្ញាត។ ប្រព័ន្ធផ្សព្វផ្សាយឯកជនបានសារភាពថា បានធ្វើការចាប់ពិរុទ្ធលើខ្លួនឯងខ្លះ ដោយខ្លាចរដ្ឋាភិបាលធ្វើការសងសឹក។ អ្នកសារព័ត៌មានអះអាងថា ម្ចាស់កាសែតប្រាប់កុំឲ្យគេសរសេរពីរឿងដែលធ្វើឲ្យរដ្ឋាភិបាលខឹង ហើយបាននិយាយថា ខ្លួនបានធ្វើការពិនិត្យចាប់ពិរុទ្ធលើខ្លួនឯង ដោយសារក្នុងពេលថ្មីៗនេះ មានការចោទប្រកាន់ព្រហ្មទណ្ឌលើអ្នកសារព័ត៌មាន។

<u>ច្បាប់បរិហារកេរ្តិ៍</u>៖ ច្បាប់កំហិតការសម្តែងមតិដែលបំពានលើសន្តិសុខសាធារណៈ បរិហារកេរ្តិ៍ឬមូលបង្កាច់ព្រះមហាក្សត្រ ហើយហាមប្រាមនិពន្ធនាយកនិងម្ចាស់សារព័ត៌មានមិនឲ្យផ្សព្វផ្សាយរឿងដែលមើលងាយ ឬបង្ខូចកេរ្តិ៍ព្រះមហាក្សត្រ ថ្នាក់ដឹកនាំរដ្ឋាភិបាល ឬស្ថាប័នសាធារណៈ។ រដ្ឋាភិបាលប្រើច្បាប់បរិហារកេរ្តិ៍ មួលបង្កាច់ បកអាក្រាត ដើម្បីធ្វើការរឹតត្បិតលើការនិយាយគ្នាជាសាធារណៈលើបញ្ហាដែលរដ្ឋាភិបាលគិតថាមានភាពរសើប ឬប្រឆាំងនឹងផលប្រយោជន៍របស់ខ្លួន។

<u>សន្តិសុខជាតិ</u>៖ រដ្ឋាភិបាលបានបន្តលើកឡើងពីកង្វល់សន្តិសុខជាតិធ្វើជាហេតុផលនៃការរឹតត្បិតលើសិទ្ធិរបស់ពលរដ្ឋ ដែលរិះគន់មន្ត្រី និងនយោបាយរដ្ឋាភិបាល។

ពីខែមករា ដល់ខែមិនា រដ្ឋាភិបាលបានចាប់ខ្លួនមនុស្សចំនួន ១៧ នាក់ ដែលផ្សាយព័ត៌មានស្តីពីមេរោគកូវីដ១៩ នៅលើប្រព័ន្ធផ្សព្វផ្សាយ។ អ្នកនាំពាក្យរដ្ឋាភិបាល គឺលោក ផៃ ស៊ីផាន បាននិយាយថា ការចែករំលែកព័ត៌មានបែបនេះ "ជាការបង្ករចលាចល និងគ្រោះថ្នាក់"ហើយអាចប៉ះពាល់ដល់សន្តិសុខជាតិ និងបណ្តាលឲ្យមានការស្លន់ស្លោ។

## សេរីភាពអ៊ីនធឺណែត

មានការនិយាយដ៏គួរឲ្យទុកចិត្តបានថា ស្ថាប័នរដ្ឋធ្វើការតាមដានការឆ្លើយឆ្លងគ្នាតាមអ៊ិនធ័រណែត។ ច្បាប់ស្តីពីទូរគមនាគមន៍ត្រូវបានរិះគន់ជាទូទៅ ដោយសកម្មជនសិទ្ធិមនុស្ស និងសកម្មជនសំខាន់ៗក្នុងសង្គមស៊ីវិលថា ផ្តល់អោយរដ្ឋាភិបាលនូវអំណាចទូលំទូលាយក្នុងការលួចស្តាប់ការពិភាក្សាជាសាធារណៈតាមអ៊ិនធ័រណែត ដោយប្រើឧបករណ៍ទាក់ទងគ្នាជាឯកជន។ ច្បាប់នេះផ្តល់ឲ្យរដ្ឋាភិបាលមានអំណាចតាមផ្លូវច្បាប់ក្នុងការតាមដានគ្រប់ការសន្ទនាតាមទូរស័ព្ទ សារតាមទូរស័ព្ទ អ៊ីម៉េល សកម្មភាពតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងការឆ្លើយឆ្លងរបស់បុគ្គល ដោយគ្មានការយល់ព្រមឬដឹងពីពួកគេ ឬដោយគ្មានហេតុផលត្រឹមត្រូវ។ មតិសំដែងដែលត្រូវបានគេគិតថារំលោភលើន័យសន្តិសុខជាតិដែលកំណត់ដោយរដ្ឋាភិបាល អាចនាំដល់ការចាប់ដាក់ពន្ធនាគាររហូតដល់ ១៥ឆ្នាំ។

រដ្ឋាភិបាលមានអំណាចបិទទំព័រផ្សព្វផ្សាយសង្គម ឬគេហទំព័រ ដែលផ្សព្វផ្សាយព័ត៌មានដែលនាំដល់ "ចលាចលក្នុងសង្គម ដែលបំផ្លាញការការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាតិជាមួយប្រទេសដទៃ សេដ្ឋកិច្ច សណ្តាប់ធ្នាប់សង្គម ការរើសអើង ឬប្រពៃណី ឬវប្បធម៌ជាតិ។  នៅខែមេសា អាជ្ញាធរបានដកអាជ្ញាប័ណ្ណនៃទូរទស្សន៍តាមហ្វេសបុក TV FB ដោយប្រធាននៃទូរទស្សន៍នេះបានដកស្រង់សម្តីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទាក់ទងនឹងមេរោគកូវីដ ១៩។

"ក្រុមសង្គ្រាមតាមប្រព័ន្ធអ៊ិនធ័រណែត" នៅក្នុងអង្គភាពប្រតិកម្មរហ័សនិងផ្នែកសារព័ត៌មានរបស់ទីស្តីការគណរដ្ឋមន្ត្រី មាននាទីតាមដាន និងប្រឆាំងនឹងព័ត៌មាន "មិនត្រឹមត្រូវ" ពីផ្នែកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ នៅឆ្នាំ ២០១៩ លោកនាយករដ្ឋមន្ត្រីបានគំរាមថា អ្នកជំនាញខាងអ៊ិនធ័រណែតរបស់លោកអាចរកឃើញទូរស័ព្ទរបស់អ្នកដែលបង្ហោះសារបេរិហារកេរ្តិ៍តាមហ្វេសបុក តែក្នុងរយៈពេល ៤ នាទី។ ហើយក្នុងចំងាយតែ ៥ ហ្វីតទេ នូវអ្នកដែលបង្ហោះសារប្រមាថ នៅតាមហ្វេសបក។ នៅថ្ងៃទីប ២៦ តុលា បានបង្ហោះសារនៃការប្រជុំជាឯកជនតាម Zoom ដែលនៅក្នុងនោះ លោក ហូ វ៉ាន់ នៃគណបក្សប្រឆាំង បានបំផុសឲ្យអ្នកគាំទ្រធ្វើការតវ៉ា នៅមុខស្ថានទូតចិន។ លោក ហ៊ុន សែនបានព្រមានឲ្យលោក ហូ វ៉ាន់ "ប្រព្រឹត្តឲ្យបានត្រឹមត្រូវ" ដោយប្រពន្ធ និងកូនរបស់លោកកំពុងតែរស់នៅក្នុងប្រទេសកម្ពុជាទេ។

## សេរីភាពខាងការសិក្សាអប់រំ និងពិធីវប្បធម៌

រដ្ឋាភិបាលពុំមានរឹតត្បិតសេរីភាពផ្នែកការសិក្សាអប់រំឬពិធីវប្បធម៌ឡើយ ជាផ្លូវការ ឬជាចំហឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកធ្វើការក្នុងផ្នែកសិក្សាអប់រំច្រើនមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងនយោបាយ ដោយសារខ្លាចប៉ះពាល់អ្នកនយោបាយ ។ មានគ្រូជាច្រើនធ្វើការចាប់ពិរុទ្ធលើខ្លួនឯង ឬសំដែងមតិជាលក្ខណៈមិនបញ្ចេញឈ្មោះ។

## ខ. សេរីភាពប្រមូលផ្តុំគ្នា និងសេរីភាពបង្កើតអង្គការ/សមាគម

រដ្ឋាភិបាលធ្វើការរឹតត្បិតលើសេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធី និងការចងក្រងគ្នាជាក្រុម ជាសមាគម។

## សេរីភាពប្រមូលផ្តុំគ្នា ដោយសន្តិវិធី

ថ្វីត្បិតតែរដ្ឋធម្មនុញ្ញមានចែសេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធីក្តី ប៉ុន្តែពេលខ្លះ រដ្ឋាភិបាលមិនបានគោរពសិទ្ធិនេះទេ ។ នៅក្នុងការអង្កេតមួយ ដែលលទ្ធផលត្រូវបានបញ្ចេញកាលពីខែកក្កដា សម្រាប់គម្រោងតាមដាន Fundamental Freedoms Monitoring Project គេរកឃើញថា មានតែ ៤០%តែប៉ុណ្ណោះនៃអ្នកឆ្លើយបាននិយាយថា គេអាចធ្វើការប្រមូលផ្តុំគ្នាដោយសន្តិភាព បើប្រៀបធៀបនឹងឆ្នាំ២០១៦ មាន ៦៥%។

ច្បាប់ តំរូវអោយមានការប្រាប់ជាមុននូវការតវ៉ា ការដើរក្បួន ឬបាតុកម្ម តែអាជ្ញាធរមិនបានអនុវត្តបានខ្ជាប់ខ្ជួនលើការទាមទារនេះទេ។ ខមួយចែងពីការត្រូវជំរាបប្រាប់ចំនួន ៥ ថ្ងៃមុន សំរាប់ការធ្វើបាតុកម្មដោយសន្តិវិធីភាគច្រើន ចំណែកខមួយទៀតចែងពីការតំរូវអោយជូនដំណឹងចំនួន ១២ ម៉ោងមុន សំរាប់ការប្រមូលផ្តុំគ្នាដោយមិនមានការគ្រោងទុក នៅលើទីកន្លែងឯកជន ឬសំរាប់ការតវ៉ានៅកន្លែងកំណត់ ហើយកំរិតចំនួនអ្នកចូលរួមត្រឹម ២០០ នាក់។ តាមច្បាប់ អាជ្ញាធរខេត្ត និងអាជ្ញាធរក្រុងមានអំណាចសំរេចចេញការអនុញ្ញាតអោយធ្វើបាតុកម្ម។ តាមភាពជាក់ស្តែង ពិសេសនៅភ្នំពេញ មន្ត្រីអាជ្ញាធរថ្នាក់ក្រោមបដិសេធសំណើសុំ បើសិនជាថ្នាក់ជាតិមិនផ្តល់ការអនុញ្ញាតច្បាស់លាស់សំរាប់ការប្រមូលផ្តុំគ្នានោះទេ។ តាមធម្មតា អាជ្ញាធរតាមគ្រប់លំដាប់ថ្នាក់មិនផ្តល់ការអនុញ្ញាតដល់ក្រុមដែលរិះគន់គណបក្សដឹកនាំប្រទេសទេ ។ អាជ្ញាធរលើកហេតុផលពីតម្រូវការអោយមាន"ស្ថិរភាព" និង "សន្តិសុខសាធារណៈ" ដែលជាពាក្យមិនមាននិយាយនៅក្នុងច្បាប់ ហើយដូច្នេះ ត្រូវបានបកស្រាយតាមចិត្ត សំរាប់ការមិនផ្តល់ការអនុញ្ញាត។

របាយការណ៍ដែលគួរអោយទុកចិត្តបាន បានអោយដឹងថា រដ្ឋាភិបាលរារាំងមិនអោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរៀបចំពិធីជាសាធារណៈទាក់ទងនឹងសិទ្ធិមនុស្ស ដោយលើកហេតុផលថា ក្រុមទាំងនោះមិនបានទទួលការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន តែច្បាប់មិនតម្រូវអោយមានការយល់ព្រមជាមុនសំរាប់ធ្វើពិធីបែបនេះទេ ។ អាជ្ញាធររដ្ឋាភិបាល ពេលខ្លះថែមទាំងលើកឡើងពីខនៅក្នុងច្បាប់អង្គការ ដើម្បីរារាំងអង្គការ សមាគមមិនអោយរៀបចំពិធីជាសាធារណៈ ឬបំបែកការប្រជុំឬការរៀនសូត្រ ដែលគេគិតថា ប្រឆាំងនឹងរដ្ឋាភិបាល។

ទោះបីជាមានការរឹតត្បិតទាំងនេះក្តី ក៏ផ្នែកសារព័ត៌មានបានរាយការណ៍ពីការតវ៉ាដោយគ្មានការអនុញ្ញាតជាសាធារណៈជាច្រើន ដែលភាគច្រើនទាក់ទងនឹងដីធ្លី ឬជំលោះដីធ្លី និងការទាមទារឲ្យដោះលែងអ្នកទោសនយោបាយ។ តាំងពីការចាប់ខ្លួនមេសហជីព លោក រ៉ុង ឈុន នៅថ្ងៃទី ៣១ កក្កដាមក អាជ្ញាធរជាញឹកញាប់ បានធ្វើការបំបែកក្រុមអ្នកតវ៉ា ដែលទាមទារឲ្យដោះលែងគាត់ ហើយបណ្តាលឲ្យមានរបួសយ៉ាងតិច ៤ នាក់។ នៅក្នុងករណីផ្សេងទៀត នគរបាលបានចាប់ខ្លួន និងចោទប្រកាន់បាតុករខ្លះ ពីបទចូលទៅក្នុងដីឯកជន ហើយធ្វើការតវ៉ាដោយគ្មានការអនុញ្ញាតត្រឹមត្រូវ។ នៅថ្ងៃទី ៧ ខែកញ្ញា នគរបាលបានចាប់ខ្លួនអ្នករៀបចំមួយចំនួននៃការប្រមូលផ្តុំធ្វើការតវ៉ា នៅភ្នំពេញ នៅថ្ងៃបន្ទាប់ ដើម្បីទាមទារឲ្យដោះលែងលោក រ៉ុង ឈុន និងសកម្មជនដទៃទៀត។ ការប្រមូលផ្តុំគ្នានោះនៅតែបន្តធ្វើ ហើយអ្នកចូលរួមមួយចំនួនត្រូវបានចាប់ខ្លួន។

បើយោងតាមរបាយការណ៍របស់ NGO ក្នុងស្រុកមួយ ដោយគិតមកត្រឹមខែកក្កដា មាន ៦២ ករណីនៃការរំលោភលើសេរីភាពនៃការប្រមូលផ្តុំគ្នា។ NGO ផ្នែកសិទ្ធិមនុស្សមួយទៀតបាននិយាយថា មាន ១៨៥ ករណីនៃការប្រមូលផ្តុំគ្នា ដោយ ១០១ ទាក់ទងនឹងសិទ្ធិដីធ្លី ៦៨ ទាក់ទងនឹងសិទ្ធិកម្មករ ហើយ ១៦ ទាក់ទងនឹងរឿងផ្សេង គិតពីខែមេសា ឆ្នាំ ២០១៩ ដល់ខែមិនា។ ពិតមែនហើយ រដ្ឋាភិបាលបានរឹតត្បិតលើករណីចំនួន ៥៣ ក្នុងលក្ខណៈណាមួយ ហើយបានបញ្ឈប់ករណីចំនួន ២១ បន្ថែមទៀត។

នៅថ្ងៃទី ១០ កក្កដា នៅខួបលើកទី៣ នៃការបាញ់សម្លាប់លោក កែម ឡីអាជ្ញាធរបានបិទហាងលក់នៅហ្គារ៉ាសសាំងកាល់តិចបូកគោ ហើយអាជ្ញាធរមិនអនុញ្ញាតឲ្យ NGO និងសកម្មជនធ្វើការជួបជុំគ្នានៅស្រុកកំណើតរបស់គាត់ទេ ដើម្បីរារាំងបាតុកម្ម ឬការតវ៉ា ដែលអាចមាន។

## សេរីភាពបង្កើតអង្គការ/សមាគម

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពបង្កើតអង្គការ/សមាគម តែរដ្ឋាភិបាលមិនបានគោរពសិទ្ធិនេះអោយបានជាប់លាប់ទេ ដោយដៅជាពិសេសទៅលើក្រុម ដែលខ្លួនជឿថា មានការពាក់ព័ន្ធនឹងអ្នកប្រឆាំងផ្នែកនយោបាយ ។ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល តំរូវអោយគ្រប់អង្គការ សមាគមទាំងអស់មានអព្យាក្រិតភាពផ្នែកនយោបាយ ដែលការនេះមិនត្រឹមតែរឹតត្បិតលើសិទ្ធិក្នុងការចូលរួមតែប៉ុណ្ណោះទេ តែថែមទាំងរឹតត្បិតសិទ្ធិនៃអង្គការទាំងនោះនៅក្នុងការសំដែងមតិដោយសេរីថែមទៀតផង។

បញ្ញាតិដែលចែងមិនច្បាស់នៅក្នុងច្បាប់មួយចំនួន ហាមប្រាមសកម្មភាពណាទាំងអស់ដែលអាច "ធ្វើអោយខូចដល់សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ" ឬប៉ះពាល់ដល់ "សន្តិសុខជាតិ សាមគ្គីជាតិ ប្រពៃណី និងវប្បធម៌នៃសង្គមជាតិកម្ពុជា"។ អង្គការសង្គមស៊ីវិលបានសំដែងកង្វល់ចំពោះបទបញ្ញាតិដែលចែងមិនច្បាស់ ថាបានបង្កើតអោយមានការប្រឈមខ្លាំងនឹងការរឹតត្បិតតាមចិត្ត និងដោយភ្ជាប់ទៅនឹងនយោបាយ លើសិទ្ធិរបស់អង្គការ សមាគម។ យោងតាមអ្នករិះគន់ ច្បាប់អង្គការ និងច្បាប់សហជីព ចែងពីដំណើរការចុះបញ្ជីស្មុគស្មាញ និងច្រើនជំហាន ហើយខ្វះការការពារផ្នែករដ្ឋបាល និងតម្លាភាព ដែលជាការធ្វើអោយដំណើរការនៃការចុះបញ្ជីរឹងខ្លាំងនឹងការជំទាសរបស់អ្នកនយោបាយឬអ្នកច្បាប់ ក្នុងរឿងចុះបញ្ជី។ ច្បាប់នេះ ដែលកំណត់អោយមានការធ្វើរបាយការណ៍យ៉ាងតឹងតែងស្តីពីថវិកា និងសកម្មភាព រួមទាំងការត្រូវបង្ហាញសំណើសុំថវិកាដែលបានទទួលថវិកា កិច្ចព្រមព្រៀងលើថវិកាជំនួយ កិច្ចព្រមព្រៀងផ្នែកហិរញ្ញវត្ថុ គណនេយ្យធនាគាររបស់អង្គការសមាគម ថែមទាំងចោទជាបន្ទុកធ្ងន់ដែលអាចអនុញ្ញាតឲ្យមន្ត្រីធ្វើការរឹតត្បិត ឬបិទអង្គការ ដោយសារហេតុផលបន្តិចបន្តួច។ NGO ខ្លះ និងសហជីពបានត្អូញត្អែរពីការដែលនគរបាលតាមដានជាប់ លើសកម្មភាពរបស់ពួកគេ ហើយគម្រាមអ្នកចូលរួម ដោយបានបញ្ជូននគរបាលក្នុងឯកសណ្ឋាន និងស្លៀកពាក់ស៊ីវិលឲ្យធ្វើការសង្កេតក្នុងការប្រជុំ និងវគ្គបណ្តុះបណ្តាលរបស់ពួកគេ។

NGO ក្នុងស្រុកមួយបានកត់ត្រាឃើញ ៣៣៣ ករណីស្តីពីការដែលអាជ្ញាធរធ្វើការរឹតត្បិតលើសេរីភាពនៃការចងក្រងជាអង្គការ សមាគមន ពីខែមេសា ឆ្នាំ ២០១៩ ដល់ខែមិនា និងក្រុមសហគមន៍ក្រៅផ្លូវការ ចំនួន ២៣ ករណី។

## គ. សេរីភាពសាសនា

ចំពោះសេចក្តីរៀបរាប់លំអិតស្តីពីសេរីភាពសាសនា សូមមើល*របាយការណ៍ស្តីពីសេរីភាពសាសនា* តាមគេហទំព័រ www.state.gov/religiousfreedomreport/ ។

## ឃ. សេរីភាពដើរហើរ

ច្បាប់មានចែងអំពីសេរីភាពដើរហើរនៅក្នុងប្រទេស ការធ្វើដំណើរនៅបរទេស ការធ្វើអន្តោប្រវេសន៍ និងមាតុភូមិនិវត្តន៍ ហើយជាទូទៅ ក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាលបានគោរពសិទ្ធិទាំងនេះ ។ នៅខែមេសា រដ្ឋាភិបាលបានធ្វើការរឹតត្បិតលើការចេញចូលរបស់មនុស្សក្នុងក្រុងភ្នំពេញ ថ្ងៃបុណ្យចូលឆ្នាំ ដើម្បីទប់ស្កាត់ការរាលដាលនៃមេរោគកូវីដ ១៩។

<u>និរទេស</u>៖ អ្នករិះគន់រដ្ឋាភិបាល និងអ្នកនយោបាយនៃគណបក្សប្រឆាំងខ្លះបាននិរទេសខ្លួនឯងទៅបរទេស។ នៅក្នុងករណីខ្លះ រដ្ឋាភិបាលចាត់វិធានការរាំងខ្ទប់មិនអោយអ្នកធ្វើនិរទេសខ្លួនត្រឡប់មកវិញ។

### ជនភៀសខ្លួនក្នុងប្រទេស

អត់មាន។

ការការពារជនភៀសខ្លួន

<u>ការចាប់បញ្ជូនជនភៀសខ្លួនត្រឡប់វិញ៖</u>

រដ្ឋាភិបាលបានធ្វើសហប្រតិបត្តិការជាមួយការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) និងអង្គការមនុស្សធម៌ដទៃទៀត ដើម្បីផ្តល់ការការពារ និងជំនួយដល់ជនផ្លាស់ទីលំនៅក្នុងប្រទេស ជនភៀសខ្លួន ជនភៀសខ្លួនដែលបានវិលត្រឡប់មកវិញ អ្នកស្វែងរកសិទ្ធិជ្រកកោន អ្នកគ្មានរដ្ឋ និងមនុស្សដទៃទៀតដែលជាទីកង្វល់។

<u>លទ្ធភាពទទួលបានការជ្រកកោន៖</u>

ច្បាប់ប្រទេសកម្ពុជាមានចែងអំពីការផ្តល់សិទ្ធិជ្រកកោន ឬឋានៈជាជនភៀសខ្លួន ហើយរដ្ឋាភិបាលបានរៀបចំប្រព័ន្ធមួយសម្រាប់ផ្តល់កិច្ចការពារដល់ជនភៀសខ្លួន ។ រដ្ឋាភិបាលមិនបានផ្តល់លទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធនេះដល់អ្នកសុំសិទ្ធិជ្រកកោន និងជនភៀសខ្លួនទាំងអស់ទេ ហើយក៏គ្មានតម្លាភាពដែរ។ អ្នកស្វែងរកសិទ្ធិជ្រកកោនដែលចូលក្នុងប្រទេសដោយគ្មានឯកសារ ឬស្នាក់នៅហួសទិដ្ឋាការកំណត់ អាចនឹងរកការចាប់បញ្ជូន

ចេញវិញ។ អាជ្ញាធរមិនផ្តល់ឋានៈសម្រាប់អ្នកស្នាក់នៅស្របច្បាប់ ឬសៀវភៅស្នាក់ដល់ជនភៀសខ្លួនទេ តែគ្រាន់តែផ្តល់ "ប័ណ្ណជនភៀសខ្លួន" ទេ។

សេរីភាពក្នុងការដើរហើរ៖ អាជ្ញាធររឹតត្បិតលើការដើរហើររបស់ជនភៀសខ្លួន។ ឧទាហរណ៍ អាជ្ញាធរមូលដ្ឋានតម្រូវឲ្យអ្នកស្រុកភ្នំពីប្រទេសវៀតណាម ដែលបានទទួលឋានៈជនភៀសខ្លួន ស្នាក់នៅតែនៅកន្លែងស្នាក់នៅបណ្តោះអាសន្នរបស់គេតែប៉ុណ្ណោះ ក្រៅពីពេលទៅទិញអីវ៉ាន់ប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃ។

ការងារ៖ច្បាប់អនុញ្ញាតឲ្យជនភៀសខ្លួនធ្វើការ និងបើកមុខរបរជំនួញ។ តែជនភៀសខ្លួនមិនទទួលបាននូវប័ណ្ណស្នាក់នៅទេ ដែលជាការធ្វើឲ្យគេមានការពិបាកក្នុងការអនុវត្តសិទ្ធិនេះ។

លទ្ធភាពទទួលបានការបំរើផ្នែកសេវាសាធារណៈជាមូលដ្ឋាន៖ ការដែលអាជ្ញាធរមិនព្រមផ្តល់ឲ្យនូវប័ណ្ណស្នាក់នៅដល់ជនភៀសខ្លួន ធ្វើឲ្យពួកគេមានការពិបាក ក្នុងការទទួលបានការបំរើផ្នែកសេវាសាធារណៈជាមូលដ្ឋាន។

## ជនគ្មានប្រទេស [ជនគ្មានរដ្ឋ]

ប្រទេសកម្ពុជាមានអ្នករស់នៅដែលជាជនគ្មានរដ្ឋ។ អង្គការ UNHCR បាននិយាយថា មានមនុស្សគ្មានរដ្ឋចំនួនប្រមាណ ៥៧ ៤៤៤ នាក់ បើគិតមកត្រឹមដំណាច់ឆ្នាំ ២០១៩ ហើយពួកគេភាគច្រើនជាអាណិកជនវៀតណាម។ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់ឬគោលនយោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសដល់ជនទាំងនោះអោយទទួលបានសញ្ជាតិឡើយ ។ (សូមមើលផ្នែកទី ៦ ស្តីពីកុមារ)។ ហេតុផលដែលច្រើនមានជាងគេចំពោះភាពគ្មានប្រទេសគឺ កង្វះឯកសារត្រឹមត្រូវពីប្រទេសកំណើត។

បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ បុគ្គលដែលគ្មានភស្តុតាងសញ្ជាតិ ច្រើនមិនសូវបានទទួលបានការងារផ្លូវការ ការសិក្សា ការចុះបញ្ជីអាពាហ៍ពិពាហ៍ លទ្ធភាពតាមផ្លូវតុលាការ និងកម្មសិទ្ធិដីធ្លីទេ។

## ផ្នែកទី៣. សេរីភាពក្នុងការចូលរួមក្នុងដំណើរការនយោបាយ

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការជ្រើសរើសរដ្ឋាភិបាលរបស់ខ្លួនតាមរយៈការបោះឆ្នោតជាទៀងទាត់ដោយសេរី និងយុត្តិធម៌ ដោយផ្អែកលើសិទ្ធិបោះឆ្នោតជាសាកល និងស្មើភាព តែតាមភាពជាក់ស្តែង គ្មានលទ្ធភាពបែបនេះទេ។ តាមច្បាប់ រដ្ឋាភិបាលអាចរំលាយគណបក្សនយោបាយ និងហាមបុគ្គលមិនអោយកាន់មុខតំណែងដឹកនាំក្នុងគណបក្ស និងមានជីវិតនយោបាយ។ វិសោធនកម្មទាំងនោះថែមទាំងរឹតត្បិតគណបក្សមិនអោយប្រើឯកសារជាសំលេង ជារូបភាព ឬជាសំណេរ ដែលបានមកពីជនល្មើសដែលតុលាការបានដាក់ទោស។

គិតមកត្រឹមខែសីហា មានមន្ត្រីគណបក្សសង្គ្រោះជាតិចំនួនតែ ១២ នាក់ប៉ុណ្ណោះ ក្នុងចំណោម ១១៨ នាក់ ដែលត្រូវបានហាមពីសកម្មភាពនយោបាយ បានដាក់ពាក្យ ហើយបានទទួលសិទ្ធិធ្វើនយោបាយឡើងវិញ គឺមាន ៣ នាក់ ក្នុងឆ្នាំនៃរបាយការណ៍ និង ៩ នាក់ ក្នុងឆ្នាំ ២០១៩។ អ្នកឯកទេសក្នុងស្រុក និងសមាជិកគណបក្សប្រឆាំងបានត្អូញត្អែរថា ដំណើរការ "ផ្តល់សិទ្ធិឲ្យវិញ" នោះធ្វើតាមតែចិត្តនឹកឃើញ ធ្វើឲ្យគេយល់ខុសថា អ្នកនយោបាយមកពីគណបក្សប្រឆាំងនោះ បានធ្វើខុស ហើយធ្វើឲ្យលោកនាយករដ្ឋមន្ត្រីអាចជ្រើសរើសគូប្រឆាំងនយោបាយរបស់គាត់បាន។ ការហាមប្រាមពីដើមមកលើការធ្វើសកម្មភាពនយោបាយ ដែលមានឡើងបន្ទាប់ពីការរំលាយគណបក្សប្រឆាំងនេះដោយតុលាការកំពូល នៅឆ្នាំ ២០១៧ ។ ការសម្រេចចិត្តនេះត្រូវបានមជ្ឈដ្ឋានជាច្រើនរិះគន់ថា មានភាពលំអៀងផ្នែកនយោបាយ ដោយបានកត់សម្គាល់ថាឃើញថា ការសំម្រេចធ្វើការហាមប្រាមនេះមានឡើងមុនពេលមេដឹកនាំរបស់បក្សនេះរងការដាក់ទោសដោយតុលាការពីបទក្បត់ជាតិ ។ ជាមួយនឹងការរំលាយគណបក្សនេះ មន្ត្រីជាប់ឆ្នោតចំនួន ៥០០៧ នាក់របស់គណបក្សនេះក៏ត្រូវបានដកពីតំណែង ហើយជំនួសដោយមន្ត្រីរបស់គណបក្សប្រជាជន។ គណបក្សប្រជាជនគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ទាំងអស់នៃរដ្ឋាភិបាល រាប់ពីក្រុមប្រឹក្សាស្រុកខេត្តដល់សភាជាតិ។

## ការបោះឆ្នោត និងការចូលរួមផ្នែកនយោបាយ

<u>ការបោះឆ្នោតជាតិថ្មីៗកន្លងទៅ</u>៖ ការបោះឆ្នោតជាតិក្នុងពេលថ្មីៗបំផុត ដែលត្រូវបានធ្វើនៅខែកក្កដា ឆ្នាំ ២០១៨។ មានការចូលរួមនៃគណបក្សនយោបាយចំនួន ២០ តែគ្មានការចូលរួមនៃគណបក្ស CNRP ដែលជាគណបក្សប្រឆាំងធំជាងគេ។ គណបក្សប្រឆាំងទាំង ១៩ ក្រៅពីគណបក្សគ្រប់គ្រងអំណាច CPP ដែលចូលប្រកួតប្រជែង មានការគាំទ្រតិចហើយមានច្រើនទើបនឹងបង្កើតថ្មី។

ថ្វីបើច្បាប់ធ្វើយុទ្ធនាការតម្រូវឲ្យផ្នែកសារព័ត៌មាននានាធ្វើការផ្សាយស្មើៗគ្នា សម្រាប់គណបក្សនិមួយៗដែលចូលរួមនៅក្នុងការបោះឆ្នោតនិមួយៗក្តី តែគេគ្មានឃើញភស្តុតាងដែលបង្ហាញពីការអនុវត្តច្បាប់នេះទេ នៅក្នុងការបោះឆ្នោតឆ្នាំ ២០១៨។ ផ្នែកសារព័ត៌មានផ្សាយពីគណបក្សប្រជាជនច្រើនជាងគេ។ ដោយសារមានការធ្លាក់ចុះនៃអង្គភាពសារព័ត៌មានឯករាជ្យ អង្គភាពសារព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋាភិបាល ធ្វើការផ្សព្វផ្សាយលើសលុបនៅមុនពេលបោះឆ្នោត ពិសេសនៅតំបន់ជនបទ ដែលអ្នកបោះឆ្នោតភាគច្រើនមិនសូវទទួលបានព័ត៌មានពីផ្នែកសារព័ត៌មានឯករាជ្យ។

សន្លឹកឆ្នោតចំនួនប្រហែល ៦០០ ០០០ សន្លឹកយកជាការមិនបាន ក្នុងការបោះឆ្នោតលើកមុន ចំនួនសន្លឹកឆ្នោតយកជាការមិនបានមាន ១០០ ០០០ សន្លឹក។ អ្នកសង្កេតការណ៍និយាយថា នេះគឺជាសញ្ញានៃការតវ៉ា ដោយសារពួកគេរងសម្ពាធឲ្យទៅបោះឆ្នោត ដោយគ្មានគណបក្ស CNRP ឈរឈ្មោះ។ អ្នកបោះឆ្នោតជាច្រើនសុខចិត្តគូសចោល ជាជាងបោះឲ្យគណបក្សប្រឆាំងណាមួយ។ បើតាមតួលេខរបស់រដ្ឋាភិបាល ចំនួន ៨៣% នៃអ្នកមានសិទ្ធិបោះឆ្នោត បានចេញទៅបោះឆ្នោត។ គណបក្សកាន់អំណាច CPP បានឈ្នះកៅអីទាំង ១២៥ នៅក្នុងរដ្ឋសភា។ ស្ថិតិរបស់រដ្ឋាភិបាលមិនអាចបញ្ជាក់បានទេ ដោយសារខ្វះអ្នកសង្កេតការណ៍ឯករាជ្យ។

អ្នកសង្កេតការណ៍ឯករាជ្យភាគច្រើនចាត់ទុកដំណើរការបោះឆ្នោតទាំងមូលថាមានកំហុសឆ្គងធ្ងន់ធ្ងរ។ ស្ថានទូតភាគច្រើននៅកម្ពុជាមិនព្រមធ្វើជាអ្នកសង្កេតការណ៍ផ្លូវការ នៅក្នុងការបោះឆ្នោតនេះទេ។ អង្គការសង្កេតការណ៍បោះឆ្នោតដែលមានមែនរបស់រដ្ឋ ដោយរួមមានទាំងមជ្ឈមណ្ឌល Carter Center និង Asian Network for Free Elections ក៏បានសម្រេចចិត្តមិនមកធ្វើការតាមដានការបោះឆ្នោតនេះដែរ ពីព្រោះអង្គការទាំងនោះចាត់ទុកថា ការបោះឆ្នោតនេះខ្វះភាពត្រឹមត្រូវជាមូលដ្ឋាន។ គជប បានចោទសហគមន៍អន្តរជាតិថា មានភាពលំអៀង ដោយនិយាយថា សហគមន៍អន្តរជាតិគាំទ្រ គជប តែនៅពេលណាមានការចូលរួមការបោះឆ្នោតរបស់គណបក្ស CNRP តែប៉ុណ្ណោះ។ ទោះបីជាមានឈ្មោះថា ឯករាជ្យក្តី តែរដ្ឋាភិបាលបានដាក់កាមេរ៉ាថតនៅ គជប ដែលធ្វើឲ្យវាអាចតាមដានការងាររបស់គជបបាន។

<u>គណបក្សនយោបាយ និងការចូលរួមនយោបាយ</u>៖ គិតមកត្រឹមខែកក្កដា រដ្ឋាភិបាលបានបញ្ជាក់ថា មានគណបក្សនយោបាយចំនួន ៥៥ បានចុះបញ្ជីការជាមួយក្រសួងមហាផ្ទៃ។ លើកលែងតែគណបក្សប្រជាជន និងគណបក្សតូចៗមួយចំនួនដែលគាំទ្ររដ្ឋាភិបាល គណបក្សនយោបាយនានាបានរងការរើសអើងតាមផ្លូវច្បាប់ ការអនុវត្តច្បាប់មិនស្មើភាព ការគំរាមកំហែង និងការផ្សាយព័ត៌មានដោយមានលំអៀង។ កត្តាទាំងអស់នេះនាំអោយគណបក្ស CPP យកផ្តាច់មុខនូវអំណាចនយោបាយ។ អ្នកកាន់មុខតំណែងជាច្រើននៅក្នុងរដ្ឋាភិបាលត្រូវតែជាសមាជិកនៃគណបក្ស CPP ។ គិតមកត្រឹមខែកក្កដា NGO ក្នុងស្រុកមួយបាននិយាយថា មានករណីគម្រាមកំហែងចំនួន ២៣ ដល់សកម្មជននយោបាយ។ នៅថ្ងៃទី ១៩ ខែតុលា មានមនុស្ស ២ នាក់ជិះម៉ូតូ បានវាយលើឌិន រ៉ារិន អគ្គលេខាធិការនៃគណកម្មាធិការប្រតិបត្តិរបស់គណបក្សសង្គ្រោះជាតិ ដែលត្រូវបានរំលាយ ក្នុងពេលដែលគាត់ដើរមកផ្ទះ ពីហាងកាហ្វេ ដោយយកដុំថ្មគប់លើមុខរបស់គាត់។ គិតមកត្រឹមខែវិច្ឆិកា មន្ត្រីគណបក្សប្រឆាំងយ៉ាងហោចណាស់ចំនួន ១០ នាក់បានរងការវាយបែបនេះ តែអាជ្ញាធរមិនបានចាប់ខ្លួនជនសង្ស័យណាម្នាក់បានទេ។

<u>ការចូលរួមរបស់ស្ត្រី និងក្រុមជនជាតិភាគតិច</u>៖ គ្មានច្បាប់ដែលដាក់កំហិតព្រំដែនលើការចូលរួមរបស់ស្ត្រី និងជនជាតិភាគតិច នៅក្នុងដំណើរការនយោបាយទេ តែវប្បធម៌ប្រពៃណីកម្រិតការចូលរួមរបស់ស្ត្រីនៅក្នុងនយោបាយ និងរដ្ឋាភិបាល ជាពិសេសច្បាប់ស្រី ដែលមានតាំងពីសតវត្សទី ១៤ មក មានចំណែករារាំងខ្លាំងក្នុងរឿងនេះ ។ ទោះបីជាគណបក្ស CPP បានសន្យាម្តងហើយម្តងទៀតថា នឹងបង្កើនតំណាងរបស់ស្ត្រីក្តី តែចំនួនបេក្ខជនជាស្ត្រីដែលជាប់ឆ្នោតនៅក្នុងការបោះឆ្នោតជាតិនៅខែកក្កដា ឆ្នាំ

២០១៨ មានការថយចុះមកត្រឹម ១៩ នាក់ ពី ២៥ នាក់ ក្នុងការបោះឆ្នោតជាតិឆ្នាំ ២០១៣។ ការបោះឆ្នោតថ្នាក់មូលដ្ឋាន នៅឆ្នាំ ២០១៧ ឃើញមានជាលើកដំបូង នូវការចូលរួមនៃគណបក្សប្រជាធិបតេយ្យជនជាតិដើមកម្ពុជា ។

## ផ្នែកទី៤ ៖ អំពើពុករលួយ និងកង្វះតម្លាភាពក្នុងរដ្ឋាភិបាល

ច្បាប់មានចែងអំពីទោសព្រហ្មទណ្ឌសម្រាប់អំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីនានា ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពឡើយ ហើយមន្ត្រីជាញឹកញាប់ តែងតែប្រព្រឹត្តអំពើពុករលួយដោយមាននិទណ្ឌភាព ។

<u>អំពើពុករលួយ</u>៖ ក្រមព្រហ្មទណ្ឌបានកំណត់អំពើពុករលួយនានា ហើយកំណត់ច្បាស់នូវទោសចំពោះការប្រព្រឹត្តអំពើទាំងនេះ។ ច្បាប់ប្រឆាំងអំពើពុករលួយចែងពីមូលដ្ឋានច្បាប់សំរាប់អោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយទទួល និងស៊ើបអង្កេតបណ្តឹងទាក់ទងនឹងអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយមិនសហការអោយបានញឹកញាប់ជាមួយសង្គមស៊ីវិល ហើយត្រូវបានគេមើលឃើញថា គ្មានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ផ្ទុយទៅវិញ អង្គភាពប្រឆាំងអំពើពុករលួយមានភាពសកម្មនៅក្នុងការដឹកនាំការស៊ើបអង្កេតទៅលើសមាជិកនៃគណបក្សប្រឆាំង ដែលជាការនាំអោយគេនាំគ្នាយល់ថា អង្គភាពនេះបំរើផលប្រយោជន៍របស់គណបក្សកាន់អំណាច។ អង្គភាពនេះមិនដែលស៊ើបអង្កេតសមាជិកជាន់ខ្ពស់នៃគណបក្សកាន់អំណាចទេ ទោះបីមានការចោទប្រកាន់ជាច្រើនពីបទពុករលួយ ក្នុងលំដាប់ថ្នាក់ជាន់ខ្ពស់នៃគណបក្ស និងរដ្ឋាភិបាលក្តី។ ឧទាហរណ៍ យោងតាមរបាយការណ៍ស៊ើបអង្កេតចេញខែកញ្ញា របស់វិទ្យុអាស៊ីសេរី កូនស្រី ២ នាក់របស់ទេសរដ្ឋមន្ត្រី និងជាអតីតអគ្គមេបញ្ជាការ ប៉ុល សារឿន បានចេញមុខក្នុងការបន្លំទាក់ទងនឹងអចលនទ្រព្យ នៅអូស្ត្រាលី ដែលមានតម្លៃប្រមាណ ១០០ លានដុល្លា។ របាយការណ៍មួយរបស់វិទ្យុអាស៊ីសេរីបាននិយាយនៅខែមេសាថា  ហ៊ុន គឹមឡុង ដែលជាក្មួយស្រីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោកមេនគរបាលជាតិ នេត សាវឿន ជាប្តី បានទិញវីឡាមួយនៅប្រទេសស៊ីព ក្នុងតម្លៃ ២,៧ លានដុល្លា។ អ្នកទាំងពីរស្ថិតក្នុងចំណោមខ្សែអ្នកធំចំនួន ៨ នាក់ ដែលមានឈ្មោះក្នុងរបាយការណ៍ដែលចេញនៅខែតុលា ឆ្នាំ ២០១៩ ដោយសារព័ត៌មាន Reuters ថាបានទទួលសញ្ជាតិស៊ីព បន្ទាប់ពីបានបោះទុនវិនិយោគក្នុងម្នាក់ៗចំនួន ២,២ លានដុល្លា នៅក្នុងប្រទេសនោះ។

មន្ត្រីរាជការត្រូវមានការយល់ព្រមពីប្រធាន មុនពេលឆ្លើយសំណួររបស់សាខានិតិបញ្ញត្តិ ទាក់ទងនឹងការចោទប្រកាន់ស្តីពីអំពើពុករលួយ។

អំពើពុករលួយមានលក្ខណៈរាលដាល នៅក្នុងសង្គម និងរដ្ឋាភិបាល។ មានសេចក្តីរាយការណ៍មកថា នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងចៅក្រមជំរះក្តី បានទទួលសំណូកពីអ្នករកស៊ី ទាំងស្របច្បាប់ ទាំងខុសច្បាប់។ ពលរដ្ឋតែងតែត្អូញត្អែរជាសាធារណៈអំពីអំពើពុករលួយ។ បៀវត្សរ៍មិនគ្រប់គ្រាន់រួមចំណែកឱ្យ មាន "អំពើពុករលួយដើម្បីរស់" ក្នុងចំណោមមន្ត្រីថ្នាក់ទាប ចំណែកវប្បធម៌និទណ្ឌភាពធ្វើអោយអំពើពុករលួយរីកសាយក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ។

យោងតាមការវាស់ស្ទង់ដែលមានឈ្មោះថា 2016 Global Corruption Barometer តុលាការគឺជាវិស័យដែលពុករលួយជាងគេ នៅក្នុងរយៈពេល ៥ ឆ្នាំជាប់គ្នា ដែលបន្ទាប់មកមានផ្នែកអនុវត្តច្បាប់។

ការប្រកាសទ្រព្យសម្បត្តិ៖ រាជការ រួមទាំងមន្ត្រីតែងតាំង និងមន្ត្រីជាប់ឆ្នោតផង តាមច្បាប់ ត្រូវប្រកាសទ្រព្យសម្បត្តិរបស់គេ។ អង្គភាពប្រឆាំងអំពើពុករលួយ (ACU) ទទួលខុសត្រូវក្នុងការទទួលយកសេចក្តីប្រកាស ចំណែកការពិន័យចំពោះការមិនគោរពតាមមានការជាប់ពន្ធនាគាររាប់ពី ១ ខែទៅ ១ ឆ្នាំ។ ការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីជាន់ខ្ពស់មិនត្រូវបានអោយដឹងដល់សាធារណៈទេ ហើយនៅបិទជិតក្នុងស្រោមសំបុត្រ រហូតទាល់តែមានការប្តឹងទាក់ទងនឹងអំពើពុករលួយ។ មានតែសេចក្តីប្រកាសទ្រព្យសម្បត្តិតែមួយគត់ត្រូវបានបើកមើល គឺសេចក្តីប្រកាសរបស់អតីតប្រធានគណបក្ស CNRP កឹម សុខា ។ NGO បានទាមទារឲ្យមានវិសោធនកម្មលើច្បាប់ប្រឆាំងអំពើពុករលួយ ហើយសុំឲ្យមានចុះក្នុងកំណត់ហេតុសាធារណៈ នូវទ្រព្យសម្បត្តិទាំងអស់ របស់មន្ត្រីរដ្ឋាភិបាល។

## ផ្នែកទី៥ ៖ ឥរិយាបថរបស់រដ្ឋាភិបាលចំពោះការស៊ើបអង្កេតរបស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលលើការចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្ស

មានរបាយការណ៍ជាច្រើនអំពីកង្វះការសហការ ហើយនៅក្នុងករណីមួយចំនួន មានការបំភិតបំភ័យដោយមន្ត្រីរដ្ឋាភិបាលលើអ្នកស៊ើបអង្កេតសិទ្ធិមនុស្ស។ រដ្ឋាភិបាលបានគម្រាមប្តឹង NGO ចំនួន  គឺអង្គការលីកាដូ STT និងអង្គការ Central ទាក់ទងនឹងការចេញរបាយការណ៍ ស្តីពីផលអវិជ្ជមាននៃកម្ចីខ្នាតតូច លើអ្នកទទួលកម្ចី។

មានអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារផ្នែកសិទ្ធិមនុស្សប្រមាណជា ២៥ នៅក្នុងប្រទេស និងមានចំនួនប្រហែល ១០០ ទៀតដែលផ្តោតការយកចិត្តទុកដាក់លើវិស័យផ្សេងទៀត ដែលមាននៅក្នុងបញ្ហាសិទ្ធិមនុស្ស ប៉ុន្តែមានតែអង្គការមួយចំនួនតូចប៉ុណ្ណោះ ដែលធ្វើសកម្មភាពក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ឬស៊ើបអង្កេតការរំលោភសិទ្ធិមនុស្ស ។

អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត៖រដ្ឋាភិបាល ជាទូទៅ បានអនុញ្ញាតអោយតំណាងអង្គការសហប្រជាជាតិមកធ្វើទស្សនកិច្ច ។ តែរដ្ឋាភិបាលច្រើនតែមិនព្រមជួបប្រជុំថ្នាក់ខ្ពស់ ជាមួយតំណាងនៃអង្គការសហប្រជាជាតិ ហើយមិនអោយពួកគេជួបជាមួយមន្ត្រីបក្សប្រឆាំង ដោយរួមទាំងលោក កឹម សុខាផងដែរ។ អ្នកនាំពាក្យរបស់រដ្ឋាភិបាលតែងតែរិះគន់តំណាងពិសេសនៃអង្គការសហប្រជាជាតិជាសាធារណៈ ចំពោះការនិយាយរបស់គេស្តីពីបញ្ហានានាផ្នែកសិទ្ធិមនុស្ស។

ស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាល៖ រដ្ឋាភិបាលមានស្ថាប័នសិទ្ធិមនុស្សចំនួន ៣ ដែលរួមមានគណៈកម្មាធិការដាច់ដោយឡែក ទទួលបន្ទុកការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង នៅក្រោមព្រឹទ្ធសភា និងរដ្ឋសភា ព្រមទាំងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលស្ថិតនៅក្រោមខុទ្ទកាល័យនាយករដ្ឋមន្ត្រី។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាប្រគល់របាយការណ៍របស់រដ្ឋាភិបាល ដើម្បីចូលរួមក្នុងដំណើរការពិនិត្យសិទ្ធិមនុស្សជាអន្តរជាតិ ដូចជាការពិនិត្យទៀងទាត់ជាសកល និងបានឆ្លើយតបចំពោះរបាយការណ៍របស់ស្ថាប័នរដ្ឋាភិបាល និងអង្គការអន្តរជាតិ ប៉ុន្តែមិនបានធ្វើការស៊ើបអង្កេតស្ថានភាពសិទ្ធិមនុស្សដោយឯករាជ្យឡើយ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សដែលគួរឱ្យទុកចិត្តបានចាត់ទុកថា គណៈកម្មាធិការរបស់រដ្ឋាភិបាលថា មានប្រសិទ្ធភាពការងារនៅមានកំរិត ហើយ

បានរិះគន់តួនាទីរបស់គេនៅក្នុងការនិយាយការពារការបង្ក្រាបរបស់រដ្ឋាភិបាល ទៅលើសង្គមស៊ីវិល និងគណបក្សប្រឆាំង។

អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC) បានបន្តធ្វើការស៊ើបអង្កេត និងដាក់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើយង់ឃ្នង ដែលត្រូវបានប្រព្រឹត្តពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។ ECCC គឺជាតុលាការកូនកាត់ ដោយមានបុគ្គលិក និងចៅក្រមជាតិ និងអន្តរជាតិ ហើយគ្រប់គ្រងដោយច្បាប់ក្នុងស្រុករបស់កម្ពុជាផង និងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិផង។ មិនទាន់មានការសម្រេចលើករណីប្រឆាំងនឹងឈ្មោះ មាស មុត និងអៅ អាននៅឡើយទេ។ នៅខែសីហា តុលាការកំពូលបានបិទករណី អៅ អាន ដោយសារគ្មានការយល់ស្របគ្នាលើការកាត់ក្តីលើអៅ អាន។ គិតមកត្រឹមខែវិច្ឆិកា ECCC មិនទាន់សម្រេចថា តើត្រូវបន្តលើករណីណាមួយ ដែលនៅសល់នោះទេ។

## ផ្នែកទី៦៖ ការរើសអើង ការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្ស

## ស្ត្រី

ការរំលោភសេពសន្ថវៈ និងហឹង្សាក្នុងគ្រួសារ៖ ការរំលោភសេពសន្ថវៈ និងអំពើហឹង្សាក្នុងគ្រួសារគឺជាបញ្ហាធំ។ ច្បាប់ដែលមិនបញ្ជាក់ភេទនៃជនរងគ្រោះ ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើរំលោភសេពសន្ថវៈ និងការបំពារបំពាន។ អំពើរំលោភសេពសន្ថវៈត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារពី ៥ឆ្នាំ ទៅ ៣០ឆ្នាំ។ អំពើរំលោភសេពសន្ថវៈ ប្តី/ប្រពន្ធមិនត្រូវបានចែងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌឡើយ ប៉ុន្តែ អាចធ្វើការចោទប្រកាន់ថាជា "អំពើរំលោភសេពសន្ថវៈ" "ការបង្ករបួសស្នាម" ឬ "ការបំពារបំពានមិនសមរម្យ"បាន។ កម្រមានការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈប្តី/ប្រពន្ធណាស់។ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារកំណត់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែ មិនមានចែងជាក់លាក់អំពីការដាក់ទោសឡើយ។ គេអាចប្រើក្រមព្រហ្មទណ្ឌ ដើម្បីដាក់ទោសចំពោះបទល្មើសហឹង្សាក្នុងគ្រួសារ ដោយដាក់ទោសពន្ធនាគារចាប់ពី ១ ឆ្នាំរហូតដល់ ១៥ឆ្នាំ។

អំពើហិង្សាក្នុងគ្រួសារនិងការរំលោភផ្លូវភេទច្រើនតែមិនត្រូវបានគេរាយការណ៍អស់ ដោយសារជនរងគ្រោះខ្លាចការសងសឹកដោយជនល្មើស ការរើសអើងនៅក្នុងសង្គម និងការដែលគេមិនទុកចិត្តប្រព័ន្ធតុលាការ។ នៅក្នុងចំណោមមន្ត្រីតុលាការ មានចំនួននារីតិចតួច។ ១៤% នៃចៅក្រម ១២% នៃព្រះរាជអាជ្ញា ២០% នៃមេធាវី ដែលទំនងជាមូលហេតុនាំឲ្យមានការរាយការណ៍មិនអស់ពីការរំលោភសេពសន្ថវៈ និងការរំលោភធ្វើបាបក្នុងគ្រួសារ។ អង្គការ NGO បាននិយាយថា អាជ្ញាធរមិនសូវប្រឹងប្រែងខ្លាំងក្នុងការអនុវត្តច្បាប់គ្រួសារទេ ហើយជៀសវាងការពាក់ព័ន្ធក្នុងជំលោះក្នុងគ្រួសារ។

ការរំលោភផ្លូវភេទ និងអំពើហឹង្សាក្នុងគ្រួសារ ពេលខ្លះ បណ្តាលអោយស្លាប់៖ អង្គការ NGO មួយបាននិយាយថា មានការសម្លាប់ចំនួន ១០ ករណី នៅក្នុងការសង្កេត នៅឆ្នាំ២០១៨ លើករណីអំពើហឹង្សាក្នុងគ្រួសារចំនួន ៣៩ និង

ករណីរំលោភផ្លូវភេទចំនួន ១៨។ នៅក្នុងចំណោមករណីទាំង ៥៧ នេះ អាជ្ញាធរបានចាប់ខ្លួនជនល្មើសបានតែ ២៣ នាក់ទេ។ អ្នកសង្កេតការណ៍ភាគច្រើនជឿថា ទាំងអាជ្ញាធរ ទាំងសាធារណជន ជាទូទៅ មិនចាត់ទុកអំពើហឹង្សាក្នុងគ្រួសារថាជាបទល្មើសព្រហ្មទណ្ឌទេ។

ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារីបានចាប់ផ្តើមអនុវត្តក្រមអាកប្បកិរិយាសំរាប់ប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងហឹង្សាទៅលើនារី។ ក្រមនេះហាមប្រាមការបោះពុម្ពព័ត៌មាន ដែលរួមទាំងរូបនៃជនរងគ្រោះ ការបង្ហាញពីការស្លាប់ របួស ឬភាពអាក្រាតរបស់ជនរងគ្រោះ និងការប្រើពាក្យប្រមាថទៅលើស្ត្រី។ ក្រសួងកិច្ចការនារីថែមទាំងបានប្រកាសពីប្រព័ន្ធធ្វើសេចក្តីរាយការណ៍ នៅក្នុងជួររដ្ឋាភិបាល ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាព នៅក្នុងការឆ្លើយតបរបស់រដ្ឋាភិបាល ចំពោះហឹង្សាទៅលើស្ត្រី។

<u>ការបៀតបៀនផ្លូវភេទ</u>៖ ក្រមព្រហ្មទណ្ឌដាក់ទោសព្រហ្មទណ្ឌចំពោះការបៀតបៀនផ្លូវភេទ ដោយដាក់ពន្ធនាគារពី ៦ ថ្ងៃទៅ ៣ ខែ និងពិន័យជាទឹកប្រាក់បន្តិចបន្តួច។ ការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការត្រូវបានគេជឿថាមានជាទូទៅ( សូមមើលផ្នែក ៧.ឃ )។

នៅថ្ងៃទី ១០ កក្កដា នគរបាលស្រីចំនួន ៤ នាក់បានដាក់លិខិតទៅលោកឧបនាយករដ្ឋមន្ត្រី ស ខេង ដោយនិយាយពីការបៀតបៀនផ្លូវភេទដោយលោក អ៊ុក កុសល មេនគរបាលខេត្តកំពង់ធំ។ លិខិតនោះសរសេរថា ពួកគេបានរាយការណ៍ជាច្រើនលើកមកហើយ តាំងពីឆ្នាំ ២០១៨ មក តែមិនដែលបានទទួលយុត្តិធម៌ឡើយ។ មេនគរបាលនោះបានលាលែង ហើយបានទៅបួស តែក្នុងរយៈពេលប៉ុន្មានថ្ងៃដែលលិខិតនោះលេចលឺដល់សាធារណជន តែគិតមកដល់ខែវិច្ឆិកា គេមិនឃើញតុលាការចាត់វិធានការអ្វីឡើយ។

<u>ការបង្ខិតបង្ខំក្នុងការកំណត់ចំនួនប្រជាជន</u>៖ គ្មានសេចក្តីរាយការណ៍ពីការរំលូតកូនដោយបង្ខំ ការធ្វើមិនអោយមានកូនដោយមិនទៅតាមការស្ម័គ្រចិត្តទេ។

<u>ការរើសអើង</u>៖ រដ្ឋធម្មនុញ្ញចែងអំពីសិទ្ធិស្មើភាពគ្នាសំរាប់ស្ត្រី ការទទួលបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា និងឋានៈស្មើគ្នាក្នុងអាពាហ៍ពិពាហ៍។ អាជ្ញាធរមិនអនុវត្តច្បាប់បានល្អទេ។ ជាទូទៅ ស្ត្រីមានសិទ្ធិលើទ្រព្យសម្បត្តិស្មើភាពគ្នា មានសិទ្ធិតាមផ្លូវច្បាប់ដូចគ្នាក្នុងការដាក់ពាក្យបណ្តឹងលែងលះ និងសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ និងការងារមួយចំនួន។ ប៉ុន្តែ ប្រពៃណីវប្បធម៌ និងការទទួលខុសត្រូវក្នុងការមើលកូនបានកម្រិតលទ្ធភាពរបស់ស្ត្រីក្នុងការឈានទៅដល់ការទទួលបានមុខតំណែងខ្ពស់នៅក្នុងការងារ ឬបានការងារធ្វើ ( សូមមើលផ្នែក ៧ ឃ )។

អាជ្ញាធររំពឹងថា ស្ត្រីស្លៀកពាក់សមស្របតាម "ប្រពៃណីខ្មែរ"។ នៅខែកុម្ភៈ លោកនាយករដ្ឋមន្ត្រីបានចោទស្ត្រីខ្លះថាបាន "ស្លៀកពាក់ខ្លីមុខខ្លីក្រោយ" នៅពេលលក់ទំនិញតាមអ៊ិនធ័រណែត ហើយបានបញ្ជាឲ្យអាជ្ញាធរធ្វើការស៊ើបអង្កេត។ ២ ថ្ងៃក្រោយមក នគរបាលចាប់ខ្លួន រចនា អ្នកលក់តាមហ្វេសបុក ពីបទអាសអាភាស ដោយស្លៀកពាក់ដែល "ប៉ះពាល់កិត្តិយសនារីខ្មែរ"។ នៅថ្ងៃទី ២៤ មេសា នាងត្រូវបានដាក់ទោសឲ្យជាប់ពន្ធនាគារចំនួន ៦ ខែ។

## កុមារ

<u>ការចុះសំបុត្រកំណើត</u>៖ តាមច្បាប់ សញ្ជាតិអាចទទួលបានតាមរយៈកំណើតពីឪពុកម្តាយដែលមិនមែនជាជនជាតិខ្មែរ ក្នុងករណីដែលឪពុកម្តាយទាំងពីរនោះបានកើត និងរស់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា ឬករណីដែលឪពុក/ម្តាយណាម្នាក់ទទួលបានសញ្ជាតិកម្ពុជាតាមរយៈមធ្យោបាយផ្សេងទៀតតាមផ្លូវច្បាប់។ ជនជាតិខ្មែរដើមត្រូវបានចាត់ទុកថាជាពលរដ្ឋ។ ក្រសួងមហាផ្ទៃបានគ្រប់គ្រងប្រព័ន្ធចុះបញ្ជីកំណើតតាមបែបទំនើប ប៉ុន្តែទារកទាំងអស់មិនសុទ្ធតែត្រូវបានចុះបញ្ជីភ្លាមៗឡើយ ពិសេសដោយសារកង្វះការយល់ដឹងពីសារៈសំខាន់នៃការចុះបញ្ជីកំណើត និងអំពើពុករលួយច្រើន របស់អាជ្ញាធរមូលដ្ឋាន។

ការខកខានមិនបានចុះបញ្ជីកំណើតនាំអោយមានការរើសអើង រួមទាំងក្នុងការមិនផ្តល់សេវាសាធារណៈផងដែរ។ កុមារជនជាតិភាគតិច និងកុមារដែលគ្មានសញ្ជាតិច្រើនត្រូវបានផាត់ចេញពីដំណើរការចុះបញ្ជីកំណើត។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាចំពោះសហគមន៍ដែលត្រូវបានគេផាត់ចេញ បានរាយការណ៍ថា ជារឿយៗកុមារដែលគ្មានសំបុត្រកំណើត និងសៀវភៅគ្រួសារ បាត់បង់លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព។ អង្គការមិនមែនរដ្ឋាភិបាលទាំងនោះក៏បានបញ្ជាក់ផងដែរថា អ្នកទាំងនេះច្រើនតែគ្មានលទ្ធភាពក្នុងការទទួលបានការងារធ្វើ ការមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ការចូលរួមបោះឆ្នោត ឬការប្រើប្រាស់ប្រព័ន្ធច្បាប់។

ការសិក្សា៖ ការអប់រំរហូតដល់ថ្នាក់ទី៩ គឺឥតមានបង់ថ្លៃឡើយ ប៉ុន្តែ មិនមែនជាកាតព្វកិច្ចត្រូវតែរៀនទេ។ កុមារជាច្រើនបានឈប់រៀនដើម្បីជួយគ្រួសារក្នុងការងារកសិកម្មលក្ខណៈគ្រួសារ ធ្វើការងារនៅក្នុងសកម្មភាពផ្សេងទៀត ។ អ្នកខ្លះទៀតចូលរៀននៅអាយុច្រើន ឬមិនចូលរៀនសោះតែម្តង។ រដ្ឋាភិបាលមិនបដិសេធក្មេងស្រីក្នុងការទទួលបានការអប់រំស្មើភាពគ្នាទេ។ ប៉ុន្តែ ជារឿយៗ គ្រួសារដែលមានធនធានមានកំរិត ផ្តល់អាទិភាពដល់ក្មេងប្រុសជាងក្មេងស្រី ពិសេសនៅតំបន់ជនបទ។ បើយោងតាមរបាយការណ៍អង្គការអន្តរជាតិ បន្ទាប់ពីកម្រិតបឋមសិក្សា ចំនួនក្មេងស្រីចុះឈ្មោះចូលរៀនធ្លាក់ចុះយ៉ាងខ្លាំងនៅតំបន់ក្រុង ចំណែកការចូលរៀនរបស់ក្មេងប្រុសនៅក្រោយថ្នាក់បឋមសិក្សា មានចំនួនធ្លាក់ចុះច្រើន នៅតំបន់ជនបទ។

<u>ការរំលោភធ្វើបាបកុមារ</u>៖ បើតាមអ្នកសង្កេតការណ៍ ការរំលោភធ្វើបាបកុមារច្រើនកើតមាន ហើយការប្តឹងប្រឆាំងនឹងជនប្រព្រឹត្តកម្រមានណាស់។ បើយោងតាមរបាយការណ៍របស់អង្គការ UNICEF ស្តីពីហឹង្សាលើកុមារ កុមារកម្ពុជាម្នាក់ក្នុងចំណោម ២ នាក់ធ្លាប់រងហឹង្សាខ្លាំង។ ការរំលោភផ្លូវភេទលើកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរនៅឡើយ ហើយសេចក្តីរាយការណ៍ស្តីពីបទល្មើសនេះឃើញមានច្រើនឡើងៗ នៅក្នុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ គិតត្រឹមខែកក្កដា NGO មួយដែលធ្វើការផ្នែកសិទ្ធិមនុស្ស នៅក្នុងស្រុកបានធ្វើការស៊ើបអង្កេតលើបទរំលោភលើសិទ្ធិកុមារចំនួន ៦៧ ករណី ហើយឃើញថា ៥៦គឺជាករណីរំលោភសេពសន្ថវៈ ឬការប៉ុងរំលោភសេពសន្ថវៈ។ នៅថ្ងៃទី ៤ ខែតុលា នគរបាលបានចាប់ខ្លួនកុមារាមានជំងឺសរសៃប្រសាទម្នាក់ ដោយចោទថា លួចរបស់ពីទីស្នាក់ការកណ្តាលរបស់គណបក្សប្រឆាំង។ នគរបាលបានដាក់ខ្នោះគាត់ ហើយបានបង្ខំឲ្យចុះហត្ថលេខាលើយល់ព្រមក្នុងការឈប់ចូលមកក្នុងកន្លែងហាមឃាត់ ហើយបានដោះលែងវិញ ក្រោយឃុំខ្លួនបាន ២ ថ្ងៃ។

ការឆាប់រៀបអាពាហ៍ពិពាហ៍ និងការបង្ខំអោយរៀបអាពាហ៍ពិពាហ៍៖ អាយុគ្រប់ការតាមច្បាប់សំរាប់ក្មេងប្រុស និងក្មេងស្រីគឺ ១៨ ឆ្នាំ តែកុមារអាយុត្រឹម ១៦ ឆ្នាំអាចរៀបការដោយស្របច្បាប់បាន បើមានការយល់ព្រមពីឪពុកម្ដាយ។

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ៖ ការរួមភេទជាមួយកុមារអាយុក្រោម ១៥ ឆ្នាំ គឺជាអំពើខុសច្បាប់។ រដ្ឋាភិបាលបានបន្តចុះឆ្មក់ផ្ទះបន ដើម្បីរកមើល និងប្រមូលជនរងគ្រោះដោយសារការជួញដូរផ្លូវភេទជាកុមារ ថ្វីបើភាគច្រើននៃការជួញដូរផ្លូវភេទលើកុមារមានការលាក់បាំង មាននៅតាមកន្លែងបំរើផ្លូវភេទ "ដោយមិនផ្ទាល់" ដូចជាតាមបៀហ្គាដិន កន្លែងធ្វើម៉ាសា កន្លែងកែសម្ផស្ស បាខារ៉ាអូខេ និងកន្លែងមិនមែនធ្វើពាណិជ្ជកម្មនានា។ នគរបាលបន្តស៊ើបអង្កេតលើករណីជួញដូរកុមារ នៅតាមផ្ទះបន ឬក្នុងករណីដែលជនរងគ្រោះមកប្ដឹងដោយផ្ទាល់ តែមិនធ្វើការលើករណីស្មុគស្មាញខ្លាំងទេ ឧទាហរណ៍ ការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ិនធ័រណែត។ រដ្ឋាភិបាលមិនអនុញ្ញាតអោយមានការប្រើបច្ចេកទេសស៊ើបអង្កេតសំងាត់នៅក្នុងការស៊ើបអង្កេតលើការជួញដូរទេ ដែលជាការធ្វើអោយនគរបាលច្រើនមិនអាចចាប់អោយអ្នកប្រព្រឹត្តិការជួញដូរលើកុមារទទួលខុសត្រូវបានទេ។

ប្រទេសកម្ពុជានៅតែជាគោលដៅទេសចរណ៍ផ្លូវភេទលើកុមារ។ រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ ដើម្បីកាត់ទោសទាំងអ្នកទេសចរផ្លូវភេទ ទាំងពលរដ្ឋដែលកេងប្រវ័ញ្ចកុមារក្នុងពេស្យាចារ។ ច្បាប់ដាក់ទោសជាប់ពន្ធនាគារចាប់ពី ២ ទៅ ២០ ឆ្នាំ ចំពោះការកេងប្រវ័ញ្ច ជួញដូរផ្លូវភេទលើកុមារ។ ច្បាប់នេះក៏ហាមប្រាមផងដែរនូវការផលិត និងការមានរូបអាសអាភាសកុមារ។

អង្គការផ្នែកសិទ្ធិមនុស្ស និងអ្នកជំនាញក្នុងស្រុកបានសំដែងកង្វល់អំពីការខកខានរបស់រដ្ឋាភិបាល ក្នុងការដាក់ទោសអោយបានសមស្របទៅលើជនបរទេសដែលទិញការរួមភេទជាមួយកុមារ។ អំពើពុករលួយដែលរាលដាលនៅគ្រប់ផ្នែកទាំងអស់ក្នុងរដ្ឋាភិបាល ដាក់កំហិតព្រំដែនយ៉ាងខ្លាំងលើលទ្ធភាពរបស់មន្ត្រីម្នាក់ៗ ក្នុងការចាប់អោយជនប្រព្រឹត្តការជួញដូរផ្លូវភេទលើកុមារទទួលខុសត្រូវ ហើយរដ្ឋាភិបាលមិនធ្វើការស៊ើបអង្កេតឬកាត់ទោសមន្ត្រីដែលឃុបឃិតឡើយ។

កុមារផ្លាស់ទីលំនៅ៖ កុមារផ្លាស់ទីលំនៅនៅតែជាបញ្ហាធ្ងន់ធ្ងរ និងកំពុងកើនឡើងខ្លាំង។ រដ្ឋាភិបាលបានផ្ដល់សេវាមានកំរិត និងមិនគ្រប់គ្រាន់ដល់កុមាររស់នៅតាមចិញ្ចើមថ្នល់ នៅមជ្ឈមណ្ឌលស្តារនីតិសម្បទា ដែលមានតែ១ នៅភ្នំពេញ។ នៅឆ្នាំ ២០១៧ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានវាយតម្លៃថា មានកុមារតាមចិញ្ចើមផ្លូវក្នុងចំនួនប្រហែលជាពី ១២០០ ទៅ ១៥០០ នាក់នៅក្នុងរាជធានីភ្នំពេញ ដែលគ្មានទំនាក់ទំនងគ្រួសារ ហើយកុមារប្រមាណជាពី ១៥ ០០០ ទៅ ២០ ០០០នាក់ បានធ្វើការងារនៅតាមចិញ្ចើមផ្លូវ ប៉ុន្តែ បានត្រឡប់ទៅផ្ទះវិញនៅពេលយប់។

កុមារនៅតាមមណ្ឌល អង្គការ៖ អង្គការ NGO និងអ្នកសង្កេតការណ៍ដទៃទៀតបានចោទថា មជ្ឈមណ្ឌលកុមារកំព្រាឯកជនជាច្រើនគ្មានការគ្រប់គ្រងល្អទេ ហើយមានកុមារអត់កំព្រាច្រើន ដើម្បីទាក់ទាញអំណោយពីជនបរ

ទេស។ បើយោងតាមអង្គការ UNICEF និងការស្រាវជ្រាវមួយដែលធ្វើដោយសាកលវិទ្យាល័យ Columbia នៅឆ្នាំ ២០១៨មានកុមារក្នុងចំនួនពី ៣៦ ០០០ ទៅ ៤៩ ០០០ នាក់រស់នៅតាមផ្ទះដែលផ្តល់ការថែទាំ ឬមជ្ឈមណ្ឌលកុមារកំព្រា។ ប្រហែល ៨០% នៃកុមារទាំងនេះមានយ៉ាងហោចណាស់ក៏ឪពុក ឬក៏ម្តាយដែរ។ ការថែទាំអោយស្នាក់នៅតាមផ្ទះនាំអោយមានការលូតលាស់ឬលទ្ធផលសុខភាពទាបសំរាប់កុមារ ហើយធ្វើអោយពួកគេប្រឈមនឹងការកេងប្រវ័ញ្ច នៅពេលអនាគត។ គ្មានកម្មវិធីការពារកុមារដែលដំណើរការឬទ្រទ្រង់ដោយរដ្ឋ សំរាប់ផ្តល់ជម្រើសមានសុវត្ថិភាពសំរាប់កុមារទេ។

ការចាប់ជំរិតកុមារឆ្លងដែន៖ ប្រទេសកម្ពុជាមិនមែនជាហត្ថលេខីនៃអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៨០ ស្តីពីទិដ្ឋភាពស៊ីវិលនៃការចាប់ជំរិតកុមារឆ្លងដែនឡើយ។ សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកស្តីពីការចាប់កុមារឆ្លងដែន តាម travel.state.gov/content/travel/en/International-Parent-Child-Abduction/for-providers/legal-reports-and-data.html ។

### ការប្រឆាំងនឹងសាសនាជ្វីស (Anti-Semitism)

មានសហគមន៍អនិកជនកាន់សាសនាជ្វីសតូចមួយនៅក្នុងរាជធានីភ្នំពេញ ហើយមិនមានរបាយការណ៍អំពី ទង្វើប្រឆាំងនឹងសាសនានេះឡើយ។

## ការជួញដូរមនុស្ស

សូមចូលមើលរបាយការណ៍ស្តីពីការជួញដូរមនុស្ស របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅគេហទំព័រ www.state.gov/trafficking-in-persons-report/ ។

### ជនពិការ

ច្បាប់ហាមប្រាមការរើសអើង ការព្រងើយកន្តើយ ការកេងប្រវ័ញ្ច ឬការបោះបង់ជនពិការ ទាំងពិការរាងកាយ ទាំងពិការផ្នែកសតិបញ្ញា តែមិនត្រូវបានគេអនុវត្តឲ្យមានប្រសិទ្ធភាពទេ។ ច្បាប់នេះមិននិយាយពីការបង្ករលក្ខណៈងាយស្រួលសំរាប់ជនពិការ ក្នុងការធ្វើដំណើរទេ។ ក្រសួងសង្គមកិច្ចជាអ្នកទទួលខុសត្រូវរួមក្នុងការការពារសិទ្ធិរបស់ជនពិការ ថ្វីបើច្បាប់កំណត់ដាក់ភារកិច្ចដោយឡែកជាក់លាក់សំរាប់ក្រសួងដទៃទៀត ដែលរួមមានក្រសួងសុខាភិបាល អប់រំ សាធារណការ និងដឹកជញ្ជូននិងក្រសួងការពារជាតិក្តី។

ជនពិការជួបប្រទះការរើសអើងជាច្រើនពីសង្គម ជាពិសេសក្នុងការទទួលការងារជំនាញ ។

កុមារដែលមានភាពពិការខ្លះៗបានចូលរៀននៅសាលាធម្មតា។ បើយោងតាមរបាយការណ៍ឆ្នាំ ២០១៩ របស់ក្រសួងអប់រំ មានសិស្សពិការចំនួន ៦០ ២៨៤ នៅទូទាំងប្រទេស។ ក្រសួងបានធ្វើការលើការបណ្តុះ

បណ្ដាលគ្រូស្ដីពីវិធីបញ្ចូលសិស្សពិការអោយរៀនជាមួយសិស្សមិនពិការ។កុមារដែលពិការខ្លាំង បានរៀននៅសាលាដោយឡែក ដែលឧបត្ថម្ភដោយអង្គការ NGO នៅភ្នំពេញ។ ការសិក្សាសំរាប់ពួកគេគ្មាននៅក្រៅភ្នំពេញទេ។

ពុំមានការកម្រិតតាមច្បាប់ណាមួយចំពោះសិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមក្នុងកិច្ចការនានារបស់ពលរដ្ឋឡើយ ប៉ុន្តែរដ្ឋាភិបាលមិនបានចូលរួមខិតខំប្រឹងប្រែង ដើម្បីជួយដល់ជនពិការអោយចូលរួមកាន់តែច្រើនក្នុងនាមជាពលរដ្ឋឡើយ ។

## សញ្ជាតិ/ពូជសាសន៍/ជាតិពន្ធុភាគតិច

អ្នកជំនាញបានទទួលស្គាល់ថាមានប្រតិកម្មមិនល្អទៅលើចំនួនកាន់តែច្រើនឡើងនៃជនជាតិចិននៅក្នុងប្រទេស ម្យ៉ាង ដោយសារគេយល់ថា ចិនច្រើនធ្វើសកម្មភាពល្មើស ពិសេសនៅក្រុងព្រះសីហនុ។ កាសែតជាភាសាខ្មែរមានចុះច្រើន នូវរឿងស្ដីពីបទល្មើសដែលប្រព្រឹត្តដោយជនជាតិចិន និងថៅកែចិន នៅកម្ពុជា ដោយរួមមានទាំងហឹង្សាដោយក្រុមយូកូង ការក្លែងក្លាយរបស់ រូបអាសអាភាស ការបើកបរដោយស្រវឹង និងថ្នាំញៀន។ នៅថ្ងៃទី ១៥ សីហា អាជ្ញាធរបានចាប់ខ្លួនចិនចំនួន ២៩ នាក់ ហើយបានចោទពួកគេថា ធ្វើការចាប់ជំរិតមនុស្ស។ នៅខែវិច្ឆិកា អាជ្ញាធរបានរាយការណ៍ថា បានចាប់បញ្ជូនចេញ នូវជនបរទេសចំនួន ៥៤២ នាក់ ដោយសារធ្វើសកម្មភាពខុសច្បាប់ ដោយក្នុងនោះ ភាគច្រើនជាជនជាតិចិន នៅក្នុងរយៈពេល ៩ ខែដំបូង។ នៅថ្ងៃទី ២០ វិច្ឆិកា មន្ត្រីនៅទីក្រុងព្រះសីហនុបានចាប់បញ្ជូនចេញនូវស្ត្រីចិន ២ នាក់ ពីបទពេស្យាចារ។

## អំពើហឹង្សា ការរើសអើង និងអំពើហឹង្សាដោយផ្អែកលើប្រភេទនៃចំណង់ផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ

គ្មានច្បាប់ដែលដាក់ទោសចំពោះការរួមភេទនៃមនុស្សភេទដូចគ្នាដោយមានការព្រមព្រៀងគ្នាទេ ហើយក៏គ្មានការរើសអើងជាផ្លូវការចំពោះក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស បុគ្គលស្រឡាញ់ទាំងពីរភេទ និងបុគ្គលប្តូរភេទ (LGBTI) ទេ ទោះបីជាការរើសអើង និងការពេបជ្រាយនៅតែមានក្តី ជាពិសេសនៅតំបន់ជនបទ។

ជាទូទៅ ក្រុម LGBTI ពុំសូវមានឱកាសទទួលបានការងារធ្វើទេ ដោយសារមានការរើសអើងនិងការផាត់ពួកគេចេញ។ មនុស្សក្នុងក្រុមនេះ ច្រើនតែត្រូវបានគេយាយី និងសំលុត ដោយសារការងាររបស់គេនៅក្នុងកន្លែងកំសាន្ត និងផ្នែកជួញដូរផ្លូវភេទ។

# ផ្នែកទី៧ ៖ សិទ្ធិកម្មករ

## ក. សិទ្ធិបង្កើតអង្គការ/សមាគម និងសិទ្ធិចរចាអនុសញ្ញារួម

ច្បាប់អនុញ្ញាតអោយអ្នកធ្វើការផ្នែកឯកជនបង្កើត និងចូលរួមសហជីពតាមការជ្រើសរើសរបស់ខ្លួនគេផ្ទាល់ សិទ្ធិក្នុងការធ្វើកូដកម្ម និងសិទ្ធិក្នុងការចរចាអនុសញ្ញារួម។ ច្បាប់ដាក់កំហិតព្រំដែនលើសិទ្ធិក្នុងការធ្វើកូដកម្ម សំរួលអន្តរាគមរបស់រដ្ឋាភិបាលនៅក្នុងកិច្ចការផ្ទៃក្នុងរបស់សហជីព ផាត់មិនអោយកម្មករប្រភេទខ្លះចូលរួមក្នុងសហជីព ហើយអនុញ្ញាតអោយភាគីទី៣ ស្វែងរកការរំលាយសហជីព ដោយទន្ទឹមនឹងនោះ ធ្វើការដាក់ពិន័យតិចតួចលើថៅកែចំពោះការប្រព្រឹត្តមិនត្រឹមត្រូវជាមួយកម្មករ។ អាជ្ញាធរមិនបានអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាពទេ។ ការដាក់ពិន័យចំពោះការរើសអើងនៅក្នុងការជ្រើសរើសមនុស្សធ្វើការ និងបណ្តេញចេញពីការងារមានតុល្យភាពជាមួយនឹងការដាក់ពិន័យចំពោះការរើសអើងប្រភេទដទៃទៀត។

ច្បាប់ស្មុគស្មាញស្តីពីការចុះបញ្ជីសហជីពមានន័យថា ជាការទាមទារអោយមានការអនុញ្ញាតជាមុន សំរាប់ការបង្កើតសហជីព។ លក្ខខ័ណ្ឌទាមទារក្នុងការចុះបញ្ជីសហជីពរួមមានការដាក់បញ្ចូលធម្មនុញ្ញ ការស្រង់ឈ្មោះមន្ត្រី និងសមាជិកគ្រួសាររបស់គេ ហើយផ្តល់សេចក្តីលំអិតទាក់ទងនឹងធនាគារ ទៅក្រសួងការងារ។ ច្បាប់ហាមមិនអោយសហជីពដែលមិនបានចុះបញ្ជីការដំណើរការទេ។ មន្ត្រីរាជការ គ្រូបង្រៀន អ្នកធ្វើការនៅតាមសហគ្រាសរដ្ឋ និងអ្នកធ្វើការផ្នែកធនាគារ ផ្នែកថែទាំសុខភាព និងវិស័យក្រៅផ្លូវការ អាចបង្កើតបានតែ "សមាគម" ទេ មិនអាចបង្កើតសហជីពបានទេ។ ការនេះធ្វើអោយគេអាចការពារកម្មករបានតិចជាងសហជីព។ ច្បាប់ថែមទាំងហាមមិនឲ្យអ្នកមិនចេះអក្សរកាន់តួនាទីដឹកនាំសហជីពទេ។ ក្រសួងការងារបានយល់ព្រមលើការបង្កើតសហជីពថ្មីចំនួន ៦៧ នៅក្នុងពេល ៩ ខែដំបូង គឺថយចុះ ៦៣៥ ពីឆ្នាំ ២០១៧ ថ្វីបើរោគរាតត្បាតកូវីដ ១៩ ប្រហែលជាអាចប៉ះពាល់ក្នុងដំណើរការចុះបញ្ជីសហជីពក្តី។

តាមសេចក្តីរាយការណ៍មកថា និយោជកខ្លះមិនព្រមចុះហត្ថលេខាទទួលស្គាល់សហជីពជាផ្លូវការទេ ឬមិនព្រមបន្តកុងត្រារយៈពេលខ្លីដល់កម្មករដែលបានចូលរួមនៅក្នុងសហជីព (កម្មករភាគច្រើន នៅក្នុងវិស័យកម្មន្តសាលផ្លូវការធ្វើការតាមកុងត្រារយៈពេលខ្លី)។ និយោជក និងមន្ត្រីអាជ្ញាធរមូលដ្ឋាន ជាញឹកញាប់ មិនព្រមផ្តល់ឯកសារចាំបាច់សំរាប់ចុះបញ្ជីការសហជីពទេ។ និយោជកខ្លះឆ្លៀតកេងពីដំណើរការយឺតនៃការចុះបញ្ជី ដើម្បីបញ្ឈប់មន្ត្រីសហជីពជាប់ឆ្នោតពីការងារ នៅមុនពេលសហជីពត្រូវបានចុះបញ្ជីការជាផ្លូវការ ដែលជាការធ្វើឲ្យពួកគេមិនអាចបម្រើក្នុងសហជីពបាន ហើយរឹតតែធ្វើឲ្យដំណើរនៃការចុះបញ្ជីសហជីពកាន់តែយឺត។

សកម្មជនការងារបាននិយាយថា ធនាគារជាច្រើនមិនបើកកុងអោយសហជីពដែលមិនទាន់ចុះបញ្ជីទេ ថ្វីបើតាមច្បាប់ សហជីពមិនអាចចុះបញ្ជីបានទេរហូតទាល់តែគេបានផ្តល់ព័ត៌មានលំអិតស្តីពីធនាគារសិន។ អាជ្ញាធរការងារថ្នាក់ខេត្ត តាមសេចក្តីរាយការណ៍មក បានទុកចោលដោយគ្មានកំណត់ថ្ងៃ នូវពាក្យសុំចុះបញ្ជីការ ដោយសួររកឯកសារបន្ថែម ឬអោយដាក់ពាក្យមកសារជាថ្មី ដោយសារមានកំហុសបន្តិចបន្តួច នៅក្នុងរយៈពេលដាក់ពាក្យម្តងៗ ដែលកំណត់ត្រូវមានរយៈពេល ៣០ ថ្ងៃ។ តែមានភស្តុតាងបង្ហាញថា ការធ្វើដូច្នេះមានការថយចុះ ពិសេសសំរាប់សហជីពក្នុងវិស័យកាត់ដេរសំលៀកបំពាក់និងស្បែកជើង។

កម្មករបាននិយាយពីឧបសគ្គនានានៅក្នុងការអនុវត្តសិទ្ធិរបស់គេក្នុងការចូលរួមក្នុងសមាគមដោយសេរី។ មានសេចក្តីរាយការណ៍ពីការរំខានរបស់រដ្ឋាភិបា ទៅលើមេដឹកនាំកម្មករឯករាជ្យ ដោយរួមទាំងការចោទប្រកាន់តាមផ្លូវច្បាប់មិនសមរម្យ។ មេដឹកនាំកម្មករលេចធ្លោមួយចំនួនដែលមានទំនាក់ទំនងជាមួយគណបក្សប្រឆាំង ឬសហជីពឯករាជ្យបានរងការចោទប្រកាន់ ឬស្ថិតនៅក្រោមការតាមមើលរបស់តុលាការ។ ឧទាហរណ៍ នៅខែកក្កដា អាជ្ញាធរបានចាប់ខ្លួនមេដឹកនាំសហជីពដែលបានដឹកនាំជាយូរមក និងជាប្រធាននៃសហភាពនៃសហព័ន្ធសហជីព ដែលគាំទ្រគណបក្សប្រឆាំង គឺលោក រ៉ុង ឈុន ពីបទ "ញុះញង់" ដោយសារតែបាននិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយដោយរិះគន់រដ្ឋាភិបាល ក្នុងជំលោះព្រំដែនជាមួយប្រទេសវៀតណាម។ គិតមកត្រឹមខែវិច្ឆិកា លោកនៅជាប់ឃុំនៅឡើយ។

នៅថ្ងៃទី ១៧ មករា អាជ្ញាធរបានចាប់ខ្លួនមេសហជីព ៤ រូប នៅរោងចក្រធ្វើកាបូបមួយ ហើយបានចោទពួកគេពីបទ "ញុះញង់" ដោយរៀបចំការតវ៉ាមួយ ដើម្បីទាមទារឲ្យចូលធ្វើការវិញ នូវសមាជិកសហជីព ៣ រូប ដែលត្រូវបានបណ្តេញចេញពីការងារ។ អស់រយៈពេលជិត ២ ខែ មន្ត្រីរដ្ឋាភិបាល ដែលតាមសេចក្តីរាយការណ៍មកថាតាមការស្នើរបស់និយោជក គឺក្រុមហ៊ុន Superl Cambodia បានឃុំខ្លួនមេដឹកនាំសហជីពម្នាក់ នៅរោងចក្រមួយដែលធ្វើកាបូបដៃ បន្ទាប់ពីគាត់បានបង្ហោះនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ស្តីពីផែនការរបស់រោងចក្រ ក្នុងការរំលាយកម្មករ។

នៅឆ្នាំ ២០១៩ កម្មករប្រមាណ ១៤០ នាក់ប្រឈមនឹងការការចោទប្រកាន់ព្រហ្មទណ្ឌ ចំពោះសកម្មភាពនៃសហជីពរបស់គេ ដោយប្រហែល ២០ នាក់ត្រូវបានដាក់ទោសដោយតុលាការ។ នេះបើតាមរបាយការណ៍ចេញជាសាធារណៈ។

មានសេចក្តីរាយការណ៍ថា មានជាបន្តនូវទំរង់ដទៃទៀតនៃការយាយី និងពេលខ្លះ ហឹង្សា។ នៅខែកុម្ភៈ បុរសបិទមុខ ៥ នាក់បានវាយប្រហារលើមេដឹកនាំសហជីពម្នាក់ បណ្តាលឲ្យសម្រាកពេទ្យ។ សហជីពខ្លះបានត្អូញត្អែពីរឿងនគរបាលតាមដានសកម្មភាពរបស់គេ ហើយគម្រាមកំហែងអ្នកចូលរួម ដោយបញ្ជូននគរបាលស្លៀកពាក់ឯកសណ្ឋានទៅឈរនៅក្រៅការិយាល័យរបស់គេ ក្នុងពេលប្រជុំ (សូមមើលចំណុច ២.ខ)។ សហជីពកម្មករសំណង់មួយបានត្អូញត្អែរថា អាជ្ញាធរបានរំខានការប្រជុំរបស់គេ ដោយសួររកការចុះបញ្ជីស្នាមរបស់សហជីព និងឯកសារជួលផ្ទះ។

សហជីពមួយចំនួនបាននិយាយពីកំណើននៃការធ្វើទុក្ខ ក្នុងពេលដែលសេដ្ឋកិច្ចមានការធ្លាក់ចុះ ដោយសារមេរោគកូវីដ ១៩។ ឧទាហរណ៍ នៅខែមេសា រោងចក្រចំនួន ២ បានបណ្តេញចេញនូវមេដឹកនាំសហជីពចំនួន ៥ នាក់ បន្ទាប់ពីគេបានរៀបចំការតវ៉ាប្រឆាំងនឹងការសម្រេចចិត្តរបស់រដ្ឋាភិបាល ក្នុងការពន្យារបុណ្យចូលឆ្នាំ។ នៅខែ

កក្កដា សណ្ឋាគារ Le Meridien Hotel នៅសៀមរាប បានបណ្តេញសកម្មជនសហជីពចំនួន ៣ នាក់ ដោយសារតែបានបង្ហោះសារ និងសេចក្តីគាំទ្រមតិដទៃទៀតតាមប្រព័ន្ធផ្សព្វផ្សាយសង្គម សម្រាប់កម្មករ នៅក្នុងសណ្ឋាគារ។

ច្បាប់មានចែងថាកម្មករអាចធ្វើកូដកម្មបាន តែបន្ទាប់ពីបំពេញបានតាមលក្ខខ័ណ្ឌទាមទារមួយចំនួនតែប៉ុណ្ណោះ ដូចជាការចុះបញ្ជីបានត្រឹមត្រូវនៃសហជីព ដូចជាការដែលវិធីសាស្ត្រដោះស្រាយវិវាទដទៃទៀតមិនបានទទួលជោគជ័យ (ដូចជាការចរចារ ការផ្សះផ្សា ឬការដោះស្រាយដោយអាជ្ញាកណ្តាល ជាដើម) ការបញ្ចប់រយៈពេលរង់ចាំ ៦០ ថ្ងៃ បន្ទាប់ពីមានលេចឡើងនូវជំលោះ ការបោះឆ្នោតដោយសម្ងាត់របស់សមាជិកសហជីព និងការជូនដំណឹងជាមុនរយៈពេលប្រាំពីរថ្ងៃទៅកាន់និយោជក និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) ។ អ្នកធ្វើកូដកម្មអាចត្រូវមានទោសព្រហ្មទណ្ឌ បើគេបិទផ្លូវ មាត់ច្រកចូល ឬប្រព្រឹត្តអ្វីផ្សេងទៀត ដែលអាជ្ញាធរមូលដ្ឋានចាត់ទុកថាប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ នៅខែមករា តុលាការបានចេញបញ្ជាបែបនេះ ដោយឲ្យបុគ្គលិកកម្មករ នៅសណ្ឋាគារនិងកាស៊ីណូ NagWorld កុំធ្វើកូដកម្ម។ បុគ្គលិកកម្មករប្រមាណ ៣០០០ នាក់មិនគោរពតាមបទបញ្ជានោះ ហើយបន្តធ្វើកូដកម្ម ដោយនៅទីបំផុត ទទួលបានការដំឡើងប្រាក់ខែ និងការឲ្យចូលធ្វើការវិញ នូវមេដឹកនាំសហជីពម្នាក់ ដែល NagaWorld បានបណ្តេញចេញ។  តុលការអាចចេញសេចក្តីសំរេចប្រឆាំងនឹងការធ្វើកូដកម្ម ហើយតំរូវអោយចាប់ផ្តើមឡើងវិញនូវការចរចាជាមួយនិយោជក។

មានរបាយការណ៍គួរអោយជឿទុកចិត្តថា កម្មករត្រូវបានបណ្តេញចេញពីការងារដោយសារហេតុផលមិនសមរម្យ បន្ទាប់ពីបានរៀបចំ ឬចូលរួមក្នុងកូដកម្ម។ សហជីពផ្តើមកូដកម្មដោយមិនបានបំពេញបានតាមការទាមអារខាងលើនេះទេ ដែលជាការមួយមានភាពខុសច្បាប់ បើតាមបច្ចេកទេស។ នេះបើយោងតាមកម្មវិធីរោងចក្រល្អនៅកម្ពុជា (BFC)។ តែការចូលរួមនៅក្នុងកូដកម្មខុសច្បាប់មិនអាចជាហេតុផល ដែលអាចទទួលយកបានដោយស្របច្បាប់សម្រាប់ការបណ្តេញកម្មករពីការងារឡើយ ។ ក្នុងករណីមួយចំនួន និយោជកមិនបន្តកុងត្រារយៈពេលខ្លីសំរាប់សមាជិកសហជីពដែលសកម្មទេ ហើយក្នុងករណីខ្លះទៀត និយោជកបានគាបសង្កត់អោយកូដករ ឬបុគ្គលិកសហជីពទទួលយកសំណង ហើយលាលែងពីការងាររបស់ខ្លួន ។ រដ្ឋាភិបាលមិនបានដោះស្រាយអោយមានប្រសិទ្ធភាពទេចំពោះការបណ្តេញចេញបែបនេះ។

គណកម្មកាធិការដោះស្រាយបាតុកម្ម កូដកម្មរបស់ក្រសួងការងារបាននិយាយថា នៅក្នុងឆមាសទី ១ មានកម្មករចំនួន ៥០ ៧០០ នាក់បានធ្វើបាតុកម្ម និងកូដកម្មចំនួន ៩២ ដង។ នៅក្នុងអំឡុងពេលដូចគ្នា ក្នុងឆ្នាំ ២០១៩ មានកូដកម្មចំនួន ២៦ ដែលមានការចូលរួមនៃកម្មករចំនួន ១៦ ៥៨៥ នាក់។ របាយការណ៍នោះនិយាយថា គណកម្មាការនេះបានដោះស្រាយដោយជោគជ័យ នូវ ៥៧ ករណី ក្នុងចំណោមករណីទាំង ៩២ ហើយ ៣៥ ករណីទៀតត្រូវ

បានបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ កូដកម្មភាគច្រើនទាក់ទងនឹងប្រាក់ខែដែលមិនត្រូវបានបង់ និងការមិនផ្តល់ប្រាក់អត្ថប្រយោជន៍ បន្ទាប់ពីរោងចក្របិទទ្វារ ដោយសារមេរោគកូវីដ១៩។

នៅក្នុងឆ្នាំនោះ រដ្ឋាភិបាលបានរឹតត្បិតលើសិទ្ធិកម្មករក្នុងការធ្វើការប្រមូលផ្តុំគ្នា។ អាជ្ញាធរបដិសេធសំណើរបស់សហជីពភាគច្រើន ក្នុងការសុំធ្វើការប្រមូលផ្តុំ ដោយសារហេតុផលតម្រូវការរក្សាគម្លាតសង្គម ដែលជាការធ្វើឲ្យមានការពិបាកឋ ឬមិនអាចរៀបចំព្រឹត្តិការណ៍បាន។ សហជីពបានត្អូញត្អែរថា នគរបាលបានរារាំងពួកគេមិនឲ្យនាំគ្នាដើរហែរ ហើយបានបំបែកពួកគេ មុនពេលគេអាចទៅដល់ទីដៅរបស់គេបាន។

ដំណោះស្រាយជំលោះជាមួយកម្មករមានភាពមិនស៊ីចង្វាក់គ្នា មួយភាគធំដោយសារមន្ត្រីរដ្ឋាភិបាលចាត់ទុកជំលោះថា ជាជំលោះ "បុគ្គល" ជាជាងជំលោះ "សមូហភាព"។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយតែជំលោះសមូហភាពទេ។ សហជីពបាននិយាយថា មានភាពជឿនលឿនក្នុងលទ្ធភាពរបស់ "សហជីពមានតំណាងភាគតិច" ក្នុងការធ្វើជំណាងកម្មករ នៅក្នុងជំលោះសមូហភាព។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលឯករាជ្យបានកត់សំគាល់ឃើញថា ខ្លួនបានទទួលករណីចំនួន ៤៥ នៅក្នុងរយៈពេល ៧ ខែដំបូង ហើយចំនួននេះថយពីចំនួន ៦៨ នៅក្នុងរយៈពេលដូចគ្នា នៃឆ្នាំ ២០១៩។

គ្មានតុលាការឯកទេសសំរាប់ជំលោះក្នុងការងារទេ។ ជំលោះការងារដែលត្រូវបានគេកំណត់ថា ជាជំលោះ "បុគ្គល" អាចយកទៅអោយតុលាការដោះស្រាយ ថ្វីបើប្រព័ន្ធតុលាការមានភាពលំអៀង និងគ្មានតំលាភាពក្តី។ ច្បាប់តម្រូវឲ្យមានការធ្វើសេចក្តីរាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដូចជានៅក្រោមកាលៈទេសៈខ្លះ សេចក្តីប្រកាសដែលត្រូវបានធ្វើសវនាការឯករាជ្យ។ តំណាងសហជីពបារម្ភថា គេមិនអាចបំពេញបានតាមការទាមទារជាច្រើនក្នុងច្បាប់។

## ខ. ការហាមការងារដោយបង្ខំ ឬដោយការតំរូវ

ច្បាប់ហាមប្រាមគ្រប់ទំរង់ទាំងអស់នៃការងារដោយបង្ខំ ឬដោយការតំរូវ។

រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះអោយមានប្រសិទ្ធភាពទេ។ ពិន័យដែលកំណត់ដោយច្បាប់ ចំពោះការបង្ខំអោយធ្វើពលកម្ម ឬការជួលមនុស្សឲ្យធ្វើពលកម្មដើម្បីដោះបំណុល (អាចមានទោសជាប់ពន្ធនាគារហូតដល់ ១ ខែ ឬការពិន័យជាប្រាក់) តែវាមិនសមទៅនឹងពិន័យសម្រាប់ទោសធ្ងន់ ដូចជាការចាប់ជំរិត (យ៉ាងហោចណាស់ជាប់ពន្ធនាគារមួយឆ្នាំ)។ មន្ត្រីនានាបាននិយាយថា ការបង្ខំឲ្យធ្វើពលកម្មច្រើនមាននៅក្នុងវិស័យសំណង់។លើសពីនេះទៀត មានភស្តុតាងខ្លះដែលបង្ហាញថា និយោជក ពិសេសម្ចាស់ឡអិដ្ឋ រំលោភលើច្បាប់ហាមប្រាមលើពលកម្មដោយបង្ខំឬទាសភាពបំណុលពលកម្ម ។

ថ្វីបើរដ្ឋាភិបាលប្រឹងប្រែងក្នុងការទាញការចាប់អារម្មណ៍ទៅលើការងារដោយបង្ខំនៅក្នុងប្រទេសក្តី តែប្រសិទ្ធភាពនៃការខិតខំទាំងនេះនៅមិនច្បាស់។

បំណុលដែលជំពាក់ភាគីទី ៣ នៅតែជាបញ្ហាសំខាន់មួយនៅក្នុងការជំរុញអោយមានពលកម្មដោយបង្ខំ។ បើយោងតាមរបាយការណ៍ខែសីហារបស់អង្គការលីកាដូ ប្រជាជនកម្ពុជាចំនួនជាង ២,៦ លាននាក់ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ រហូតដល់ប្រហែល ១០ ពាន់លានដុល្លា ដែលជាការនាំឲ្យមានកំណើននៃពលកម្មកុមារ និងពលកម្មដោយសារជាប់បំណុល។សមាគមមីក្រូហិរញ្ញវត្ថុ និងសមាគមធនាគារកម្ពុជានិយាយថា គ្មានបញ្ហាធំដល់ប៉ុណ្ណឹងទេ។

ការបង្ខំអោយធ្វើការងារលើសម៉ោង នៅតែជាបញ្ហានៅតាមរោងចក្រដែលផលិតរបស់សម្រាប់នាំចេញ។ សហជីព និងកម្មករបាននិយាយថា អ្នកគ្រប់គ្រងខ្លះបញ្ឈប់កម្មករពីការងារ បើគេមិនព្រមធ្វើការលើសម៉ោង។

កុមារក៏ប្រឈមនឹងការបង្ខំអោយធ្វើពលកម្មដែរ (សូមមើលផ្នែក ៧.គ)។

សូមមើលផងដែរនូវរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកដែលមានចំណងជើងថា *របាយការណ៍ស្តីពីការជួញ ដូរមនុស្ស* ដែលមានអាស័យដ្ឋាន www.state.gov/trafficking-in-persons-report/

## គ. ការហាមឃាត់ពលកម្មកុមារ និងអាយុអប្បបរិមាដែលអាចធ្វើការបាន

ច្បាប់បានកំណត់ថា អាយុ១៥ឆ្នាំ គឺជាអាយុអប្បបរិមាសម្រាប់បំពេញការងារ និង អាយុ១៨ ឆ្នាំជាអាយុអប្បបរិមាសម្រាប់បំពេញការងារដែលមានគ្រោះថ្នាក់ ។ ថ្វីបើច្បាប់ហាមពលកម្មកុមារអោយុក្រោម ១៥ ឆ្នាំ តែវាមិនប្រើលើកុមារនៅក្រៅទំនាក់ទំនងការងារក្រៅផ្លូវការទេ។ ច្បាប់អនុញ្ញាតអោយកុមារ អាយុចន្លោះពី១២ ទៅ១៥ឆ្នាំធ្វើ "ការងារស្រាល" ដែលមិនមានគ្រោះថ្នាក់ដល់សុខភាព និងមិនប៉ះពាល់ដល់ការសិក្សារបស់គេ ។ បទបញ្ញាសំរាប់អនុវត្តមាននិយាយច្រើនពីសកម្មភាព ដែលត្រូវបានចាត់ទុកថាជា "ការងារធ្ងន់"។ សកម្មភាពទាំងនេះរួមមានកសិកម្ម ការងារនៅអិដ្ឋ នេសាទ ថ្នាំជក់ និងផលិតកម្មជំឡូង។  ច្បាប់កំណត់ព្រំដែនអោយកុមារដែលស្ថិតក្នុងអាយុពី ១២ ដល់ ១៥ ឆ្នាំ ធ្វើការយ៉ាងច្រើនត្រឹម ៤ ម៉ោងនៅថ្ងៃរៀន និង យ៉ាងច្រើនត្រឹម ៧ ម៉ោងនៅថ្ងៃអត់រៀន ហើយហាមប្រាមការធ្វើការពីម៉ោង ៨ យប់ដល់ម៉ោង ៦ ព្រឹក។

ក្រសួងការងារបានចេញបទបញ្ញាមួយដែលកំណត់ច្បាស់ពីពាក្យថា ការងារតាមផ្ទះ ហើយបានកំណត់អាយុអប្បបរិមាសម្រាប់ការងារតាមផ្ទះ គឺ ១៨ ឆ្នាំ។ តែបទបញ្ញានេះមិនបានកំណត់ពីសិទ្ធិអ្នកធ្វើការតាមផ្ទះឲ្យបងប្អូនទេ។

ថ្វីបើបទបញ្ញានេះចែងពីការពិន័យលើអ្នកដែលរំលោភលើបញ្ញាតិស្តីពីពលកម្មកុមារក្តី តែវាកម្រត្រូវបានគេអនុវត្តណាស់។ ការពិន័យចំពោះការជួលកំលាំងពលកម្មកុមារមិនស៊ីគ្នានឹងការពិន័យចំពោះបទល្មើសធ្ងន់ធ្ងរប្រហាក់ប្រហែលនេះ ដូចជាការចាប់ជំរិត (យ៉ាងហោចណាស់ជាប់ពន្ធនាគារមួយឆ្នាំ) លើកលែងតែការជួលកុមារ

នៅក្នុងស្ថានភាពការងារដែលប៉ះពាល់សុខភាព ឬការលូតលាស់នៃរាងកាយរបស់កុមារ ដែលមានទោសជាប់ពន្ធនាគារពី ២ ទៅ ៥ឆ្នាំ (១០ ឆ្នាំបើស្ថានភាពកងារនោះបណ្តាលឲ្យកុមារស្លាប់)។

អធិការកិច្ចលើពលកម្មកុមារផ្តុំនៅទីក្រុងភ្នំពេញ និងនៅតាមរោងចក្រក្នុងវិស័យផ្លូវការនៅតាមខេត្ត ដែលផលិតទំនិញសំរាប់នាំចេញ ជាជាងតំបន់ជនបទ ដែលមានចំនួនកុមារធ្វើពលកម្មលើសលុប។ ការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ធ្វើអោយអាជ្ញាធរមូលដ្ឋានខ្វះសមត្ថភាពនៅក្នុងការពង្រឹងការអនុវត្តបទបញ្ញាទាំងនេះ ពិសេសនៅតាមតំបន់ជនបទ និងនៅក្នុងវិស័យដែលមានការប្រឈមខ្លាំង។ លើសពីនេះទៀត គណកម្មាធិការជាតិប្រឆាំងពលកម្មកុមារបានិយាយថា អធិការការងារមិនធ្វើអធិការកិច្ចនៅតាមកន្លែងបដិសណ្ឋារកិច្ច ឬកន្លែងក្លិបរាត្រី នៅពេលយប់ទេ ពីព្រោះខ្វះថវិកាសម្រាប់ឲ្យអធិការធ្វើការលើសម៉ោង។ នៅឆ្នាំ ២០១៩ រដ្ឋាភិបាលបានធ្វើការពិន័យលើក្រុមហ៊ុនចំនួនតែ ៣ ទេ ពីបទរំលោភលើបទដ្ឋានពលកម្មកុមារ ។

កុមារជាច្រើនធ្វើការជាមួយឪពុកម្តាយ នៅចំការកៅស៊ូ ចំការស្វាយចន្ទី និងចំការចេក ។ នេះបើតាមសហជីពមួយដែលធ្វើការងារទាក់ទងនឹងវិស័យកសិកម្ម។ ក្នុងចំណោមអ្នកធ្វើការនៅតាមចំការទាំងនោះ មានកុមារពី ៥ ទៅ ១០ ភាគរយ។

កុមារងាយរងនឹងពលកម្មកុមារក្នុងទម្រង់អាក្រក់បំផុត ដូចជានៅក្នុងការងារកសិកម្ម កន្លែងធ្វើអិដ្ឋក្បឿង និងការជួញដូរផ្លូវភេទ (សូមមើលផ្នែក ៦ ស្តីពីកុមារ) ។ ការមិនសូវទទួលបានការសិក្សាជាមូលដ្ឋាន និងការគ្មានកំណត់ថាចាំបាច់ត្រូវអោយរៀនដល់ត្រឹមណានោះ រួមចំណែកធ្វើអោយកុមារងាយរងការកេងប្រវ័ញ្ច។ កុមារមកពីគ្រួសារក្រីក្រងាយរងគ្រោះ ដោយសារគ្រួសារអ្នកមានខ្លះ តាមសេចក្តីរាយការណ៍មកថា ធ្វើជាចិត្តល្អហើយជួលកុមារអោយបំរើការងារក្នុងផ្ទះ តែបែរជារំលោភធ្វើបាប និងកេងប្រវ័ញ្ចទៅវិញ។ កុមារក៏រងផងដែរនូវការបង្ខំអោយដើរសុំទាន។

ពលកម្មកុមារនៅតាមរោងចក្រសំលៀកបំពាក់សំរាប់ការនាំចេញមានការថយចុះច្រើន នៅក្នុងពេលប៉ុន្មានឆ្នាំនេះ។ អ្នកវិភាគខ្លះគិតថា ការនេះបណ្តាលមកពីការគារសង្កត់នៃកម្មវិធីតំរូវអោយមានការកែលំអចាំបាច់របស់កម្មវិធីរោងចក្រល្អនៅកម្ពុជា (BFC) ។ តាំងពីឆ្នាំ ២០១៥ មក BFC បានរកឃើញកុមារធ្វើពលកម្មចំនួនមិនដល់ ២០ នាក់ទេ ក្នុងមួយឆ្នាំ ក្នុងចំណោមរោងចក្រប្រមាណ ៥៥០។ នៅក្នុងរបាយការណ៍សរុបចុងក្រោយរបស់ខ្លួន សំរាប់រយៈ ឆ្នាំ ២០១៩ BFC បានរកឃើញករណីចំនួន ២ ដែលក្នុងនោះ កុមារអាយុក្រោម ១៥ ធ្វើការនៅតាមរោងចក្រកាត់ដេរសម្រាប់នាំចេញ។ តែ BFC និងអង្គការផ្សេងទៀតបានសម្តែងកង្វល់ថា ពលកម្មកុមារនិងការរំលោភផ្សេងទៀតប្រហែលអាចមានច្រើន នៅតាមរោងចក្រផលិតស្បែកជើង និងសម្ភារៈសម្រាប់ការធ្វើដំណើរសម្រាប់ការនាំចេញ ឬអ្នកម៉ៅការបន្ត ពីព្រោះផ្នែកទាំងនេះមិនស្ថិតនៅក្រោមអាណត្តិតាមដានមើលរបស់ BFC ទេ។

សូមចូលមើលផងដែរនូវលទ្ធផលរកឃើញស្តីពីទំរង់អាក្រក់បំផុតនៃពលកម្មកុមាររបស់ក្រសួងការងារសហរដ្ឋអាមេរិក តាមគេហទំព័រ http://www.dol.gov/agencies/ilab/resources/reports/child-labor/findings/។

## ឃ. ការរើសអើងទាក់ទងនឹងការងារ

ច្បាប់ហាមការរើសអើងក្នុងការងារ ដោយសារពូជសាសន៍ ពណ៌សម្បុរ ភេទ ពិការភាព សាសនានា គំនិតនយោបាយ កំណើត ប្រភពដើមក្នុងសង្គម ឬសមាជិកភាពក្នុងសហជីព។ ច្បាប់មិនហាមច្បាស់នូវការរើសអើងដោយផ្អែកលើចំណង់ផ្លូវភេទ អត្តសញ្ញាណយេនឌ័រ អាយុ ភាសា ឬជំងឺឆ្លងទេ។ រដ្ឋធម្មនុញ្ញចែងថា ពលរដ្ឋទាំងពីរភេទទទួលបានប្រាក់បៀវត្សស្មើគ្នា ចំពោះការងារស្មើគ្នា។

ជាទូទៅ រដ្ឋាភិបាលមិនពង្រឹងការគោរពចំពោះច្បាប់ទាំងនេះទេ។ តាមច្បាប់ ទណ្ឌកម្មចំពោះការរើសអើងក្នុងការងាររួមមានការពិន័យជាប្រាក់ សំណងប៉ះប៉ូវរដ្ឋប្បវេណី និងរដ្ឋបាល។

ការបៀតបៀនទៅលើនារីមានច្រើន។ ពិន័យចំពោះការបៀតបៀនផ្លូវភេទ (ជាប់ពន្ធនាគារពី ៦ ថ្ងៃទៅ ៣ ខែ បូកនិងប្រាក់ពិន័យ នេះបើតាមក្រមព្រហ្មទណ្ឌ)មិនសមស្របនឹងពិន័យចំពោះប្រភេទមួយចំនួននៃការជ្រៀតជ្រែកក្នុងការបោះឆ្នោត (ជាប់ពន្ធនាគារពី១ ទៅ ៣ ឆ្នាំ)។ បើយោងតាមរបាយការណ៍របស់ BFC កាលពីឆ្នាំ ២០១៨ កម្មករចំនួន ៣៨% ដែលបានអង្កេតទៅលើ មានអារម្មណ៍មិនល្អ "ជាញឹកញាប់" ឬ "នៅពេលខ្លះ" ដោយសារអាកប្បកិរិយានៅក្នុងរោងចក្រ ហើយ ៤០% នៃកម្មករមិនជឿថា មានប្រព័ន្ធច្បាស់លាស់ និងត្រឹមត្រូវ សំរាប់អោយគេរាយការណ៍ពីការយាយីផ្លូវភេទ នៅក្នុងរោងចក្ររបស់គេទេ។

## ង.លក្ខខ័ណ្ឌការងារដែលអាចទទួលយកបាន

ច្បាប់មិនបានកំណត់បៀវត្សអប្បបរិមាសំរាប់វិស័យណាមួយទេ លើកលែងតែវិស័យកាត់ដេរសំលៀកបំពាក់និងស្បែកជើង។ វាមានច្រើនជាងការប៉ាន់ប្រមាណជាផ្លូវការ សម្រាប់កម្រិតចំណូលនៃអ្នកក្រ។

ច្បាប់មានចែងអំពីរយៈពេលធ្វើការប្រចាំសប្តាហ៍តាមបទដ្ឋានស្របច្បាប់ចំនួន ៤៨ម៉ោង មិនអោយលើសពី ៨ ម៉ោងក្នុងមួយថ្ងៃឡើយ ។ ច្បាប់កំណត់អត្រា ១៣០ ភាគរយនៃប្រាក់ឈ្នួលធ្វើការនៅពេលថ្ងៃ សម្រាប់វេនការងារនៅពេលយប់ និង ១៥០ ភាគរយសម្រាប់ការងារបន្ថែមម៉ោង ដែលត្រូវកើនឡើងដល់ ២០០ ភាគរយ ប្រសិនបើការងារលើសម៉ោងនោះកើតមានឡើងនៅពេលយប់ នៅថ្ងៃអាទិត្យ ឬនៅថ្ងៃឈប់សម្រាក ។ និយោជិកត្រូវបានអនុញ្ញាតអោយធ្វើការលើសម៉ោងយ៉ាងច្រើន ២ ម៉ោងក្នុងមួយថ្ងៃ។ ច្បាប់ហាមការធ្វើការលើសម៉ោងជ្រុល ចែងថាការធ្វើការលើសម៉ោងទាំងអស់ត្រូវតែទៅតាមការស្ម័គ្រចិត្ត ហើយចែងពីការឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល។ អ្នកធ្វើការនៅផ្នែកដឹកជញ្ជូនតាមទឹក និងអាកាសមិនទទួលបានប្រាក់ឧបត្ថម្ភសន្តិសុខសង្គម និងប្រាក់ចូលនិវត្តន៍ទេ ហើយត្រូវបានលើកលែងពីការកំណត់ព្រំដែនម៉ោងការងារ ដែលត្រូវបានចែងដោយច្បាប់។

កម្មករបានរាយការណ៍ថា មានការងារលើសម៉ោងច្រើនហួសកម្រិត ហើយជួនកាលគេតំរូវអោយធ្វើជាចាំបាច់ទៀតផង ។ មានច្រើនគ្នាបានត្អូញត្អែថា ថៅកែបង្ខំអោយគេធ្វើការ ១២ ម៉ោងក្នុងមួយថ្ងៃ ថ្វីបើច្បាប់កំណត់ត្រឹម ១០ ម៉ោងក្តី ដោយរួមទាំងម៉ោងលើសផង។ ជាញឹកញាប់ កម្មករប្រឈមនឹងការបណ្តេញចេញ ការពិន័យ ឬការបាត់បង់ប្រាក់បំណាច់ បើសិនជាគេមិនព្រមធ្វើការថែមម៉ោង។

ក្រសួងការងារគឺជាអ្នកទទួលខុសត្រូវក្នុងការពង្រឹងការអនុវត្តច្បាប់ការងារ តែរដ្ឋាភិបាលមិនបានពង្រឹងការអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពទេ។ ការពិន័យកម្រត្រូវបានវាយតំលៃណាស់ ហើយមានមិនគ្រប់គ្រាន់សំរាប់ដោះស្រាយបញ្ហាទេ។  ការពិន័យចំពោះការរំលោភច្បាប់ ស្តីពីប្រាក់ខែអប្បបរិមា (ជាប់ពន្ធនាគារពី ៦ ថ្ងៃទៅ ១ ខែ)និងការងារលើសម៉ោង (ពិន័យស្មើនឹង ពី ៣១ ទៅ ៦០ ដងនៃប្រាក់បៀវត្សរ៍ធម្មតាប្រចាំថ្ងៃ)។ នៅក្រៅឧស្សាហកម្មកាត់ដេរសម្រាប់ការនាំចេញ អាជ្ញាធរកម្រអនុវត្តច្បាប់កំណត់ម៉ោងការងារណាស់។ អាជ្ញាធរអនុវត្តបទដ្ឋានដោយអន្លើ ដោយសារបុគ្គលិកមិនសូវទទួលបានការបណ្តុះបណ្តាល ខ្វះបរិក្ខារចាំបាច់ និងអំពើពុករលួយ។ មន្ត្រីរបស់ក្រសួងការងារបានសារភាពពីភាពអសមត្ថភាព នៅក្នុងការធ្វើអធិការកិច្ចពេញលេញ លើម៉ោងការងារ ហើយពឹងទាំងស្រុងលើ BFC អោយធ្វើការងារនេះ នៅតាមរោងចក្រដេរសំលៀកបំពាក់សំរាប់នាំចេញ។

ដោយសារក្រុមហ៊ុនសំណង់ និងរោងចក្រឡអិដ្ឋភាគច្រើនដំណើរការក្រៅប្រព័ន្ធ ដោយគ្មានការចុះបញ្ជីកម្មករនៅក្នុងវិស័យនេះមិនសូវទទួលបានប្រាក់ផលប្រយោជន៍ច្រើនទេ។ គ្មានការកំណត់ប្រាក់បៀវត្សរ៍អប្បបរិមាសម្រាប់ពួកគេទេ។ គេគ្មានការធានារ៉ាប់រង ហើយធ្វើការនៅថ្ងៃចុងសប្តាហ៍ និងថ្ងៃបុណ្យ ដោយមានថ្ងៃឈប់តិច។ ភាគច្រើននៃអ្នកធ្វើការតាមឡអិដ្ឋគ្មានទទួលបានការថែទាំសុខភាពដោយឥតបង់ថ្លៃ ពីមូលនិធិសន្តិសុខសង្គមជាតិទេ  ដោយសារកន្លែងទាំងនោះមិនបានចុះបញ្ជីជាសមាជិកនៃមូលនិធិទេ។

តាមច្បាប់ បទដ្ឋានសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការត្រូវតែគ្រប់គ្រាន់សម្រាប់សុខមាលភាពរបស់កម្មករ។ អធិការការងារវាយតំលៃប្រាក់ពិន័យ ដោយយោងទៅតាមរូបមន្តស្មុគស្មាញ ផ្អែកលើភាពធ្ងន់ធ្ងរ និងរយៈពេលនៃកំហុស ព្រមជាមួយនឹងចំនួនកម្មករដែលទទួលរង។ អធិការរបស់ក្រសួងការងារមានអំណាចវាយតំលៃប្រាក់ពិន័យទាំងនេះ នៅនឹងកន្លែង ដោយមិនបាច់មានការសហការពីនគរបាលទេ តែគ្មានបទបញ្ញត្តិជាក់ច្បាស់ណាមួយសំរាប់ការពារកម្មករ ដែលតវ៉ាពីស្ថានភាពប៉ះពាល់ដល់សុខភាព ឬគ្មានសុវត្ថិភាពទេ។ ការធ្វើអធិការកិច្ចដោយអាជ្ញាធរ នៅកន្លែងសំណង់ គឺមិនគ្រប់គ្រាន់ទេ។ ការពិន័យចំពោះការរំលោភលើច្បាប់ស្តីពីសុវត្ថិភាព និងសុខភាពនៅកន្លែងការងារ (តាមធម្មតាបង់ពិន័យពី ៣០ ទៅ ១២០ ដងនៃប្រាក់បៀវត្សរ៍ធម្មតាប្រចាំថ្ងៃ) គឺមិនស្របតាមទណ្ឌកម្មចំពោះបទល្មើសប្រហាក់ប្រហែលគ្នានេះ ដូចជាការបន្លំ (ដែលត្រូវជាប់ពន្ធនាគារពី ៦ ខែទៅ ៣ ឆ្នាំ)។

ការដួលសន្លប់ទាំងហ្វូងៗនៅតែជាបញ្ហាមួយនៅឡើយ។ NSSF បាននិយាយថា កម្មករចំនួន ២៣៩ នាក់បានដួលសន្លប់នៅក្នុងរោងចក្រចំនួន ៣ នៅក្នុងរយៈពេល ៦ ខែដំបូង។ ចំនួននេះថយចុះពីចំនួន ៤១៧ នាក់ដែលបានដួលសន្លប់ នៅក្នុងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៩។ អ្នកសង្កេតការណ៍បាននិយាយពីការធ្វើការលើសម៉ោងជ្រុល សុខភាពទ្រុឌទ្រោម ការដេកមិនគ្រប់ ខ្យល់ចេញចូលមិនល្អ កង្វះអាហារូបត្ថម្ភត្រឹមត្រូវសំរាប់កម្មករ ថ្នាំ

SENSITIVE BUT UNCLASSIFIED

សំលាប់សត្វចង្រៃត្រូវបានបាញ់នៅក្នុងវាលស្រែក្បែរខាង ហើយចំហាយជាតិពុលចេញមកពីសកម្មភាពផលិតកម្មក៏មានចំណែកធ្វើអោយកម្មករសន្លប់ច្រើនគ្នាផងដែរ។

ការគោរពតាមបទដ្ឋានសុវត្ថិភាពការងារ និងសុខភាពនៅតែជាបញ្ហាប្រឈមមួយ នៅក្នុងវិស័យនាំចេញសំលៀកបំពាក់ ជាទូទៅដោយសារនិតិវិធី និងគោលនយោបាយរបស់ក្រុមហ៊ុនមិនសមស្រប ហើយនិងការទទួលខុសត្រូវ និងតួនាទីគ្រប់គ្រងមិនត្រូវបានកំណត់ច្បាស់។

កម្មករ និងអង្គការពលកម្មនានាមានកង្វល់ផងដែរថា ការប្រើកុងត្រារយៈពេលខ្លី ពិសេសនៅក្នុងវិស័យកាត់ដេរ ដែលច្រើនគ្មានកំណើននៃផលិតភាព អនុញ្ញាតអោយក្រុមហ៊ុនគេចផុតពីលក្ខខ័ណ្ឌទាមទារខ្លះតាមច្បាប់ និងលើប្រាក់បៀវត្ស។ កុងត្រារយៈពេលខ្លីថែមទាំងអនុញ្ញាតអោយថៅកែមានសេរីភាពច្រើន ក្នុងការបញ្ចប់ការងាររបស់អ្នករៀបចំបង្កើតសហជីព និងនារីមានផ្ទៃពោះ ដោយគ្រាន់តែមិនបន្តកុងត្រាអោយពួកគេ។ ច្បាប់កំណត់រយៈពេលអោយអនុវត្តកុងត្រាបែបនេះច្រើនបំផុតត្រឹមតែ ២៤ ខែ តែសាលាចរណ៍ថ្មីៗអនុញ្ញាតឲ្យនិយោជកបន្តរយៈពេលនៃការអនុវត្តបែបនេះដល់ ៤ ឆ្នាំ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអង្គការ ILO បានជំទាស់នឹងការបកស្រាយច្បាប់នេះ ដោយកត់សម្គាល់ថា ក្រោយរយៈពេល ២៤ ខែ កម្មករត្រូវតែទទួលបាន "កុងត្រាដែលមានរយៈពេលមិនកំណត់ព្រំដែន" អចិន្ត្រៃយ៍ (សូមមើលផ្នែក ៧.ក)។

របួសនៅក្នុងការងារ និងបញ្ហាសុខភាពនៅតែកើតមានច្រើន។ នៅថ្ងៃទី ៤ មករា អាគារមួយដែលកំពុងត្រូវបានសាងសង់ នៅកែប បានរលំ បណ្តាលឲ្យស្លាប់កម្មករខ្មែរចំនួន ៣៦ នាក់ ហើយ ២៣ នាក់ទៀតរបួស។ នៅខែកក្កដា ជងសន្ទូចមួយបានរលំ នៅការដ្ឋានសំណង់ នៅក្រុងប៉ោយប៉ែត ហើយបណ្តាលឲ្យមនុស្ស ៥ នាក់ស្លាប់។

# ឧបសម្ព័ន្ធទី១១ ៖
# របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងរបាយការណ៍របស់អគ្គលេខាធិការ ឆ្នាំ២០២០

អង្គការសហប្រជាជាតិ A/HRC/45/56

# មហាសន្និបាត

ចែកចាយ៖ ទូទៅ
៤ សីហា ២០២០
ឯកសារដើម៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីសែសិបប្រាំ**
ថ្ងៃទី១៤ ខែកញ្ញា ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០
របៀបវារៈចំណុចទី២ និង ទី១០
**របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យ ឧត្តមស្នងការ និងអគ្គលេខាធិការ**

**ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

## តួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស

## របាយការណ៍របស់អគ្គលេខាធិការ

*សេចក្ដីសង្ខេប*

បានដាក់បញ្ជូនស្របតាមសេចក្ដីសម្រេចចិត្តលេខ៤២/៣៧ របស់ក្រុមប្រឹក្សាសិទ្ធមនុស្ស របាយការណ៍នេះបង្ហាញពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (ការិយាល័យOHCHR) ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។

រយៈពេលនេះ មានការកត់សម្គាល់ឃើញថា មានការរួមតូចនៃលំហាពលរដ្ឋ និងភាពតានតឹងផ្នែកនយោបាយនៅតែបន្តមាន។ ការិយាល័យOHCHR បានបន្តផ្ដល់កិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងវិស័យសំខាន់ៗមួយចំនួន រួមមាន ការពង្រឹងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ និងការពារសេរីភាពជាមូលដ្ឋាន និងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ការិយាល័យ ក៏បានលើកឡើងផងដែរអំពីផលប៉ះពាល់ខាងសិទ្ធិមនុស្ស ដោយសារការរាតត្បាតនៃជំងឺកូរ៉ូណាថ្មី (ជំងឺកូវីដ-១៩)។

# I. សេចក្តីផ្តើម

១. ការរៀបចំរបាយការណ៍ ស្របតាមសេចក្តីសម្រេចលេខ ៤២/៣៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍នេះបង្ហាញពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យOHCHR) ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។ របាយការណ៍នេះ ធ្វើបច្ចុប្បន្នភាពលើរបាយការណ៍របស់អគ្គលេខាធិការស្តីពីប្រធានបទតែមួយ ដែលបានបង្ហាញជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនាសម័យប្រជុំលើកទីសែសិបពីររបស់ខ្លួន (A/HRC/42/31) ។ ការិយាល័យOHCHR ទទួលបានសេចក្តីផ្តល់មតិជាអង្គហេតុលើសេចក្តីព្រាងរបាយការណ៍ពីរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ហើយសេចក្តីផ្តល់មតិទាំងនេះ ត្រូវបានរួមបញ្ចូលនៅត្រង់ចំណុចដែលសមស្រប។

២. នៅទូទាំងរយៈពេលនៃរបាយការណ៍នេះ ការិយាល័យOHCHR បានបន្តសកម្មភាពកិច្ចសហ-ប្រតិបត្តិការបច្ចេកទេសជាមួយស្ថាប័នតុលាការ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ក្រុមប្រឹក្សាសកម្មភាពជនពិការនិងតួអង្គរដ្ឋាភិបាល និងសង្គមស៊ីវិលដទៃទៀត។ ការិយាល័យOHCHR បានបន្តឃ្លាំមើលស្ថានភាពសិទ្ធិមនុស្ស រួមទាំងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ការប្រើប្រាស់សិទ្ធិសេរីភាពជាមូលដ្ឋាន សិទ្ធិចូលរួមក្នុងជីវភាពពលរដ្ឋ និងនយោបាយ ដំណើរការជំនុំជម្រះក្តី និងស្ថានភាពនៅកន្លែងឃុំឃាំង។ ការិយាល័យ OHCHR ក៏បានកែសម្រួលសកម្មភាពសហប្រតិបត្តិការបច្ចេកទេសរបស់ខ្លួនផងដែរ ដើម្បីឆ្លើយតបទៅនឹងការផ្ទុះឡើងនៃជំងឺកូរ៉ូណាថ្មី (ជំងឺកូវីដ-១៩) នៅកម្ពុជា។

៣. ការិយាល័យOHCHR បានបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា ដឹកនាំក្រុមប្រធានបទសិទ្ធិមនុស្ស។ ការិយាល័យ បានគាំទ្រការបញ្ជ្រាបសិទ្ធិមនុស្ស ក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិសម្រាប់ ឆ្នាំ២០១៩-២០២៣ និងសហដឹកនាំក្រុមលទ្ធផលស្តីពីការចូលរួម និងគណនេយ្យភាព។ ការិយាល័យOHCHR បានគាំទ្រផងដែរនូវសកម្មភាពរួមគ្នារបស់អង្គការសហប្រជាជាតិ ដែលរួមមានការឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដើម្បីលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា។[1]

# II. បរិបទ

៤. ការិយាល័យOHCHR បានផ្តល់ជំនួយផ្នែកបច្ចេកទេសដល់រដ្ឋាភិបាល ក្នុងបរិបទផ្លាស់ប្តូរមួយ។ ទោះបីជាប្រទេសកម្ពុជា រួចផុតពីទំហំនៃអត្រាប្រេវ៉ាឡង់នៃជំងឺកូវីដ-១៩ ដែលធ្លាប់មាននៅប្រទេសមួយចំនួនដទៃទៀតក៏ដោយ ក៏រោគរាតត្បាតទាមទារឲ្យមានអ្នកជំនួយការដ៏សំខាន់

[1] មាត្រា១២ នៃកតិកាសញ្ញាអន្តរជាតិ (គ) (២)ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលកម្ពុជាគឺជារដ្ឋភាគី តម្រូវឱ្យរដ្ឋាភិបាលចាត់វិធានការការពារព្យាបាល និងត្រួតពិនិត្យជំងឺឆ្លង ជំងឺរាតត្បាត និងជំងឺបណ្តាលមកពីវិជ្ជាជីវៈ និងជំងឺផ្សេងទៀត។ មាត្រា៧២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏តម្រូវផងដែរ ឱ្យរដ្ឋាភិបាល យកចិត្តទុកដាក់យ៉ាងពេញលេញដល់ការការពារជំងឺ" និងព្យាបាលជំងឺ។"

នៅក្នុងសកម្មភាពការិយាល័យOHCHR ដោយថ្លឹងថ្លែងនឹងតម្រូវការសម្រាប់ការចូលរួមជាបន្តលើបញ្ហាស្នូលមួយចំនួនដែលពាក់ព័ន្ធ។

៥. ការិយាល័យOHCHR បានផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាល ដោយព្យាយាមធានាថាការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះជំងឺកូវីដ-១៩ មានភាពស្របគ្នានឹងកាតព្វកិច្ចរបស់ខ្លួន ក្នុងការចាត់វាល់វិធានការចាំបាច់ ដើម្បីការពារ ព្យាបាល និងគ្រប់គ្រងជំងឺ ដែលជាផ្នែកមួយនៃសិទ្ធិទទួលបានសុខភាព។[2] ធានាថាគ្មាននរណាម្នាក់ត្រូវគេទុកចោល ការិយាល័យOHCHR បានតស៊ូមតិឲ្យមានការអនុម័តនូវវិធានការពិសេសមួយចំនួន ដើម្បីការពារក្រុម និងបុគ្គលដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ជាពិសេសដោយជំងឺឆ្លង រួមទាំង ជនជាតិដើមភាគតិច និងជនជាតិភាគតិច បុគ្គលទាំងឡាយដែលត្រូវបានគេដកហូតសេរីភាព ប្រជាជនក្រីក្រ និងសហ-គមន៍ជនបទ។

៦- នៅក្នុងបរិបទនោះដែរ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ច្បាប់ស្ដីពីការគ្រប់គ្រងប្រទេសក្នុងស្ថានភាពអាសន្នបានចូលជាធរមាន។ ដោយបានធ្វើឡើងឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ដោយគ្មានការពិគ្រោះយោបល់ជាសាធារណៈ សេចក្ដីព្រាងច្បាប់ផ្ដល់អំណាចដល់រដ្ឋាភិបាលក្នុងការប្រកាសភាពអាសន្នដល់ទៅបីខែ ដែលអាចពន្យាពេល ៣ ខែទៀត ដោយមិនចាំបាច់ពិនិត្យឡើងវិញ។ សេចក្ដីព្រាងច្បាប់នេះ អនុញ្ញាតផងដែរ ឲ្យដាក់ការរឹតត្បិតលើ សិទ្ធិសេរីភាពក្នុងការដើរហើរ និងការជួបប្រជុំ សិទ្ធិទទួលបានព័ត៌មាន សិទ្ធិឯកជន និងសិទ្ធិការងារ ក្នុងចំណោមសិទ្ធិដទៃទៀត។ អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងនីតិវិធីពិសេសផ្សេងៗទៀតរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស[3] បានផ្ញើលិខិតឧបាស្រ័យ[4] មួយច្បាប់ទៅរដ្ឋាភិបាល អំពីច្បាប់នោះ។ នៅក្នុងសេចក្ដីថ្លែងការណ៍រួមគ្នាមួយ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០២០ អ្នកកាន់អាណត្តិនីតិវិធីពិសេសមួយចំនួនបានលើកឡើងថា សេចក្ដីព្រាងច្បាប់នេះអាចប្រឈមនឹងហានិភ័យនៃ " ការរំលោភសិទ្ធិឯកជន ការបំបិទសេរីភាពបញ្ចេញមតិ និងដាក់ទោសព្រហ្មទណ្ឌដល់ការជួបប្រជុំដោយសន្តិវិធី"[5] ។ ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀតនៅទីក្រុងហ្សឺណែវ បានចេញនូវលិខិតឆ្លើយតបមួយច្បាប់[6] ដោយបញ្ជាក់ថាច្បាប់នេះ "ត្រូវបានអនុញ្ញាតិដោយឧបករណ៍សិទ្ធិមនុស្សជាតិនិងអន្តរជាតិ ដែលហៅថារដ្ឋធម្មនុញ្ញ" ការិយាល័យOHCHR ចែករំលែកក្ដីកង្វល់របស់អ្នករាយការណ៍ពិសេស ទាំងចំពោះបញ្ហានេះ ទាំងអំពីការអនុម័ត

[2] សូមមើល www.ohchr.org/EN/NewsEvents/Pages/COVID19Guidance.aspx

[3] ដែលមានឈ្មោះថាអ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិជនគ្រប់រូបក្នុងការទទួលបានបទដ្ឋានខ្ពស់បំផុតនៃសុខភាពរាងកាយ និងផ្លូវចិត្ត អ្នករាយការណ៍ពិសេសស្ដីពីការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ក្នុងពេលកំពុងប្រឆាំងនឹងអំពើភេរវកម្ម និងក្រុមការងារស្ដីពីការឃុំឃាំងដោយបំពាន។

[4] KHM១ដែលមាននៅ ២០២០/លើគេហទំព័រ https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile? GId = 25186

[5] អ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិជនគ្រប់រូបក្នុងការទទួលបានបទដ្ឋានខ្ពស់បំផុតនៃសុខភាពរាងកាយ និងផ្លូវចិត្ត អ្នករាយការណ៍ពិសេសស្ដីពីការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ក្នុងពេលកំពុងប្រឆាំងនឹងអំពើភេរវកម្ម អ្នករាយការណ៍ពិសេសស្ដីពីការសម្លាប់ភ្លាមៗ ឬដោយបំពាន ក្រៅប្រព័ន្ធតុលាការ និងក្រុមការងារស្ដីពីការឃុំខ្លួនដោយបំពាន។ សូមមើលគេហទំព័រ www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx? newsID = 25801 & LangID = E

[6] សូមមើលគេហទំព័រ https://spcommreports.ohchr.org/TMResultsBase/DownLoadFile?gId=35228

ច្បាប់ជាបន្ទាន់ និងទាំងខ្លឹមសារនៃច្បាប់នេះ ហើយថាបទប្បញ្ញត្តិទាក់ទងនឹងបដិប្បញ្ញត្តិគឺភាពមិនច្បាស់លាស់ និងទូលំទូលាយពេក នៅក្នុងវិសាលភាព និងដាក់ឱ្យស្ថិតក្នុងការពិនិត្យឡើងវិញ និងការត្រួតពិនិត្យមិនគ្រប់គ្រាន់។

៧. ការិយាល័យOHCHR បានផ្តល់ផងដែរនូវជំនួយបច្ចេកទេស ក្នុងបរិបទនៃការធ្លាក់ចុះនូវលំហរពលរដ្ឋ និងភាពតានតឹងផ្នែកនយោបាយដែលកំពុងបន្តមាន។ លោក សម រង្ស៊ី មេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំដទៃទៀត នៃគណបក្សប្រឆាំងដ៏ធំមួយ គឺគណបក្សសង្គ្រោះជាតិកម្ពុជា បានប្រកាសថា លោកនឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញពីការនិរទេសខ្លួនដោយបង្ខំ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលជាថ្ងៃបុណ្យឯករាជ្យ។ ការប្រកាសនេះ បានឃើញមានការដាក់ពង្រាយកងកំលាំងសន្តិសុខនៅទូទាំងប្រទេស និងការបិទព្រំដែនមួយផ្នែកជាមួយប្រទេសថៃ ដើម្បីរារាំងការចូលជាថ្មីរបស់គាត់។ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា "បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងអំពីការកើនឡើងខ្ពស់នៃការបង្ក្រាប បែបនយោបាយនៅទូទាំងប្រទេស ដោយអំពាវនាវឱ្យរដ្ឋាភិបាល គោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំ"។[7]

៨. ទោះបីជា លោក សមរង្ស៊ី នៅទីបំផុត មិនបានវិលត្រឡប់មកស្រុកវិញក៏ដោយ ក៏នៅចន្លោះពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ និងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០ យ៉ាងហោចណាស់ក៏មានមនុស្សចំនួន ១៤០ នាក់ដែរ ដែលជាប់ទាក់ទងជាមួយអតីតគណបក្សសង្គ្រោះជាតិកម្ពុជា ត្រូវបានចាប់ខ្លួន ការចោទប្រកាន់ពីបទរួមគំនិតក្បត់ប្រឆាំងនឹងរដ្ឋ ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ និងការមិនគោរពតាមសេចក្តីសម្រេចរបស់តុលាការ និងត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ការនេះ បានលើកឡើងជាកង្វល់ដ៏ធ្ងន់ធ្ងរអំពីសិទ្ធិមនុស្ស ដោយសារមានករណីជាច្រើន ដែលអាជ្ញាធរមិនបានគោរពច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីការចាប់ខ្លួន នីតិវិធីត្រឹមត្រូវ និងការដកហូតសេរីភាព។ នេះរួមទាំង ការគ្មានដីកាចាប់ខ្លួន ការមិនបានផ្តល់ហេតុផលសម្រាប់ការចាប់ខ្លួន ការមិនអាចជួបមេធាវី និងសមាជិកគ្រួសារ ប្រព្រឹត្តកម្មបែបរើសអើងនៅក្នុងកន្លែងឃុំឃាំង និងអូសបន្លាយរយៈពេលឃុំខ្លួន ដោយគ្មានការជំនុំជម្រះ នៅក្នុងអគារដែលមានមនុស្សច្រើនចង្អៀតណែន។

៩. នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ការជំនុំជម្រះក្តី លោក កឹម សុខា អតីតមេដឹកនាំមួយរូបទៀតនៃគណបក្សសង្គ្រោះជាតិកម្ពុជា បានផ្តើមធ្វើនៅសាលាដំបូងរាជធានីភ្នំពេញ។ ការជំនុំជម្រះរបស់គាត់គឺបានលើកពេលដោយគ្មានកំណត់ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដោយហេតុផលនៃជំងឺកូវីដ-១៩។ គាត់ត្រូវបានចោទប្រកាន់ពីបទ "សន្ទិដ្ឋិភាពជាមួយបរទេស" [8] លោក កឹម សុខា ប្រឈមនឹងការជាប់ពន្ធនាគារពី១៥ ឆ្នាំទៅ ៣០ ឆ្នាំ ប្រសិនជាត្រូវបានផ្តន្ទាទោស។ អ្នកកាន់អាណត្តិនីតិវិធីពិសេសមួយចំនួន បានកត់សម្គាល់នៅក្នុងសេចក្តីថ្លែងការណ៍មួយនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ដែលមាន "មូលដ្ឋានរឹងមាំអាចជឿបានថា បទចោទក្បត់

[7] សូមមើលគេហទំព័រ www.ohchr.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=25260&LangID=E

[8] មាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០)) ។

ជាតិ លើរូប លោក សុខា "គឺ" ជាហេតុផលនយោបាយ និងជាផ្នែកមួយនៃលំនាំដ៏ធំមួយនៃការប្រើប្រាស់ច្បាប់មិនត្រឹមត្រូវ ដែលតម្រង់គោលដៅទៅលើគូប្រជែងនយោបាយ និងការរិះគន់រដ្ឋាភិបាល។[9] រដ្ឋាភិបាលបានចេញសេចក្តីប្រកាសព័ត៌មាន ក្នុងការឆ្លើយតប។[10]

១០. ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ចែករំលែកកង្វល់នៅក្នុងវិស័យទាំងនេះ។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ នៅក្នុងការធ្វើបច្ចុប្បន្នភាពជាសកល នាសម័យប្រជុំលើកទីសែសិបបីរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ឧត្តមស្នងការបានថ្លែងថា៖ "នៅប្រទេសកម្ពុជា យើងនៅតែបន្តទទួលបានរបាយការណ៍ស្តីពីសកម្មភាពបំភិតបំភ័យទៅលើសង្គមស៊ីវិល និងអង្គការសិទ្ធិមនុស្សផ្សេងៗ ដែលរារាំងដល់សមត្ថភាពរបស់ពួកគេក្នុងការឃ្លាំមើល និងរាយការណ៍ រួមទាំង ទៅក្រុមប្រឹក្សានេះផងដែរ។ អ្នករិះគន់ និងគូប្រជែងនយោបាយក៏នៅតែបន្តក្លាយជាគោលដៅ តាមរយៈវិធានការគាបសង្កត់ រួមមាន ការឃុំខ្លួនដោយបំពាន និងការប្រើប្រាស់ខុសយ៉ាងច្បាស់ក្រឡែតនូវច្បាប់ព្រហ្មទណ្ឌ។ ទោះបីជាមានកិច្ចសហការរបស់អាជ្ញាធរជាមួយការិយាល័យលើផ្នែកបច្ចេកទេស និងសកម្មភាពកសាងសមត្ថភាពត្រូវបានស្វាគមន៍ក្តី ក៏ខ្ញុំសូមអំពាវនាវឱ្យរដ្ឋាភិបាលគោរពការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការលើកស្ទួយសិទ្ធិមនុស្សទាំងអស់របស់ប្រជាជនរបស់ខ្លួន រួមទាំងសិទ្ធិសេរីភាពប្រព័ន្ធផ្សព្វផ្សាយ នីតិរដ្ឋមិនលំអៀង និងសិទ្ធិចូលរួមដោយសេរីក្នុងកិច្ចការសាធារណៈ ដោយមិនភ័យខ្លាចការធ្វើទុក្ខបុកម្នេញ"[11]

## III. ការលើកកម្ពស់ការចូលរួម និងការការពារលំហាពលរដ្ឋ

១១. លំហាពលរដ្ឋ និងប្រជាធិបតេយ្យបានបន្តធ្លាក់ចុះ ចាប់តាំងពីគណបក្សសង្គ្រោះជាតិកម្ពុជា (CNRP) ត្រូវបានតុលាការកំពូលរំលាយក្នុងឆ្នាំ២០១៧។ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងអ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ បានផ្ញើលិខិតឧបាស្រ័យ[12] ទៅរដ្ឋាភិបាល ស្នើឱ្យដោះស្រាយបញ្ហា "ការប្រើប្រាស់អាជ្ញាធរនគរបាល និងតុលាការ ដើម្បីបំភិតបំភ័យ យាយីរំខាន ឬឃុំខ្លួន" អតីតសមាជិក និងអ្នកគាំទ្រគណបក្សសង្គ្រោះជាតិកម្ពុជា "ដោយសារតែពួកគេបានប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធីរបស់ខ្លួន"។

[9] អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ និងអ្នករាយការណ៍ពិសេសស្តីពីឯករាជ្យភាពចៅក្រម និងមេធាវី។ សូមមើលគេហទំព័រ https://cambodia.ohchr.org/sites/default/files/pressstatementsource/emSokhaTrial_Final_EN.pdf

[10] មាននៅលើគេហទំព័រ www.facebook.com/cambodiaembassy.ch/posts/2271392509820033

[11] សូមមើលគេហទំព័រ www.ohchr.org/EN/HRBodies/HRC/Pages/NewsDetail.aspx?NewsID=25621&LangID=E

[12] KHM ២មាននៅ ២០៩៩/លើគេហទំព័រ https://spcommreports.ohchr.org/TMResultsBase/DownLoadPublicCommunicationFile?GId = 24636

១២. ទោះជាមានការដកលក្ខខណ្ឌតម្រូវឱ្យអង្គការសង្គមស៊ីវិល ផ្ដល់ការជូនដំណឹងរយៈពេល ៣ ថ្ងៃមុនសកម្មភាពដែលបានគ្រោងទុក[13] ចាប់ពីខែមិថុនា ឆ្នាំ២០១៩ ដល់ខែមេសា ឆ្នាំ២០២០ ក្ដី ក៏ការិយាល័យOHCHR បានចងក្រងឯកសារចំនួន ៤៦ ករណី ដែលសកម្មភាពរបស់អង្គការសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិលមួយចំនួន បានទទួលរងនូវការជ្រៀតជ្រែករំខានហួសហេតុ ការបំភិតបំភ័យ ឬការឃាយឃីពីសំណាក់អាជ្ញាធរ។ យ៉ាងហោចណាស់ក៏មានចំនួន ៣ ករណី ដែរ ស្ថិតក្នុងវត្តមានរបស់ការិយាល័យOHCHR ដែលមន្ត្រីនគរបាលបានបង្គាប់ឱ្យអង្គការសង្គមស៊ីវិល សុំការអនុញ្ញាតជាមុន មុនការប្រជុំដែលបានគ្រោងទុក ឬបានប៉ុនប៉ងចូលក្នុងទីតាំងបរិវេណឯកជន ដើម្បីថតរូប និងប្រមូលព័ត៌មានអំពីអ្នកចូលរួមក្នុងអំឡុងពេលនៃព្រឹត្តិការណ៍។ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ ការិយាល័យOHCHR បានផ្ញើលិខិតមួយច្បាប់ទៅក្រសួងមហាផ្ទៃ ពិពណ៌នាអំពីករណីដែលបានរាយការណ៍អំពីការជ្រៀតជ្រែករំខានក្នុងសកម្មភាពរបស់សង្គមស៊ីវិល ដោយលើកឡើងពីកង្វល់មួយចំនួនថា សកម្មភាពបែបនេះ អាចរឹតត្បិតមិនសមហេតុផលលើសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងជាសមាគម និងបង្កើតបរិយាកាសភ័យខ្លាច និងការបំភិតបំភ័យ។ ការិយាល័យOHCHR មិនបានទទួលការឆ្លើយតបពីក្រសួងមហាផ្ទៃទៅនឹងលិខិតរបស់ខ្លួនឡើយ។

១៣. ការិយាល័យOHCHR បានបន្តចូលរួមជាមួយរដ្ឋាភិបាល លើសំណើដែលស្នើសុំកែប្រែច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល។ ក្រសួងមហាផ្ទៃបានបើកវេទិកាពិគ្រោះយោបល់ចំនួន ៥ ស្ដីពីច្បាប់នេះ ដែលពេលនោះ សង្គមស៊ីវិលបានលើកឡើងពីកង្វល់អំពីតម្រូវការចុះបញ្ជី ដែលមានលក្ខណៈរឹតត្បិតលើអង្គការមិនមែនរដ្ឋាភិបាល (NGOs) ។

១៤. ការិយាល័យOHCHR បានទទួលផងដែរ នូវរបាយការណ៍អំពីការរឹតត្បិតហួសហេតុលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី នៅក្នុងបរិបទនៃជំងឺកូវីដ-១៩។ ការិយាល័យOHCHR បានចងក្រងឯកសារទាក់ទងនឹងការចាប់ខ្លួនបុគ្គលមួយចំនួន ដោយសារតែការអត្ថាធិប្បាយជាសាធារណៈ និងការបង្ហោះលើបណ្ដាញសង្គមទាក់ទងនឹងជំងឺកូវីដ-១៩ ដែលក្នុងនោះ យ៉ាងហោចណាស់ក៏មានមនុស្ស ១៤ នាក់ដែរ ដែលត្រូវបានចោទប្រកាន់ពីបទល្មើសនេះ រួមទាំង ការផ្សាយព័ត៌មានក្លែងក្លាយ ឬព័ត៌មានមិនពិត ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ និងការធ្វើផែនការប្រឆាំងនឹងរដ្ឋាភិបាល[14] រដ្ឋាភិបាលក៏បានដកហូតអាជ្ញាប័ណ្ណផ្សព្វផ្សាយរបស់មជ្ឈមណ្ឌលផ្សព្វផ្សាយ TVFB ផងដែរ បន្ទាប់ពីនិពន្ធនាយកនៃមជ្ឈមណ្ឌលនេះ បានដកស្រង់សន្ទរកថាជាសាធារណៈរបស់មន្ត្រីជាន់ខ្ពស់មួយរូប ដែលបង្ហាញពីអសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការផ្ដល់ថវិកាគាំទ្រដល់អ្នករត់ម៉ូតូឌុប នៅក្នុងពេល

[13] សារាចរណែនាំលេខ ១៧៥ ដែលចេញដោយក្រសួងមហាផ្ទៃ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ បានបញ្ជាក់ថាអង្គការ" មិនមែនរដ្ឋាភិបាល និងសមាគម រួមទាំង សហគមន៍មូលដ្ឋាន ដែលបានចុះបញ្ជីជាមួយក្រសួងរួចហើយ មានសេរីភាពពេញលេញក្នុងការអនុវត្តសកម្មភាពស្របច្បាប់ ដោយមិនចាំបាច់ជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានរយៈពេលបីថ្ងៃជាមុន ដូចដែលអង្គការទាំងនោះបានធ្វើពីមុនទៀតឡើយ។"

[14] បទល្មើសមួយចំនួន ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ គឺបទជេរប្រមាថជាសាធារណៈ ប្រម)ាថព្រះមហាក្សត្រ) (មាត្រា ៣០៧ (បទរួមគំនិតក្បត់) មាត្រា ៤៥៣) បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ (មាត្រា ៤៩៥និង (បទក្លែងព័ត៌មាន )មាត្រា ៤២៥។ (

មានវិបត្តិជំងឺកូវីដ-១៩។ និពន្ធនាយករូបនេះ ប្រឈមនឹងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌពីបទញុះញង់ឱ្យមានការស្អប់ខ្ពើម និងអំពើហិង្សា។[15]

១៥. ការិយាល័យOHCHR បានចូលរួមជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងភាពជាដៃគូជាមួយអង្គការពលកម្មអន្តរជាតិ (ILO) សហជីពកម្មករ និងដៃគូសង្គមស៊ីវិល ក្នុងការបន្តស្វែងរកឱ្យមានការធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីព។ វិសោធនកម្មច្បាប់នេះ ដែលបានធ្វើក្នុងខែមករា ឆ្នាំ២០២០ មិនបានបញ្ចូលអនុសាសន៍មួយចំនួនពីសហជីពកម្មករ អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនផ្សេងៗ រួមទាំង ការផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីសម្រេចលើករណីទាំងឡាយដែលទាក់ទងនឹងការបញ្ចប់ការងាររបស់តំណាងសហជីពកម្មករ និងមេដឹកនាំសហជីព និងបន្ធូរបន្ថយលក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីសហជីពឡើយ។

១៦. នៅក្នុងការបង្កើតច្បាប់ដទៃទៀត ក្រសួងព័ត៌មានបានរៀបចំឱ្យមានកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។ ទោះបីជាមានការទទួលស្គាល់ពីសារៈសំខាន់នៃច្បាប់នេះក៏ដោយ ក៏ការិយាល័យOHCHR លើកទឹកចិត្តឱ្យរដ្ឋាភិបាល ធ្វើឱ្យប្រាកដថា អនុសាសន៍នានា ដែលបានធ្វើឡើងដោយទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត ត្រូវបានដាក់បញ្ចូល ដើម្បីបំពេញឲ្យបានគ្រប់គ្រាន់តាមគោលបំណងនៃច្បាប់នេះ។ ក្រសួងមហាផ្ទៃបានរាយការណ៍អំពីវឌ្ឍនភាពរបស់ខ្លួន ក្នុងការបង្កើតសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ប៉ុន្តែសង្គមស៊ីវិលបានសម្តែងកង្វល់អំពីផលប៉ះពាល់ ដែលអាចកើតមាននៃសេចក្តីព្រាងច្បាប់ស្តីពីសេរីភាពបញ្ចេញមតិតាមអ៊ិនធឺណិត និងកង្វះតម្លាភាពក្នុងដំណើរការនេះ។ ការិយាល័យOHCHR នៅតែមានកង្វល់អំពីកង្វះវឌ្ឍនភាពឆ្ពោះទៅរកការដោះស្រាយកង្វល់សិទ្ធិមនុស្ស ដែលអង្គការសង្គមស៊ីវិលបានលើកឡើង ។

១៧. ការិយាល័យOHCHR បន្តការឃ្លាំមើលសិទ្ធិមនុស្សទាក់ទងនឹងសិទ្ធិជួបប្រជុំដោយសន្តិវិធី និងសិទ្ធិចូលរួមក្នុងជីវភាពពលរដ្ឋ និងនយោបាយ រួមទាំង ការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ។ ចាប់ពីថ្ងៃទី០៧ ដល់ថ្ងៃទី០៩ ខែធ្នូឆ្នាំ២០១៩ ការិយាល័យបានតាមឃ្លាំមើលការដើរហែរជាក្បួន និងព្រឹត្តិការណ៍ផ្សេងៗ នៅរាជធានីភ្នំពេញ និងនៅខេត្តបាត់ដំបង កំពង់ឆ្នាំង កោះកុង សៀមរាប និងខេត្តស្វាយរៀង។ ក្នុងករណីចំនួនពីរ ការិយាល័យOHCHR បានតស៊ូមតិជាមួយអាជ្ញាធរ ក្នុងការគាំទ្រដល់សហគមន៍មូលដ្ឋាន និងអង្គការដៃគូ ដើម្បីអនុញ្ញាតឱ្យមានការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ។

១៨. ការិយាល័យOHCHR បន្តកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលនៅកម្ពុជា។ ការិយាល័យបានបណ្តុះបណ្តាលអ្នកឃ្លាំមើល និងសកម្មជនសិទ្ធិមនុស្ស ស្តីពីការចងក្រងឯកសារ និងការរាយការណ៍អំពីការអះអាងពីការរំលោភសិទ្ធិមនុស្ស និងការតស៊ូមតិដែលពាក់ព័ន្ធជាមួយអាជ្ញាធរ។ ការិយាល័យOHCHR បានជួយពង្រឹងបណ្តាញសង្គមស៊ីវិល បង្កើតជាបណ្តាញថ្មីៗនៅខេត្តបាត់ដំបង ខេត្តព្រះសីហនុ និងនៅរាជធានីភ្នំពេញ ដែលរួមទាំងសហជីកម្មករ អង្គការ និងសកម្មជនសិទ្ធិដីធ្លី និងព្រៃឈើ។ ការិយាល័យOHCHR បានបង្កើនការចូលរួមរបស់ខ្លួនជាមួយ

[15] ក្រោមមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។

អង្គការសិទ្ធិស្ត្រី និងជាមួយក្រុមផ្សេងៗ ដែលលើកកម្ពស់សិទ្ធិមនុស្សស្រីស្រលាញ់ភេទដូចគ្នា ប្រុសស្រលាញ់ភេទដូចគ្នា មនុស្សស្រលាញ់ភេទទាំងពីរ មនុស្សប្តូរភេទ និងមនុស្សមានភេទមិនច្បាស់លាស់ (LGBTI)។

១៩. នៅខែតុលា ឆ្នាំ២០១៩ ការិយាល័យOHCHR សហការជាអង្គការពលកម្មអន្តរជាតិ (ILO) ក្រសួងការងារ និងវិជ្ជាជីវៈបណ្តុះបណ្តាល និងក្រសួងមហាផ្ទៃបានរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលចំនួន ៤ ដល់មន្រ្តីនគរបាលអំពីច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី និងសៀវភៅណែនាំអនុវត្ត ដែលបានបង្កើតឡើងដោយក្រសួងមហាផ្ទៃដោយមានការគាំទ្រពីការិយាល័យ OHCHR និងសង្គមស៊ីវិល។

២០. ការិយាល័យOHCHR បានពង្រឹងកិច្ចសហការរបស់ខ្លួនជាមួយអង្គការយុវជន និងបណ្តាញយុវជនក្រៅប្រព័ន្ធ ដោយគាំទ្រដល់ការចូលរួមរបស់ពួកគេក្នុងវិស័យសិទ្ធិមនុស្ស។ ក្រោមប្រធានបទសកល " យុវជនក្រោកឈរ ដើម្បីសិទ្ធិមនុស្ស" ការិយាល័យOHCHR បានរៀបចំឱ្យមានការប្រកួតពានរង្វាន់យុវជនគាំទ្រសិទ្ធិមនុស្ស ។ ក្រុមបង្គោលបានបង្កើតគម្រោងដែលលើកកម្ពស់សិទ្ធិមនុស្សតាមរយៈការចូលរួមរបស់ពលរដ្ឋនៅក្នុងសហគមន៍របស់ពួកគេ ដូចដែលបានបង្ហាញនៅក្នុងវីដេអូខ្លីៗចំនួនប្រាំ ដែលត្រូវបានបង្ហោះនៅលើទំព័រហ្វេសប៊ុករបស់ការិយាល័យOHCHR [16] ទស្សនិកជនជាតិ បានបោះឆ្នោតសំដែងការគាំទ្ររបស់ពួកគេ ដោយអ្នកឈ្នះរង្វាន់ជ័យលាភី ត្រូវបានប្រកាសនៅក្នុងព្រឹត្តិការណ៍អបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ។ ក្រុមដែលចូលរួមបានជួបជាមួយអាជ្ញាធរជាតិផ្សេងៗ រួមមាន សមាជិកព្រឹទ្ធសភា និងតំណាងមកពីក្រសួងនានារបស់រដ្ឋាភិបាល និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីពិភាក្សាអំពីបញ្ហាយុវជន។ ការិយាល័យ OHCHR បានធ្វើការសិក្សាស្រាវជ្រាវដែលមានចំណងជើងថា "ចំណេះដឹងយុវជន ឥរិយាបថ និងការអនុវត្តជាក់ស្តែងស្តីពីសិទ្ធិមនុស្ស និងការងារចូលរួម" លទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវនេះនឹងឈានដល់ការកំណត់ពីការងារចូលរួមរបស់យុវជន។

២១. ដើម្បីលើកកម្ពស់ការការពារដល់អង្គការសង្គមស៊ីវិល ការិយាល័យOHCHR បានបញ្ចប់សៀវភៅណែនាំស្តីពីការការពារនេះ ដែលបានតាក់តែងឡើងដោយមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល។ សៀវភៅណែនាំនេះ រួមមានព័ត៌មានជាក់ស្តែង ក្នុងទម្រង់សាមញ្ញមួយដើម្បីជួយដល់បុគ្គល និងអង្គការផ្សេងៗ ក្នុងការបង្កើតផែនការសន្តិសុខ និងសុវត្ថិភាព និងដើម្បីបង្កើនការយល់ដឹងអំពីយន្តការការពារសិទ្ធិមនុស្ស។ សៀវភៅណែនាំនេះ នឹងត្រូវបានបោះពុម្ពផ្សាយនៅឆមាសទីពីរឆ្នាំ២០២០ ហើយនឹងត្រូវបានបញ្ចូលទៅក្នុងកម្មវិធីទូរស័ព្ទចល័ត ដើម្បីងាយស្រួលមើល និងប្រើប្រាស់។

## IV. ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌

### ក - កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

[16] មាននៅលើគេហទំព័រ https://bit.ly/2xL9qud

២២. ការិយាល័យOHCHR បានបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ការិយាល័យOHCHR និងក្រសួងយុត្តិធម៌ បានធ្វើជាសហប្រធាននៃក្រុមការងារបច្ចេកទេស ផ្នែកកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលដើរតួនាទីជាស្ថាប័នសម្របសម្រួលសម្រាប់វិស័យយុត្តិធម៌។ នៅខែមិថុនា ឆ្នាំ ២០១៩ សហប្រធានបានអនុម័តសូចនាករត្រួតពិនិត្យរួមគ្នា ដើម្បីគាំទ្រដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (២០១៩-២០២៣)។ សូចនាករទាំងនេះរួមបញ្ចូលអនុសាសន៍របស់យន្តការសិទ្ធិមនុស្សអន្តរជាតិចំពោះប្រទេសកម្ពុជា រួមទាំងតម្រូវការសម្រាប់ច្បាប់ គោលនយោបាយ និងកម្មវិធីថ្នាក់ជាតិ ដើម្បីបំពេញតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។

២៣. ការិយាល័យOHCHR បានតាមដានដំណើរការនៅក្នុងការជំនុំជម្រះក្តីជាង ៣៥ ករណី។ ក្នុងករណីជាច្រើន ការិយាល័យOHCHR បានសង្កេតឃើញការមិនគោរពតាមនីតិវិធីត្រឹមត្រូវ និងបញ្ញត្តិធានាការពារការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលត្រូវបានការពារដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក៏ដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ជាតិ[17] រួមទាំងទាក់ទងទៅនឹងការចាប់ខ្លួន សិទ្ធិត្រូវបានគេប្រាប់ឱ្យដឹងភ្លាមៗពីការចោទប្រកាន់ សិទ្ធិមានតំណាងស្របច្បាប់ ការសន្មត់ជាមុនជាប្រយោជន៍ដល់ការដោះលែងឱ្យនៅក្រៅឃុំ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យាពេល និងការសន្មត់ថាគ្មានទោស។

២៤. ការិយាល័យOHCHR បានបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឱ្យប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌមានលក្ខណៈវិជ្ជាជីវៈ។ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ បានរៀបចំកិច្ចពិភាក្សាផ្នែកច្បាប់សម្រាប់មេធាវីក្នុងស្រុក ដោយទាញយកបទពិសោធន៍ និងការអនុវត្តជាក់ស្តែងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ បញ្ហាដែលត្រូវបានពិភាក្សារួមមានការផ្តល់ជំនួយផ្នែកច្បាប់នៅដំណាក់កាលមុនការជំនុំជម្រះ និងសិទ្ធិក្នុងការសន្មតថាគ្មានទោស ការមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការរៀបចំមេធាវីការពារក្តី និងជាមធ្យោបាយដោះស្រាយដ៏មានប្រសិទ្ធិភាពមួយសម្រាប់ការរំលោភសិទ្ធិ។

## ខ. ពង្រឹងនីតិរដ្ឋ និងការទទួលបានយុត្តិធម៌

២៥. នៅថ្ងៃទី២៧ និងទី២៨ ខែមិថុនា ឆ្នាំ២០១៩ ក្នុងភាពជាដៃគូជាមួយក្រសួងយុត្តិធម៌ ការិយាល័យOHCHR បានរៀបចំសន្និសីទថ្នាក់ជាតិស្តីពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅរាជធានីភ្នំពេញ។ សន្និសីទនេះ មានគោលបំណង ពង្រឹងការសម្របសម្រួលរវាងតុលាការ ព្រះរាជអាជ្ញា និងពន្ធនាគារ និងធ្វើឱ្យដំណើរការមានលក្ខណៈបទដ្ឋាននៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ សំដៅកាត់បន្ថយការពន្យាពេលមិនចាំបាច់ ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនបណ្តោះអាសន្នរយៈពេលវែង និងការពន្យាពេលដោះលែងក្រោយពីបានបញ្ចប់ទោស ដែលក្លាយទៅជាការឃុំខ្លួនខុសច្បាប់ និងដោយបំពាន។ ក្រសួងយុត្តិធម៌បានបើកយុទ្ធនាការរយៈពេល ៦ ខែ ដើម្បីដោះស្រាយករណីសំណុំរឿងកកស្ទះនៅតុលាការ ដែលនឹងអនុវត្តតាមអនុសាសន៍ទទួលបានពី

[17] មាត្រា ៣២ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

សន្និសីទនេះ។ យោងតាមរដ្ឋាភិបាល ការឃុំខ្លួនបណ្ដោះអាសន្នរយៈពេលវែង ដោយសារតែមានសំណុំរឿងច្រើន និងចៅក្រម ព្រះរាជអាជ្ញា និងមេធាវីមានចំនួនតិច គួរផ្សំនឹងការចាប់ខ្លួនមានការកើនឡើង ជាពិសេស បទល្មើសទាក់ទងនឹងគ្រឿងញៀន។ កង្វះការប្រាស្រ័យទាក់ទងអំពីសាលក្រមស្ថាពរ បណ្ដាលឱ្យមានការឃុំខ្លួនជនជាប់ឃុំដោយបំពាន បន្ទាប់ពីពួកគេបានបម្រើទោសចប់។ បន្តបន្ទាប់មកទៀត ការិយាល័យOHCHR បានគាំទ្រដល់កិច្ចប្រជុំរបស់ "នគរបាល តុលាការ និងពន្ធនាគារ" នៅក្នុងខេត្តចំនួនបួន ដែលដឹកនាំដោយព្រះរាជអាជ្ញាខេត្ត ដើម្បីបង្កើនការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានរវាងនគរបាល តុលាការ និងអាជ្ញាធរពន្ធនាគារ។

២៦. ការិយាល័យOHCHR បានបន្តគាំទ្រដល់ការបញ្ចូលមូលដ្ឋានទិន្នន័យករណីព្រហ្មទណ្ឌដែលបច្ចុប្បន្ននេះបាននិងកំពុងដំណើរការនៅសាលាដំបូងទាំងអស់នៅទូទាំងប្រទេស។ មូលដ្ឋានទិន្នន័យនេះ ត្រូវបានរចនាឡើងដើម្បីបង្កើនតម្លាភាព និងប្រសិទ្ធភាពនៅក្នុងតុលាការ និងចៀសវាងការឃុំខ្លួនបណ្ដោះអាសន្នហួសនីតិវិធី និងការពន្យាពេលការដោះលែង បន្ទាប់ពីបានបម្រើទោសរួច ដោយលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន និងការប្រាស្រ័យទាក់ទងរវាងស្ថាប័ននានាសម្រាប់ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌។

២៧. ការិយាល័យOHCHR បានបន្តធ្វើការតស៊ូមតិ ដើម្បីប្រព័ន្ធជំនួយផ្នែកច្បាប់ដ៏ទូលំទូលាយមួយ និងសម្រាប់ ការអនុម័តគោលនយោបាយជាតិជំនួយផ្នែកច្បាប់។ ថវិកាជំនួយផ្នែកច្បាប់របស់រដ្ឋាភិបាល បានកើនឡើងដល់៣០ ម៉ឺនដុល្លារ នៅឆ្នាំ២០១៩ ប៉ុន្តែការទទួលបានជំនួយផ្នែកច្បាប់ដែលត្រួតពិនិត្យដោយស្ថាប័នរដ្ឋាភិបាលជាច្រើន នៅតែមានភាពស្មុគស្មាញ។ ការិយាល័យ OHCHR បានផ្ដល់ហិរញ្ញប្បទានដល់អង្គការមិនមែនរដ្ឋាភិបាលដើម្បីគាំទ្រដល់ការផ្ដល់ជំនួយផ្នែកច្បាប់របស់ពួកគេ។ តាមរយៈហិរញ្ញប្បទានរបស់ការិយាល័យOHCHR មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ បានផ្ដល់យោបល់ផ្នែកច្បាប់ និងការតំណាងស្របច្បាប់ក្នុងករណីព្រហ្មទណ្ឌ និងរដ្ឋប្បវេណីយ៉ាងហោចណាស់ក៏ចំនួន ៤៧ ករណីដែរ ទាក់ទងនឹងបញ្ហាដីធ្លី និងសិទ្ធិលំនៅដ្ឋាន។ ទោះបីជាករណីមួយចំនួនក្នុងចំណោមករណីទាំងនោះ ស្ថិតក្រោមការពិនិត្យពិចារណារបស់តុលាការក៏ដោយក៏អ្នកទទួលជំនួយផ្នែកច្បាប់ទាំងអស់ ត្រូវបានដោះលែងក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមរយៈនេះគឺដើម្បីជៀសវាងការឃុំខ្លួនរយៈពេលយូរ នៅក្នុងដំណាក់កាលឃុំខ្លួនបណ្ដោះអាសន្ន។ នេះបង្ហាញពីសារៈសំខាន់នៃការទទួលបានជំនួយផ្នែកច្បាប់នៅក្នុងដំណាក់កាលដំបូងនៃដំណើរការរបស់តុលាការ ដូចជាការមានជំនួយផ្នែកច្បាប់ជារឿយៗកំណត់ថាតើបុគ្គលម្នាក់អាចចូលរួម ឬអត់ ក្នុងនីតិវិធីពាក់ព័ន្ធប្រកបដោយអត្ថន័យ។[18]

២៨. ក្នុងខែកក្កដា ឆ្នាំ២០១៩ ការិយាល័យOHCHR បានចេញផ្សាយរបាយការណ៍ស្ដីពី "ការកាត់ទោសដោយមហាជន" [19] ដែលបានចងក្រងជាឯកសារនូវឧប្បត្តិហេតុចំនួន ៧៣ នៃអំពើហិង្សា

---

[18] សូមមើលគណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅ លេខ ៣២ ស្ដីពីសិទ្ធិស្មើគ្នាចំពោះមុខតុលាការ (២០០៧)និងសាលាក្ដី និងការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ កថាខណ្ឌ ១០ ។

[19] ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការកាត់ទោសដោយមហាជន៖ ការបង្ការ និងការឆ្លើយតបចំពោះ" ការកាត់ទោសដោយមហាជន "នៅកម្ពុជា។ មាននៅលើគេហទំព័រ https://cambodia.ohchr.org/sites/default/files/report/other-report/OHCHR%20Report%20EN.pdf.

ដោយហ្វូងមនុស្ស ការវាយប្រហារ និងសកម្មភាពធ្វើទុក្ខបុកម្នេញប្រឆាំងនឹងបុគ្គល ដែលត្រូវគេចោទប្រកាន់ថាជាអំពើអាបធ្មប ចាប់ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១៨។ នេះ ជាការវិភាគបឋម នៃអំពើហិង្សាប្រឆាំងនឹងបុគ្គលបែបនេះនៅកម្ពុជា របាយការណ៍បានកំណត់កត្តាជំរុញនៅពីក្រោយអំពើហឹង្សាបែបនេះ រួមទាំងការប្រកាន់ពូជសាសន៍ ដែលមានជាយូរមកហើយ និងឥរិយាបទសង្គមរើសអើង ការខ្វះការជឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌ផ្លូវការ ភាពក្រីក្រ និងកង្វះការអប់រំ។ ការិយាល័យOHCHR បានធ្វើការជាមួយនគរបាល ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ និងដើម្បីគាំទ្រដល់ការបង្កើត និងការអនុម័តគោលការណ៍ណែនាំស្តីពីកិច្ចអន្តរាគមន៍របស់នគរបាលក្នុងករណីបែបនេះ។ ការិយាល័យOHCHR បានបើកយុទ្ធនាការផ្សព្វផ្សាយពាក់ព័ន្ធនឹងករណីការកាត់ទោសដោយមហាជនរយៈពេលជាង ៥ ខែលើកញ្ចក់ទូរទស្សន៍ និងវិទ្យុជាតិ[20] កាសែត និងនៅលើបណ្តាញសង្គម។

## គ. សិទ្ធិទទួលបានយុត្តិធម៌សម្រាប់ជនពិការ

២៩. ការិយាល័យOHCHR បានបន្តអនុវត្តគម្រោងរួមគ្នារបស់ខ្លួន ជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) អំពីសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ជនពិការ ដោយផ្តោតលើការកសាងសមត្ថភាព។ ការិយាល័យOHCHR បានចូលរួមចំណែកក្នុងការអភិវឌ្ឍរបស់រដ្ឋាភិបាលនូវផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៩-២០២៣ ដំណាក់កាលទីពីរ សំដៅផ្តល់សិទ្ធិអំណាច និងធានាការដាក់បញ្ចូលជនពិការ រួមទាំងនៅក្នុងវិស័យយុត្តិធម៌។ ដំណើរការធ្វើសេចក្តីព្រាងនេះ បានជួយក្នុងការកសាងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាសកម្មភាពជនពិការ ស្ថាប័នរដ្ឋទទួលខុសត្រូវក្នុងការពង្រឹងកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ស្តីពីសិទ្ធិជនពិការ ក៏ដូចជាអង្គការទាំងឡាយដែលតំណាងឱ្យជនពិការ។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ការិយាល័យOHCHR បានចូលរួមនៅក្នុងក្រុមការងារដែលដឹកនាំដោយក្រុមប្រឹក្សាសកម្មភាពជនពិការ ដើម្បីពិភាក្សាអំពីការពិនិត្យឡើងវិញនាពេលខាងមុខ នូវច្បាប់ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិជនពិការភាព។ ដំណើរការត្រួតពិនិត្យជាផ្លូវការបានចាប់ផ្តើមធ្វើនៅខែឧសភា ឆ្នាំ២០២០ ហើយការិយាល័យOHCHR នឹងបន្តធ្វើការតស៊ូមតិ ដើម្បីឱ្យច្បាប់នេះស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេស អនុសញ្ញាស្តីពីសិទ្ធិជនពិការ ដែលកម្ពុជាបានផ្តល់សច្ចាប័ន ឆ្នាំ២០១២។

៣០. តាមរយៈកម្មវិធីបណ្តុះបណ្តាល និងការគាំទ្រដោយផ្ទាល់ ការិយាល័យOHCHR បានបង្កើនសមត្ថភាពអង្គការសង្គមស៊ីវិល ដែលតំណាងឱ្យជនពិការ ក្នុងការចងក្រងឯកសារ និងតាមដានករណីរំលោភសិទ្ធិមនុស្ស និងការរំលោភបំពានលើជនពិការ នៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប។ អង្គការទាំងនេះ បានបញ្ជូនសំណុំរឿងចំនួន ៥០ ករណី រួមបញ្ចូលទាំង ១៥ ករណីដែលពាក់ព័ន្ធនឹងស្ត្រី ទៅយន្តការក្នុងប្រព័ន្ធតុលាការ និងយន្តការក្រៅប្រព័ន្ធតុលាការ។

៣១. តាមរយៈហិរញ្ញប្បទានរបស់ការិយាល័យOHCHR អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាល បានផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ដល់មនុស្សចំនួន ១៦ នាក់ និងតំណាងស្របច្បាប់ដល់មនុស្ស ១៣ នាក់ ផ្សេងទៀត ដែលមានពិការភាពផ្លូវកាយ និងផ្លូវចិត្ត។

---

[20] ការប្រកាសអំពីសេវាសាធារណៈ មាននៅលើគេហទំព័រ https://bit.ly/2yyYuA4.

ការិយាល័យOHCHR បានគាំទ្រអង្គការនេះ ក្នុងការបង្កើតគោលការណ៍ណែនាំជាក់ស្តែង ស្តីពីជំនួយផ្នែកច្បាប់សម្រាប់ជនពិការ ដែលពាក់ព័ន្ធនឹងការពិគ្រោះយោបល់ជាមួយវេទិកាតំណាងជនពិការ។

៣២. ការិយាល័យOHCHR បានគាំទ្រដល់គម្រោងប្រតិបត្តិការមិនដាក់ច្រវ៉ាក់ នៃអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា ដែលព្យាបាល និងផ្តល់ការស្តារនីតិសម្បទាដល់បុគ្គលដែលមានពិការភាពផ្លូវចិត្ត ដែលត្រូវបានចាក់សោរ ឬត្រូវបានបង្ខាំងរូបកាយ ដោយសមាជិកគ្រួសារ ក្នុងករណីជាច្រើនដោយសារតែការមាក់ងាយ និងកង្វះលទ្ធភាពទទួលបានការព្យាបាល។ តាមរយៈការងាររបស់អង្គការនេះ មានមនុស្សចំនួន ៧៨ នាក់ ត្រូវបានដោះលែង និងធ្វើសមាហរណកម្មពួកគេទៅក្នុងសហគមន៍ នៅចន្លោះខែមិថុនា និងខែធ្នូ ឆ្នាំ២០១៩ ។

## ឃ. គាំទ្រកំណែទម្រង់ពន្ធនាគារ

៣៣- ចំនួនជនជាប់ឃុំនៅកម្ពុជា បានបន្តកើនឡើង។ ទោះបីជាច្រើនចង្អៀតណែនក្តី ការប្រើជម្រើសផ្សេងក្នុងការឃុំខ្លួន រួមទាំងការដាក់ប្រាក់ធានាឱ្យនៅក្រៅឃុំ ក្រោមការត្រួតពិនិត្យរបស់តុលាការ និងការព្យួរទោស នៅតែមានកំណត់។ ក្នុងអំឡុងខែមីនា និងខែមេសា ឆ្នាំ២០២០ ការិយាល័យOHCHR បានជួបជាមួយអាជ្ញាធរតុលាការរាជធានីភ្នំពេញ ដើម្បីតស៊ូមតិសម្រាប់ការដាក់ឱ្យនៅក្រៅឃុំស្ត្រីមានផ្ទៃពោះ ២៥ នាក់ និងស្ត្រីមានកូនតូចៗ ដែលកំពុងស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន។ ខ្វះខាតការទទួលបានជំនួយផ្នែកច្បាប់ ស្ត្រីទាំងនោះបានដាក់ពាក្យស្នើសុំនៅក្រៅឃុំ ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលមានបង្កើតបែបបទពាក្យសុំនៅក្រៅឃុំដែលមានលក្ខណៈសាមញ្ញ។ មានរីកចម្រើនគួរឱ្យស្វាគមន៍ ស្ត្រី ១២ នាក់ ត្រូវបានដោះលែងពីការឃុំខ្លួន អ្នកខ្លះនៅក្រៅឃុំ និងខ្លះទៀតបន្ទាប់ពីការជំនុំជម្រះរបស់ពួកគេត្រូវបានពន្លឿន។ ការិយាល័យOHCHR នឹងបន្តធ្វើការតស៊ូមតិសម្រាប់ទម្រង់បែបបទពាក្យសុំនៅក្រៅឃុំដែលមានលក្ខណៈសាមញ្ញជាងមុន ដើម្បីប្រើប្រាស់ឱ្យកាន់តែទូលំទូលាយថែមទៀត។

៣៤. ការិយាល័យOHCHR បានបន្តឃ្លាំមើលទីតាំង និងលក្ខខណ្ឌនៃការឃុំខ្លួន និងប្រព្រឹត្តកម្មលើជនជាប់ឃុំ។ រដ្ឋាភិបាលមិនបានអនុញ្ញាតឱ្យធ្វើសំភាសន៍ជាសម្ងាត់ "ស្របតាមច្បាប់ស្តីពីពន្ធនាគារ" ឡើយ។ ការិយាល័យOHCHR បានរកឃើញជាទៀតទាត់ថា លក្ខខណ្ឌនៃការឃុំខ្លួនជាទូទៅ មិនបំពេញតាមបទដ្ឋានអន្តរជាតិទេ រួមទាំង អំពីការទទួលបានការថែរក្សាសុខភាពរបស់អ្នកជាប់ឃុំ និងការព្យាបាលផ្នែកវេជ្ជសាស្ត្រ អនាម័យ និងការសួរសុខទុក្ខពីសមាជិកគ្រួសារ និងតំណាងស្របច្បាប់ផងដែរ។

៣៥. ការិយាល័យOHCHR បានចងក្រងជាឯកសារនូវការស្លាប់ចំនួន ៣ នាក់ នៅក្នុងមន្ទីរឃុំឃាំង។ ក្នុងករណីពីរ អគ្គនាយកដ្ឋានពន្ធនាគារបានចាត់វិធានការកែតម្រូវមួយចំនួន ទោះជាដូច្នេះក្តី អាជ្ញាធរមិនបានរកឃើញភ័ស្តុតាងណាមួយពីការធ្វើទារុណកម្ម ឬការធ្វើបាបឡើយ។ ការិយាល័យOHCHR មិនអាចបញ្ជាក់អំពីថាតើការស៊ើបអង្កេតទាំងនោះ បាន ឬមិនបានបំពេញតាមគោលការណ៍ឯករាជ្យភាព មិនលំអៀង តម្លាភាព និងភាពរហ័សរហួនឡើយ។ ក្នុងករណីទីបីដែលបានកើតឡើងនៅខេត្តបន្ទាយមានជ័យ កាលពីខែធ្នូ ឆ្នាំ២០១៩ មានមន្ត្រីនគរបាលចំនួន ២

នាក់ ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការស្លាប់នេះ ហើយនៅតែស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅឡើយ។

៣៦. បណ្ឌិត្យសភានគរបាលកម្ពុជា បានបញ្ចូលមេរៀនថ្មីមួយ គឺអនុសញ្ញាស្តីពីសិទ្ធិជនពិការ ក្នុងការបណ្តុះបណ្តាលរយៈពេល ៤ ខែ សម្រាប់បុគ្គលិកពន្ធនាគារថ្មី។ ការបណ្តុះបណ្តាលនេះ ដែលត្រូវបានផ្តល់ដោយការិយាល័យOHCHR គ្របដណ្តប់លើច្បាប់ជាតិ និងច្បាប់អន្តរជាតិ ក្របខ័ណ្ឌទាក់ទងនឹងការឃុំខ្លួន រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

៣៧. ការិយាល័យOHCHR និងគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម[21] បានរៀបចំវគ្គបណ្តុះបណ្តាលរួមគ្នាចំនួន ៤ សំដៅលើកកំពស់ការយល់ដឹងដល់មន្ត្រីអនុវត្តច្បាប់និងមន្ត្រីពន្ធនាគារ។ វគ្គបណ្តុះបណ្តាលនេះ បានប្រារព្ធធ្វើនៅខេត្តកំពង់ចាម ខេត្តកំពត ខេត្តព្រៃវែង និងខេត្តស្វាយរៀង ចន្លោះពីថ្ងៃទី២៤ ខែតុលា ដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ វគ្គបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើតួនាទី និងអាណត្តិរបស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម។ ដោយមានកិច្ចសហការជាមួយព្រះរាជអាជ្ញាខេត្ត ការិយាល័យOHCHR បានធ្វើបទបង្ហាញសង្ខេប សម្រាប់មន្ត្រីអនុវត្តច្បាប់ស្តីពីការបង្ការទារុណកម្ម ការប្រើប្រាស់កម្លាំង និងសិទ្ធិនៅពេលចាប់ខ្លួន នៅខេត្តស្វាយរៀង និងខេត្តតាកែវ នៅថ្ងៃទី១៩ និងទី២៦ ខែធ្នូ ឆ្នាំ២០១៩ ផ្សេងៗគ្នា។

៣៨. វិបត្តិកូវីដ- ១៩ បង្ហាញពីហានិភ័យធ្ងន់ធ្ងរដល់ជនជាប់ឃុំក្នុងពន្ធនាគារ ជាពិសេស ការដាក់មនុស្សច្រើនចង្អៀតណែនជាយូរមកហើយ ដែលមិនអាចឱ្យពួកគេរក្សាគំលាតពីគ្នាបាន។ នៅថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២០ ក្រសួងមហាផ្ទៃ បានផ្អាកជាបណ្តោះអាសន្នរាល់ដំណើរទស្សនកិច្ចនៅតាមពន្ធនាគារ ជាវិធានការបង្ការ។ សេចក្តីណែនាំជាបន្តបន្ទាប់ តម្រូវឱ្យដាក់ខ្លួននៅដាច់ដោយឡែក (ចត្តាឡីស័ក) ក្នុងរយៈពេល ១៤ ថ្ងៃ ដល់ជនជាប់ឃុំដែលទើបនឹងចូលថ្មី។ រដ្ឋាភិបាលបានបញ្ជាក់ថា ខ្លួនបានពន្លឿនដំណើរការចោទប្រកាន់ រួមទាំង ការប្រើប្រាស់ប្រាក់ធានាឱ្យនៅក្រៅឃុំ ចំពោះបទលហុ ដើម្បីបន្ធូរបន្ថយភាពចង្អៀតណែនរបស់ពន្ធនាគារ។ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០២០ ការិយាល័យOHCHR មូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ (UNICEF) និងអង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងអង្គការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (UN-Women) បានធ្វើលិខិតរួមគ្នាមួយទៅក្រសួងក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានពន្ធនាគារ តស៊ូមតិឱ្យមានការដោះលែងជនជាប់ឃុំ ក្នុងស្ថានភាពដែលងាយរងគ្រោះដោយសារជំងឺកូវីដ-១៩ រួមទាំង ស្ត្រីមានផ្ទៃពោះ ជនចាស់ជរា និងជនជាប់ឃុំដែលមានជំងឺប្រចាំកាយ។ ការិយាល័យOHCHR មិនបានទទួលការឆ្លើយតបចំពោះលិខិតនោះទេ ហើយក៏មិនបានដឹងអំពីការដោះលែងអ្នកទោស និងជនជាប់ឃុំ ដោយមូលហេតុជំងឺកូវីដ-១៩ ដែរ។

## V. សិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច

[21] យន្តការបង្ការថ្នាក់ជាតិរបស់ប្រទេសកម្ពុជា ក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។

## ក. ស្ថានភាពសិទ្ធិដីធ្លី និងលំនៅដ្ឋាន

៣៩. បញ្ហាប្រឈមនៅតែមានក្នុងវិស័យដីធ្លី និងសិទ្ធិលំនៅដ្ឋាន ដោយសារតែការបណ្តេញចេញដោយបង្ខំ កខ្វះបទដ្ឋានត្រឹមត្រូវស្តីពីការតាំងទីលំនៅថ្មី និងរយៈពេលវែង ស្មុគស្មាញ មិនច្បាស់លាស់ និងការចំណាយប្រាក់ច្រើនក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។ ការបែងចែក ការលក់ និងការប្រើប្រាស់ដីធ្លីបានបន្តដំណើរការតាមប្រព័ន្ធវិនិយោគ ដែលមានវិសមភាពរចនាសម្ព័ន្ធ ដែលជះឥទ្ធិពលមិនសមាមាត្រទៅលើបុគ្គលដែលរស់នៅក្នុងភាពក្រីក្រ និងក្នុងស្ថានភាពងាយរងគ្រោះ។ មិនមានច្បាប់ ឬគោលនយោបាយរដ្ឋថ្មី ទាក់ទងនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ត្រូវបានបង្កើតឡើង ឬអនុម័តឡើយ។

៤០. ការិយាល័យOHCHR បានទទួលញត្តិពីបុគ្គល និងក្រុមមួយចំនួនដែលស្វែងរកអន្តរាគមន៍របស់ខ្លួន ក្នុងបញ្ហាទំនាស់ដីធ្លី រួមទាំងសហគមន៍ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិដែលកំពុងប្រឈមនឹងហានិភ័យពីការបណ្តេញចេញដោយបង្ខំ។ ការិយាល័យOHCHR បានចុះធ្វើទស្សនកិច្ចជាក់ស្តែង ដើម្បីស្វែងរកការពិត បានជួបធ្វើការជាមួយអាជ្ញាធរពាក់ព័ន្ធ បានធ្វើការសម្របសម្រួលកិច្ចសន្ទនារវាងអាជ្ញាធរមូលដ្ឋាន និងភាគីដែលរងផលប៉ះពាល់ បានឃ្លាំមើលការងាររបស់យន្តការដោះស្រាយវិវាទ និងបានផ្តល់ជំនួយផ្នែកបច្ចេកទេសដល់សហគមន៍និងអង្គការសង្គមស៊ីវិល។ ការិយាល័យOHCHR បានចូលរួមផងដែរ ក្នុងក្រុមសម្របសម្រួលវិស័យដីធ្លី ដែលមានសមាសភាពទីភ្នាក់ងារអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដែលធ្វើការលើបញ្ហាដីធ្លី និងផ្ទះសម្បែង វេទិកានេះសម្របសម្រួលការចែករំលែកព័ត៌មាន និងផ្តល់លទ្ធភាពដល់សកម្មភាពសម្របសម្រួល។

៤១. នៅខែមិថុនា ឆ្នាំ២០១៩ ក្នុងការបន្តឃ្លាំមើលវិវាទដីធ្លីទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច ការិយាល័យOHCHR ក្នុងភាពជាដៃគូជាមួយអង្គការអុកស្វាម (Oxfam) បានរៀបចំកិច្ចពិភាក្សាពហុភាគីពាក់ព័ន្ធ ដែលមានចំណងជើងថា "ការវិនិយោគផ្ទាល់ពីបរទេសដោយមានការទទួលខុសត្រូវក្នុងវិស័យកសិកម្មនៅកម្ពុជា"។ កិច្ចពិភាក្សាបានកំណត់ពីភាពចន្លោះប្រហោងនៃក្របខណ្ឌសម្បទានដីសេដ្ឋកិច្ច និងបានដាក់ចេញជាអនុសាសន៍សម្រាប់រដ្ឋាភិបាល។ ជាលទ្ធផល អាជ្ញាធរមូលដ្ឋាននៅក្នុងខេត្តកំពង់ស្ពឺ ខេត្តមណ្ឌលគីរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែងបានចូលរួមក្នុងដំណើរការស្រមុះស្រមួលជាផ្លូវការ ដើម្បីដោះស្រាយទំនាស់ដីធ្លីដែលមានពាក់ព័ន្ធនឹងក្រុមហ៊ុនឯកជន។

៤២. ការិយាល័យOHCHR បានប្រើប្រាស់លទ្ធផលនៃការសិក្សាខែឧសភា ឆ្នាំ២០១៨ របស់ខ្លួន ដែលមានចំណងជើងថា "វាយតម្លៃផលប៉ះពាល់នៃសម្បទានដីសង្គមកិច្ចលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ"[22] ជាមូលដ្ឋានសម្រាប់ការតស៊ូមតិជាមួយអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន។ សម្បទានដីសង្គមកិច្ចអនុញ្ញាតឱ្យមានការផ្ទេរដីរដ្ឋទៅប្រជាពលរដ្ឋក្រីក្រ ឬបុគ្គល

[22] មើលគេហទំព័រ https://cambodia.ohchr.org/sites/default/files/InfoNotes/Finding%20SLC%20Infographic%20with%202cm%20bleed-0%20Sep%202019%20low.pdf.

និងគ្រួសារដែលគ្មានដីធ្លី សម្រាប់គោលបំណងធ្វើលំនៅដ្ឋាន និងបង្កើតប្រាក់ចំណូល ដូចជាកសិកម្មជាដើម។ នៅខែវិច្ឆិកា ឆ្នាំ២០១៩ ការិយាល័យOHCHR និងអង្គការទិន្នន័យអំពីអភិវឌ្ឍកម្ពុជា បានផលិតក្រាហ្វិកព័ត៌មានដែលសង្ខេបចំណុចដែលបានរកឃើញសំខាន់ៗនៃរបាយ-ការណ៍នេះ និងឯកសារអង្គហេតុមួយស្ដីពីដំណើរការផ្ដល់ដីសម្បទានសង្គមកិច្ច ។ ការិយាល័យ OHCHR ក៏បានចុះទៅពិនិត្យជាក់ស្ដែងផងដែរនៅខេត្តកំពត ខេត្តមណ្ឌលគីរី និងខេត្តព្រះសីហនុ ដើម្បីពិភាក្សាអំពីលទ្ធផល និងអនុសាសន៍នៃការសិក្សាជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាជន។ នៅខែធ្នូ ឆ្នាំ២០១៩ ការិយាល័យOHCHR បានរៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិមួយ ដើម្បីពិភាក្សាមេរៀនបទពិសោធន៍និងវិធីទៅថ្ងៃមុខ។ អនុសាសន៍គន្លឹះៗមួយចំនួន រួមមាន ការធ្វើការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន មុនពេលនឹងផ្ដល់សម្បទានដីសង្គមកិច្ច ហើយចេញឲ្យសម្រាប់តែដីសម្បទានសង្គមកិច្ចលើដីណាដែលជាប់នឹងដីរបស់ក្រុមជនជាតិដើមភាគតិច នៅពេលដែលពួកគេដាក់ពាក្យសុំកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិសមូហភាព ត្រូវបានដំណើរការ និងវាយតំលៃយ៉ាងពេញលេញតែប៉ុណ្ណោះ។

៤៣. ការិយាល័យOHCHR បានបន្តតស៊ូមតិជាមួយអាជ្ញាធរលើករណីបណ្ដេញចេញដោយបំពាន រួមទាំងក្នុងការគាំទ្រដល់ការពិគ្រោះយោបល់ជាមុនជាមួយគ្រួសារ និងបុគ្គលដែលរងផលប៉ះពាល់ នីតិវិធីតាំងទីលំនៅថ្មី សិទ្ធិទទួលបានព័ត៌មាន និងសំណង។ នេះរួមទាំងការចូលរួមជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្ដីពីសំណងដល់សហគមន៍ដែលរងផលប៉ះពាល់ ។ ការិយាល័យOHCHR បានបំពេញបេសកកម្មឃ្លាំមើលចំនួន ៧ ទាក់ទងនឹងការបណ្ដេញចេញដែលនឹងកើតមាន ចំពោះប្រជាពលរដ្ឋប្រមាណជា ២.០០០ គ្រួសារ នៅទូទាំងខេត្តកំពង់ធំ ខេត្តកោះកុង រាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ និងខេត្តព្រះសីហនុ។ ក្នុងករណីមួយការិយាល័យ OHCHR បានចរចារឱ្យមានការពន្យាពេលការបណ្ដេញសហគមន៍ចេញ និងការផ្ដល់ដីសម្បទានសង្គមកិច្ចជាបន្តបន្ទាប់ ដោយអាជ្ញាធរមូលដ្ឋានដល់ប្រជាពលរដ្ឋចំនួន ៣១ គ្រួសារ ដែលរងផលប៉ះពាល់។ ក្នុងករណីពីរផ្សេងទៀត ដែលករណីមួយពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ១.០០០ គ្រួសារដែលត្រូវបានបណ្ដេញចេញដោយបំពាន នៅក្នុងខេត្តកំពង់ធំ និងករណីមួយផ្សេងទៀតពាក់ព័ន្ធនឹង ៣៤៧ គ្រួសារ ដែលប្រឈមនឹងការបណ្ដេញចេញក្នុងខេត្តពោធិសាត់ ដោយសារការសាងសង់ទំនប់វារីអគ្គិសនី អាជ្ញាធរមូលដ្ឋានយល់ព្រមដោះស្រាយវិវាទដីធ្លី និងផ្ដល់សំណងដល់គ្រួសារប្រជាពលរដ្ឋដែលត្រូវបណ្ដេញចេញ។ គិតត្រឹមខែឧសភា ឆ្នាំ២០២០ សំណងមិនទាន់ត្រូវបានផ្ដល់នៅឡើយទេ។

៤៤. ការិយាល័យOHCHR បានបន្តធ្វើការសិក្សាលើកន្លែងតាំងទីលំនៅថ្មី ចំនួន ១៧ កន្លែង នៅកម្ពុជា ដោយធ្វើបទសម្ភាសន៍ ៤៣ ភាគរយ នៃគ្រួសារដែលរងផលប៉ះពាល់ ប្រមាណ ២.៣៤១ នាក់។ ការសិក្សានេះនឹងត្រូវចេញផ្សាយនៅឆ្នាំ២០២០ រួមជាមួយសេចក្តីព្រាងគោលការណ៍ណែនាំស្ដីពីការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី។

៤៥. នៅខែមីនា ឆ្នាំ២០២០ ការិយាល័យOHCHR និងអង្គការក្លាហាន ដែលជាអង្គការសិទ្ធិស្ត្រី បានបោះពុម្ព ផ្សាយព្រឹត្តបត្រព័ត៌មាន ចំនួន ៦ ដែលស្វែងយល់ពីទំនាក់ទំនងរវាងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ស្ត្រី ការរំលោភសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាននៅកម្ពុជា ។[23]

[23] មើលគេហទំព័រ

៤៦. តាមសំណើរបស់ក្រសួងយុត្តិធម៌ ក្នុងខែវិច្ឆិកាឆ្នាំ ២០១៩ ការិយាល័យOHCHR បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់មន្ត្រីនាយកដ្ឋានសន្ទានកម្ម និងយុត្តិធម៌មូលដ្ឋាន នៅរាជធានីភ្នំពេញ។ វគ្គបណ្តុះបណ្តាលគ្រូបង្គោលនេះ បានរៀបចំឡើងដោយមានភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលផ្សេងៗ វគ្គបណ្តុះបណ្តាលនេះបានផ្តល់ការណែនាំស្តីពីយន្តការដោះស្រាយបណ្តឹងតវ៉ាក្រៅប្រព័ន្ធតុលាការ ដោយផ្តោតជាពិសេសលើវិវាទដីធ្លីទាក់ទងនឹងយេនឌ័រ។ ការិយាល័យ OHCHR បានឃ្លាំមើល និងគាំទ្រដំណើរការសន្ទានកម្ម (សម្រុះសម្រួល) មួយ នៅក្នុងខេត្តមណ្ឌលគីរី រវាងក្រុមហ៊ុនកៅស៊ូសុកហ្វីន និងសហគមន៍ជនជាតិដើមភាគតិចពូនង។ ការស្រមុះស្រមួលនេះ ដែលបានចាប់ផ្តើមនៅឆ្នាំ ២០១៧ បានដោះស្រាយនូវដីប្រពៃណីដែលផ្តល់ទៅឱ្យក្រុមហ៊ុនជាសម្បទានដីសេដ្ឋកិច្ច។ ដោយមានការគាំទ្រពីការិយាល័យOHCHR វិវាទដីធ្លីភាគច្រើនដែលទាក់ទងនឹងតំបន់សមូហភាពត្រូវបានដោះស្រាយ ហើយនឹងត្រូវបញ្ចូលទៅក្នុងពាក្យសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។

៤៧. នៅខែកក្កដា ឆ្នាំ ២០១៩ ការិយាល័យOHCHR បានរៀបចំកម្មវិធីបណ្តុះបណ្តាលមួយស្តីពីការអនុវត្តអាជីវកម្មប្រកបដោយការទទួលខុសត្រូវ និងការទទួលបានដំណោះស្រាយក្រៅប្រព័ន្ធតុលាការ សម្រាប់អង្គការសង្គមស៊ីវិលក្នុងស្រុកមួយចំនួន។ ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា អង្គការ Interchurch Organization for Development Cooperation គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និងអង្គការអាក់សិនអេត វគ្គបណ្តុះបណ្តាលបានដោះស្រាយនូវយន្តការបណ្តឹងក្រៅប្រព័ន្ធតុលាការជាតិ និងអន្តរជាតិ។

៤៨. ដោយមានជំនួយគាំទ្រពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យOHCHR) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានបញ្ចប់គម្រោងរបស់ខ្លួនស្តីពីការលើកកម្ពស់បទដ្ឋានសិទ្ធិមនុស្សនៅក្នុងវិស័យធុរកិច្ច និងដីធ្លី នៅខែធ្នូ ឆ្នាំ ២០១៩។ គម្រោងបានបង្កើតនូវឯកសារលើកកម្ពស់ការយល់ដឹងចំនួន ១២ ស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស រួមមាន ខិតប័ណ្ណ សលាកប័ត្រព័ត៌មាន និងដ្យាក្រាមព័ត៌មាន ហើយបានរៀបចំកម្មវិធីវិទ្យុចំនួន ១២។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានផ្តល់កម្មវិធីបណ្តុះបណ្តាលចំនួនបួនស្តីពីធុរកិច្ច និងសិទ្ធិមនុស្សសម្រាប់មន្ត្រីរដ្ឋ មេធាវី និងតំណាងវិស័យឯកជន។

៤៩. ក្រៅពីនេះការវិវត្តទាំងនេះ រដ្ឋាភិបាលមិនទាន់បានរៀបចំផែនការសកម្មភាពជាតិនៅឡើយទេ ហើយការប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ដោយវិស័យសាធារណៈ ឬឯកជន នៅតែមានកម្រិតនៅឡើយ។

## ខ. ការទទួលបានដីសម្រាប់ជនជាតិដើមភាគតិច

https://cambodia.ohchr.org/sites/default/files/Promotional-materials-soft/ESC%20rights%20and%20land%20rights%20violations%20OHCHR%20Klahaan%202020-compressed.pdf.

៥០. ការិយាល័យOHCHR ធ្វើការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន អាជ្ញាធរមូលដ្ឋាន ធនាគារពិភពលោក និងអង្គការសង្គមស៊ីវិល ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ជនជាតិដើមភាគតិច ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាព។

៥១. ការិយាល័យOHCHR បានបន្តធ្វើការតស៊ូមតិដើម្បីពន្លឿនដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាព។ ចាប់តាំងពីការអនុម័តនៅឆ្នាំ ២០០៩ នៃអនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចមក មានសហគមន៍ជនជាតិដើមភាគតិច ចំនួន ១៥១ ត្រូវបានគេទទួលស្គាល់អត្តសញ្ញាណជនជាតិដើមរបស់ពួកគេ ដែលជាជំហានដំបូងនៃដំណើរការនេះ។ សហគមន៍ជនជាតិដើមភាគតិចចំនួន ១៣១ ផ្សេងទៀត បានឈានទៅជំហានទី ២ នៃដំណើរការនេះ ដោយបានចុះឈ្មោះជានីតិបុគ្គល។ សហគមន៍ចំនួន ៣០ ផ្សេងទៀត បានឈានទៅមុខជំហានទីបី និងចុងក្រោយ ដែលពាក់ព័ន្ធនឹងការវាស់វែងដី មុនពេលមានការយល់ព្រមចុងក្រោយ និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លី។ ការិយាល័យOHCHR បានគាំទ្រសហគមន៍ចំនួនបួនលើជំហានដំបូង និងសហគមន៍ចំនួនបី លើជំហានទីបីនៃដំណើរការនេះ។

៥២. នៅខែធ្នូ ឆ្នាំ ២០១៩ ការិយាល័យOHCHR បានរៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីដំណើរការចុះបញ្ជីដីធ្លីសមូហភាព ដល់មន្ត្រីមូលដ្ឋាន មកពីខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តមណ្ឌលគីរី ខេត្តព្រះវិហារ ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។ វគ្គបណ្តុះបណ្តាលនេះត្រូវបានសហការរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៥៣. នៅខែកុម្ភៈឆ្នាំ ២០២០ ការិយាល័យOHCHR បានចូលរួមបេសកកម្មវាយតម្លៃមួយធ្វើឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ស្តីពីការលំបាកនានាដែលសហគមន៍ជនជាតិដើមភាគតិចកំពុងប្រឈមខណៈពេលដែលពួកគេកំពុងរស់នៅក្នុងតំបន់ការពារបរិស្ថាន។ បេសកកម្មនេះផ្តោតលើការចុះឈ្មោះដីដូនតាជាដីសហគមន៍ជនជាតិដើមភាគតិច។ ក្នុងដំណើរទស្សនៈកិច្ចទៅកាន់ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ការិយាល័យOHCHR បានសង្កេតឃើញកង្វះនៃភាពស៊ីសង្វាក់ និងនីតិវិធីបទដ្ឋានក្នុងការបែងចែកដីដែលត្រូវបានចាត់ជាតំបន់ការពារបរិស្ថានដល់សហគមន៍ជនជាតិដើមភាគតិច។

## គ. ស្ថានភាពជនជាតិភាគតិច

៥៤. ការិយាល័យOHCHR បានបន្តដោះស្រាយស្ថានភាពរបស់ជនជាតិភាគតិច រួមទាំង ជនជាតិវៀតណាមដែលពួកគេខ្លះជាជនគ្មានរដ្ឋ។ ទោះបីជាយើងឃើញមានការរីកចម្រើនមួយចំនួនក្នុងការផ្តល់ឋានៈស្នាក់នៅសម្រាប់ជនបរទេសក៏ដោយ ក៏ការិយាល័យOHCHR បានចងក្រងជាឯកសារនៃការចោទប្រកាន់អំពីការរំលោភសិទ្ធិលើសញ្ជាតិ សិទ្ធិទទួលបានការអប់រំ និងជីវិតគ្រួសារ ក៏ដូចជា សេរីភាពពីការរើសអើងដែរ។ ការិយាល័យOHCHR បានបកប្រែបទប្បញ្ញត្តិ

រដ្ឋបាលចំនួនបួន[24] ដែលមានចែងអំពីអន្តោប្រវេសន៍ និងជនបរទេស ពីភាសាខ្មែរទៅអង់គ្លេស ដើម្បីគាំទ្រដល់ការងារតស៊ូមតិរបស់អង្គការសង្គមស៊ីវិល គួអង្គអភិវឌ្ឍន៍អន្តរជាតិ និងអង្គភាពដទៃទៀត ដែលធ្វើការជាមួយជនជាតិភាគតិច។ បន្ទាប់ពីការិយាល័យOHCHR តាមដាន និងតស៊ូមតិជាមួយអាជ្ញាធរខេត្ត និងអនុសាសន៍ពាក់ព័ន្ធដោយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អាជ្ញាធរមូលដ្ឋាន[25] នៅក្នុងខេត្តកំពង់ឆ្នាំង បានបញ្ឈប់ផែនការដែលអាចបណ្តាលឱ្យមានការបណ្តេញចេញនូវប្រជាជនជនជាតិវៀតណាមប្រមាណ ១០.០០០ នាក់ ដែលកំពុងរស់នៅផ្ទះបណ្តែតទឹកលើបឹងទន្លេសាប។ នៅថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០២០ ការិយាល័យ OHCHR បានផ្ញើលិខិតមួយច្បាប់ ជូនសាលារាជធានីភ្នំពេញ ទាក់ទងនឹងផែនការបណ្តេញចេញដោយបង្ខំលើក្រុមគ្រួសារជនជាតិខ្មែរ និងជនជាតិវៀតណាម ចំនួន ៤២ គ្រួសារ ពីសហគមន៍បណ្តែតទឹកនៅរាជធានីភ្នំពេញ។

៥៥. នៅខែសីហា ឆ្នាំ ២០១៩ ការិយាល័យOHCHR បានសម្របសម្រួលកិច្ចប្រជុំនានានៅរាជធានីភ្នំពេញ រវាងការិយាល័យអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងទំនួលខុសត្រូវក្នុងការការពារ[26] និងអង្គការសង្គមស៊ីវិល ដែលធ្វើការលើបញ្ហាជនជាតិភាគតិច។ អ្នកចូលរួមមួយចំនួនមានពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០២/០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានទទួលការផ្តន្ទាទោសជាលើកដំបូងចំពោះអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម។[27] កិច្ចប្រជុំផ្តល់ឱកាសដល់ការិយាល័យអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងទំនួលខុសត្រូវក្នុងការការពារ ដើម្បីរៀនអំពីស្ថានភាពរបស់ជនជាតិភាគតិចនៅកម្ពុជា និងដើម្បីវាយតម្លៃហានិភ័យទាក់ទងនឹងភាពសាហាវព្រៃផ្សៃ។

៥៦. ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីសង្ខេបនៃគោលនយោបាយរបស់អគ្គលេខាធិការស្តីពីជំងឺកូវីដ-១៩ និងសិទ្ធិមនុស្ស[28] ជនជាតិដើមភាគតិច និងសហគមន៍ជនជាតិភាគតិចមួយចំនួនប្រឈមនឹងហានិភ័យជាពិសេសពីផលវិបាកនៃជំងឺកូវីដ-១៩។ សកម្មភាពនៃការរើសអើងត្រូវបាន

[24] សេចក្តីណែនាំ ស្តីពីការចេញលិខិតរដ្ឋបាល និង លិខិតអត្រានុកូលដ្ឋានឲ្យសហព័ទ្ធជាខ្មែរ កូន និង ជនបរទេសអន្តោប្រវេសន្ត ប្រកាសស្តីពីការឈប់ទទួលពាក្យសុំសម្រាប់ជនអន្តោប្រវេសន៍បរទេស និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ច្បាប់សញ្ជាតិ ដែលបានធ្វើវិសោធនកម្ម ឆ្នាំ ២០១៨ និងអនុក្រឹត្យលេខ ១២៩ )ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើមោឃភាព (និងការដកហូតឯកសាររដ្ឋបាលមិនទៀងទាត់របស់កម្ពុជា បច្ចុប្បន្នត្រូវបានកាន់កាប់ និងប្រើប្រាស់ដោយជនអន្តោប្រវេសន៍បរទេស។

[25] សូមមើលគេហទំព័រ www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=24579&LangID=E

[26] ការិយាល័យគាំទ្រទីប្រឹក្សាពិសេសរបស់អគ្គលេខាធិការស្តីពីការបង្ការអំពើប្រល័យពូជសាសន៍ និងទីប្រឹក្សាពិសេសរបស់អគ្គលេខាធិការស្តីពីទំនួលខុសត្រូវក្នុងការការពារ។

[27] "សភា បានរកឃើញថា ជំនុំជម្រះ]នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការប្រល័យពូជសាសន៍ជនជាតិភាគតិចវៀតណាម ក្រុមជាតិ និងពូជសាសន៍។ សភាជំនុំជម្រះក៏បានកាត់ទោសបន្ថែមទៀត លើ នួន ជា ពីបទប្រល័យពូជសាសន៍ក្រុមសាសនា និងជាតិពន្ធុចាម ក្រោមលទ្ធិស្តីពីការទទួលខុសត្រូវរបស់ថៅហ្វាយនាយ។ សូមមើលគេហទំព័រ www.eccc.gov.kh/en/case/topic/ 1298

[28] "ជំងឺកូវីដនិងសិទ្ធិមនុស្ស៖ យើងទាំងអស់គ្នា ១៩-នៅក្នុងស្ថានភាពនៃជំងឺកូវីដ-១៩ រួមគ្នា "(ខែមេសា ឆ្នាំ២០២០ (មាននៅលើគេហទំព័រ www.un.org/sites/un2.un.org/files/un_policy_brief_on_human_rights_and_covid_23_april_2020.pdf

ចងក្រងជាឯកសារប្រឆាំងនឹងជនជាតិចាម (ដែលភាគច្រើនជាជនជាតិភាគតិចមូស្លីម) បន្ទាប់ពីមានការឆ្លងរាលដាលនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងព្រឹត្តិការណ៍សាសនាមួយដែលមានការចូលរួមពីជនជាតិចាមមួយចំនួននៅប្រទេសម៉ាឡេស៊ី។ រដ្ឋាភិបាលបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការផ្តល់សេវាសុខភាពសាធារណៈក្នុងលក្ខណៈរាប់បញ្ចូល និងស្មើភាពគ្នា។ ប្រការនេះធ្វើឲ្យស្ថានភាពកាន់តែលំបាក ដោយសារមិនមានច្បាប់ជាក់លាក់ដោះស្រាយពាក្យសម្តីស្អប់ខ្ពើម និងបទល្មើសពីពាក្យសម្តីស្អប់ខ្ពើម និងមិនមានច្បាប់ប្រឆាំងនឹងការរើសអើង។ ការិយាល័យOHCHR បានចេញផ្សាយតាមបណ្តាញសង្គមនូវអត្ថបទមួយចំនួនដែលដោះស្រាយការរើសអើង ការស្អប់ខ្ពើមជនបរទេស និងការមាក់ងាយនៅក្នុងបរិបទនៃជំងឺកូវីដ-១៩។

## ឃ. សិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច ក្នុងបរិបទជំងឺកូវីដ-១៩

៥៧. រដ្ឋាភិបាលបានចាត់វិធានការវិជ្ជមានមួយចំនួន ដើម្បីដោះស្រាយជំងឺរាតត្បាតកូវីដ-១៩។ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិស្តីពីជំងឺកូវីដ-១៩ និងគណៈកម្មាធិការអន្តរក្រសួងដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ- ១៩ ហើយបានដាក់ចេញនូវផែនការមេថ្នាក់ជាតិសម្រាប់ជំងឺកូវីដ-១៩ នេះ។ រដ្ឋាភិបាលបានអនុម័តវិធានការជំរុញសេដ្ឋកិច្ច រួមមាន កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់អ្នកក្រីក្រ ធ្វើយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងដល់សហគមន៍ ចេញសេចក្តីប្រកាសព័ត៌មានប្រចាំថ្ងៃ និងធ្វើសន្និសីទកាសែតប្រចាំសប្តាហ៍ ហើយក្រសួងសុខាភិបាលបានបង្កើតបណ្តាញទូរស័ព្ទបន្ទាន់សម្រាប់ឆ្លើយតបនឹងជំងឺកូវីដ-១៩។ រដ្ឋាភិបាលបានលុបចោលថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំខ្មែរ (១៣ ដល់ ១៥ មេសា ២០២០) ហើយបានដាក់ការហាមប្រាមលើការធ្វើដំណើរពីខេត្តមួយទៅខេត្តមួយ ពីថ្ងៃទី៩ ដល់ ថ្ងៃ១៦ ខែមេសា ឆ្នាំ ២០២០។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសថាមានកម្មកររោងចក្រប្រមាណ ៣ ម៉ឺន នាក់ ដែលបានធ្វើដំណើរពីខេត្តមួយទៅខេត្តមួយទោះបីជាមានការហាមឃាត់ ដោយត្រូវដាក់នៅដាច់ដោយឡែករយៈពេល ១៤ ថ្ងៃ ក៏ដោយ។ កន្លែងដាក់ឱ្យនៅដាច់ដោយឡែកចំនួន ១០ ត្រូវបានបង្កើតឡើងនៅតាមសាលារាជធានីភ្នំពេញ ដើម្បីទទួលយកកម្មករដែលមានរោគសញ្ញាជំងឺកូវីដ-១៩ ឬមិនអាចដាក់ខ្លួនឲ្យនៅដាច់ដោយឡែកដោយខ្លួនឯងបាន។

៥៨. ទោះបីជាមានការទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងទាំងនេះក៏ដោយ ក៏ការិយាល័យOHCHR កត់សម្គាល់ឃើញនូវកង្វះព័ត៌មានដែលអាចរកបានលើទិដ្ឋភាពសំខាន់ៗនៃការត្រៀមបង្ការ និងឆ្លើយតបផ្នែកសុខភាពលើជំងឺកូវីដ-១៩ របស់រដ្ឋាភិបាលដែរ រួមមាន ទីតាំងវេជ្ជសាស្ត្រសម្រាប់តែជំងឺកូវីដ-១៩ ពិធីសារដាក់ឲ្យដាច់ដោយឡែក បុគ្គលិកវេជ្ជសាស្ត្រជំនាញ និងលទ្ធភាពរកបាននូវឧបករណ៍ចាំបាច់។ ការធ្វើតេស្តជំងឺកូវីដ-១៩ ក៏មានកំណត់ផងដែរ និងមានការរឹតត្បិតយ៉ាងតឹងរឹង ហើយមានភាពមិនទាន់ច្បាស់ក្នុងការទទួលបានសេវាពីសហគមន៍តាមជនបទងាយរងគ្រោះ និងបាត់បង់ឱកាស។

៥៩. ការិយាល័យOHCHR បានផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាលក្នុងគោលបំណងធានាថាការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ស្របនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន ដើម្បីចាត់វិធានការ